គ្រួមជំនុំជម្រះក្តីបន្ទាន់
COMMISSION DES MINEURS & COUTUMES

តាន្តជសុទ្ធិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី២៨ លេខ ៧ ខែកក្កដា ព.ស.២៤៩៩ គ.ស.១៩៥៦

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ភ្នំពេញសន្ទនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	ឧបាសក	ទំព័រ
— វិចារណកថា (សន្តិភាពតាមគតិពុទ្ធសាសនា)	ព្រះភិក្ខុ ខៀវ-ដុំ	៦០៣
— អត្ថុទ្ធារកថា	ព្រះឧបាលិវង្សសុវ-ហាយ	៦១០
— ប្រជុំជាតិឧបាសក (តទៅ)	ព្រះទេពសង្គា កឹម-ឆ្លូវ	៦២៧
— សីលធម៌និងសិល្បសាស្ត្រ	ឃុនបណ្ណាគុរ័ក្ស ប៊ូ-ប៊ី	៦៣៦
— ជាតកថារឿងពុទ្ធរូបបុរាណ (ត-ចប់)	ឃុនអត្ថកោវិទ ជា-យ៉ូរ ប្រែ	៦៣៩
ផ្នែកអក្សរសាស្ត្រ		
— វិធីអប់រំជនជាតិខ្មែរ	លោក ភ័យ-ប៊ុក	៦៥១
— ឧភាទមាគា	ព្រះមហា ខៀក-អម៉ា	៦៥៦
— ពេទ្យព្រះរាជា (តទៅ)	លោក ស៊ិន-ហ៊ាន ប្រែ	៦៦១
— រឿងសាមកុក (តទៅ)	ឧកញ៉ា ឆ្ង-ពន	៦៦៨
— រឿងបល្ល័ង្កទិព្យ (តទៅ)	លោក ភ័យ-ប៊ុក	៦៧៦
— រឿងសៅរ៍សោយ (តទៅ)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៊ម ប្រែ	៦៨៤
កំណត់ទីតិប្រវត្តិការណ៍		
— មន្ត្រីរាជការព្រះសង្ឃ នៅខែត្រតាកែវ	ពុទ្ធសាសនបណ្ឌិត្យ	៦៩៦

មួយឆ្នាំមាន ១២ លេខ — ដំឡៃជាវ ៤៣០រ, ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE: *Page*

- Editorial (la paix dans le Bouddhisme) . . . . . *par Vénérable KHIEU-CHUM* 603
- Atthadvarakatha . . . . . *par Vénérable SO-HAY* . . 610
- Recueils des disciplines Bouddhique des fidèles (suite) . . *par Vénérable KEM-TO* . . 627
- Siladharma et Silpasastra . . *par M. BOU-PO* 636
- Les statues Bouddhiques primitives (suite et fin) . . . *Traduit par M. CHEA-YOU* 639

PARTIE LITTÉRAIRE:

- Conseils aux Cambodgiens . . *par M. RAY-BUC* 651
- Les Conseils d'une mère. . . *par Vénérable DŒURK-AM* 656
- Conte « Le Diamant du Raja » (suite) . . . . . *Traduit par M. SIN-HEAN* 661
- Histoire du Samkok (suite.) . . *par Lokha NOU KAN* . . 668
- Les trente-deux récits du Trône (suite) . . . . . *Traduit par M. RAY-BUC* 676
- Le «Sau-Soy» ou l'influence saturnienne (suite) . . . . . *par Vénérable PEUNG-PAM* 684

NOTES ET CHRONIQUES:

- L'hôpital des Bonzes dans la Province de Takeo . . . . . *par l'Institut Bouddhique* . . . 692

Prix d'abonnement annuel (comprenant 12 numéros) 230$00

វិចារណកថា

សន្តិភាពតាមគតិពុទ្ធសាសនា

ព្រះភិក្ខុ ខៀវ-ជុំ រៀបរៀង

—■—

សន្តិភាពគឺអ្វី? តាមគោលព្រះពុទ្ធសាសនា "សន្តិភាព" ដោយសេចក្តីមេត្រីភាប់រកគ្នា លះបង់ទ្វេ គតិសង្គ្រាម កាន់យកទ្វេ គតិធម៌ របស់ប្រជាពលលោក ដោយការសាងទាន-សីល-ភាវនា តាមផ្លូវសាកលនិយម ។

ទាន, សីល, ភាវនា, តាមផ្លូវសាកលនិយមនោះគឺអ្វី? គឺទាន-សីល ភាវនា ដែលចេញផុតអំពីអគតិជម្មិ ៤ (ឆន្ទាគតិ ទោសាគតិ ភយាគតិ មោហាគតិ) នៃអ្នកខ្លាំងដែលបានធ្វើដល់អ្នកខ្សោយដោយសម្លឹងបើញ ខ្លួនឯតុមប្រយោជន៍ ដែលត្រូវយកមកប្រើរួមគ្នាកុងដីភាពបច្ចុប្បន្ននៃ ប្រជាពលលោក ហើយដំកល់ខ្លួនទៅកុងគតិសាកលកុងសកម្មភាព គ្រប់យ៉ាង ។

ព្រះពុទ្ធបរមគ្រូទ្រង់បង្ហាញខ្លួសេចក្តីឃើញរបស់ព្រះអង្គថា "ប្រជាពលលោកទាំងអស់ ត្រូវការដើរភាព សីលភាព ធម៌មនុស្សភាព" ។ អាស្រ័យហេតុនេះ ទើបព្រះអង្គទ្រង់ស្រាយបញ្ជាដើរភាពដោយការឲ្យទាន, ទ្រង់ស្រាយបញ្ជាសីលភាពដោយការរក្សាសីល, ទ្រង់ស្រាយ

បញ្ហាមនុស្សភាពដោយការរក្សាមនុស្សធម៌, ដោយទ្រង់ណែនាំជាមនុស្ស
ពាំងអស់ត្រូវការរស់ ត្រូវការមិនឲ្យគេជិះជាន់នូវសេចក្តីរស់របស់ខ្លួន ត្រូវ
ការរស់នៅជាមួយគ្នាយ៉ាងជិតស្និទ្ធ ។ សេចក្តីត្រូវការនេះកើតមកជាមួយ
នឹងធម្មជាតិ មិនមានអ្នកណាអាចរំលាយចោលបានឡើយ ។ កាលណា
មនុស្សមិនបានជួបនឹងសេចក្តីត្រូវការនេះទេ សង្គមមនុស្សក៏ប្រែប្រួល
ចង្អូរការមិនសុខ ស្ងប់ ប្រធាំងនឹងធម្មជាតិ ដែលជាទំនាស់នឹងសេចក្តី
ត្រូវការរបស់ខ្លួនភ្លាម ។ ដើម្បីសេចក្តីរស់នៅរបស់មនុស្ស ព្រះពុទ្ធ
សាសនាបានដឹកនាំឲ្យមនុស្សតាំងខ្លួនទៅក្នុងសម្បទាបច្ចុប្បន្ន ៤ ប្រការ:

១_ ឧដ្ឋានសម្បទា ត្រៀកឡើងធ្វើការ ដើម្បីសេដ្ឋកិច្ច ...;

២_ អារក្ខសម្បទា រក្សាការពារនូវកិច្ចការដើម្បីសេដ្ឋកិច្ច ...;

៣_ កល្យាណមិត្តតា រាប់រកគ្នាដោយផ្លូវល្អ;

៤_ សមជីវិតា រស់នៅស្មើៗ មិនចំរើតណ្ហារបស់ខ្លួន ។

ដោយសកម្មភាពប៉ុណ្ណេះនៅមិនទាន់លុបត្រប់គ្រាន់ឲ្យមនុស្សរស់
នៅសុខស្រួលជាមួយគ្នាបាន, ព្រោះមនុស្សខ្លះខ្ជាំងដោយធម្មជាតិ ខ្លះ
ខ្ជាំងដោយការអប់រំ, មនុស្សខ្លះខ្សោយដោយធម្មជាតិ ខ្លះខ្សោយដោយ
ការអប់រំ ។ ព្រះពុទ្ធសាសនាក៏បានប្រដៅមនុស្សត្រប់ជាតិ ឲ្យរៀន
រស់នៅជាមួយគ្នាដោយការធ្វើទាន តឹឲ្យអ្នកមានចែវ្យសម្បត្តិជួយអ្នក
ខ្វះក្រ ដោយមិនលើកយកជាតិ, គោត្ត, សៃ, ត្រកូល ។ល។ មកធ្វើ
ជាគ្រឿងចែកគន់ ។ ក្នុងពេលណាដែលមនុស្សបានជួយគ្នាដោយទាន

ជាសាកលហើយ ក្នុងគ្រានោះ មនុស្សក៏មានជីវភាពស្រេចស្រៀងៗគ្នា ។ ប៉ុន្តែជីវភាពនេះនឹងត្រូវជួបប្រទះនូវសេចក្តីជិះជាន់ដោយប្រការដទៃទៀត, ព្រះពុទ្ធសាសនាទើបប្រដៅឲ្យមនុស្សធ្វើសីលគ្រប់គ្នាដើម្បីឲ្យឃើញថា:

-សព្វសត្វទាំងអស់ត្រូវការសេចក្តីសុខសប្បាយ, ត្រូវការសេរីភាព, សិទ្ធិភាព, អាជីវតេយ្យ, ត្រូវការរស់នៅយ៉ាងយូរ, ត្រូវការរស់នៅជួបជុំប្រពន្ធកូនស្វាមី, មិនត្រូវការសេចក្តីស្លាប់ ។ ល ។ ដូច្នេះមនុស្សដែលមានសេចក្តីត្រូវការដូចគ្នា មិនត្រូវបៀតបៀនគ្នាទីងគ្នាឡើយ ។

- សព្វសត្វទាំងអស់ ត្រូវការទ្រព្យសម្បត្តិ ស្រឡាញ់ទ្រព្យសម្បត្តិ មិនមានទីបំផុតក្នុងការចង់មានចង់បាន, ដើម្បីយុត្តិធម៌ក្នុងទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់គេ ដែលគេហួងហែងរក្សាទុកនោះ អ្នកមានសេចក្តីត្រូវការដូចគ្នាមិនត្រូវលួចទ្រព្យសម្បត្តិរបស់គេឡើយ ។

- សព្វសត្វទាំងអស់ មានសញ្ជាតវេគក្នុងការបណ្តុះកម្មពន្ធ (ពូជមនុស្ស) តាមប្រពៃណី បរិភោគកាមរវាងបុរសស្ត្រី ដោយសេចក្តីស្នេហាដែលកើតមកអំពីធម្មជាតិ, ជនអ្នកមានស្នេហាដូចគ្នា មិនត្រូវល្មើសសិទ្ធិស្នេហាក្នុងគូគ្រងរបស់អ្នកដទៃឡើយ ។

- សព្វសត្វទាំងអស់ តែមានសញ្ញាតញ្ញាណ ក្នុងការរួមពួក, រួមសង្គម ដើម្បីរួមកម្លាំងគ្នាតស៊ូនឹងភ័យ ដែលកើតអំពីធម្មជាតិ ហើយត្រូវការសេចក្តីខ្ចីខ្ចុកចិត្តរវាងគ្នាទីងគ្នា, ជនអ្នកមានចំណងត្រូវគ្នាមិនគួរពោលពាក្យកុហកឡើយ ។

- សព្វសត្វទាំងអស់ ត្រូវការស្មារតីល្អអំពីជនដទៃ ដើម្បី

ប្រសើយ ពាក់ខន្ធគ្នាឲ្យបានស្រួល, មិនត្រូវការឲ្យសង្គមមានសេចក្តីរង្គៀសសង្សីយ, បើស្មារតីរបស់ខ្លួនប្រែប្រួលហើយ ក៏មិនអាចនឹងយុំគ្រងខ្លួរសេចក្តីល្អរបស់ខ្លួនឲ្យសង្គមពុកចិត្តបានឡើយ, អ្នកត្រូវការសេចក្តីល្អថ្លៃថ្លូរ ត្រូវតែរៀរចាកសេពសុភ ។

- សេរីភាពរបស់មនុស្ស រមែងកើតឡើងដោយសីលសាកល តែបើមនុស្សគ្រប់គ្នានៅតែឃើញមនុស្សដោយជាតិ, ដោយគោត្ត ដោយសែ ដោយត្រកូល ដោយវណ្ណៈ ដោយទំាយ ។ល។ ការរស់នៅរបស់មនុស្ស ក៏មិនបានដិតស្និទ្ធជាមួយគ្នាឡើយ ។ ព្រះពុទ្ធសាសនាទើបប្រដៅមនុស្សឲ្យចំរើនចិត្តជាសាកល (ភាវនាសាកល) គឺពាល់តែវេលាដែលគិតទឹកដល់មនុស្សនោះ ត្រូវគិតតែគឺមមនុស្ស។សត្វ។ កុំគប្បីទឹកដល់ជាតិ, គោត្ត, សែ, ត្រកូល, វណ្ណៈ, ហានៈ, លទ្ធិ, ទំាយ, សាសនា ។ល។ អ្វីៗឡើយ ត្រូវទឹកថា " សូមឲ្យសត្វមនុស្សទាំងឡាយ ចូរកុំមានពៀរទន្ទឹងគ្នា ចូរមានតែសេចក្តីសុខ ចូរកុំឲ្យមានសេចក្តីទុក្ខ ចូរកុំបៀតបៀនគ្នា ចូររចេរក្សាខ្លួនឲ្យបានសុខ, ដែលមានទុក្ខសូមឲ្យអស់ទុក្ខទៅ, ដែលមានភ័យសូមឲ្យអស់ភ័យទៅ, ដែលមានជម្ងឺសូមឲ្យអស់ជម្ងឺទៅ, ដែលមានសោកសូមឲ្យអស់សោកទៅ " ភាលណាចិត្តសាកលនេះកើតឡើងហើយ មនុស្សយើងនឹងរស់នៅជាមួយគ្នាយ៉ាងដិតស្និទ្ធ នឹងមិនមានសេចក្តីរើងរួសដោយឥត្យសម្បត្តិ, ជាតិ, គោត្ត, សែ តឹងលះបង់ខ្លួរភាវសង្កត់សង្កិនជិះជាន់ជាតិឯទៀត ជនឯទៀតដោយជាតិ, ដោយគោត្ត, ដោយឥត្យសម្បត្តិ, យូរៗទៅនឹងអាចយកជាតិ, គោត្ត,

ទ្រព្យសម្បត្តិ, យសសក្តិ (ល) មកបំរើសង្គមមនុស្សបាន ។ អនាគត, លោកគំនិរលាយជាតិ, គោត្ត, សែ, ត្រកូល, លទ្ធិ, សាសនា, និកាយ ចូលគ្នាបានដោយងាយ ។ លទ្ធផលខាងចុងបំផុតគឺសន្តិភាពមិនមានសង្គ្រាមក្នុងពិភពនៃមនុស្សទុំនងផង ។

ក្នុងបច្ចុប្បន្ននេះ, លោកបានអនុវត្តលក្ខន្តិកសន្តិភាពស្របមកនឹងលក្ខន្តិកសាសនាដោយច្រើន ។ ក្នុងសហប្រជាជាតិ មានការប្តូរបទ, កតិកា, ធម្មនុញ្ញលោកនឹងសិទ្ធិមនុស្ស ដែលអង្គការនេះបានរៀបចំឡើងដោយសន្ទិសិទដោយសមាជ នឹងដោយប្រជាមតិស្របជាមួយនឹងមតិសាសនាជាច្រើនអន្ទើ ។ ចំពោះរឿងនេះ, តាំងពីកាលណាមក គេមិនសូវបានជួបប្រទះនឹងមតិស្របគ្នារវាងលោកនឹងសាសនាសោះឡើយ ។ អស់រយៈកាលយូរយារណាស់ហើយ ដែលលោកស្វែងរកសន្តិភាពដោយការពុះខ្លះ ដោយកម្ចាំងបាយខ្លះ ដោយវត្ថុនិយមខ្លះ ដូចមានការសិតអ្នកអ៊ីរ៉ុបមួយបានដាស់តឿនប្រជាជនថា "ចើអ្នកត្រូវការសន្តិភាពត្រូវរៀបចំសង្គ្រាម" ។ ដែលសាសនាស្វែងរកសន្តិភាពដោយបន់ស្រន់បួងសួងចំពោះព្រះជាម្ចាស់វាល់ ។ ព្រះអង្គខ្លះ, ដោយនាមនិយមខ្លះ ដូចមានពាក្យអំពាវនាវក្នុងពេលសង្គ្រាមថា « ! ព្រះម្ចាស់ខ្ញុំអើយ ! » ។

របៀបដោះស្រាយនេះ លទ្ធផលមិនត្រឹមតែនាំឲ្យបែកបាក់ប្រជាជនឯណាតែប៉ុណ្ណោះទេ ថែមទាំងមានគ្រោះថ្នាក់ដោយសង្គ្រាមជាញឹកញាប់ទៀតផង ។

ក្នុងវេលានេះ, លោកបានរកសន្តិភាពដោយផ្លូវចិត្តផង ដោយផ្លូវវត្ថុ

ផង ។ ខាងផ្លូវវត្ថុគេពន្យឹកដំរីកាពប្រជាជនដោយសេដ្ឋកិច្ច, ខាងផ្លូវចិត្ត
គេសូប្រជាជនដោយសីលធម៌ មនុស្សធម៌និងអាវុធម៌ ។ ការដោះ
ស្រាយបញ្ហាលោកតាមរបៀបថ្មីនេះ ជាការមួយនាំឲ្យប្រជាជនមាន
សង្ឃឹមសន្តិភាពច្រើន ហើយជាការស្របជាមួយនឹងរបៀបដោះស្រាយ
បញ្ហាសន្តិភាពលោករបស់ព្រះពុទ្ធសាសនា ។ ព្រះពុទ្ធសាសនា, ជា
សាសនាដោះស្រាយបញ្ហាលោកដោយត្រង់ ព្រោះព្រះពុទ្ធសាសនា
បានរៀបចំលក្ខន្តិកធម៌ សម្រាប់អនុវត្តន៍ច្រើកក្នុងដំរីកាពមនុស្សបច្ចុប្បន្ន
ដោយសម្បទាច្រយោជន៍ ៤ យ៉ាង ដូចបានពោលមកហើយ ;

ក្នុងដំរីកាពអនាគត ដោយសម្បទាច្រយោជន៍របស់លោក ៤ យ៉ាងគឺ

๑– សទ្ធាសម្បទា (សទ្ធាសម្បទ)

๒– សីលសម្បទា (សីលសម្បទ)

๓– ចាគសម្បទា (ចាគសម្បទ)

๔– បញ្ញាសម្បទា (បញ្ញាសម្បទ)

ក្នុងចំណុតនៃដំរីកាព (បណ្តុលដំរីកាព) ដោយបរមត្ថច្រយោជន៍
៤ យ៉ាងគឺ

๑– ទុក្ខសច្ច (សេចក្តីពិតនៃទុក្ខ);

๒– ទុក្ខសមុទយសច្ច (សេចក្តីពិតនៃហេតុរបស់ទុក្ខ);

๓– ទុក្ខនិរោធសច្ច (សេចក្តីពិតនៃទីរំលត់ទុក្ខ);

๔– មគ្គសច្ច (សេចក្តីពិតនៃឧបាយសម្រាប់រំលត់ទុក្ខ);

មានតែព្រះពុទ្ធសាសនាមួយប៉ុណ្ណោះទេ ដែលស្រាយបញ្ហាលោកដោយផ្លូវវត្ថុផង ដោយផ្លូវចិត្តផង ឬនឹងថាស្វែងរកសន្តិភាពដោយសន្តិភាពបាន ។ ដូច្នេះ បើលោកសម័យនេះចង់បានសន្តិភាពលោក ចាំផ្លូវវត្ថុចាំផ្លូវចិត្ត ហើយអនុវត្តន៍ប្រែអង្គការនេះពេញលក្ខណៈ, សន្តិភាពលោកក៏អាចនឹងកើតមានទៀងតុំខាន ។

* * *

ឯកម្មវាចនៈ

សន្តិភាពតាមមតិពុទ្ធសាសនា ប្រកាសថាលះចម្បាំងរាំងដល់ចេញ
កាន់យកធម៌គឺទានសីលភាវនាវិញ ហើយបំពេញព្រហ្មវិហារដល់សព្វសត្វ ។
ព្រោះចម្បាំងនាំឲ្យចិត្តក្តួចចងពៀរ ជាប់ពំនៀរជាអង្វែងរួរលង់ខ្ពាត់
នាំឲ្យគ្មានសន្តិភាពនៅក្នុងរដ្ឋ ជាទុក្ខក្តាត់រកក្តីសុខគ្មានតែម្តង ។
បំណែកធម៌គឺទានសីលភាវនា ព្រហ្មវិហារបើពលរដ្ឋកាន់ម៉ឺងម៉ឺង
អាចឲ្យមានសន្តិភាពពេកក្រុង អស់មនុស្សជុងក្នុងប្រទេសលែងទាស់គ្នា ។
ដោះយើងខ្មែរគួរតែប្រឹងបណ្តុះចិត្ត ឲ្យផ្តេកផ្តិតក្នុងទានសីលភាវនា
ដែលជាធម៌អព្យាក្រឹតជាតវោ ត្រង់ ៗ គ្នាកុំបីធ្វេសប្រហែសអីយ !

យូរ - អ៊ុន

ព្រះឧបាលិវង្ស សូរ-ហាយ

ក្រុមដំនុំព្រះត្រៃបិដក រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
អាពោគ្យមិច្ចេ បរមញ្ច លាភំ
សីលញ្ច ពុទ្ធានុមតំ សុគញ្ច
ធម្មានុរុទ្ធី ច អលីនតា ច
អត្ថស្ស ទ្វារា បមុខា ឆឡេតេ ។

វេលានេះ ជាថ្ងៃទ្រោសថ គាត្មាភាពបានទទួលនិមន្តមកទេសនាតាមវិត្តុទ្ទេសនស័ព្ទកម្ពុជា ប្រចាំថ្ងៃទ្រោសថ ដើម្បីជាសណ្តាប់នៃពុទ្ធបរិស័ទចាំធ្លាយ ដូចធម្មកថាដែលត្រូវសំដែងតទៅនេះ ៖

ពុទ្ធភាសិតដែលតាំងទុកខាងលើនេះ មានឈ្មោះថាអត្ថទ្វារៈ មានមាតិកាធម៌ ៦ យ៉ាង ដែលសំដែងអំពីទ្វារនៃប្រយោជន៍របស់មនុស្ស ។

ពាក្យថា "ប្រយោជន៍" នេះ ជាពាក្យដែលយើងធ្លាប់និយាយសិប់សាំមកណាស់ហើយ ព្រមទាំងបានយល់សេចក្តីជាក់លាក់ហើយដែរ ប៉ុន្តែក្នុងទីនេះ សូមអធិប្បាយបញ្ជាក់ថែមទៀត ដូចសេចក្តីតទៅ :

ប្រយោជន៍ ប្រែថា "ការប្រកប, វត្ថុជាទីលែលក, វត្ថុសម្រាប់ប្រើប្រាស់, ផលដែលសម្រេចដូចបំណង សេចក្តីត្រូវការ, អត្ថន័យ" ។ មួយទៀត ដែលហៅថា "ប្រយោជន៍" នោះ បានដល់ឥដ្ឋារម្មណ៍ គឺ

អាម្នាក់ជាទីគ្រាថ្នាជាទីចង់បានរបស់មនុស្សពាំងអស់ ដែលឥតមាន
នរណាម្នាក់បដិសេធចោលឡើយ សុទ្ធតែគេត្រូវការចង់បានគ្រប់ៗគ្នា ។
ប្រជាជនគ្រប់ជាតិក្នុងលោកនេះ ដែលមានជីវិតកាន់កាយជាទី
ស្រឡាញ់ តែងចែរមុខឈមទៅរកប្រយោជន៍ ទំរឹងប្រែងស្វែងរក
ប្រយោជន៍ក្នុងជាតិនេះ ដើម្បីយកមកចំនុកបំរុងជីវិតកាន់កាយរបស់ខ្លួន
ឲ្យរស់នៅដោយសុខស្រួល ។ ពិតណាស់ ការសិក្សារៀនសូត្រ ក្នុង
ផ្លូវវិទ្យាសិល្បៈណាមួយក្តី ក្នុងផ្លូវកសិកម្មពាណិជ្ជកម្មក្តី របស់មនុស្ស
ក្នុងសម័យអតីត ឬសម័យបច្ចុប្បន្ននេះ សុទ្ធតែជាមធ្យោបាយ សម្រាប់
ដេញស្វាត់រកចាប់យកប្រយោជន៍ មកឧបត្ថម្ភជីវិតកាន់កាយពាំងអស់
ប៉ុន្តែការស្វះស្វែងរកប្រយោជន៍របស់ប្រជាជននោះ ជួនកាលក៏កាត់
កប ជួនកាលក៏ចេះតែហ្មាងចេះតែឆ្អែន គឺថាអ្នកស្វែងខ្វះចេះតែមានលាភ
មានចំណេញ អ្នកខ្វះក៏ចេះតែឃ្លាង ចេះតែខាត មិនបានឡើងហាន:
ទៅជាអ្នកមានទ្រព្យនឹងគេសោះ នៅតែក្រីក្រជុនជាប ខាបថាកអស់
មួយជីវិតក៏មាន ចាន់ឡើងដល់ថ្នាក់ខ្ពង់ខ្ពស់ក៏មាន ។ ធម៌ ៦ យ៉ាង
ដែលបានអាងដំកល់ខុកខាងលើ ជាសុភាសិតគាថានេះ ជាធម៌នាំផ្លូវ
ប្រជាជនទៅរកប្រយោជន៍ ដែលបណ្ឌិតអ្នកប្រាជ្ញសំដែងខុកមកមានក្នុង
គម្ពីរអដ្ឋកថាជាតក ឯកនិបាត ឈ្មោះថា អត្ថទ្វារជាតក ។

សេចក្តីប្រែស្រាយក្នុងសុភាសិតគាថានោះបាន:

"ធម៌ ៦ យ៉ាងនេះ ជាទ្វារដ៏ប្រធានៃប្រយោជន៍ គឺអ្នកប្រាជ្ញលោក
ជាំក្រៃលែង អាស្រ័យអាកេតុ: គឺការមិនមានកេត ១ សីល ១ ពុទ្ធ-

ធម្មតា ១ សុតៈ ១ ធម្មានុវត្តិ គឺការប្រព្រឹត្តតាមធម៌ ១ អលិនតា គឺការមិនជំអក់ ១" ។

ក្នុងផ្នែកសុភាសិតគាថានេះមានធម៌ ៦ យ៉ាង ដូចសេចក្តីអធិប្បាយចំពោះអត្ថបទនៃធម៌មួយៗ តទៅនេះ ៖

១- អាពោគ្យៈ = ការមិនមានរោគ ;

២- សីលៈ = ការប្រព្រឹត្តរៀបរយល្អ ;

៣- ពុទ្ធានុម័ត = ការយល់តាមធម៌នៃព្រះពុទ្ធ ;

៤- សុតៈ = ការស្តាប់, ការរៀនសូត្រ ;

៥- ធម្មានុវត្តិ = ការប្រព្រឹត្តតាមធម៌ ;

៦- អលិនតា = ភាពនៃការមិនជំអក់ ។

១- អាពោគ្យៈ = ការមិនមានរោគ

រោគគាថាផ្សេងៗ ដែលកើតមានឡើង សុទ្ធតែកើតអំពីសរីរកាយរបស់មនុស្សសត្វ គឺថាជម្ងឺដម្កាត់ចាំងអស់ មានសរីរកាយជាសមុដ្ឋាន ឬជាប្រភព (ជាដែនកើត) នៃរោគ ដោយហេតុថា រាងកាយរបស់មនុស្សសត្វ សុទ្ធសឹងប្រឡាក់ដោយសាច់ឈាម ព័ទ្ធព័ទ្ធដោយស្បែកខាក់ខេះដោយសរសៃ បញ្ចុះជ្រាំដោយក្រពះទងំរោះរៀនធំតូច សួតថ្លើម មានឆ្អឹងជាសសរនឹងជាចន្លុះ របស់ចាំងនេះទុកជាសំបុកនៃរោគ ។ រួបរួមប្រជាប់គ្រោងកាយនេះ មានចិត្តចេតសិកជាម្ចាស់ អាចជ្រកអាស្រ័យនៅខាងក្នុង ដែលនាំយើងឲ្យចង្អុលដឹងសុខ ទុក្ខ ក្តៅ ត្រជាក់

ស្រែក ឃ្វានជាដើម ។ កាយរបស់យើង ដែលត្រូវគ្រោះថ្នាក់ដោយកេតាពាធ មានការឈឺចាប់ចុកសៀត រួយស្រពន់ជាដើម ពុំមែនមានកំហុសអំពីអ្នកណាមួយ ចែកមកឲ្យយើងទេ គឺកេតកើតមកតែអំពីយើងមានរូបកាយ គឺទាស់មកអំពីយើងចង់កើត ប៉ុន្តែយើងមិនបានគិតពីហេតុនៃការកើតនោះថា តើការកើតជ្រាកជាទៃខន្ធ ៥ ជាហេតុយ៉ាងណាខ្លះ? ព្រោះតែយើងកើត ឬជាយើងត្រូវទទួលលទ្ធផលគឺចាស់ឈឺស្លាប់ ឬថាព្រោះតែយើងមានសរីរកាយ ឬជាយើងត្រូវទទួលផលនៃសរីរកាយវិញ គឺកេតាពាធនេះឯង ។ ដំណើរនេះ ថើតាមបាលីពុទ្ធសាសនាថា រូបកាយតែងទទួលទុក្ខវេទនា ដោយកេតាពាធណាមួយ ព្រោះហេតុតែកំហុសរបស់មនុស្សសត្វ ដែលដើមជំបូងឡើយ នាំគ្នាច្រឹងច្រានរលេញចង់កើត ប៉ុន្តែឥតគិតអំពីហេតុរបស់ការកើតសោះ លុះដល់ពេលមានកេតាពាធបៀតបៀនញាំញី ទើបក្តៅក្រហាយស្តាយគ្រោយយំយែកស្រែកថ្ងូរ ។

កេតាពាធទាំងអស់ ជាលទ្ធផលខាងអាក្រក់របស់មនុស្សសត្វដែលកើតមកអំពីបាបកម្មរបស់ខ្លួនកន្លងមុនក៏មាន កន្លងបច្ចុប្បន្នក៏មាន ។ កាយរបស់បុគ្គលដែលបានសាងបុញ្ញកម្ម ក៏ត្រូវមានលទ្ធផលល្អ នាំឲ្យមានសុខភាព សុខសប្បាយពុំសូវមានកេត ដែលនាំឲ្យឈឺចាប់ក្រៀមក្រំឡើយ ។ ភាពនៃកាយដែលគ្មានជម្ងឺដង្កាត់, មិនមានអាការក្តៅក្តៅលាល, មិនមានការឈឺចាប់ មិនមានការរួយស្រពន់ជាដើមទាំងនេះហៅថា ការមិនមានកេត ។

បុគ្គលណាមួយ បុរសឬស្ត្រីដែលមានពណ៌កាយប្រែបដោយពេគ-ពាធច្រើន មិនអាចនឹងរកប្រយោជន៍បានឡើយ ដូចយ៉ាងលាភយស ដែលត្រូវបានក៏មានបាន, កោគសម្បត្តិដែលកើតមានហើយ ក៏វិនាសខូចខាតទៅវិញ ដែលមិនទាន់កើតក៏កើតឡើងមិនបាន ។ ភាពនៃបុគ្គលមានពេគនេះ ជាទោសមួយនាំឲ្យអភ័ព្វខាតប្រយោជន៍ត្រង់យ៉ាង ទោះជាប្រយោជន៍បច្ចុប្បន្នក្តី ផ្លូវលោកក្តី ផ្លូវធម៌ក្តី ។ ហេតុនោះការដែលមិនមានពេគទើបឈ្មោះថាជាលាភដ៏ប្រសើរណាស់ ឈ្មោះថាជាទ្វារ ឬជាផ្លូវចង្អុរមកនូវប្រយោជន៍ ព្រោះថាបើពណ៌កាយមានសុខភាពល្អហើយ គេនឹងស្វែងរកអម្រែស់អម្រែណាមួយចេះតែកើតមាន ចាន់ដ៏អស់តាមសមត្ថភាពរបស់ខ្លួន សមដូចព្រះពុទ្ធភាសិតថា អារោគ្យបរមា លាភា "លាភដ៏ឯកើតមានព្រោះការមិនមានពេគជាការប្រសើរបំផុត" ។

ភាពនៃការមិនមានពេគនេះ រមែងជាទីស្រឡាញ់ ជាទីចង់បានរបស់មនុស្សត្រង់ជាតិ ឥតមាននរណាមួយចង់ឲ្យមានពេគឡើយ ព្រោះហេតុនោះបានជាអ្នកវេជ្ជសាស្ត្រ បានបង្កើតច្បាប់អនាម័យ ដើម្បីបង្រៀនដឹកនាំប្រជាជនឲ្យយល់ច្បាស់ក្នុងការរក្សាត្រង់ត្រង់ពណ៌កាយ ឲ្យមានសុខភាព មិនឲ្យមានជម្ងឺដំណាត់ ។

ការរៀបចំខ្លួនតាមវិធីអនាម័យនោះគឺ

๑) ការសំអាតកាយដោយការងូតលាងឲ្យស្អាត;

๒) ការបោកគក់សំពត់អាវឲ្យស្អាត;

๓) ការបោសប្រាកដីលំនៅឲ្យស្អាត;

๔) ការហ៊ោសត្រាសគេហដ្ឋានទាំងខាងលើខាងក្រោម;

๕) ការប្រយ័ត្នចំពោះអាហារបរិភោគ;

๖) ការសំអាតបរិវេណគេហដ្ឋានកុំឲ្យមានជ្រាំ ។

๒— សីល:= ការប្រព្រឹត្តិរៀបរយល្អ

ពាក្យថា "សីល" សំដៅយកការប្រព្រឹត្តិល្អដោយកាយវាចា ជាន ដល់ការដាក់ទុនទុកក្នុងផ្លូវដែលត្រូវ គឺមិនឲ្យកាយវាចា ប្រព្រឹត្តឈ្លោន ពាន់ពាក់ដល់ដំរែតកងកាយ ទ្រព្យសម្បត្តិ ទឹងសិទ្ធិសេរីភាពនៃអ្នក ដទៃ, ការប្រព្រឹត្តិល្អ តាមប្រពៃណីរបស់ត្រកូលដែលភ្ជាប់មានសណ្តាប់ ភ្ជាប់ល្អមកស្រាប់ ដូចយ៉ាងការមិនសម្លាប់សត្វជាដើម ឬមិនសេពសុក មិនប្រព្រឹត្តកងផ្លូវអែបាយមុខទាំង ៤ យ៉ាងណាមួយ ទាំងនេះ ហៅថា "សីល" គឺជាច្បាប់សម្រាប់កំងេសសៃរ៍ មិនឲ្យកើតឡើងបាន ។

សីលនេះ បើចាត់តាមប្រភេទបុគ្គលមាន ២ យ៉ាងគឺ គហដ្ឋសីល ជាន ដល់សីលរបស់គ្រហស្ថ មានន័ច្ចសីលជាដើម ๑, បព្វជិតសីល ជាន ដល់សីលរបស់បព្វជិត គឺកិក្ខុ - សាមណេរដែលត្រូវរក្សាត្រប់ត្រងនូវ បតុប្បាសុទ្ធិសីល ទឹងអតិរេកសីល ๑ ។ បុគ្គលជាគ្រហស្ថទឹងបព្វជិត កាលបើបានរក្សាសីលឲ្យបរិសុទ្ធតាមត្រណមនៃសិក្ខាបទ សមគួរដល់ ឋានៈនៃខ្លួនជាគ្រហស្ថ ជាបព្វជិត ទើបឈ្មោះថាជាគ្រហស្ថមានសីល ឈ្មោះថាជាបព្វជិតមានសីល ។ សីលនេះលោកចាត់ជាកុសលផ្លូវល្អខ្លួន ដែលនាំឲ្យបានសុខដល់ខ្លួនឯងផងដល់អ្នកដទៃផង ។ ម៉ើពោលដោយ

វិរតិគឺការវៀរ មាន ៣ យ៉ាងគឺ សម្បត្តវិរតិ ការវៀរចំពោះសត្វឬទ្រព្យ ដែលជួបច្រកគួរសម្ងាប់គួរលួចយក ហើយមិនសម្ងាប់មិនលួចយក ១, សមាទានវិរតិ ការវៀរចាកអំពើទុច្ចរិតទុកតាមុនដោយអំណាចសមាទាន ១, សមុច្ឆេទវិរតិ ការវៀរចាកទុច្ចរិត មានបាណាតិបាតជាដើម ដោយដាច់ស្រឡះរបស់ព្រះអរិយបុគ្គលមានសោតាបន្នជាដើម ១ ។ បុគ្គលអ្នកមានសីលបរិសុទ្ធរមែងបាននូវលាភនិងសរសើរឃើញជាក់ច្បាស់ តាំងអំពីជាតិនេះរហូតដល់បរលោក ឈ្មោះថាជាអ្នកបើកទ្វារដើម្បីរកប្រយោជន៍តាំងបច្ចុប្បន្នទល់បរលោក បានដោយប្រពៃ គ្មានសង្ស័យឡើយ ។

๓ – ពុទ្ធានុស្សតិ – ការយល់តាមធម៌នៃព្រះពុទ្ធ

ធម៌របស់ព្រះពុទ្ធ ហើយជាពុទ្ធសាសនិកក្នុងសម័យនេះបានសិក្សាចេះដឹង ក៏កាន់តែច្រើនដែរហើយ ។ ពាក្យថា "ធម៌" នេះមានន័យច្រើនយ៉ាងណាស់ មិនអាចនឹងតាប់ឲ្យអស់បានក្នុងទីនេះទេ សូមលើកយកចំពោះតែធម៌ ២ យ៉ាងត្រមាំងអធិប្បាយ ដូចតទៅនេះ ៖

๑) លោកិយធម៌ – ធម៌ជាវិស័យនៃសត្វលោក;

๒) លោកុត្តរធម៌ – ធម៌ដែលគួរនឹងផុតចាកលោក ។

ពាក្យថា "ធម៌" នេះសំដៅយកពុទ្ធវចនៈទាំងអស់ ដែលព្រះសម្ពុទ្ធសំដែងទុកដើម្បីឲ្យពុទ្ធបរិស័ទសិក្សា ឲ្យប្រតិបត្តិតាមឲ្យយកជាច្បាប់សម្រាប់ត្រង់ទុក មិនឲ្យភ្លាត់ចុះចាកហានៈខ្ពង់ខ្ពស់ បានដល់ពុទ្ធានុញ្ញាត ទីឆ ពុទ្ធប្បញ្ញត្តិ ។ ពួកកុសលធម៌គឺ អលោភៈ

ការមិនជាប់ចំពាក់ក្នុងអារម្មណ៍, អ្នកទោសៈ ការមិនប្រកួតប្តូរ មិនទទឹងចំពោះអារម្មណ៍, អ្នកមោហៈ ការមិនវង្វេង មិនភាន់ច្រឡំក្នុងអារម្មណ៍ ពាំងនេះចាត់ជាការវៃតព្វធម៌ គឺជាធម៌ត្រូវចំរើនបណ្តុះឲ្យកើតមានឡើង ។ ពួកអកុសលធម៌ គឺលោភៈ ទោសៈ មោហៈ ពាំងនេះចាត់ជាបហាតព្វធម៌ គឺជាធម៌ត្រូវលះចោល មិនត្រូវបណ្តាយឲ្យកើតមានឡើយ ។ ពួកអកុសលធម៌ណា ដែលព្រះសម្ពុទ្ធសំដែង ដើម្បីដឹកនាំឲ្យប្រព្រឹត្តប្រតិបត្តិតាម ឲ្យចំរើនរឿយៗ ពួកកុសលធម៌នោះ សង្គ្រោះបូលក្នុងព្រះពុទ្ធញ្ញាតពាំងអស់។ ពួកអកុសលធម៌ណាដែលព្រះសម្ពុទ្ធសំដែងទុកមក ដើម្បីតែគ្រាន់តែជាទិដ្ឋន្ត (សម្រាប់ចង្អុលបង្ហាញ) ថានេះជារបស់អាក្រក់ត្រូវលះចេញ ពួកអកុសលធម៌នោះ សង្គ្រោះបូលក្នុងបញ្ញត្តិ គឺការហាមឃាត់មិនឲ្យប្រព្រឹត្ត ។ ពួកធម៌ពាំងចំណែកកុសលទឹងអកុសល ដែលសត្វលោកតែងប្រតិបត្តិកាន់តាមឬអាចលះចេញបាន តាមវិស័យនៃលោក ដូច្នេះឈ្មោះថាលោកិយធម៌ ។

មួយទៀត ព្រហ្មវិហារ ๔ យ៉ាងគឺ មេត្តា សេចក្តីពាប់អានជាតស្និទ្ធចំពោះមនុស្សសត្វទូទៅ ๑, ករុណា សេចក្តីអាណិតអាសូរចំពោះមនុស្សដែលកំពុងមានទុក្ខ ๑, មុទិតា សេចក្តីត្រេកអរចំពោះមនុស្សសត្វ ដែលកំពុងមានសេចក្តីសុខចំរើន ๑, ឧបេក្ខា ការតាំងចិត្តប្រកបដោយតុល្យភាព ផ្សាយទូទៅចំពោះមនុស្សសត្វពាំងអស់ ๑ ។ ព្រហ្មវិហារធម៌នេះចាត់ជាលោកិយធម៌ គឺធម៌ដែលប្រព្រឹត្តទៅក្នុងលោក ឬធម៌ជាប់ពាក់ព័ន្ធនៅក្នុងលោក ដែលសត្វលោកគួរបណ្តុះ ឲ្យកើតឡើងក្នុងចិត្ត ដើម្បី

ឈានទៅរកលោកុត្តរធម៌ ។ ព្រហ្មវិហារធម៌នេះ ជាការវែតឰធម៌ គឺធម៌ដែលត្រូវចំរើនឲ្យកើតមានក្នុងសន្តានជារឿយ ។ ។

លោកុត្តរធម៌សំដៅយកធម៌ជាន់ខ្ពស់ ដែលអាចញុំាងសត្វឲ្យឆ្លងចាកលោកបាន ។ លោកុត្តរធម៌ មាន៩ យ៉ាងគឺ មគ្គ ៤ ផល ៤ និព្វាន ១ ។ ធម៌ទាំងនេះ ជាធម៌ប្រសើរបំផុត ជាលទ្ធផលនៃពុទ្ធសាសនិក ដែលបានប្រតិបត្តិតាមលោកិយធម៌ ។ លោកុត្តរធម៌នេះ អាចញុំាងសត្វឲ្យស្អាតចាកកិលេសទាំងពួង ឲ្យដល់នូវសមុច្ឆេទប្បហាន ជាធម៌មិនកម្រើកញាប់ញ័រក្នុងលោកទៀតឡើយ ជាធម៌ស្ងប់រម្ងាប់ចាកអារម្មណ៍ទាំងអស់ ដល់នូវព្រះនិព្វានជាឯកន្តសុខ គឺសុខខ្ពស់ឯកជាងសេចក្តីសុខក្នុងលោក ។

ព្រះអរិយៈទាំងឡាយ មានព្រះសម្ពុទ្ធជាដើម តែងសំដែងធម៌បញ្ញត្តិវិនិយ ដើម្បីស្ងប់ចាកទោសទាំងបច្ចុប្បន្នទាំងបរលោក ដើម្បីមិនឲ្យសត្វលោកមានពាំនៀវ មានការអាឃាតដល់គ្នានឹងគ្នាតទៅ ។ បុគ្គលណាមួយ ពោះគ្រហស្ថឬបព្វជិត មានចិត្តជ្រះថ្លាយល់ឃើញតាមធម៌របស់លោកអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើមដូចសំដែងមកនេះ បុគ្គលនោះឈ្មោះថា ឋានបើកទ្វារចូលទៅរកប្រយោជន៍ គឺសេចក្តីសុខចំរើនទាំងជាតិនេះទាំងជាតិមុខ ដរាបដល់ព្រះនិព្វានពុំខាន ។ ប្រជាជនក្នុងលោកគ្រប់ប្រទេស បើអាចព្រមព្រៀងគ្នាសុខចិត្តទទួលយកពុទ្ធសាសនាទៅអនុវត្តឲ្យត្រឹមត្រូវម៉ត់ចត់នោះ ប្រាកដជាទទឹងបានទទួលផលសន្តិសុខឃើញជាក់ច្បាស់តាំងអំពីជាតិនេះជាប្រាកដ ។

๔- សុតៈ = ការស្តាប់, ការរៀនសូត្រ

ការស្តាប់ឬការរៀននេះ ពុកជាការណីយកិច្ចមួយមុនដំបូងបង្អស់របស់មនុស្ស ដើម្បីលើកហានៈមនុស្សឲ្យខ្ពង់ខ្ពស់ឲ្យមានវឌ្ឍនធម៌ សីលធម៌ល្អឡើង ព្រោះថាមនុស្សពាល់អស់ដែលមានហានៈផ្សេងគ្នានោះ ដោយហេតុតែមានការសិក្សាបរិបូណ៌ ឬខ្វះខាតការសិក្សាប៉ុណ្ណោះ ។ ការស្តាប់ ការរៀននេះ មានសារប្រយោជន៍ច្រើនរកាស់ គឺជាមូលហេតុនាំឲ្យអ្នកស្តាប់ អ្នករៀនមានសមត្ថភាពមានប្រាជ្ញាស្មារតីរឹងប៉ឹងដឹងខាន់ពាលសម័យ ។ បណ្តាការណីយកិច្ចរបស់មនុស្សពាល់អស់, សុតៈ ការស្តាប់, ការរៀននេះ ពុកជាប្រធានធំជាងការណីយកិច្ចឯទៀតៗ ដូចពាលព្រះសម្មាសម្ពុទ្ធគង់ព្រះដន្ទនៅឡើយ ទ្រង់សំដែងម្តងៗ ញាំងពុទ្ធបរិស័ទ អ្នកស្តាប់ដោយគោរពឲ្យបានសម្រេចមគ្គផលជារច្រើនម៉ឺនណាស់ ។

ពាក្យថា សុតៈ ឬ សវនៈ ដែលប្តូរមកថា "ស្តាប់" ប៉ុន្តែបើតាមជម្រៅជាលីនេះ ពុំមែនតែស្តាប់ដោយត្រចៀកតែម្យ៉ាងទេ សំដៅយកការសិក្សារៀនទន្ទេញដោយមាត់ផង ការពិនិត្យមើលសៀវភៅធម៌អាថ៌ មើលហើយមើលទៀតដោយភ្នែកផង ដើម្បីឲ្យចេះចាំយល់សេចក្តីបាន ។ ការស្តាប់ធម៌ទេសនាតាមវត្តកម្ពុជា ប្រចាំថ្ងៃ១កោសឋ-ស័លក្តី ស្តាប់កន្លះគាសបុណ្យណាមួយក៏ដែលលោកអ្នកបានធ្វើមកពាក់ថាជាមង្គលដ៏ត្រួតដោយឡែកមែនពិតហើយ ប៉ុន្តែបើអ្នកស្តាប់នោះ

មិនធ្លាប់បានរៀនមកពីមុនផងទេ ក៏យល់សេចក្តីបានដោយគ្រប់ៗ ដំណើរនេះយើងអ្នកមានបំណងល្អ តុំគួរពឹងផ្អែកទៅលើតែការស្តាប់មួយយ៉ាងប៉ុណ្ណោះទេ ត្រូវមានការរៀនទៀតផង, ការមើលសៀវភៅ, ការពិនិត្យពិចារណាផង ៖ ទើបមានប្រយោជន៍រឹតធំធូលាយ ជំនួយដល់ការស្តាប់នោះទៀត ។

ការស្តាប់នឹងការរៀននេះ រួមមកហៅថាការសិក្សា ។ ការសិក្សាកប់ថាជាដំហានទី ១ របស់មនុស្ស ដើម្បីឲ្យមានវឌ្ឍនធម៌ ព្រោះថាការសិក្សាសិល្បវិទ្យានេះ ទុកដូចជាកូនសោសម្រាប់ចាក់បើកទ្វារ ការកប្រយោជន៍គាំងបង្ហូរប្រៀនទីងបរលោក ។ ការសិក្សានេះ ជាអង្គការចាំបាច់រឹតមួយ ដ៏ប្រសើរបំផុតរបស់មនុស្ស ដែលនាំឲ្យមានច្បាស្មារតីចំពោះសាមីខ្លួនអ្នកសិក្សាផង នាំឲ្យថ្កុំថ្កើងចំពោះជាតិសាសនាផង ។ ការសិក្សាទុកជាអាយុជីវិត ឬជាមូលដ្ឋានរបស់អក្សរសាស្ត្រ ដែលនាំឲ្យអក្សរបស់ជាតិលូតលាស់ចំរើនឡើង ដោយពិត ។ អក្សរសាស្ត្រឈ្មោះថាជាឃ្លាំង សម្រាប់ផ្ទុកវិទ្យាសាស្ត្រផ្សេងៗ ។ ព្រោះហេតុនោះ ការស្តាប់ធម៌ទេសនាក្តី ស្តាប់សន្ទិសិទណាមួយក្តី ក៏គួរស្តាប់ដោយគោរព ដោយហេតុថាការស្តាប់នេះ ទុកជាមេរៀនមួយក្នុងផ្លូវបណ្តុះច្បាស្ញា សមដូចពុទ្ធភាសិតថា សុស្សូសំ លភតេ បញ្ញំ "អ្នកស្តាប់ដោយគោរព តែងយកចិត្តទុកដាក់រមែងបានខ្លួវបញ្ញា" ។ ព្រោះថា ច្បាស្ញារមែងកើតមានព្រោះការស្តាប់ ដែលលោកហៅថា

សុំតាមយថាបញ្ញា ។ ការស្តាប់នេះខុសថាជាមគ្គខ្ពស (ជាធម៌ទាំងអស់) ចង្អុលបង្ហាញច្បាប់ប្រយោជន៍ ដូចអធិប្បាយមកនេះ ។

๔- ធម្មានុវត្តិ = ការប្រព្រឹត្តិតាមធម៌

ពាក្យថា "ប្រព្រឹត្ត" នេះ បានសេចក្តីថា "ការធ្វើតាម, ការប្រតិបត្តិតាម, ការគាន់យកតាម ដែលចេញពីបាលីថា "អនុវត្តិ" ។ ឯពាក្យថា "ធម៌" ក្នុងទីនេះ សំដៅយកសុចរិតធម៌ ។ ការណ៍យកចិត្តនាទីមុខការរបស់មនុស្សគ្រាំងអស់ត្រូវធ្វើឲ្យប្រកបដោយសុចរិតធម៌ ទើបឈ្មោះថា ប្រព្រឹត្តតាមធម៌ ។

ដែលហៅថានាទីឬមុខការនោះ ដូចមាតាបិតាមានទាក់ទងការគ្រប់គ្រងកូនប្រុសស្រី, កូនប្រុសស្រីត្រូវមានទាក់ទងបុគ្គលការគុណនៃមាតាបិតាវិញ, ព្រះឧបជ្ឈាយាចារ្យមានទាក់ទងប្រៀនប្រដៅជាសំតៀនសិស្សគណ, សិស្សគណក៏ត្រូវមានទាក់ទងតួលនឹងព្រមទាំងតបឧបការគុណនៃព្រះឧបជ្ឈាយាចារ្យវិញ, ផ្នែកតិចាលមានទាក់ទងគ្រប់គ្រងពលរដ្ឋដោយស្មោះត្រង់ ដើម្បីឲ្យបានសុខចំរើនដល់ជាតិប្រទេស ពលរដ្ឋក៏ត្រូវមានទាក់ទងចំពេញការណ៍យកចិត្តទុកដាក់នៃពលរដ្ឋ មានការបង់ពន្ធជារដើម ។ មនុស្សគ្រប់ប្រភេទដែលមានទាក់ទងដូច្នេះ ត្រូវប្រព្រឹត្តដោយស្មោះត្រង់ខ្ជាប់ខ្ជួនតាមគន្លងច្បាប់ មិនត្រូវធ្វេសប្រហែសតាយងាយ ចំពោះនាទីរបស់ខ្លួនឡើយ ។ ការប្រតិបត្តិតាមនាទីរៀងៗខ្លួនដោយសុចរិតដូច្នេះឈ្មោះថាការប្រព្រឹត្តិតាមធម៌ ។

ក្នុងផ្លូវព្រះពុទ្ធសាសនា បព្វជិតទាំងភិក្ខុទាំងសាមណេរត្រូវមាន
នាទីខាងសិក្សារៀនសូត្រ ប្រតិបត្តិ តាមធម៌វិន័យតែសិក្ខាឲ្យត្រឹមត្រូវ
វិសេសឡើងជាងគ្រហស្ថ ព្រោះបព្វជិតបានទទួលការបត្តម្ភដោយ
បច្ច័យបួនអំពីគ្រហស្ថ មានគ្រហស្ថជាមូលដ្ឋាននៃអាជីវៈរបស់បព្វជិត ។
កាលបើយ៉ាងនេះ បព្វជិតត្រូវតែគាន់យកនាទីមុខការរបស់ខ្លួនដោយម៉ត់
ចត់ មិនត្រូវប្រព្រឹត្តពាយ៉ាយដែលឲ្យគេរិះគន់តេះជាយបានឡើយ ។
បព្វជិតទុកជាពុទ្ធបរិស័ទឆ្ងាំ, ឧបាសក ឧបាសិកា ជាពុទ្ធបរិស័ទបួន
ព្រះពុទ្ធបរមគ្រូទុកដូចជាបិតា ។ បើកូនឆ្កាំប្រព្រឹត្តធ្លាយយោកខាប
មិនត្រូវតាមនាទីរបស់ខ្លួន ដែលមានហាន:ជាបងទេ គឺពុំដឹកនាំប្អូនទៅ
រកល្អ គួរឲ្យប្អូនសង្ឃឹមកក់ក្តៅគោរងជាយចិត្តបងបានទេ តើឲ្យប្អូនមាន
សទ្ធាជ្រះថ្លាចំពោះបងដូចម្តេចកើត ?

ការប្រព្រឹត្តិរបស់បព្វជិតនោះ មិនចាំបាច់ដល់ទៅប្រព្រឹត្តអាក្រក់
ត្រូវពោសធំៗទេ សូម្បីគ្រាន់តែដើរអើតងើតកងផ្សារញឹកញយ ឬកត្រុក
ចូលទៅកាន់ទីដែលមានមនុស្សអ៊ូអរច្រើនក្តី ឃុំចិត្តដើរសើយជាយម្ខាង
ជាក់លើស្មាក្តី ដើរទន្ទឹមគ្នា និយាយជជែកគ្នាដូចគ្រហស្ថក្តី គំពុំគួរ
សមដល់សមណសារុប្ប (នាទីរបស់សមណ:) ដែរ ។ ករណីយ៍នេះ
បព្វជិតត្រូវតែប្រព្រឹត្ត អនុវត្តវិន័យឲ្យច្បាស់លាស់ឡើង សមដូចពុទ្ធ-
ភាសិតថា សាមញ្ញេ សមណោ តិដ្ឋេ "សមណ:ត្រូវឋិតនៅក្នុងធម៌
របស់សមណ: ដើម្បីរក្សាកិត្តិយសឲ្យមានតម្លៃផង ដើម្បីជាបុញ្ញក្ខេត្ត
នៃគ្រហស្ថជាបួនៗ ដែលមានសទ្ធាកុំឲ្យធ្លាក់ចុះផង" ។

ឋាតុជិតគួរពិចារណារឿយៗ ចំពោះទេសធម្មសូត្រ ដែលព្រះសម្ពុទ្ធ
បរមគ្រូសំដែងដឹកនាំ ចំពោះឋាតុជនៈពុទ្ធសាវក ដើម្បីឲ្យមានសីលធម៌
ល្អទៀងធ្ងន់ គួរឲ្យគ្រហស្ថមានសទ្ធាជ្រះថ្លា ។ ទេសធម្មសូត្រនោះគុកជា
កម្មវាចា ១ ដ៏ប្រសើរបំផុត ជាដំនួយដល់ការប្រតិបត្តិកន្លងផុតព្រះនិព្វាន ។
ការអនុវត្តតាមធម៌ ឬ នាថ ពាក់ថាជាគ្រាវដែលជាប្រធានរបស់ប្រយោជន៍
សម្រាប់បុគ្គលន័មួយ ។ ដូចពណ៌នាមកនេះ ។

៦_ អលីនតា = ភាពនៃការមិនជំអក់

ការមិនជំអក់នេះ ជាឈ្មោះនៃសេចក្តីព្យាយាមក្នុងការណ៍យកចិត្ត
ទាំងអស់ដែលបុគ្គលត្រូវប្រែកបត្រូវខ្លួន ។ ការងារដែលត្រូវខ្លួនទាំង
ប៉ុន្មាន សុទ្ធតែមានផលតាមសមគួរជាជាកបៈ បើការងារធំ មានផលក៏
ច្រើន, ការងារតូច មានផលក៏តិចៈ ប៉ុន្តែការងារនីមួយៗរបស់បុរសស្ត្រី
ច្រើនតែមានឧបស័គ្គ គឺហេតុការណ៍ឧបទ្រពចរមកជ្រៀតជ្រែកកកាំង
ស្ទាក់ដំណើរពុំសូវដែលខាន គឺបើការងារខ្លួនធ្ងន់ត្រូវប្រទះឧបស័គ្គធំ
បើការងារថោកទាបត្រូវជួបឧបស័គ្គក៏តូច ព្រោះហេតុនោះ បានជាព្រះ
បរមគ្រូទ្រង់សរសើរសេចក្តីព្យាយាម ថាជាគុណដ៏ប្រសើរបំផុត ដែល
អាចតស៊ូទឹងឧបស័គ្គបាន ។ បុគ្គលណាជាមនុស្សជំអក់ខ្ជិលច្រអូស មាន
អាការអកអាយយឺតៗ រអ៊ើលៗ មិនចេះប្រឹងប្រែងប្រកិបត្តិរបស់ខ្លួន ក្នុងកាល
ដែលគួរចេះប្រឹងៈ បុគ្គលនោះ រមែងធ្លាក់ខ្លួនទៅក្នុងរណ្តៅថោកទាប គឺ
សេចក្តីទុក្ខលំបាករហេមរហាមក្តៅក្រហាយជាច្រើនជ ។

ពាក្យថា មិនដំអក់ គឺមិនរួញរា មិនថយក្រោយ ដោយខ្លាចនូវសំគ្គ
ណាមួយទេ ។ បុគ្គលណាមានព្យាយាមមិនរួញរា ជាអ្នកប្រកបដោយ
សេចក្តីក្លាហានក្នុងការងារ បុគ្គលនោះរមែងឈានកន្លងនូវសេចក្តីទុក្ខ
លំបាកបានដោយពិត សមដូចព្រះពុទ្ធភាសិតថា វីរិយេន ទុក្ខមច្ចេតិ
បុគ្គលកន្លងនូវសេចក្តីទុក្ខបាន ព្រោះសេចក្តីព្យាយាម” ។ ផលប្រយោជន៍
គឺខ្យងសម្បត្តិយសបរិវារ ដែលបុគ្គលបានសម្រេចដូចគោលបំណងនោះ
ក៏សុទ្ធតែកើតមកដោយអាស្រ័យកម្លាំងសេចក្តីព្យាយាមមិនរួញរា ។
អ្នកដែលមានខ្យងសម្បត្តិស្កុកស្កម្ភ រមែងបានខ្លួលអំណរក្នុងចិត្តថា
“ខ្យងរបស់អាត្មាអញមានបរិបូណ៌ ធំធាយជាងខ្ទុកប៉ុន្តែសារបស់
អាត្មាអញ ឬធ្វើអ្វីក៏បានដូចបំណង” ។ សេចក្តីត្រែកអរចំពោះខ្យង
សម្បត្តិនេះ ជាផលានិសង្សដែលកើតមកអំពីសេចក្តីព្យាយាមមាំមួនមិន
រួញរា ព្រមទាំងការយកចិត្តទុកដាក់ចំពោះខ្យងសម្បត្តិដែលបានមក
ហើយ ដោយមានការសន្សំរេចទុកដាក់ឲ្យគង់នៅប្រកបដោយ
អារក្ខសម្បទា ជាអ្នកវៀរចាកអបាយមុខ ៤ យ៉ាង មានល្បែងលេងស្រី
ជាដើម ។

ខ្យងដើមទុនតិចសោះ ប៉ុន្តែអាចឡើងទៅជាខ្យងច្រើនបាន
ព្រោះគុណានុភាពនៃសេចក្តីព្យាយាមច្រើនវែងឆ្ងាយ ដូចព្រះពុទ្ធភាសិតថា
ឧដ្ឋាតា វិន្ទតេ ធនំ “បុគ្គលអ្នកក្រោកឡើងច្រើនវែងរមែងបានខ្លួ
ខ្យង” ។ ដំណើរនេះមានទិដ្ឋានក្នុងគម្ពីរថា បុរសម្នាក់ជាអ្នកចំរើបុណ្យក-

សេដ្ឋីបានឃើញកណ្តុរស្វាប់មួយ ហើយរើសយួរយកទៅលក់ឲ្យអ្នកចិញ្ចឹមឆ្មារ បានមួយកាកណិក ដែលជារបស់ចាយយ៉ាងតិចបំផុត គ្រាប់ស្មើនឹងមួយសេនរបស់យើង ។ បុរសនេះមានដើមទុនដំបូងតែមួយសេនប៉ុណ្ណោះសោះ ប៉ុន្តែលុះដល់ចំណេរតមកចៃតែទិញដូរលក់នេះខ្លះនោះខ្លះមិនឈប់ សន្សំម្តងបន្តិចៗ យូរៗ ទៅទាល់តែបានទ្បើងហាន: ទៅជាសេដ្ឋីដោយកម្លាំងនៃសេចក្តីព្យាយាមក្នុងការស្វែងរក, ក្នុងការសន្សំដូចសំដែងមកដោយសង្ខេបប៉ុណ្ណោះ ។ ភាពនៃការមិនដំអក់ខ្ជិលនឹង គឺសេចក្តីព្យាយាមរៀសរៀវដោយការប្រឹងប្រែងអន្ទោកអន្ទាល ខ្ជូចចំពោះកិច្ចការ ទាន់កាលសម័យ មិនឈប់មិនដាក់ធុរៈចោលនេះលោកពាប់ថាជាទ្វារដ៏ប្រសើរមួយ ដែលអាចនាំឲ្យមានប្រយោជន៍យ៉ាងច្រើន ដូចពណ៌នាមកនេះ ។

ធម៌ទាំង ៦ ប្រការដែលបានអធិប្បាយមកនេះ ឈ្មោះ អត្ថទ្វារកថា ពណ៌នាអំពីទ្វារសម្រាប់បើកចូលទៅរកប្រយោជន៍ដូចបានសំដែងមក ។ ធម៌ទាំង ៦ ប្រការនេះកាលបើបំពេញទៅបរិបូណ៌ក្នុងបុគ្គលណា រមែងញុំាងបុគ្គលនោះឲ្យបានចូលទៅតាមទ្វារ ដើម្បីចួបប្រទះនូវប្រយោជន៍ណាមួយដូចចំណង់ក្នុងលោកនេះឬលោកខាងមុខពុំខាន ។

មុនទីឋបញ្ចប់ធម្មកថានេះអាត្មាភាពសូមបួងសួងដូចតទៅនេះ ៖

សាសនស្ស ច លោកស្ស វុឌ្ឍី ភវតុ សព្វទា

សាសនម្បិ ច លោកញ្ច ទេវា រក្ខន្តុ សព្វទា ។

(ដោយអានុភាពនៃធម្មទេសនានេះ) សូមឲ្យព្រះពុទ្ធសាសនានឹងសត្វលោកមានសេចក្តីចំរើនគ្រប់ៗ កាល! សូមទេវតាទាំងឡាយរក្សានូវព្រះពុទ្ធសាសនាផង នូវសត្វលោកផង (ឲ្យបានសេចក្តីសុខ-ចំរើន) គ្រប់ៗ កាល!

ទុក្ខប្បត្តា ច និទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្ពេបិ ពុទ្ធិកា ។

(ដោយអានុភាពនៃធម្មទេសនា ដោយអានុភាពនៃកុសលចិត្តរបស់ពុទ្ធបរិស័ទ ដែលបានគោរពបូជាស្តាប់ធម្មទេសនានេះ) ពួកពុទ្ធបរិស័ទទាំងអស់ ដែលជាប់នូវទុក្ខ សូមឲ្យបាត់ទុក្ខ! ដែលជាប់នូវភ័យ សូមឲ្យបាត់ភ័យ! ដែលជាប់នូវសោកគ្រឹមក្រំ សូមឲ្យបាត់សោកគ្រឹមក្រំទៅ!

និគមវិបន:

បើសង្កេចបៃបទេសនាខាងលើនេះ មានន័យដូច្នេះគឺប្រយោជន៍ដ៏ថ្លៃថ្លា
ដែលកើតមានដល់ជនានុជនណា លុះតែត្រាប្រកបគុណ ៦ ឆត់ ។
គឺទី ១ ជនខ្លះឯងគ្មានជម្ងឺ, ទី ២ គឺជាអ្នកកាន់សីលហ្មត់ចត់,
ផ្នែកទី ៣ ជាអ្នកយល់ត្រូវប្រាកដ មិនខុសភ្លាត់ឃ្លាតជាកធម្មិដ្ឋិវរ ។
ទី ៤ គឺជាអ្នកចេះចំណេះស្តាំ, ផ្នែកទី ៥ គឺជាអ្នកប្រព្រឹត្តធម៌,
ទី ៦ គឺជាអ្នកស្តាប់ក្តីប្រ មិនឲ្យមក់ដោយទស្សាហ៍មិនទំរន់ ។
យើងជាខ្មែរជាអ្នកកាន់ពុទ្ធសាស្ន គួរប្រកាសកាន់ធម៌នេះត្រង់ដំបន់
បើកាន់បានត្រាកដជាយើងមិនអន់ ថ្លៃនិរន្តរ៍សព្វប្រទេសកោតសរសើរ ។

ប្រជុំធម៌ឧទាសក

ប្រស្នាសួរ-ឆ្លើយ

ព្រះទេពសត្ថា កឹម-ភ្ជួរ ចន្ទមង្គលោ

ក្រុមដំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

(តមក)

៥— ផលនៃសរណាគមន៍

ស. ផលនៃសរណាគមន៍ បែកខាងលោកុត្តរដូចម្តេច? បែកខាងលោកិយ ដូចម្តេច? ចូរអធិប្បាយ!

ឆ. សាមញ្ញផល ៤ (គឺផលនៃមគ្គទាំង ៤) ទំនឹងការអស់ទៅនៃទុក្ខទាំងពួង នេះជាផលនៃលោកុត្តរសរណាគមន៍ សមដូចព្រះគាសិតថា បុគ្គលណា បានដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាសរណៈហើយ បុគ្គលនោះរមែងឃើញដោយប្រាជ្ញាដ៏ប្រពៃនូវអរិយសច្ចទាំង ៤ គឺ ទុក្ខ ១ សមុទ័យជាហេតុកើតឡើងនៃទុក្ខ ១ និរោធជាទីកន្លងផុតនូវទុក្ខ ១ មគ្គមានអង្គ ៨ ដ៏ប្រសើរ ជាដំណើរទៅកាន់ទីរម្ងាប់នូវទុក្ខ ១ សរណៈរបស់បុគ្គលនោះឯង ឈ្មោះថាជាសរណៈដ៏ក្សេម ឈ្មោះថាជាសរណៈដ៏ឧត្តម បុគ្គលអាស្រ័យនូវសរណៈដ៏ក្សេមដ៏ឧត្តមនោះ រមែងរួចចាកទុក្ខទាំងពួង នេះជាផលនៃលោកុត្តរសរណាគមន៍ ។

កាសម្បទា (ការបរិបូណ៌ដោយកាយ) ១ ភោគសម្បទា (ការបរិបូណ៌

ដោយកោតសម្បីទ) ๑ ពាំង ๒ នេះ ជាផលនៃលោកិយសរណគមន៍ សមដូចពុទ្ធភាសិតថា "ពួកជនណាមួយ ឋានដល់នូវព្រះពុទ្ធជាសរណៈ ពួកជនោះទឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់កាយជារបស់មនុស្សហើយ ទឹងបានទៅកើតក្នុងពួកទេវតា" ។ សេចក្តីនេះបញ្ជាក់ឲ្យឃើញថា ជាផលនៃលោកិយសរណគមន៍ ។

ន័យមួយទៀត លោកសម្តែងថា កាលព្រះឥន្ទ្រនាំពួកទេវតា ๘๐.๐๐๐ អង្គចូលទៅថ្វាយបង្គំគាល់ព្រះមហាមោគ្គល្លានត្ថេរ រំលោះព្រះមហាមោគ្គល្លានត្ថេរ ឋានពោលពាក្យនេះចំពោះព្រះឥន្ទ្រថា:

បពិត្រទេវរាជជាធំជាងពួកទេវតា ! ការដល់នូវព្រះពុទ្ធជាសរណៈប្រពៃណាស់ សត្វពួកខ្លះក្នុងលោកនេះ លុះបែកធ្លាយរាងកាយ ទាងមុខអំពីសេចក្តីស្លាប់ក៏ឋានទៅកើតក្នុងសុគតិ គឺសួគ៌ទេវលោក ព្រោះហេតុនៃការដល់នូវព្រះពុទ្ធជាសរណៈនេះឯង ពួកទេវតានោះរមែងរុងរឿងកន្ទុងផុតពួកទេវតាដទៃដោយបណ្តាការ ๑๐ យ៉ាង គឺ

๑_ ទិព្វំ អាយុំ អាយុជាទិព្វ

๒_ ទិព្វំ វណ្ណំ វណ្ណៈ (ពណ៌សម្បុរ) ជាទិព្វ

๓_ ទិព្វំ សុខំ សុខជាទិព្វ

๔_ ទិព្វំ យសំ យសជាទិព្វ

๕_ ទិព្វំ អាធិបតេយ្យំ ភាពនៃអធិបតីជាទិព្វ

๖_ ទិព្វំ រូបំ រូបជាទិព្វ

๗– ទិព្វំ សទ្ទំ សំឡេងជាទិព្វ

๘– ទិព្វំ គន្ធំ ក្លិនជាទិព្វ

๙– ទិព្វំ រសំ រសជាទិព្វ

๑๐– ទិព្វំ ផោដ្ឋព្វំ ផ្សព្វជាទិព្វ ។

បណ្ណាការតាំង ๑๐ នេះជាផលនៃលោកិយសរណាគមន៍ ។

ស. សេចក្តីដែលបានពោលរួចមកហើយនេះ យើញចំពោះតែផលនៃការដល់ទូវព្រះពុទ្ធជាសរណៈ ចុះចំណែកខាងការដល់ទូវព្រះធម៌ និងព្រះសង្ឃជាសរណៈ មានផលផ្សេងគ្នាពីនោះ ឬ ដូចគ្នា ?

ឆ. មិនផ្សេងពីគ្នាទេ ការដល់ទូវព្រះធម៌និងព្រះសង្ឃជាសរណៈ មានផលច្រើនដូចការដល់ទូវព្រះពុទ្ធជាសរណៈដែរ ។

๖– សេចក្តីសៅហ្មងនៃសរណាគមន៍

ស. ដូចម្តេចហៅថា សេចក្តីសៅហ្មងនៃសរណាគមន៍ ?

ឆ. សរណាគមន៍ មិនចរិសុទ្ធស្អាត មិនរុងរឿង មិនមានពន្លឺរស្មីផ្សាយចេញ ហៅថា សេចក្តីសៅហ្មងនៃសរណាគមន៍ ។

ស. សរណាគមន៍ប្រភេទណា មានសេចក្តីសៅហ្មង ? ប្រភេទណា មិនមានសេចក្តីសៅហ្មង ?

ឆ. លោកុត្តរសរណាគមន៍ មិនមានសេចក្តីសៅហ្មងទេ, ឯលោកិយសរណាគមន៍ ទើបមានសេចក្តីសៅហ្មង ។

ស. លោកយ៉សរណាគមន៍ដែលសៅហ្មងនោះ តើសៅហ្មងដោយហេតុប៉ុន្មានយ៉ាង? អ្វីខ្លះ?

ឆ. សៅហ្មងដោយហេតុច្រើនយ៉ាង តែក្នុងទីនេះសូមលើកយកត្រឹមតែហេតុ ៣ យ៉ាងគឺ

๑— អញ្ញាណ: ការមិនដឹង ឬមិនយល់ចំពោះវត្ថុដ៏សក្តិសិទ្ធិទាំង ៣ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ,

๒— សំសយ: ការសង្ស័យមិនដាច់ស្រេច ចំពោះព្រះវត្ថុត្រៃយ៍,

๓— មិច្ឆាញ្ញាណ: ការយល់ខុសចំពោះព្រះវត្ថុត្រៃយ៍ ។

๗— ការបែកធ្លាយនៃសរណាគមន៍

ស. សរណាគមន៍ប្រភេទណានៅមានការបែកធ្លាយ? ប្រភេទណាមិនមានការបែកធ្លាយ?

ឆ. លោកុត្តរសរណាគមន៍ មិនមានការបែកធ្លាយ ឬដាច់ខែឯលោកិយសរណាគមន៍ ទើបមានការបែកធ្លាយ ។

ស. ចុះលោកុត្តរសរណាគមន៍ ដែលមិនមានការបែកធ្លាយនោះ តើព្រោះអ្វី?

ឆ. ព្រោះថា អរិយសាវ័កដែលអន្ទោលទៅក្នុងភពតូចភពធំ មិនឧស្សាហ៍ចំពោះគ្រូដទៃ គឺថាមិនយកគ្រូខាងក្រៅពុទ្ធសាសនាមកជាទីពឹងទីរឭក ។

ស. លោកយ៉ាសរណាគមន៍ដែលនឹងបែកធ្លាយឬជាប់ ដោយហេតុអ្វីខ្លះ?

ឆ. ដោយហេតុដែលត្រឡប់ទៅប្រតល់កាយថ្វាយខ្លួន ចំពោះត្រូវជាខាងក្រៅពុទ្ធសាសនាជាដើម ១ ដោយការធ្វើមរណភាពទៅកាន់បរលោក ១ ។

ស. បុគ្គលដែលបានប្តេជ្ញាខ្លួនចូលសរណាគមន៍រួចហើយ ទៅសម្តែងសេចក្តីគោរពមានសំពះ ឬថ្វាយបង្គំជាដើមចំពោះពួកញាតិដែលចូលទៅបួសក្នុងសំណាក់និគ្រន្ថតិរ្ថិយខាងក្រៅពុទ្ធសាសនា តើជាប់សរណាគមន៍ឬទេ? ព្រោះអ្វី?

ឆ. មិនជាប់ មិនសៅហ្មងទេ ព្រោះគិតថាជាញាតិសាលោហិតរបស់ខ្លួន ហើយសំដែងសេចក្តីគួរសមសំពះទៅប៉ុណ្ណោះ ។

ស. ជាប់សរណាគមន៍ បែបណាដែលមានទោស? ជាប់បែបណាដែលមិនមានទោស?

ឆ. បុគ្គលបានដល់សរណាគមន៍សិប់សួនហើយ បែរជាត្រឡប់ទៅប្រតល់កាយថ្វាយខ្លួន ដល់ត្រូវជាខាងក្រៅពុទ្ធសាសនា ហើយតិះដៀលសរណាគមន៍មានព្រះពុទ្ធជាដើមវិញ សរណាគមន៍របស់បុគ្គលនោះឈ្មោះថា ជាប់ហើយមានទោស; បុគ្គលបានដល់សរណាគមន៍ហើយធ្វើកាលកិរិយាស្លាប់ទៅ ឈ្មោះថា ជាប់សរណាគមន៍ដែរ តែមិនមានទោសទេ ។

๘_ សីលនៃឧបាសកឧបាសិកា

ស. សីលដែលឧបាសកឧបាសិកា អាចរក្សាបានតាមសេចក្តីជ្រះថ្លារបស់ខ្លួន តើមានប៉ុន្មានយ៉ាង? អ្វីខ្លះ?

ឆ. មាន ៣ យ៉ាងគឺ និច្ចសីល ១ ឧបោសថសីល ១ អតិរេកសីល ១។

ស. សីលទាំង ៣ យ៉ាងនេះ មានកំណត់ចំនួនសិក្ខាបទផ្សេងគ្នាដូចម្តេច?

ឆ. មានកំណត់ចំនួនសិក្ខាបទផ្សេងគ្នាដូច្នេះ សិក្ខាបទ ៥ មានបាណាតិបាតជាដើម មានសុភជាទីបំផុត ហៅថា និច្চសីល ។ សិក្ខាបទ ៨ មានបាណាតិបាតជាដើម មានឧច្চាសយនៈ ជាទីបំផុត ហៅថា ឧបោសថសីល ។ សិក្ខាបទ ១០ មានបាណាតិបាតជាដើម មានជាតរូបជាទីបំផុត ហៅថា អតិរេកសីល ឬនឹងហៅថា និច្চសីលវិញក៏បាន ។

ស. បណ្តាសីលទាំង ៣ យ៉ាងនុ៎ះ ណាមានសេចក្តីវិសេសជាងណា?

ឆ. មានសេចក្តីវិសេសជាងគ្នាយ៉ាងនេះគឺ ឧបោសថសីលមានសេចក្តីវិសេសជាងនិច្চសីល, អតិរេកសីល មានសេចក្តីវិសេសជាងឧបោសថសីល ។

ស_ កុងនិច្চសីល (សីល ៥) ត្រង់សិក្ខាបទទី ៣ ថា កាមេសុមិច្ឆាចារៈ, កុងឧបោសថសីល (សីល ៨) ត្រង់សិក្ខាបទទី ៣ ថា អព្រហ្មចរិយៈវិញ តើមានសេចក្តីផ្សេងគ្នាយ៉ាងណា? ព្រោះហេតុអ្វី?

๔. មានសេចក្តីផ្សេងគ្នាយ៉ាងនេះ គាមេសុ មិច្ឆាចារៈ វៀរចំពោះស្ត្រី ๒๐ចំពួក លើកលែងតែស្វាមីនឹងកំយោវបស់ខ្លួនចេញ ឯអព្រហ្មចរិយៈ វៀរចំពោះគ្រាមគ្គទាំង ๓๐ គ្រាណាមួយអស់អំណាចកាលដែលរក្សាឧបោសថ ព្រោះហេតុថា និច្ចសីល មានហាន:ថាបធ្លុវថយជាងឧបោសថសីល ។

ស. ស្ត្រី ๒๐ ចំពួកនោះ ចានដល់ស្ត្រីបែបណាខ្លះ?

ឆ. ស្ត្រី ๒๐ ចំពួកនោះ គឺ

๑— មាតុរក្ខិតា ស្ត្រីដែលមាតាគ្រប់គ្រងរក្សា

๒— បិតុរក្ខិតា ស្ត្រីដែលបិតាគ្រប់គ្រងរក្សា

๓— មាតាបិតុរក្ខិតា ស្ត្រីដែលមាតាបិតាគ្រប់គ្រងរក្សា

๔— ភាតុរក្ខិតា ស្ត្រីដែលបងប្រុស ប្អូនប្រុសគ្រប់គ្រងរក្សា

๕— ភគិនីរក្ខិតា ស្ត្រីដែលបងស្រី ប្អូនស្រីគ្រប់គ្រងរក្សា

๖— ញាតិរក្ខិតា ស្ត្រីដែលញាតិគ្រប់គ្រងរក្សា

๗— គោត្តរក្ខិតា ស្ត្រីដែលគោត្រជាមួយគ្នា គ្រប់គ្រងរក្សា

๘— ធម្មរក្ខិតា ស្ត្រីដែលបព្វជិតពួកណាមួយ អ្នកប្រតិត្តធម៌ត្រូវគ្នា គ្រប់គ្រងរក្សា

๙— សារក្ខា ស្ត្រីដែលប្រកបដោយការរក្សា គឺស្ត្រីដែលមានស្វាមីហើយ ឬមានគេប្រកាន់ទុកហើយ

๑๐_ សបរិទណ្ឌា ស្ត្រីដែលចែកបដោយអាជ្ញា គឺស្ត្រីដែលព្រះពុទ្ធជាម្ចាស់ព្រះពោធិសត្វអាជ្ញាមិនឲ្យប្រព្រឹត្តតាមអំពើចិត្ត ឬមិនឲ្យបុរសណាមួយទៅប្រព្រឹត្តកន្ទួន

๑๑_ ធនក្កីតា ស្ត្រីដែលគេទិញ ឬលោះដោយទ្រព្យ យកមកធ្វើជាភរិយា ឬត្រឹមតែលោះមកប៉ុណ្ណោះមិនបានយកធ្វើជាភរិយាទេ

๑๒_ ឆន្ទវាសិនី ស្ត្រីដែលតែងតាមទៅនៅធ្វើជាភរិយារបស់បុរសដោយសេចក្តីពេញចិត្តរបស់ខ្លួន ខាងបុរសក៏ខ្ជិលត្រមង់ដែរ

๑๓_ ភោគវាសិនី ស្ត្រីដែលទៅនៅធ្វើជាភរិយារបស់បុរសព្រោះតែភោគៈ គឺស្ត្រីដែលបានភោគៈយ៉ាងហោចត្រឹមតែអង្រែនឹងតម្បាល់ជាដើមអំពីបុរសណា ក៏ទៅនៅធ្វើជាភរិយារបស់បុរសនោះ

๑๔_ បដវាសិនី ស្ត្រីដែលទៅនៅធ្វើជាភរិយារបស់បុរសព្រោះតែសំពត់ គឺស្ត្រីអ្នកកំសត់ដែលគ្រាន់តែគេឲ្យសំពត់ ស្បែកជណ្តាប់ប៉ុណ្ណោះ ក៏ព្រមចូលទៅនៅធ្វើជាភរិយា

๑๕_ ឱទបត្តកិនី ស្ត្រីដែលគេផ្គាប់ដៃជាមួយនឹងបុរសជ្រលក់ទៅកងតាងទឹក ឬផ្តួលទឹកមួយ ហើយគេពោលថា អ្នកនាងចាំងឡាយចូរច្រឡំគ្នា ចូរកុំបែកចាក់គ្នា ដូចជាទឹកនេះ

๑๖_ ទាសភរិយា ស្ត្រីដែលគេជាក់ខ្លួនចុះអំពីក្បាល គឺស្ត្រីអ្នករកទុសជាដើម ដែលបុរសណាមួយ ជួយជាក់ខ្លួនអំពីក្បាលហើយនាំយកទៅធ្វើជាភរិយា

๑๗- ทาสีภริยา ប្រែថាស្ត្រីដែលជាទាសីគេផង ជាភរិយាគេផង គឺស្ត្រីជាទាសីរបស់បុរសណាមួយ ហើយបុរសនោះយកធ្វើជាភរិយា

๑๘- กัมมการีภริยา ប្រែថាស្ត្រីដែលជាកូនឈ្នួលគេផង ភរិយាគេផង គឺស្ត្រីដែលចូលទៅនៅធ្វើការស៊ីឈ្នួលឲ្យគេ ហើយមានបុរសណាមួយ ប្តូរផ្ទៅរបស់ខ្លួននោះទៅរួមសង្វាសជាមួយ លែងត្រូវការដោយភរិយារបស់ខ្លួន

๑๙- ธชาหฏา ស្ត្រីដែលសេនាទាំមកដោយទង់ជ័យ គឺស្ត្រីដែលសេនាដំឡើងទង់ជ័យលើកទ័ពទៅច្បាំងដណ្តើមដែនរបស់ស្តេចដទៃកៀរយកបានមក ហើយមានបុរសណាមួយ យកធ្វើជាភរិយា

๒๐- ปุพฺพาธิกา ស្ត្រីដែលមានបុរសទៅកប់ប្រសព្វតែមួយស្រាប់ ។ គឺស្ត្រីដែលជាសហាយស្នំរបស់បុរសណាមួយ ។

ส. บุคคลผู้ควรสงเคราะห์ มีธรรมอย่างไร สำหรับช่วยการงานมิให้เสียหายนั้น ตามนัยพระบาลี?

ต. มีธรรม ๒ ประการ คือ หิริ ความละอายบาป ๑ โอตตัปปะ ความเกรงกลัวบาป ๑ สำหรับช่วยการงาน ๆ

(มีต่อ)

សំនួរ-ចម្លើយ

ឃុនបណ្ណាគុរក្ស ប៊ូ-ប៊ូ រៀបរៀង

សំនួរ- សីលធម៌ និង សិល្បសាស្ត្រផ្សេងគ្នាដូចម្តេច?

ចម្លើយ - ផ្សេងគ្នាយ៉ាងនេះ: សីលធម៌សំដៅយកសីលនិងធម៌ដែលមនុស្សលោកត្រូវគាន់ ត្រូវប្រព្រឹត្ត មានឧប្បសីលនិង។ ចោសថសីលជាដើម ឬថា វិរតិចេតនាដែលវៀរចាកអំពើអាក្រក់ ការប្រព្រឹត្តិល្អដោយកាយវាចា, ការមិនប្រព្រឹត្តិល្មើសកន្ទងសិក្ខាបទ រួមហៅថា សីលធម៌ ។ បើនិយាយឲ្យខ្លីថា ការគាន់ចរិយាល្អ, ការសង្រួម, គំនិតមានយោនល្អ, មានសណ្តាប់ធ្នាប់ ចាត់ជាសីលធម៌ ។ សីលធម៌នេះ កើតមានក្នុងសន្តានចិត្តរបស់ខ្លួនតែម្យ៉ាង មិនកើតពីអ្នកដទៃទេ ។ ចំណែកសិល្បសាស្ត្រ សំដៅយកក្បួនដែលនិយាយពីចំណេះវិជ្ជាគ្រប់មុខ ដូចយ៉ាងនិយាយពីការជាងផ្សេង។, ការហត្ថកម្ម, រហូតដល់ការបង្ហាត់សេះ, ដំរី, ចំណេះភ្លេងតន្ត្រី, ច្រៀង, កំជាដើម ឬប្រជាប់តាក់តែង, ការរចនាវិចិត្រផ្សេង។, មន្ត, អាគម, គាថាខ្ទាំងពួក ចាត់ជាសិល្បសាស្ត្រទាំងអស់ ។ សិល្បសាស្ត្រនេះ កើតមានដោយសារបានរៀនសូត្រអំពីគ្រូអាចារ្យដទៃ មិនមែនកើតឯងឯងទេ ឯងឯង ។

សំនួរ- សីលធម៌និងសិល្បសាស្ត្រ ត្រូវអាស្រ័យគ្នាដែរឬទេ?

ចម្លើយ - ត្រូវអាស្រ័យគ្នាជាដរាប ខានមិនបាន ព្រោះថា ក្នុង

មនុស្សម្នាក់ ថើមានតែសីលធម៌ គ្មានសិល្បសាស្ត្រទេ មិនអាចនឹងចិញ្ចឹមជីវិតឲ្យសុខស្រួលបានទេ ព្រោះមិនចេះធ្វើការងារផ្សេង ។ ។ ចំណែកអ្នកដែលមានតែសិល្បសាស្ត្រតែម្យ៉ាង គ្មានសីលធម៌ ក៏មិនអាចនឹងតាំងខ្លួនឲ្យសុខសប្បាយ ឲ្យចំរើនវុឌ្ឍិបានដែរ ដ្បិតអ្នកចេះសិល្បសាស្ត្រនោះ មានគំនិតមារយោគគក់ ប្រព្រឹត្តខុសច្បាប់លោកច្បាប់ធម៌ ដូចជាអ្នកចេះមន្តស្នេហ៍លួចពង្រត់កូនក្រមុំគេ មុខជាគេប្តឹងផ្តល់រកចាប់ខ្លួនធ្វើទោសពុំខាន ។ ហេតុនេះ មនុស្សម្នាក់ៗ ត្រូវតែមានសីលធម៌ផង មានសិល្បសាស្ត្រផង ខ្វះណាមួយមិនបាន ។

សំនួរ - ចុះមនុស្សដែលចេះតែសិល្បសាស្ត្រម្យ៉ាង គ្មានសីលធម៌នោះតើ ដូចជារឿងអ្នកណា ?

ចម្លើយ - ដូចរឿងគ្រូពេទ្យម្នាក់ គិតចង់បានវ៉ាន់លាភសក្ការៈពីអ្នកស្រុក ក៏ចាប់យកពស់វែកមួយទៅបញ្ចុកក្នុងវត្តឈើ ហើយបញ្ឆោតក្មេងឃ្វាលគោប៉ាថាកូនសត្វសាកែ ឲ្យប៉ាប់ក្មេងចាប់យកមកលេង ។ លុះក្មេងទៅចាប់យកមកស្គាល់ថាជាពស់វែក ក៏តិះដៀលណាស់ តំគ្រែវែងពស់ទៅលើខ្លួនគ្រូពេទ្យ ពស់ចឹកគ្រូពេទ្យនោះស្លាប់មួយរំពេចទៅ ។

សំនួរ- ចុះមនុស្សដែលចេះសិល្បសាស្ត្រផង មានសីលធម៌ផងនោះ តើដូចជារឿងអ្នកណា ?

ចម្លើយ- ដូចជារឿងគ្រូពេទ្យម្នាក់ឈ្មោះដីវកកោមារភច្ច ជាន មើលជម្ងឺសេដ្ឋីម្នាក់ដែលមានពេលឈឺក្បាល ៧ ឆ្នាំមកហើយ ពួកគ្រូពេទ្យធំៗមើលពុំជា យកតែវ៉ាន់អស់ជាច្រើនហើយតត់ចោលលែងមើលទៅ

សេដ្ឋីសន្យាថា បើលោកគ្រូមើលជម្ងឺខ្ញុំជា ខ្ញុំនឹងជូនសម្បត្តិទាំងអស់ឯខ្ញុំនេះ ក៏ទៅធ្វើជាខ្ញុំលោកទៀត ។ គ្រូពេទ្យដីកកោមរកត្បូងពួលព្រម ក៏ឲ្យសេដ្ឋីដេកលើគ្រែចងភ្ជាប់នឹងគ្រែរួចហើយ ក៏វះក្បាលវែកលលាដ៍ចេញផ្តើរយកសត្វមេពេគល្អិត ។ ជាន់ពីមកបង្ហាញឲ្យគេមើលគ្រប់គ្នា ។ ឲ្យសេដ្ឋីដេកផ្ទាល់នឹងផ្នែង ៧ ថ្ងៃ ៣ ដងលើគ្រែសះមុខរបួសហើយឲ្យក្រោកឡើង ។ សេដ្ឋីជូនសម្បត្តិឲ្យទាំងអស់ គ្រូពេទ្យប្រកែកមិនយក ទទួលយកតែប្រាក់ ១ សែនរៀលសម្រាប់ខ្លួន នឹងបង្គាប់ឲ្យថ្វាយចំពោះព្រះបាទពិម្ពិសារជាម្ចាស់ខ្លួន ១ សែនរៀលទៀតប៉ុណ្ណោះ ។

តមក គ្រូពេទ្យដីកកោមរកត្បូងបានឡើងសក្តិយសជាមន្ត្រីជាន់ខ្ពស់ព្រមទាំងមានសម្បត្តិឲ្យច្រើន ដោយសារតែចេះសិល្បសាស្ត្រខាងពេទ្យស្ទាត់ជំនាញហើយថែមទាំងមានសីលធម៌បរិបូណ៌ក្នុងខ្លួនផង ។

ចប់

បំណេះរឿងមិនស្មើមារយាទ

មនុស្សប្រុសស្រី ធ្វើការអ្វី ។ ដោយអាងវិជ្ជា
តាមចេះច្រើនតិច យល់តិចនានា បានផលប្លែកគ្នា
ទៅតាមមារយាទ ។

ប៊ូ-ប៊ូ

ទាបកថារឿងពុទ្ធរូបបុកណា

ឃុនអត្ថការវិទ ជា-ឃ្លែរ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែចាកទស្សនាវដ្តី ដំណាំងសាសនា ឆ្នាំទី ១ ច្បាប់ទី ៦ ភាសាថៃ

(ចប់)

ឥឡូវនេះនឹងពោលដល់វិធីសង្កេតឲ្យដឹងថា ព្រះពោធិសត្វអង្គណា ជាឧបជ្ឈាតិកៈរបស់ព្រះពុទ្ធអង្គណា គឺថាបើជាឧបជ្ឈាតិកៈរបស់ព្រះពុទ្ធអង្គណា ក៏មានរូបព្រះពុទ្ធអង្គនោះជាប់នៅលើព្រះនលាដៈ (ថ្ងាស) ជាគ្រឿងសំគាល់ ដូចព្រះពោធិសត្វរបស់ព្រះវៃរោចនៈ មានព្រះពុទ្ធរូបសម័យបឋមទេសនា ជាគ្រឿងសំគាល់, បើជាព្រះពោធិសត្វរបស់ព្រះអក្សោភយៈ មានព្រះពុទ្ធរូបសម័យមារវិជ័យជាគ្រឿងសំគាល់, បើជាព្រះពោធិសត្វរបស់ព្រះរតនសម្ភវៈ មានព្រះពុទ្ធរូបសម័យប្រទានពរជាគ្រឿងសំគាល់, បើជាព្រះពោធិសត្វរបស់ព្រះអមិតាភៈ មានព្រះពុទ្ធរូបសម័យសមាធិជាគ្រឿងសំគាល់, បើជាព្រះពោធិសត្វរបស់ព្រះអមោឃសិទ្ធៈ មានព្រះពុទ្ធរូបសម័យប្រទានអភ័យជាគ្រឿងសំគាល់ ។

កាលសាស្តាចារ្យថែកទាំងមហាយាន ផ្ទាស់វិធីប្រកាសសាសនាដូច្នេះ ក៏ធ្វើឲ្យមនុស្សនិកាយហាក់ចិត្តស្រឡាញ់កាន់យកចុះចូលជាច្រើន ព្រោះគេគិតឃើញថា ព្រះពុទ្ធជាម្ចាស់បរិនិព្វានទៅហើយ តែនៅមានព្រះអាទិពុទ្ធ ទើបព្រះធ្យានិពុទ្ធទៅនាហានសួគ៌ជាដើមបាន ។ កាលប្រែរបៀបប្រកាសសាសនាដូច្នេះ មនុស្សដែលល្ងង់ខ្លៅអាប់ឥតប្រាជ្ញាក៏ជឿបានដោយងាយ, អ្នកប្រកាសក៏ចេះតែមានផ្លូវមិនចាញ់សាសនា

ព្រាហ្មណ៍ ។ ព្រះពុទ្ធសាសនានឹងសាសនាព្រាហ្មណ៍ មានន័យមិនផ្សេងគ្នាណាស់ទេ ដូចបានពោលមកហើយ ព្រោះដូច្នោះទើបជាសាសនាដែលទៅជាមួយគ្នាមកជាមួយគ្នាបាន ដូចក្នុងប្រទេសយើងសាសនាព្រាហ្មណ៍ បានផ្សាយមកដល់ស្រុករព្រះពុទ្ធសាសនា ដែលចូលមកដល់ស្រុកយើងថ្មី ។ នោះដែរ ។

ព្រះពុទ្ធរូបយុគបន្ទាប់មកពីសម័យគ្មារវតី គឺសម័យស្រីវិជ័យ ។ សម័យស្រីវិជ័យ គេកាប់អានព្រះពុទ្ធសាសនាប៉ែកខាងមហាយាន ដូចបានពោលមកហើយ ។ ក្នុងពុទ្ធសាសនាខាងមហាយានគេកាប់អានព្រះពោធិសត្វថាជាតួរអង្គដ៏សំខាន់ ព្រោះដូច្នោះទើបមានរូបព្រះពោធិសត្វជាច្រើនពៃក្រៃលែង ។ ព្រះបោះពុម្ព ២០.៣០ អង្គ សុទ្ធតែជាព្រះពោធិសត្វទាំងអស់ សូម្បីតែព្រះសំរឹទ្ធក៏ដូចគ្នាដែរ មិនសូវឃើញមានព្រះពុទ្ធរូបឃើញតែរូបព្រះពោធិសត្វជាច្រើន ព្រោះដូច្នោះព្រះពុទ្ធរូបក្នុងសម័យនេះទើបមានតិច ។ វិធីសង្កេតកំមានរបៀបដូចគ្នា គឺត្រូវមើលព្រះអង្គធំជាគំរូ តែថារកបានដោយតិបាកបន្តិច, ឯអង្គសំខាន់ទីអង្គធំដែលច្រើនជាបែបសិក្សាបានន្ទោះ មានន្ទៅវត្តបវរនិវេសន៍ ១ អង្គ ហៅថាព្រះពុទ្ធវៃរ៉ោចនាស (វៃរ៉ោចនាភ) ជាព្រះអង្គធំ, ក្រៅពីន្ទោះមានន្ទៅពិពិធកណ្ឌនៃជាតិ ជារបស់សម្តេចព្រះចូឡចមក្លៅ ដែលសម្តេចក្រុមពញាតម្រង់ពជានុភាព ស្តេចទៅប្រទះឃើញន្ទៅវត្តមហាជាតុស្រុកដៃយា (ដៃយ៉ា) ហើយយកមកថ្វាយសម្តេចព្រះចូឡចមក្លៅ ឥឡូវនេះគេយកទៅទុកន្ទៅពិពិធកណ្ឌស្ថាន ។ ព្រះពុទ្ធរូបដែលពួកអស់លោកនាំមកប្រឡងនេះមាន

ពីរអង្គ ដែលទំនងជាប្រើជាគំរូសម្រាប់សិក្សាប៉ែកខាងព្រះសម្ម័យស្រីវិជ័យ ។ ការសិក្សានោះទៀតក៏មានរបៀបដូចគ្នា គ្រូរំលេចគ្រឿងប្រដាប់ឲ្យដឹងថា គេធ្វើផ្ទះតែវដូចម្តេច ធ្វើទ្រណ្ឌាសោម ធ្វើព្រះហស្ត ធ្វើព្រះពស្ត្រ ធ្វើត្របកឈូកដូចម្តេច មានវិធីសិក្សាដូចគ្នាទាំងអស់ ។

តពីសម្ម័យស្រីវិជ័យក៏មកដល់សម្ម័យលពបុរី ។ សម្ម័យលពបុរីនេះជាសម្ម័យដែលខ្មែរ (វ៉ៃរ) មានអំណាច ចូលមកគ្រប់គ្រងប្រទេសនេះតាំងរាជធានីរបស់ព្រះចក្រពត្តិ បញ្ជាការគ្រប់គ្រងទៅលពបុរី ព្រោះដូច្នោះទើបហៅព្រះទាមព្រះពុទ្ធរូបសម្ម័យនោះថា ព្រះសម្ម័យលពបុរីតាមឈ្មោះរាជធានី ជាស្នាដៃគ្រូលជាងខ្មែរធ្វើក្នុងប្រទេសនេះ ។ ព្រះពុទ្ធរូបក្នុងសម្ម័យនោះមានច្រើនយ៉ាង មានគាំងធ្វើដោយសំលេះធ្វើដោយលោហៈ គំរូដែលយើងត្រូវសិក្សា គ្រូរំលេចព្រះពុទ្ធរូបអង្គធំៗ ក្នុងសម្ម័យនោះ ដែលប្រើជាគំរូសម្រាប់សិក្សាចូលយ៉ាងល្អ មានទៅក្នុងពិព័ធកណ្ឌព្រះពុទ្ធរូបសម្រាប់វត្តនេះគំរូច្រើន ហើយទៅពិព័ធកណ្ឌនៃជាតិគំរូច្រើន ហើយដែលយកមកបង្ហាញទៅទីនេះក៏មានច្រើនអង្គដែរ ជាព្រះពុទ្ធរូបដែលប្រើជាគំរូសម្រាប់សិក្សាបាន ។ យើងខ្ញុំអាចអធិប្បាយបានយ៉ាងល្អថាព្រះពុទ្ធរូបសម្ម័យនោះ មានលក្ខណៈដូច្នោះ ។ តែយើញថាមិនសូវមានប្រយោជន៍ព្រោះអស់លោកគង់តែចាំមិនបាន ។ ការសិក្សាដែលឲ្យចាំបានល្អនោះ គ្រូរំលេចមើលខ្លួនឯងគឺគ្រូរំលេចធ្វើឲ្យដល់ថ្នាក់ប្រតិបត្តិ បើយើងរៀនត្រឹមតែថ្នាក់បរិយត្តិ មិនសូវចាំបានច្បាស់ដទេ ។

តពីនោះមក ក៏មកដល់សម្ម័យជ្វៀងសែន គឺជាសម្ម័យដែលថៃ

ចានចូលមកតាំងគោលចារឹកនៅក្នុងប្រទេសថៃនេះ ហើយចានតាំងរាជធានីនៅក្រុងជៀងសែន ហើយចានផ្ទាស់មកនៅជៀងកាំយ តមកទៀតផ្ទាស់មកនៅជៀងម៉ៃដោយលំដាប់ ។ ព្រះពុទ្ធរូបសម័យនេះហៅថាសម័យជៀងសែន, សម័យជៀងសែននេះចាត់ជាពីរយុគ គឺយុគមុនពេលដែលថៃចុះមកតាំងគោលចារឹកនៅក្នុងប្រទេសនេះ កន្លងពុទ្ធសករាជ ១៦០០ រហូតដល់សាងក្រុងជៀងម៉ៃ ពាក់ជា ១ យុគគឺយុគដំបូង ។ យុគដំបូងនេះគេចានបែបផែនព្រះពុទ្ធរូបមកពីប្រទេសឥណ្ឌាដែរ គឺបែបយ៉ាងព្រះពុទ្ធរូបឥណ្ឌាសម័យរាជវង្សគុប្ត: ។ លក្ខណៈព្រះពុទ្ធរូបសម័យជៀងសែនយុគដំបូង គឺមានសង្ឃាដិខ្ចី មានព្រះនលាដលោមខ្ពស់មក ឬដូចផ្កាឈូកក្រពុំ បល្ល័ង្កធ្វើជាត្របកឈូកសឹមដោយស្រទាប់តូច ។ ទឹងមានកេសរដូចជាបែបរាជវង្សគុប្ត: ក្រៅពីលំអដែលផ្ទាស់ប្តូរទៅតាមលំអបែបថៃ ។ សំពាក់យុគក្រោយនៃជៀងសែននោះពាក់តាំងពីសាងក្រុងជៀងម៉ៃស្រេចហើយតមក គេយកតាមបែបព្រះពុទ្ធរូបសម័យសុខោទ័យដែលចានតែបែរទៅតាមបែបលង្កាវង្ស ក្នុងកាលដែលចានបែបលង្កាវង្សមក តែទៅមានលក្ខណៈដូចពីដើមច្រើនយ៉ាងដូចត្របកឈូកគង់ទៅជាដែល ព្រះកន្ទុលគង់ទៅជាដែល តែវែងបន្តិចស្រដៀងព្រះពុទ្ធរូបសុខោទ័យ ។

ក្នុងសម័យជាមួយនឹងសម័យជៀងសែនយុគនេះ មានព្រះពុទ្ធរូប១ត្រកូលទៀតដែលចានបួបបែរទៅខាងខេត្តប៉ក្បាតៃ (ខេត្តថៃគាតក្រោម) ដូចខេត្តនគរស្រីធម្មាជ (ស៊ីធម្មាត) មានព្រះពុទ្ធរូប ១ ត្រកូលហៅថា

"ព្រះខេត្តនគរស្រែធម្មាជ" ឬ "ព្រះខេត្តនគរ" គឺព្រះដែលធ្វើនៅក្នុងខេត្តនគរនោះឯង សឹងបានបែបផែនមកតាមជាវង្សចាស់ដែរ ។ លក្ខណៈព្រះពុទ្ធរូបដូចបែបព្រះពាជាវង្សចាស់ មានរឿងរ៉ាវតាមប្រវត្តិសាស្ត្រថា ក្នុងសម័យដែលពាជាវង្សចាស់ចំរើនរុងរឿងក្នុងស្រុកតន្លៀនោះ មានមហាវិទ្យាល័យពែកមាន់ព្រះពុទ្ធសាសនានៅស្រុកនាលន្ទា មានព្រះសង្ឃតិចិសមាន់កើតនៅសិក្សាច្រើនរូប មានព្រះសង្ឃនៅស្រុកកូមា ស្រុកមន ទឹងស្រុកថៃជាដើម ហើយនាំយកបែបផែនពុទ្ធចេតិយមកសាងទុកបូជានៅស្រុករបស់ខ្លួន ព្រោះដូច្នោះទើបកើតបែបផែនព្រះពុទ្ធរូបជឿងសែន ទឹងព្រះពុទ្ធរូបខេត្តនគរឡើង ។ ព្រះខេត្តនគរជាព្រះពុទ្ធរូបដែលធ្វើតាមអត្តិតលនៃព្រះអណ្តៀសម័យពាជាវង្សចាស់ ដូចព្រះជឿងសែនយុគដំបូង តែជាស្នាដៃថៃភាគក្រោម ផ្សេងផ្សំទឹងបែបខ្មែរបន្តិចបន្តួច ចំណែកព្រះជឿងសែនយុគដំបូងជាស្នាដៃថៃភាគលើដោយពិត មិនបានធ្វើផ្សេងផ្សំទឹងបែបណាទេ ។

តអំពីនោះមកក៏ដល់សម័យសុខោទ័យ ជាសម័យដែលពាជាវង្សព្រះរួង (ពញាក្រែង) គ្រប់គ្រងក្រុងសុខោទ័យ ប្រហែលក្នុង ព.ស ១៨០០ ក្នុងសម័យនេះពួកថៃចំរើនរុងរឿងណាស់ ក្នុងការកសាងព្រះពុទ្ធរូបព្រោះហេតុដែលយើងបានទទួលបែបផែនមកពីលង្កា យកមកផ្សេងផ្សំកែប្រែតំរូវតាមលក្ខណៈព្រះពុទ្ធរូបរបស់យើង គឺក្នុងសម័យមុនៗនោះព្រះពុទ្ធរូបរបស់ថៃមានទ្រង់ទ្រាយដូចបែបជឿងសែនយុគដំបូង តែបែបសុខោទ័យជាបែបដែលធ្វើផ្សេងទឹងគំនិតរបស់លង្កា គឺធ្វើសង្ឃាដិវែង សមាធិភាព

ទុណ្ណាលោមវែង ។ ក្នុងសម័យនេះព្រះកត្តិមាន ៣ បែប, បែបដំបូងគេ
ធ្វើព្រះកត្តិមូលស្រដៀងព្រះពុទ្ធរូបលង្កា ដូចព្រះអង្គារសដែលមាននៅ
កន្លែងវិហារវត្តស្រះកេស (ស្រះកែត) មិនសូវមានសាយភាយច្រើនណាស់
ទេ ; បែបទី ២ គេធ្វើព្រះសិរខាន់លើធំ ហើយរៀបចុះតូចមក ដូចព្រះរូង
នៅខនរបឋម ទំនងព្រះសុរភីពុទ្ធពុម្មនៅវត្តបរិនាយក បែបនេះមានសាយ
ភាយខ្លះៗ ; បែបទី ៣ ជាបែបល្អផុតលេខ ដែលហៅថាព្រះពុទ្ធរូប
ខេវតាសាន តឺព្រះពុទ្ធជិនពាជ ព្រះពុទ្ធជិនសីហ៍ ឬជិនស្រី ។ ព្រះពុទ្ធរូប
យុគនេះពាក់ថាជាព្រះពុទ្ធរូបដែលល្អផុតលេខ ក្នុងសម័យសុខោទ័យ តាល់
តែជាហេតុឲ្យសម្តេចព្រះចូលឆមក្តៅ កាលកំពុងខ្ចង់សាងវត្តបញ្ចម-
បតិត្រនេះ ខ្ចង់សែងរកព្រះពុទ្ធរូបដែលត្រឹមត្រូវតាមលក្ខណៈ គ្រប់ខេត្ត
ដើម្បីនិមន្តន៍មកធ្វើជាព្រះជីវិតក្នុងព្រះវិហារ មិនឃើញមានអង្គឯណាក្នុង
អាណាចក្រថៃ ដែលមានលក្ខណៈល្អដូចព្រះពុទ្ធជិនពាជ តែព្រះពុទ្ធជិន-
ពាជនៅខែត្រពិស្ណុលោក ជាវត្ថុដែលប្រជាជនគោរពកាន់តាមពេញទាំង
ខែត្រទៅហើយ ទំនងនិមន្តន៍មកធ្វើជាព្រះជីវិតំនាស់ចាស់ចិត្ត
របស់ប្រជារាស្ត្រ ទើបខ្ចង់ឲ្យសិតចំឡងមក ដើម្បីឲ្យប្រជាជននៅក្រុង
ទេព (ចាងកក) ទំនងខែត្រជិតខាងបានឧបត្ថម្ភារបូជាគ្រប់ៗ គ្នា ។

តមកពីសម័យសុខោទ័យ ក៏ដល់មកសម័យក្រុងស្រីអយុធ្យា ។
សម័យស្រីអយុធ្យាក៏មានពីរយុគដែរ តឺយុគដំបូងគេហៅថាព្រះពុទ្ធរូប
ស្រុកអ៊ូថង ឬស្រុកសង (សរវត៌) គេធ្វើដូចចង្កាមនុស្ស ព្រះកត្តិ
ខ្លះមានស្រដៀងនឹងព្រះខ្មែរ. ដែលពួកអ្នកលេងព្រះពុទ្ធរូប គេហៅថា

ព្រះខ្មែរចង្អាមនុស្ស តែទុសតីព្រះខ្មែរច្រើនយ៉ាង ដូចព្រះកេសា ចល័ត្ត តែបកលូកជាដើម ជាបែបបៃ គាន់តែព្រះកក្តូលាយស្រដៀងនឹងព្រះខ្មែរប៉ុណ្ណោះ ចាំងនេះកំព្រោះជាព្រះពុទ្ធរូបធ្វើដោយស្នាដៃថៃ ផ្សំនឹងស្នាដៃខ្មែរ ។ តាមពិតសម័យនេះជាសម័យជាមួយគ្នានឹងសម័យសុខោទ័យ តែជាស្នាដៃថៃភាគក្រោម, សុខោទ័យជាស្នាដៃថៃភាគលើ។ ព្រះដែលសាងមុនការស្ថាបនាក្រុងស្រីអយុធ្យាមានច្រើនអង្គ ដូចព្រះធំនៅវត្តព្នំញាដើង (ផ្ទះធំង) នឹងព្រះពុទ្ធរូបនៅវត្តធម្មិកពជាដើមនោះកំជាព្រះអ៊ូថង យ៉ាងពិតប្រាកដដែរ ។ វត្តព្នំញាដើងនេះសាងមុនក្រុងស្រីអយុធ្យាដល់ ២៦ ឆ្នាំ តមកគ្រាយរជ្ជកាលព្រះបរមរៃលោកនាថ គឺសម័យព្រះពាមជិបតីទី ២ ជាព្រះសម័យអយុធ្យាធម្មតា ឬព្រះសម័យអយុធ្យាជាន់ក្រោយ ។ យើងមិនចាប់មើលដទៃឡើយ មើលតែព្រះមង្គលបពិត្រក៏ចានហើយព្រះនោះជាព្រះបែបសុខោទ័យធ្វើក្នុងសម័យអយុធ្យា។ ខនេះព្រោះហេតុដូចម្តេច? ព្រោះហេតុថាព្រះពាមជិបតីទី ២ ជាឧបាសកខ្ជាប់ខ្ជួនក្នុងខេត្តពិស្ណុលោកជាមុន ចានរៀនបែបដែនកក្នុងការគ្រប់គ្រងក្នុងផ្លូវព្រះពុទ្ធសាសនា សូម្បីបែបព្រះចេតិយសម័យសុខោទ័យ លោកក៏យកមកសាងឡើងជាថ្មី ដូចព្រះចេតិយវត្តព្រះស្រីសរតេ្ន (ផ្ទះស៊ីសំនផេក) ជាដើម ព្រោះដូច្នោះព្រះពុទ្ធរូបអយុធ្យាជាន់ក្រោយ គឺព្រះពុទ្ធរូបដែលធ្វើតាមបែបសុខោទ័យនោះឯង ។

តពីសម័យអយុធ្យា កំមកដល់សម័យក្រុងធនបុរី ។ សម័យនេះមិនមានព្រះពុទ្ធរូបដែលសម្រេចពីតកូលជាង់ណាឡើង ព្រោះថា

សម័យធនបុរី ជាពេលដែលយើងត្រូវធ្វើចំបាំងកាន់ជល់មិនមានចំនេះ ចាំងជាសម័យដែលមានអាយុពេលដ៏ខ្លី គ្មានពេលនឹងសាងពុទ្ធចេតិយ បានឡើង ចាំងព្រះពុទ្ធរូបក៏មិនច្បាកជាថាបានសាងឡើងដែរ ។

សម័យតនកោសិន្ទ្រ រជ្ជកាលទី ១ មិនបានសាងព្រះពុទ្ធរូបសំខាន់ដែលមានអង្គធំៗ សោះ តែបានឲ្យទៅនិមន្តន៍នាំយកមកពីខេត្តក្រៅជាច្រើន ដូចព្រះស្រីសាក្យមុនី វត្តសុទ័សន៍ (សុថ័ត) ឲ្យនិមន្តន៍នាំយកមកពីខេត្តសុខោទ័យ ក្រៅអំពីនោះមានជាង ១ តាន់អង្គទៀត ដែលបានឲ្យនិមន្តន៍នាំមកពីខេត្តក្រៅ យកមកដំកល់ទុកនៅក្នុងវិហារវត្តពោធិ៍ទឹងវត្តដទៃទៀត ចាំងបានព្រះពុទ្ធរូបមកក្រុមព្រះពុទ្ធរូបវរៈ យកទៅដំកល់ទុកនៅវត្តមហាធាតុកំរែច្រើន ចាំងនេះជាព្រះពុទ្ធរូបដែលឲ្យនិមន្តន៍មកពីខែត្រលើចាំងអស់ ។ ក្នុងរជ្ជកាលទី ១ នេះស្រុកខេមរៈក៏នៅមិនទាន់សូវរៀបរយ នៅមានចំបាំងកាន់ជល់ជាច្រើនណាស់ដែរ តែហេតុដែលមិនបានសាងព្រះដ៏វិសេសធំៗ នោះ ប្រហែលជាមកពីបានឲ្យនិមន្តព្រះពុទ្ធរូបចាស់ៗ មកពីខែត្រក្រៅច្រើនគ្រប់គ្រាន់ណាស់ហើយទើបមិនបានសាងព្រះដ៏វិសេស ឃើញច្បាកជាតែបានសាងព្រះគន្ធាររដ្ឋ ទុកសំរាប់ធ្វើព្រះពុទ្ធពិធីច្រត់ព្រះនង្គ័ល និងពិធីសូមភ្លៀង ១ អង្គ ដែលនៅក្នុងហោព្រះគន្ធារៈនាវត្តព្រះតែវត្តក្នុងសម័យនេះ តែបែបនេះមិនបានផ្សាយទូទៅដល់បណ្តាក្រុងដទៃៗឡើយ ។ ព្រះដ៏វិសេសធំ ១ អង្គទៀតដែលច្បាកជាសាងក្នុងរជ្ជកាលទី ១ គឺព្រះដ៏វិសេនៅវត្តមហាធាតុ ព្រមទាំង

រូបព្រះសារីក ដែលក្រុមព្រះពជកំឯបវរខេត្តឲ្យសាងឡើង ជាព្រះពុទ្ធរូបដែលល្អគ្រាន់បើដែរ ខុកជាបែបផែនសម័យរតនកោសិន្ទ្រូបាន ។

ដល់មករជ្ជកាលទី ២ ព្រះបាទសម្តេចព្រះណាំង*ក្សៅ កាលទ្រង់នៅជាព្រះអង្គម្ចាស់បានទ្រង់សាងវត្តពជនរស (ព័តនរ៉ុត) ឧទ្ទិសថ្វាយព្រះដីរឡើង កាប់ថាជាព្រះស្ថិតក្នុងសម័យរតនកោសិន្ទ្រដ៏ពិតប្រាកដ តែលក្ខណៈក៏នៅតែជាព្រះសម័យអយុធ្យាផ្សំនឹងបែបសុខោទ័យដដែល តែធ្លើសរសៃព្រះកេសល្អិតធ្វាព្រះនលាដ៍ស្មើងឡើងបន្តិចប៉ុណ្ណោះ ។

ដល់មករជ្ជកាលទី ៣ បានទ្រង់សាងច្រើនអង្គ ដូចព្រះជីរនៅក្នុងវិហារវត្តសុទស្សន៍ ជាព្រះស្ថិតដែលធំបំផុតក្នុងសម័យរតនកោសិន្ទ្រ ឧទ្ទិនៅក្នុងវិហារវត្តពជន្តា (ព័ត-ណាត់ ជា) វត្តធ្នឹមព្រះកៀរ (ធ្នឹមព្រះកៀត) តែមានបែបដូចគ្នា គឺជាបែបអយុធ្យាផ្សំនឹងបែបសុខោទ័យ ដូចពោលមកហើយ ។

ដល់មករជ្ជកាលទី ៤ ទ្រង់ជាអ្នកប្រាជ្ញ បានទ្រង់ពិនិត្យលក្ខណៈព្រះពុទ្ធរូបជាច្រើន ទ្រង់គិតសាងព្រះពុទ្ធរូបខុកជាតំរូ ។ ក្នុងរឿងព្រះមោលីនោះ ព្រះអង្គបានត្រួតត្រាមើលក្នុងព្រះត្រៃបិដកចាំឯអស់ មិនយើញប្រាកដថា ព្រះពុទ្ធអង្គទ្រង់មានព្រះសិរដូច្នោះឡើយ ដែលជារបស់ទុសធម្មតា ទ្រង់គិតឲ្យលែងធ្វើព្រះមោលី ឲ្យធ្វើព្រះសិរមូលទៅវិញ ហើយធ្វើព្រះនលាដ៍លោមនៅកណ្តាលព្រះសិរ ដូចព្រះនិរន្តរកាយដែលបានបែបខុកនៅវត្តជម្ពុត្តកនិកាយខ្លះ ឧទ្ទិនព្រះសម្ពុទ្ធពណ្ណ

(សម្ពុទ្ធជាន់ទី) ដែលប្រតិស្ឋានទៅមុខបុស្សក្រព្រៃកែវមកគត ទាំងនេះ ជាគំរូបស់ព្រះអង្គ ដែលជាព្រះពុទ្ធរូបគ្មានព្រះមោលី ។

កាលសម្តេចព្រះបូព្វចមក្តៅ ទ្រង់សាងវត្តពាជបពិត្រនិងវត្តនិវេសន៍ធម្មប្រវត្តិ ឋានទ្រង់សាងព្រះពុទ្ធរូបមិនមានព្រះមោលីពីរអង្គទៀត, តមកព្រះអង្គម្ចាស់ប្រទិត ជាជាងហួន ក្រាបទូលសេចក្តីពិតដល់សម្តេចព្រះបូព្វចមក្តៅថា ព្រះមោលីនោះជារបស់សំខាន់ចំផុត ហើយមានមនុស្សពាប់អានជាងពាន់ឆ្នាំមកហើយ បើតែប្រែ មិនមានអ្នកណាយល់ថាល្អឆ្ងល់ឡើយ ។ ព្រោះដូច្នោះរឿងព្រះមោលីនេះ សូម្បីរជ្ជកាលទី ៤ ទ្រង់តិតលុបចោល ដោយទ្រង់យល់ថាខុសធម្មតា តែក៏មិនសម្រេច ព្រោះហេតុថាមានមនុស្សពាប់អានជាងពាន់ឆ្នាំមកហើយ ជាការកែមិនកើត បើមានអ្នកណាមួយលុបព្រះមោលីចោល គង់តែគ្មានគេស្រឡាញ់ មិនល្អ គ្មានទ្រង់ទ្រាយ ទាំងគ្មានគ្រឿងទទួលសម្រស់ គឺថាទៅលើសរសៃព្រះកេស តួរនឹងមានអ្វីមួយទទួលព្រះណ្ហាលោម បើដូចរាងចាញ្ជ្រៀនត្រូវមានត្បូងទទួលលំអ បើកាត់ព្រះមោលីចេញក៏គ្មានគ្រឿងទទួលលំអ ជាការមានខំនាស់ច្រើនយ៉ាង ព្រោះដូច្នោះក្រៅពីព្រះដំរីនៅវត្តពាជបពិត្រនិងវត្តនិវេសន៍ធម្មប្រវត្តិហើយ គ្មានអ្នកណាសាងព្រះដំរីដែលគ្មានមោលីនៅកន្លែងណាទៀតឡើយ ។

រជ្ជកាលទី ៥ ឋានទ្រង់សាងព្រះពុទ្ធជីនពាជចំឡង ដែលគេឋានដឹងខ្លះ ដូចពោលមកហើយ ។

ដល់មករជ្ជកាលទី ៦ ឋានទ្រង់សាងព្រះសៃយាវត្តពាជាធិវាស (ក៏.

ធាជិវ័ត) មានព្រះមោលិស្ស ណាស់ គួរគាន់យកជាគំរូសម័យវតនកោ-
សិន្ទ្រូបាន តែមិនមានសាយការយូរទៅ ព្រោះថាសម័យវតនកោសិន្ទ្រូ
នេះគ្មានបែប ដោយចំពោះមានតែបែបផ្សំពីសម័យមុនៗមក ។ ព្រះ
បែបក្រុងវតនកោសិន្ទ្រូនៅវត្តពាជនារស វត្តសុទ័សន៍ វត្តធ្វើម ព្រះកៀតក៏ជា
ព្រះបែបអយុធ្យាទីដែរ បែបសុខោទ័យ, បែបដែលកើតឡើងចំពោះនៅក្រុង
វតនកោសិន្ទ្រូមិនមានឡើយ, ដែលគេនិយមសាងនៅក្នុងសម័យសព្វ-
ថ្ងៃនេះ ជាព្រះពុទ្ធរូបបែបផ្សំពាក់ដែរអស់ ។

រឿងព្រះពុទ្ធរូបដែលខ្ញុំបានពណ៌នាមកនេះ ជាការគោលយ៉ាង
សង្ខេបបំផុត, រឿងពាក់ដែរនេះសំរេចក្តីឲ្យឃើញថា ការសិក្សាព្រះពុទ្ធរូប
នោះ មិនមែនជាការងាយពេក រហូតដល់អ្នកមានបញ្ញាជាន់ខ្ពស់ធ្ងន់
ពាន់ជិនណាយ ហើយមិនមែនជារបស់ពិបាក រហូតដល់ជនធម្មតាសិក្សា
មិនកើត ជារឿងដែលគប្បីសិក្សាបានពាក់ដែរអស់គ្នា បើយើងរៀនតាល់តែ
មានសមត្ថភាព អាចមើលលក្ខណៈព្រះពុទ្ធរូបបាន ក៏ទីដែរតែងសាធ
សព្វជាកិរិយាភាពឡើង ដូចខ្ញុំបានពោលមកហើយនោះ ព្រោះហេតុ
នោះការដែលពុទ្ធសមាគមនៃប្រទេសថៃ បានរួបរួមគ្នាទីដែរគណៈដើម្បីវត្ត
បញ្ចមបពិត្រ ចាត់ឲ្យមានការបែបរូបព្រះពុទ្ធរូបឡើង ដើម្បីឲ្យឃើញថា
ព្រះពុទ្ធរូបអង្គណា ត្រឹមត្រូវតាមលក្ខណៈនៃមហាបុរិសលក្ខណសាស្ត្រ
ហើយមានលំអដូចម្តេច ជាបុពណវត្តជាន់ចាស់ជាដែរគេដូចម្តេច ដែលជា
ហេតុឲ្យអ្នកដែលបានមកទស្សនាមានសេចក្តីចូលចិត្ត ហើយបែរមុខមក
សិក្សាលក្ខណៈព្រះពុទ្ធរូប ដែលជាទីគោរពយ៉ាងកំពូល ក្នុងព្រះពុទ្ធ-

សាសនាយើងឲ្យរឹងរឹតតែច្រើនឡើង ជាងដែលមាននៅក្នុងឥឡូវនេះ ដែលជាហេតុឲ្យកើតកម្ចីឈ្មោះដល់ស្រុកទេស ហើយបើមានពួកនានាជាតិ គេមកសួរលោកថា ព្រះពុទ្ធរូបអង្គនេះគេសាងកន្លងក្នុងសម័យណា ជាព្រះពុទ្ធរូបជាន់ថាស់ឬជាន់ថ្មីដូចម្តេច លោកក៏ឆ្លើយតបថាយ៉ាងត្រឹមត្រូវ ជាការសំដែងឲ្យឃើញថា ពួកយើងអ្នកកាន់សាសនាព្រះពុទ្ធសាសនាមានសេចក្តីបេះដឹងក្នុងលក្ខណៈព្រះ ដែលជាទីគោរពរបស់យើងដែរព្រោះដូច្នោះ បើមានចំនួនអ្នកសិក្សាលក្ខណៈព្រះពុទ្ធរូបរឹងរឹតតែច្រើនឡើងហើយ ព្រះពាជបំណងរបស់សម្តេចព្រះចុឡាចមក្លៅ ដែលថាខ្ចង់សាងពិពិធកណ្ឌព្រះពុទ្ធរូបឡើងក្តី វត្តបំណងក្នុងការប្រឡងព្រះពុទ្ធរូបដែលពុទ្ធសមាគមទទឹងគណៈដើងវត្តបញ្ចូមបពិត្រចាត់ឲ្យមានឡើងក្តី ក៏ជាការសម្រេចបានយ៉ាងត្រឹមត្រូវពេញទំហឹង ។

ខ្ញុំព្រះករុណា ខ្ញុំសូមបញ្ចប់ជាឋកថារឿងព្រះពុទ្ធរូបត្រឹមតែប៉ុណ្ណេះ ហើយសូមអរគុណចំពោះព្រះសង្ឃសាមណេរទាំងឡាយ ព្រមទាំងសាធុជន ដែលបានមកអង្គុយស្តាប់ខ្ញុំព្រះករុណាខ្ញុំ អស់ថ្ងៃវេលាដ៏យូរនេះ ហើយសូមឲ្យអស់លោកទាំងឡាយ បានចំរើនក្នុងព្រះពុទ្ធសាសនាតរៀងទៅ ។

វិធីអប់រំជនជាតិខ្មែរ

លោក វ៉ាយ-ប៊ុក ក្រមការដើមខ្សែ លេខ ២ តែង

លោកយូរ-អ៊ុន កែសម្រួល

កម្ពុជាពីអតីតកោជនាហារ
ថ្លៅតអស្ចារ្យមានមួយកាត់ផៅឮរាបាន
ឥឡូវនេះហាសិបរៀលទើបចរបាន
បំបាត់ឃ្លានចិញ្ចឹមពោះមួយទិវា ។
មានជនខ្លះខំបន្តយន្តវិកោជន
ដោយគិតគន់ឲ្យសមល្មមនឹងទ្រព្យ
មិនហ៊ានចាយឲ្យច្រើនដ្រុលក្រែងវេទនា
ដោយថវិកាក្នុងផ្ទះខ្លួនខូចរបៀបរៀប ។
សូមជនខ្មែរប្រែគំនិតគិតជាថ្មី
ខំឃ្លាតខ្លីធ្វើការងារកុំបីខ្ជិល
ខំសូត្រសៀនសព្វរបៀនត្រមាំងដង្គិល
នូវមន្ទិលពន្លិលបាបអកុសល ។
ខំរកទ្រព្យជាប៉ារីយៈគាំងយប់ថ្ងៃ
កុំសំចៃកំឡាំងកាយខំខ្ជាយខ្ជល់

ធ្វើឲ្យមានភោគសម្បត្តិចាយទៅសល់
ហើយត្រូវផ្តល់សាងប្រទេសនឹងជួយជាតិ ។
ក្រៅពីព្រឹកនឹកគិតត្រប់ច្បាវច្ចការ
ស្រែចម្ការកុំបីធ្វេសទំនុកាត
រិះគិតគូរហើយប្រឹងធ្វើឲ្យដល់ភ្នាត
ខាត់សំអាតសាងវាស្ថានទឹងនិស្ស័យ ។
ការតាំងខ្លួនកូនលោកនេះមិនមែនងាយ
ដូចឪឪ្រាយត្រូវមានដៃគាបច្ច័យ
ធ្វើនាម៉ឺនឫតាណាជំពាលថ្ងៃ
ទើបបានថ្ងៃមានមុខស្មើនឹងគេពិត ។
កុំអាងខ្លួនធ្វើនាម៉ឺនហើយធ្វើងឹង
គួរលើកដៃគាន់បបរប៉ែលគាប់ដីស្អិត
ធ្វើស្លួនត្រូវគួរជាក់ជាំជំណាំពិត
ហើយពិនិត្យថែទាំមើលឲ្យសព្វគ្រប់ ។
ជាំមើមស្លាបេកអំពៅត្រាំដំឡូង
ជាំដើមជួងក្សរបង់ខុកជាមួប់
ជាំដកខឹមនឹងកុលាបផ្កាឈូយឈ្ងប់
ជាំឲ្យសព្វជាលំអជិតគ្រឹះហា ។
ជាំមេសត្រប់ជាំសណ្តែកពោតក្តាតខ្ញី
ចំណែកស្រីច្បាក់ខែប្តីខុកឲ្យជា

ត្រូវចិតចំជួញលក់ដូរបុលយកការ
ជួយផ្គងផ្គាំគ្នាទើបចំរើនសិរីគ្រប់ ។
អបាយមុខគួរតែលះបង់ឲ្យបាន
ដោយក្លាហានចំតស៊ូកុំសេពគប់
តាំងពាក្យទុកញ្ញាស្រាស្រីគ្រប់
ត្រូវកុំគប់គ្រប់តាំងល្បែងដេលំនាំក្រ ។
សព្វថ្ងៃនេះចំនិញថ្ងៃគួរឆេះចាយ
កុំឲ្យខ្ជាយតែចាយធំនឹងមិនល្អ
សូវឲ្យស្គុចកុំឲ្យជាប់គ្រាន់បន្ត
ការពារក្រែអនាគតទៅឯមុខ ។
បានមួយរៀលចាយជុំកាក់ខុកជុំកាក់
សន្សំជាក់ចូលកុងហ៊ឹបសន្សំខុក
ក្រែងមានកេគមានអាសន្នទៅខាងមុខ
គ្រាន់ដោះខ្លួនទើបបានពេញជាមនុស្សជាតិ ។
កូនចៅក្រោយកុំបណ្តោយទៅតាមខ្លួន
ត្រូវផ្តាច់ផ្តិលការមន្ទិលឲ្យចេញឃ្លាត
ត្រូវគោរពជាតិសាសនាឲ្យពេញខ្នាត
ទើបសមជាតិកើតជាមនុស្សជ្រុងជ្រះស្មោះ ។
ត្រូវគោរពព្រះមហាក្សត្រប្រមុខរដ្ឋ
ឲ្យហ្មត់ចត់ល្អពិត ។ អស់ពីពោះ

បំរើជាតំមាតុភូមិឲ្យផុតគ្រោះ
ឲ្យជាតិធ្លុះភ្លឺតែចះល្បីសព្វសាយ ។
គោរពផ្តដ៏ចំពោះតែធំព្រះតែតែ
កុំឲ្យភ្លាត់ប្រពឹត្តតាមច្បាប់ចរិយាយ
តប់សប្បុរសព្យាយាមធ្វើការខាំងឡាយ
ដោយខ្វល់ខ្វាយឲ្យសម្បូណិត្យធនធាន ។
ធម្មតាច្បាក់រត់រកមនុស្សនោះវាងាយ
មនុស្សខាំងឡាយរត់រកច្បាក់ពិបាកបាន
បើចង់សុខត្រូវលំបាកខ្សែយខ្លួនច្បាណ
បើចង់បានត្រូវតែបង់តាមការពិត ។
ស្រុកឥឡូវមិនមែនដូចពីមុន
ពីដើមពុនឥឡូវវែកគង់នៅគិត
ពីដើមដើរឥឡូវហើរហោះរត់មិត
ម្តេចជីវិតស្ទើរប្រពឹត្តទៅមិនបាន ។
តាមដែលពិតពិនិត្យមើលកាលទេសៈ
កង់រយៈឥឡូវនេះគួរជំងឺច្បាណ
ថាធ្វើអ្វីម្នាក់ឯ ឯងមិនចំណាន
មិនស្ទើបានឆឹងដែលធ្វើជាស្មាគម ។
ធ្វើសហការដោយរួបរួមចូលហ៊ុនគ្នា
ហ៊ុនទ្រព្យឲ្យការងារបានជារឹង

បើធ្វើស្រែត្រូវហ៊ុនស្រូវប្រមូលផុំ
ធ្វើចម្ការត្រូវហ៊ុនផុំគោតសណ្តែក ។
ធ្វើបែបនេះច្បាកដជាពួកនាយខុន
ទឹងមានស្កុនដោយមិនអាចទឹងបិទក្អែក
ធម្មោកយើងយកចំណេញជាអនេក
ព្រោះយើងបែកលែងទៅចុលខ្លួចងការ ។
ដោយយើងមានសហការណ៍ដែលស្មោគម
ជួយឧបត្ថម្ភកងពេលខាល់ផ្តល់ឲ្យណា
ឲ្យយើងយកមកប្រកបកិច្ចការងារ
ហើយយកការដោយយ៉ាងតិចជាចំផុត ។
ច្បាក់ការនោះលុះដល់ឆ្នាំដែលចែកគ្នា
យើងដែលជាសមាជិកជាក់ចំហុត
ទឹងត្រូវបានតាមភាគហ៊ុនដោយបរិសុទ្ធ
ជាផលធុតយើញខាន់ហាន់ទឹងនៅគ្រា ។
សូមសង្ឃឹមបែបនុ៎ះសុភាសិត
ជ័រចិត្តប្រជៅជនជាតិខ្មែរក
ទឹងទុកស្មៃត្រឹមប៉ុណ្ណេះលែងចរចា
ហើយសូមលាអស់បងប្អូនរួមជាតិអើយ ។

ជាតកមាតា

ព្រះឯហ ឌ្វើក-អ៊ែម៉រ វត្តឧណ្ណាលោម តែង

លោកចាប-ពិន កែសម្រួល

ហៃកូនពន្ធុកមាសម្តាយអើយ! ខ្លួននាងធំហើយគួរសិក្សា
វិជ្ជាផ្លូវធម៌ផ្លូវលោកា កុងវជ្ជខេមកណាមាសម្តាយ ។
ត្បិតមនុស្សវង្សវង្វៃតែវាណាស់ ចាំងតែងចាំងចាស់កល់រូបកាយ
ស្វែងរៀនវិជ្ជាផងចាំងព្យាយ សិក្សាសប្បាយមិនខ្ជិលខេ ។
អក្សរសាស្ត្រជាតិឃ្មាតខ្វៃរៀន កុំខ្ជាសកុំអៀនណាមាសមេ
រួចហើយកូនអើយចូរព្រះវេ អក្សរសាស្ត្រគេផងចាំងព្យាយ ។
ត្រូវកូនត្រិះរិះរៀនសិក្សា ឲ្យចេះច្រើនសាសន៍ណាមាសម្តាយ
ចេះហើយត្រូវកូនខំខ្វល់ខ្វាយ កាន់តាមតម្រាយក្បួននានា ។
អ្នកល្ងង់មិនចេះកងសម័យ លោកិយសព្វថ្ងៃប្រៀបដូចថា
តាមគេដិះជាន់ចំកន្ត្តា ហេតុតែអវិជ្ជាការល្ងង់ខ្លៅ ។
នេះគឺជាផលដែលផ្តល់ឲ្យ ខ្ចោចផ្សាស្តាយក្រោយហើយមួមៅ
មួចិត្តត្បិតអីខ្លួនឯងខ្លៅ ទឹកភ្នែកមិនបានពេលសិក្សា ។
ប្រសិនទៅពេលបុណ្យម្តង។ កុងស្រុកកូមិឆង្វាត្តភ៌
មានមនុស្សអ្នកចេះទៅត្រៀបត្រា អ្នកល្ងង់នោះណាមិនហ៊ានដិត ។
គេប្រើធ្វើការសព្វបែបយ៉ាង វែកទឹកដាក់អាង៎ពេញពាងពិត
ពុះអុសញើសហូរមួយជីវិត ព្រោះភ្លើលង្ងល់ល្ងីតចាំងនោះហើយ ។

រីឯអ្នកចេះកុងសម័យ លោកយសព្វថ្ងៃណាកូនអើយ ! ។
កើត្តីឈ្មោះមិនចេះសោបសូន្យឡើយ លាន់ឮគ្រប់ត្រើយឬទីហាន ។
អ្នកចេះផ្លូវធម៌ផ្លូវលោកា ទៅទីណា ។ សែនស្រួលជ្រាណា
ពេលឆ្លើមគ្គិលឬបុណ្យងាន អ្នកចេះតែងបានដឹងខ្លួនថា ។
គេលើកតម្កើងខ្លួនពេកក្រៃ លើសអ្នកដទៃផងណា ។
កន្ទេលថ្មីទៃងស្អាតភ្លឺថ្លា គេរៀបបូជាអ្នកចេះពិត ។
អ្នកល្ងង់ប៉ុន្មានគាល់ត្រៀបត្រា ខ្លះដាក់ពានស្មាជូនបណ្ឌិត
ខ្លះថ្វីដៃលើកតាមគំនិត គួរគិតស្តាប់តែមិនឲ្យខ្លះ ។
ប្រសិនបុណ្យពានក្រែវត្តក៏ មានអស់បណ្តាអ្នកធំខ្លះ
អ្នកចេះឥតខ្លាចអាចចូលប៉ះ ពាំងផុតស្រឡះការមើលងាយ ។
ព្រោះតែអ្នកធំគេស្គាល់ពិត យល់ជាបណ្ឌិតពង្រាជ្រុងជ្រាយ
ប្រើងប្រែងកប់អានអង្គែលកាយ រួសកយសប្បាយទៅកន្លា ។
ទឹកក្រចសូដាសាស៊ីសព្វ ជាតែកញ្ចប់ភ្ជុំនសោកា
តែប្រើនខ្លៃតឥតគណនា នេះផលថ្លៃណាមាសម្តាយ ! ។
ដែលគេប្រឹងរៀនពីក្មេងមក រៀនរិះរៀនកេរ្តិ៍ឆ្នាំជ្រាយ
ទើបគេធំឡើងស្រណុកកាយ ជ្រាជ្រ ។ ពាំងឡាយនិយមក្រៃ ។
ម៉ែឆ្ងាប់ជានព្វពាក្យអ្នកស្រុក តែងពោលលំអុកពាល់ ។ ថ្ងៃ
ប្រាប់កូនប្រឹងស្តាប់ណាថ្ងៃមថ្ងៃ រួចហើយគិតឆ្លៃឲ្យអស់អាថ៌ ។
អ្នកស្រុកខ្លះពោលឥតខ្លាសអៀន ថាឲ្យកូនរៀនធ្វើពជការ
ពាំងគេពាំងខ្ចីគ្រប់គ្រួសារ ឬស្រែចំការនឹងសល់ពិត ។

ព្រោះអីអ្នកស្រុកតាំងអស់គ្នា ឃុំវែងតែនានាបានគួរគិត
ឲ្យកូនសិក្សាវិជ្ជាពិត តើកូនណាគិតនៅធ្វើកស្ត្រ ។ ។
អ្នកពោលនេះហៅចេះតែថា ដោយឥតបញ្ញាមិនវែងឆ្ងាស
ពោលតាមតែខ្លួនឯកឃើញពាស នៃមាសថ្លៃម្លាយកុំដឿឡើយ ។
អ្នកប្រាជ្ញលោកខ្ពើមសំដីហ្នឹង លោកគិតជញ្ជឹងមិនកន្តើយ
ស្តប់ពាក្យអ្នកថាណាស់ទៅហើយ បើឮនឹងធ្វើយតបមិនខាន ។
អ្នករៀនចំណេះផងនានា រៀនសព្វវិជ្ជាតាំងប៉ុន្មាន
មិនមែនរៀនចេះសុទ្ធតែអាន រៀនហើយនឹងបានធ្វើពជការ ។
អ្នកស្រុកយល់ខុសច្រើនគ្នាណាស់ ម៉ែឪថាស់ៗ ច្រើនត្រូសារ
តើតនៅស្រុកវែងឆ្ងាយ ។ ផ្សារ ខ្លាចសល់ចំការស្រែឈើព្រៃ ។
ប្រទេសធំ ។ សព្វថ្ងៃនេះ គេចេះតែដឹងតែស៊ីវិល្ហៃ
ដោយគេបានរៀនច្រើនពេកក្រៃ គេតាន់សម័យមិនថយក្រោយ ។
ព្រោះគេបានរៀនទើបគេប្រាជ្ញ គេប្រឹងប្រសាចឥតបណ្តោយ
បណ្តែតអាត្មាឲ្យលង់ខ្លោយ អ្នកណាក៏ដោយក៏រៀនដែរ ។
គេរៀនចេះហើយគេច្រើបាប់ ខ្លះចាប់ធ្វើស្រែឥតគ្រូញាត់ផ្អែរ
ខ្លះធ្វើចំការខ្លះទៀតបែរ ធ្វើលក់ឲ្យខ្មែរទូវែងជាន់ ។
ខ្លះធ្វើកញ្ចក់ធ្វើវ៉ែនតា ខ្លះទៀតបិទស្រាល្អសំខាន់
ម៉ាកតែលគោញាក់ខ្មែរពាប់ពាន់ ចំញ៉ាំឥតលាន់ៗ មកយូរហើយ ។
ខ្លះទៀតធ្វើតធ្វើម៉ាស៊ីនដេរ គ្មានពេលចំនេះដើរលេងឡើយ
លុះធ្វើបានច្រើនណាកូនអើយ ! ខ្មែរមិនកន្តើយចំញ៉ាប្រើប្រាស់ ។

ចបដីកចបគាប់ពាប់រយលាន ចានផ្តិលដើងភានមានច្រែនណាស់
គាំចិតពួរថៅមានថ្នាំចាស់ ខ្មែរទិញច្រើច្រាស់ទាំងប្រុសស្រី ។
ខ្លះទៀតដំដែកធ្វើកំប៉ុង ជាក់ផ្លែឈើក្តង ឬជាក់ត្រី
ស្រុកខ្មែរមានដែរឥតខ្លះអ្វី ផ្លែឈើ ឬត្រីពេញពៃមិន ។
ប៉ុន្តែខ្មែរល្ងង់មិនចេះពិត ចានជាមិនគិតទាំគ្នាច្រើន
ធ្វើជាក់ច្រអប់ដូចគេហ្នឹង ខ្មែរពើនទិញគេគ្នានច្រើន ។
សំពត់កាតុ ឬខេសឯក លេចមកប្រែក ។ មិនខ្លះសោះ
ខ្មែរក្រែង ខ្មែរផ្សារខ្មែរគៀនគោះ ទិញស្មៀកគ្នានលោះរូបមួយណា ។
នេះហើយកូនអើយចូរកូនដឹង ! វត្តទាំងហ្នឹងលោកចាត់ថា
កើតមកអំពីយើងសិក្សា ទើបចេះធ្វើណាកូនមាសម្លាយ ! ។
រីខ្មែរយើងខ្លះយល់មិនត្រូវ ហៅយល់ខុសផ្លូវច្រើដ្រទាំងឡាយ
គួរតែប្រែចិត្តគិតឲ្យឆ្ងាយ គិតផ្លូវច្រើដ្រច្រើយកុំពាលា ។
កូនកើតមកហើយគួរឲ្យរៀន សិក្សារៀនផងនានា
គួរអ្វីឃាត់ឃាំងកំងកគ្នា ឲ្យរៀនវិជ្ជាទើបពេញខ្មែរ ! ។
ប្រសិនកូនរៀនមានចំណេះ កុំចេះតែយល់ថារៀនដែរ
រៀនបួចកូនអញមិនធ្វើស្រែ កូនអញរៀនដែរធ្វើកជការ ! ។
ដើម្បីនឹងបានបៀវត្សរ៍ចាយ អញជាឪពុកម្តាយបានដោយសារ
ព្រោះអីកូនបានធ្វើកជការ យើងមេត្រួសារថ្កើងមុខផង ។
ចំណែកវប្បម៉ែមិនយល់ច្បាះ ព្រោះយល់នេះខុសចំនង
ម៉ែមិនស្តាប់ពាក្យអ្នកផង ពោលខុសចំនងបែបនេះណា ។

លុះដល់កូនឯងបានរៀនទៅ ចូរពៅគិតតែខំសិក្សា
គោះបីម្តាយទំលែកម្តេចម្តា ចិត្តចង់ឲ្យបានចេះច្រើនកែក ។
លុះរៀនរួចហើយកូនកុំគិត ស្រែយើងមានតិតណា+មាសថ្លៃ
ប្រឹងធ្វើទិនម្តាយពាល់ៗថ្លៃ ធ្វើយកតំរៃចិញ្ចឹមប្អូណា ។
ដោយមើយល់ឮសក្តិកន្ធចិន្តា ថាការសិក្សាតាំងប៉ុន្មាន
នៃមនុស្សគ្រប់រូបណា+កល្យាណ រដ្ឋអាចឆ្លើងថ្កានមិនអន់ទេ ។
ថៃមិតាំងក្តើរឈ្មោះស្រុកយើងសាយ ខ្លះខ្លាយលាខំឮទៅដល់គេ
ព្រោះខ្មែរចេះច្រើនណា+មាសមេ ខ្មែរចេះដូចគេរដ្ឋនានា ។
ខ្មែររៀនតាំងប្រុសរៀនតាំងស្រី ខ្មែរចេះឃ្លាតខ្លីរៀនផ្ងារ
ខ្មែររៀនចេះហើយខ្មែរសុះសូ ខ្មែរកម្ពុជាច្រើនខ្វល់ខ្វាយ ។
ខ្មែរមិនគិតតែធ្វើលោភធំ ខ្មែរយល់ហាក់តុំសង្កត់កាយ
ខ្មែរធ្វើមិនមែនបោកកស្តែចាយ ខ្មែរធ្វើខ្វល់ខ្វាយបំរើកស្តែ ។
ខ្មែរខ្លះធ្វើស្រែចំការពិត ខ្មែរខ្លះគូរគិតការពេញពាស
ខ្មែរធ្វើនាហ៊ីនបំរើកស្តែ ខ្មែរដៀសក្បត់កស្តែការអកុសល ។
ខ្មែរបើកឲ្យខ្មែរតាំងប្រុសស្រី ខ្មែរបើកសេរីសិទ្ធិផ្តល់
ខ្មែរធ្វើឲ្យខ្មែរបាត់ងើងឆ្ងល់ ខ្មែរយល់នាហ៊ីនមិនកូតករ ។
ខ្មែរដឿថាខ្មែរអាណិតកស្តែ ខ្មែរធ្វើធំពាសមិនតែកវែ
ខ្មែរឃើញកស្តែខ្មែរវេទនាគរ ខ្មែរមិនសាទរខ្មែរធ្វើដឹង ។
ខ្មែរជួយយឺតយោងមិនរើសមុខ ខ្មែរឃើញខ្មែរពុកខ្មែរខំប្រឹង
ខ្មែរសួយជីវភាពខ្មែរតាំងហ៊ឹង ខ្មែរប្រឹងឲ្យកស្តែពុំដល់អីយ ! ។

លោក ស៊ុន - ហ៊ាន ប្រែរៀបរៀង

លោក យ៊ូរ - អ៊ុន ពិនិត្យកែសម្រួល

(តមក)

បិតាខ្ញុំគ្រែកអវតន៍ៈពក ចានគ្រាប់ខ្ញុំវិញថា:

- ឫទ្ធិស័ត្យ ! ឥឡូវនេះ ឯងធំហើយ, កូនស្រីរបស់លោកនង្គិជាក្មេងស្រីស្អាតចំណាប់ចំនួនណាស់ នេះតាមដែលក្មេកឥតុកសំឡឹងទៅឃើញ, បើកូនឯងឃើញដូចឥតុកដែរ ក៏ត្រូវតែជួយយកធ្យូរៈមើលថែទាំឲ្យល្អទៅ, ប្រសិនបើមានការអ្វីជាប់ជំពាក់ ត្រូវកូនឯងមកប្រឹក្សាឥតុកជាមុន; នែឫទ្ធិស័ត្យ ! វេលានេះល្ងាចណាស់ហើយ ឯងត្រូវប្រញាប់ទៅផ្ទះលោកនង្គិសិនចុះ ថ្ងៃក្រោយយើងគង់នឹងបានសេចក្តីស្និទ្ធស្នាលនឹងលោកនង្គិតែតែជិតជិតឡើងទៀត ។

បិតាឫទ្ធិស័ត្យមិនទាំងប៉ន់និយាយពាក្យនេះនឹងឫទ្ធិស័ត្យ មកអំពីមុនទេ ទើបតែថ្ងៃនេះជាគ្រាដំបូង ដែលលោកនិយាយលើកតំកើងស្រីក្រមុំហើយនឹងកូនខ្លួន, លោកអង្គុលខ្នងឫទ្ធិស័ត្យសំដែងសេចក្តីមេត្តា, ឫទ្ធិស័ត្យពេញចិត្តនឹងពាក្យបិតាណាស់ មានទឹកមុខក្រហមច្រាលដោយលោហិត ។

វេលាល្ងាចមួយ ឫទ្ធិស័ត្យឈរទៅមុខផ្ទះ ១ ខ្នងដែលតាំងទៅក្បែរមាត់ច្រាំងទន្លេត្រង់ផែនដីដែលព្រះពជាព្រះពជាចានដល់នង្គិអាមាត្យ នឹងគ្រួសារ, ឫទ្ធិស័ត្យសម្លឹងមើលទៅកន្លែងបរិវេណផ្ទះ ឃើញស្ត្រី ១ រូបឈរ

ថែរទ្ធនឲ្យ នាងកំពុងសម្លឹងពិចារណាដើមឈើ-ផ្កាឈើ ហាក់ដូចជាកំពុងមានទុក្ខ, ឫទ្ធិស័ត្យដើរទៅក្បែរបង្អួច ហៅឈ្មោះនាងដោយសំឡេងស្រាលៗថា: "កាញ្ចនា! កាញ្ចនា!" ។

នាងនោះថែរមុខមកខាងសម្លេងហៅ បើកភ្នែកធំ បន្ទឹមក្បត់បរិញ្ញាងឹតពេញចិត្តថា: "ឫទ្ធិស័ត្យ" រួចរត់មកវាស បើកទ្វារទទួលភ្ញៀវ ។

- សប្បាយណាស់ឬកាញ្ចនា! ថ្ងៃនេះខ្ញុំទៅសួរលោកឪពុកនាងនឹងបងនាង ហើយវិលមកជ្រាបដំណឹងឲ្យនាងជ្រាប, យើងទៅនិយាយគ្នាលេងខាងក្នុងបានឬទេ? ។

- អញ្ជើញបង! នាងកាញ្ចនាតបវិញ ហើយនាំឫទ្ធិស័ត្យចូលទៅខាងក្នុងហើយសួរថា: លោកឪពុកខ្ញុំនឹងបងខ្ញុំឲ្យដំណឹងមកខ្ញុំដូចម្តេចខ្លះ? ។

ឫទ្ធិស័ត្យកាលអង្គុយរៀបរយហើយ ទើបតបពាក្យសួររបស់នាងកាញ្ចនា គេមិនហ៊ានប្រាប់នាងត្រង់តាមសេចក្តីពិតថា បិតារបស់នាងមានសេចក្តីសោកសៅជាខ្លាំងដូច្នេះទេ ខ្លាចក្រែងនាងមានសេចក្តីទោមនស្ស ជាការបង្កឲ្យកើតទុក្ខដល់នាងថែមទៀត គេគ្រាន់តែប្រាប់ថា:

- លោកឪពុកនាងនឹងបងប្រុសនាងប្រើខ្ញុំឲ្យមកប្រាប់នាងថា មិនបានទទួលសេចក្តីលំបាកអ្វីប៉ុន្មានទេ ខុសប្លែកគ្នានៅឯផ្ទះបន្តិចបន្តួចប៉ុណ្ណោះ ឲ្យខ្ញុំដាស់តឿននាងរឿយៗថា សុំឲ្យនាងគិតថាជារឿងធម្មតា, មិនយូរប៉ុន្មានទេ លោកឪពុកនាងនឹងបងប្រុសនាងបានត្រឡប់មកទៅផ្ទះវិញដូចដើមហើយ ព្រោះមិនមានកំហុសអ្វីដែលនឹងឲ្យជាក់ទោសបាន

ទេ ខ្ញុំក្តីនណោ ។ ក្តីគំរើចំពោះសេចក្តីចរិសុទ្ធិ ព្រោះគុណសេចក្តីល្អ
របស់លោកឥតុកនាងទើងបង្ហាញនាងអំពីមុនទៅមានទម្ងន់ពន់ពេក" ។

កាញ្ចនាអង្គុយ ស្តាប់ឫទ្ធិស័ត្យនិយាយយ៉ាងស្ងប់ស្ងៀម ទឹកមុខ
ស្រងូត ធ្វើឲ្យឫទ្ធិស័ត្យនឹកពិការ, កាញ្ចនាជាស្ត្រីក្រមុំមានរូបល្អស្រស់
តែមិនស្ងួរបេះស្តីនិយាយ នាងបែរមកសម្លឹងឫទ្ធិស័ត្យដោយការសំដែង
អាការសៅសោក និយាយថា:

- "ឫទ្ធិស័ត្យ! ខ្ញុំអស់ពីពឹងហើយក្នុងពេលនេះ លោកឥតុកខ្ញុំទើង
បង្ហាញខ្ញុំដែលឲ្យខ្លួរសេចក្តីត្រជាក់ត្រជំដល់ខ្ញុំ ត្រូវមានគ្រោះកម្ម ខ្ញុំមិនដឹង
ទើងនិយាយដូចម្តេចឲ្យត្រូវឡើយ ឫទ្ធិស័ត្យ!" កាញ្ចនានិយាយបាន
ត្រឹមនេះ ទឹកភ្នែកនាងហូរស្រោចស្រប់ទៅលើថ្ពាល់ពាំងសងខាង ជ្រប
មុខទៅលើថ្នែរ សំដែងអាការកន្ទក់កន្ទេញ ។

ឫទ្ធិស័ត្យចង់លួងលោម ចង់ធ្វើដូចម្តេចឲ្យស្ត្រីក្រមុំឈប់យំ ទើម
និយាយថា: "កុំគោមនស្សភ្ញាំងពេក កាញ្ចនា! ត្រែងទៅជាឈឺចាប់,
ខ្ញុំនៅទើងមុខនាងពិតជាមនុស្សពេញលក្ខណៈ, ជឿខ្ញុំចុះ កាញ្ចនា!"
ឫទ្ធិស័ត្យអង្អែលស្មាស្ត្រីក្រមុំ ។

កាញ្ចនារៀបរាប់តទៅទៀតថា: "ឫទ្ធិស័ត្យ! កាញ៉ាស្ទើរតែទើង
ក្តួតហើយសព្វថ្ងៃនេះ, កាញ៉ាមិនមានម្តាយ, កាញ៉ាជាកូនកំព្រា, បើ
ម្តាយនៅ ម្តាយតង់ទើងកំដរស្រករកាញ៉ាបានយ៉ាងស្រួល តុន្តោ . . .
ឥតុកទើងបង្ហាលះចោលកាញ៉ាទៅហើយ" ។

ឫទ្ធិស័ត្យដឹងនាទីរបស់ខ្លួនយ៉ាងល្អ ថាគួរតែលួងលោមស្ត្រីក្រមុំឲ្យ

រសាយទុក្ខទៅខ្លះ ស្រួលជាជាងបណ្តោយឲ្យនៅតែកើតទុក្ខដូច្នេះ ទើប
លួងលោមថា:

-"កាញ្ចៅ! ខ្ញុំនៅទីណាមុខពិតជាមនុស្សគេញាលក្មេង, លោកឪពុក
នាងទីណាបងនាងបានអង្វរកឲ្យខ្ញុំមើលរក្សាសុខទុក្ខនាង ហើយខ្ញុំក៏ទទួល
ដោយសេចក្តីគ្រែកអរ, ប្រសិនបើមែរជាបងនាងទីណាលោកឪពុកនាង
ទីណាមិនអង្វរកខ្ញុំវិញទេ ក៏ការមើលសុខទុក្ខនាងគ្រែតែជានាទីរបស់ខ្ញុំដែរ,
កាញ្ចៅនាងគ្រែកអរឬទេ? ប្រាប់ខ្ញុំមកមើល កាញ្ចៅ!" ។

តែស្តីគ្រែម៉ុំមិនអាចរសាយទ្រូវសេចក្តីសោកបាន នាងនៅតែបន្ទុះ
នទៀលកន្ទុកកន្ទេញដែរមុខទៅលើបាតដៃតាំងគូ ។

-"ខ្ញុំសំគាល់ថា នាងរង្គៀសនឹងខ្ញុំ" ឫទ្ធិស័ត្យក្លែងធ្វើជាតូចចិត្ត
គ្រែកឈរឡើងហើយនិយាយថា: "បើនាងរង្គៀសនឹងខ្ញុំមែន ខ្ញុំលេង
មកជាន់ទីនេះទៀតហើយ" ។

-"ខ្ញុំមិនបានរង្គៀសនឹងបងទេ ឫទ្ធិស័ត្យ" កាញ្ចនាប្រញាប់
គ្រែកឈរឡើងតាម: "ពុទ្ធោ... កាញ្ចៅ គ្រាន់តែសៅសោកខ្លាំង
បន្តិចថ្ងៃនេះឯង ព្រោះអត់គ្រែចំពោះទុក្ខនេះច្រែនថ្ងៃមកហើយ" ។

-"បាទ! កាញ្ចៅ! ខ្ញុំដឹងហើយ នាងគួរធ្វើចិត្តឲ្យទំនួនល្អ ហើយ
គិតចំពោះតែរឿងដែលមានហេតុផល, នាងចូរដឹងថា កាលម៉ែបាងនាងទីណ
បងប្រុសនាងធ្វើមរណកាលទៅ តើនាងនឹងមានសេចក្តីសោកគ្រែមណា?
នេះគ្រាន់តែគ្រែវាឃុំឃាំងប៉ុណ្ណោះ ខ្ញុំសូមក៏ប់រងថា ព្រះពុទ្ធជាមិនដាក់ទោស
ធ្ងន់ប៉ុន្មានទេ ការដាក់ទោសទុក្ខនេះដោយច្រែនតំពូងឡាល់ប៉ុណ្ណោះ" ។

នាងកាញ្ចនាបានបង្ហោចន៍ទូរសេចក្តីសោកខ្លះ, ឫទ្ធិស័ត្យដឹងច្បាស់ថាស្តេក្រែមុំជឿសំដីខ្លួន, បន្ទាប់មកនាងក្រែមុំឆ្លើយតបមុខរកាយ បញ្ជូញក៏បាត់ផ្សាយពីពេញចិត្តនៃឫទ្ធិស័ត្យដែលមកជួបគ្នាជាមួយនង ។

ឫទ្ធិស័ត្យ យើញនាងក្រែមុំបង្ហោចន៍ទូរសេចក្តីសោកខ្លះហើយ គេទើបសួរមូលហេតុនាងក្រែឡប់ទៅផ្ទះគេវិញដោយប្តេជ្ញាចិត្តថា ខ្លឹងព្យាយាមមកសួរនាំកំដរស្រែករកែអផ្សុកនាងកាញ្ចនាឲ្យកាលថ្ងៃ ។

កាលដែលឫទ្ធិស័ត្យដើរចេញពីផ្ទះទៅ ដួងចិត្តស្តេក្រែមុំបាត់ផ្តើមស្រងូតស្រងាត់បន្តិចម្តងៗ, កាលផុតកន្លុយភ្នែកហើយ នាងក៏ធ្លាក់ទៅក្នុងសេចក្តីក្រៀមក្រំដូចដើមវិញ មិនមានអ្វីនឹងមកលួងលោមចិត្តនាងបានល្អស្មើនឹងបួលទៅសម្លឹងទៅក្នុងបន្ទប់ព្រះពុទ្ធរូបទេ កាញ្ចនាទើបដើរបួលទៅក្នុងបន្ទប់ព្រះពុទ្ធរូបដោយដំណើរទន់ភ្លន់ បាប់យកធូបទៀនអំពីពានមុខតុដុតបូជាព្រះពុទ្ធរូប ដោតទៀនធឹងធូបស្រេចហើយ នាងក្រាបថ្វាយបង្គំគ្រប់ប៉ាជង់ធើយមុខឡើងប្រណម្យដៃ ភ្នែកមើលត្រង់ទៅអង្គព្រះពុទ្ធរូបដោយពន្លឺទៀនដ៏រុងរឿង មានក្លិនធូបគ្រអូបឈ្មួយឈ្ងប់ កាញ្ចនាពិនិត្យសម្លឹងព្រះពុទ្ធរូប អធិដ្ឋានសូមបារមីព្រះ ខ្លឹងវត្តស័ក្តិសិទ្ធិគ្រប់គ្រងការពារផុតពុកនាងនឹងបងប្រុសនាងឲ្យរួចផុតចាកកំយុត្តកំយ ជាកិច្ចវត្តដែលនាងត្រូវធ្វើពាល់ត្រឹកល្ងាច, កាញ្ចនាសម្លឹងមើលដួងព្រះនេត្រព្រះពុទ្ធរូប ចិត្តនាងផ្តើមរំងុំងុំងឿង មានសេចក្តីសង្ឃឹមបន្តិចៗ ទឹកភ្នែកក៏រំងស្ងួតទៅ ស្រែចកិច្ចវត្តហើយ ត្រឡប់ចេញមកអំពីបន្ទប់ព្រះពុទ្ធរូប

នាងឃើញស្ត្រីជរាដែលនាងស្រឡាញ់គាត់ដូចម្តាយបង្កើត រៀបចំអាហារល្ងាចទុកឲ្យ ហើយនឹងថ្ងៃនាងឲ្យខួលថានអាហារទៀត ។

- "មកយាយ! ព័សាថ្ងៃយជាមួយនឹងខ្ញុំ" កាញ្ចនាចាញដៃគាត់អង្គុយចុះ រួចថ្លាប់ថា "យាយ! ថ្ងៃនេះ ឫទ្ធិស័ត្យមកសួរនាំខ្ញុំទៅទីនេះ គេថ្លាប់ថា បងសុរពលនឹងលោកឪពុកឲ្យគេមកថ្លាប់ដំណឹងនឹងផ្តាំផ្ញើកាញ្ចនាឲ្យគាត់ជួយមើលថែទាំនង" ។

- "ស្អួលហើយចៅ! ឫទ្ធិស័ត្យជាមនុស្សល្អណាស់ បើគេមិនរវល់ទៀសទេ យាយយល់ថានឹងពីងគេថានក្នុងគ្រាក, អើ! ចុះឪពុកចៅនឹងសុរពលនិយាយដូចម្តេចខ្លះហើយចៅ! យាយអាលោះអាល័យណាស់ យាយនឹកមើលទៅក៏ថាគ្រោះកម្មពិតៗ យាយដឹងចិត្តឪពុកនឹងបងប្អូនរបស់ចៅ ជាមនុស្សស្មោះត្រង់ណាស់ មិនថ្លាប់កោងកាចនឹងនរណាទេ យាយគិតទៅថាជាកម្មដែលបានធ្វើពុកពីជាតិមុនមកណាចៅ! បើចៅឯងឮយាមគិតយ៉ាងនេះក៏នឹងបានស្បើយខ្លួនបានខ្លះ" ។

ស្តីគ្រែមុខខួលថានអាហារបណ្តើរ ស្តាប់យាយនិយាយបណ្តើរ, ដែលជាពាក្យជាស់តឿនប្រៀនដែល ។ តាមវិស័យរបស់មនុស្សចាស់ គ្រប់ពេលដែលឃើញកាញ្ចនាសៅសោក ។

*
* * *

— ៥ —

កន្លងទៅមួយអាទិត្យជាពីរអាទិត្យ ពីរអាទិត្យជាបីអាទិត្យហើយ, ឧទ្ធិគាមាត្យនឹងបុត្រប្រុសនៅតែជាប់ឃុំក្នុងគុកនៅឡើយ ឫទ្ធិស័ត្យបាន

ធ្វើតាមពាក្យខ្លួនដែលខឹងលើសពីសុវត្ថិភាព គេទុស្សាហ៍ទៅសួរនាំទៅទីឃុំឃាំង ប្រាប់ដំណឹងភាន់ភ្លេចថា នាងកាញ្ចនាបានក្តីសុខដូចធម្មតាទេ លោកនន្ទិនឹងបុត្រប្រុសនឹកពេញចិត្តនឹងឫទ្ធិស័ត្យពន់ពេក, ទុកាសខ្ទុះលោកក៏សួរគេថា "មានសេចក្តីរង្កៀសនឹងកាញ្ចនាយ៉ាងណាខ្លះដែរឬទេ?" ។ ឫទ្ធិស័ត្យតបថា "មិនមានរង្កៀសនឹងនាងឡើយ" ។ លោកនន្ទិទើបនិយាយផ្តុកផ្តាក់ថែមទៀត ព្រោះគិតថា "មើលទៅព្រះពជ្រាមិនដោះលែងខ្លួនលោកឲ្យផុតទោសទេ, ឫទ្ធិស័ត្យមិនមានសេចក្តីរង្កៀសនឹងនាងកាញ្ចនាឡើយ ព្រោះភ្ជាប់បានទៅផ្ទះរបស់លោកញយ ។ តង់បានឃើញនូវសេចក្តីស្រឡូតស្រស់ផាត់នៃនាងកាញ្ចនា ដែលជាហេតុឲ្យកើតសេចក្តីអាណិតអាសូរ ដែលនឹងត្រូវមានមុនសេចក្តីស្រឡាញ់ច្រកបដោយសេចក្តីមេត្តា ក្នុងទីបំផុតឫទ្ធិស័ត្យគង់កើតសេចក្តីស្រឡាញ់នាងកាញ្ចនា តែគេផ្ចឹបខ្ទុកយ៉ាងស្ងាត់ៗ" ។ កាលលោកនន្ទិនិយាយផ្តុកផ្តាក់ដូច្នោះហើយ ឫទ្ធិស័ត្យក៏ញាយាមកេតុកាសសំដែងអាការៈឲ្យកាញ្ចនាដឹងតាមវិស័យរបស់មនុស្សដែលមានសេចក្តីស្រឡាញ់ជាដំបូង ។

(មានត)

កណ្ឌទី ២៤

ឧកញ៉ាវិបុលរាជសេនា ន្ង-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាំងរៃឆ្លាសប៉ើបាន១អាន
ធឹងបេះឧបាយកលបំណាន
ទាំងមាន១សន្តាន១ស្នេហាជាតិ ។

ខណៈកាលគួន១អ៊ូនាំបង់ថ្លៃទៅដល់គ្រែយម្ចាស់ ជាដែនស្រុកគឺជាវេបស់អ្នួនសៀវ គួន១អ៊ូដំរេះតាមវាថៅ មានវិតក្កព្រួយណាស់ជកដង្វើមធំគិតថា "យើងមកគ្រានេះវែកខំលាយគយល្បាតជាច្រើនអាទ្វីហើយសម្ងាប់នាយគាហានចូលស្ងាប់ដល់ ៦ នាក់ ព្រោះសេចក្តីខើសគាល់ប៉ើចូលមិនតិចារណាឲ្យល្អិតល្អន់ទេ ក៏ធឹងឃើញថាជាមនុស្សគាក្រក់គ្នានកតញ្ញូ" ខណៈលួតឡេកឃើញស៊ុនខៀនដំរេះមកដល់ គួន១អ៊ូមាន១សេចក្តីសោមន១ស្សណាស់សួរថា កាលអ្នកទៅជួបធឹងខ្ញុំឯស្រុកយើញាំនោះអ្នកថាធឹងទៅស៊ើបដំណឹងមកច្បាប់ខ្ញុំ ឥឡូវអ្នកបានដឹងជួបម្តេចខ្លះ? ។

ស៊ុនខៀនធ្វើយថា កាលគ្រោយដែលអ្នកលើកទ័ពត្រឡប់ទៅនោះ ខ្លៅផង, កុងតៅក៏លើកទ័ពត្រឡប់មកវាយយកស្រុកយីឡាំបាន ទើបឲ្យខ្ញុំកាន់សំបុត្រទៅដល់អ៊ូនសៀវថា ខ្ញុំសុំចុះចូលមកធ្វើភជការផង, អ៊ូនសៀវក៏ព្រម ហើយគិតប្រឹក្សាខ្ញុំតាហានតាំងពួនប៉ងខ្ញុំលើកទ័ពទៅវាយយកក្រុងហ៊ូតោ ប៉ុន្តែទីប្រឹក្សាតាំងពួនជជែកមិនចុះរុះគ្នា បានជាខ្ញុំរិះគិតខ្ញុំតីឲ្យលាអ៊ូនសៀវមកនៅស្រុកយីឡាំ ខ្ញុំបានគិតការកំចាត់ចូលចេញ អ៊ូនសៀវក៏ព្រមឲ្យខ្លៅតីមក ឥឡូវខ្លៅតីនៅបាវម្តក្រែងអ្នកដើរតម្រង់ទៅស្រុកគីជីវតែម្តង បានជាឲ្យខ្ញុំមកចាំស្តាក់ទាំផ្លូវទៅស្រុកយីឡាំដែលខ្លៅតីទៅនៅនោះវិញ ។

គួនអ៊ូបានស្តាប់ដូច្នោះក៏មានចិត្តសោមនស្សណាស់ នាំស៊ុនខៀនទៅឯវេបងវិញ ។ ស៊ុនខៀនតំនាប់ហើយសារសំតូរឿងដែលខ្លៅតីទៅនៅខ្ញុំអ៊ូនសៀវ ហើយអ៊ូនសៀវក្រោធថា គួនអ៊ូសម្លាប់ដាន់លៀងខ្ញុំង ប៉ុនធីវាជាតាហានឯក អ៊ូនសៀវប្រែងខ្ញុំសម្លាប់ខ្លៅតីសងសឹកវិញដល់ ២ គ្រាមកហើយ ខ្លៅតីចេះតែដោះស្រាយរួចខ្លួនបានគ្រប់គ្រា ទើបមិនបានអន្តរាយ រហូតមកដល់ឥឡូវនេះហានមកនៅស្រុកយីឡាំហើយ ។ នាងតាំង ២ បានស្តាប់រឿងក៏វាខ្លៅតីសព្វគ្រប់ កំនួនជ្រប់ជាក់មុខនឹកខ្លោចផ្សាចិត្តអាណិតខ្លៅតីពន់ប្រមាណ ខប់ពុំបានកំសោកាពិលាបទៅលើរថស្មើខ្ញុំងបានវិញ្ញាណ ។ គួនអ៊ូឲ្យស៊ុនខៀនទាំផ្លូវទៅស្រុកយីឡាំ, ខណៈកាលដើរផ្លូវទៅនោះ ខ្លួលបានឮសំឡេងមនុស្សស្រែកហ៊ោតី

ស្រែអង្កង គួនអ៊ូស្រែឡកៅឃើញហៃហ៊ុនលើកតាហានឆ្លងទន្លេហាន
ហោតាមមកជាច្រើន ឃើញហៃហ៊ុនដឹះសេះចេញមកខាងមុខតាហាន
ហើយស្រែកថា អាគួនអ៊ូឈប់សិន ។ គួនអ៊ូបានឮដូច្នោះក៏ឱយឈប់
ស៊ុនទៀនឱ្យចង្កឹបរថៅមុខ ខ្លួនគួនអ៊ូនៅរោកការពារពីក្រោយ ហើយ
គួនអ៊ូក៏បរសេះត្រឡប់មុខមកក្រោយឈរនៅនោះ លុះឃើញហៃហ៊ុន
ចូលមកជិត គួនអ៊ូក៏ស្រែកសួរថា ដែលអ្នកឃុំតាហានមកនេះ យើង
ឃើញថាស្មើសតាក្យមហាឧបរាជ ។ ហៃហ៊ុនឆ្លើយតបថា "ខ្លួនមិនមាន
សំបុត្រ មហាឧបរាជបើកគយឱ្យមក ហើយអាចហ៊ានហៃកំណាយគយ
ល្បាតកន្លងខ្វែត្រឱ្យមកជាច្រើនតំបន់ សម្ងាប់ចៅហ្វាយស្រុកទឹង
មេគយល្បាតស្លាប់ជាច្រើន ហើយមកដែមសម្ងាប់តាហានរបស់យើង
ដែលមកតាំងបន្ទាយកាំងខ័ណ្ឌនៅទីនេះស្លាប់ទៀត យើងនឹងចាប់ខ្លួនឯង
បញ្ជូនទៅឱ្យមហាឧបរាជធ្វើគោសជាឧទាហរណ៍" ថាហើយក៏បរសេះចូលទៅ
ទីឯចាប់ខ្លួនគួនអ៊ូ ។ ខុលសេះបំរើបំផាយមកស្រែកឃាត់ហៃហ៊ុនថា
"កុំឱ្យធ្វើអន្តរាយគួនអ៊ូឡើយ" ហើយហុចសំបុត្រនោះឱ្យហៃហ៊ុន
មើលរួចថា មហាឧបរាជមានចិត្តមេត្តា ដោយឃើញថាគួនអ៊ូនេះជា
មនុស្សមានសេចក្តីសត្យពិតត្រង់មានចំណងនឹងទៅរកឡាតី តែខ្លាច
ចៅហ្វាយស្រុកទឹងនាយគយល្បាតចាំងពួងឃាត់ខាំងខ្លួនពុក ទើបប្រើ
ខ្ញុំថាឱ្យកាន់សំបុត្រចេកគយមកឱ្យលោកបានដែរ ។

* * *

កណ្ឌទី ២៥

តាំងពីហែហួនុន តាមទៅប្លាំងប៊ីងនឹងចាប់ខ្លួនគួនអ៊ូ នៅព្រើយទន្លេហងហោ រហូតដល់អ៊ូនសៀវធ្វើសំបុត្រឲ្យតាន់ជិនយកទៅបញ្ចុះបញ្ចូលស៊ុនសឹកស្រុកកាំងតាំង ឲ្យលើកទ័ពមកប្លាំងនឹងបួច ។

ហែហួនុនក៏សួរបំរើសេះថា គួនអ៊ូគោរពកាចអាចហ៊ានកាប់ចំណាយតយល្បាតហើយសម្លាប់ចៅហ្វាយស្រុកនឹងនាយតយល្បាតជាច្រើនដំបន់នោះ មហាឧបរាជបានផ្ទាចដែរឬទេ ? ។ បំរើសេះឆ្លើយថា ដែលគួនអ៊ូធ្វើដូច្នេះមហាឧបរាជមិនបានផ្ទាបទេ ។ ហែហួនុនថា ដែលគួនអ៊ូធ្វើល្មើសខ្លាំងដូច្នេះ ហើយមហាឧបរាជមិនផ្ទាបនោះ ត្រូវតែយើងតាមចាប់ខ្លួនគួនអ៊ូឲ្យបាន ហើយបញ្ជូនទៅជាប្រញាប់ ។ គួនអ៊ូបានឮក៏ខឹងណាស់ឆ្លើយតទៅនឹងហែហួនុនថា "ហេតុដូចម្តេចបានជាខ្លួនមកបរាជូច្នេះ ខ្លួនស្មានថាយើងខ្លាចខ្លួនឬ ?" ហើយគួនអ៊ូក៏បរសេះចូលប្លាំងនឹងហែហួនុនបាន ១០ ភ្លេង ខ្លួលឃើញបំរើសេះម្នាក់កាន់ទង់សំពាប់ខ័ពចូលបក់ស្រែកឃាត់មកថា អ្នកតាំង ២ កុំអាលប្លាំងគ្នាសិន ។ ហែហួនុនក៏ឈប់ហើយសួរបំរើសេះនោះថា: មានសំបុត្រមហាឧបរាជផ្តាំឲ្យយើងចាប់ខ្លួនគួនអ៊ូបញ្ជូនទៅឬ ? ។ បំរើសេះថា មិនមែនទេ មហាឧបរាជខ្លាចក្រែងតយល្បាតតាមផ្លូវឃាត់តាំងគួនអ៊ូមិនឲ្យទៅ ទើបប្រើខ្ញុំបាទឲ្យយកទង់សំពាប់ខ័ពមកឃាត់ជាសំគាល់ទៀត ។ ហែហួនុនសួរបំរើសេះថា: មហាឧបរាជផ្ទាបឬទេ ដែលគួនអ៊ូមកតាមផ្លូវបានសម្លាប់ចៅហ្វាយស្រុកនឹងនាយតយល្បាតជាច្រើននាក់នោះ ? ។ បំរើសេះឆ្លើយថា មិនផ្ទាប

ទេ ។ រៀបហួនុនថា "គួនអ៊ូឆ្លើយស្មើសអាជ្ញា មហាឧបាជមិនបានដឹង យើងនឹងបើកឲ្យគេមិនបានទេ" ហើយក៏បង្គាប់ថាហានតាំងពួនឲ្យឡោមព័ទ្ធគួនអ៊ូជុំវិញ ។ គួនអ៊ូឯណាស់ បរសេះកាំជាវបួលប្រយុទ្ធនឹងរៀបហួនុនមួយលើកទៀត ទទួលទៀវលៀវបំផាយសេះបួលទៅដល់ហើយស្រែកយាត់ថា អ្នកតាំង ២ ឈប់ច្បាំងគ្នា ។ រៀបហួនុននឹងគួនអ៊ូក៏ឈប់; ទៀវលៀវនិយាយប្រាប់រៀបហួនុនថា មហាឧបាជជ្រាបថាគួនអ៊ូចំលាយគយល្បាតចេញមក ហើយសម្ងាប់ចៅហ្វាយស្រុក ទឹងនាយគយល្បាតស្លាប់ច្រើននោះ មហាឧបាជបារម្ភណាស់ក្រែងសេនាពាហានឯទៀតនឹងមានកំហឹងគុំគួនព្រួតគ្នាតាមតតាំងច្បាំង មិនឲ្យគួនអ៊ូចេញទៅបានដោយស្រួល បានជាច្រើនខ្ញុំឲ្យស្រែកមកយាត់ ។ រៀបហ៊ីនុនប្រាប់ទៀវលៀវថា ដំនតីជាកូយស្ងួយ៉ឹង ។ ច្រើឲ្យមកធ្វើពាជការជាមួយនឹងខ្ញុំ ឥឡូវគួនអ៊ូសម្ងាប់ដំនតីស្លាប់ទៅទៀត បើស្ងួយ៉ឹងដឹងហើយនឹងខឹងច្រើនប្រាកដជាខ្ញុំមិនលែង ។ ទៀវលៀវតបថា ដំណើរឬងនោះអ្នកកុំព្រួយ ទុកឲ្យខ្ញុំទៅនិយាយដោះសានឹងស្ងួយ៉ឹងចុះ ឯត្រង់គួនអ៊ូនេះមហាឧបាជមានសេចក្តីមេត្តាគេច្រើនណាស់ ត្រូវតែបណ្តោយឲ្យគេចេញទៅរកឡាតាមសញ្ញាចុះ បើអ្នកមកយាត់ទាំងមិនឲ្យគួនអ៊ូទៅនោះឃើញថាខឹងនឹងប្រសាសន៍មហាឧបាជខ្លាំងណាស់ ។ រៀបហ៊ីនុនឮដូច្នោះក៏ហៅយកពាហានដែលឡោមព័ទ្ធនោះថយត្រឡប់ទៅវិញ ។

រឿងត្រង់នេះគឺជាសេចក្តីមានពោលពុកមកថា កាលគួនអ៊ូទៅនោះបួនក្នុកគិតថាមុខជាគួនអ៊ូចេញទៅមិនរួច ព្រោះមានកន្លែងគយល្បាតជា

ច្រែនសង្កាត់ណាស់ លុះចូឆូដឹងថាគួនអ៊ូសម្លាប់ខ្លួនស៊ីវនាយតយជាន់
កូនស្លាប់ហើយ ថែមទាំងសម្លាប់ចៅហ្វាយស្រុកទឹងនាយតយជាលំជាប់
ច្រែនសង្កាត់ទៀតជាច្រែននាក់ ចូឆូក៏គិតលើកទ័ពទៅតាមចាប់គួនអ៊ូ
តែមកក្រែងគេទឹងគរហានខ្លាំងថា ធ្វើជាធំចរចាជាពាក្យ ២ ម៉ាត់ មួយ
យ៉ាងទៀតមកគិតឃើញថាចៅហ្វាយស្រុក ទឹងនាយតយកាត់នោះក៏
ស្លាប់ៗស់ទៅផង ទោះបីទឹងលើកទ័ពធ្វើទៅតាមចាប់គួនអ៊ូមកបាន ក៏
មិនមែនសេនាគាហានដែលស្លាប់នោះរស់ឡើងវិញបានឡើយ ម្ល៉ោះ
ហើយចូឆូក៏ឃល់ថាគួនអ៊ូកន្ទុងជុតដែនខ្លែត ជាចំណុះរបស់ខ្លួនទៅហើយ
ក៏តែរិះគិតត្រឡប់ចិត្តបាន ថាត្រូវតែធ្វើគុណទឹងគួនអ៊ូឲ្យហួតពុកទៅ
ប្រសើរជាង អំណើះទៅមុខគង់តែគួនអ៊ូទឹងគិតឃើញគុណវិញ បានជា
ក្លែងប្រើបំរើសេះឲ្យកាន់សំបុត្រទឹងខន់ជ័យ ហើយប្រើទៀវលៀវឲ្យទៅ
ឃាត់ទៀត ដើម្បីឲ្យឃើញថាចិត្តថ្លើមរបស់ចូឆូនោះស្រឡាញ់គួនអ៊ូច្រែន
ណាស់ សូម្បីទឹងធ្វើទុស្សេស្សយ៉ាងណា ចូឆូក៏មិនបានយកទោស
កំហុសសោះ ។

ខណៈនោះ ទៀវលៀវក៏សួរគួនអ៊ូថា ដែលអ្នកមកនេះ ទឹងទៅក
ឡៅតីឯទីណា ? ។ គួនអ៊ូធ្វើយថា កាលពីថ្ងៃមុនខ្ញុំឮថាឡៅតីបងខ្ញុំនៅ
ទឹងអ៊ូនសៀវ បានជាខ្ញុំប៉ងទឹងទៅក ឥឡូវមានគេមកប្រាប់ថាបងខ្ញុំ
ចេញពីអ៊ូនសៀវទៅហើយ ខ្ញុំក៏ត្រូវតែស្វែងទៅស៊ើបសួរកឲ្យឃាលែតែ
ឃើញ ។ ទៀវលៀវថា បើអ្នកតាមកឡៅតីមិនដឹងថាទៅឯណាទេ ចូរ
អ្នកវិលត្រឡប់ទៅនៅទឹងមហាឧបាជវិញសិនចុះ កាលណាឮដំណឹងថា

ទៀតពីនៅឯណា ។ ជាច្រើនដងហើយ សឹមអ្នកត្រឡប់ទៅវិតទៀត ។ គួនអ៊ូឮហើយក៏អស់សំណើចហើយថា អ្នកនិយាយនេះមិនត្រូវសោះ បើអ្នកនឹងវិលត្រឡប់ចូលទៅក្រុងវិញ សូមឲ្យជួយយកសេចក្តីណាសមគួរប្តឹងមហាឧបភជថា សូមកុំឲ្យអាក់អន់ចិត្តនឹងខ្ញុំឡើយ បើបានជាធ្វើគុណហើយក៏ចូរធ្វើឲ្យរហូតទៅចុះ ទៅថ្ងៃមុខគង់តែខ្ញុំនឹងតបស្នងសងគុណមហាឧបភជវិញទេ ។ ទៀរលៀវក៏លាគួនអ៊ូត្រឡប់ទៅវិញ ។

ខណៈនោះ គួនអ៊ូក៏បរសេះទៅដល់រថបងថ្ងៃ ហើយអធិប្បាយរឿងដែលបានតតាំងច្បាំងនឹងហែហួនខុន ព្រមទាំងធ្វើយោងសាគ្នានឹងទៀរលៀវឲ្យបងថ្ងៃនឹងស៊ុនខៀនស្តាប់ ហើយនាំគ្នាដើរផ្លូវទៅ ៥ ថ្ងៃ; ខួលក្មៀងរំលោភណាស់នឹងរកទីសំណាក់ពុំបាន ក៏ក្រឡេកទៅឃើញផ្ទះ១នៅលើភ្នំ ទើបនាំគ្នាឡើងទៅនឹងសំណាក់អាស្រ័យ ។ គួរសៀនម្ចាស់ផ្ទះនោះជាមនុស្សចាស់ជក ក៏សួរសាកមកវិញថា អ្នកឈ្មោះអ្វី? មកពីណាទៅណា? ។ គួនអ៊ូប្រាប់ថា "ខ្ញុំឈ្មោះគួនអ៊ូ" ហើយពណិនាពីរឿងប្រាប់គួរសៀនឲ្យស្តាប់សព្វគ្រប់ប្រការ ។ គួរសៀនក៏ថា "តាំងពីដើរតាដូនខ្ញុំមកតែងអាស្រ័យរកស៊ីធ្វើស្រែចំការនៅទីនេះ ជាយូរហើយ ខ្ញុំក៏ធ្លាប់ឮគេនិយាយរឿងមកថា អ្នកមានថ្មីដែលខ្លាំងពូកែណាស់ ខ្ញុំឮតែឈ្មោះ ទើបតែបានឃើញមុខច្បាស់ថ្ងៃនេះ" ហើយគួរសៀនអញ្ជើញគួនអ៊ូនឹងកាយាទៅពីនោះ ឲ្យឡើងទៅលើផ្ទះហើយតាក់តែងបាយទឹកតាមគួរសមឲ្យគួនអ៊ូនឹងកាយាទៅតបវិកោគ ។

លុះវេលាយប់បន្តិច កូនប្រុសគួរសៀនក៏នាំពួកគ្មើន ៧ នាក់ចូល

មកកន្លែងផ្ទះ, គួសឿនយើញក៏ហៅឲ្យកូននោះឡើងមកគំនាប់គួនអ៊ូ ដើម្បីនឹងសួមផ្ញើខ្លួនកូននោះឲ្យទៅនឹងគួនអ៊ូ, កូននោះក៏ឡើងទៅយើញគួនអ៊ូតែមិនបានគំនាប់តាមពាក្យបិតា គឺត្រឡប់ចុះទៅនាំបក្សពួកចេញទៅក្រៅផ្ទះ ។ គួនអ៊ូក៏សួរគួសឿនថានណាដែលមកអំបាញ់មិញនេះ ត្រូវជាអ្វីនឹងអ្នក? ។ គួសឿនឃំហើយជំរាបថា អំបាញ់មិញនេះគឺជាបុត្រផងខ្ញុំ ។ មានតែបុត្រមួយនេះ វាគ្មានចិត្តនឹងចង់ធ្វើស្រែចំការរកស៊ីសោះ គប់តែតែកឿនដើរបាញ់សត្វលេង គ្មានបានការអ្វីទេ ដែលខ្ញុំមានបុត្រយ៉ាងនេះក៏ជាកម្មរបស់ខ្ញុំឯង ។ គួនអ៊ូថា ផែនដីឥឡូវនេះកើតចលាចលកល់ស្រែកល់ចែត ដែលនឹងដើរបរបាញ់សត្វលេងនោះ បើមានថ្លៃដង្វែកបាញ់ធ្ងន់ដៃ កំលាំងយោងខ្លួនរួចបាន ហេតុម្តេចបានជាអ្នកថាមានកម្ម? ។ គួសឿនតបថា កូនខ្ញុំនេះវាយើញតែការសប្បាយ គប់បាបមិត្តប្រព្រឹត្តតែសេចក្តីអាក្រក់ផ្សេង ។ លេងបាញ់សត្វវាតជញ្ជាត់ត្រីគោះជាមានថ្លៃដែរចេះបាញ់ក៏ចេះគ្មានត្រូវបង្ហាត់ នឹងពប់ថាចេះស្ទាត់ម្តេចបានខ្ញុំយើញថាតម្រេះវាវានេះនឹងយោងខ្លួនបាណាមិនបានទេ ខ្ញុំទើបតើតខ្លុតព័ត្រែតែវា ។ គួនអ៊ូបានស្តាប់ហើយក៏ដកដង្ហើមធំទើបថា ជាទម្លាប់ប្រពៃណីមកហើយ បើបុត្រល្អប្រសើរ មាតាបិតាក៏ជាសុខ បើបុត្រអាក្រក់ដូជាតិ មាតាបិតានឹងសាច់ញាតិក៏ជាទុក្ខព្រួយដោយសារ ។ គួសឿនស្តាប់ហើយក៏ទាល់ច្រឡំ ទើបរៀបរាប់ទូន្មានឲ្យគួនអ៊ូនឹងកវៀកឡៅតី ខ្លួលដំណេក ហើយខ្លួនឯងក៏ចេញទៅដេកនៅលើផ្ទះក្រៅ ។

(មានត)

រឿងបល្ល័ង្កធំៗ សាមសិបពីររឿង

រឿងព្រេងឥណ្ឌា

លោកសម៉ន ម្ចាស់វត្តជម: តែង

លោក រ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

ទិទានទៀរូបទេពធិម្មិតទី ២៤

មានកាលមួយថ្ងៃ, រូបទេពធិម្មិតទីម្ភៃបួន បានបង្គំទូលឃាត់ព្រះបាទកោជ: កុំឲ្យព្រះអង្គគង់នៅលើបល្ល័ង្កទំពូនេះថា: "ទ្រង់ព្រះបាទកោជ:, គេមិនអាចរកព្រះមហាក្សត្រិយ៍ ដែលជួយទបត្តម្ភដ៏វិសុទ្ធ ឲ្យដូចជាព្រះបាទវិក្រមាទិត្យបានទេ, មានតែព្រះបាទវិក្រមាទិត្យ ដែលអាចគង់នៅលើបល្ល័ង្កទំពូនេះបាន" ។ ព្រះបាទកោជ:ទ្រង់មានព្រះបន្ទូលសួររូបទេពធិម្មិតទីម្ភៃបួនថា: "តើព្រះបាទវិក្រមាទិត្យទ្រង់ជួយទំនុកបម្រុងដ៏វិសុទ្ធនោះយ៉ាងណា?" ។ រូបទេពធិម្មិតមានបន្ទូលថា: "សូមព្រះអង្គទ្រង់ចាំព្រះសណ្ដាប់, ទូលព្រះបង្គំនឹងពណ៌នាទូរឿងនេះថ្វាយដូចតទៅនេះ:

មានកាលមួយថ្ងៃ, ព្រះបាទវិក្រមាទិត្យទ្រង់កំពុងធ្វើមហាសន្និបាតនៅព្រះពដមន្ទីរដ៏ប្រិក្សាជាមួយនឹងពួកវដ្ឋមន្ត្រីរបស់ព្រះអង្គ, ស្រាប់តែមានបណ្ឌិតម្នាក់នៅប្រទេស កេរេល: (Kerala) មានវិជ្ជាជ្រៅជ្រះខាងជោតិសាស្ត្រមកដល់ ចូលទៅគាល់ព្រះអង្គថ្វាយព្រះពរជ័យមង្គលជា

ពាក្យពេយន៍ពាក្យកាព្យ រួចអង្គុយទៅលើកៅអី ដែលព្រះអង្គព្រះរាជទាន ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជឧត្តារសួរថា: "នែបណ្ឌិត លោកចេះជ្រៅជ្រះខ្លួរសាស្ត្រណា ?" ។ បណ្ឌិតនោះក៏ក្រាបបង្គំទូលថា: "ទូលព្រះបង្គំជាខ្ញុំចេះជ្រៅជ្រះខ្លួរជោតិសាស្ត្រ" ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលថា: "ចូរអ្នកពណិនាមកចុះ តើក្នុងឆ្នាំនេះព្រះរាជអាណាចក្រយើងនឹងមានព្រឹត្តការណ៍យ៉ាងណាខ្លះ ?" ។ បណ្ឌិតក្រាបបង្គំទូលថា: "សូមទ្រង់ព្រះមេត្តាប្រោស, ឆ្នាំនេះ ព្រះរាជអាណាចក្ររបស់ព្រះអង្គ ត្រូវជួបប្រទះនឹងទុព្ភិក្ខភ័យយ៉ាងធំ" ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលតបទៅបណ្ឌិតនោះថា: "នៅក្នុងព្រះរាជអាណាចក្រយើង គ្មានអ្នកណាមិនប្រព្រឹត្តតាមនីតិសាស្ត្រ, គ្មានអយុត្តិធម៌, ពួកជីវសត្វមិនដែលអ្នកណាធ្វើបាបរំលោភសោះ, សូម្បីតែយល់សប្តិក្នុងការធ្វើបាបក៏គ្មាន, គ្មានអ្នកណាអាចយាត់ត្រង់ការប្រព្រឹត្តិសកម្មភាពក្នុងគុណធម៌សោះឡើយ, គ្មានអ្នកណាហ៊ានប្រមាថមើលងាយពួកព្រាហ្មណ៍ ធ្វើបាបជីវសត្វ ធ្វើទណ្ឌកម្មដោយខុសច្បាប់ ស្វែងរកកិច្ចដែលជាអកុសលលាមក ប្រព្រឹត្តមិនសមរម្យ ឱយចំបាក់ចំបែករួបនាដេវធីតា ធ្វើបាបពួកសប្បុរស, ឬមិនប្រតិបត្តិតាមសាស្ត្រសោះឡើយ រឿងវិវាទអស់នេះគ្មាននៅផ្ទះរបស់យើងទេ, ហេតុម្តេចក៏យើងត្រូវជួបប្រទះនឹងទុព្ភិក្ខភ័យ ?" ។ បណ្ឌិតនោះក្រាបបង្គំទូលថា: "ជោតិសាស្ត្របានសំដែងថា ទកាតុឡ: "សៅរ៍" បានបំបាក់នូវពាជរថ

ពេហ៊ីបានចូលទៅកន្លែងនៃគាតុឡៈ "សុក្រ" ឬនៃគាតុឡៈ "អង្គារ" បានជាមានកើតទុក្ខភ័យទៅទីនេះ; ចូលព្រះបង្គំក្រាបបង្គំទូលនេះ តាមបទបញ្ញត្តិនៃសាស្ត្រ" ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់បណ្ឌិតនោះហើយ ទ្រង់មានព្រះរាជហ្ឫទ័យភ័យតក់ស្លុតពន់ពេក ។ ដើម្បីនឹងបត្តម្ភប្រជាភស្តារបស់ព្រះអង្គ ឲ្យចៀសផុតនូវទុក្ខភ័យនោះ ទ្រង់ក៏បានចរិចាគព្រះរាជទ្រព្យទៅជាទាន, ធ្វើព្រះរាជពលិកម្ម. សូត្រជម្រើធ្វើព្រះរាជអំណោយ ។ ល ។ ទោះបីទ្រង់បានបព្រឹត្តព្រះរាជករណីយកិច្ចដ៏ប្រសើរនេះ, ក្តៅឆ្អឹងក៏នៅតែមិនធ្លាក់មកលើព្រះរាជអាណាចក្ររបស់ព្រះអង្គ, គ្រាប់ស្រូវលែងពន្លកដុះ ។ ប្រជាជនទាំងអស់រំជួលពេញប្រទេស, ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជហ្ឫទ័យខ្វះខ្វែងពន់ពេក ក្នុងរឿងនេះ ។

ក្នុងពេលនោះ មានសំឡេងមួយលាន់រំពងឡើងពីនភាល័យថា: "ទ្រង់ព្រះបាទវិក្រមាទិត្យ, បើទ្រង់មានពលភាពអាចបូជាយ័ញ្ញដោយមនុស្សដែលមានចរិយាជាមហាក្សត្រិយ៍មួយនាក់បាន, ក្តៅឆ្អឹងនឹងធ្លាក់មកលើព្រះរាជអាណាចក្ររបស់ព្រះអង្គ" ។ លុះព្រះមហាក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់នូវពាក្យទេវតាដូច្នោះហើយ ទ្រង់ក៏ហូតព្រះខ័ទ្ធថា ដើម្បីនឹងកាត់ព្រះរូបព្រះអង្គបូជា ស្រោចស្រង់សត្វលោកឲ្យផុតពីទុក្ខភ័យ ។ ស្រាប់តែនាងទេវធីតានៅលើនភាល័យ ស្ទុះមកចាប់ព្រះខ័ទ្ធថាជាប់ហើយ ពោលពាក្យថា "មហាវរៈ, ព្រះអង្គពិតជាភជួបត្តម្ភក៍នៃសត្វលោក, ខ្ញុំម្ចាស់មកជួយអនុគ្រោះព្រះអង្គ ។ មានព្រះរាជបំណងចង់សុំអ្វី, ចូរសុំមក

តាមច្បាប់ចុះ" ។ ព្រះមហាក្សត្រិយ៍ខ្ញែមានព្រះបន្ទូលតបនាង
ទេវធីតាវិញថា: "ការណ៍ដែលយើងសុំនោះ គឺសុំឲ្យព្រះពុទ្ធអាណាចក្រ
យើងផុតពីទុព្ភិក្ខភ័យក្នុងពេលឥឡូវនេះ" ។

នាងទេវធីតាក្រាបបង្គំទូលថា "សូមព្រះពុទ្ធចំណង់បានសម្រេច
កុំបីឃ្លៀងឃ្លាតឡើយ" ។ ដល់ពោលពាក្យដូចនេះហើយ, នាង
ទេវធីតានោះក៏បាត់ខ្លួនពីទីនោះទៅ ។

តាំងពីនោះមក ក្នុងប្រទេសអវន្តី គ្មានទុព្ភិក្ខភ័យឡើយ ។
ព្រះបាទកោដ: ខ្ញែមព្រះសណ្តាប់ធ្នូវពាក្យពោលនៃរូបទេពធិម្មិតទី
៦៤ ខ្ញែមក៏យាងចេញពីបល្ល័ង្កទៅ ។ មានធ្វើមុខថ្នាក់សេកក្នុងពេលនោះ ។

*
* *

ធិទានដែរូបទេពធិម្មិតទី ២៥

មានកាលមួយថ្ងៃ, ព្រះបាទកោដ: ខ្ញែមយាងចូលទៅដិតបល្ល័ង្កទៅ
ដើម្បីខំធ្វើពាក់សេក ។ រូបទេពធិម្មិតទីមួយក៏ក្រាបបង្គំទូលថា:
"ទ្រង់ព្រះបាទកោដ:, បើបុគ្គលណា គ្មានព្រះពុទ្ធកិរិយាដូចព្រះបាទ
វិក្រមាទិត្យទេ, បុគ្គលនោះមិនអាចគង់លើបល្ល័ង្កទៅទេ" ។
ព្រះបាទកោដ: ខ្ញែមមានព្រះបន្ទូលសួរតបទៅវិញថា: "តើមហាពុទ្ធ
វិក្រមាទិត្យនោះមានព្រះពុទ្ធចរិយាយ៉ាងណាទៅ?" ។ រូបទេពធិម្មិតទី
២៥ ក្រាបបង្គំទូលថា: "កិត្តិសព្ទនៃវីរភាពព្រះបាទវិក្រមាទិត្យ គឺ
ព្រះពុទ្ធប្តូចំយក្ខាហាន, ព្រះបុត្តាមោះមុត, មហាសប្បុរិសធម៌,

សម្បូណ៌ភាព, កិត្តិគុណដ៏ធំនេះ ឮទៅដល់ស្ថានសួគ៌, ហើយពួកទេវតានៅស្ថានសួគ៌ ក៏សរសើរនូវកិត្តិយសនៃមហាពលវិក្រមាធិត្យ ។ មានកាលមួយថ្ងៃ, សម្តេចព្រះឥន្ទ្រាធិរាជជាស្តេចនៃទេវតាដ៏ឆ្ងាយ ទ្រង់កំពុងគង់នៅលើព្រះបល្ល័ង្ក ទ្រង់មានព្រះរាជឫទ្ធានូវព្រះបន្ទូលសួរ. សីហនាទ ទៅកាន់ពពួកទេវតាថា: "ក្នុងសម័យបច្ចុប្បន្ននេះ នៅលើផែនដី តើមានអ្នកណាមានចរិយាវិសេសវិសាលឲ្យដូចព្រះបាទវិក្រមាធិត្យ ព្រោះទ្រង់អាចធ្វើនូវការជួយទ្រទ្រង់សត្វលោកទាំងអស់ នូវការព្យាយាមបំពេញគុណធម៌គ្រប់យ៉ាង នូវការមិនស្អប់ជីវិតរបស់ខ្លួន នូវការខំនុកបម្រុងដីវសត្វ នូវការស្មោះស្ម័គ្រចំពោះកិច្ចបំពេញសីលធម៌ទាន ព្រហ្មវិហារធម៌ ។

បណ្តាពួកទេវតាក្នុងទេវសភា មានទេវតាពីរបួប ឮនូវដូច្នោះ មានចិត្តសន្ទិះសង្ស័យ ហើយក៏ចង់ពិសោធមើល តើព្រះពលវរុត្តាវនៃព្រះឥន្ទ្រាធិរាជពិតឬមិនពិត ទេវតាទាំងពីរបួបក៏ហោះទៅកាន់ទន្លេអនុត្តិ ។

ក្នុងពេលនោះ, ព្រះបាទវិក្រមាធិត្យទ្រង់គង់លើអស្សរថ ដែលជាសេះប៉ុនប្រសប់ដើរ, លុន, ឆ្លៀវដំណើរលើកដើងពីរឥតឱនសាស, ផាយ, លោត, កំពុងស្តេចយាងក្រសាលសប្បាយទៅក្នុងព្រៃពលវន ទៅខាងបូព៌ព្រៃនគរ ។ ក៏ស្រាប់តែទេវតាមួយអង្គក្នុងខ្លួនជាគោញ៉ាចាស់, ទេវតាមួយទៀត ក្នុងខ្លួនជាខ្លាធំសម្បើមអស្ចារ្យ ។ គោញ៉ាចាស់ក្រឡេកឃើញខ្លា ក៏មានចិត្តតក់ស្លុតឥតឧបមា ហើយក៏ប្រាសទៅ, ខ្លារត់

តាមគោញ្ចឹចាស់ពីក្រោយ ។ គោញ្ចឹចាស់តេះទៅដល់ត្រពាំងមួយ ក៏លោតទៅក្នុងត្រពាំងនោះជាប់កក់ដកមិនរួច ។

ក្នុងពេលនោះព្រះបាទវិក្រមាទិត្យ ទ្រង់ស្តេចយាងមកដល់ទីនោះដែរ ។ គោញ្ចឹឮគាក់ទៅជាប់កក់ក្នុងត្រពាំង ក្រសែកទៅឃើញខ្លាមកជិតដល់ខ្លួន ក៏តក់ស្លុតភ័យពន់ប្រមាណ ស្រែកកេងំជាខ្លាំងក្រញ្ជាលក្នុងកក់នោះ ។ ព្រះបាទវិក្រមាទិត្យទ្រង់ទតទៅឃើញគោញ្ចឹចាស់ជាប់កក់ស្រែកខ្លាំងដូច្នោះ ហើយស្ថិតនៅក្នុងស្ថានការណ៍ដ៏លំបាក ទ្រង់ក៏ចុះពីលើព្រះទីនាំងអស្សតរកាន់ព្រះខ័នថ្មានៅព្រះហស្តស្តាំ, ឯព្រះហស្តឆ្វេងទ្រង់ចាប់គោញ្ចឹចាស់ ហើយទ្រង់ឈរប្រចាប់នៅក្នុងត្រពាំងនោះ ។ ទ្រង់ព្រះតម្រិះថា: បើអញឲ្យគោញ្ចឹចាស់ចេញពីកក់ហើយដើរចោលគោញ្ចឹចាស់ឲ្យនៅទីនេះ, គោញ្ចឹចាស់មិនអាចតេះរួចពីមាត់ខ្លាមុខជាខ្លាស៊ីមិនខាន; បើអញលះបង់ចោលគោញ្ចឹចាស់ មិនឲ្យចេញពីកក់ទេ, ក្រោយដែលបានពិយាជខ្លាហើយ, គោញ្ចឹចាស់ដោយជាប់កក់ក្នុងត្រពាំងគ្មានកម្លាំងនឹងដើរតេះទៅទៀត ហើយបើមានសត្វសាហាវណាមួយមកដល់ទីនេះ ក៏នឹងសម្លាប់គោញ្ចឹចាស់នេះមិនខាន ។ ព្រះមហាក្សត្រិយ៍ទ្រង់មិនអាចនឹងធ្វើយ៉ាងណាបាន, ទ្រង់ក៏កាន់គោញ្ចឹចាស់នោះត្រឡប់ព្រះខ័នថ្មា, ឈរប្រចាប់ក្នុងទឹកត្រពាំងសោយទុក្ខលំបាកដោយអង្គាននឹងខ្យល់រហូតមួយយប់ត្រី ។

លុះដល់ព្រឹកឡើង, ទេវតាថាំងពីអន្លង់ក៏ចុះបង់ខ្លួរូបភាពជាគោញ្ចឹចាស់ឯងជាខ្លា, ហើយប្រែខ្លួនដូចដើមវិញ រួចក្រាបបង្គំទូលព្រះបាទ

វិក្រមាទិត្យថា: "បពិត្រព្រះបាទវិក្រមាទិត្យ ជាព្រះសម្ចុតិទេព, យើងខ្ញុំ ទាំង ๒ នាក់នេះ ជាទេវតាដែលចង់ល្បងមើល តើព្រះអង្គមានព្រះពុទ្ធ-ហ្ឫទ័យស្មោះស្ម័គ្រទន្ទឹងបទបញ្ញត្តិយ៉ាងណា, មានព្រហ្មវិហារគ្រឹមណា, បានជាយើងខ្ញុំនាំគ្នាកេងជារូបសត្វដូច្នេះ, ឥឡូវនេះ យើងខ្ញុំបានយល់ជាក់ច្បាស់ហើយ, ប្រៀបដូចជាទេវតាយកចង្កឹះសព្វសិដ្ឋ ក្បរទឹកសមុទ្រ ដែលពេញទៅដោយទឹកខ្សែរពីសិដ្ឋ បានស្គាបនាខ្សែរឆ្ងន់ព្រះចន្ទដោយដំណក់ខ្សែរនោះយ៉ាងណាមិញ ព្រះអាទិទេពដែលទ្រង់ក្បរទឹកសមុទ្រដែលពេញដោយព្រហ្មវិហារ បានយកដំណក់ទឹកសមុទ្រនេះមកបន្ថែមព្រះហឫទ័យវត្តព្រះអង្គយ៉ាងនោះ! តើយើងខ្ញុំនឹងសរសើរព្រះអង្គយ៉ាងណាទៀត? ព្រះឥន្ទ្រាធិពជជាម្ចាស់នៃយើងខ្ញុំបានសរសើរព្រះអង្គ ចំពោះមុខពពួកទេវតានៅទេវសភា ទើបថ្ងៃនេះ យើងខ្ញុំបានយល់ជាក់ច្បាស់ថា សេចក្តីសរសើរចំពោះព្រះអង្គនៃព្រះឥន្ទ្រាធិពជ មានសភាពពិតមែន, ឥឡូវនេះ សូមព្រះអង្គទ្រង់ជ្រះថ្លាតាមព្រះពុទ្ធហ្ឫទ័យ តើទ្រង់មានព្រះពុទ្ធបំណងអ្វី យើងខ្ញុំនឹងថ្វាយព្រះអង្គមួយរំពេច"។ ព្រះបាទវិក្រមាទិត្យទ្រង់មានព្រះពុទ្ធដីកាទៅកាន់ទេវតាថា: "យើងឥតមានត្រូវការអ្វីឡើយ បើយើងមានត្រប់គ្រាន់ហើយ តើយើងនឹងត្រូវការសុំអ្វីទៀត!"។ ទេវតាក៏ក្រាបបង្គំទូលទ្រង់ថា "ដែលយើងខ្ញុំពិសោធឥរិយាញ៉ាំមិញនេះ មិនមែនជាការឥតប្រយោជន៍ទេ យើងខ្ញុំសូមថ្វាយចំពោះព្រះអង្គនូវរតនវត្ថុមួយហៅថា កាមធេនុ (Kâmadhenu) ប្រែថា "មេគោនៃតណ្ហា" សូមព្រះអង្គទ្រង់ទទួល, បើកាលណាទ្រង់មានព្រះពុទ្ធបំណងចង់បានអ្វី, សូម

ទ្រង់គ្រាន់តែមានបន្ទូលសុំពី "កាមធេនុ" នេះ វត្ថុនោះក៏ឆ្ពោះមកឯដ៏ៗ ឥតព្រួយបារម្ភឡើយ" ។

ក្រោយដែលបានថ្វាយនូវតនវត្ថុនោះ ចំពោះព្រះបាទវិក្រមាទិត្យ, ទេវតាក៏ក្រឡេសខ្លួនបាត់ពីទីនោះទៅ ។

ព្រះមហាក្សត្រិយទ្រង់បានកាមធេនុនោះហើយ ក៏ស្តេចយាងវិលត្រឡប់មកគាន់ព្រះពាជនិវេសនដ្ឋានវិញ ។ លុះស្តេចយាងមកដល់ពាក់កណ្តាលផ្លូវ មានសមណគិតម្នាក់មកសូមទានព្រះអង្គ ។ ក៏ព្រះពាជទានន្ទូវកាមធេនុនោះទៅសមណោះ ហើយទ្រង់ត្រឡប់ចូលព្រះពាជធានីវិញ ។

ព្រះបាទកោដៈ ក្រោយដែលទ្រង់ព្រះសណ្តាប់នូវអត្ថាធិប្បាយនៃរូបទេពនិម្មិតទី ២៩ ទ្រង់ក៏ដឿសចេញឆ្ងាយពីបល្ល័ង្កទៅ ។

(មានត)

តោះអានជាំ ឲ្យតើតគ្រាជ្ញា

បើអានទោះតិបប្រើន ធឹងបំរើនសព្វថ្ងៃទៅ
ដួចឃ្លាំងបាប់ទឹកនៅ ផ្លាឈើក្រៅនោះប៉ុន្មាន ។

រឿងសៅរ៍សោយ

(សិរីសោភាគត)

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាបាលីរងវិត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមគម្រោយសាស្ត្រាស្ទឹកវាត

ស្រែចក្ងាឆនាងខ្ទេច វិលក្ងងចូលតង់កខ្ទែង
ចាំស្តាប់សំឌូសែង ដំណឹងតម្កែងកស្តា ។
ថ្ងៃឯសេនីយ អមាត្យមន្ត្រីនោះណា
នាំគ្នាយាត្រា គ្រាច់ត្រង់តម្រង់កំងជ័យ ។
ឯពួកយោធា ដែលនាំបញ្ជាមកនៃ
ពីព្រះជៀស្ដជ័យ ក្ងូនន័យសិសៅរ៍នោះហោង ។
ចាត់ឲ្យធ្វើជា អ្នកនាំមាគ៌ាជាមួង
បីខែកន្ទុង ទើបដល់អចលសីមា ។
សេនាបតី បញ្ជាប់សេនីយសេនា
នៅត្រៃសីមា ហើយតែងអាត្មាចូលគាល់ ។

ពាក្យពី

សិរីសៅរ៍ចៅរៅត្រាស់សាកសួរ រឿងក៏រៀតាមគួរខ្លួរៀងពាល់
ទាំងព្រះមហេសីស្រីតំនាល់ អ្នកមានអ្នកគាល់ដល់មន្ត្រី ។

អមាត្យទុហាតសង្ឃាតខួល រឿងក៏រៀងមូលដល់ចប់គ្រឹ
ឯបពិត្រចមកពនរបតី រីព្រះមហេសីស្រីកញ្ញា ។
តាំងពីព្រះអគ្គមហេសី ព្រះនាងនាថនៅសោងឯកា
ទន្ទឹកឮក្រឮលអួលទុក សោយជលនេត្រាជារកោដន ។
ទើបច្រើយើងខ្ញុំក្រុមតាំង ឲ្យតាមចមកពត្រង់ដំបន់
យើងខ្ញុំទំស្ទុះខ្នុះខ្នែងគន់ លុះត្រានឿយលន់ពន់ប្រមាណ ។
នគរធំ ។ ក្រុមឯទៀត យើងខ្ញុំទំធ្វើតជើតត្រង់ហាន
រៀវតែប្រទេសតួចនេះឯង យើងខ្ញុំត្រង់ប្តូរណាពុំបានមក ។
ព្រោះគិតថារដ្ឋតួចដូច្នេះ ទ្រង់គន់ពុំរវែរមកជក
យើងខ្ញុំតាំងក្រុមទើបពុំមក ពវរកព្រះអគ្គទ្រង់ឡើយណា ។
ស្តាប់ចប់ចមកពទ្រង់តបទៅ នេះព្រោះយើងស្តេរទៅបញ្ជា
ពុំជឿសំដីនៃហោរ ទើបវង្គុស្តាមហាចំបែង ។
កាលយើងចាកពីទីបុរី ជ្រមុំទុក្ខីកែកខ្សែង
ក្តុកក្តួលកណ្តោចខ្វោចកណ្តែង ដើរលង់វង្វែងតែឯងគត់ ។
មានតែសេះមួយជាត្រួយចិត្ត ជាគូដំរិតមិត្តកំសត់
អត់ជាយច្រែនថ្ងៃក្រៃហប់ហត់ អំណត់អត់ឃ្លានពុំមានស្បៃយ ។
តែឯកឯកម្នួចំកាយ ពុំបាត់ឃ្លាតឆ្ងាយរសាយឡើយ
តែងតែផ្តួលដួលជាត្រួយ ណាឡើយនឹងបានសម្រាន្តសុខ ។
យើងត្រូវអ្នកស្រែផងតាំងឡាយ នាំគ្នាប្រញាយរាយធ្វើទុក្ខ
ជណ្តើមកជទ្រព្យសព្វត្រង់មុខ យើងជាកំពុកទុក្ខស្ទើរក្សៃយ ។

តែបុណ្យជាខ្មុនមុនទៅមាន យើងទើបរស់ានបានផុតភ័យ
មិនខ្ចោះគង់អស់ជីវិតក្បុយ ប្រល័យសូន្យជាច់ស្រែចទៅហើយ ។
ស្តេចខ្ញុំតម្រាស់គ្រាស់ពន្យល់ សព្វរឿងទុសពលឥតសល់ឡើយ
ដរាបដល់បានស្រាន្តល្អែល្អើយ ស្បែស្បើយសប្បាយឆ្ងាយខ្មុំគ្នា ។
មន្ត្រីតូចធំក្រុមសេរីក ស្តាប់ជាក់សង្វែគអនេកា
អាណិតបរមចមចគ្រា ស្រក់ទឹកនេត្រាពុំឆ្អែត ។
ខ្លះទៀតចិត្តខ្ទន់អន់ស្មារតី អាសូរចក្រីក្រៃហួសចិត្ត
កំស្រែកយែកយំពុំខ្វាចក្រែត្យ ព្រោះចិត្តអាណិតឥតប្រៀបបាន ។
ស្រែចព្រមចមពង្សវង្សក្រែសំត្រែ ខ្លួលាកំនុវត្តមហាក្សត្រក្សាន្ត
" សូមទានព្រះអង្គខ្ញុំប្រែបាសជ្ញាណ ខ្ញុំលាវិលថ្កានហានបុរី ។
ដ្បិតខ្ញុំប្រាស់ព្រាត់រដ្ឋសីមា ជាយូរហើយណាណាចក្រី
ចោលព្រះជាយោជាមហេសី ចោលកស្តេចប្រុសស្រីមន្ត្រីផង ។
ឥឡូវខ្ញុំសុំផ្លូវវិលមម្តង ថ្វាយថ្វាត់ព្រះអង្គខ្ញុំវិញហោង
សូមខ្ញុំគង់ទៅឥតសៅហ្មង ឲ្យកស្តេចាសផងធ្វើខ្មុំកុំភ័យ " ។
កំនុវត្តបានស្តាប់សព្ទតម្រាស់ ការវិលក្រឡះព្រះវៀស្ងជ័យ
ទើបខ្ញុំគ្រាស់សួរព្រះកូរំយ ពីថ្ងៃវិលជាមង្គល ។
ដែលទំនិលទៅលំទៅហាន ក្សត្រក្សាន្តកំបានខ្លួលពន្យល់
ថាស្តេចនេះជាគ្រាមង្គល ទំនិលើកពួកពលវិលបុរី ។
កំនុវត្តកំតែងឯកែងសេនា ខ្មុកហែចក្រាយាត្រាខ្ញុំ
ហើយជ្រើសរើសយកមុខមន្ត្រី ដែលមានស្មារតីវៃឆ្លាត ។

ចាន់គ្រែបំចំនួនជា ៤ នាក់ ខុកឲ្យតាំងគ្នាថែរក្សា
មើលការខុសត្រូវពៅជីតា តំណាងអាត្មាក្សត្រាឯង ។
លុះលង់សង្សារកន្ត្រើស្ងាត់ កន្ទុះត្តវិលថ្ងាត់ចូលកន្លែង
ហៅពជធីតាមកថ្វាថ្លែង សាកសួរឲ្យចែងតំណែងស្រែ ។
ដែលត្រូវពៅនៅនឹងកស្តា ប្រតិបត្តិអាត្មាបំរើប្តី
នាងនាថកញ្ញាជីតាស្រែ ក៏ខូលចក្រែតតបីងាក់ ។
" បពិត្រចិតុរង្គ្រែងំតម័ស រឿងនេះខ្ញុំម្ចាស់ចេះប្លាស់ជាក់
ប្លាប់ស្រីដែលស្តីត្រូវថ្នមថ្នាក់ រួមជាក់ឲ្យសព្វមាន ១០ ។
១ គឺក្មេងកន្ធំតំពុងក្តៅ កុំនាំពៅត្រែក្តៅមិនល្អ
២ គឺក្មេងត្រែក្តៅនោះក៏ កុំពាំនាំមកក្នុងគ្រឹះហា ។
៣ ឲ្យដល់អ្នកដែលស្មុគ្រស្មោះ ឲ្យយើងវិញនោះមោះទើបជា
៤ កុំឲ្យដល់អ្នកកាលគ្នា ដែលជាមេកោយមិនឲ្យយើង ។
៥ ពោះគេឲ្យឬមិនឲ្យ យើងត្រូវអំណោយដោយកុំឆ្មើង
៦ សុខុមត្រមដៃដើង គឺយើងអត្តុយឲ្យជាសុខ ។
៧ គោគត្តាអហារផង ឲ្យត្រូវចំនង់ដែលធ្វើងខុក្ខ
៨ ដំណេកដេកជាសុខ រាំងគេចមុខពីខុក្ខា ។
៩ ត្រូវស្នងថែធួនក្មេង ញាប់ដៃវៃដើងយ៉ាងខ្សោយ
១០ គោរពសព្វទេវតា ខាងក្នុងគេហាជាប្រក្រតី" ។
កាលនាងពណិនាជា ១ ។ គ្រប់ ១០ ហើយក៏ព្រះបក្រឹ
ឲ្យនាងអធិប្បាយស្រាយសេចក្តី ក្សត្រីខូលតបទៅវិញថា ៖

"១ ស្រីមានប្តីត្រែប់ៗកាយ ទឹងរឿងខាំងឡាយនៃកស្តា
ប្តមែនប្តីស្តីបរចា គរហារិះគន់ជនដទៃ ។
កុំនាំរឿងនោះឆ្ពោះទៅថ្ងៃ ច្រាប់តែច្រាប់ឯងវែងកើតភ័យ
ព្រោះក្តៅរឿងនេះឆេះខ្លាំងវែក លើសលើក្តៅវែងអ្វីនានា ។
២. បើនារីកូនច្របសា ឮគេគរហាថានិន្ទា
មែនឮប្តីក្តីពុំជា កុំមកពណិនាច្រាប់មាតា ។
ប្តកំបិតានឹងស្វាមី ជាហេតុកក្តៃនៃទោសា
ព្រោះជនខាំងហ្មឹងជំងឺកាលណា គង់ខឹងខ្លាំងក្លាច្រាកដជាក់ ។
៣. ស្រីមានប្តីគប្បីចាត់ សម្បត្តិធនទ្រព្យសព្វមាសច្រាក់
កុំប៉ះយមាយឲ្យធ្លាយធ្លាក់ ត្រូវរំពឹងខ្ចីថែរក្សា ។
បើមានគេមករកសុំខ្លី របស់អ្វី ។ នៃអាត្មា
ជាមនុស្សស្មោះត្រង់សងវិញណា ត្រូវតែមេត្តាឲ្យគ្នាខ្លី ។
៤ បើមនុស្សណាចិន្តាវៀច គេចកៀចសំណាងពុំសងខ្លី
ចូរកុំសន្តោសច្រោសច្រាណី ឲ្យមនុស្សនោះខ្លីអ្វីយកទៅ ។
ព្រោះបើបណ្តោយឲ្យដូច្នោះ ទ្រព្យគង់រលោះអស់ពុំនៅ
ថ្ងៃក្រោយធ្លាក់ក្រកំកើតក្តៅ ហ្មងសៅគោកយ៉ាកលំបាកចិត្ត ។
៥. សមដៃលសូមមានគោត្តា ឬញាតិកាសាលោហិត
តិក្រគោកយ៉ាកលំបាកពិត មូលមិត្តចូលមករកសុំអ្វី ។
យើងគួរចាត់ឲ្យដោយសព្វ ពោះជននោះគ្មានធ្លីវាហ៊ាន
ពុំបានតបស្នងសងវិញក្តី កូនស្រីគប្បីតែសង្រ្កែង ។

៦. ស្រីស្ងួនកូនប្រុសា អង្គុយទីណាជាចំពោះ
បើឃើញមែ-ន្ទូវប្តីនោះ កុំបីបែរបោះសោះកន្តើយ ។
បើទីកន្លែងនោះឯងឯកា លុមគ្រោកឡើងបានគ្មានអ្វីឡើយ
ត្រូវគ្រោកខ្លួលដោយស្រួលហើយ កុំបីកន្តើយព្រងើយស្ងៀម ។
៧. ទុហាតថាត់របស់ អាហារទាំងអស់នោះស្រស់ក្រៀម
ចំអាបបង្អែមតាមចំនៀម បម្រុងប្រុងត្រៀមជាធម្មតា ។
ហើយមើលបំរុងប្រុងធ្លុងថែ ឲ្យមែឲ្យប្តីឲ្យបិតា
បរិភោគសម្រេចស្រេចកាលណា សឹមខ្លួនគោក្តាវេលាក្រោយ ។
៨. កូនស្រីជាប្រពន្ធ ត្រូវកុំចំអែកុំបណ្តោយ
ត្រូវចាត់ដំណែកទីដេកឲ្យ ប្រកបទៅដោយក្តីរមនា ។
ហើយគក់តែតួនតួចំពោះ ទាល់ជនទាំងនោះលុះលក់ជា
ស្រេចកូវសឹមទៅទៅនិទ្រា ទើបជាចំណាប់ដ៏គប្បី ។
៩. ត្រូវស្ងួនមើលធ្លុងថែ ទាំងមែទាំងន្ទូវស្វាមី ។
ឲ្យបានសុខាជាប្រក្រតី កុំបីធ្វេធ្វេសប្រហែសច្បាណ ។
ជនទាំងនេះណាទុកជាភ្លើង ឲ្យយើងកក់ក្តៅនៅសុខសាន្ត
បើមិនអើពើបំរើភ្លាន គង់ជានក្តីក្តៅសៅចិត្តា ។
ទី១០. គឺសព្វកុលស្ត្រី គប្បីនុនគ្រាបពាបសិរសា
បង្គំមែន្ទូវកស្តា ជាអ្នករក្សាការពារកំយ ។
ត្រូវតាំងលោកថ្លានក្នុងហាន: ទំសក្តារៈថ្នាក់ប្រពៃ
ដូចជាទៅសួគាល័យ វែលឲ្យជោគជ័យសិរីសុខ ។

នេះណាជាច្បាប់សម្រាប់ស្រី គប្បីចាំចេះច្បាប់នេះខុក
ធ្វើតាមដោយល្អតទៅមុខ គង់ខ្ចាត់ចាត់ទុក្ខបានសុខា ។
កន្ទុះវត្តសណ្តាប់សព្វអធិប្បាយ ដែលស្រស់ទោមនាយថ្វាយអគ្គា
ទ្រង់ពេញព្រះទ័យក្រៃណាស់ណា សរសើរធីតាជាអនេក ។
ស្រេចស្តេចនាំខ្លួន៤មន្ត្រី ដែលមានស្មារតីប្រពៃឯក
ដែលទ្រង់ដើរសយកមកគ្រប់ផ្នែក សឹងបុនផដែកវែកបញ្ញា ។
ខុកឲ្យកែក្តីនៃស្រីពៅ ដែលត្រូវទៅនៅឱឯកស្តា
ប្រគល់ឲ្យដល់ស្រស់កល្យាណ៍ ស្រេចថ្នាត់ក្សត្រាយាត្រាខ្ញុំ ។
វិលបួលបន្ទំផ្ទំសេយ្យា លង់លក់សុខាអស់ពត្រី
លង់លុះព្រឹកព្រាងស្ងាងរង្ស៊ី ចក្រីទើបលាកចាកបន្ទប់ ។
ចាត់ចតុរង្គអគ្គិសេនា ពេញព្រៃបត្រៃបត្រាបង្ការគ្រប់
ខុកហែបរមអង្គចមកព តឡប់ធានីទីលំនៅ ។

បទកុដន្តលីលា

ឱដ៏ចែងសំដែងថ្លែងទៅ ព័ត៌ព្រះសិរីសៅរ៍ ចមកពនរបតី ។
លុះបានពេលយាកសី អស់មុខមន្ត្រី រញ៉ីណែនណាន់ ។
ព្រះអង្គទ្រង់ពាពស្តេកណ្តូ មកុដសុវ៌ណ្ណ ប្រពៃថ្លៃថ្លា ។
សុខត្តរវ៉ែត្តកញ្ញា នាងតែងកាយា កក្រើបប្រមប្រិយ ។
សិរីសៅរ៍ចមចៅនរបតី ឡើងគង់ហត្ថី ដ៏រវែត្តរឿង ។
គជេន្ទូនរេន្ទូចន៍គ្រឿង ល្អអង្គរុងរឿង ចុំថ្លៃដ៏ថ្លៃថ្លា ។
សុខត្តរវ៉ែត្តន៍នោះណា ឡើងគង់គជសា បម្ងាប់ស្វាមី ។

យោធាសេនាមន្ត្រី　　ហែក្បួនត្រឃ្មុតខ្ទឹ　　រញ្ជឹគ្រប់ច្រាណ ។
ក្អូសកុំកិរម្យាថ្ពើងថ្ពាន　　ចាំងចំចក្បួនក្បាន្ត　　ឲ្យបានសុខជា ។
តាន់តាប់ខ្ទាន់ខ្ទាប់មហិមា　　ដង្ហែរជា　　លីលាចេញខ្ទឹ ។
ពួកស្មុំមេទំពាស៊ី　　ខ្មោមព័ទ្ធក្បួនត្រី　　អ៊ឹកៈធំកគ្រឹកគ្រេងឆ ។
កែះគន់ចំអន់គ្នាលេង　　ច្រៀងកំផ្សំភ្លេង　　សើចលេងភ្នាកភ្នាយ ។
ពួកពលសកលតាំងឡាយ　　ខ្លះបែកខ្លែកខ្លាយ　　ខ្វល់ខ្វាយចាញ់ម្រីគ ។
សូរសព្ទសន្ធាប់សន្ធឹក　　គគ្រែងគគ្រឹក　　កុងព្រឹក្សាសាខ្ពុ ។
ខ្លះមិញបរចាញ់សត្វចាន　　ត្រែកអង្រែមាណ　　អូសថ្ពាន់ច្រញាប់ ។
មើលម៉ងផ្លែងផ្លងផ្សារផ្គាប់　　និយាយប្រាយប្រាប់　　ស្រែផងតាំងឡាយ ។
ពាមើលសើចគ្នីលភ្នាកភ្នាយ　　ខ្លះថាវ៉ីយ៉ាយ　　នេះសោតសត្វអី ។
ឯព្រានច្រាប់ថ្ពានអស់ស្រែ　　ថាសត្វនេះខ្ទឹ　　ប្រុសស្រែហៅគ្នាន ។
ខ្លះវៃលូកដៃទៅគាន់　　ថាអា ! សត្វក្តាន់ !　　សំខាន់ណាស៎ុី ។
មើលសត្វច្រៃនពិតឥតបី　　សត្វហើរដើរដី　　រញ៉ើកខ្ទង ។
ខ្លះគួចខ្លះធំដំបង　　រមាសច្រៃសផង　　ចោលធ្នាត់ខ្ចាត់ខ្ចាយ ។
មានតាំងខន្ធាឆ៍ខន្ធាយ　　ផ្តើលត្រូចច្រញាយ　　ពយប៉ាយទីឆៃ ។

(មានត)

កំណាត់ដំណឹងប្រវត្តិការណ៍

មន្ទីរពេទ្យព្រះសង្ឃ
បានកើតឡើងនៅខែត្រតាកែវ

ពុទ្ធសាសនបណ្ឌិត្យ

កាលពីព្រឹកថ្ងៃអាទិត្យទី ២៤ ម៉ឺនា ១៩៥៦ នៅទីក្រុងតាកែវ មានធ្វើ ក្រោមអធិបតីភាពនៃលោក ឡិញ-ភ័ញ រដ្ឋលេខាធិការក្រសួងធម្មការ នូវពិធីសម្ពោធមន្ទីរពេទ្យជាលអាពាធព្រះសង្ឃមួយ ដែលអ្នកស្រុកកសាងឡើង ។

កុងឧកាសនោះ គេសង្កេតឃើញ ផ្នែកខាងព្រះសង្ឃ មានព្រះគ្រូសង្ឃសត្តា ប៊ុណ្យ-សុម្ភាជ ជាគំណាងសម្តេចព្រះសង្ឃនាយកគណៈមហានិកាយ ព្រះតេជគុណ:មេគណៈ អនុគណៈ ចៅអធិការ ព្រមទាំងព្រះថេរានុត្ថេរៈ ជាច្រើនអង្គក្នុងខេត្ត ; ផ្នែកខាងគ្រហស្ថ មានលោកឡេ-ប៊ុនថា អនុរដ្ឋលេខាធិការ ខន្ធសការៈខាងសហការណ៍ លោកអៀប-ហុងលឹម អតីតចៅហ្វាយខេត្តតាកែវ, លោកបេកេង-ហ៊ាន អតីតគ្រូពេទ្យនាយក; លោកយិត-គឹមសេង គ្រូពេទ្យនាយកបច្ចុប្បន្ន, នាយក្រុមនានា, លោកយុង-យ៉ា ចៅហ្វាយខែត្ត, ចៅហ្វាយស្រុកទាំងអស់, នាម៉ឺនសព្វមុខមន្ត្រីក្នុងខែត្រតាកែវ សមាជិកគណៈកម្មាធិការកសាងមន្ទីរពេទ្យព្រះសង្ឃ ព្រមទាំងឧបាសកឧបាសិកាជាច្រើនរយនាក់ ចូលរួមផង អញ្ជើញទៅកុងពិធីបុណ្យនេះដែរ ។

សុន្ទរកថាលោក យុង-យ៉ា

លុះដួចដុំហើយ លោកយុង-យ៉ា បានហ្វាយខេត្តបានថ្វៃដ៏សុខ្ទរកថាមួយយ៉ាងក្បោះក្បាយ ពាក់ព័ន្ធអំពីដំណើរការស្ថាបនាមន្ទីរពេទ្យបាលអាពាធព្រះសង្ឃ មានសេចក្តីដូចតទៅនេះ ៖

សូមពិតពុទ្ធដីកាព្រះបវរមុនីនាថ ! .

សូមប្រណិប័តន៍លោករដ្ឋលេខាធិការក្រសួងធម្មការនិងសាសនាការជាតិ !

សូមជំរាប អស់លោក-អ្នកសប្បុរសទាំងឡាយ ដែលបានមកសន្និបាតប្រជុំនៅពេលនេះ !

សូមមានប្រសាសន៍ សូមជ្រាប ។

ពេលនេះ ជាថ្ងៃមង្គលបុណ្យសម្ពោធជាផ្លូវការ នៅមន្ទីរពេទ្យសម្រាប់ព្រះសង្ឃ នៅក្នុងទីរួមខេត្តតាកែវ ក្រោមអធិបតីភាពនៃលោករដ្ឋមន្ត្រី, ដែលបានអញ្ជើញមកពីក្រុងភ្នំពេញ ។

គណៈបានជាប្រធាននៃគណៈកម្មាធិការ ដែលបានផ្តើមកសាងមន្ទីរពេទ្យព្រះសង្ឃនេះ, ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វៃដ៏អំណរគុណជាតិយោភាពចំពោះព្រះបវរមុនីនាថ ត្រេប់អង្គ មានព្រះតេជព្រះគុណ ព្រះគ្រូសង្ឃសន្ត ប៉ុណ្យ-សុម្ពាជ ជាតំណាងសម្តេចព្រះសង្ឃនាយកជាដើម, ចំពោះលោករដ្ឋមន្ត្រីជាតំណាងព្រះពជរដ្ឋាភិបាល ព្រមទាំងអស់លោក-អ្នកសប្បុរសជិតឆ្ងាយទាំងប៉ុន្មាន ដែលបានខំមនុស្សបានអញ្ជើញមក ក្នុងពិធីបុណ្យនេះ ជាទីទាំងឲ្យមានខ្សែរីសួស្តីជយមង្គលជាអនេកប្បការ ។

ជាបឋមកថ្ច, ខ្ញុំព្រះករុណា, ខ្ញុំ, សូមអធិប្បាយរៀបរាប់ដោយ
សង្ខេប អំពីមូលហេតុនៃបុញ្ញកម្មនេះ ដើម្បីជាសណ្តាប់ប្រគេន-ជូន
ព្រះករុណានិងអស់លោក អ្នកសប្បុរស ឲ្យមានសទ្ធាជ្រះថ្លាដ៏ក្លៀវក្លា
ឡើងជាលំអាន ។

ព្រះករុណា ! អស់លោក !

មន្ទីរពេទ្យសំរាប់ព្រះសង្ឃនេះ បានស្ថាបនាកាលឆ្នាំ ១៩៥៣
មានលោក អៀប-ហុង-លីម អតីតប្រមុខវៃត្រ និងលោក ឆេ-តេង-
ហ៊ាន អតីតមន្ត្រីសុខាភិបាល, ជាមេគំនិតផ្តួចផ្តើមបបួលអស់លោកនាយ
ក្រុម (គហាន-ប៊ួលិស និងស៊ីលែ) ក្នុងខ័ណ្ឌវៃត្រតាកែវ ធ្វើជា
សមាជិករួបរួមធ្វើគ្រោងការប្រមូលទុនបច្ច័យ, ដោយមធ្យោបាយ តាម
គន្ថធម៌ព្រះពុទ្ធសាសនា, មិនឲ្យខាតខ្វះនិងបទបញ្ញត្តិខាងរាជការព្រះ
រាជអាណាចក្រសោះឡើយ ។

ក្រោយពីបានទទួលអនុញ្ញាតច្បាប់ជាក្រមត្រូវអំពីព្រះរាជរដ្ឋាភិបាល
រួចហើយ, គណៈកម្មការបានចាប់ផ្តើមធ្វើបុណ្យដំបូង បាននាំគ្នាលេងរបាំ
និងនាំគ្នាយោសនាយកបច្ច័យមកទិញគ្រឿងឈើ-ឥដ្ឋ-ក្បឿង ស៊ីម៉ងត៍-
ដែក ។ល។ និងដួលជាងសង់មន្ទីរពេទ្យនេះបណ្តើរៗ ក្រោមបទបញ្ជា
នៃលោកនាយផ្នែកក្រសួងសាធារណការតាមកម្លាំងទុន ដែលប្រមូល
បានមួយលើក ។

ការកសាងនេះ ពុំទាន់បានដឿនទៅឡើយ, ទទួលលោក អៀប-
ហុង-លីម និងលោក ឆេ-តេង-ហ៊ាន ដែលត្រូវផ្លាស់ទៅកាន់តំណែង

ថ្មីៗតទៅ, ការដែលបានជួបផ្តើមឆ្នើមកនេះ កំអាក់ខានតាំងពីខែះ រហូតមក ។

ដោយហេតុតែកុសលរបស់ព្រះថេរានុត្ថេរៈ ឧទ្ទិសលោក - អ្នក សប្បុរសទាំងប៉ុន្មាន ដែលមានសទ្ធាជ្រះថ្លាយ៉ាងមុតមាំក្នុងការនេះពិត ប្រាកដ ទើបកុសលបណ្តាលឲ្យព្រះពុទ្ធរង្គាគិចាល ចាត់លោក ខ្លោ-ប៊ុនចាំ មកធ្វើជាប្រមុខខែត្រ, លោកក៏បានរួបរួមឧទ្ទិសលោក យិត-គឹមសេង ជានាយក្រុមសុខាភិបាល ព្រមទាំងអស់លោកនាយក្រុមឯ ទៀតៗក្នុងទីរួមខែត្រ បន្តការកសាងមន្ទីរពេទ្យព្រះសង្ឃនេះ ទាល់តែ បានហើយស្រេចនៅពេលនេះ ដូចមានរូបភាពត្រដែតត្រដឹមបញ្ចេញ ច្បាស់ច្រាយ ជាប្លង់ទីយស្ថានមួយយ៉ាងទំនើប ស្ថាបនាដោយគ្រឿង ឥដ្ឋ ស៊ីម៉ងត៍ មានទំហំទទឹង ១១ម,៩០ បណ្តោយ ១៣ម,៩០ កំពស់ ៦ម,៩០ យ៉ាងធំល្អាយ លំអដោយពណ៌សលឿងខ្ចី ថ្កុំថ្កែងឆ្ងាយ ស្ថិតនៅកន្លែងមួយដ៏ស្អាត ឃ្លាតពីចំណោមបណ្តាជន សមរម្យជាទី សំណាក់អាស្រ័យនៃព្រះសង្ឃ គួរឲ្យចង់តែទស្សនាសព្វកាលសព្វ វេលា ហើយស្ងើចសរសើរគ្រប់ៗគ្នាផង ។

នៅក្នុងផ្ទៃមន្ទីរនេះ មានបែកខ្ញែកជាបន្ទប់ៗ យ៉ាងល្អាយច្រើនជាប់ សព្វគ្រប់ ដោយគ្រែសំណាង ១៥ មានមុង កន្ទេល ខ្នើយ បង្កើនគោម ភ្លើងអគ្គិសនីភ្លឺចែងចាំង នៅពេលកត្តីជាច្រើនតី ។

ខាងក្រៅ មានថ្នល់បែកខ្នែងជា ៤ ទិស មានសួនច្បាលំអដោយ ក្តីផ្កាច្រាលខ្នាល គួរឲ្យព្រះសង្ឃសំណាក់នៅបានសុខស្រួល ដោយ

សេចក្តីរីករាយដ៏ថ្លៃវិសេសបំផុត ជាទីនាំឲ្យឆាប់សះជាស្បើយនូវជម្ងឺរោគ
របស់លោកថែមទៀតផង ។

ឯតម្លៃកសាងមន្ទីរពេទ្យនេះ អស់ប្រាក់បីសែនមួយម៉ឺនប៊ុំពាន់
ប៊ុំមួយរយកៅសិបមួយរៀល សាមសិបសេន (៣១៥៦៩១រ៣០)
ប្រាក់នេះគឺសុទ្ធតែប្រាក់ដែលព្រះករុណា គ្រប់អង្គគ្រប់វត្ត ទឹងប្រាក់ផ្ទាល់
ខ្លួន អស់លោក.អ្នកសប្បុរសគ្រប់ស្រុក គ្រប់ភូមិ គ្រប់ឃុំ ក្នុងខេត្ត
តាកែវនេះ ទឹងខេត្តជិតខែងខ្លះ, មានឯកឧត្តមភជប្រតិភូឈួន.មុល
ពេជ្រ ខេត្តសៀមរាបជាដើម ចូលបរិច្ចាគធនធានផ្ទាល់ខ្លួន ព្រមជាមួយ
ទឹងសហការីរបស់លោកមកជួយជាកំលាំង គាល់តែបានកើតជាសេនា.
សនៈនេះដោយមនោសាមគ្គីយ៉ាងមហាស្ចារ្យ ។

មន្ទីរពេទ្យព្រះសង្ឃថែបនេះ ក្នុងកម្ពុជរដ្ឋរបស់យើង ពុំទាន់មាន
ច្រើនទៅឡើយទេ, ដែលខេត្តតាកែវយើងបានកសាងហើយនេះ គួរឲ្យ
កើតមិត្តិជិះថ្លាវកទីបំផុតគ្មាន ។

ព្រះសម្ចាសម្តេចជាម្ចាស់ បានត្រាស់ថា: សេនាសនទាន ពោះបី
បានកសាងចិត្តិយបន្ទប់ស្តុបស្ទើង ត្រឹមតែគ្រែទេសនា គ្រែសំណាងប្តូបង្គន់
មួយប្រគេនដល់ព្រះសង្ឃ ក៏គង់បានផលានិសង្សយ៉ាងស្តុកស្តម្ភ ។ ចំពោះ
យើងបានរួបរួមកំលាំងសទ្ធាសាងបានជាតួគ្រឹះស្ថានធំស្តឹមស្កែ តម្លៃច្រើន
សែនរៀល សម្រាប់ជាមន្ទីរពេទ្យព្យាបាលរោគព្រះសង្ឃថែបនេះ ផលា-
និសង្សនៃមហាសេនាសនទាន ក៏តែតែចំរើនទ្វេគុណឡើង ជាមហាស្ចារ្យ
ពុំអាចនឹងគណនាវាស់តំនរបុណ្យថា ប៉ុណ្ណេះប៉ុណ្ណោះបានឡើយ ។

ខ្ញុំព្រះករុណា ខ្ញុំ ស្តាយពេក ដែលតុំបានយកនាម ផ្ទាល់អង្គ ផ្ទាល់ខ្លួនអស់លោក - អ្នកសប្បុរសមកថ្វែង រៀបរាប់ឲ្យសព្វគ្រប់ក្នុងពេលនេះ ព្រោះមានច្រើនគ្នាណាស់ជាការហួសនិស្ស័យនឹងថ្វែងទៅបាន សូមមេត្តាអភ័យទោស សូមតាំងចិត្តជាកុសលថា: ទោះយ៉ាងណា យើងក៏ទៅក្នុងសម្បាច់ជាម្ចាស់ទាន ម្ចាស់បុណ្យគ្រប់ៗ គ្នា យើងគប្បីខ្លួលអនុមោទនាយកចំណែកបុណ្យមគ្គផល ដោយចិត្តសោមនស្សជាអស្ចារ្យកុំស្ងាត់ស្ងៀរឡើយ ។

ឥឡូវមហាសេនាសនទានរបស់យើងនេះសន្មតថា បានសម្រេចការជួបជុំថ្ងាហើយ ។

យើងខ្ញុំតំណឡាយ សូមលើកមន្ទីរនេះថ្វាយចំពោះព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង សូមទ្រង់ព្រះមេត្តាប្រោសមានព្រះបញ្ជាឲ្យចារឹកពុកក្នុងបញ្ជីអស្ចារ្យមិនឆ្ងាយសូមព្រះពុទ្ធទានខ្ញុំបុគ្គលិក ព្រមទាំងសម្ភារៈនឹងគ្រឿងទុសថរផ្សេងៗ សម្រាប់ព្រះសង្ឃឲ្យបានគ្រប់គ្រាន់ទៅឲ្យទាន ដោយអនុគ្រោះ ។

ទៅពេលនេះយើងខ្ញុំព្រះអង្គ បានប្រមូលប្រជុំគ្នា, ធ្វើបុណ្យសម្ពោធធ្វើមហាសេនាសនទាននេះ ដើម្បីបើកឧកាសប្រគេនព្រះសង្ឃចូលមកសំណាក់ព្យាបាលរោគាពាធ របស់លោកជាបឋម ។ ទៅមានការបន្ទាប់បន្សំត្រូវធ្វើតទៅទៀត គឺជាក់ម៉ាស៊ីនទឹកនឹងធ្វើបង្គន់ តាមរបៀបសម័យនោះយើងខ្ញុំក្រែមល្អង់ធួលីព្រះបាទនឹងសូមអំពាវនាវ អស់លោកអស់អ្នកសប្បុរស ឲ្យជួយឧបត្ថម្ភដើម្បីបង្ហើយការ លុះត្រាតែគ្រប់គ្រាន់ ។

យើងខ្ញុំតាំងក្បាយ សូមស្វាគមន៍ខ្ញុំសូមថ្វាយព្រះពរជាកុសល ចំពោះព្រះគុណាជាអម្ចាស់ដ៏វិសេសលើសលុង ទីសម្តេចព្រះមហាសុត្រិយានជាទ័គោរព, សូមព្រះអង្គទ្រង់ប្រទានសមប្រកបដោយសេចក្តីបរមសុខក្សេមក្សាន្ត ក្នុងព្រះសិរីពរជ័យសម្បត្តិជាយូរអង្វែង, ព្រមទាំងសម្តេចសហជាតិនៃ ๆ នភេន្តម . សីហាឧវ៉ុន ๆ ជាបិតាឯកពរជ្យជាតិ, សូមទ្រង់មានជោគជ័យល្បីល្បាញព្រះកិត្តិនាមស្ថិតថេរក្នុងសាកលលោកជរាបរទៅ ។

ជាទីបញ្ចប់, ខ្ញុំព្រះគុណា, ខ្ញុំ សូមអរគុណជាពន្លឺកចំពោះព្រះថេរានុត្ថេរៈព្រមទាំងអស់លោក - អ្នកសប្បុរសគ្រប់គ្នា, គោរពព្រះគុណទីងអស់លោក . អ្នកសប្បុរសដែលបានចំណាយ ធនធានគ្រាស់រៃក្រែលក្នុងការកុសលនេះក្តី ដែលបានចាប់មគ្គផលក្នុងការកុសលនេះតួចតួចក្តី ឬគ្រាន់តែមានចិត្តជ្រះថ្លា ជួយអនុមោទនាអបអរសាទរដោយដៃឆ្នះឆ្នៃដោយកាយវាចាក្នុងកិច្ចបុណ្យនេះក្តី គោរពបីបានទិមន្តបានអញ្ជើញមកក្តី មិនបានមកក្តី ក៏សូមឲ្យបានទទួលចំណែកបុណ្យនេះស្មើ ๆ គាត្តា ថើ ប្រាថ្នាយ៉ាងណា ក៏សូមឲ្យបានសម្រេចយ៉ាងនោះកុំបីឃ្លៀងឃ្លាតឡើយ ។

* * *

សុន្ទរកថាលោកទ្រីញ - វ៉ាឡា

លុះលោកយុង - យ៉ា ថ្លែងចប់ហើយ លោកទ្រីញ ភ័ញ រដ្ឋលេខាធិការ ក្រសួងធម្មការបានថ្លែងសុន្ទរកថាមួយ សរសើរអំពីសទ្ធាចិត្តដែលបានសាងមន្ទីរពេទ្យព្រះសង្ឃនេះ ព្រមទាំងបញ្ជាក់ទូវបុណ្យកុសល មានសេចក្តីដូចតទៅនេះ ៖

សូមថ្វាយបង្គំព្រះចេកខុន្តេះ ទាំងឡាយគ្រប់ព្រះអង្គ, សូមជំរាប
សហជីវនៈ ចៅហ្វាយខេត្ត ព្រមទាំងអស់លោក . អ្នកទាំងឡាយ ដែល
បានចំណុះអញ្ជើញមកប្រជុំក្នុងពិធីនេះ ។

ព្រះគុណាគ្រប់ព្រះអង្គ !

អស់លោក - អ្នក !

ឱកាសនេះជាកត្តិយសមួយ ដ៏ប្រសើរចំពោះប្អូនខ្ញុំព្រះគុណា ខ្ញុំ
ដែលតណៈកម្មាធិការ នៃការកសាងមន្ទីរពេទ្យព្រះសង្ឃនាខេត្តនេះ មាន
សោមនស្សត្រូវមកលើប្អូនខ្ញុំព្រះគុណា ខ្ញុំ ឲ្យធ្វើជាអធិបតី ក្នុងពិធី
សម្ពោធបើកមន្ទីរពេទ្យព្រះសង្ឃជាឧឡារិកនេះ ។

ដូច្នេះ ក្នុងហានៈជាអធិបតីនៃពិធីនេះផង ទីឯកុងហានៈជាវដ្ឋលេខា-
ធិការក្រសួងធម្មការផង ខ្ញុំព្រះគុណា ខ្ញុំ សូមថ្លែងនូវអំណរគុណជា
អនេក ទីឯសូមសំដែងនូវមនោសញ្ចេតនាដ៏ផ្អែមល្ហែមក្រៃលែង ចំពោះ
ឧត្តមគតិដ៏ថ្លៃថ្លា ទីឯជាមហាកុសលរបស់ពលរដ្ឋជាពុទ្ធបរិស័ទទាំងឡាយ
ក្នុងខេត្តនេះ ដែលមានសាមគ្គីធម្មិដ៏ប្រសើរក្នុងការផ្តួចផ្តើមកសាងឡើង
ជាបឋម នូវអស្ចារ្យមួយគួរសម្រាប់ប្អូនជាចំពោះព្រះពុទ្ធសាសនានេះ ។

មន្ទីរពេទ្យចាស់អាចព្រះសង្ឃនេះ ជាកន្លែងគិលានសង្គ្រោះមួយ
យ៉ាងសមរម្យ បានចាត់ចែងកសាងឡើងដោយកម្លាំងសទ្ធានៃពុទ្ធបរិស័ទ
គ្រប់ជាន់ - ថ្នាក់ទាំងបព្វជិតទាំងគ្រហស្ថ នៅក្នុងខែត្តតាកែវទាំងមូល
ដើម្បីទុកជាសេនាសនៈ សម្រាប់ព្យាបាលពេទព្រះសង្ឃពុទ្ធសាសនិកជាច់
ដោយឡែកពីគ្រហស្ថ ។

ដំណើរនេះជាដំណើរត្រូវតាមគន្ថដ៏ប្រពៃណីពីបុរាណកាល ដែលជាប់មានក្នុងសម័យព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយ មានព្រះមហាក្សត្រិយ៍មួយព្រះអង្គទ្រង់ព្រះនាមថា ធម្មាសោកភាជ ឬព្រះបាទអសោកមហាភាជសោយភាជ្យក្នុងក្រុងបាតលីបុត្រ ដែនមគធៈ ប្រទេសឥណ្ឌូទ្រង់មានព្រះពាជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដោយពេញកម្លាំង បានសាងអាវេគ្យសាលាជាច់ដោយឡែក ស្មើលតតមានទាស់ទំនឹងរាំនួយ ។

ក្រោយមកទៀតនៅលង្កាទ្វីប មានព្រះមហាក្សត្រិយ៍មួយព្រះអង្គព្រះនាមព្រះបាទទុដ្ឋគាមិនីអភ័យ បានកសាងមន្ទីរពេទ្យមួយ សម្រាប់ព្យាបាលរោគព្រះសង្ឃជាច់ដោយឡែកនៅក្រុងអនុរាធបុរី ។

ក្នុងចំណោមតពួកបូព៌ាប្រទេស ដែលព្រះពុទ្ធសាសនាផ្សាយមកដល់ប្រទេសកម្ពុជាយើងក្នុងសម័យនគរធំ មានព្រះមហាក្សត្រមួយព្រះអង្គមានព្រះកិត្តិសព្ទល្បីល្បាញខ្ចរខ្ចាយក្នុងលោក គឺព្រះបាទជយវរ្ម័នទី ៧ ព្រះមហាក្សត្រិយ៍អង្គនេះ មានព្រះពាជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដ៏លើសលុប បានកសាងអាវេគ្យសាលាដោយឡែកសម្រាប់ព្រះសង្ឃជូបកាលព្រះបាទធម្មាសោកដែរ ។

សរុបសេចក្តីថ្លៃឃើញថាពុទ្ធបរិស័ទក្នុងខេត្តតាកែវ បេះស្រាវជ្រាវរកប្រពៃណីដ៏ល្អយកមកផ្គត់ផ្គង់ជាបច្ច័យបួន ចំពោះព្រះសង្ឃដោយយកចិត្តទុកដាក់ជាទីបំផុត ។

(មានត)

ភក្តីបសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៨ លេខ ៨ ខែសីហា ព.ស.២៤៩៩ គ.ស.១៩៥៦



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— សន្តោសកថា	ឃុនបណ្ឌានុរក្ស ប៊ូ-ប៉ូ	៧០៣
— ប្រដុំធម៌ទាសក (ត-ចប់)	ព្រះទេពសត្ថា ភិម-តុរ	៧១២
— ទោសនៃសុរា	ព្រិន្ទបាលទោ ជា-ប៉ូរ	៧២៩
ផ្នែកអក្សរសាស្ត្រ		
— សេចក្តីសុខនឹងសេចក្តីចំរើនរបស់ប្រទេសតែងប្រព្រឹត្តទៅជាមួយនឹងវិប្បធម៌	លោក រ័យ-ប៊ុក	៧៣៣
— ពេជ្រព្រះរាជា (តមក)	លោក ស៊ីន-ហ៊ាន ប្រែ	៧៤៥
— រឿងសាមកុក (តមក)	ឧកញ៉ា នូ-ហន	៧៥៩
— រឿងបស្ចិមទិព្យ (តមក)	លោក រ័យ-ប៊ុក ប្រែ	៧៦២
— រឿងកូនក្លោះ	អ្នកស្រី សារិះយ៉ាន់ ប្រែ	៧៦៧
— រឿងសៅរ៍សោយ (ត-ចប់)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៊ម ប្រែ ...	៧៧៧
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ ..	លោក ជាប-ពិន	៧៨៥
កំណត់ទំនឹងប្រវត្តិការណ៍		
— មន្ទីរពេទ្យព្រះសង្ឃ ទៀត្រតាកែវ (ត-ចប់)	ពុទ្ធសាសនបណ្ឌិត្យ	៧៩០

មួយឆ្នាំមាន ១២ លេខ — ដំឡៃជាវ ២៣០,០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Santosakatha	*par M. BOU-PO*	*703*
— Recueil des disciplines Bouddhiques des fidèles (suite et fin)	*par Vénérable KEM-TO* . . .	*712*
— Les conséquences de l'alcool .	*par M. CHEA-PO*	*729*

PARTIE LITTÉRAIRE:

— La culture est la base du progrès.	*par M. RAY-BUC* . . .	*733*
— Conte "Le Diamant du Raja" (suite)	*Traduit par M. SIN-HEAN*	745
— Histoire du Samkok (suite) . .	*Traduit par M. NOU-KAN.*	*755*
— Les trente-deux récits du Trône (suite)	*Traduit par M. RAY-BUC .*	*762*
— Histoire de deux frères jumeaux	*par Mme. SARIS-YANN . .*	*767*
— Le "Sau-Soy" ou l'influence saturnienne (suite et fin) . . .	*par Vénérable PEUNG-PAM*	*777*
— Activités de la Commission des Mœures et Coutumes . .	*par M. CHAP-PIN*	*785*

NOTES ET CHRONIQUES:

— L'hôpital des Bonzes dans la Province de Takeo (suite et fin)	*par l'Institut Bouddhique* . . .	*790*

Prix d'abonnement annuel (comprenant 12 numéros) 230$00

សន្ទោសកថា

ឃុនបណ្ណាន៉ុក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

ខ្ញុំធ្លាប់បានឮអ្នកខ្លះនិយាយបន្ទោសព្រះពុទ្ធសាសនាថា "ពុទ្ធ-សាសនាធ្វើឲ្យមនុស្សខ្ជិល, ឲ្យល្ងង់ខ្លៅ, ធ្វើឲ្យស្រុកទេសអាប់ឱនមិនបំរើន ព្រោះព្រះពុទ្ធសាសនាប្រដៅមនុស្សឲ្យកាន់ធម៌សន្តោស ។ មើលបុះមនុស្សជាតិខ្មែរប្រើនតែខ្ជិល, ប្រើនតែល្ងង់ខ្លៅ, ស្រុកខ្មែរអាប់ឱនមិនបំរើនដូចស្រុកគេ ។ ហេតុតែជាតិខ្មែរកាន់ធម៌សន្តោស បានជាខ្មែរទម្រន់, ខ្ជិលប្រអូស, មិនខំធ្វើការ, មិនបង់មានបាន, បេះតែបណ្តោយឲ្យជនបរទេសចូលមកលុកលុយដណ្តើមយកការងារក្នុងប្រទេសខ្លួនបាន ។ ជាតិខ្មែរបេះតែចាញ់ប្រៀបជនបរទេសគ្រប់អន្លើ តាំងពីដំណាំរហូតដល់សេដ្ឋកិច្ចជាតិធ្លាក់ដុនដាបដើបមិនរួច មកពីជាតិខ្មែរកាន់ពុទ្ធសាសនា ហើយធ្វើតាមធម៌សន្តោស" ។

ខ្ញុំសូមឆ្លើយតបទំនឹងពាក្យបន្ទោសខាងលើនេះថា "ជាតិខ្មែរអ្នកពុទ្ធសាស្ត្រ មិនយល់ត្រឹមទទួលថាព្រះពុទ្ធសាសនាប្រដៅមនុស្សឲ្យអន់ខន់តាបដូចជាពាក្យបន្ទោសនោះទេ ។ ឯពាក្យបន្ទោសនោះផ្ទុយនឹងព្រះពុទ្ធសាសនាស្រឡះ បើបន្ទោសចំពោះលើរូបមនុស្សអ្នកកាន់ពុទ្ធសាសនាវិញទើបត្រឹមត្រូវជាង ព្រោះថាធម្មតាសាសនាតាំងអស់ សុទ្ធតែមានវត្ថុបំណងក្នុងការដឹកនាំមនុស្សទៅរកសេចក្តីសុខ ទំនឹងសេចក្តីចំរើនដូចគ្នា ប៉ុន្តែបើអ្នកកាន់សាសនានោះ នៅតែបានទុក្ខកោសវិនាសខ្មែតនោះមិនមែនមកពីសាសនាទាំឲ្យទុក្ខទេ គឺមកតែពីអ្នកនោះឯងមិនធ្វើឲ្យខ្មែងតាត្រឹមត្រូវតាមសាសនា ។

បើតាមយោបល់ខ្ញុំថា "ខ្មែរយើងដែលជាអ្នកកាន់ព្រះពុទ្ធសាសនា មិនមែនសុទ្ធតែឆ្កួល, សុទ្ធតែល្ងង់ខ្លៅទាំងអស់គ្នាទេ មានអ្នកឧស្សាហ៍, អ្នកចេះដឹងដែរ មិនខុសគ្នាពីជាតិដទៃប៉ុន្មាន តាំងស្រុកខេសក៏មិនសុទ្ធតែអាប់ឧនដែរ មានចំរើនទៅដល់ថ្នាក់មហាអំណាចផងតាមកាលៈទេសៈ ទំនឹងតាមជាតុទឹកដីអាកាសធ្វើគ្នាជួយជាកំឡាំង" ។

ខ្ញុំសូមអធិប្បាយអំពីធម៌សន្តោស ។ ពាក្យថា "សន្តោស" ជាភាសាបាលី ប្រែថា "សេចក្តីត្រេកអរឬពេញចិត្ត ចំពោះវត្ថុអ្វី ។ ដែលជារបស់ខ្លួន" គឺថា បើមាន បើបានប៉ុន្មាន ក៏ស្កមចិត្តត្រឹមប៉ុណ្ណោះ មិនរវើរវាយ មិនព្រាតអាត្មិ ហួសហេតុឬហួសចំនង ។

តែងំពាក្យថា "បើមាន បើបានប៉ុន្មាន ក៏ស្កមចិត្តត្រឹមប៉ុណ្ណោះ" មិនមែនបង្គាប់ឲ្យឈប់ស្វែមលែងធ្វើការរកស៊ីទេ គឺត្រូវតែមានព្យាយាម

ចំរកទ្រព្យថ្នូតទៅទៀត ប្រៀបដូចសួម បើគេឲ្យប៉ុន្មានក៏សុខចិត្តទទួលយកប៉ុណ្ណោះមិនហ៊ានប្រកែក ហើយចំដើរទៅសួមគេខាងមុខទៀតមិនឈប់ ។ អ្នកមានទ្រព្យសម្បត្តិរបស់ខ្លួនស្រាប់ហើយ ហើយនៅតែប្រឹងប្រែងស្វែងរកឲ្យបានទ្រព្យសម្បត្តិថ្មីថែមមកទៀត ដោយគ្រឹមត្រូវតាមផ្លូវច្បាប់លោកនឹងច្បាប់ធម៌ ចាត់ជាអ្នកកាន់ធម៌សន្តោស ។ អ្នកណាកុហកបញ្ឆោតបោកប្រាស់លួចលាក់បំបាត់ យកទ្រព្យគេមកធ្វើជាទ្រព្យខ្លួន អ្នកនោះចាត់ជាមនុស្សគ្មានធម៌សន្តោស ។ ហេតុនោះព្រះពុទ្ធសាសនាបញ្ញត្តសីលសិក្ខាបទទី ២ (អទិន្នាទាន) កុំឲ្យលួចលាក់ទ្រព្យគេមានម្ចាស់នឹងចេសជាដើមនោះ ដើម្បីឲ្យកើតធម៌សន្តោស, មើលចុះ ការលួចប្លន់ឆក់គ្នាកើតមានជារាល់ថ្ងៃមិនដាច់ មិនមែនកើតមកពីហេតុអ្វីទេ កើតមានមកតែអំពីមនុស្សអ្នកឥតធម៌សន្តោសប៉ុណ្ណោះ ។ បើមនុស្សគ្រប់រូបមានសន្តោសហើយ អំពើចោរកម្មនោះក៏គ្មានដែរ ។ អ្នកហ៊ានសម្លាប់គេ, ហ៊ានលួចទ្រព្យគេ, ហ៊ានលួចប្តីប្រពន្ធគេ, ហ៊ាននិយាយកុហកគេ, ហ៊ានផឹកទឹកស្រវឹង មកពីគ្មានចិត្តសន្តោស ។ អ្នកឥតសន្តោសឈ្មោះថាធ្វើបាបខ្លួនឯង នឹងបៀតបៀនអ្នកដទៃឲ្យបានទុក្ខទោស រហូតដល់ធ្វើស្រុកទេសឲ្យអាប់ឱន ធ្វើសេដ្ឋកិច្ចជាតិឲ្យធ្លាក់ខ្សត់ខ្សោយ ។

ព្រះពុទ្ធសាសនាប្រដៅមនុស្សឲ្យកាន់ធម៌សន្តោស ដើម្បីធ្វើខ្លួនឯងនឹងអ្នកឯទៀតឲ្យបានសុខចំរើន ។ ព្រះពុទ្ធសាសនាប្រដៅមនុស្សឲ្យចេះស្វែងរកប្រយោជន៍កុងបច្ចុប្បន្ន ៤ យ៉ាងគឺ ៖

๑- ឲ្យចំរើនទ្រព្យសម្បត្តិឲ្យបានច្រើន (ទដ្ឋានសម្បទា);

๒- ឲ្យចេះថែរក្សាទ្រព្យខ្មុកឲ្យល្អ (អារក្ខសម្បទា);

๓ ឲ្យចេះចាយវាយទ្រព្យល្មមប្រមាណ (សមជីវិតា);

๔- ឲ្យសេពគប់មនុស្សល្អជាមិត្ត (កល្យាណមិត្តតា)។

ព្រះពុទ្ធសាសនាមានពាក្យប្រៀនប្រដៅមនុស្សច្រើនប្រការណាស់ មិនអាចនឹងយកមកពណ៌នាឲ្យចប់បានទេ។ ពាក្យប្រដៅទាំងនោះមានរបៀបប្លែកៗគ្នាទៅតាមភូមិតាមភេទ បើភេទគ្រហស្ថត្រូវការធម៌បែបនេះ បើភេទបព្វជិតត្រូវការធម៌បែបនោះ។ បើគ្រហស្ថចង់បានទ្រព្យសម្បត្តិ ឬយសសក្តិក្នុងបច្ចុប្បន្នជាតិនេះត្រូវការធម៌ដូច្នេះ បើគ្រហស្ថចង់បានស្ថានសួគ៌ ឬព្រះនិព្វានត្រូវការធម៌ដូច្នោះ គោលធម៌ទាំងនោះមានសេចក្តីល្អិតពិស្តារនៅក្នុងព្រះសុត្តន្តបិដក។

ព្រះពុទ្ធសាសនាតែងតែលើកតំកើងសរសើរគុណនៃសេចក្តីព្យាយាមជាខ្លាំងផុតថា "មនុស្សនឹងធ្វើឲ្យផុតពីទុក្ខទោសទៅបានដោយសារតែសេចក្តីព្យាយាម" ហើយតិះដៀលសេចក្តីខ្ជិលច្រអូសថា "កុំធ្វើឲ្យជាមនុស្សចង្រៃលោក, មនុស្សមិនត្រូវប្រគល់ខ្លួនទាំងមូលឲ្យគេទេ, មនុស្សមិនត្រូវរស់នៅដោយសារគេទេ" ប៉ុណ្ណេះជាដើម។

ជនជាតិខ្មែរអ្នកកាន់ពុទ្ធសាស្ន៍ មិនចេះធ្លាក់ចាន់ទឹងព្រះពុទ្ធសាសនាទេ ទាំងកាន់ព្រះពុទ្ធសាសនាខ្លាំងក៏ដោយការស្លៀកពាក់ក្រាបក្រហមមិនចាប់មានគេមកបង្ខិតបង្ខំឡើយ ព្រោះមនុស្សប្រុសជាតិខ្មែរបានបួសរៀនសូត្រតែគ្រប់គ្នា ក្លាប់ចេះដឹងហើយថា ព្រះពុទ្ធសាសនាមានគោល

ប្បាប់យ៉ាងត្រឹមត្រូវណាស់ ព្រះពុទ្ធសាសនាជាឃ្លាំងសម្រាប់ផ្ទុកនូវ
គុណដ៏ប្រសើរគ្រប់មុខឥតខ្វះ ដូចជាប្បាប់រក្សាខ្លួន, ប្បាប់រក្សាគ្រួសារ,
ប្បាប់សម្រាប់មុខមន្ត្រីនឹងព្រះមហាក្សត្រ ។ ល ។

អ្នកពុទ្ធសាស្ត្រគ្រប់ជាតិ មិនតែជាតិខ្មែរមួយទេ តែងបានដឹងវត្ត
ចំណងរបស់ព្រះពុទ្ធសាសនាប្បាស់លាស់ហើយ បានជាទំនាក់ធម៌
សន្តោស ព្រោះយល់ឃើញថាធម៌សន្តោសនេះមានផលប្រយោជន៍
យ៉ាងធំធូលាយណាស់ អាចដឹកនាំខ្លួនឯងនឹងអ្នកឯទៀតឲ្យបានសុខ
សប្បាយ រហូតដល់ធ្វើស្រុកទេសឲ្យបានចំរើនរុងរឿង មិនឲ្យមានការ
ទាស់ទែងខ្វែងគំនិតគ្នា, មិនឲ្យបៀតបៀនគ្នា, មិនឲ្យមានសឹកសង្គ្រាម
កាប់សម្លាប់គ្នា ។ ចំណែកអ្នកបន្ទោសព្រះពុទ្ធសាសនាថាប្រដៅមនុស្សឲ្យ
ល្ងង់ជាដើមនោះ សូមជ្រាបថា មិនមែនព្រះពុទ្ធសាសនាប្រដៅមនុស្ស
ឲ្យល្ងង់ទេ គឺល្ងង់ពីមនុស្សដែលមិនព្រមរៀនធ្វើតាមឧត្តរបស់ព្រះ
ពុទ្ធសាសនានោះទេតើ ប្រៀបដូចគ្រូបង្ហាត់ឲ្យសិស្សចេះបានច្រើនបង្ហាត់
បង្រៀនណាស់ ប៉ុន្តែបើសិស្សមិនខំរៀនសោះ សិស្សនោះក៏ល្ងង់
ល្ងង់ខ្លៅល្ងៅ ដូច្នេះតើនឹងបន្ទោសគ្រូឯណាបាន ។

ពួកពុទ្ធសាស្ត្រមិនអាក់អន់ចិត្តនឹងអ្នកបន្ទោសទេ ព្រោះសំគាល់
ថា ពាក្យបន្ទោសនោះជាគុណជាប្រយោជន៍ អាចតាញឹកចិត្តអ្នកកាន់
ពុទ្ធសាសនាឲ្យតែតែងច្រើនកាន់ធម៌សន្តោសនោះខ្លួនឡើងទៀត ។

រឿងអ្នកគ្មានសន្តោស

ឧទាសនេះសូមនាំរឿងអ្នកគ្មានសន្តោសមកដំណាលថា កាលពីព្រៃឥន្ទាយ(១) មានបុរេហិតម្នាក់ឋិតក្នុងព្រះបាទពាវណសី ចេះមន្តបរិជ័យ គឺមន្តសំរាប់បញ្ចូលចិត្តអ្នកដទៃឲ្យនៅក្រោមអំណាចខ្លួន ។ ថ្ងៃមួយ បុរេហិតនោះចូលទៅក្នុងព្រៃស្ងាត់អង្គុយលើផែនថ្មមួយផ្ទាំងសូត្រមន្តចប់ហើយ ក្រោកដើរចេញមកវិញ ។ បានជាបុរេហិតមិនហ៊ានសូត្រមន្តក្នុងផ្ទះ ព្រោះខ្លាចក្រែងគេឮនឹងចេះចាំមន្តដូចខ្លួនដែរ ។ ក្នុងពេលដែលបុរេហិតកំពុងសូត្រមន្តនោះ មានចចកមួយដេកក្នុងរូងឈើក្បែរថ្មដែលបុរេហិតអង្គុយនោះ ស្តាប់ឮមន្តនោះហើយក៏ចាំបានទើបចូលទៅក្នុងព្រៃសូត្រភយមន្តនោះឡើង ហៅចចកជារាប់រយឲ្យមកប្រជុំគ្នា ក៏ធ្វើសត្វសត្វចតុប្បាទដូច ដំរី, សេះ, សីហៈ, ខ្លាធំ, ខ្លាឃ្មុំ, ទន្សឹមតជាដើម ឲ្យនៅក្នុងអំណាចខ្លួនបានហើយ ក៏តាំងខ្លួនឯងជាព្រះរាជាមាននាមថា "សត្វទាឋៈ" ព្រមទាំងអគ្គិសេកមេចចកមួយ ឲ្យធ្វើជាអគ្គមហេសី ហើយបង្គាប់ឲ្យដំរីពីរឈរទន្ទឹមគ្នា ឲ្យសីហៈមួយឡើងទៅឈរនៅលើខ្នងដំរីទាំងពីរនោះ ឯខ្លួនឯងនាំមហេសីឡើងទៅអង្គុយលើខ្នងរាជសីហ៍មួយជាន់ទៀត សោយរាជ្យជាស្តេចលើសត្វចតុប្បាទក្នុងព្រៃទាំងអស់ ។

ស្តេចចចកសត្វទាឋៈ សូម្បីមានឫទ្ធិអំណាចយសសក្តិធំដល់ម្ល៉ោះ ហើយក៏នៅតែមិនស្កប់ស្កល់ តើតថិត្តព្រហ្មនគាងកាចលោភចង់បាន

---

១) សត្វទាឋជាតក ទសមវគ្គ ទុកនិបាត ។

ហួសប្រមាណខុសច្បាប់លោកច្បាប់ធម៌ គឺគ្មានចិត្តសន្តោសសោះ ហ៊ាន
លើកកងទ័ពសត្វចតុប្បាទ មានចំនួនប្រមាណ ១២យោជន៍ ទៅតំបន់គរ
ពាកណាសី ប្រដងច្បាំងដណ្តើមយកពរជសម្បត្តិ ប្រើទូតឲ្យកាន់ពរជសាស្ត្
ចូលទៅថា ព្រះបាទពាកណាសីនឹងឲ្យពរជសម្បត្តិមកយើង ឬបេញច្បាំង
ជាមួយយើង ចូរប្រាប់ឲ្យឆាប់ ។ ពួកអ្នកនគរមានសេចក្តីតក់ស្លុត
ខ្លាំងណាស់ នាំគ្នាបិទទ្វារនគរជិតអស់ ។ បុរោហិតក្រាបទូលសម្តែ
ព្រះទ័យព្រះពរាជា ឱដ សម្តែងចិត្តអ្នកនគរទាំងឡាយឲ្យសប្បាយរីករាយ
ហើយទូលជានាថា ការច្បាំងនឹងស្តេចចចកស្រែចលើខ្លួន ទើបឡើង
ទៅលើប៉មស្រែកសួរចចកថា នែសត្វតាបៈសំឡាញ់ ! អ្នកនឹងធ្វើម្តេចបាយ
ដូចម្តេច ទើបដណ្តើមយកពរជសម្បត្តិបាន ។ ស្តេចចចកឆ្លើយថា យើង
នឹងឲ្យពរជសីហ៍ស្រែកសម្រែកឲ្យពួកមនុស្សបែកកែវត្រចៀកស្ងាប់ ហើយ
ដណ្តើមយកពរជសម្បត្តិ ។

បុរោហិតឮដូច្នោះហើយចុះពីប៉មមកវិញ ប្រើមនុស្សឲ្យប្រាប់ស្តេ
ប្រកាសប្រាប់អ្នកនគរថា អ្នកទាំងឡាយចូរយកសំឡីបុកត្រចៀកឲ្យជិត
គ្រប់គ្នា ។ អ្នកនគរក៏យកសំឡីបុកត្រចៀករៀងខ្លួន ព្រមទាំងបុកត្រចៀក
សត្វដើរបួនជើងដូចដំរី, សេះ, គោ, ក្របី, ឆ្កែ, ធ្នាដាដើម ។ លុះអ្នកស្រុក
បុកត្រចៀកស្រេចហើយ បុរោហិតឡើងទៅលើប៉មម្តងទៀត និយាយ
បញ្ជឹចិត្តចចកឲ្យខឹងថា នែរាជសត្វតាបៈមុខក្រាស់អើយ ! ឯងប្រើ
ពរជសីហ៍ឲ្យកំណរសម្តែងមិនបានទេ ព្រោះថាធម្មតាកេសរពរជសីហ៍ ជា
សត្វមានជាតិខ្ពង់ខ្ពស់ណាស់ មានដើងមុខនឹងដើងក្រោយដ៏ក្រហម កាល

ណាទីដើរតាមបង្គាប់របស់ចចកកញ្ជ្រោងដូចជាខ្ញុំឯងនេះកើត បើថាឯងគ្រាន់បើណាស់ ចេះប្រែកជសីហ៍ឲ្យស្រែកបាន ឯងចូរប្រែឲ្យស្រែកទៅមើល យើងឥតខ្វាចបន្តិចសោះ ។

ស្តេចសត្វគោះចចកឮដូច្នោះខឹងច្រឡោត កើតចិត្តមានះត្រហឹងស្រែកប្រកាសដល់បណ្តាពជសីហ៍ថា "សីហៈឯទៀតចូរឈប់សិន្ទុះ កុំអាលស្រែក ឲ្យតែពជសីហ៍ ๑ ដែលយើងអង្គុយលើខ្នងនេះស្រែកមុនគេ" ថាហើយក៏តន្ទ្រើដើងធាក់ខ្នងពជសីហ៍ ។

ពជសីហ៍ឮស្តេចចចកប្រាប់ដូច្នោះ ក៏ជាក់មាត់ខ្ជប់ទៅលើពោងដំរីហើយស្រែក ๓ ដងដោយធ្វើសម្រែកយ៉ាងឮខ្លាំងអស្ចារ្យ ដែលសត្វឯទៀតមិនអាចនឹងស្រែកគ្រាប់បាន ។ ឯដំរីកំយុតស្ងុតស្ងាំងកំងរ, ស្តេចសត្វគោះចចកនឹងមហេសីជាំក្បាលធ្លាក់ចុះពីខ្នងពជសីហ៍ ទៅនៅក្បែរដើងដំរី ។ ស្ទុះច្របោតជាន់ក្បាលចចកបែកស្លក់ខ្ចេចខ្ជឹស្ទាប់មួយរំពេច ។ បណ្តាដំរីទាំងឡាយកើតគិតក័យតក់ស្ងុតដាលច្បូលច្របល់ដេញព្រៃផ្សាចាក់គ្នាឯងស្ទាប់អស់ ។ ចំណែកសត្វចតុប្បាទទាំងពួងក្រៅពីពជសីហ៍ក៏ស្ទាប់ទៅទីនោះទាំងអស់ សល់តែហ្វូងពជសីហ៍នាំគ្នាបោលចូលព្រៃបាត់អស់ទៅ ។ សាច់សត្វដែលស្ទាប់មានចំនួនប្រមាណដល់ ๑๒ យោជន៍ក៏ទៅតវ្នាដេរដាសពាសពេញទីនោះ ។

បុរោហិតយើញដូច្នោះ ប្រើមនុស្សឲ្យវាយស្គរប្រកាសប្រាប់អ្នកនគរថា បើអ្នកណាត្រូវការសាច់សត្វ ចូរមកជីកជញ្ជួនយកទៅតាមចិត្តចុះ ។ មនុស្សទាំងពួងនាំគ្នាដឹកជញ្ជួនយកសាច់សត្វទៅបរិភោគរាល់ខ្នុ

សាច់ដែលសល់ក៏ធ្វើជាដើរតហាលឲ្យស្ងួតក្រៀម ទុកបរិភោគទៅថ្ងៃមុខ ទៀត ។ ហេតុនោះមានលោកខ្លះចូលចិត្តថា សាច់ដើរតកើតមានឡើងតាំងពីគ្រានោះជាដើមមក ។

រឿងនេះបានគតិ:

១— យើងមិនត្រូវមើលងាយការងារនឹងមនុស្សសត្វទេ ។

២— យើងមិនត្រូវចង់បានយសសក្តិធំហួសសមត្ថភាពខ្លួនទេ ។

៣— យើងមិនត្រូវចង់បានវត្ថុអ្វីៗដែលផុតនិស្ស័យខ្លួនប្រាថ្នាទេ ។

៤— យើងត្រូវមានចិត្តសន្តោស គឺត្រេកអរតែនឹងសម្បត្តិរបស់ខ្លួនតាមមានតាមបាន, ។

ព្រោះបើស្វែងរកទ្រព្យសម្បត្តិ ឬប្រាថ្នាបុណ្យសក្តិត្រូវតាមថ្នាក់ខ្លួននោះវមែងបានចំរើន ។ បើស្វែងរកទ្រព្យ ឬចង់បានបុណ្យសក្តិហួសថ្នាក់ខ្លួនហើយ វមែងវិនាសខូចលាភ ទ៍ឥយស់ចាស់ផង ខានបានលាភ ទឹងយសថ្មីទៀតផង ដូចជាស្តេចចចកសព្វទាប: ត្រូវខូចខាតលាភទឹងយសរហូតដល់ជីវិតខ្លួនដែលជាទីស្រឡាញ់យ៉ាងក្រៃលែង សមដូចសុភាសិតថា "ចចើងចង់លាភ វែងបាត់ធនៅ" ។

ប្រជុំធម៌ឧបាសក

ប្រស្នាស្បូរ-ធ្លើយ

ព្រះទេពសន្ដ កឹម-ឡ្ងី ចន្ទមង្គលោ

ក្រុមដំនុំព្រះត្រៃបិដកក្នុងពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

(ត-ចប់)

ស. សីលនេះ បង្ហាញផលឲ្យឃើញច្បាស់ដូចម្ដេច ដែលអាចឲ្យគេសំគាល់បានថា មនុស្សនេះជាអ្នកមានសីល មនុស្សនោះជាអ្នកមិនមានសីល ?

ឆ. បើបុគ្គលណាជាអ្នកមានសីល, សីលតែងធ្វើបុគ្គលនោះឲ្យជាអ្នកស្អាតកាយ ស្អាតវាចា ស្អាតចិត្ត, តែបើមិនស្អាតកាយវាចាចិត្តទេ ត្រូវដឹងថាមិនមែនជាអ្នកមានសីលឡើយ ។

ស. គួរឲ្យចង់ដឹងថា ចុះសីលដែលមិនទាន់កើតនៅឡើយ ហើយអាចកើតឡើងបាន ដែលកើតឡើងហើយក៏អាចតាំងនៅដោយបរិសុទ្ធ មិនមានបែកធ្លុះធ្លាយទៅវិញ តើដោយមានអ្វីជាហេតុ ?

ឆ. ដោយមានធម៌ ២ យ៉ាងជាហេតុ ។

ស. ធម៌ ២ យ៉ាងនោះអ្វីខ្លះ ?

ឆ. ធម៌ ២ យ៉ាងនោះ គឺ

១ — ហ៊ិរិ ធម្មជាតដែលអៀនខ្មាសចំពោះអំពើទុច្ចរិត

២_ ទុក្ខប្បៈ ធម្មជាតដែលខ្វាចតក់ស្ទុតចំពោះផលវិបាកនៃអំពើ ទុច្ចរិត ។

អធិប្បាយ : កាលបើធម៌ទាំង ២ យ៉ាងនេះ មាននៅក្នុងសន្តានៃបុគ្គលណាហើយ ទុកជាបុគ្គលនោះមិនទាន់បានរក្សាសីលនៅឡើយ ក៏នឹងរកអាក់ខានមិនតើត មុខជានឹងស្ទុះស្ទាំថ្វីងរក្សាត្រាតែបាន; កាលបើបានរក្សាសីលហើយ ទុកជាមានហេតុដល់ស្លាប់ជីវិតក៏មិនប្រថុយចំណាយនូវសីលរបស់ខ្លួនឡើយ ។

ស. សីលជាច់មានប៉ុន្មានយ៉ាង ?

ឆ. មាន ២ យ៉ាងគឺ ជាច់មានទោស ១ ជាច់មិនមានទោស ១ ។

ស. តួរឲ្យចង់ដឹងថា ជាច់មានទោសនោះដូចម្តេច ? ជាច់មិនមានទោសនោះដូចម្តេច ?

ឆ. ជាច់មានទោសនោះ គឺការប្រព្រឹត្តកន្លងឲ្យនូវសិក្ខាបទទាំងអស់ឬសិក្ខាបទណាមួយដែលជាលោកវជ្ជៈ (ទោសសម្រាប់លោក), ជាច់មិនមានទោសនោះ គឺស្លាប់ ។

ស. ឧបោសថ បើតំណត់ឈ្មោះតាមប្រភេទរបស់បុគ្គលអ្នករក្សាតើមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូរអធិប្បាយ !

ឆ. មាន ៣ យ៉ាងគឺ គោបាលឧបោសថ ១, និគ្គន្ថឧបោសថ ១, អរិយឧបោសថ ១ ។

អធិប្បាយ : អ្នករក្សាឧបោសថមិនសូវមានសេចក្តីត្រេកអរពេញចិត្តនឹងរក្សាប៉ុន្មាន ទន្ទឹងឲ្យតែអស់កាលឧបោសថ ហើយនឹងប្រព្រឹត្តធ្វើ

តិច្ចអ្វីផ្សេង ។ តាមសេចក្តីប្រថ្នាវបស់ខ្លួន ។ ចោសថនេះមានផលតិច មានអានិសង្សតិច ដូចជាអ្នកគង្វាលគោ ស៊ីឈ្នួលឃ្វាលគោឲ្យគេ គៀងគោ ៧ កាន់តែដែលមានទឹកនឹងស្មៅ អ្នកគង្វាលគោនោះ តែងទន្ទឹងឲ្យតែដល់ពេលល្ងាច ទើងាលគៀងគោមកប្រគល់ឲ្យម្ចាស់គោវិញ, រួចទារយកតែថ្លៃឈ្នួលប៉ុណ្ណោះ ឯត្រង់បញ្ហាគោរស (រសនៃគោ ៥ យ៉ាង) ក៏គត មានដឹងរស់ជាតិអ្វីបន្តិចបន្តួចសោះ; អ្នករក្សាទោសថបែបនេះ ហៅថា គោបាលទោសថ ។

ពួកនិគ្រន្ថរក្សាទោសថ រៀរអំពើអាក្រក់ មានកំណត់ទីឬកំណត់សត្វ ។ កំណត់ទីនោះ ដូចសត្វនៅទិសខាងកើតសម្លាប់មិនបាន, សត្វនៅទិសខាងលិចសម្លាប់បាន; កំណត់សត្វនោះ ដូចសម្លាប់មាន់បាន សម្លាប់ទាមិនបាន ដូច្នេះជាដើម; ចំណែកខាងបុគ្គលណារក្សាទោសថ កាន់យកតាមរបៀបពួកនិគ្រន្ថដូច្នេះ ហៅថា និគ្រន្ថទោសថ ។

ទោសថរបស់អរិយបុគ្គល ដែលលះកិលេសណាបានហើយ កិលេសនោះមិនត្រឡប់កើតឡើងវិញ លោករក្សាទោសថដើម្បីកំចាត់បង់នូវកិលេសដែលសែសសល់តាំងប៉ុន្មាននោះ ឲ្យស្អាតពីសន្តានរបស់លោក; អ្នករក្សាទោសថ កាន់របៀបអរិយបុគ្គល ដើម្បីនឹងកំចាត់បង់នូវកិលេសដូច្នេះ ហៅថា អរិយទោសថ ។

ស - ត្រង់ពាក្យថា បញ្ហគោរស (រសនៃគោ ៥ យ៉ាង) នោះគឺអ្វីខ្លះ?

๘ – ๑. ปีฐิ ទឹកដោះស្រស់, ๒. ទធិ ទឹកដោះជូរ, ๓. ឃតំ ទឹកដោះខ្ចាស, ๔. តក្កំ ទែឆន, ๕. ដោនីតំ(๑) ទឹកដោះខាប់ ។

ស – ពាក្យថា ឧបោសថកម្ម, ឧបោសថសីល, ឧបោសថកាល ទាំង ๓ នេះមានសេចក្តីផ្សេងគ្នាយ៉ាងណា ?

ឆ – មានសេចក្តីផ្សេងគ្នាយ៉ាងនេះ : ឧបោសថកម្មនោះ គឺជាអំពើដែលឧបាសកឧបាសិកា ត្រូវធ្វើក្នុងថ្ងៃឧបោសថ មានទទួលព្រះរតនត្រ័យជាដើម ឈ្មោះថា ឧបោសថកម្ម ។ ឧបោសថសីលនោះ គឺសីលដែលកើតអំពីការសមាទានអង្គសីលបទទាំង ៨ ក្នុងថ្ងៃឧបោសថនោះ ឈ្មោះថា ឧបោសថសីល ។ ឧបោសថកាលនោះ គឺថ្ងៃដែលត្រូវរក្សាអង្គឧបោសថ មានថ្ងៃ ៥ កើតជាដើម ក្នុង ១ ខែមានកាលដែលត្រូវរក្សាឧបោសថ ៨ ថ្ងៃ ដូច្នេះ ឈ្មោះថា ឧបោសថកាល ។

ស – ឧបោសថ ដែលឧបាសកឧបាសិកាគួរក្សាបាន តាមសេចក្តីពេញចិត្តរបស់ខ្លួន តើមានប៉ុន្មាន ? អ្វីខ្លះ ? ចូរអធិប្បាយ !

ឆ – មាន ๓ គឺ បកតិឧបោសថ ๑, បដិជាគរឧបោសថ ๑, ចាដិហារិយឧបោសថ ๑ ។

អធិប្បាយ : បកតិឧបោសថនោះក្នុង ๑ ខែមាន ๘ ថ្ងៃ គឺថ្ងៃបញ្ចមី, អដ្ឋមី, ចាតុទ្ទសី, បណ្ណរសី ទាន់ទ្វេគត ๔ ថ្ងៃ ទាន់រោចគត ๔ ថ្ងៃ ត្រូវជា ๘ ថ្ងៃ។ បដិជាគរឧបោសថនោះ កំណត់យកថ្ងៃអមទាន់ដើមទឹងទាន់ចុងនៃថ្ងៃ

---

๑ មានប្រើដោយច្រើនដង ឥតីតំ ។

បកតិឧបោសថ ហៅថា បដិជាគរឧបោសថ ។ បដិហារិយឧបោសថ
នោះ មានសេចក្តីអធិប្បាយក្នុងអដ្ឋកថាមនោរថបូរណីតម្ពីរអង្គុត្តរនិកាយ
ថា ឧបោសថដែលបុគ្គលត្រូវរក្សាជាប់ជានិច្ចអស់ ៣ ខែខាងក្នុងវស្សា គឺ
កំណត់ពីត្រឹមថ្ងៃចូលវស្សាទៅដល់ថ្ងៃបវារណាចេញវស្សា ហៅថា បាដិ-
ហារិយឧបោសថ ។ ម្យ៉ាងទៀត បើបុគ្គលមិនអាចនឹងរក្សាអស់កំណត់
កាល ៣ ខែខាងក្នុងវស្សានោះបានទេ ត្រូវរក្សាឲ្យបានជាប់ជានិច្ចអស់ ១
ខែកន្លះនៃបវារណាចាំងពីរ គឺកំណត់ពីត្រឹមថ្ងៃ ១ កេចខែអស្សុជទៅ
ដល់ថ្ងៃពេញបូណ៌មីខែកត្តិក, កាលបើបុគ្គលមិនអាចនឹងរក្សាអស់កំណត់
១ ខែកន្លះនៃបវារណាចាំងពីរនោះបានទេ ត្រូវរក្សាជាប់ជានិច្ចអស់
កាលត្រឹមតែ១ខែ ចាប់ដើមតាំងអំពីថ្ងៃបឋមបវារណាមក គឺកំណត់ពីត្រឹម
ថ្ងៃ ១ កេចទៅដល់ថ្ងៃ ១៤ កេចខែអស្សុជ ក៏បាន ហៅថា បាដិហារិយ-
ឧបោសថដែរ ។

ន័យមួយទៀត ក្នុងអដ្ឋកថាបរមត្ថជោតិកា គម្ពីរខុទ្ទកនិកាយ សុត្ត-
និបាត លោកវិនិច្ឆ័យត្រង់ពាក្យថា បាដិហារិយឧបោសថនេះ មាន
កំណត់កាល ៥ ខែ គឺខែអាសាធពេញ ១ ខែ, ខាងក្នុងវស្សា ៣ ខែ, ខែ
កត្តិកពេញ ១ ខែ; ចាំង ៥ ខែនេះលោកហៅថា កាលជាទីរក្សាទ្វារបាដិ-
ហារិយឧបោសថ ។ មានអាចារ្យដ៏ខ្លះទៀតពោលថា មានត្រឹមតែ ៣ ខែ
គឺ ខែអាសាធ, កត្តិក, ផល្គុន, ចាំង ៣ ខែនេះ ហៅថា កាលជាទីរក្សា
ទ្វារបាដិហារិយឧបោសថ ។ មានអាចារ្យមួយពួកទៀតពោលថា ថ្ងៃសែស
គូ គឺថ្ងៃ ១៣ កើត ១៣ កេច, ថ្ងៃ ១ កើត ១ កេច, ថ្ងៃ ៧ កើត ៧ កេច,

ថ្ងៃ ៨ កើត ៩ រោច គ្រែបច្ចូសំ (ចាំងជុំណ្ហបក្ស "ខាងខ្មែត" ចាំងកាឡបក្ស "ខាងរនោច") ដោយអំណាចថ្ងៃខាងដើមនឹងខាងចុងនៃថ្ងៃឧបោសថ ហៅថា កាលជាទីរក្សាខ្លួនជាដំហាយឧបោសថ។ ពាក្យដែលបានពោលមកចាំងប៉ុន្មានអន្លើនោះ បើបុគ្គលពេញចិត្តពាក្យណាគប្បីកាន់យកតាមពាក្យនោះចុះ ប៉ុន្តែបុគ្គលអ្នកចង់បានបុណ្យ គួរតែធ្វើឲ្យបានសព្វគ្រប់ តាមន័យនោះ។ ។

ស.- ចាំដំហាយឧបោសថ ត្រូវរក្សាសីលប៉ុន្មាន?

ឆ.- ត្រូវរក្សាសីល ៨ ប៉ុន្តែត្រូវរក្សាជាប់ជានិច្ច តាមកាលកំណត់ ដូចបានអធិប្បាយរួចមកហើយ ។

ស.- ចាំដំហាយ ប្រែថាដូចម្តេច? ហើយមានសេចក្តីវិសេសជាងឧបោសថណាខ្លះ?

ឆ.- ប្រែថា: ធម្មជាតិនាំចេញនូវធម៌ជាសត្រូវ ឬថាកំចាត់បង់នូវធម៌ជាសត្រូវឲ្យអស់ពីខ្លួនសន្តាន, មានសេចក្តីវិសេសជាងបកតិឧបោសថនឹងបដិជាគរឧបោសថ ។

៩- វិធីដែលឧបាសកឧបាសិកាត្រូវរក្សាសីល

ស.- កាលបើដល់ថ្ងៃដឹតនឹងរក្សាខ្លួនឧបោសថសីល គឺថ្ងៃមុន ១ ថ្ងៃដែលដឹតប្រាកដថាត្រឹតឡើងនឹងរក្សាខ្លួនឧបោសថសីលនេះ តើឧបាសកឧបាសិកាគប្បីប្រតិបត្តិដូចម្តេចខ្លះ? ។

ឆ.- ឧបាសកឧបាសិកា គប្បីប្រតិបត្តិដូចខ្លះគឺ ត្រូវចាត់ចែងការងារដែលគួរនឹងចាត់ចែង មានអាហារជាដើម ឲ្យហើយក្នុងថ្ងៃនោះមុន តែកុំ

ចាត់ចែងការងារដែលមិនប្រកបដោយធម៌ ដែលខ្លួនជាឧបាសកឧបាសិកា មិនគួរនឹងចាត់ចែងនោះឡើយ ។

ស – លុះដល់ព្រឹកឡើងជាថ្ងៃឧបោសថកាល ត្រូវរក្សាទុកឧបោសថសីល តើឧបាសកឧបាសិកាត្រូវប្រតិបត្តិដូចម្តេចខ្លះទៀត ? ។

ឆ – ឧបាសកឧបាសិកា ត្រូវភ្ញាក់ក្រោកឡើងអំពីព្រលឹម ហើយពុំមានដំរេះធ្វេញឱ្យស្អាត រួចហើយសមាទានឧបោសថសីលក្នុងវេលានោះភ្លាម តែបើសមាទានព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់ទុកឧបោសថកាល គឺកាលជាទីរក្សាទុកឧបោសថសីលក្នុង ១ ថ្ងៃ ១ យប់នោះ ដោយបញ្ចេញវាចាអធិដ្ឋានថា: អជ្ជុឧបោសថោ ឥមញ្ច រត្តិំ ឥមញ្ច ទិវសំ ឧបោសថិកោ ភវិស្សាមិ (ប្រែថា) "ថ្ងៃនេះ ជាថ្ងៃត្រូវរក្សាទុកឧបោសថសីល ខ្លួនអាត្មាអញនឹងជាអ្នករក្សាទុកឧបោសថសីលអស់ថ្ងៃនេះនឹងយប់នេះ" ។ លុះអធិដ្ឋានកំណត់កាលដូច្នេះរួចហើយ ត្រូវតាំងវិរតិចេតនាវៀរចាកសីលភេទ គឺហេតុដែលជាទីខំណាយនៃសីលនោះៗ ឲ្យគ្រប់សិក្ខាបទទាំង ៨, តអំពីពេលនោះមក កំគប្បីសមាទានទុកឧបោសថសីលអំពីបុគ្គលដទៃមានកិក្ខុជាដើម តាមកាលដ៏គួរបុះ បើពុំជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើងប្រមាណពេញពន្ធឹងទេ ទើបបានសមាទាន ក៏ឈ្មោះថាបានសមាទានដោយប្រពៃ ឈ្មោះថាបានរក្សាទុកឧបោសថសីលពេញកាលកំណត់ ១ ថ្ងៃ ១ យប់ ដោយបរិបូណ៌មិនខ្វះខាត ទាំងវិរតិចេតនាសោតក៏កើតក្នុងគ្រប់គ្រាន់ក្នុងសន្តាន ក៏ឆ្ងាយផលានិសង្សច្រើនដូចគ្នា ។

ស– ពុទ្ធាសកពុទ្ធាសិកា ដែលបានទទួលសមាទានខ្សែពុទ្ធោសថ-សីលក្នុងថ្ងៃពុទ្ធោសថកាលនោះរួចហើយ បើចង់ឲ្យបានផលានិសង្សក្នុងថ្ងៃនោះយប់នោះ ត្រូវប្រែតបត្តិដូចម្តេច? ។

ឆ– ត្រូវប្រែតបត្តិ គឺសង្ឃមកាយទន្ធឆ្លងក៏ថា ឲ្យបានសមគួរវៀរបរយតាមពុទ្ធានុញ្ញាតពុកមក ។

ស– ការសង្ឃមកាយទន្ធឆ្លងក៏ថា ឲ្យបានសមគួរនោះ តើត្រូវធ្វើដូចម្តេច?

ឆ– ការដែលសង្ឃមកាយឲ្យបានសមគួរនោះ គឺត្រូវលះបង់ខ្សែការងារទាំងពួយ មានការក្លែវស្រែទំនប់ចំការជាដើម ដែលជាការនាំឲ្យសៅហ្មងដល់ព្រហ្មចរិយសីល ដែលខ្លួនបានទទួលសមាទានហើយក្នុងថ្ងៃនោះយប់នោះ; ឯការសង្ឃមកចាឲ្យបានសមគួរនោះ គឺត្រូវលះបង់ខ្សែតិរច្ឆានកថា ๒๘ យ៉ាងចេញ ហើយគួរពោលខ្សែពាក្យដែលនាំឲ្យកើតសទ្ធៃគ ឬពោលអំពីកថាវត្ថុ ๑๐ ប្រការវិញ យ៉ាងនេះឈ្មោះថាសង្ឃមកាយទន្ធឆ្លងក៏ថាឲ្យបានសមគួរវៀរបរយតាមពុទ្ធានុញ្ញាត ។

ស– ពាក្យថា ពិរ្ហាឆកបិ នោះប្រែថាដូចម្តេច? ដែលថាមាន ๒๘ យ៉ាងនោះតើអ្វីខ្លះ?

ឆ– ប្រែថា "សំដីឥតប្រយោជន៍ ឬសំដីដែលនិយាយទទឹងផ្លូវនឹងសំដីដែលមានប្រយោជន៍" ឬប្រែថា "សំដីដែលទទឹងកន្លងដំណើរដែលទៅកាន់ឋានសួគ៌ ឋាននិព្វាន" ដែលថាមាន ๒๘(๑) យ៉ាងនោះគឺ

---

๑ ន័យខ្លះថា មាន ๒๗ យ៉ាង, ខ្លះថាមាន ๓๒ យ៉ាង ។

๑_ រាជកថា និយាយអំពីស្តេច

๒_ ចោរកថា និយាយអំពីចោរ

๓_ មហាមត្តកថា និយាយអំពីអមាត្យធំ ។

๔_ សេនាកថា និយាយអំពីសេនាគាហន

๕_ ភយកថា និយាយអំពីហេតុដែលនាំឲ្យភ័យ

๖_ យុទ្ធកថា និយាយអំពីចម្បាំង

๗_ អន្នកថា និយាយអំពីបាយម្ហូបចំណី

๘_ បានកថា និយាយអំពីទឹកផឹក

๙_ វត្ថុកថា និយាយអំពីសំពត់

๑๐_ សយនកថា និយាយអំពីទំដេក

๑๑_ មាលាកថា និយាយអំពីផ្កាកម្រង

๑๒_ គន្ធកថា និយាយអំពីគ្រឿងក្រអូប

๑๓_ ញាតិកថា និយាយអំពីញាតិ

๑๔_ យានកថា និយាយអំពីយាន (គ្រឿងជំនិះ)

๑๕_ គាមកថា និយាយអំពីស្រុក

๑๖_ និគមកថា និយាយអំពីនិគម

๑๗_ នគរកថា និយាយអំពីនគរ

๑๘- ជនបទកថា និយាយអំពីជនបទ

๑๙- ឥត្ថីកថា និយាយអំពីស្ត្រី

๒๐- បុរិសកថា និយាយអំពីបុរស

๒๑- សូរកថា និយាយអំពីជនដែលក្លៀវក្លា

๒๒- វិសិខាកថា និយាយអំពីច្រកផ្លូវ ឬផ្លូវបែក

๒๓- កុម្ភដ្ឋានកថា និយាយអំពីកំពង់ទឹក

๒๔- បុព្វបេតកថា និយាយអំពីញាតិដែលបែកហាន៎ទៅ
កាន់បរលោកហើយ

๒๕- នានត្តកថា និយាយអំពីពាក្យដែលឥតប្រយោជន៍
មានសភាពផ្សេងៗ

๒๖- លោកក្ខាយិកកថា និយាយអំពីលោក

๒๗- សមុទ្ទក្ខាយិកកថា និយាយអំពីរឿងដីកសមុទ្រ

๒๘- ឥតិ ភវាភវកថា និយាយអំពីសេចក្តីចំរើននឹងមិនចំរើន
ដូច្នេះខ្លះ ដូច្នោះខ្លះ ។

ស- ពាក្យថា កថាវត្ថុ នោះប្រែថា ដូចម្តេច? ដែលថា ๑๐ ប្រការនោះ តើអ្វីខ្លះ?

ឆ- ប្រែថា "ពាក្យឬរឿងដែលគួរនិយាយ"; ដែលថា ๑๐ ប្រការនោះគឺ

๑ – អប្បិច្ឆកថា និយាយនាំឲ្យមានសេចក្តីប្រាថ្នាតិច

๒ – សន្តុដ្ឋិកថា និយាយនាំឲ្យមានសេចក្តីសន្តោស

๓ – បវិវេកកថា និយាយនាំឲ្យស្ងាត់កាយស្ងាត់ចិត្ត

๔ – អសំសគ្គកថា និយាយនាំមិនឲ្យជាប់ដំណាក់ដោយប័ក្សពួក

๕ – វីរិយារម្ភកថា និយាយដឹកនាំឲ្យមានព្យាយាម

๖ – សីលកថា និយាយដឹកនាំឲ្យតាំងនៅក្នុងសីល

๗ – សមាធិកថា និយាយដឹកនាំឲ្យមានសមាធិចិត្ត

๘ – បញ្ញាកថា និយាយដឹកនាំឲ្យកើតប្រាជ្ញា

๙ – វិមុត្តិកថា និយាយនាំឆ្ពោះឲ្យចិត្តផុតចាកកិលេស

๑๐ – វិមុត្តិញាណទស្សនកថា និយាយដឹកនាំឲ្យកើតសេចក្តីដឹងនូវសេចក្តីយល់ឃើញក្នុងវិមុត្តិ ។

ស. ឧបាសកឧបាសិកា បើបានសង្ឃមកាយវាចាសមគួរហើយក្នុងថ្ងៃនោះយប់នោះ ត្រូវធ្វើអ្វីខ្លះ?

ឆ. ត្រូវស្តាប់ធម៌ទេសនា ឬធ្វើនូវធម្មសាកច្ឆា គឺសាកសួរអំពីធម៌អាថ៌ ។ បើមិនបានស្តាប់ធម៌ទេ ត្រូវសង្រួមចិត្តគឺតាំងចំរើនវិកម្មដ្ឋានក្នុងសមថកម្មដ្ឋាន ๔๐ ប្រការ ត្រង់កម្មដ្ឋានណាមួយក៏បាន ប៉ុន្តែមុនដំបូង ត្រូវចំរើនមូលកម្មដ្ឋានគឺពុទ្ធានុស្សតិកម្មដ្ឋានជាមុនសិន ហើយសឹមឲ្យចំរើនវិកម្មដ្ឋានឯទៀតតទៅ តាមគួរដល់អធ្យាស្រ័យ ។

ស– មុនទឹងចំកើនទូវកម្មជានោះ ត្រូវពិចារណាអ្វីខ្លះ? ចូរ
អធិប្បាយឲ្យហូរហែមកផង?

ឆ– ត្រូវពិចារណាទូវទោសនៃកាមគុណឲ្យឃើញច្បាស់ថា រូប
សំឡេង ក្លិន រស សម្ផស្ស ទាំង៥នេះ ជាបេះរមែងឲ្យកើតទោស
ទុក្ខផ្សេង។ ឬនឹងពិចារណាទូវខន្ធ៥ ឲ្យឃើញថាជា អនិច្ចំ ទុក្ខំ អនត្តា
គឺពិចារណាឲ្យឃើញថា រូបក្ខន្ធនេះ មិនទៀងមិនតាំងនៅបិតរេរ តែង
វិនាសទៅដោយហេតុផ្សេង។ មានវិនាសដោយចំហាយក្តៅនឹងត្រជាក់
ជាដើម, រូបនេះរមែងនាំមកទូវសេចក្តីទុក្ខព្រួយ, រូបនេះរមែងបែកធ្លាយ
ជាធម្មតា រកខ្ទឹមសារគ្មានសោះឡើយ ទាំងវេទនាខន្ធ សញ្ញាខន្ធ
សង្ខារក្ខន្ធសោតទៀត ក៏ជាអនិច្ចំ ទុក្ខំ អនត្តា ដូចគ្នានឹងរូបក្ខន្ធនេះដែរ។
ម្យ៉ាងទៀត ត្រូវពិចារណាធម៌ជាទីសង្វេគថា ជនទាំងឡាយដែលកើតមក
កន្លងលោកនេះ រកទីពឹងពំនាក់ឲ្យមាំមួនពុំមានទេ សុទ្ធតែជាអ្នកកំព្រា
ម្នាក់ឯង មានមាតាបិតា ស្វាមីបុត្រភរិយា មិត្រសម្លាញ់ ទ្រព្យសម្បត្តិ
ទាំងប៉ុន្មានក៏ទុកដូចជាគ្មាន ព្រោះថាជនទាំងឡាយមានមាតាបិតាជាដើម
នោះ មិនអាចនឹងចែកទូវសេចក្តីសុខទុក្ខឲ្យដល់គ្នានឹងគ្នាបានឡើយ, មិន
អាចនឹងជួយការពារ ឬជួនដំណើរគ្នានៅកន្លងកាលដែលមរណៈស្ត្រាមមកដល់ចំពោះរូបទីមួយ។ នោះបានឡើយ; ពេលដែលមរណៈស្ត្រាមមកដល់ខ្លួន សត្វទាំងអស់ក៏ជាអ្នកឥតមានគ្នាគ្នាទេ បើប្រទះបានសេចក្តីទុក្ខដែលកើតអំពីអកុសលកម្ម ដែលខ្លួនធ្លាប់ធ្វើហ័យកន្លងកាលមុនស្លាប់
នោះ ក៏ត្រូវតែទទួលយកទូវសេចក្តីទុក្ខនោះដោយធាវហ៊ាស ឬបើប្រទះ

ជាន់សេចក្តីសុខដែលជាផលនៃកុសលកម្ម ដែលខ្លួនបានធ្វើល្អទុកមក ហើយក្នុងពេលមុនស្លាប់នោះ ក៏ត្រូវខ្លួលយកនូវសេចក្តីសុខនោះចំពោះតែខ្លួនមួយប៉ុណ្ណោះ គោះខ្លួនមានទ្រព្យសម្បត្តិក្នុងលោកនេះតិចច្រើនប៉ុន្មាន។ ក៏មិនអាចនឹងនាំយកទៅជាមួយបាន ។ ឯបាសកឧបាសិកា កាលបើបានពិចារណាឃើញយ៉ាងនេះហើយ ក៏នឹងមានចិត្តនន់ទៅកាន់ពុទ្ធគុណធម្មគុណសង្ឃគុណ បើឃើញថាចិត្តរបស់ខ្លួននន់ទៅកាន់គុណព្រះរត្នត្រ័យហើយ គប្បីបរិកម្មនូវព្រះនាមរបស់ព្រះសម្ពុទ្ធជាម្ចាស់ទាំង ១០ ព្រះនាម មានអរហំជាដើម ឲ្យបានតាំងសេចក្តីជ្រះថ្លាក្នុងព្រះនាមទាំងនោះ ហើយគប្បីលើកឡើងនូវព្រះនាមនោះមកភាវនា គឺថាយកគុណទាំងនោះមកតាំងតែក្នុងចិត្តម្យ៉ាង មិនបាច់បន្លឺសំឡេងឲ្យលាន់ឮឡើយ ។

ស– វិធីដែលនឹងភាវនាពុទ្ធគុណនោះមានប៉ុន្មានយ៉ាង? អ្វីខ្លះ?

ឆ– មាន ៣ យ៉ាងគឺ

១– ឲ្យភាវនាថា ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។ល។ពុទ្ធោ ភគវា ហើយត្រឡប់មកតាំងភាវនាពីខាងដើមទៅវិញ ភាវនាយ៉ាងនេះ ទោះ១វេយចប់ ឬ ១ ខាន់ចប់ក៏បាន ។

២– ទំនងភាវនាថា សោ ភគវា ឥតិបិ អរហំ, សោ ភគវា ឥតិបិ សម្មាសម្ពុទ្ធោ ។ល។ សោ ភគវា ឥតិបិ ភគវា ហើយត្រឡប់មកភាវនាតាំងពីខាងដើមទៅវិញ យ៉ាងនេះបាន ១ វេយចប់ឬ ១ ខាន់ចប់ក៏បាន ។

៣– ទំនងភាវនាតែ ១ បទ។ ដូចភាវនាថា អរហំ។ ឬថា សម្មា-

សម្ពុទ្ធោ ។ ល ។ ពុទ្ធោ ឬថា ភគវាំ ដូច្នេះក៏បាន ការនាយ៉ាងនេះកន្លះបទ ខ្លះ បាន ១ រយចប់ក្តី ១ ពាន់ចប់ក្តីក៏បាន តាមពេញចិត្តរបស់ខ្លួន តែត្រូវការនាឲ្យដឹងសេចក្តីកន្លងពុទ្ធគុណនោះផង ។

ស– ចុះទីសេនាសនៈដែលឧបាសកឧបាសិកា ទើបអង្គុយចំរើនខ្លះ គប្បីវែកទីដូចម្តេច? គប្បីកែពេលដូចម្តេច?

ឆ– គប្បីវែកទីឲ្យសមគួរ ឲ្យស្ងាត់ ទាំងពេលសោតក៏ត្រូវឲ្យស្ងប់ស្ងាត់ចាក់សូរសៀងសម្លេងទាំងពួងកុំឲ្យលាន់ឮគឹកកងដើម្បីនឹងធ្វើអារម្មណ៍ឲ្យតាំងនៅនឹងល្អ ។

ស– ការបើឧបាសកឧបាសិកា បាននាការពារដល់ពុទ្ធគុណដូច្នេះហើយ តើនឹងអាចឲ្យកើតផលអ្វី?

ឆ– អាចឲ្យកើតត្រឹមបីតិ ៥ យ៉ាងណាមួយ ។

ស– បីតិ ប្រែថាដូចម្តេច? ដែលថាមាន ៥ យ៉ាងនោះអ្វីខ្លះ?

ឆ– ប្រែថា «សេចក្តីត្រេកអរ ឬសេចក្តីរីករាយផ្អែមក្នុងចិត្ត; ដែលថាមាន ៥ យ៉ាងនោះគឺ

๑– ខុទ្ទកា បីតិ សេចក្តីត្រេកអរព្រឹកមែនព្រឹកស្បែក;

๒– ខណិកា បីតិ សេចក្តីត្រេកអរប្រាកដដូចជាផ្លេកបន្ទោរ

๓– ឱក្កន្តិកា បីតិ សេចក្តីត្រេកអរមានអាការប្រាកដ ដូចជារលកទឹកបោកផ្ចង់មកត្រូវ;

๔– ឧព្វេគ្គា បីតិ សេចក្តីត្រេកអរខ្លាំង អាចញាំងកាយឲ្យអណ្តែតទៅបាន;

๕— ผิรณา ปีติ សេចក្តីត្រេកអរធ្វើឲ្យត្រជាក់ជ្រួតជ្រាបខ្លួនៗ
កាយ ។

ស— បីតិចំនួន ๕ យ៉ាងនេះ បីតិណាមួយដែលកើតឡើងដោយ
អំណាចការនាំចំរើនខ្លួនវិបុលគុណ ដែលជាមូលកម្មដ្ឋានយ៉ាងនេះហើយ តើ
នឹងបានផលានិសង្សអាចឲ្យសម្រេចគុណវិសេសអ្វីតទៅទៀត ? ព្រោះអ្វី ?

ឆ— អាចឲ្យបានសម្រេចតែត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាច
នឹងឲ្យសម្រេចដល់អប្បនាឈាន គឺបឋមជ្ឈានបានឡើយ ព្រោះពុទ្ធ-
គុណនេះ ជាគុណជ្រាលជ្រៅអនេកអនន្តពន់ពេកណាស់ អ្នកដែល
ចំរើននោះមិនអាចនឹងពិចារណាឲ្យឃាប់សព្វគ្រប់ទៅបាន ។

๑๐— វិបត្តិនៃឧបាសក

ស— វិបត្តិ (ធម្មជាតិដល់នូវសេចក្តីវិនាស, សេចក្តីអន្តរាយ)
របស់ឧបាសក តើដូចម្តេច ?

ឆ— សីលវិបត្តិ សេចក្តីវិនាសនៃសីល នឹង អាជីវវិបត្តិ សេចក្តី
វិនាសនៃការចិញ្ចឹមជីវិតត្រឹមត្រូវ នេះហៅថា វិបត្តិរបស់ឧបាសក ។
ន័យមួយទៀត ការមិនជឿគុណព្រះរត្នត្រ័យ ๑, ការដែលទ្រុស្តសីល ๑,
ការជឿមង្គលក្បត់ផ្លូវ ๑, សេចក្តីប្រកាន់ជឿមង្គល មានទិដ្ឋមង្គល
ជាដើម មិនប្រកាន់ជឿកម្ម ๑, ការស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅ
ពុទ្ធសាសនានេះ ហើយធ្វើនូវកុសលកម្មមានទានជាដើម ចំពោះ
ទក្ខិណេយ្យបុគ្គលខាងក្រៅសាសនានោះជាមុនចង្អុរ ๑, ធម៌ចំនួន ๕
យ៉ាងនេះ ក៏ហៅថា វិបត្តិរបស់ឧបាសកដែរ ។

ស– បើឧបាសកណា ប្រកបដោយវិបត្តិដូចបានពោលមកហើយ នេះ ឧបាសកនោះ ឲ្យឈ្មោះថាជាឧបាសកអ្វី ?

ឆ– ឲ្យឈ្មោះថា ឧបាសកបណ្ឌាល គឺឧបាសក ដូចជាមនុស្ស បណ្ឌាល ប្តូថាឧបាសកគាចចំពោះសាសនាផង ឈ្មោះថា ឧបាសកប្បជ្ជមលៈ ឧបាសកជាមន្ទិលចំពោះសាសនាផង ឈ្មោះថា ឧបាសកប្បជ្ជកិដ្ឋៈ ឧបាសកលាមកអាក្រក់ជាទីបំផុត ឬឧបាសកដែលអ្នកច្រាជ្រមាំងឲ្យលោកតិះដៀលផង ។

๑๑– សម្បត្តិនៃឧបាសក

ស– សម្បត្តិ (ការបរិបូណ៌ដោយសេចក្តីល្អ) របស់ឧបាសក តើដូចម្តេច ?

ឆ– សីលសម្បទា ការបរិបូណ៌ដោយសីល អាជីវសម្បទា ការបរិបូណ៌ដោយការចិញ្ចឹមជីវិតត្រឹមត្រូវ ហៅថា សម្បត្តិនៃឧបាសក ។

ន័យមួយទៀត ធម៌៤យ៉ាងគឺ សទ្ធោ ហោតិ ឧបាសកមានសេចក្តីជឿជាក់ច្បាស់ក្នុងព្រះរត្នត្រ័យ ๑ សីលវា ហោតិ ឧបាសកមានសីល ๑ ន កោតុហលមង្គលិកោ ហោតិ ឧបាសកមិនប្រកបដោយមង្គលភ្ជាក់ផ្អើល ๑ កម្មំ បដ្ឋេតិ នោ មង្គលំ ឧបាសកប្រកាន់ជឿនូវកម្ម មិនប្រកាន់ជឿនូវមង្គល ๑ ន ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅពុទ្ធសាសនាឡើយ ហើយធ្វើនូវកុសលកម្មមានទានជា

ដើមចំពោះខ្ញុំណេយ្យបុគ្គលក្នុងពុទ្ធសាសនានេះជាមុនបង្អស់ ១ ចាំង ៥ នេះ ក៏ហៅថា សម្បត្តិរបស់ឧបាសកដែរ ។

ស - ឧបាសកណា ប្រកបដោយសម្បត្តិ ៥ យ៉ាងនេះហើយ ឧបាសកនោះនឹងឲ្យឈ្មោះថា ឧបាសកអ្វីខ្លះ ?

ឆ - ឲ្យឈ្មោះថា ឧបាសកវិជ្ជមានៈ ឧបាសកដូចជាវត្ថុមានតែវ ជាដើមធង ឈ្មោះថា ឧបាសកបទុមៈ ឧបាសកដូចជាផ្កាឈូកក្រហម ធង ឈ្មោះថា ឧបាសកបុណ្ឌរីកៈ ឧបាសកដូចជាផ្កាឈូកសធង ។

ស - ធម៌សម្រាប់ពួកឧបាសក ឧបាសិការក្សានឹងប្រតិបត្តិ មានចំនួនតែត្រឹមដែលបានរៀបរៀងមកប៉ុណ្ណោះទេ ឬមានផ្សេងពីនេះទៀត ?

ឆ - មិនមែនមានត្រឹមតែប៉ុណ្ណោះទេ មានច្រើនជាងនេះជាអនេក ដូចគុណរបស់ឧបាសក ១០ យ៉ាង, កម្មបថ ១០, កម្មបថ ៤០ នឹងធម៌ដទៃ ។ ទៀតជាច្រើន តែកង់ទីនេះ មិនបានដកស្រង់មករៀបរៀងឲ្យសព្វគ្រប់ទេ សូមមើលបន្ថែមឯទៀតជាជំនួយផងចុះ ។

ចប់ ប្រជុំធម៌ឧបាសក ដោយសង្ខេប

សុភាសិតដែលគួរពិចារណា

ឆេះមិនឈ្នះចង់	ព្រងើយមិនឈ្នះខាល់
កាល់មិនឈ្នះតិត	ឫទ្ធិមិនឈ្នះភោគ
លោភមិនឈ្នះលាភ	ខាញមិនឈ្នះទៅ
នៅមិនឈ្នះនាង	រាងមិនឈ្នះភាគ
លាភមិនឈ្នះលោភ	ស្មោកមិនឈ្នះល្មម
ព្រមមិនឈ្នះព្រៃង	លេងមិនឈ្នះមែន ។

ព្រះមន្ត្រីឧត្តមលេខា ជា - ប៉ូរ រៀបរៀង

—▪—

កាព្យពាក្យ ៩

ផ្តុំហត្ថាជាតំណាងតាងបទុម
ចិត្តបរិសុទ្ធលំអុតកាយថ្លាយបង្គំ
ដល់ច្រៃជុំវត្ថុត្តមថ្លៃវិត្រៃរតនា ។
សូមតេជះព្រះវិជិតឫទ្ធិបញ្ចន់
ជួយតម្រង់ផ្តង់តម្រែវផ្លែវពាចា
សូមបរិយាយកាយសេចក្តីពីសុភ
ដែលព្រះពុទ្ធុម្មជលោកាខាងឆាត់ ។
មិនឲ្យសេពគ្រែបជញ្ជក់ភ្លក្សសោះឡើយ
តែធឹកហើយស្បើយបញ្ចាក្ខាពាក្យមាត់
ឫកក្តើងក្អាងយ៉ាងគ្រាន់បើដើរសើយលាត់
ខាងធាក់ខាត់ស្តាត់ឃ្លានពាន្នគ្នានគេដល់ ។
ចោលក្តើខ្មាសអាសអាភាសពាសកូមិហាន
ញាតិសន្តានបានខុកខ្ពុយជួយវល់
ស្តីរំលឹកនឹករំលែកចែករយោបល់
ឲ្យគិតដល់ផលចង្រៃនៃសុភ ។
តឡប់ជាភាវកខឹងនឹងព្រៀងលាន

ដែលគេមានសន្ដានចិត្តស្និទ្ធមេត្តា
ជួយជាស់គ្រឿនក្រែនស្មារតីនៃអាត្មា
ដើរខុសមគ្គឆ្ងាត់កាយកាវហ៊ានដៃ ។
ចូលចិត្តស្ងើគេអ្នកអែបអបប្រែបបញ្ឆោរ
ឡើងជំនោរជោរចំណាប់ធាប់ត្រូវក្រែ
បបួលក្មែមគែមភេហារន្ធារដើងដៃ
ចាយកាសប្ញាក់ហាក់វិស័យសេដ្ឋីធំ ។
អស់ប្ញាក់ហើយស្បើយសំដីស្ដីមួយ ។
នៃអាថេរកេចិតព្ជួយកុំបារម្ភ
គ្រង់ប្ញាក់កាសមិនផ្ដាសសោះមនុស្សយ៉ាងខ្ញុំ
ដូចដឹងស្រាប់ឆ្ងាប់ចាយធំពុំឲ្យថោក ។
លុះថ្ងៃក្រោយដោយគេការជាញឹកញាប់
មុខស្រអោនទន្ទេរតាមជាប់ទុក្ខសោក
នាងប្រពន្ធធន់មិនបានខានយល់យោគ
ស្ដីកំរោកបោកកំចាយខ្លួយដំណោះ ។
ប្រពន្ធគាប់ធ្ងាប់គោតក្រែងរឯងប្ដី
ដល់ហួសណាស់ឈ្នះគ្រាំអីស្ដីទ្រគោះ
ខ្លួនប្រឡោតក្រោធប្រឡំទំតឈ្លោះ
គ្មានពិគ្រោះគោះខុសត្រូវទៅចំពាន ។

---

๑ ពាក្យចិន ប្រែថា ថែមមួយកែវ ។

បះស្រីណាចិន្តាស្រាលកាលមួមៅ
មិនឈ្នះតែពាំពាក្តីក្តៅទៅសន្ធាន
ប្តីឯទៅក្រមសុំដំរះលះលែងថ្កាណ
ពាល់តែខានបានរួមរ័ក្សស្នំគ្រែស្នេហា ។
អ្នកប្រមឹកកុំប្រមាណបានសប្បាយ
ទឹកស្រវឹងនឹងឲ្យកាយខ្លាយសុខា
បង្កើតកេតុយោគកង្វល់ដល់មរណា
ពីព្រោះឆាតុជាតិសុភជាថ្នាំពុល ។
កុំស្មានថាស្រាជាថ្នាំនាំក្សាហាន
ធ្វើឲ្យថ្កាណមានបញ្ញាក្សោយបល់
ឲ្យក្សាដែរតែក្សាល្ងីយធើយហួសផល
បានកង្វល់ដល់ខោសទុក្ខគុកខ្នោះឃ្នាង ។
ថ្កាណកំស្តុយហុយអសោចដូចខ្មោចឆ្កែ
ក្អែកល្អក់ស្លែបែរចំគេគេដើរកង
ឯដំណើរដើរទ្រេតទ្រោតលោតយកកង
ជួនមួលជួលចង្រ្កានស្រែងផ្សារ ។
រឿងសម្ងាត់ចាត់សម្ងំចិត្តជាំង
តែផឹកជ្រលង្វុលជោគខ្លាំងតាំងកេហារ
ប្រឹងសំដែងចែងសំដីដោយទីផ្សារ
ពាល់បែកការចារឿងនោះសុសគូមិហាន ។

ចូលដំខុំប្រជុំជនខន់សីរី
ខោះពាក្យអ្វីស្តីទៅតាមស្នាមលំអាន
គង់តែគេមែរខ្នង់ឲ្យដោយគិតស្មាន
ដឿថាប្រាណបានតែប្រាជ្ញអំណាចស្រា ។
គ្រាក្រខ្លះស្គាល់អ្នកមានធនធានស្តុក
ទៅខ្ចីបុលវុលតត្រែកមុខឆ្កែធ្មារ
អង្វរគេគេមិនឲ្យដោយដឿថា
អ្នកប្រមឹកផឹកសុរាណាចេះសង ។
ម្ល៉ោះហើយគ្រាពាក្តីត្រកកូនចៅ
ត្រូវគេដៅមាំដល់ពង្សវង្សផាងង
ថាពូជខោះលុះល្បែងស្រាក្លាកន្ទង
មិនត្រូវប៉ងចងជាមិត្តស្និទ្ធមេត្រី ។
ទ្រព្យកំមស់យសកំអាប់យ៉ាប់ពាំងត្រប់
គួរតែឈប់គប់សុរាការអប្រិយ
សាងជីវិតតិតផ្លូតផ្លង់អគ្គជាថ្នូ
កបសិរីល្អក្តើរឈ្មោះយសថ្កើងអើយ ! ។

និគមវាចន

បទភាពតិ

ស្រាតាំខ្លួចប្រាណ ស្រាហ៊ានហួសហ៊ាន ស្រាបានខ្លួចឈ្មោះ
ស្រាតាំហ៊ានទ្រព្យ ស្រាផ្តាច់ឲ្យឈ្មោះ ស្រាបាត់ចិត្តស្មោះ ស្រាកោះចូលគុក

សេចក្តីសុខ និង សេចក្តីចំរើន
របស់ប្រទេសតែងប្រព្រឹត្តទៅជាមួយនឹងវប្បធម៌

លោក រ៉ាយ - ប៊ីកូ រៀបរៀង

១.— អ្វីដែលហៅថា វប្បធម៌ ? វប្បធម៌ជាភាសាបាលី ប្រែថា: "ការសោធ, ការព្រោះ, ការបណ្តុះពូជ" ។ សំដៅយកការសោធព្រោះនូវវិជ្ជាគំនិតផ្លូវលោកគំនិតផ្លូវធម៌ ហៅថា វប្បធម៌ ។

ប្រទេសនីមួយៗ ត្រូវពឹងអាស្រ័យលើវប្បធម៌ គឺវិជ្ជាផ្លូវលោកនឹងវិជ្ជាផ្លូវធម៌ ទើបមានវឌ្ឍនភាពតទៅអនាគតបាន ។ វិជ្ជាគំនិតីរនេះ ឲ្យតម្លៃដល់មនុស្ស គឺមនុស្សដែលមានសេចក្តីអង់អាចក្នុងប្រជុំជន ក្នុងមហាសន្និបាត ដោយសារមានវប្បធម៌, ពោលគឺចេះវិជ្ជានោះឯង ។ មនុស្សណាដែលមានវិជ្ជា, មនុស្សនោះគេហៅថា បណ្ឌិត ឬអ្នកប្រាជ្ញ ។ ប្រទេសនីមួយៗ ដែលនឹងចំរើនទៅបាន មកអំពីបណ្ឌិត, អ្នកប្រាជ្ញ, អ្នកមានវិជ្ជាដែលចេះពិចារណានិរកមធ្យោបាយផ្សេងៗ ដើម្បីនឹងដោះស្រាយនូវបញ្ហាប្រទេសដែលមានសភាពស្មុគស្មាញ ដូចជាប្រទេសកម្ពុជាយើង ដែលបានឡើងទៅកាន់ឯករាជ្យ ក៏អាស្រ័យមានព្រះមហាបុរស គឺសម្តេចព្រះនរោត្តម - សីហនុ ។

ចើរពោលតាមលោកសារីរយេដឺគ្រីស្តង់ (Charier de Christan) ថា: វប្បធម៌ បានដល់លំនាំនៃប្រាជ្ញា គឺការហាត់ស្ទាត់ជំនាញនូវតត្តជាតុ

ដែលនាំឲ្យកើតច្បាប់ ដោយយកការហាត់តាមក្បួនសិក្សាជាមូលដ្ឋាន គឺសម្បទាដែលនាំឲ្យយល់នូវតុំាងអស់ ដែលជាលក្ខណៈនៃច្បាប់ជំមុះមុត ។

លោកអក្សរសាស្ត្រជាតិបារាំង ឈ្មោះ "ឡឺសាស" (Le Sage) បានសរសេរទុកក្នុងសៀវភៅ "តិលក្ខាសដឹសងខិយ៉ាន" ថា: "វប្បធម៌ជាគ្រឿងច្រជាប់សាសន" ព្រោះថាវប្បធម៌មិនមែនសំដៅយកព្រឹត្តិការណ៍ដែលមានមកដោយភាគ ។ ល ។ គឺសរុបយកព្រឹត្តិការណ៍តុំាងអស់មកជាក្បួនមួយ ដែលគ្មានហេតុការណ៍ខាងក្រៅសោះឡើយ ។ ដូចក្នុងវចនានុក្រមរបស់លោក "ដេសតាំត្ស" ពោលថា គំនិតន័យមួយ ។ មានន័យដូចគំនិតឯទៀត ។, ហើយគំនិតតុំាងអស់បានផ្តិតពណ៌សម្បុរឲ្យគំនិតន័យមួយ ។ គឺថា: "តុំាងអស់មានក្នុងមួយ មួយមាននៅក្នុងតុំាងអស់" ។

តាមពាក្យលោក ថែន - វែន - តេង អធិការសិក្សាក្រសួងសិក្សាធិការជាតិ ទីក្រុងណាំង់តាំងថា: "ការសិក្សាទំនឹងវប្បធម៌មានហេតុមានបច្ច័យទាក់ទងគ្នា ព្រោះថាការចំរើនៃវប្បធម៌របស់ប្រជាជាតិមួយ ។ គឺមកពីថ្នាក់ទំនឹងជម្រៅនៃការសិក្សាប្រជាជាតិនោះ ។ ដែលមានការរួមរបស់ខ្លួនជាមូលដ្ឋាន ។ តាមគោលការណ៍នេះ ការសិក្សាទំនឹងវប្បធម៌បំបែកញែកចេញពីគ្នាមិនជាប់" ។ ដោយហេតុនេះហើយបានជាថា: "ការសិក្សាត្រូវប្រស្រ័យទំនឹងវប្បធម៌ ត្រូវប្រស្រ័យទំនឹងការសិក្សា" ។

វប្បធម៌ដែលមានន័យជាច្រើនបែបច្រើនយ៉ាងនេះ សរុបសេចក្តីមក គឺវិជ្ជាផ្លូវលោកទំនឹងវិជ្ជាផ្លូវធម៌នោះឯង ។

២.- ចុះវិជ្ជាផ្លូវលោកមានប៉ុន្មានយ៉ាង?

វិជ្ជាផ្លូវលោក, បើតាមលោកកវីឯកខ្មែរឈ្មោះទុកញ៉ាសុត្តន្តថ្រែជាឥន្ទ្ធ
ចាន់ថ្លែងក្នុងសៀវភៅ "លោកនីតិបករណៈ" ថា: មាន ១៨ យ៉ាង គឺ

សិល្បសាស្ត្រតាំង១ឃ្លាយដប់ប្រាំបី ក្នុងចាលីលោកបែកមាតិកា
ស្លូពិតីមន្តស្តាប់ភាសា សម្បុពិថាចេះធម្មសាស្ត្រជាក់
សង្ខ្យាគឺចេះលេខបូកគុណហា យោគា គឺចេះការកាប់ចាំងឆ្លាក់
ជីពិ គឺនីតិសារតម្រាលក្ខណ៍ វិសេសការជាក់ឆាយជោគជ័យ ។
គន្ធព្វាចេះក្បួនច្រៀងរាំស្អាត់ កណិកាចេះផ្ចាត់ដោយម្រាមដៃ
ធនុវ្ហោទ ចេះមន្តធសិល្បសៃ ប្បរណាចេះលៃលកក់ថា ។
តិកិច្ឆា ចេះពេទ្យរក្សាពេគ តិតិហាសាយោគចេះការពារ
ជោតិ គឺចេះតែតវ៉ា សព្វមាយាគឺចេះព្យូហ៍កងទ័ព ។
ឆន្ទសិ គឺចេះឆន្ទនិសាស្ត្រ កេតុគឺធ្វើវាទ្យាសង្គមសង្គ្រាមជាប់
មន្តា គឺចេះមន្តមន្ទាប់ សទ្ទា គឺចេះផ្គាប់ចិត្តអ្នកស្តាប់ ។
សិល្បសាស្ត្រតាំង ១៨ យោគ មានកងឥតលោក ។ ប្រជាប់
តែងតាំងទុកឲ្យអ្នកផងគ្រាប់ រៀនជាច្បាប់សម្រាប់ការលោកិយ ។

វិជ្ជាផ្លូវលោក, បើពោកតាមបណ្ឌិតសម័យថ្មី មានដោយសង្ខេប
២០ យ៉ាង គឺ:

๑ – បរមត្ថវិជ្ជា	Métaphysique
๒ – ទស្សនវិជ្ជា	Phylosophie
๓ – ចិត្តវិជ្ជា	Psychologie
๔ – វិទ្យាសាស្ត្រ	Sciences
๕ – ធម្មសាស្ត្រ	Jurisprudence, droit
๖ – គណិតសាស្ត្រ	Mathématiques
๗ – អក្សរសាស្ត្រ	Littérature
๘ – ប្រវត្តិសាស្ត្រ	Histoire
๙ – ភូមិសាស្ត្រ	Géographie
๑๐ – ធរណីសាស្ត្រ	Géologie
๑๑ – រណសាស្ត្រ	Art militaire
๑๒ – សិល្បសាស្ត្រ	Beaux arts
๑๓ – ឧទកសាស្ត្រ	Océanographie
๑๔ – ទំនៀមទម្លាប់ប្រពៃណីវិជ្ជា	Ethnologie
๑๕ – សមជ្ជវិជ្ជា	Musique
๑๖ – ឧតុនិយមវិជ្ជា	Météorologie
๑๗ – តារកសាស្ត្រ	Astronomie
๑๘ – ហោរាសាស្ត្រ	Astrologie
๑๙ – នយោបាយ	Politique
๒๐ – គរុវិជ្ជា	Pédagogie

បើរៀកមួយបែបទៀត មាន ១០ យ៉ាង គឺ

១ — វិជ្ជានយោបាយ

២ — „ សេដ្ឋកិច្ច

៣ — „ ហិរញ្ញវត្ថុ

៤ — „ សិក្សា

៥ — „ សាធារណការនិងដឹកនាំគមនាគមន៍

៦ — „ ពាណិជ្ជកម្ម

៧ — „ សុខភាពនិងអនាម័យ

៨ — „ តុលាការ

៩ — „ ឃោសនា

១០ — „ គ្រប់គ្រងបរទេស ។

មនុស្សណាដែលមានវិជ្ជាម្ភៃយ៉ាង ឬ ១០ យ៉ាង ឬ វិជ្ជាណាមួយ គេហៅថា បណ្ឌិត ។

៣.— ចុះវិជ្ជាទាំងជាប់ដែលពាក់ព្រៃយបង្ហស់នេះ ឲ្យសុខឲ្យចំរើនដល់ប្រទេសយ៉ាងណាខ្លះ?

ក) វិជ្ជានយោបាយ បុគ្គលអ្នកមានវិជ្ជាខាងនយោបាយ ចេះរិះរកនូវមធ្យោបាយគ្រប់យ៉ាង ដើម្បីទំនងធ្វើដំណើរការប្រទេសជាតិមាតុភូមិឲ្យបានសុខស្រួលទៅតាមសន្ធិភាព ។ បើតាមពិត គឺនាយករដ្ឋមន្ត្រីនេះឯងជាមេនយោបាយប្រទេស ។ ប្រទេសដែលឡើងទៅកាន់វឌ្ឍនភាព ឬចុះទៅកាន់វិនាសកម្ម ក៏មកពីនាយករដ្ឋមន្ត្រី, ប្រៀប

ដូចនាយកាច់ចង្កឹតនាក់ ត្រូវតែតស៊ូនឹងរលកព្យុះសង្ឃរា ទើបនាវាទៅដល់តាមគោលគឺសន្តិភាពបាន ។ អ្នកនយោបាយបែបនេះគេហៅថា អ្នកនយោបាយឯក, អ្នកនយោបាយដំនាញ, វីរបុរស, មហាបុរស ។ ប្រទេសកម្ពុជាយើងក្នុងសម័យនេះ មានតែសម្តេចព្រះឧបយុវរាជនរោត្តមសីហនុនេះឯង ជាអគ្គបុរសនយោបាយ ព្រះអង្គប្រកបដោយព្រះប្រាជ្ញាដ៏ឈ្លាសវាងវៃ, មានព្រះបដិភាណគួរឲ្យស្រប់ស្ងែង ទ្រង់បានដឹកនាំប្រទេសកម្ពុជាទៅកាន់ឯកភាពព្រលឹងគ្នាណា: ទឹងឲ្យចូលជាសមាជិកនៃអង្គការសហប្រជាជាតិ ដោយគ្មានលោហិតហូរមួយតំណក់សោះ បានជាប្រជារាស្ត្រខ្មែរលើកតំកើងព្រះអង្គ ថ្វាយព្រះបរមនាមថា: "ព្រះមហាវីរក្សត្រិយ៍, ព្រះបិតាឯកភាពនៃប្រទេសកម្ពុជា" ។

យ៉ាងដូចម្តេចដែលហៅថា នយោបាយ? តើនយោបាយមានប៉ុន្មានយ៉ាង?

មុននឹងពណ៌នាអំពីនយោបាយ សូមលើកយកសេចក្តីត្រៀមមកពោលមុន:

មានអ្នកដំណើរម្នាក់ មានប្រាក់ ១០.០០០ រៀល ដើរតាមផ្លូវមួយ, ផ្លូវនោះមានព្រៃភ្នំ, រួចទៅដល់ស្ទឹងមួយមានក្រពើ, មានផ្លូវតទៅទៀត មានចោរពួនស្កាត់នៅកំមួយ, រួចទើបបានទៅដល់ភូមិដែលខ្លួនប៉ុនឹងទៅ ។ ចើអ្នកដំណើរនោះ បានធ្វើដំណើរទៅហើយ បានរួចពីមាត់ខ្លា, មាត់ក្រពើ, ផុតពីកណ្តាប់ដៃចោរបាន គេហៅថាជាអ្នកមេនយោបាយឯក ។ ព្រោះហេតុនេះ នយោបាយនោះ បានដល់វិជ្ជាចេះ

ប្រកបរៀតាមកាលៈទេសៈ ដូចអ្នកដំណើរខាងលើ, អ្នកធ្វើនយោបាយ
លុះត្រាតែចេះវិជ្ជាលក្ខណៈខ្លួន, ចរិយាក្រៅ, កិរិយាចោរ ហើយលៃ
រៀតាមមធ្យោបាយផ្សេង ។ ឲ្យផុតពីកណ្តាប់ដៃចង្កូមិត្តខាងអស់, ទើប
ហៅថាជាអ្នកចេះនយោបាយ, ជាមេនយោបាយយ៉ាងឆ្នើម ។

ប្រទេសន័មួយៗ ត្រូវមានទាយកវដ្តមន្ត្រីជាមេនយោបាយ ចេះប៉ុន
ប្រសប់ត្រួតត្រាប្រទេស ឲ្យប្រជាកសិកម្មបានសេចក្តីសុខស្រួល, ធ្វើឲ្យ
ប្រទេសសម្បូណ៌ដោយកោតទ្រព្យ, ជីកនាំប្រទេសឲ្យមានកិត្តិស័ព្ទ
ល្បីល្បាញរៀតដល់មហាប្រទេសខាងក្រៅ ។ នយោបាយនេះឯង
ជាវិប្បធម៌ដែលអាចឲ្យសុខ - ចំរើនដល់ប្រទេសបាន ។

ខ) វិជ្ជាសេដ្ឋកិច្ច ជាវិជ្ជាមួយដែលធ្វើមនុស្សឲ្យចេះធ្វើ
កសិកម្ម, កសិកម្ម, ពាណិជ្ជកម្ម, ឧស្សាហកម្ម ដែលអាចរាងនាប្រ-
ទេសឲ្យមានកោតទ្រព្យសម្បត្តិសម្បូណ៌ ធ្វើឲ្យប្រជាកសិកម្មរៀតជាកុដុម្ពីភ័ក,
គហបតី, សេដ្ឋី ។ វិជ្ជានេះឯងហើយដែលធ្វើឲ្យមហាប្រទេស សហរដ្ឋ
អាមេរិក, ប្រទេសអង់គ្លេស, ប្រទេសបារាំង, ប្រទេសរុស្ស៊ី,
ប្រទេសចិន, ប្រទេសជប៉ុន ជាដើម មានតម្លៃ មានសម្បត្តភាព មាន
កិត្តិសព្ទខ្ចរខ្ចាយខ្ទរខ្ទៀតពេញសកលលោក ។

គ) វិជ្ជាបរិរក្ខវិត្ត ជាវិជ្ជាមួយដែលអាចត្រួតត្រាបាក់
ចំណូលចំណាយក្នុងប្រទេស, យកបាក់នោះមកធ្វើជាប្រយោជន៍

សាធារណៈ ចំពោះជាតិមាតុភូមិ ចេះពណ៌នាអំពីក្បួនធ្វើចញ្ចឹសព្វគ្រប់, ថវិកាជាតិ, គម្រោងនានា, វិធានការណ៍ខាងរូបិយប័ណ្ណជាដើម ។

ឃ) វិជ្ជាសិក្សា អាចឲ្យប្រជាពលស្គាចេះដឹងនូវវិជ្ជាគ្រប់យ៉ាង ពាំងវិជ្ជាលោកវិជ្ជាធម្ម, អាចទុបត្តម្ភប្រទេសឲ្យសម្បូណ៌ដោយអ្នកចេះដឹងច្រើន ទៅជាវេជន ។ វេជនេះឯង ជាអ្នកជួយដោះស្រាយបញ្ហាប្រទេសដែលចុះក្នុងស្ថានការណ៍ដុនជាប ឲ្យបានសន្តិភាព ។ វិជ្ជាខាងផ្លូវធម្មជាក្បែកច្រមុះរបស់វិជ្ជាខាងផ្លូវលោក ។ ប្រទេស, បើមានតែវិជ្ជាផ្លូវធម្ម គ្មានវិជ្ជាផ្លូវលោក ប្រជាពលស្តូនឹងទៅជាអ្នកស្លូតបូត, ប្រទេសដទៃនឹងមកកំរើញ, គំរាម យកធ្វើជាអាណានិគម ។ ប្រទេស, បើមានតែវិជ្ជាលោក គ្មានវិជ្ជាធម្ម ប្រជាពលស្តូនឹងទៅជាអ្នកគាចពាលសាមាន្យ, ក្តៅឆេះគ្មានចិត្តលត់ ។ ព្រោះហេតុដូចនេះ វិជ្ជាផ្លូវលោកផ្លូវធម្មទាំងពីរ ត្រូវមានក្នុងប្រទេសទីមួយៗ ដើម្បីទំនងលៃលកតាមគួរការតាមស្ថានការណ៍តឹងផ្លូវនៃប្រទេស តាមពេលវេលា ។

ង) វិជ្ជាសាធារណការ និង ទូរគមនាគមន៍ អាចទុបត្តម្ភប្រទេសឲ្យមានអាកាសយាន, អាយស្ថ័យយាន, ផ្លូវថ្នល់, វិថី, ស្ពាន, គេហដ្ឋាន, អណ្តូងទឹក ទៅតាមសេចក្តីត្រូវការ ទំនងតាមកាលៈទេសៈ, ឲ្យមានវៃប្រសណីយ៍, ទូរលេខ, ទូរស័ព្ទ, បញ្ជូនដំណឹងដល់គ្នាទំនងគ្នាបានទំនងផ្សាយវិទ្យុដែលជាសំឡេងប្រទេស ឲ្យនាំកិត្តិស័ព្ទដ៏ល្អទៅប្រាប់បរទេស ។

ប) វិជ្ជាយោសនា ជាវិជ្ជាដឹកនាំដណ្តឹងទៅផ្សាយ គ្រប់ទិគម ជនបទ, ខែត្រ, ស្រុក, ឃុំ ឲ្យប្រជាពស្តុបានជាបន្ទូវអត្ថរសនៃកិច្ចការ ចាំងផ្សាយរបស់រដ្ឋ ។

ឆ) វិជ្ជាទាបាន ឬរណវិជ្ជា ជាវិជ្ជាសម្រាប់ការពារប្រទេស កុំ ឲ្យបច្ចាមិត្តចូលមកលុកលុយបាន; វិជ្ជាក្បួនខ័ពដើងគោក, ដើងទឹក ទឹងដើងអាកាស. នេះជាកំពែងគាំពារឲ្យប្រជាពស្តុបានសុខស្រួល, ប្រកបរបរចិញ្ចឹមជីវិតបានដោយងាយ, ធ្វើគមនាគមន៍មិនមានភ័យកិត ទឹងចោរកម្ម . . . (ល) ។

ជ) វិជ្ជាសុខភាព ឬអនាម័យ ដែលហៅថាវេជ្ជវិជ្ជា ជាវិជ្ជាថែ រក្សាថ្នាលពេតអ្នកមានអាយុ, ឲ្យទុសថ, ផ្សាយក្បួនប្រសូតបុត្រ, ការពារវប្បកម្ម, ថ្នោសច្រាសសំអាតគេហដ្ឋាន ទីលំនៅ, សំអាតខ្លួន ច្បាណ . . . (ល) ។ បើប្រជាពស្តុមានសុខភាពបរិបូណ៌ហើយ ទឹងអាចបំពេញការណ៍យកិច្ចជាពលរដ្ឋបានពេញកម្លាំង, ប្រទេសនឹង បានចំរើនជាមិនខាន ។

ឈ) វិជ្ជាតុលាការ សម្រាប់ឲ្យប្រជាពស្តុណាមិនប្រតិត្ត តាមច្បាប់របស់រដ្ឋ ត្រូវខ្លួលខ្លាកម្មឲ្យពងចាល, ឲ្យតួតីចាំងសងខាង មានន្ទូវតែក៏ជំនុំជំរះតីចាំងឲ្យ, សម្រេចតីបេញសាលក្រមកាត់ទោស ជាក់តុក ពិន័យលក់ជាដើម ។ បើគ្មានតុលាការ, មនុស្សទឹងអាង

កម្ចាំងបាយ, អ្នកណាញ៉ែកដាល់តប់ អ្នកនោះនឹងទៅជាចៅហ្វាយគេជាម្ចាស់គេ ។

៣) វិជ្ជាគ្រប់គ្រងប្រទេស ជាវិជ្ជាសម្រាប់ឲ្យចេះរៀបចំគ្រប់គ្រងមនុស្សឲ្យបានសុខស្រួល, ឲ្យមានសន្តិភាព, ឲ្យប្រកបការងារកខ្វក់ខ្វាន់បានដោយសេរីជាដើម ។

ក្រៅពីនេះ, នៅមានវិជ្ជានៃការអប់រំមូលដ្ឋាន ដែលមានបុគ្គលជាសាស្ត្រាចារ្យជំនាញទៅពន្យល់ប្រដាក់ស្ដែប្រុស ស្រី ឲ្យចេះនូវសុខភាព, អនាម័យ, របៀបរកបរខ្វក់ខ្វាន, របៀបដឹកអណ្ដូងទឹក . . . (ល) ។

នៅមានវិជ្ជាជាច្រើនទៀត ដូចជាវិជ្ជាហាត់ប្រាណដែលអប់រំរូបកាយ ឲ្យមានពលភាព, សុខភាព, វិជ្ជាខាងសាសនា មានពុទ្ធសាសនា, គ្រីស្ដសាសនា, ព្រហ្មញ្ញសាសនាជាដើម ទំនងខ្លះឯទៀត ដែលភោលអំពីសីលធម៌ បង្ហាញនូវវិធីប្រតិបត្តិឲ្យបានសុខស្រួល ចង្អុលផ្លូវទៅកាន់ឋាន, កណ្ដាល, ខ្ពស់ ដែលយើងទាំងអស់គ្នាត្រូវដើរដើម្បីនឹងទៅកាន់សុភមង្គលតាំងពីលោកនេះ រហូតដល់លោកខាងមុខ, ពីសុខជាន់ទាប គឺអាមិសសុខ ដែលជាសុខលាយច្រឡំដោយទុក្ខក្នុងលោក រហូតដល់សុខជាន់ខ្ពស់ គឺនិរាមិសសុខ ដែលជាសុខដ៏ឧត្តម, សុខក្នុងព្រះនិព្វាន ។

ការបណ្ដុះវិជ្ជាទាំងអស់នេះហៅថា វប្បធម៌ ។ នេះ ជាអរិយទ្រព្យដ៏ប្រសើរ, ជាគេនៈដ៏វិសេសក្នុងលោក អាចឲ្យសុខ - ឲ្យចំរើនដល់

ប្រទេសជាតិមាតុភូមិបាន ដូចលោកសុត្តន្តប្រឹជា ឥឡូ បានតោលខុកក្នុង "លោកនីតិបករណៈ" ថា:

"នាកាលកើតកលិយុគយុទ្ធនា ព្រះពោធិត្រវការអ្នកក្លាហាន,
នាកាលកើតព្យាធិយាយីច្រណា ទ្រង់ចង់បានពេទ្យចេះមន្តសុខា។
នាកាលពេលបរិភោគអាហារឆ្ងាញ់ ចង់បានមិត្តសំឡាញ់មកភោគ,
នាកាលកើតកិច្ចអាថ៌ប្រស្នា សឹងច្រើបារកច្រើជ្រអាចដោះស្រាយ"។

ម៉ើព្រះមហាក្សត្រិយ៍ មានបណ្ឌិតខាងវិប្បធម៌គ្រប់ប្រភេទដូច្នេះ ប្រទេសជាតិមាតុភូមិ នឹងបានសេចក្តីសុខ-ចំរើន ព្រោះបណ្ឌិតទាំងនេះ អាចជួយជ្រោមជ្រែងព្រះមហាក្សត្រិយ៍ ក្នុងការដោះស្រាយបញ្ហាប្រទេសដែលកើតមានឡើងភ្លាម។ បាន ។ វិប្បធម៌នេះ មានគុណានុភាពជាអនេកប្បការ ព្រោះហេតុនោះ ការរាជានាប្រទេសជាតិមាតុភូមិ ត្រូវតែរាជានាវិប្បធម៌ជាមូលដ្ឋាន ។

វិប្បធម៌នេះឯង ម៉ើស្ថិតនៅលើបុរសឬស្ត្រីណា អាចធ្វើបុរសស្ត្រីនោះឲ្យមានតម្លៃ មានកិត្តិសព្ទល្បីល្បាញ, ទៅណាមកណាទេវតានឹងមនុស្សទាំងឡាយតែងគោរពបូជា ។ វិប្បធម៌នេះ ក្នុងពេលដែលប្រទេសជាក់ក្នុងអាសន្នកម្ម អាចជួយទ្រទ្រង់ប្រទេសឲ្យរួចផុតពីកន្លះបង្ខូច, ឲ្យរួចអំពីវិនាសកម្ម ឲ្យបានសេចក្តីសុខ-ចំរើនជាកិច្ចការពិតទៅ ។ ប្រទេសណាសម្បូណ៌ដោយវិប្បធម៌, ប្រទេសនោះមានបណ្ឌិត, អ្នកជ្រាបច្រើនទុកជាព្រះពាជព៌ចៃក្សៃនៃព្រះមហាក្សត្រិយ៍, ដើម្បីនឹងធ្វើនយោបាយខាងក្នុងប្រទេសនឹងខាងក្រៅប្រទេស ឲ្យស្របទៅតាមនយោបាយ

នៃមហាប្រទេសចាំងឡាយ ជាហេតុឲ្យកើតនូវសេចក្តីសុខ-ចំរើនក្នុងលោកសន្និវាសតទៅអនាគត ។ ប្រទេសកម្ពុជាបានឯកភាពផ្សេងប្រកបដោយភេតនភ័ណ្ឌគ្រប់យ៉ាង ហើយបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិអស់រយៈពេលវែងប្រមាណជាប្រាំបីសិបឆ្នាំមកហើយ ណាំនាក់ គឺប្រទេសកម្ពុជានេះ ទៅកាន់វឌ្ឍនភាព, សម្បូរណ៌ភាព, សន្តិភាព សមទៅតាមព្រះពុទ្ធដំណាងនៃសម្តេចព្រះទេបយុវរាជ នរោត្តម សីហនុ ។ សេចក្តីសុខ-ចំរើននៃប្រទេសកម្ពុជា ស្ថិតទៅត្រង់ការអប់រំនូវវប្បធម៌ ។ បើជនជាតិខ្មែរមានវប្បធម៌ហើយ ឈ្មោះថាមានបណ្ឌិតច្រើន ដែលគេទុកជាបុប្ផាតែងផ្សាយក្លិនក្រអូបទៅគ្រប់ទិសានុទិស ។ បណ្ឌិតវប្បធម៌ជាសសរកន្ទោង ដែលគាំទ្រគេហដ្ឋានជាតិគឺប្រទេសកម្ពុជា ការពារកំដៅថ្ងៃ, ទឹកភ្លៀង, ខ្យល់ព្យុះសង្ឃរា, ពេគាគ្រប់យ៉ាង ជានសេចក្តីសុខ-ចំរើនដល់ប្រជាពលស្តេចគ្រប់គ្រងអស់ ។ បើប្រជាពលស្តេចបានសុខហើយ ទើបធ្វើការជាប្រយោជន៍ជាតិ, សាសនា, មហាក្សត្រិយ៍, ឲ្យបានលូតលាស់ចំរើនតទៅបាន ។ វប្បធម៌, បណ្ឌិតទុកជាកំពែងការពារមាតុភូមិ សម្រាប់ការពារជាតិ, សាសនា, មហាក្សត្រិយ៍, វប្បធម៌ជាជីវិតនៃមាតុភូមិ ត្រូវតែប្រជាជនខ្មែរព្យាយាមអប់រំ ចិន្តាប្រែងសិក្សាឲ្យបានខាន់តាលសម័យ ដើម្បីទំនើបទៅរួមប្រជុំ ដើម្បីសន្តិភាពជាតិ ទំនើសន្តិភាពលោកជាអវសាន ។

ពេទ្យព្រះរាជា

លោក ស៊ុន-ហាន ប្រែរៀបរៀង

លោក យ៊ូរ-អ៊ុន ពិនិត្យកែសម្រួល

(តទៅ)

ថ្ងៃមួយ, ឫទ្ធិស័ត្យទៅផ្ទះលោកនន្ទិដើម្បីសំដែងសេចក្តីស្និទ្ធស្នាលនឹងនាងកាញ្ចនាឲ្យតែតែទាំងឡាំង ព្រោះគេចង់នៅជិតកាញ្ចនា ចង់មើលវង្វន់មុះដែលប្រកបដោយលំអ នឹង ចង់ស្តាប់ពាក្យរបស់ស្ត្រីក្រមុំដែលមានសម្ងេងពីរោះគួរឲ្យចង់ស្តាប់, ឥឡូវនេះ ឫទ្ធិស័ត្យស្និទ្ធស្នាលនឹងកាញ្ចនាលើសដើម ឫទ្ធិស័ត្យចេញចិត្តយកចិត្តស្ត្រីក្រមុំ កាលដឹងថានាងត្រូវការអ្វីឬចូលចិត្តអ្វី ក៏គេបំពេញបំណងនាងភ្លាម, តាមពិត កាញ្ចនាជាស្រីចិត្តទន់ចូលចិត្តថ្វាយបង្គំព្រះ, ឫទ្ធិស័ត្យកាលមករកនាង គេច្រើនតាំងផ្កាឈើស្រស់ៗមកផ្ញើកាញ្ចនាឲ្យនាងនាំទៅបូជាព្រះ ហើយគេតាំងពីរនាក់ចូលទៅនៅក្នុងបន្ទប់ព្រះជាមួយគ្នា, ឫទ្ធិស័ត្យពេញចិត្តនឹងការថ្វាយបង្គំព្រះរបស់កាញ្ចនា ក្នុងខណៈដែលនាងថ្វាយបង្គំព្រះដោយបញ្ចង្គប្រតិស្ឋាន ។

ឫទ្ធិស័ត្យអត់ទ្រាំសរសើរនាងពុំបាន ទើបនិយាយនឹងនាងថា:

–"កាញ្ចនា នាងជាស្ត្រីល្អគ្រប់យ៉ាង ខ្ញុំសូមសរសើរតាមសេចក្តីពិត"។

–"មិនមែនទេ បងប្អូន ! កាញ្ចនាមិនមែនជាមនុស្សស្រស់ល្អ កាញ្ចនាជាមនុស្សអកតូ" នាងតបដោយញញឹមទៅរកឫទ្ធិស័ត្យវិញ ។

ឫទ្ធិស័ត្យទើបធ្វើកល់ទិយាយទឹងនាងថា :

- "កាញ៉ា ! ខ្ញុំមិនទិយាយពីស្អកឯកាយនាងតែម្យ៉ាងទេ ខ្ញុំទិយាយពីស្អដួងចិត្តនាងផង ហើយខ្ញុំមិនបានទិយាយពីសេចក្តីអភ័ព្វរបស់នាងឡើយ ព្រោះអភ័ព្វជារបស់ធម្មតានៃមនុស្ស" ។

- "មិនទិយាយម្តេចបាន បងប្អូន ! កាញ៉ានៅមិនទាន់ស្គាល់សេចក្តីសុខពិតនៅឡើយ ទោះបីកាញ៉ាមានមនុស្សសរសើរថាកាញ៉ាល្អស្រស់ថាកាញ៉ាជាកូនស្ត្រីមានភួង ១ រូប កាញ៉ាក៏មិនពេញចិត្តស្មើនឹងកាញ៉ាមានឥតុកមានម្តាយទឹងបងនៅស្មើមុខនឹងគេទេ ដូច្នេះហើយដែលកាញ៉ាអែនដំហរថាកាញ៉ាជាអ្នកអភ័ព្វ" ។

ក្នុងចិត្តឫទ្ធិស័ត្យពេញទោរទៅដោយសេចក្តីអាណិតអាសូរ ចំពោះកាញ៉ានាដែលច្បាប់អំពីការដឹងខុនរបស់នាង ។ មែនហើយ វត្តដែលមនុស្សក្រលំគ្នាតែងច្បាស់ថាគឺសេចក្តីសុខ, ឯការមានឥតុកដែលស្រឡាញ់កូន មានម្តាយដែលដឹងចិត្តកូន ទឹងមានបងដែលស្រឡាញ់ប្អូនដូចនាងកាញ៉ានាច្បាស់ ជាសេចក្តីសុខមួយយ៉ាងរបស់នាង ដែលនាងបានយកចិត្តទុកដាក់ដល់ជាទីបំផុត ប្លែកអំពីឫទ្ធិស័ត្យ ដែលបិតាមាតារបស់គេនៅមាន ហើយមានបងប្អូនមនុស្សច្រើរហូតដល់ទ្រព្យសម្បត្តិគេមិនមានទុក្ខអ្វី គេក៏ព្យាយាមលួងលោមតាញ៉ាយកសេចក្តីទុក្ខរបស់នាងឲ្យអស់ទៅបងឃើញនាងមានសេចក្តីសប្បាយ គេទើបនឹកឃើញពាក្យដែលច្រកបដោយសេចក្តីពិតមកលោលជាស់តឿនាងថា :

- "កាញ្ចៅ! នាងជាមនុស្សដែលខ្ញុំអាណិតខ្លាំងណាស់ ចាប់តាំងអំពីខ្ញុំដែលបានដឹងបានឃើញមកដល់ឥឡូវនេះ, សេចក្តីទុក្ខរបស់នាងតាំងប៉ុន្មាន សឹងជ្រួតជ្រាបពេញក្នុងចិត្តរបស់ខ្ញុំ តើដឿខេ កាញ្ចៅ!" ។

កាញ្ចនាបានស្តាប់ឫទ្ធិស័ក្យនិយាយហើយ នាងស្រស់មុខបន្តិចនិយាយតបថា :

- "ខេខេ មិនដឿខេ! ព្រោះសេចក្តីទុក្ខរបស់មនុស្សម្នាក់ទឹងបែងចែកឲ្យទៅមនុស្សម្នាក់ទៀតមិនបានជាជាប់ខាត" ។

- "បាន កាញ្ចៅ! បើកាញ្ចៅដឹងចិត្តខ្ញុំ ឃើញចិត្តខ្ញុំពិត។ នាងនឹងអាចដឹងបានថា ខ្ញុំមានទុក្ខរួមផងនឹងនាងច្រើនដង តែនេះប្រហែលនាងមិនឃើញ នាងបើញតែខាងក្រៅ, សូម្បីនាងគិតមើល! ពេលណាដែលនាងប្រាប់ខ្ញុំថា នាងមានទុក្ខ, ខ្ញុំក៏រំភើបញាប់ញ័រក្នុងចិត្ត, នាងដឿថាខ្ញុំទទួលយកចំណែកនៃសេចក្តីទុក្ខរបស់នាង ហើយកើតទុក្ខជាមួយនឹងនាងផងឬទេ?" ។

- "កាញ្ចៅដឿតាក្យបងឫទ្ធិឯងខ្លះដែរ ម៉ែនិយាយចំពោះត្រង់ដែលបងឃើញកាញ្ចៅកើតទុក្ខបងក៏ទុក្ខផង សូម្បីតែកាញ្ចៅមិនមានទុក្ខ កាលឃើញគេមានទុក្ខ កាញ្ចៅក៏កើតទុក្ខដែរ ដូចឃើញសុនខឫឆ្កាអត់បាយ កាញ្ចៅអាណិតអាសូរក់ណាស់ កាញ្ចៅក៏ទឹកដល់ខ្លួនរបស់ខ្លួនឯង ប្រៀបដៀបខ្លួនឹងសត្វ វាមិនមានចំណែកអ្វីដែលប្លែកគ្នាទេ ខុសគ្នាតែនិយាយប្រាប់យើងមិនបាន បើជានិយាយបានវិញ វាគង់ប្រាប់យើង វាគង់

និយាយនឹងយើង សុំវត្តដែលវាត្រូវការ កាញ្ចៅមិនត្រមង់ឲ្យសត្វចិញ្ចឹមក្នុងផ្ទះ គឺសុនខនឹងធ្លាត្រូវអត់អាហារ ក៏ព្រោះហេតុនេះឯង" ។

ឫទ្ធិស័ត្យពេញចិត្តនឹងការណ៍ ដែលខ្លួនបានណែនាំឲ្យកាញ្ចនាវសាយនូវសេចក្តីទុក្ខខ្លះ ទើបបបួលនាងទៅអង្គុយត្រែមនូបព្រះវិញ ។ កាលអង្គុយចុះរៀបរយហើយ ឫទ្ធិស័ត្យទើបសួរនាងថា :

-"កាញ្ចៅ ដូចម្តេចមិនព្យាយាមធ្វើចិត្តឲ្យសប្បាយវិកពាយខ្លះទៅ ? ខ្ញុំបានស្តាប់សំដីរបស់នាងហើយ ខ្ញុំស្មានថានាងមានគំនិតត្រូវ ល្មមនឹងជាស់តឿនចិត្តខ្លួនឯងបាន ព្រោះបើយើងព្យាយាមគិតថាសេចក្តីទុក្ខនេះជារបស់ធម្មតា តែយើងនឹងបំបាត់របស់ធម្មតានោះមិនបាន កាលបើគិតយ៉ាងនេះ យើងគង់ធូរស្រាលក្នុងចិត្តខ្លះពុំខាន" ។

"ឫទ្ធិស័ត្យ ! កាញ្ចៃគិតយ៉ាងដែលបងនិយាយណាស់ដែរ តែមិនរសាត់បាត់ទុក្ខព្រួយសោះ ត្រឡប់ជាកើតខ្លាំងក្លាឡើងវិញ មិនតែប៉ុណ្ណោះខ្ញុំគិតថា ឥពុកនឹងបងខ្ញុំបានទទួលការស្រឡាញ់កត្តិអំពីព្រះពុទ្ធជាតាំងពីដើមរហូតមក, តែឥឡូវនេះប្រែទៅជាព្រះពុទ្ធធ្វើទោសយ៉ាងធ្ងន់វិញ កាញ្ចៃគិតឃើញថាគឺទោសបាបគ្រោះនឹងបាបកម្ម អំពីបុព្វជាតិតាមផ្តល់ឲ្យផល នេះឯងដែលជាសេចក្តីគិតបង្កគ្រោយបំផុតរបស់ខ្ញុំ ដើម្បីលួងលោមចិត្តខ្លួនឯង ឲ្យរសាយអំពីសេចក្តីសៅហ្មង" កាញ្ចនាកាលនិយាយបានត្រឹមនេះ នាងត្រឡប់មានមុខស្រងូតស្រងាត់ទៀត, សេចក្តីវិកពាយដែលផ្តើមបញ្ចាំងឡើងបន្តិចនោះក៏រលត់ដូចពន្លឺភ្លើង ក្លែករលេង

រលោងដោយទឹកភ្នែកហើយស្រក់ចុះមក, នាងជ្រប់មុខយំអណ្តឹតអណ្តក
មិនស្ងាត់សោះ នាងអង្គុយបណ្តោយឲ្យទឹកភ្នែកស្រក់ចុះតាមចិត្ត ។

- "ត្រូវធ្វើស្មារតីឲ្យរឹងនាង ! កាលបើនាងគិតដល់ធម្មតាមិនបាត់
ទុក្ខព្រួយទេ នាងត្រូវគិតឲ្យជៀតទៅមុខទៀតថា វត្ថុនេះកើតមានដល់
យើងហើយ ហើយរយើងដឹងថាក៏បានកើតហើយ យើងត្រូវមានល្បិចនឹក
មួយបែបទៀតថា របស់ណាដែលកើតមានដល់យើង, របស់នោះមកជា
សុខផងមកជាទុក្ខផង ដូច្នេះ នាងត្រូវតាំងស្មារតីឲ្យរឹង កុំបណ្តោយទៅ
តាមអារម្មណ៍ជាទុក្ខនេះឡើយ" ឫទ្ធិសត្យរំលឹកនាងកាញ្ចនា ។

នាងកាញ្ចនាមានទឹកភ្នែកកំពុងហូរ កាលស្តាប់ពាក្យរំលឹកនេះ
ហើយក៏ជាត់ស្រក់ រង្វង់ភ្នែកនាងក៏ដិះថ្លាឡើង ហើយពោលតបថា :

- "និមន្តយទៅទៀត បងឫទ្ធិ ! ខ្ញុំបង់ស្តាប់បងឫទ្ធិឯងនិយាយ
ណាស់ ខ្ញុំគិតថា ខ្លួនខ្ញុំចង់ត្រូវស្ងាប់ ដោយសារសេចក្តីវេទនាចិត្តនេះ
តែឥឡូវនេះខ្ញុំនឹកថាខ្ញុំមិនស្ងាប់វិញទេ ព្រោះបានស្តាប់ពាក្យបងឯង
ដូច្នេះសូមបងនិយាយទៅទៀតណា" ។

ឫទ្ធិសត្យមានចិត្តរីករាយលើសលុប គេកំពុងតែគិតចង់ជ្រាបនាង
កាញ្ចនាថា "គេនិយាយនេះដោយសេចក្តីស្រឡាញ់, ម្ចាស់នៃសេចក្តី
ស្រឡាញ់ អាចជាស់តឿនកាញ្ចនាថា កុំឲ្យទៅក្នុងអំណាចទុក្ខវេទនា,
តែខ្លួនគេជាស់តឿនខ្លួនឯងថា កុំឲ្យមៅគ្រាមអំណាចនៃសេចក្តីស្រឡាញ់
មិនបាន" កាលកំពុងគិតយ៉ាងនេះក៏ភ្ញាត់មាត់ថា :

- "កាញ្ចនៃ ដែលខ្ញុំធ្វើយ៉ាងនេះ គឺធ្វើដើម្បីគិតដោះស្រាយខ្សែសេចក្តី

វេទនាចិត្តរបស់នាង នឹងលួងលោមនាងឲ្យបាត់ទុក្ខព្រួយ តែខ្ញុំធ្វើនេះ ព្រោះខ្ញុំស្រឡាញ់នាង" សម្លេងរបស់គេរបូតចេញចាកមាត់យ៉ាងនេះ ដោយមិនដឹងខ្លួន ; ពាក្យសារភាពថាស្រឡាញ់ឮសូរស្រាល។ ស្ទើរតែនាងកាញូនាស្តាប់មិនឮ ។

នាងកាញូនាលុះស្តាប់ឮហើយក៏ញាប់ញ័ររន្ធត់ស្ទុះចិត្ត តែត្រឡប់ជាមិនសូវដឿងពាក្យនោះប៉ុន្មានវិញ ទើបសួរថា :

"អ្វីទៅបងប្អូនិ! ស្រឡាញ់។...ដែលបងនិយាយអម្បាញ់មិញ..." កាញូនាមិនអាចនិយាយអ្វីបានទៀត ។

"បាទ! បងស្រឡាញ់អូនឯង, ប៉ុះអូនច្បាប់បងបានទេ តើអូនស្រឡាញ់បងដែរឬយ៉ាងណា" ឫទ្ធិស័ក្តិសួរដោយសំឡេងថ្នមស្រាល។ មានពីកមុខលាយចំរុះអារម្មណ៍ភ័យ មានវង្វន់តែកសំឡឹងចំនាង ។

នាងកាញូនាដាក់មុខប៉ុនៅស្ងៀមមិនតបពាក្យវិញ ដោយស្ទុះចិត្តដ្បិតចំទើបមានកម្ងោះនិយាយចែចង់ជាដំបូង ។

* * *

— ៧ —

"លោកចាលិតជាទីស្រឡាញ់! ឥឡូវនេះលោកបានស្គាល់ឈ្មោះខ្ញុំដ៏ពិតច្បាស់ដហើយ ព្រមទាំងបានស្គាល់តែកូលរបស់ខ្ញុំទៀត ទីបផុតលោកបានដឹងថា ខ្ញុំស្រឡាញ់នូវកូនក្រមុំលោកនន្ទិ ដែលមានចិត្តច្រកបព្រមដោយគុណធម៌ តែយើងទាំង២ នាក់ស្រឡាញ់គ្នាតែក្នុងចិត្ត ចំណែកកាយ យើងមិនទាន់ប៉ះពាល់គ្នាទេ ។ លោកចាលិតជាទី

ស្រឡាញ់ ! សូមលោកជ្រាបថា ថ្ងៃក្រោយមក លោកនន្ទិនីនឹងសុរពល ចាននឹងលួចការដោះលែងអំពីឪឃុំយ៉ាង, កាប់ជាវេលាដែលនៅក្នុងឃុំយ៉ាង អស់ ៤ ខែ, ការណ៍ដែលរួចទោសនេះ ដោយព្រះពាជាទ្រង់មានសេចក្តីអាណិតអាសូរខ្លាំង ទើបទ្រង់ត្រាស់បញ្ជាឲ្យអមាត្យនន្ទិនីនឹងសុរពលឲ្យត្រឡប់មកនៅក្នុងផ្ទះ, តែរដ្ឋមន្ត្រីបានវិនិច្ឆ័យទោសរបស់អមាត្យទាំងពីរថាឲ្យដកយសស័ក្តិនឹងតំណែងពជការ ។ តើលោកដឿឬទេ ថាកាលនន្ទិអមាត្យចេញចាកគុកហើយក្នុងថ្ងៃនោះ ក៏ស្រាប់តែបាត់អំពីផ្ទះ ទាំងសុរពលនឹងនាងកាញ្ចនាក៏បាត់ទៅជាមួយគ្នា មិនមានអ្នកណាដឹងឬជួបឃើញឡើយ, ខ្ញុំកាលបានដំណឹងថា លោកនន្ទិរួចអំពីឪឃុំយ៉ាង ក៏បានទៅសួរនាំលោកយ៉ាងហើយរហូតក្នុងថ្ងៃនោះ តែថ្ងៃណាស់ទៅហើយទើបខ្ញុំទៅដល់ ខ្ញុំជួបតែយាយចាំរើម្នាក់ដែលស្មោះត្រង់របស់លោកនន្ទិកំពុងយំខ្លួញរៀបកាប់នៅជណ្តើរផ្ទះ" ឫទ្ធិសត្យនិយាយ ។

– "យី ! លោកនន្ទិនឹងឫត្រូវទៅបាត់អំពីផ្ទះ ?" អមាត្យបាលិតសួរបញ្ជាក់ដោយខឹកផ្ទៃកក់ក្តចិត្ត ។

– "បាទ ! ទៅបាត់, រហូតមកដល់ឥឡូវនេះ ខ្ញុំមិនទាន់ជាដឹងនឹងអ្នកណាម្នាក់ ក្នុងបណ្តាមនុស្សទាំង ៣ នាក់នោះនៅឡើយ, លោកគិតមើលចុះ តើខ្ញុំមានសេចក្តីទុក្ខលំបាកចិត្តយ៉ាងណាទៅ ចំពោះការអាឡោះអាល័យនាងកាញ្ចនា" ឫទ្ធិសត្យតបវិញ ។

អមាត្យបាលិតស្តាប់រឿងក៏រំជួល ដែលមាណពនិយាយមកទាំងអស់នេះក៏នឹកអស្ចារ្យក្នុងចិត្តថា "ដែលអញមកនេះ គ្រាមតែដើម្បីនឹងស៊ើបរក

អ្នកមានសេចក្តីឈ្លាសវៃតាមបញ្ញាព្រះពុទ្ធ តែត្រឡប់មកបានស្គាប់ឯរឿងរ៉ាវរបស់មនុស្សម្នាក់ក្នុងនគរ១ ដែលជារឿងពិតវិញ, អ្នកនិយាយបានអាងដល់សេចក្តីចេះដឹង ច្រកបដោយគុណធម៌យ៉ាងជ្រាលជ្រៅរបស់បុគ្គលចាំងអស់នោះ តែដែលបានពោលមកហើយចំពោះអមាត្យនេះ, លោកនេះប្រហែលមានសេចក្តីខូចចិត្តយ៉ាងខ្លាំង ទើបនាំបុគ្គលបរត់ទៅទៅដីដទៃ, បុគ្គលដែលគួរអាណិតអាសូរនេះ ទើបទៅទិសណា ទៅកន្លែងណា ត្រូវណាហើយបានទទួលសេចក្តីសុខទុក្ខត្រឹមណា ក៏ជាការកម្រមានស្មានត្រូវ, ឯសេចក្តីស្រឡាញ់រាងកូនស្រីលោកនេះនឹងមាណពបុត្តិសត្យ ក៏ជាសេចក្តីស្រឡាញ់បរិសុទ្ធិមិនមានសៅហ្មងដោយទុសបវេណីឡើយ” អមាត្យថ្លាលិតលុះតិតមកដល់ត្រឹមនេះ ទើបដឹងថាវេលាវត្តិកាលយប់ជ្រៅណាស់ហើយ ទើបគ្រឿនបុត្តិសត្យថា:

– “បុត្តិសត្យ! លោកគួរខំរម្ងាប់ចិត្តទើបខំធ្វើចិត្តឲ្យជាសុខ រង់ចាំមួយថ្ងៃពីរថ្ងៃទៀត រឿងលោកនឹងបានជួបស្តីក្រមុំជាគូសង្សារនោះព្រោះវេលានេះយប់ជ្រៅណាស់ហើយ គួរយើងនាំគ្នាសម្រាកទៅ” ។

– “អញ្ជើញលោកទៅសម្រាមុនចុះ ខ្ញុំសូមអង្គុយទៅត្រង់នេះមួយស្រមក់សិន” មាណពបុត្តិសត្យអង្គុយទៅម្នាក់ឯងត្រង់ទីនោះ គេអង្គុយនឹកដល់ដំរិតគេដែលកន្លងទៅហើយ ចាប់តាំងអំពីគេបានចេញដើរផ្លូវចាកក្រុងរាជគ្រឹះទៅត្រង់ច្រកល្ហក ដើម្បីស្វះស្វែងរកនាងកាញ្ចនាជាគូស្នេហាប៉ុណ្ណោះ ដោយមិនអាល័យស្រុក មិនអាល័យបិតាគេទេ កាលគេទៅលាបិតាគេ បានដឹងថា គេមិនមានសេចក្តី

សុខគាំងអំពីនាងកាញ្ចនាទៅបាត់ បិតាគេក៏មិនខឹងទាស់ ព្រោះគាត់ស្រឡាញ់គេជាងកូនឯទៀត ព្រមទាំងបណ្តោយឲ្យគេបានតាមចិត្ត ព្រោះឃើញគេស៊ីមិនបានដេកមិនលក់ ព្រមទាំងគាត់ចេញប្រាក់ឲ្យគេជាតម្លៃចាយវាយក្នុងការដើរផ្លូវអំពីក្រុងភជគីរនេះទៀតផង គេអង្គុយលើខ្នងសេះស្ងាយជាដើរសេះឈប់សម្រាកជារឿយ ។ បើបានជួបប្រទះស្រុកណា ផ្ទះណា ដែលបិតានៅក្បែរផ្លូវគេតែងសួរថា “ បានឃើញតាចាស់ទឹងបុត្រប្រុសបុត្រស្រីដើរមកតាមផ្លូវនេះដែរឬ ? ” គ្រប់ស្រុកទឹងគ្រប់ផ្ទះដែលគេទៅសួរវេក មិនមានអ្នកណាម្នាក់ប្រាប់ថា “ បានឃើញ ” សោះ ឫទ្ធិសំត្យបណ្តោយចិត្តឲ្យអណ្តែតទៅតាមសេចក្តីគិតទាំងនោះ ដូចជាចិត្តគេជួបជាទឹកចង់កាត់អាល័យនាងកាញ្ចនាឲ្យបាន, ដូនជាវេលានោះឲ្យល់ក្នុងភ្នែកំពុងបក់ចូលមកម្តង ។, ធ្វើឲ្យព្រះចន្ទបញ្ចេញពន្លឺភ្លឺ ដែលជាវេទាងន្តេីតជិតបួរទៅខាងវេនោះហើយ ឫទ្ធិសត្យមើលទៅដែលជ្រៃជិតទឹងលិចបាត់ជ្រងហោក ទើបចិត្តគេចាប់ភ្ញឹកវេលឹកដល់បិតាដែលគេចេញចោលមកយូរណាស់ហើយ រហូតដល់ទឹកឃើញពាក្យដែលបិតាគេពោលទឹងគេថា ‘ ឫទ្ធិ ! ឪពុកបង់ឲ្យកូនឯងមានសេចក្តីសុខណាស់, ឥឡូវនេះឪពុកជាពណាស់ហើយ បើឯងមានសេចក្តីសុខចំរើនជាន់ឪពុកទៅវេស ឪពុកទឹងស្លាប់ដោយបិទក្អែកជិត ទៅក៏ទៅចុះកូន ! បើឯងត្រូវការទឹងតាមវេកវិត្តនោះ ដោយសំគាល់ឃើញថាជាគួរត្រែងកូនឯងហើយ, ឪពុកទឹងប្តូងសួងសូមឲ្យសេចក្តីប្រាថ្នារបស់កូនឯងសម្រេចសមដូចបំណង ឪពុកសូមអំណាយពរឲ្យគុណព្រះជួយគ្រប់គ្រងរក្សា

កូនឯង" រួចបិតាគេស្លាប់ក្សាលគេ កាលគេនៅក្សាលគ្រាប់ស្បែរដើង
របស់ឪពុក ។

ពីមុនមកឫទ្ធិសត្យមិនធ្លាប់គិតដល់ផ្ទះសោះ ទើបតែកើតមានក្តីចិត្ត
លើកនេះជាគ្រាដំបូង ពាប់អំពីបានចេញចាកផ្ទះមក, មនុស្សគ្រប់គ្នាដែល
ឃ្លាតអំពីផ្ទះតែងគិតដល់ផ្ទះ មិនថាផ្ទះនោះធំឬតូចយ៉ាងណាទេ, ការចេញ
ចោលមកយូរៗគេនឹងត្រូវគិតដល់ផ្ទះដែលគេធ្លាប់នៅជាខ្លាំង, ឫទ្ធិសត្យ
ទើបចុះសម្រុងចិត្តយ៉ាងដាច់ខាតថា ខ្លួនត្រូវត្រឡប់ទៅរកបិតាយ៉ាងរហ័ស
វិញ, គេបានឧកត្រៃកអរក្នុងការប្រថុយយកជីវិតរបស់គេ ជួយដោះ
ជីវិតសត្វដែលកំពុងខ្វល់គ្រោះកម្ម ដោយពាធីបូជាយញ្ញរបស់ព្រះពុទ្ធ
លុះគិតដល់ត្រឹមនេះ គេក្រោកចាកទីអង្គុយដើរមកកាន់ត្រែដេក ចាប់យក
ធូបមកដុត ហើយដោតចុះក្នុងដើងដើងធូបដែលនៅត្រង់ក្បាលដំណេក
រួចអង្គុយប្រណម្យដៃអធិដ្ឋានក្នុងចិត្តរំឭកគុណនៃព្រះពុទ្ធ ព្រះធម៌ ព្រះ
សង្ឃ, ដោយអំណាចនៃសេចក្តីមេត្តាដែលគេបានធ្វើមកក្នុងការជួយ
ដោះជីវិតសត្វជាច្រើន សូមឲ្យគេបានជួបនឹងនាងកាញ្ចនា, ហើយគេក៏
ដេកលើត្រែ មិនយូរប៉ុន្មាន មាណពឫទ្ធិសត្យក៏ដេកលក់ស្កប់ឫ ។

(នៅមានតទៅទៀត)

ឧកញ៉ាវិបុលរាជសេនា ង្វ-កាង ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> ធំងបេះខុបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

គួនអ៊ូធំស៊ុនខៀនក៏ដេកលក់ទៅមួយស្របក់ស្រាប់តែឮសូរសំឡេងសេះធំងមាត់មនុស្សស្រែក ក៏ភ័យក្រាក់ឡើង ។ គួនអ៊ូក៏ស្រែកហៅតាហានដែលក្បុះសេះ, តាហានគាំងនោះក៏ដេកលក់សូន្យមិនដឹងខ្លួនសោះ ។ គួនអ៊ូធំស៊ុនខៀន ក៏ក្រោកកាន់ក្រែបចុះទៅមើល ស្រាប់តែឃើញម៉ក្ពួកបងប្អូនធំងអតស្រុកលើកគ្នាមកដេរកូនគួសៀងដែលជួលទៅពីនោះ ។ គួនអ៊ូក៏សួរពួកនោះថា ហេតុម្ដេចបានជាកូនគួសៀងមកជួលទៅដូច្នេះ ? ។ ពួកនោះក៏ឆ្លើយថា អាដែងនេះវាអាក្រក់ណាស់ វាយើញសេះរបស់លោកស្អ វាលបចូលមកធំងលួចយកទៅ សេះនោះក៏ជាក់វាជួលទៅពីនេះ ខ្ញុំបានឮសំឡេងស្រែក បានជាបបួលគ្នាមកមើល ។ គួនអ៊ូបានស្ដាប់ដូច្នោះខឹងណាស់ ទើបនិយាយថា វានេះអាក្រក់ណាស់ បង្ខូងឲ្យវាជំងខ្លួនក្រាក់ឡើងធំងធ្វើទោសវាជាមុន ។

គួសៀងបានឮសំឡេងអីនកនឹកក៏ភ័យភ្ញាក់ឡើង ស្ទុះចុះទៅមើលឃើញកូនរបស់ខ្លួនដួលសន្លប់ដូច្នេះ ឮអ្នកស្រុកនឹងបងប្អូនទំាយរឿងក៏ឲ្យស្តាប់ គួសៀងក៏គំនាប់អង្វរគួនអ៊ូថា សូមឲ្យលោកអាណិតខ្ញុំមង់ចុះកូនខ្ញុំនេះវាគ្រក់ណាស់ ខ្ញុំក៏បានដំរាបរឿងវាឲ្យលោកជ្រាបមកពីមុនរួចហើយ ដែលវាធ្វើខុសដូច្នេះ ខ្ញុំនឹងបានចូលគំនិតជាមួយនឹងវាក៏ខ្លាយវាមានចិត្តស្រឡាញ់វា ព្រោះកូនតែមួយ សូមឲ្យលោកអាណិតអាសូរខ្ញុំ លើកទោសដែលវាធ្វើខុសនោះឲ្យបានចុះ ។ គួនអ៊ូថា "ដែលអ្នកប្តឹងអំពីទុក្ខអ្នកដល់ខ្ញុំនោះ ក៏ដូចគាក្យអ្នកជាប្តឹងដដែរ ទោសរបស់វាខ្ញុំក៏ព្រមលើកចោលឲ្យអ្នកហើយ" ទើបបង្គាប់ឲ្យវាឈប់ឈរឲ្យស្រួលសេះទុកឲ្យល្អ ហើយក៏នាំស៊ុនខៀនឡើងមកដេកវិញ ។

លុះព្រឹកឡើង គួសៀងនឹងករយោចេញមកគំនាប់គួនអ៊ូហើយថា កូនខ្ញុំធ្វើខុសហើយលោកអនុញ្ញាតលើកទោសចេញនោះ គុណរបស់លោកវាកខ្វក់ពំផុតគ្មានឡើយ ។ គួនអ៊ូឆ្លើយថា អ្នកចូរហៅឲ្យវាចេញមកជួបនឹងខ្ញុំ ។ នឹងដួយស្តីប្រដៅ ។ គួសៀងឆ្លើយថា កាលពីយប់មិញវាភ្ញាក់ដឹងខ្លួនហើយ ក៏នាំពួករកឹនវ៉ៃរគេចទៅឯណាបាត់ទៅហើយ ។ គួនអ៊ូបានស្តាប់ហើយ កំណាគួសៀងនាំបងប្អូនខ្លួនស៊ុនខៀនចេញពីផ្ទះនោះទៅចម្ងាយផ្លូវប្រហែល ៣០០ សិន (១២ គ.ម.) ទទួលក្រឡេកឃើញកូនគួសៀងនោះដំរះសេះនាំមេចោរម្នាក់ជួតក្បាលសំពត់លឿង ដំរះសេះកាន់ខ្លួនលើកពួករកឹនប្រហែល ១០០ ជ្វាយនាក់ ចុះពីលើភ្នំមកស្ទាក់ទប់ផ្លូវ មេចោរនោះក៏ស្រែកហៅគួនអ៊ូថា ខ្លួនយើងឈ្មោះ

ហ៊ុយឆ្ងួនសៀវជាគាហានទៀវកុក ខ្ញុនទឹងទៅណាទើបអាចហាន់គ្នា ធ្វងដែនយើងមក បើខ្ញុនស្រឡាញ់ដីតែ ចូរយកសេះដែលដិះនោះមក ឲ្យយើង។ ទឹងលែងឲ្យទៅ ។ គួនអ៊ូបានស្តាប់ដូច្នោះក៏អស់សំណើចហើយថា ខ្ញុនជាគាហានទៀវកុកជាចោរនោះឆ្ងាប់បានឮឈ្មោះខ្លាំពី, គួនអ៊ូ, ទៀវហ៊ុយដែរឬទេ ? ។

ហ៊ុយឆ្ងួនសៀវឆ្លើយថា ខ្ញុំមិនដឹងទេ គ្រាន់តែឮឈ្មោះ តែគួនអ៊ូនោះ ឮគេថាមុខត្រហមតុកមាត់វែង មានថ្ងីដៃខ្លាំងពូកែណាស់, ចុះអ្នកឯងនេះឈ្មោះអ្វី ? ។ គួនអ៊ូក៏ស្រាយយកថង់ដែលព្យួរខ្នងតុកមាត់នោះចេញមកឲ្យហ៊ុយឆ្ងួនសៀវមើល ។ ហុយឆ្ងួនសៀវឃើញបញ្ជាស់ដូច្នោះក៏ដឹងថាជ្រាកជាគួនអ៊ូ ទើបលោតចុះពីលើសេះហើយចោះខ្លួនចេញពីដៃ នាំកូនគួសៀងចូលទៅលុតជង្គង់គំនាប់គួនអ៊ូហើយថា "ខ្ញុំបាទមិនដឹងសោះ, ដែលខ្ញុំបាទបាននិយាយមើលងាយទ្រគោះប្រមាថដល់លោកនោះ សូមឲ្យលោកអភ័យទោសខ្ញុំបាទចុះ ព្រោះខ្លួនខ្ញុំបាទនេះគាំងតែពីទៀវកុកស្លាប់ទៅកាលណា ក៏នាំពួកគ្រឿនមកធ្វើជាចោរនៅក្នុងខ្ចីក្នុងនេះ, ដែលខ្ញុំបាទបានគិតមកប្រឆ៍ងទឹងប្រឆូសព៉ាយលោកគ្រានេះ ព្រោះកូនគួសៀងបបួលនាំមក" ហើយក៏ពណិនារឿងកំរៀងដែលកូនគួសៀងនាំគិតប្រឆូសព៉ាយនោះឲ្យគួនអ៊ូស្តាប់គ្រប់ប្រការ ។ កូនគួសៀងក៏លន់តួអង្វរថា ខ្ញុំបាទខុសហើយ សូមឲ្យលោកអភ័យទោសចុះ ។

គួនអ៊ូថា ទោសខ្ញុនខុសពីយប់មិញម្តងហើយ យើងក៏លើកលែងមិនប្រកាន់ ឥឡូវខ្ញុនមកគិតគប់គ្នាធ្វើយើងម្តងទៀត បើយើងទឹងសម្លាប់

ចេញក៏បាន តែយើងគិតដល់ផ្លូវមេត្រីនឹងគួរសៀង ឯគោសខ្លួនពាំង ២ គ្រានេះ យើងលើកគោសឲ្យ ដោយយល់ដល់គួរសៀងជាបិតាឯង ។ កូនគួរសៀងក៏មានសេចក្តីត្រេកអរណាស់ ហើយលាគួនអ៊ូចេញទៅ ។ ហ៊ុយង៉ួនសៀវនិយាយច្រៀបគួនអ៊ូថា គឿនខ្ញុំបាទម្នាក់ជាពួកអ្នកស្រែក ឯលិចនៅផ្ទះតាហានខ្វៀវចៅ" ឈ្មោះដីវឆង រួចកង្គួសង់ធំមានកម្ពាំងខ្ពាំងវែករបស់បានខមួយ ១០ ហាម លុះខ្វៀវចៅ"ស្លាប់ទៅហើយ ដីវឆងក៏ឃុំពួកគឿនមកធ្វើជាចោរនៅក្នុងោ៉ដីវស័ន ផ្លូវអំពីនេះទៅប្រហែល ៣០០ សិន (១២ គ.ម.) ខ្ញុំបាទទៅមករកដីវឆង។ តែឆន្ទិយាយចេញឈ្មោះលោកជារឿយ។ ហើយបបួលខ្ញុំបាទថា មើរាជួបនឹងលោកទំនង់ខ្ញុំបាទមកនៅទំនងលោក ឥឡូវនេះជាកត្តបុណ្យខ្ញុំបាទបានមកជួបទំនងលោកមុន ។ គួនអ៊ូតបថា បានកើតជាប្រុសហើយនាំគ្នាមកធ្វើជាចោរនៅព្រៃដូច្នេះនរណាទំនងពាប់អានថាល្អបាន ត្រូវចោលគំនិតអាក្រក់នោះចេញ ហើយនាំគ្នាទៅធ្វើស្រែចំការរកស៊ីក្នុងស្រុកជាប្រក្រតីប្រសើជាជាងនៅព្រៃ ។ កាលកំពុងតែនិយាយគ្នានៅទីនោះ ស្រាប់តែគួនអ៊ូក្រឡេកទៅឃើញនាយចោរម្នាក់ដឹះសេះនាំតាហានប្រហែល ១០០ ចូយ នាក់តម្រង់មក ។ ហ៊ុយង៉ួនសៀវ ក៏ដំរាបគួនអ៊ូថា ដីវឆងមកពីនោះហើយ ។ គួនអ៊ូឃើញរូបកាយដីវឆងខ្ពស់ធំក៏សរសើរថា សមជាតាហាន ។ ដីវឆងមកដល់ក្រឡេកឃើញគួនអ៊ូក៏មានអំណរណាស់ ចុះពីលើសេះបោះខ្លួនចេញហើយក៏ចូលមកលុតជង្គង់គំនាប់គួនអ៊ូ។ ក៏សួរថា ហេតុដូចម្តេចបានជាអ្នកឯងស្គាល់ខ្ញុំរាប់អានខ្ញុំ ។

ជីវធនធ្វើយថា កាលដែលខ្ញុំបាទនៅនឹងខ្លែវចាំជាមេចារនោះ ឃ្លានដឹងថា លោកមានថ្លៃដៃខ្លាំងតែងនឹងមានសតិបញ្ញា ខ្ញុំមានចិត្តស្រឡាញ់ថ្នាក់ថ្នមនឹងមកនៅនឹងលោក តែជាសេចក្តីខ្ញាល់គំនុំតព្រោះដ្បិតឃ្លានជាទៅនៅក្នុងអំណាចខ្លែវចាំហើយ លុះខ្លែវចាំស្លាប់ ខ្ញុំបាទក៏មកនៅធ្វើជាចារវៃពអស្រ័យនៅក្នុងភ្នំគង្គាជីវសន្ត ក៏បាននិយាយនឹងហ៊ុយឆ្នូនសៀវតែតដល់លោកមិនជាប់ ឥឡូវបានមកដួបនឹងលោកហើយក៏ជាបុញ្ញលាភរបស់ខ្ញុំ។ សូមនៅធ្វើជាភាហានគាន់សៀសេះតាមលោកចុះ ។

គួនអ៊ូបានស្តាប់ដូច្នោះ ក៏ពិគ្រោះមើលក្នុងពាក្យសំដីជីវធនដែលនិយាយនោះ ក៏ឃើញដូចជាត្រង់សុចរិត ក៏ឲ្យមានចិត្តស្រឡាញ់អាណិតពន់ប្រមាណណាស់ទើបសួរថា: បើអ្នកបង់ទៅនៅនឹងយើង តើពួកគ្រឿនរបស់អ្នកនោះនឹងជាម្តេចទៅវិញ? ។ ពួកគ្រឿនជីវធនបានឮដូច្នោះគាំងអស់គ្នា ក៏ចូលមកលុតជង្គង់គំនាប់គួនអ៊ូហើយថា យើងខ្ញុំគាំងអស់គ្នាសូមចូលទៅនៅនឹងលោកផង ។ គួនអ៊ូឮដូច្នោះ ក៏ចុះពីលើសេះទៅប្រាប់បងថ្លៃគាំងពីរ ។ នាងកាំហ៊ូយិនប្រាប់ថា គាំងពីយើងចេញពីស្រុកហ៊ូតោមកក៏បានសេចក្តីខ្វះខ្លួយលំបាកពន់ពេកណាស់ ឬមកគ្មានទីកគិតនឹងរកអ្នកឯណាជាពួកគ្រឿនសោះ រំលងនេះមកជួបខ្វះខ្លួយហើយនឹងខ្ចួលមនុស្សយកទៅប្រយោជន៍អ្វី មួយទៀត លៀវហ៊ូមេចារនោះក៏មានគុណដល់បងបានអង្វរសុំមកជាមួយផង ឬមងឯងក៏ថាជាចារនឹងឲ្យជួនមកវិញគេតរហូតនិន្ទាថាតប់ទឹងចារ រំលងនេះបើឬនទៅខ្ចួលជីវធនវិញជាគួរឬមិនគួរយ៉ាងម្តេច ស្មែចនៅលើឬនគិតមើលទៅចុះ ។

គួនអ៊ូបានស្តាប់ដូច្នោះ កំលោតឡប់ទឹកឃើញហើយនិយាយទឹងជីវធនថា បងថ្លៃយើងតាំង ៤ ជាង មិនព្រមឲ្យអ្នកទៅផងទេ អ្នកចូរគ្រប់គ្រងរក្សាគ្នាវង់ចាំទៅទីនេះសិនចុះ បើយើងទៅជួបទឹងឡើតីជាបងយើងវេលាណា សឹមយើងត្រឡប់មកទទួលអ្នកយកទៅទៅជាមួយគ្នា ។ ជីវធនបានស្តាប់ដូច្នោះ កំលុតជង្គង់តំនាប់ហើយថា ខ្ញុំខ្ញុំបាទបានកើតមកជាជាតិតាហ៊ានបានប្រព្រឹត្តភ្លាត់ភ្លំងទៅធ្វើជាពួកចោរ ទបមាដូចជាចូលទៅទៅកងទីងងឹត ឥឡូវមកជួបទឹងលោកដូចបានមកឃើញទីដែលភ្លឺស្វាងទោះបីបងថ្លៃលោកយល់ឃើញថា ពួកខ្ញុំបាទជាពួកចោរមិនគួរទឹងយកទៅ តែពួកគ្រឿងតាំងអស់នោះខ្ញុំបាទនឹងឲ្យទៅទឹងហ៊ុយងួនសៀវចុះ ឯខ្លួនខ្ញុំបាទមួយ ទឹងសូមកាន់សែសេះតាមលោកទៅ ទំកំតែអស់ជីវិតសូមឲ្យលោកអាណិតចុះ ។

គួនអ៊ូបានស្តាប់ដូច្នោះហើយក៏មានចិត្តអាណិតមេត្តា ទើបវិលសាយកសេចក្តីនោះទៅជំរាបអង្វរបងថ្លៃទៀត ។ នាងគាំហ៊ូយិនថា បើគេទឹងបងទៅតែមួយនាក់ពីរនាក់ ក៏ទៅចុះ ។ គួនអ៊ូក៏វិលមកប្រាប់ជីវធនវិញតាមពាក្យបងថ្លៃ ។ ហ៊ុយងួនសៀវឮហើយក៏ថា ខ្ញុំបាទសូមទៅផងបាន ជា ២ នាក់ទឹងជីវធន ។ ឆ្លើយថា បើអ្នកទៅផងហើយ តើពួកគ្រឿងរបស់យើងទឹងបាននរណាត្រួតត្រាក្សា ទឹងមិនខ្ចាត់ខ្ចាយទៅទេឬ ? អ្នកចូរនៅគ្រប់គ្រងរក្សាពួកគ្រឿងសិនចុះ ចាំយើងទៅទឹងគួនអ៊ូ បើបានទីកន្លែងសំណាក់ហើយ ទឹងវិលត្រឡប់មកទទួលអ្នកទឹងពួកគ្រឿងតាំងអស់នាំ

យកទៅ ។ ហ៊ុយដួនសៀវយល់ឃើញត្រូវ កំលាគួនអ៊ូត្រឡប់នាំពួក
ម៉ាកទៅខៅកន្លែងដែលគ្នាប់ទៅនោះវិញ ។

គួនអ៊ូក៏នាំបងថៃថ្ងៃនឹងស៊ុនខៀនដើរតេងដើរថ្ងូរទៅបាន ៣ ថ្ងៃ ស្រាប់
តែត្រូវកមើលទៅឃើញកំពែងលើខ្នងភ្នំធំ ១ គួនអ៊ូក៏សួរអ្នកស្រុកនោះ
ថា ស្រុកនេះឈ្មោះអ្វី នរណាទៅរក្សា ? ពួកអ្នកស្រុកនោះថ្កាប់ថា
ឈ្មោះស្រុកកៅសៀ មានចាហានម្នាក់ឈ្មោះខៀវហ៊ុយមានថ្លៃដៃខ្លាំង
ពូកែណាស់ បានទាំពួកកៀនប្រហែល ៥០ ថ្ងៃយនាក់ចូលមកជេញទៅ
ហ្វាយស្រុកនេះចេញ ខៀវហ៊ុយក៏នៅរក្សាស្រុកលុះដល់សព្វថ្ងៃ តែង
តែបញ្ចុះបញ្ចូលមនុស្សម្នាមហាជនជាកម្លាំងបានប្រហែល ៥ ០០០ ថ្ងៃយ
ស្បៀងអាហារក៏បរិបូណ៌ឥតខ្វះ បណ្តាខែត្រខ័ណ្ឌតូចធំទាំងពួងក៏គោត
ញញើតថ្លៃដៃខៀវហ៊ុយ មិនមាននរណាអាចមកញាំញីបានឡើយ តាំង
ពីខៀវហ៊ុយមកឈរក្សាស្រុកនេះប្រហែលជា ៥ ខែហើយ ។

គួនអ៊ូបានស្តាប់ដូច្នោះក៏សែនមានអំណរណាស់ ទើបនិយាយនឹង
ស៊ុនខៀនថា តាំងពីបែកខ្លួនស្រុកដីចិវមក យើងបងប្អូន ៣ នាក់ក៏ត្រាត់
ប្រាសនឹកសគ្នា ឯឡៅពីនោះបានដឹងដំណឹងហើយ ទៅតែខៀវហុយ
ទើបនឹងបានដំណឹងក្នុងថ្ងៃនេះ អ្នកចូរស្រតទៅប្រាប់ដល់ខៀវហ៊ុយឲ្យ
ចេញមកទទួលបងថ្លៃទាំង ២ ជាប្រញាប់ចុះ ។ ស៊ុនខៀនទទួលពាក្យ
គួនអ៊ូហើយក៏លាចេញទៅ ។

(មានត)

រឿងព្រៃងគន្លឿ

លោកសមិទ្ធ ម្ចាស់ជំនះតែង

លោកវ៉ាយ-ប៊ុក ក្រមការ ដើមខ្សែប្រៃរៀបរៀង

(តមក)

និទានទីនេះរូបទេពនិម្មិតទី ២៦

មានកាលមួយថ្ងៃ, ព្រះបាទកោដៈទ្រង់ស្តេចចូលទៅដិតបល្ល័ង្កនិទ្យ, រូបទេពនិម្មិតទីម្ភៃប្រាំមួយ ក៏ក្រាបបង្គំទូលថា: "បពិត្រព្រះបាទកោដៈ មានតែព្រះបាទវិក្រមាទិត្យមួយព្រះអង្គទេ ដែលមានគុណធម៌អាចគង់នៅលើបល្ល័ង្កនិទ្យនេះបាន, សូមចាំទ្រង់ព្រះសណ្តាប់, ខ្ញុំព្រះអង្គនឹងក្រាបបង្គំទូលអំពីព្រះពជគុណធម៌ នៃព្រះបាទវិក្រមាទិត្យ ដូចតទៅនេះ: ។

មានមួយថ្ងៃ, ព្រះបាទវិក្រមាទិត្យទ្រង់ស្តេចយាងក្រសាលកន្លែងព្រះពជអាណាចក្រ ស្តេចទៅដល់បូជនីយដ្ឋានៃនាងទេវធីតាមួយជាស្ថានដែលមានសភាពសប្បាយរីករាយខុសប្លែកពីទីដទៃ ដែលទ្រង់ធ្លាប់ឃើញ ។ ក្នុងពេលនោះ មានបុគ្គលម្នាក់មកកាន់ទីនោះ ។ ក្រោយដែលបានចូលទៅក្រាបបង្គំគាល់ព្រះមហាក្សត្រិយ៍ បុរសនោះក៏ពោលពាក្យហូរដូចទឹក ។ ព្រះមហាក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់ឮវាចាបុរសនោះ ទ្រង់ព្រះតម្រិះក្នុងព្រះពជហឫទ័យថា: "បុគ្គលនេះប្រហែលជាកាចណាស់, បើមិនដូច្នោះទេម្តេចក៏និយាយច្រើនម្ល៉េះ? តាមធម្មតាមនុស្ស

សប្បុរសមិនអាចពោលពាក្យច្រើនដូច្នេះទេឬ, បុគ្គលនេះពោលសុទ្ធ
តែពាក្យឥតប្រយោជន៍; បើដូច្នេះ មនុស្សនោះជាមនុស្សពាលសាមាន្យ
យ៉ាងក្រៃលែង, មិនដែលមានបុគ្គលណាមានវណ្ណៈស្អុះស្អាយស្រែក
ខ្ទាំង ។ ដូចជាស័ង្ខស្អុះកណ្តឹងឥតអាក់ខេ, ហើយវាចាបុរសនោះគ្មាន
ខ្ចីមសារអ្វីសោះ, ដោយហេតុនេះហើយ គួរយល់ថាមនុស្សនោះគ្មាន
តម្លៃសោះ" ។ ព្រះមហាក្សត្រិយ៍លុះទ្រង់ព្រះតម្រិះដូច្នេះហើយ, ទ្រង់
មិនមានព្រះរាជទ្ធាវៀកនាំបុរសនោះឡើយ ។ បុរសនោះបិតនៅ
មួយស្រែចក់, ក៏ក្រាបបង្គំលាទ្រង់រំលេចៅគេហដ្ឋានវិញ ។

ដល់ថ្ងៃស្អែក, បុគ្គលដដែលនោះ ស្លៀកពាក់ខោអាវកណ្តាច មុខ
ស្រងូតស្រងាត់ ចូលមកក្រាបបង្គំគាល់ព្រះជាម្ចាស់ក្រមាទិត្យម្ពង់ខៀត ។
ព្រះអង្គទ្រង់រតេចយល់បុរសនោះហើយ ទ្រង់មានព្រះបន្ទូលសួរថា:
"ចូរអ្នកនិយាយមកមើល, តើហេតុដូចម្តេច ព្រឹលមិញអ្នកអញ្ជើញ
មកកាន់ទីនេះស្លៀកខោពាក់អាវល្អ ឥឡូវនេះ ម្តេចក៏អ្នកស្លៀកខោ ពាក់
អាវកណ្តាចដូច្នេះ?" ។ បុគ្គលនោះក្រាបបង្គំទូលថា: "បពិត្រព្រះ
មហាក្សត្រ, សូមទ្រង់ព្រះមេត្តាប្រោស; ខ្ញុំលព្រះបង្គំជាអ្នកលេងល្បែង
ស៊ីសង ឥឡូវនេះខ្ញុំលព្រះបង្គំខាតលិចលង់អស់ទ្រព្យសម្បត្តិរលីងគ្មាន
សល់, ខ្ញុំលព្រះបង្គំនៅតែខោអាវកណ្តាចប៉ុណ្ណោះឯង" ។ ព្រះមហាក្សត្រិយ៍
ទ្រង់ព្រះសណ្តាប់ឮវាចាបុរសនោះហើយ ទ្រង់ព្រះសម្រួលហើយក៏មាន
ព្រះបន្ទូលថា: "ល្អហើយ នេះឯងជាផ្លូវនៃអ្នកលេងល្បែងស៊ីសង,
ព្រោះបុគ្គលដែលស្វែងរកកោតទ្រព្យដោយល្បែងស៊ីសង, បុគ្គល

ដែលស្វែងរកកិត្តិយសដោយដាក់ខ្លួនឲ្យអ្នកដទៃប្រើប្រាស់តាមត្រូវការ, បុរសដែលស្វែងរកសេចក្តីសប្បាយដោយធ្វើជាសម្ភយាចក, បុគ្គលទាំងអស់នោះជាមនុស្សពាលអាប់ឥតប្រាជ្ញ ត្រូវខ្លួនខ្ជូរសេចក្តីវិនាសក្នុងអនាគតមិនខាន" ។ បុរសនោះកាលបានស្តាប់ទូន្មានព្រះបន្ទូលសូរសីហនាទនៃព្រះមហាកស្សបត្ថេរ ក៏ក្រាបបង្គំទូលថា: "សូមទ្រង់ព្រះមេត្តាប្រោស, ការដែលទ្រង់រំលេចំពោះខ្ញុំព្រះបង្គំជាការត្រូវហើយ, តែទ្រង់មិនដែលជួបប្រទះនូវសេចក្តីសប្បាយម្តងសោះ ក្នុងការលេងបៀក្នុក, ទ្រង់ដូចជាបុរសក្រីវាលពាក្យតិះដៀល ចំពោះបុគ្គលដែលត្រេកត្រអាលនឹងស្ត្រីក្មេងហើយស្អាត" ។ ព្រះមហាកស្សបត្ថេរទ្រង់មានព្រះបន្ទូលតបវិញថា: "នុអ្នកលេងល្បែងស៊ីសង, អ្នកឯងកើតទុក្ខលំបាកពន់ប្រមាណដោយព្រោះតែសូរដាក់ឈ្មោះអ្នក ព្រោះហេតុដូច្នេះ, បានជាយើងពោលពាក្យប្រៀនប្រដៅទៅកាន់អ្នក ដើម្បីនឹងជួយស្រោចស្រង់អ្នកពីហាយនភាព ដូចជាកល្យាណមិត្ត ។ អ្នកឯងកំពុងប្រឡាំងខ្លាំងណាស់ គឺជាទុក្ខយ៉ាងក្រៃលែង ដោយខ្លួនមានរូបជាមនុស្សជាតិ ហើយគ្មានចិត្តល្អបន្តិចបន្តួចសោះឡើយ គ្មានវិចារណញ្ញាណដ៏បរិសុទ្ធ, គ្មានគិតស្វែងរកមធ្យោបាយដ៏សុចរិត, គ្មានព្យាយាមល្អ, គ្មានសកម្មភាព ប្រកបដោយសៅហ្មងចេតនាទេ ហើយគិតតែស្វែងរកសុភមង្គលដោយផ្លូវខុសគឺលេងល្បែងបៀក្នុក ដែលជាប្រភពនៃទុក្ខលំបាកគ្រប់យ៉ាង, មនុស្សប្រព្រឹត្តបែបនេះគឺបំផ្លាញជីវិតរបស់ខ្លួនទៅកាន់សេចក្តីអន្តរាយពិតប្រាកដ" ។

អ្នកលេងល្បែងលុះបានស្តាប់នូវព្រះបន្ទូលព្រះមហាក្សត្រិយ៍ ក៏ក្រាបបង្គំទូលថា: "សូមទ្រង់ព្រះមេត្តាប្រោស, បើទ្រង់មានព្រះពជ្ឈំណង់ចង់ដួយទូលព្រះបង្គំ។ សូមព្រះអង្គទ្រង់ប្តេជ្ញាថា ទ្រង់នឹងចំពេញសកម្មភាពអ្វីមួយដែលទូលព្រះបង្គំសូមឲ្យទ្រង់ចំពេញ ហើយទូលព្រះបង្គំនឹងធ្វើតិច្ចសច្ចាចំពោះទ្រង់ថា នឹងឈប់លេងល្បែងស៊ីសងតទៅ" ។ ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះបន្ទូលតបថា: "បើតាំងពីថ្ងៃនេះតទៅ, អ្នកឯងលែងលេងល្បែងស៊ីសង យើងនឹងចំពេញសកម្មភាពជាយ៉ាងមុឺងម៉ាត់ ហើយយើងហ៊ានសន្យាថាយើងនឹងធ្វើតាមមិនឲ្យឃ្លៀងឃ្លាតឡើយ" ។

ដល់ព្រះមហាក្សត្រិយ៍ ទ្រង់បានធ្វើសេចក្តីថ្លែងការណ៍ដូច្នេះហើយ អ្នកលេងល្បែងស៊ីសងក៏ក្រាបបង្គំទូលថា: "បពិត្រព្រះសម្មតិទេព, សូមទ្រង់ព្រះសណ្តាប់ នៅលើកំពូលភ្នំសិនេរុ មានបូជនីយដ្ឋានឈ្មោះ ទេវធីតា នាមព្រះនាង មនស្សិទ្ធី (Manassiddhi) ។ នៅទាំងលើបូជនីយដ្ឋាននោះ មានដបកែវធ្វើដោយសុវណ្ណចរិណ ។ នៅក្នុងដបកែវនោះ គេដាក់ទឹកនៃគង្គាមហាមេឃ (ច្របាស់ជាទឹកអនោតត្តសរ) ។ អ្នកណាមួយអាចនឹងនៅយកទឹកដែលដាក់ក្នុងដបកែវនោះបាន, ធ្វើតាវៀតាពំចោះនាងទេវធីតា បានគាត់ក្បាលរបស់ខ្លួនបូជាយ័ញ្ញ, អ្នកនោះនឹងបានសម្រេចនូវតាវៀតាទាំងឡាយពីនាងទេវធីតាសព្វគ្រប់ប្រការ ។ តែជាកិច្ចលំបាកនឹងធ្វើពន់ពេក, បើទ្រង់ចំពេញព្រះពជ្ឈសកម្មភាពនេះបានគ្រប់សព្វ, ទូលព្រះបង្គំនឹងលះបង់នូវអំពើអបាយមុខនេះ ជាប្រាកដ" ។

ដល់អ្នកលេងល្បែងស៊ីសងនេះ ចាន់គ្រាបបង្គំទូលព្រះមហាក្សត្រិយ៍ ។ ខ្ញុំព្រះសុព័ណ្ណចាក្រពត្តិសិដ្ឋ ឡើងទៅលើកំពូលភ្នំសិនេរុ សំដែងគារវភាពចំពោះព្រះនាងមនស្សិនី, ហើយខ្ញុំព្រះខ័ននៅព្រះហស្ត, មានព្រះពរជ័យណាចង់កាត់ព្រះសិរ ។ ក្នុងពេលនោះ ព្រះនាងមនស្សិនី កំបង្ហាញរូបព្រះនាងឲ្យខ្ញុំឃើញហើយគ្រាបបង្គំទូលថា សូមព្រះអង្គទទួលយកវត្ថុនេះ, បើខ្ញុំមានព្រះពរជ័យយ៉ាងណា ។ ខ្ញុំនឹងបានសម្រេចដោយសារវត្ថុនេះ" ។ ព្រះអង្គទទួលវត្ថុនោះ ពីនាងទៅធីតាហើយ ខ្ញុំប្រគេនទៅអ្នកលេងល្បែងស៊ីសង ។ ខ្ញុំ កំបានធ្វើឲ្យអ្នកលេងល្បែងស៊ីសងនោះ លះបង់អំពើអកុសលអស់ចេញ ហើយខ្ញុំក៏ត្រឡប់ចូលកាន់កដ្ឋានវិញ ។

រួបទេពនិម្មិតទី ២៦ ទូលបន្ទូលថា: "ព្រះបាទកោដ: បើខ្ញុំមានព្រះបរិយាបែបនេះ ខ្ញុំអាចគង់នៅលើបល្ល័ង្កទិព្វនេះបាន" ។

ក្នុងពេលនោះ ព្រះបាទកោដ:ខ្ញុំមានព្រះទ័យរួញរា ហើយខ្ញុំយាងចេញពីបល្ល័ង្កទិព្វនោះទៅ ។

* * *

(មានត)

រឿងកូនក្មេង

របស់លោក ស. ប៉. ម. ស. អេរ៉ូយ

បុះផ្សាយក្នុងទស្សនាវដ្តី សេលេចស្យុង ខែតុលា ១៩៥២

អ្នកស្រី ពេជ្រ-សល់ ហៅ សារិះយ៉ាន់ ជាអ្នកប្រែ

យើងទាំងអស់គ្នា តែងធ្លាប់បានឃើញ ទំនងបានឮគេនិយាយអំពីកូនក្មេងជាញឹកញយណាស់ហើយ ប៉ុន្តែគ្មានអ្នកណាមួយនឹងអាចធ្វើយន្តវែបញ្ជាកូនក្មេងដែលដុសសាច់ជាប់គ្នាពីត្រឹមក្រែងជល់ពោះ ដូចខាងក្រោមនេះបានទេ :

– តើកុមារក្មេងទាំងពីរនាក់នេះ ជាមនុស្សមានវិចារណញ្ញាណជាប់ពីគ្នា ឬជាប់ចាក់ទងគ្នា ?

– បើសិនជាកុមារមួយបានប្រព្រឹត្តយាជកម្ម តើកុមារមួយទៀតមានការចោកទងជាមួយដែរឬ យ៉ាងណា ?

– អ្នកទាំងពីរនាក់ទឹកឃ្មានទងនឹងដុយដេកត្រមគ្នាឬ?

– មានសន្ធានចិត្តយ៉ាងម្តេចរវាងគ្នាទីងគ្នា ?

– បណ្តាជនទាំងពីរនេះ អ្នកណាត្រូវស្លាប់មុន ? ស្លាប់ព្រោះអ្វី ?

– តាមដែលលោកអ្នកបានដឹង តើមានស្រីមេម៉ាយប៉ុន្មាននាក់ដែលយកប្តីក្មេងនោះ ?

– ជនក្មេងដែលស្លាប់ទៅនោះ មានកូនប៉ុន្មាននាក់ ?

រឿងនេះយើញថាពិបាកនឹងដោះស្រាយណាស់ ។ បើដូច្នេះ យើង

សូមលើកយកឈ្មោះកូនក្មេង ឈ្មោះ ចាំង ទឹង អេង មកពណ៌នាជូនអស់លោកអ្នកអានស្តាប់ ដើម្បីទឹងវិនិច្ឆ័យ ដូចតទៅនេះ ៖

ចាំង ទឹង អេង ជាកូនក្មេងជាប់គ្នាពីក្នុងផ្ទៃម្តាយ ដល់ពោះ ក្រោយមកគេហៅថា ចាំង-អេង-ប៊ុនតែរ (ព្រោះមានស្ត្រីម្នាក់ឈ្មោះ ប៊ុនតែរ នៅក្រុងញូវយ៉ក មានចិត្តសប្បុរសបានទទួលយកកូនក្មេងនោះទៅចិញ្ចឹម) ។ កូនក្មេងនេះ កើតពី គ. ស. ១៨១១ ក្នុងភូមិនៃអ្នកនេសាទមួយ ដែលមៅមិនឆ្ងាយប៉ុន្មានពីក្រុងបាងកក ក្នុងប្រទេសសៀម ។ ឪពុកជាចិនសុទ្ធ តែម្តាយជាចិនកាត់សៀម ។ ចាំងមានកំពស់ ១ ម, ៥៥ អេង ១ ម, ៥៧ ។ ចាំងបានតស៊ូតែងស្បែកដើងឲ្យខ្ពស់បន្តិច ដើម្បីឲ្យបានកំពស់ស្មើទឹងអេង ។

បុរសចាំងពីរនាក់នេះ រកស៊ីចិញ្ចឹមជា យកពន្លក់ ។ អ្នកដឹងខាងគោតសរសើរចំពោះការប៉ុនប្រសប់ក្នុងការរកស៊ីរបស់ជនចាំង ២ នាក់នេះណាស់ ។ ជនចាំងពីរនេះនិយាយភាសាមួយ តែងនិយាយចាំងអស់គ្នា តំមួយចាប់ផ្តើមនិយាយ មួយទៀតជាអ្នកបញ្ចប់សេចក្តី ។

ថ្ងៃមួយ នៅពេលដែលបុរសចាំងពីរនាក់បានអាយុ ១៨ ឆ្នាំ, មានឪពុកចិញ្ចាស់ជាតិអាមេរិកាំងម្នាក់ បានចូលទៅចោះឃុតថ្មានៅតំបន់ផែក្រុងបាងកក ហើយបានជួបនឹងបុរសក្មេង តំណួចចាប់បុរសក្មេងនោះយកជាកំកូចាស់នាំទៅបុស្តង ក្រោយមកទៀតគាត់នាំទៅប្រទេសអឺរុប ។ ជនក្មេងចាំង ២ នាក់នេះបានដើរតែកង់តោះថ្វីតាន់តមួយប៉ុណ្ណោះ អស់រយៈផ្លូវចម្ងាយ ៤០០ គីឡូម៉ែត្រ ។ ក្នុងការធ្វើដំណើរនៃជនក្មេងនេះ

មានជនជាតិអង់គ្លេសប្រហែលជាង ៣០០.០០០ នាក់ ចាន់មកចោម
ពេមមើលខ្លួនបុរសក្មេងនោះ ។ សមាជិកនៃបណ្ឌិតសភាខាងសិល្ប-
សាស្ត្រ (ខាងរែកាត់) ចាន់ហៅបុរសក្មេងនេះទៅពីសាតែជាមួយ ។
សមាជិកចាំងឡាយនៃបណ្ឌិតសភា ក្រោយពីចាន់លួចសង្កេតពិនិត្យ
មើលបុរសក្មេងនោះហើយ ក៏បញ្ចេញយោបល់ថា ធម្មជាតិដែលបង្កើត
ឡើងយ៉ាងនេះ ជាការចំឡែកអស្ចារ្យណាស់ ។ ដែលយល់ថា ជា
ការប្លែកពីធម្មតានោះមិនខុសទេ ព្រោះបុរសក្មេងនោះមិនមែនគ្រាន់តែ
កើតមកម្ខាងពីរប៉ុណ្ណោះ គឺថែមចាំងកើតមកជាប់គ្នាទៀត ប៉ុន្តែគួរឲ្យអស្ចារ្យ
ពេកណាស់ ព្រោះបុរសក្មេងជាប់គ្នានេះ អាចរត់ ហែលទឹកនឹងដើរចាន
បានយ៉ាងចំនួន ១៥ គ.ម. ក្នុងមួយថ្ងៃ; សេងកាយកូនឃ្មុំ ហើយជាអ្នក
ចូលចិត្តទៅបរបាញ់សត្វផង ។ ប៉ុន្តែដើរចាន់តែខុសទិសគ្នា ។ កាលបើដេក
ដេកយកមុខឈ្លក់គ្នា ចើបែរខ្លួនទៅមួយចំហៀងទៀត ពាល់តែត្រឡប់
មួយដុំខ្លួនទើបបែរបាន ។ ការបែរខ្លួនរបៀបនេះ ចាន់ទៅជាខម្លាចយ៉ាង
ស្ងាត់ ដោយឥតចាំងក្លាក់ពីដេកទៀតផង ដូចយើងខ្លួនមួយដែរ ។ រូប
បុរសក្មេងនោះមិនមានអ្វីប្លែកពីយើង ឃើញប្លែកតែត្រង់ដុះសាច់មួយ
បន្ទុះប្រវែង ៩ សង្ទីម៉ែត្រ ទទឹងទំហំ ២០ ស-ម ភ្ជាប់គ្នាពីម្ខាក់ទៅ
ម្ខាក់តាំងពីត្រឹមពុងដង្ហើមទៅដល់ពោះដូចគ្នា ។

ចំពោះខាងក្នុងនៃសាច់មួយបន្ទុះដែលដុះភ្ជាប់នេះ អ្នកជំនាញការ
ខាងវិជ្ជាពេទ្យក្នុងសាកលលោកចេះតែមានមតិខ្វែងគ្នា ឃើញយល់
ស្របគ្នាតែត្រង់ថា ពាលណាកាត់ផ្តាច់សាច់នេះ ដើម្បីឲ្យបុរសចាំងពីរ

នៅជាប់ដោយខ្លួនពីគ្នានោះ មុខជាមានភ្លាត់ដល់បង់ជីវិតម្នាក់ ។ តុំខាន
ព្រោះគេបានយកមួល ១ ទៅចាក់ចំកណ្តាលបន្ទះសាច់នេះ ដើម្បី
ពិសោធន៍មើល គេឃើញបុរសភ្នែរញាចខ្លួនចាំងពីនាក់ ប៉ុន្តែលុះយក
មួលទៅបុចដើមបន្ទះសាច់ខាងស្តាំ ឬ ខាងឆ្វេងវិញ គេឃើញមានការ
ញាចតែអ្នកនៅជិត ឯអ្នកនៅឆ្ងាយមិនញាចទេ ។ កាលនៅពីកុមារ
ក្មេងនេះបានកើតកញ្ជ្រឹលនឹងកើតអុតព្រម ។ គ្នា ។ ប៉ុន្តែលុះក្មេងនេះ
ចាស់រៀងខ្លួន ទៅជាប្រែផ្នែកគ្នាទៅវិញ គឺម្នាក់ផឹកស្រា ម្នាក់ទៀតផឹក
ទឹកតែ ហើយមើកាលណាម្នាក់ស្រវឹង, អំណាចសុភនោះ គ្មានឲ្យផល
មកដល់ប្រុសម្នាក់ទៀតទេ ។

ក្រោយពីបានធ្វើដំណើរទៅប្រទេសអឺរ៉ុបលើកដំបូងមក ចាំងនឹង
អេងក៏បានត្រឡប់ចូលមកប្រទេសអាមេរិកវិញ ដោយគ្មានបានអ្វីក្រៅ
អំពីការពិសោធន៍ទេ ។ កាលនោះ កប៉ាល់ដែលបានតឹត់ចាំងនឹងអេង
មក ក៏ភ្លៀសគេចខ្លួនចោលចាំងនឹងអេង ។ ប៉ុន្តែជនភ្នែរចាំង ២ នាក់នេះ
បានស្គាល់គេជាច្រើននាក់ហើយ ជាពិសេសបំផុត គឺបានស្គាល់ចារុម
ដែលជាមេរបាំមួយនាក់លេងនៅទីផ្សារ ឬ នៅទីប្រជុំជនផ្សេង ។ ។
ចាំងនឹងអេងបានទៅរកស៊ីជាមួយនឹងចារុមនេះ អស់រយៈវេលា ៥ ឆ្នាំ
ប្រមូលចាក់បាន ៦០.០០០ ដុល្លា ។

យើងគ្មានទឹកស្មានថា នឹងមានស្ត្រីណាម្នាក់មានចិត្តស្នេហាចំពោះ
រូបចាំងនឹងអេងនេះទេ ចាំងបុរសភ្នែរសោតក៏យល់ដូច្នេះដែរ ប៉ុន្តែគួរឲ្យ
អស្ចារ្យណាស់ ស្រាប់តែមានស្ត្រីក្រមុំម្នាក់ឈ្មោះ សូហ្វីយ៉ា ដែលជា

កូនអ្នកមានពូជអម្បូរម្នាក់នៅក្រុងឡុងដ្រ៉ ជាន់ជួបជន់ភ្លោះនោះកំកើត
សេចក្តីស្នេហាយ៉ាងខ្លាំង ។ ចំនងនឹងអេងក៏ទៅជាស្រឡាំងកាំងតាំងពីរ
នាក់ ដោយពុំបានស្គាល់ចុកជាមុនថា ឱងកើតមានការណ៍ដូច្នេះសោះ ។
ប៉ុន្តែគួរឲ្យអាសូរនាងកញ្ញាណាស់ ពុំយូរប៉ុន្មាន សេចក្តីស្នេហារបស់នាង
ជាន់ជួបប្រទះខ្សែបស្ចិគួមួយធំដែលចៀសពុំផុត ព្រោះអ្នកជំនាញការ
ខាងវិជ្ជាពេទ្យធំ ។ នៅប្រទេសប្រ៊ីតានិកជាន់ជាប់នាងថា ចំនងនឹងអេង
នេះជាមនុស្សពីរនាក់ មិនមែនជាមនុស្សតែម្នាក់ហើយមានរូបពីរដូចជា
នាងស្មានឡើយ ។ នាងឮដូច្នេះ ក៏ស្រងាកចិត្តដោយនឹកខ្លាចក្រែង
មានរឿងព្រោះតែយកប្តីពីរ ដ្បិតថាតែកាលណារៀបការនៅជាមួយគ្នា
ទៅ មុខជានឹងទៅជាស្ត្រីមានប្តីពីរ ។

ដើម្បីនឹងសម្រាលទុក្ខ នាងក៏ទៅពឹងពាក់ឲ្យជួយតែងសេចក្តី
ជាស់ស្មាតើនាងជាពាក្យកាព្យឃ្លោង ដើម្បីបំភ្លេចចោលនូវសេចក្តីស្នេហា
របស់នាង ។ ឥរិយាណ្តិតនោះក៏ជានឧស្សាហ៍ព្រម លុះតែងរួចហើយក៏
ប្រគល់ឲ្យមកនាង ។ ឯពាក្យកាព្យនោះ មានសេចក្តីប្រហែលគ្នានឹង
កាព្យខាងក្រោមនេះ :

ធម្មតានារីមានភស្តា ពីរប្រាណទុក្ខាជាអនេក
ព្រោះកាលបើប្ងូលរួមជំណោក ឆឹងប្តីដៃលត្រេកក្នុងកាមស្នេហ្ក ។
ប្តីមួយរំដួលក្តៅក្តួលឆេះ ក្នុងទ្រូងស្ទើរប្រែដោយអន់អាក់
ម្ល៉ោះហើយរកឈឿងវាយប្រហាក់ នារីដល់ថ្នាក់ក្រៃជាំឈាម ។

ម្ខួយទៀតបើបំផ្លើប្តីម្ខួយ ប្តីម្ខួយប្រណែនប្រប់ណ្តាំភ្លាម
ធ្វើឲ្យនាងមានទុក្ខរហាម ឱអនិច្ចាកាមនារីអើយ! ។

កញ្ញាសូហ្គីយ៉ា កាលអានកំណាព្យនេះអស់រលោងជារួចនៃថ្ងៃទី កំប្លានបំភ្លេចកូនចិត្ត ទូរសេចក្តីប្រតិព័ទ្ធចំពោះបុរសក្មេះនោះបាន ។

រឿងកូនក្មេះដែលគោលមកខាងលើនេះ ជាបញ្ហាមួយដែលធ្វើឲ្យអ្នកប្រតិបត្តិច្បាប់តុលាការជាតិអាមេរិកាំង ខ្វល់ខ្វាយលជាខ្លែងព្រោះមនុស្សក្មេះនេះ តាមមតិពេទ្យថា ជាមនុស្សព្រៃនាក់ពិត ប៉ុន្តែ តើអ្នកទាំងពីរនេះ មានអ្វីជាសំគាល់ថាជាមនុស្សផ្សេងពីគ្នា? បើអ្នកទាំងពីរធ្វើអ្វី ? ក៏ធ្វើជាមួយគ្នាជាដរាបរៀងមកតាំងតែពីតូចដល់ធំ ។ នៅទីបំផុត គេបានផ្សាយយ៉ាងពិតប្រាកដថា កូនក្មេះនេះមានអំណាចនឹងចុះហត្ថលេខាលើកិច្ចសន្យាឬលើសារលិខិតកម្មសិទ្ធិ ដោយពេញច្បាប់ដាច់ដោយខ្លួនម្នាក់ៗ ក៏បាន ជាមួយគ្នាដូចធ្លាប់ជាសមាជិកក្រុមហ៊ុនក៏បានឬមួយម្នាក់ចុះហត្ថលេខាជំនួសម្នាក់ក៏បាន ប៉ុន្តែចំណែកធ្លើអាពាហ៍ពិពាហ៍វិញ ត្រូវដាច់ដោយឡែកពីគ្នា ហើយកូនរបស់ជនក្មេះម្នាក់ៗ ក៏ត្រូវបានទទួលក្តើមតិកជាច់ចំណែកពីគ្នាដែរ ។

ប៉ុន្តែ ចុះបើបណ្តាជនក្មេះទាំងពីរនេះ ជនម្នាក់បានប្រព្រឹត្តអំពើឃាដកម្ម តើម្នាក់ទៀតត្រូវចោទថាជាអ្នកសមគំនិតគ្នាដែរឬយ៉ាងណា? ចុះបើម្នាក់គ្មានធ្លើអំពើអាក្រក់ទេ តែម្នាក់ធ្លើ តើយកជនម្នាក់ដែលធ្លើនោះទៅដាក់គុកយ៉ាងដូចម្តេច ដោយកុំឲ្យអ្នកគ្មានទោសទៅរងទុក្ខជា

មួយជន? អ្នកចាំងពីរនេះ ប្តឹងប្តល់គ្នាមិនចាន់ទេ ព្រោះធ្វើអ្វីក៏ធ្វើជាមួយគ្នា គឺគ្រាកៗចាំងពីរ ឃ្លានៗចាំងពីរ បរិភោគអាហារចំនួនប៉ុនគ្នា; បើម្នាក់ជក់ជាវ បរិភោគស្មា មួយទៀតក៏ធ្វើតាមគ្នាដែរ ។ មានមនុស្សជារឿននាក់ចាន់ទៅនាំមនុស្សក្លែងនោះ ឲ្យនិយាយអំពីរឿងផ្សេងៗគ្នាលមើល ប៉ុន្តែគ្មានអ្នកណាមួយធ្វើចាន់សោះ ព្រោះបុរសក្លែងនោះ ខោះមានមតិប្លែកគ្នាយ៉ាងណាក៏ដោយ ក៏អ្នកចាំងពីរមិនអាចនិយាយរឿងពីរ ក្នុងពេលមួយជាមួយគ្នាឡើយ គឺអ្នកមួយនិយាយរឿងអ្វី អ្នកមួយបង្ហើយសេចក្តីនៃរឿងនោះ ។

គួរឲ្យអស្ចារ្យណាស់ ចាំងទឹងអេងមិនសូវឃើញនិយាយគ្នាទេ ហើយក៏ចាន់ប្រាប់គេថា "ចាំចាប់និយាយប្រាប់គ្នាធ្វើអ្វី បើយើងយល់ដូចគ្នាទៅហើយ" ។ ហេតុដូច្នេះចាន់ជាចាំងទឹងអេង មិនដែលលេងល្បែងអ្វីដែលជាល្បែងដេញប្រជាគ្នាជាមួយគ្នាដូចជាល្បែងចតុរង្គជាដើមទេ ។ ក៏លេងល្បែងតូកែណាស់ ប៉ុន្តែការដែលដឹងគំនិតគ្នាទៅវិញទៅមកហើយ ជាហេតុឲ្យអស់សប្បាយ ដូចយើងប្រែដៃស្មាំឲ្យលេងក្តាល់ជាមួយទឹងដែរនេះដូច្នោះឯង ។ តែចំណែកខាងផ្លូវនយោបាយ បុរសក្លែងមានយោបល់ប្លែកគ្នាទៅវិញ ព្រោះកងទ័ពសាធារណៈសង្គមរាស្ត្រនិយមអាមេរិកាំង កងទ័ព គ.ស.១៨៤៧ បុរសក្លែង មិនយល់ស្របតាមគ្នាទេ ចាន់ចោះឆ្នោតឲ្យបេក្ខជនផ្សេងគ្នា ។

បុរសក្លែងចាំងពីរនេះចេះនិយាយ ចេះសរសើរទឹងចេះមើលការសាអង់គ្នាចាន់សមគួរ មានសំលៀកបំពាក់តាមរបៀបអាមេរិកាំង ប៉ុន្តែ

ពុកសក់តាមរបៀបចិនបុរាណ គឺពុកសក់វែងប្រហែលមួយម៉ែត្រកន្ទុយដុំវិញក្បាល ។ ចាំងនឹងអេងជាមេការ៉ូយ៉ាងស្អាតស្អម ។

ក្រោយមកទៀត មានស្រីក្រមុំពីរនាក់ជាបងប្អូនធឹងគ្នា មានចិត្តប្រតិព័ទ្ធចំពោះរូបចាំងនឹងអេង ។ ជនខ្លះដែលចាំតែរិះគន់ គេក៏ខាំគ្នានិយាយថា ស្រីពីរនាក់នោះស្រឡាញ់ចាំងនឹងអេង ព្រោះតែឃើញចាំងនឹងអេងមានប្រាក់ ៦០.០០០ ដុល្លា ។ នៅថ្ងៃ ១ មេសា ឆ្នាំ ១៨៤៣ ចាំងបានរៀបការជាមួយនឹងនាងអាដឹឡាអ៊ុង-ឃៀត្ស, អេងរៀបការជាមួយនឹងនាង សាភ័-អាន នៅលៃតីស គុន្ទី ក្នុងស្រុកការ៉ូលីន ខែកខាងជើង ។ អ្នកផងនឹកថាមុខជាបានសុខនឹងគ្នាហើយ ព្រោះជនចាំងពីរគូសុទ្ធតែជាបងប្អូនធឹងគ្នា ប៉ុន្តែមិនបានយូរប៉ុន្មានទៅជាកើតរឿងវិវាទាស់ខែងខ្វែងគំនិតគ្នា ។ បងប្អូនស្រីចាំងពីរនាក់ចេះតែអាក់ចិត្តនឹងគ្នា ។ នៅទីបំផុត ចាំងនឹងអេងក៏ព្រមព្រៀងគ្នាឲ្យសង់ផ្ទះពីរ ឆ្ងាយពីគ្នាចម្ងាយ ៥ គ. ម. សម្រាប់ឲ្យប្រពន្ធខ្លួននៅរៀងខ្លួន ហើយបុរសក្មេះចាំងពីរទៅនៅជាមួយ ៣ ថ្ងៃម្តងៗ ។

ក្នុងរវាង ៣០ ឆ្នាំដែលជនក្មេះចាំងពីរនៅរួមរស់ជាមួយនឹងប្រពន្ធរៀងខ្លួន ចាំង ២ នាក់មានកូន ២២ នាក់ ហើយសុទ្ធតែមានប្រជាឈ្មោះសៀម, គឺអេង មានកូនប្រុស ៧ កូនស្រី ៥ កូនចាំង ១២ នេះគ្មានកែលវិការៈអ្វីទេ គឺដូចគេដូចឯងចាំងអស់ ។ ចាំងមានកូនស្រី ៧ មានកូនប្រុស ៣ ប៉ុន្តែបណ្តាកូនចាំង ១០ នេះ មានកូនប្រុសមួយ ស្រីមួយ គថ្លង់ ។

ក្នុងពេលនោះ មានកើតចម្បាំងគ្នាឯងក្នុងសហរដ្ឋអាមេរិកខាងត្បូង ។

ចាំងទឹងអេងជាពួកខាងត្បូង, លុះពួកខាងត្បូងប្លាំងចាញ់គេ ចាំងទឹងអេង
ក៏ត្រូវខ្ជួលសេចក្តីអន្តរាយជាមួយទឹងគេដែរ ហើយក៏ធ្លាក់ខ្លួនទៅជា
ក្រវិញ ។ បុរសក្មេះមានសេចក្តីវេទនាពេក ក៏បានន៎ាំគ្នាទៅនៅត្រើង
ញូវយ៉ក ដើម្បីទឹងសន្សំធ្លាក់កាស ដោយលេងរថ្មាំទៀត ប៉ុន្តែជាកសនា
អាក្រក់ ដោយអ្នកស្រុកមិនអើពើទឹងមើលរថ្មាំបុរសក្មេះទៀតឡើយ ។
ជនក្មេះលុះយើញពុំបានផល ក៏ត្រឡប់មកកាន់កន្លែងកាស៊ីដើមវិញ
ហើយទៅមកចុះឡើងទឹងផ្លូវប្រពន្ធដូចពីមុន គឺ ៣ ថ្ងៃផ្លូវប្រពន្ធចាំង,
៣ ថ្ងៃផ្លូវប្រពន្ធអេង ។

តាមសេចក្តីកត់ហេតុក្នុងសម័យនោះថា ចាំងទឹងអេង បានដំរេះ
ដើរលេង ខ្ជួលត្រូវក្មៀងខ្ទឹកផ្ងារពេក ហើយក៏ស្លាប់ចាំងពីនាក់ទៅ ។
មានអ្នកខ្លះទៀតនិយាយថា មកពីចាំងផឹកស្រាច្រើនពេក ។ តែតាម
សេចក្តីពិតវិញថា ក្នុងឆ្នាំដែលចាំងទឹងអេងបានអាយុ ៦៣ ឆ្នាំ គឺពីថ្ងៃ
សុក្រ ២៣ មករា គ. ស. ១៨៧៤ រំលាយបង់ ចាំងទឹងអេង នាំគ្នា
ចូលទៅដេកចាំងពីនោក់ ។ ហួសពេលអាត្មាតូចខ្ចិច បុរសក្មេះ
ចាំងពីនាក់ក៏ក្រោកមកអង្គុយទៅលើកៅអីមួយទៅក្បែរភ្លើងដែលគេធ្វើ
សម្រាប់គាត់ ។ អេងឆ្ងុយណាស់ ចង់ទៅដេកវិញ ប៉ុន្តែចាំងចេះតែ
ភ្ជួញថាដេកមិនបានព្រោះតឹងខ្លួណាស់ ។ បុរសក្មេះជជែកគ្នា ពីរឿង
ដេកឬមិនដេក អេងជក់ខ្សែរបណ្តើរ ។ ក្រោយបន្តិចមក អេងលត់
ភ្លើងថ្មីរហើយ ក៏ចូលទៅដេកចាំងពីនាក់លក់ស្កប់ស្កល់ទៅ ។

គួរឲ្យត្រឹមខ្លួនណាស់ លុះក្លឿងអេងគ្រាកហើយឃើញចាំងបែកធម្មតា ក៏សួរទៅកូនខ្លួនថា "ម៉េចទៅឥពុកធំឯង កូន?" ។

កូនឆ្លើយថា: ត្រជាក់ខ្លួនស្រេង ប្រហែលគាត់ស្លាប់ហើយ ។ គាន់តែឮពាក្យកូន អេងចេះតែយំ ហើយចេះតែបញ្ចេញអាការអន្ទះអន្ទែង ហើយហៅប្រពន្ធមកប្រាប់ថា "ការរស់នៅរបស់បងអស់ត្រឹមនេះហើយ" ថាតែប៉ុណ្ណេះគាត់ក៏ដាក់មុខទៅរកបងដែលស្លាប់ដេកនៅស្ងួតស្ងឹងដោយមានសេចក្តីតក់ស្លុតជាខ្លាំង ហើយស្រាប់តែញាក់ត្រឹតៗដូចគេកន្ត្រាក់ ។ ពីរមោងក្រោយមក អេងក៏ស្លាប់ដែរ ដោយពីល្ងចគ្មានឈឺអ្វីសោះ ។

សកាខាងវិជ្ជាពេទ្យបានបើកប្រជុំពិសេសមួយទៅហ្វីឡាដេលហ្វី ។ ការប្រជុំនេះ បានសម្រេចសេចក្តីថា បើសិនជាគាត់មនុស្សក្អេះដែលស្លាប់ឲ្យដាច់ចេញស្រឡះ អំពីមនុស្សក្អេះដែលរស់ក៏នៅតែមិនបាន ។ ម្យ៉ាងទៀតថា ចាំងស្លាប់ដោយដាច់សរសៃក្បាល, ឯអេងដែលស្លាប់តាមគ្នាទៅដែរនោះ គេរកហេតុពុំឃើញសោះ ហើយគេក៏បានអនុម័តថា អេងស្លាប់ព្រោះខ្លាចពេក ។

រឿងសៅរ៍សោយ

(សិរីសោភគត)

ព្រះមហាឧត្តមរាជ្ញា ធិលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាបាលីវង្សវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមគម្រោយសាស្ត្រាស្ទឹកវែត

(តចប់)

---

(១) (ពណ៌នាសរសើរព្រឹក្សវៃព្រ - ហាត់ហោងនោះនៃ បពិត្រលោកថ្លា ។

មង្ឃុតលុតសេដា	ធូរនេដូងស្វា	មាក់ប្លាងអង្គាល់ ។
ត្រឡតេមាក់ដោកសង្ឃ័រ	ត្នោតផ្លាវក្រូចឆ្មារ	ពោធិ៍សត្វសំសា ។
ក្រូចសើចចង្កឹសក់ដីកា	មាក់ប្លុងខែនំអា -	អូតន្ទូវឆ្មេញត្រី ។
គ្លូលែនលែនពែនស្រឡី	លាជផ្លុះឫស្សី	សាញប្រមាញនៃ ។
ស្រឡៅអំពៃលាំងដំយ	អំបែងរៃថ្ងៃនៃ	ជកពរក្សាសផង ។
លោតលៀចថ្ងាន់ទ្វារមេកង	ប៉ប្រែកសំពេង	ខ្លូវសត់ស៊ីតា (២) ។
ទទឹមត្រែបកហា	ស្នាយខ្លូវដែងវ្វា	ដើងចាបខ្លងហារ ។
កុមារពេជ្រពង្សធ្លឹះត្រកាល	សោមអាគ្នេយ៍ឈ្មោល	សាគុណគណនា ។
បញ្ចកក្តាំពាក់ក្រឹស្នា	ដើមចន្ទនា	គគីក្រូចរៃ ។
ពពេលធ្លឹកសូកែនៃ	កំងក្តុលូតលៃ	ចំបក់ធ្លូកផង ។
ស្រគំព្រឹងព្រួសដើមដង	ត្រាចខ្លងកគោះផង	រលួសតរនៃ ។

---

១ តាំងពីវង់ក្រចកនេះទៅដល់វង់ក្រចកខាងបុង ខ្ញុំចុកតាមបែបតម្រាដើមតាំងអស់ តុំមានកែប្រែឡើយ កែចំពោះតែអក្ខរាវិរុទ្ធិខ្លះបន្តិចប៉ុណ្ណោះ ។ ២ អានថា សេដា ។

រំដួលផ្កួលស្រទេញកែក ស្រមូរជ្រនៀងត្រៃ ឆ្នេញតែស្តៅខ្ទឹង ។
ដើមត្រៃព្រោធ៌ចាយទ្រយឹង កែខុបឥដ្ឋិង ម៉ប្រឹសកន្ទែង ។
តែឡកតែឡាត់ភ្លូកភ្លង ខ្នារបេងស្តើងផង រណាយគោនម្ហាក់ ។
គុយស្វាយខ្ទុះខ្ទីសឹងភ្លាក់ ពលផងសំណាក់ រើសស៊ីសម្បាយ ។
ខ្មែងសីរ(១) មាន់ដកពាយ ខ្មែងក្រែចគ្រាយ កន្ទុតសូរគី ។
បង្គៀចាន់ចារមូលី មាក់ប៉ែនអង្គាដី អម្ពិលពង្រ ។
ឆ្នាល់មាន់តុគ្រាសង្ស័រ ពេតក្រហមស ជ្រួយស្វាដៃខ្វា ។
កណ្តាប់ចង្អេរគ្រាលស្វា ព័ទ្ធដើមរកា ខ្នូរស្នែងស្នាច់ផង ។
សាច់គាវព័ទ្ធដើមផ្អង្អែហោង ចំពាំងចាយជូរផង ព័ទ្ធដើមបុស្សា ។
វល្ញិប្រែងព័ទ្ធដើមល្វា ពាំងដើមពត្លា ពាវព័ទ្ធត្រែសុំ ។
វល្ញិយាវព័ទ្ធដើមឥដ្ឋ វល្ញិខ្លួតព័ទ្ធរុំ ឈើត្រែលភាំងធ្នង់ ។
ខ្ទាប់ក្រៀវនូវប្រែក្រែង តាត្រាវត្បែងខ្លុង វល្ញិច្បាក់ព័ទ្ធញៀ ។
គ្រញូងញាខ្លាវល្ញិវាល្វៀ វល្ញិវើកឈើខ្លៀ វល្ញិវាយម្រែមធ្លារ ។
ដើមម្រែចពង្គឹះខ្លិតចារ៉ុំ ព្រិចឃ្លាយគ្រាសគ្រាល រលៀកដែកផង ។
កណ្តោលធ្នង់ល្វៀងហោង ព្រះកំចាត់ផង ព្រះខ្លែហឹនផងណា ។
កែវរកោតជយ័ជោតកញ្ចា ចិត្រុបុស្សហោក· ក្រវាញដីថ្ម ។
សម្បូរល្វែងឈើតែមនូវខ្លី យាគាមពាវិនី ម្ចាស់សិលា ។
កំញានធ្លាមព័ឃ្លាយណា យាហ៊ីនសោមដា មហាហង្សក្បែរ ។
អង្រែដែកតេជ្រដែកភ្លូមាន ខំលាយវត្ថុបាន តម្បាល់ដែកសែនខ្នែ ។

---

១ អានថា សេមន់ ។

វែដ្រសោមដំបងផ្តៅគ្រែ ដង្កោកំងនៃ អំនូនេសណា ។
ដំឡូងត្នោតក្តួចប្រស់ស្វា រំដេងដីសណា ប្រាលពងខ្ទៃ ។
ត្រកុតត្រថៀងឱ្យស្ងៃ ជីរខ្លាយស្លឹកគ្រៃ ប្រស់រមៀតផង ។
ការកោកខ្នែរបង្គុបហោង ចំត្រមូលក្តើងផង ព្រះក្រាបសំកុង ។
បណ្តូលពេជ្រខ្ទូរបំពង់ ស្រមោចអន្ទង់ បំពង់កំាផង ។
ប្រកុងកន្ទួចអាលហោង កែកព្រាបត្រីផង កញ្ជើចាយជាច ។
វល្ងីមាសព័ន្ធពាសដើមត្រាច វល្ងីប្រាក់សស្ងោច ឥតបើគណនា ។
ប្រដេញមមាញខ្លា កប្បាសមន្ត្រី ម្រេចខ្យាយផង ។
ពាក់ប្បាចម្ប៉ាំរំចេកហោង ចំប៉ីក្តាំងជាផង ចាយម៉ាតគាមត្រាន់ ។
ការកែសចេកខេសត្រយុង បុសនាគស្ពុះស្ពន់ ត្រកួនខ្ទួនស្រី ។
លណ្តែមហាហង្សមាលដី ស្រឡិតស្រឡី ម្ងិរត្រលាហោង ។
ត្រាំត្រែងចែងម៉ែងប្រឹងផង ក្រពាញជ្រកហោង ប៉ប្រែកលំពែងព្រះកម ។
ស្បូវក្តាំងត្រៀលគាំងសំរង ត្រប់នាឡិពុតលំញង ត្រប់ខ្លែកណ្តោលជាត ។
ក្រមួចសង្ខ្វួចចាំងក្រចាត់ កន្ត្រាកក្តួចាត លីងលាក់ម្រះត្រៀ ។
ព្រះថ្មដង្កោកំងខ្ទូវ លំពាន់ផ្តៀកផ្តៅ កំពឹងពួយហោង ។
ត្រសាំងចំហាំខ្ទឹមផង មេផាពាន់ហោង រីកពេយក្រាសត្រៃ ។
អំពៅក្តាមអំពៅព្រៃ អំពៅខ្មៅនៃ អំពៅបុសនាគ ។
អំពៅត្រែងគាមមហិមា[1] អស់ពលយោធា រមនារីកពេយ ។

---

១ ពាំងពីរដំណែកខាងដើមរហូតមកដល់ត្រង់ណោះ ខ្ញុំចុកតាមបែបចាស់ទាំងអស់ ។

រើសរើផ្លែឈើកយមាយ	ខ្លះយួរខ្លះស្ពាយ	វែកកយគ្រប់គ្នា ។
ខ្លះឈោងឡើងគោងម្ដងម្ដា	បេះឯផ្លែក	កល់គ្នាទីថៃ ។
កន្ត្រៃវៃខ្លារខ្លៃវៃត្រៃវៃក្រែ	ញាប់ញ័រខ្លុំវៃព្រៃ	វែងវៃគ្រសប្បាយ ។
ម្រឹគានានាតាំងឡាយ	ផ្ដើលវត់ខ្លាត់ខ្លាយ	ប្រតាយបញ្ជូតា ។
ក្បត្រៃក្បាន្តកំបានយាត្រា	ខតអស់ព្រឹក្សា	ចិន្តាមនោរម្យ ។
ទឹនវៃងសំវែងថ្ងៃងអំ –	ពីសត្វគួចធំ	ខ្លះខំដោយដី ។
នាងខតអស់សត្វបក្សី	ហើរត្រៃតឃ្លាតខ្លី	ផ្ទឹមផ្លូវគ្រប់ ។
មានព្រមសេកសោមរោ	ហើរចូលមូលគ្នា	ជាប់ជាគួរខ្លី ។
ចេកខ្ទុះខ្ទំចំប៉ី	ចឹកពាំចំណី	ចែកកូនដូនលៅ ។
ខុកខ្លែខ្ទំនាគាត្រៅ	ស្រែកយំគ្រែទ្ម	ជានឮត្រឹមត្រូច ។
ករវែកទំពឹកខ្មែមួច	ស្រែកយំគ្រលួច	គួរក្លួចស្រណោះ ។
កេងកងទំត្រងំកកោះ	ទំសោតលោតផ្ទោះ	ធ្លងធ្លៅទៅមក ។
ខទាទំនាដើមធ្លក	មើលមកលលក	រង៉ាវង្វេយគ្នា ។
ពញាក់ត្រាបពាក់ពញា	មានតាំងគ្នាំងងា	ផ្ការក្រែនវៃក្រែ ។
ពួកពលចល់គ្រប់ដៃ	ខ្លះបេះដកម៉ៃ	ថែថើបសប្បាយ ។
មានតាំងលាំងសាតស្ងាតស្ងាយ	ពលកំប្រញាយ	ប្រតាយជាទំគ្នា ។
ខ្លះបេះប្រៃឡេះខន្ធា	មង្ឃុតុព្រ	ជាន់គ្នាវែកវី ។
ស្រីខ្លះប្រុងសូរកី	នាំគ្នាមាម៉ី	ឡើងបេះរញ៉ី ។
ស្រីខ្លះឡើងបេះខ្លួនស្រី	ខ្លះឈោងពីដី	រំលែកចែកគ្នា ។
ឈើត្រៃត្រែនវៃក្រមហាមា	មិនដឹងនឹងជា	គណនាពប់ប្លាន ។

កូមីពោធី(๑)សត្វសាន្ត ជ័រខែខើបចាន ដល់ស្ថានបុរី ។
ថ្ងៃឯពីខេវីតីសី អនន្តតន់ស្រី ឥតបីសុខា ។
នាងនៅមើលផ្លូវកស្តា យូរខែហើយណា ។ពាឥតសេ្ងយ ។
ជ្រាបថាកស្តាមកហើយ តុំអង់រង់ខ្លើយ តែាណេតែយឃ្នាតខ្លឹ ។
ទៅទទួលវេស្សាម៍ នាងនុនសិរីសី ខុបចាខក្សត្រកក្សាន្ត ។
កន្ទែងរៃតែលែងប្រមាណ កណ្តោចខ្ទោចច្រាណ កល្យាណខូលថា ៖
“បពិត្រខ្ញុំចេស្តា ខ្ញុំម្ចាស់នេះណា ជីវ៉ាស្មើរក្បែយ ។
កាលខ្ញែងឃ្នាតបង់កំងជ័យ ខ្ញុំម្ចាស់នេះនៃ សរនែរតែលន់ ។
សោយសោកអមោក្ខពេកពន់ ។ពាពុវន់ លើសលន់ប្រមាណ ។
ខើបចាត់អមាត្យត្រែប់ច្រាណ ឲ្យរកក្សត្រកក្សាន្ត តែប់ឋានគ្នានសល់ ។
ជ្រែតជ្រកពាវកវេចល់ តែគ្មានចានយល់ ។សភលសោះខ្លើយ ។
ឆឹកថាក្សត្រាតាណេតែយ ប្រល័យក្បែយហើយ ព្រោះចាត់ស្ងាត់ឈឹង ។
ខ្ញុំម្ចាស់ព្រាត់ច្បាសចឹតឹង សោកយំពុំដឹង ពំនឹងអ្នកណា ។
នេះហេតុតែកេខផលៈ គុណបុណ្យជតា ក់សនាប្អូនស្រី ។
ខើបចានបួបប្តានចត្រី ចមតពនរចតី ដូចក្តីចំណង ។
បពិត្រខ្ញែងខ្ញុំប្អាស់ប្អង សូមខ្ញែងគង់គ្រែង ពស្តែងត្រែប់តាយ ។
សូមចានសុខសាន្តសប្បាយ ព្រះជន្មវែងឆ្ងាយ ហ្នឹនប្តូយវេស្សា ។
កុំប៉ីមានក្តីខុក្ខា បៀតបៀនចិន្តា កាយាខ្លើយហោង” ។
សិសៅរ៍ត្រាស់ទៅវិញផ្តង ចាប់ផ្តើមដើមខង ពំនង់សេចក្តី ។

---

๑ ពាក្យត្រូវតែ ពោធិ, តែនៃលេងាក់ជាពោធីនូវេះ ដើម្បីតម្រូវទៅតាមសម្ផស្សពាក្យ ។

តាំងពីស្តេចលីលាខ្ញី ចាកភពបុរី ចាកស្រីកនិដ្ឋា ។
នោកយ៉ាកលំបាកខ្លាំងខ្លា ដរាបលុះគ្រា ចក្រាបួថបួន ។
ទើរវ័ន្ទន៍សុខត្តមាសស្ងួន ហើយបានទឹមទួន ជាស្ងួនគួគ្រែង ។
មានបុត្រវិសុទ្ធខង់វង ហើយបានគ្រប់គ្រែង អចលរដ្ឋ ។
ទ្រង់បានព្រះនាន់ពេជ្រថ្លា មកុដសោតណា ទើរអាជានេយ្យ ។
ដែលស្តេចកាលត្រាប់ក្នុងវៃព្រៃ ត្រូវមនុស្សទីវៃ ចោមរ៉ែយកទៅ ។
កំបានវិញថ្លានគ្នានៅ ស្តេចច្រាប់ស្រែពៅ ឥតនៅសល់ឡើយ ។
ស្រែចប្លានក្សត្រក្សត្រានត្រើយ ត្រាស់ថា "ប្អូនណើយ ចូរនាងប្រណី
សុខត្តវរ័តន៍ក្សត្រី មានគុណឥតបើ ទើរស្តីឧបមា ។
បងបានវស់ពនជ័រ៉ា ព្រោះតែជីតា មេត្តារូបបង ។
ចូរស្រីកុំបីមានហ្មង ពាប់អានគ្នាផង ដូចញាតិដ៏ស្និទ្ធ" ។
ត្រាស់ស្រែចសម្តេចទ្រង់ឫទ្ធិ ទ្រង់ច្រាប់ព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតហោរា ។
មន្ត្រីសេនីយសេនា ឲ្យរៀបសីមា មហាបុរី ។
អកំសេកសម្តេចចក្រី ទើរតីក្សត្រី ជាថ្មីទៀតហោង ។
តាំងតន់អនន្តខង់វង ខាងស្តាំជាមួង, ឯស្តង្គតិសី ។
សុខត្តវរ័តន៍ក្សត្រី កូនរបស់ក្រី តាំងខ្លួនជាន្ទេង ។
មហោរីម្នាម្ចីពន្ទេង ខ្លួនគ្រប់សព្វភ្លេង គ្រឹកគ្រេងពេកវៃ ។
ពិធីចាប់តីនោះនៃ លុះប្រាំពីរថ្ងៃ ទើបចប់សព្វគ្រប់ ។
មហាជនលើសលន់គ្នានឈប់ ជំនឹងជាចមកគ ត្រឡប់បុរី ។
ត្រែកអរសាទរតតបី នាំគ្នាយាត្រាខ្ញី រញ៉ីសព្វថី ។

រៀបគ្រឿងដង្ហើងផ្កាក្រ៏ បូជាកូមី ជាទីស្នេហា ។
ថ្វាយពរបវរថ្លៃថ្លា ឲ្យមានជន្មសា (១) ហ្នឹងឆ្នាំជាម្ដង ។
ថ្ងៃឆ័ពោធិច្ឆាស់ច្បង ឆន្ទារសោសង ប្រែឯសេនា ។
ឲ្យសង់សំណង់សាលា ជ្រាំមួយសោតណា ជាទីឲ្យទាន ។
ខ្ចីចាយពំណាយជនជាន ធ្វើបុណ្យស៊ុន្ទរទាន តុំមានជាប់ឡើយ ។
ពួកស្មូមមកសូមគ្នានស្បើយ ក្បត្រតក្បាន្តគ្រានត្រើយ ល្អែល្អើយស្មោះ
សរ ។
កបគុណដោយបុណ្យបវរ ទសពិធកជធម៌ ប្រែពៃថ្ងៃថ្លា ។
ព្រះអគ្គស្តេចខ្ចីទសរាជ៍ រក្សាសីលា ជាប់ជាប្រក្រតី ។
ច្រឹតប្រែនខួន្នានប្រុស . ស្រី ពស្តីទាសចក្រី ជាន់ក្តីសុខសាន្ត ។
ស្រោចស្រង់មនុស្សផងត្រូប់ជ្រាណ ដោយក្តីស្មោះស្មាន តុំទានឡើយ
ណា ។
ពស្តីត្រូប់ខួសត្វតាយា សឹងស្ម័គ្រក្បា សីលាទីពៃ ។
ជាន់សុខឥតទុក្ខឥតភ័យ ដោយបុណ្យដៀស្ដង់ជ័យ ភូរន័យអម្ចាស់ ។
បើប្រៀបធម៌ធ្វើបឲ្យច្បាស់ ដូចព្រះពុទ្ធម្ចាស់ ទើបត្រាស់ជាថ្នី ។
ឯមនុស្សទាំងប្រុសទាំងស្រី ឥតទុក្ខអ្វី ។ សប្បាយត្រូប់ជ្រាណ ។
ថ្ងៃឆ័ពោធិសត្វសាន្ត ធ្វើបុណ្យស៊ុន្ទរទាន តុំមានលោះលា ។
លង់លុះដល់អស់ជន្មា ទៅសោយសុខជា នាសួគ៌ាល័យ ។
ឯក្បត្រកន្ទាត់ដៀស្ដង់ជ័យ ចំណេរចេរវៃ តើតជាទៅទត្ត ។

---

១ អានថា ជិន-ន៎ះសៈ; ពាក្យត្រូវតែជាន្ទរិស្សរៈ ។

ปุរេ ๔ នោះ ជ្រោកជ សុទ្ធសឹងភ្លាំងភ្លាត់ ឃាត់ទៅអវិចី ។
ទេវីសុទ្ធិវតី យោនយកមកខ្ញុំ ជាវិសាខា ។
អនន្តវត៌តន៌នោះណា ជាបតិដ្ឋក មហាកិត្តិ ។
សុទត្តវរវត៌តន៌ក្សត្រី កំណើតកើតខ្ញុំ ជាស្រីពិម្ពា ។
ឯបុត្រវិសុទ្ធសោភា យោនយកមកជា ព្រះកហុលជាក់ ។
អស់ពលសកលសេរ៉ក ស្តេចសាមន្តៈ គ្រប់នាក់ប្រុសស្រី ។
ចាំងមហាសេនាសេនិយ អមាត្យមន្ត្រី សម័យនោះថ្ងាត់ ។
ជ្រោកជជាពុទ្ធបរិសេទ្យ ចានលុះបរមេត្ត តាមព្រះសាស្តា ។
ខ្លះនោះតុំលុះសច្ចា កំឆ្លើសអា - បដិបត្តិឥតលោះ ។
ឯអង្គចមពង្សចំពោះ សិរីសៅរ៍អង្គនោះ គុំមោះសង្ឃ័យ ។
គឺបា្លស់ជាព្រះពុទ្ធថ្ងៃ សាសនាទៅមុខ សព្វថ្ងៃនេះហោង ។
សន្តោសខេសន៌ជ្រោសសត្វផង រួចជ្រាណាចានឆ្លង រំលងទុក្ខភ័យ ។
ខ្លះកំឡើងសួគាល័យ ដោយបុណ្យចារម៉ ប្រមប្រយសុខុម ។
ន: ន! តុង្ហោ! យើងខ្ញុំ អត័ព្វពេកតុំ ចាន់អង្គខ្ញែងញាណ ។
ព្រះអង្គស្តេចខ្ញែងនិញាន ខុកតែធម្មយាន ជាចានខ្ញុំម្ចាស់ ។
យើងខ្ញុំពិតតុំចាន់ព្រះ គឺចានចាន់ច្បាស់ តែព្រះសាសនា ។
តុំចានយល់ប្លាន់ភក្តា តុំចានស្តាប់មហា- ខេសនាខ្វែតផង ។
ថ្ងាថ្ងៃនសំដែងចែងចង ពីព្រះច្បាស់ច្បង ចប់ហោងហើយណា ។
រឿងភ័ព្រះទៅចក្រា សូវេចនាថា និដ្ឋិតាឯវំ ។

សកម្មភាពនៃក្រុមជំនុំនៀមធម្មាប់ខ្មែរ

បរិយាយពីវិធានការនៃក្រុមជំនុំ

នៅធម្មាសនៈ ១ ឆ្នាំ ១៩៥៦

លោក ចាប-ពិន រៀបរៀង

នៅធម្មាសនៈ ១ ឆ្នាំ ១៩៥៦ នេះ ក្រុមជំនុំនៀមធម្មាប់ខ្មែរ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានបើកទុកាសប្រឡងប្រជែងជ្រើសយកឯកសារនៀមធម្មាប់ខ្មែរ ១ រឿង ស្តីពីនៀមសត្វផ្សេងៗ ដើម្បីប្រមូលឯកសារអារ្យធម៌ខ្មែរមកវក្សាទុក ជាគោលចារិកប្រទេសខ្មែរតទៅ ។

ក្រុមជំនុំបានទទួលឯកសាររឿងនេះជាច្រើន អំពីបេក្ខជនជាបព្វជិតខ្លះ គហស្ថខ្លះ ដែលជាអ្នកចេះដឹងបានសរសេរមកដាក់ប្រឡង ហើយក្រុមជំនុំបានជួបជុំពិនិត្យឯកសារទាំងនោះទៅ ឃើញបានលទ្ធផលដូចតទៅនេះ ៖

– លោក គង់ - ចន្ទនៈ នៅផ្សារថ្មៃព្រៃទទឹង ឃុំថ្មៃជ្រៀង ស្រុកថ្មៃឈរ ខេត្តកំពង់ចាម ជាប់លេខ ១ ត្រូវបានរង្វាន់ ៤០០រ,០០ ;

– នាង អៀង - សុវណ្ណនារី នៅផ្ទះលេខ ១០ មហាវិថីព្រះបាទនរោត្តម ក្រុងភ្នំពេញ ជាប់លេខ ៣ ត្រូវបានរង្វាន់ ២០០រ,០០ ;

– លោក ខេត - រស់ នៅឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ ជាប់លេខ ៣ ត្រូវបានរង្វាន់ ២០០រ,០០ ;

- លោក អៀង-សឿង ខេត្តរលេខ ៧៨ វិថីព្រះអង្គឃុនន្ទរ ក្រុងភ្នំពេញ ចានជាប់លេខ ៤ ត្រូវបានរង្វាន់ ១០០រ,០០ ;

លោក ឃឿ ភ័ន ខេត្តឃុំកុំតុង តំបន់តាន ស្រុកបន្ទាយមាស ខែត្រកំពត ចានជាប់លេខ ៤ ត្រូវបានរង្វាន់ ១០០រ,០០ ។

ត្រៃពីការបែបនេះ, ខេត្តធមាសទី ១ ឆ្នាំ ១៩៥៦ នេះ ក្រុមដំនុំ ចានទទួលឯកសារទំនៀមទម្លាប់ជាច្រើនទៀត អំពីសមាជិកធ្វើយធ្វន ដែលយកចិត្តទុកដាក់ជួយឈ្នាលកិច្ចការរបស់ក្រុមដំនុំ ហើយដែលស្គាល់ប្រយោជន៍នៃការថែរក្សាទំនៀមទម្លាប់របស់ជាតិ ចានធ្វើអំណោយមក ។ ក្រុមដំនុំអរគុណយ៉ាងខ្លាំងចំពោះអំណោយនេះ សូមថ្លែងប្រកាសនាមអស់លោកជាសមាជិកទាំងនោះ ដូចតទៅ :

- ព្រះគេជព្រះគុណ ព្រហ្ម-គង មេគណ ខែត្រកំពង់ធំ ចានឲ្យឯកសារ ១ រឿង ស្តីពីទង់ក្រតើ ទង់ទង់ព្រលឹង ;

- លោក ម៉ម-ខេត អាចារ្យវត្តសន្ទុកត្រៀ ឃុំត្រកោះ ស្រុកសន្ទុក ខែត្រកំពង់ធំ ចានឲ្យឯកសារ ១ រឿង ស្តីពីពិធីលើកពស៊ី;

- លោក ឡឹម . មាស ខេត្តភូមិតូច ឃុំត្រាំងស្វាយ ស្រុកឈូក ខែត្រកំពត ចានឲ្យឯកសារ ២ រឿង ស្តីពីគ្រឿងតំណាង ១ ពិធីលើកពស៊ី ១ ;

- លោក វង្ស-ណែត ខេត្តភូមិអង្គចេក ឃុំកុំតុង (តំបន់តាន) ស្រុកបូកមាស ខែត្រកំពត ចានឲ្យឯកសារ ២ រឿង ស្តីពីគ្រឿងតំណាង ១ ពិធីលើកពស៊ី ១ ;

- លោក សុខ-ព្រហ្ម ខេត្តភូមិព្រែកគុយ ឃុំលាយប្ងរ ស្រុក

ត្រាំកក់ ខេត្តតាកែវ ចាន់ឲ្យឯកសារ ២ រឿង ស្តីពីគ្រឿងតំណាង ១ ព័ធលើកពស់ ១ ;

- លោកអាចារ្យ សួង-វង្ស នៅឃុំព្រៃតក្មៅ ស្រុកពញាឮ ខេត្តកណ្តាល ចាន់ឲ្យឯកសារ ១ រឿង ស្តីពីធម៌សូត្រលើកពស់;

- លោក ម៉ាយ. សារិន កងរក្សាខេត្ត នៅមន្ទីរយោសនាការ ស្រុកឆ្លូង ខេត្តក្រចេះ ចាន់ឲ្យឯកសារ ១ រឿង ស្តីពីសត្វ;

- លោក ជួង-ហាវ នៅភូមិត្រពាំងឈូក ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប ចាន់ឲ្យឯកសារ ២ រឿង ស្តីពីរឿងព្រៃនក្រពើ ១ រឿងព្រៃនគាត់ទេនទឹងភូមិស្រុក ១ ;

- លោក តិក្ខ ចាយ. សិង្ហអ៊ី គង់វត្តពោធិ៍ជ័យ (រកាងក្រាម) ឃុំរកាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចាន់ឲ្យឯកសារ ១ រឿង ស្តីពីត្រី;

- លោក ឈឿ-ភ័ន់ នៅឃុំតំកុង ស្រុកបន្ទាយមាស ខេត្តកំពត ចាន់ឲ្យឯកសារ ១ រឿង ស្តីពីសត្វផ្សេង ។;

- លោក កែវ-ហង្ស អតីតចាងហ្វាង នៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ចាន់ឲ្យឯកសារ ១ រឿង ស្តីពីសត្វផ្សេង ។;

- លោក គ្រូ ចាប-ចន្ធូ គង់វត្តក្តីក្រៅ ឃុំខ្វាវស ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ចាន់ឲ្យឯកសារ ១ រឿង ស្តីពីសត្វផ្សេង ។ ;

- លោក គឹម-ម៉ាន នៅឃុំគោរះ ស្រុកល្វាឯម ខេត្តកណ្តាល ចាន់ឲ្យឯកសារ ១ រឿង ស្តីពីសត្វផ្សេង ។ ;

- លោក ស្រី - អ៊ូ ក្រុមដំទុំព្រះវិត្តបំដក នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ចានឲ្យឯកសារ ២ រឿង ស្តីពីសត្វជាប្រយោលល្អអាក្រក់ ១ តឹកនឹងរឿងព្រៃនិ ;

- លោក អៀង - សៀង នៅផ្ទះលេខ ៧៨ វិថីព្រះអង្គឃុតន្ធ ក្រុងភ្នំពេញ ចានឲ្យឯកសារ ១ រឿង ស្តីពីសត្វ ;

- ខាង អៀង - សុវណ្ណនារី នៅផ្ទះលេខ ១០ មហាវិថីព្រះចាន់ នរោត្តម ភ្នំពេញ ចានឲ្យឯកសារ ១ រឿង ស្តីពីសត្វផ្សេង ។ ;

- លោកចាំង - ខាត់ ធ្វើការនៅភេនពុម្ពអ៊ុក - ម៉ុកុល ក្រុងភ្នំពេញ ចានឲ្យឯកសារ ១ រឿង ស្តីពីតឹកនឹងរឿងព្រៃនិ ;

- លោក ខេត - វស់ នៅឃុំលំចង់ ស្រុងសំរោង ខែត្រតាកែវ ចានឲ្យឯកសារ ១ រឿង ស្តីពីសត្វផ្សេង ។ ។

អស់សោកចាំងពីក្រុមដូចកយនាមខាងលើ ដែលចានសរសេរ ឯកសារទៅជាក់ប្រឡងក្តីទៅធ្វើអំណោយក្តី ក្នុងឆមាសទី ១ ឆ្នាំ ១៩៩៦ នេះឈ្មោះថាចានជួយឧបត្ថម្ភកិច្ចការរបស់ក្រុមដំទុំទំនៀមទម្ងាប់ ដែលកំពុងស្រាវជ្រាវរកទំនៀមទម្ងាប់ខ្មែរ ហើយដែលជាឧត្តមកិច្ចញ៉ាំងប្រទេសជាតិឲ្យចម្រើនឲ្យឋិតថេរគង់វង្សអស់កាលជាអង្វែងតទៅ ។

នៅទីបញ្ចប់, ក្រុមដំទុំទំនៀមទម្ងាប់ខ្មែរ សូមអំពាវនាវអស់លោកអ្នកជាបេក្ខជន ដែលភ្ជាប់ចានសរសេរឯកសារទំនៀមទម្ងាប់ប្រឡងរួចមកហើយ សូមឲ្យសរសេរប្រឡងទៀត ដើម្បីអស់លោកអ្នកជាសមាជិកធ្វើយឆ្នូងដែលភ្ជាប់ចានសរសេរឯកសារធ្វើអំណោយរួចហើយ ក៏សូមឲ្យ

សារសេរធ្វើអំណោយទៀត ។ ចំណែកអស់លោកអ្នកដែលមិនធ្លាប់ជាបេក្ខជន ឬជាសមាជិកធ្វើយធូរទេ បើបានឃើញបានផ្សាយប្រកាសប្រឡងថ្នាក់ឆមាសទី ២ ឆ្នាំ ១៩៩៦ នេះ ដែលក្រុមដំនុំខ្ញុំទទួលមកម្ចាប់បានចែកផ្សាយនោះ ហើយបើបានត្រៀតតុំតាស់សារសេរឯកសារតាមសំនួរកង់ប្រកាសនោះ ទៅជាក់ប្រឡង ឬទៅធ្វើអំណោយ ដោយឆាប់ធ្ងន់ដួយតំនុកបម្រុងកិច្ចការស្រាវជ្រាវរកឯកសារទំនៀមទម្លាប់តទៅ នោះក្រុមដំនុំសូមទទួលអំណរគុណយ៉ាងខ្ពស់ខ្ពុកជាមុន ។

ពាក្យអំពាវនាវ

សព្វថ្ងៃនេះកម្ពុជរដ្ឋ　　កំពុងត្រូវការគ្រូវិភក្ស
ទំនៀមទម្លាប់ជាតិទេឋភា　　សព្វយ៉ាងមិនជាទំនៀមអ្វី ។
ឲ្យតែទំនៀមជាតិខ្មែរយើង　　ដែលកើតមានឡើងនៅទឹកដី
កម្ពុជរដ្ឋខោះជាស់ឬី　　កំត្រូវឃ្លាតឡឹកតំរៀបរាប់ ។
ហេតុនេះអស់លោកវិញ្ញជន　　ដែលមានចិត្តឆ្ងល់ក្នុងទម្លាប់
ទំនៀមជាតិខ្មែរដែលខ្មែរធ្លាប់　　កាន់ជាប់ជាយូរអង្វែងធ្លាយ ។
សូមធ្វើតទ្ធកាសសរសេរតែង　　ឯកសារចារចែងថ្លែងបរិយាយ
ទំនៀមទម្លាប់ខ្មែរកាំងឡាយ　　អធិប្បាយប្រាប់ដើមកំណើតផង ។
តាមគោលសំនួរដែលក្នុងក្រុម　　ដំនុំបានសួរជាទំនង
នៅក្នុងប្រកាសការប្រឡង　　ប្រាំមួយខែម្តងជាទម្លាប់ ។
ឯកសារលោកណាល្អគ្រប់គ្រាន់　　ខឹងបានរង្វាន់យ៉ាងគួរគាប់
តាមលេខខ្ពស់ទាបដែលបានជាប់　　ជាភ័ព្វនៃអ្នកនិពន្ធអើយ ។

ចាប-ពិន

មន្ត្រីពេទ្យព្រះសង្ឃ
បានកើតឡើងនៅខែត្រតាកែវ

ពុទ្ធសាសនបណ្ឌិត្យ

(ត—ចប់)

គោះកន្លងសម័យពីបុរាណក្តី បច្ចុប្បន្ននេះក្តី បច្ច័យបួន ជាមធ្យោបាយ លៀងជីវិតព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ឲ្យប្រព្រឹត្តទៅបានស្រួលក្នុងព្រហ្មចរិយធម៌ សមដូចពាក្យដែលលោកចាំងអូលបបួលគ្នាទិយមថា ជីវិតាពន្ធនំ ពុទ្ធស្ស ។

ពិតណាលោកក្នុងបច្ចុប្បន្នកាលនេះ កំពុងខំប្រឹងកសាងជីវិតប្រជាជនឲ្យរស់នៅដោយស្រួល ដោយផ្តល់ឲ្យមាន ៖ ១—គ្រឿងស្លៀកពាក់, ២—អាហារបរិភោគ, ៣—ទីលំនៅ ៤—ឱសថគ្រែពេត; ចាំងបួនប្រការនេះ ឲ្យមានបរិបូណ៌ឃ្លាំងណា ក្នុងព្រះពុទ្ធសាសនាខាយកខាយិកា ក៏មានការៈផ្តល់បច្ច័យចាំង ៤ គឺ ១—ចីវរ, ២—បិណ្ឌបាត, ៣—សេនាសនៈ, ៤—គេសជ្ជ; ប្រគេនដល់ព្រះសង្ឃយ៉ាងខោះឡែព្រោះមនុស្សលោកដែលនឹងរស់នៅបាន ក៏ដោយអាស្រ័យបច្ច័យចាំង ៤ នេះឯង បើខ្វះខាតបច្ច័យណាមួយហើយមនុស្សក្នុងពិភពលោក មិនអាចរស់នៅបានទេ ឆ្លងសេចក្តីថា បើមានតែគ្រឿងស្លៀកពាក់គ្មានអាហារគ្មានទីលំនៅ គ្មានឱសថគ្រែពេតទេ មនុស្សរស់នៅមិនបាន, មានតែគ្រឿង

ស្មៀកពាក់ទឹងអាហារ តែខ្វះខាតទីលំនៅខ្លះ ទុសថតែកេត មនុស្សរស់នៅមិនបានដែរ មានតែត្រឹងស្មៀកពាក់អាហារនឹងទីលំនៅ ហើយគ្មានទុសថតែកេត មនុស្សក៏រស់នៅមិនបានទៀត ព្រោះមនុស្សយើងរមែងមានកេតតាមជាប់នឹងប្រជាសត្រូវធំ សម្រាប់បំផ្លាញសេចក្តីសុខ បើមិនបានសុខភាពហើយ តើមនុស្សធ្វើសេចក្តីចំរើនឲ្យលោកដូចម្តេចបាន ។

ពុទ្ធភាសិតបានត្រាស់មួយកន្លែងថា : "ការមិនមានកេត ជាលាភមួយយ៉ាងធំរបស់មនុស្ស" ។ ប៉ុន្តែការស្វែងរកបច្ច័យ ៤ ដើម្បីយកមកលៀងជីវិតនេះមិនមែនគ្រាន់តែសម្រាប់ឲ្យរស់នៅប៉ុណ្ណោះទេ គឺថាកាលបើរស់នៅស្រួលហើយ ត្រូវបំពេញប្រយោជន៍ខ្លួនទឹងប្រយោជន៍សង្គមជាតិ ព្រមទាំងបំពេញកុសលធម៌ដទៃទៀត មានសីលធម៌ជាដើម ដើម្បីសេចក្តីសុខធ្វើមរស់ទាំងអស់គ្នា ទឹងដើម្បីកសាងខ្លួនឲ្យទៅជាអារ្យជន, កាលបើប្រទេសណាមានអារ្យជនបរិបូណ៌ហើយ ប្រទេសនោះក៏បានឈ្មោះថា អារ្យប្រទេស ដោយពិតប្រាកដ ។

មន្ទីរពេទ្យជាលអាពាធព្រះសង្ឃនេះកសាងឡើងសម្រាប់ផ្តល់បច្ច័យ ទី ៤ គឺថ្នាំតែកេតចំពោះព្រះសង្ឃខ្លួនឯង ដើម្បីឲ្យពុទ្ធសមណៈរស់នៅបានដោយសុខស្រួលមានអនាម័យល្អ មានឱកាសរៀនសូត្របំពេញសមណធម៌ ព្រហ្មចរិយធម៌ ហើយនឹងពន្លឹកព្រះពុទ្ធសាសនាឲ្យផ្សាយខ្លួនឯងទៅពេញសាកលលោក ឲ្យពិភពលោកបានទទួលគ្រែបវរសជាតិសន្តិភាពពិត តាមព្រះពុទ្ធសាសនា ព្រមទាំងជួយប្រែនប្រែជាជន

រួមជាតិយើង ឲ្យជាសម្ភារៈដ្ឋិ តាំងនៅក្នុងចរិយាដ៏ខ្ពង់ខ្ពស់ សមជា
អារ្យពលរដ្ឋមានវិន័យដ៏ប្រសើរ ។

ខ្ញុំព្រះករុណា - ខ្ញុំសូមធ្វើតយកវាលកាសនេះ ថ្វែងសេចក្តីសរសើរ
ទឹងសេចក្តីគ្រែកអរចំពោះគណៈកម្មាធិការ ចាត់ការកសាងមន្ទីរគិលាន-
សង្គ្រោះចំពោះព្រះសង្ឃក្នុងខេត្តតាកែវនេះ ចំពោះបរិស័ទចាំងឡាយក្នុង
ខេត្ត ដែលចេះរួបរួមកម្លាំងសាមគ្គីយ៉ាងម៉ឺងម៉ាត់ ក្នុងការកសាងមន្ទីរ
ពែកសេចក្តីសុខដល់ព្រះសង្ឃឲ្យបានគ្រប់គ្រាន់នេះ ។ នៅក្នុងខេត្តនៃព្រះ
ពុទ្ធអាណាចក្រកម្ពុជា គ្រែអំពីសៀមកចនឹងពុទ្ធជាន់ចេញ ពុំមានខេត្ត
ខេត្តណាមួយបានកសាងមន្ទីរព្យាបាលរោគព្រះសង្ឃឲ្យបានគ្រប់គ្រាន់ដូចខេត្ត
តាកែវនេះទេ ។ អំពើកុសលយ៉ាងសុក្រឹតនេះសន្មតថាពុទ្ធបរិស័ទខេត្ត
តាកែវបានពាក់ពែកយើញផ្លូវល្អ ហើយអាចសង្ឃឹមថា អំពើល្អដ៏ថ្លៃថ្លានេះ
មុខជាទឹងសាយភាយទៅប្រតិស្ឋាននៅខេត្តដទៃ ។ ក្នុងកាលអនាគត
ដ៏ឆាប់នេះជាពុំខាន ។

ការកសាងដូច្នេះនេះ លុះតែតែមានឧបោថាយយល់ត្រូវទើប
ធ្វើទៅកើត ហើយឧបោថាយនេះស្រេចទៅតាមឧបោថាយនៃព្រះពុទ្ធ-
រដ្ឋាភិបាល ដែលមានព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទឹង សម្តេចព្រះ
មហាក្សត្រិយានី សម្តេចព្រះឧបយុវរាជ ជាប្រមុខ ដែលព្រះអង្គតែង
មានព្រះពុទ្ធបំណងជានិច្ច ចង់បំបាត់អាពាធព្រះសង្ឃទឹងពេគាព្យាធិ
ប្រជាជនរបស់ព្រះអង្គ ព្រោះថាជម្ងឺប្រជាជនក៏គឺជម្ងឺព្រះអង្គ ។

អ្នកមានជម្ងឺគឺអ្នកមានទុក្ខ មន្ទីរព្យាបាលព្រះសង្ឃ ជាមន្ទីរអាម្ងាប់

ពេត វម្ចាប់ទុក្ខ ជាមេបុណ្យមួយដ៏ធំសម្រាប់អ្នកប្រាថ្នាបុណ្យ សមដូច
ព្រះតម្រាស់ព្រះសម្ពុទ្ធថា "អ្នកឮធម៌ណាល ព្រះសង្ឃឈ្មោះថាឮធម៌ណាល
តថាគត" សេចក្តីនេះបញ្ជាក់ថា យើងបានបំរើព្រះបរមសម្ពុទ្ធគ្រប់ៗ
គ្នា បានអានិសង្សច្រើនអនេកអនន្ត ដែលស្របនឹងព្រះពុទ្ធដីកាមួយព្រះ
ឧស្ឋខ្មៀតថា "អ្នកមានប្រាជ្ញាជាអ្នកឲ្យសេចក្តីសុខគេ ត្រូវមានសេចក្តី
សុខមកដល់ខ្លួនវិញ" ។

ទីបំផុត ខ្ញុំព្រះករុណា ខ្ញុំ សូមបួងសួងគុណព្រះរតនត្រ័យ សូម
មេត្តាប្រោសអភិបាលរក្សាព្រះករុណាជាអម្ចាស់ដ៏វិតលើត្បូង សម្តេចព្រះ
មហាក្សត្រិយានី នឹងសម្តេចព្រះឧបយុវរាជ ព្រមទាំងអស់លោក · អ្នក
ជាពុទ្ធបរិស័ទ គណៈកម្មាធិការ កសាងមន្ទីរព្យាបាលព្រះសង្ឃនេះ
ដោយកម្លាំងចិត្តកម្លាំងកាយក្តី សូមឲ្យបានសេចក្តីសុខសួស្តីសិរីវឌ្ឍន៍
ប្រាសចាកទុក្ខភេតភ័យគ្រប់ប្រការ សមតាមសេចក្តីប្រាថ្នាកុំបីឃ្លាត ! ។

*
* *

សុត្តរកថាព្រះអាចារ្យសោម - ស៊ឹម

បន្ទាប់មកកិត្តិសោម - ស៊ឹម អាចារ្យបង្រៀនបាលី វត្តសីហវនា-
រាម (តាកែវ) ថ្លែងសុត្តរកថាតំណាងព្រះតេជព្រះគុណ ព្រះមង្គល
ទិព្វលោកវង្ស៊ី មេគណខែត្តតាកែវ មានសេចក្តីដូចតទៅនេះ ៖

សូមថ្វាយបង្គំ ពិតជាវជីកាព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សូមចំរើន
ពរលោកវរជ្ឈក្ខាធិការត្រកូងធម្មការនឹងឃោសនាការជាតិ ព្រមទាំងសហ-

ការ៉ ព្រមទាំងអស់ពុទ្ធបរិស័ទទាំងឡាយដែលបានទិមន្តបានអញ្ជើញមក
ជាអធិបតីជាកិត្តិយសក្នុងទីនេះ

សូមមានព្រះពរ សូមព្រះពរ ។

ក្នុងហានៈជាតំណាងព្រះតេជគុណ ព្រះមង្គលទិព្វលោការង្សី មេ-
គណខែត្រតាកែវ ខ្ញុំព្រះករុណាអគ្គាភាព សូមថ្វាយទូវសង្គ្រហាមួយ
ដើម្បីជាកិច្ចរំលឹកទូវដំនាន់នៃការស្ថាបនាមន្ទីរពេទ្យព្រះសង្ឃនេះ ទើប
គោរពទទួលទូវសមានចិត្តនៃព្រះថេរានុត្តរៈគ្រប់ព្រះអង្គ ព្រមទាំងអស់
លោកជាឥស្សរជនទើបអស់លោកសប្បុរសទាំងឡាយ ក្នុងពេលធ្វើបុណ្យ
សម្ពោធមន្ទីរពេទ្យ ដែលគណៈកម្មការបានតែងឡើងក្រោមអធិបតីភាព
នៃលោកជាប្រមុខខែត្រតាកែវ ។

ព្រះថេរានុត្តរៈគ្រប់ព្រះអង្គ !

អស់លោកសប្បុរសទាំងឡាយ !

ក្នុងនាមនៃព្រះតេជព្រះគុណ ព្រះមង្គលទិព្វលោការង្សី មេគណ
ខែត្រតាកែវ សូមសំដែងទូវមនោសញ្ចេតនាដ៏ជ្រាលជ្រៅ ប្រតិភា-
មោទ្យយ៉ាងក្រៃលែងចំពោះស្នាគមន៍ នៃព្រះថេរានុត្តរៈគ្រប់ព្រះអង្គ
លោការដ្ឋលេខាធិការ លោកសប្បុរសទាំងឡាយក្នុងទីប្រជុំនេះ ។

ការចាប់កំណើតនៃមន្ទីរពេទ្យនេះជាដំបូងនៅឆ្នាំ ១៩៥៣ ខែកញ្ញា
ដោយមកពីលោក អៀប - ហុងលឹម អតីតចៅហ្វាយខែត្រតាកែវ ទើប
លោកបេ តេងហ៊ាន អតីតគ្រូពេទ្យនាយក ព្រមទាំងអស់លោកជា
ក្រុមសមាជិកទាំងអស់ ដូចមានពាយនាមក្នុងការប្រកាសក្តក់នេះស្រាប់ ។

កល្យាណកម្មដ៏ត្រកាលនេះ កើតឡើងក្នុងកំចាប់មានការស្រែកអំពាវនាវ
យោសនាគ្រឿងសម្ភារៈធ្វាក់ការសម្រាប់សាងមន្ទីរពេទ្យនេះ ដល់ព្រះ
គុណាគ្រប់ព្រះអង្គក្នុងខែត្រតាំងមូល មានព្រះតេជព្រះគុណអនុគណ
ចៅអធិការ ដោយមានឧបាសកឧបាសិកាជាកំពូង ។

ការយោសនានេះបើគិតតាំងពីសេចក្តីព្រាងជាបឋម គឺជនាន់លោក
អៀប - ហុងលឹម អតីតចៅហ្វាយខែត្រតាកែវ បានចាប់ផ្តើមធ្វើបុណ្យ
ផ្លាយោសនាពីរលើក មកដល់ជំនាន់លោកឡា - ប៊ុនចាំ អតីតចៅ-
ហ្វាយខែត្រ ដែលទើបទំនងផ្ទាស់ទៅថ្មីៗ នេះ បានចាត់យោសនាម្តង
ទៀតជាគំរប់បីលើក ។ បច្ចុយតាំងអស់ដែលបានមកពីព្រះគុណាគ្រប់
ព្រះអង្គគ្រប់វត្ត ក្នុងខែត្រតាំងមូល ទឹងខែត្រជិតខែជាច្រើន ទឹងក្រុម
អស់លោកជាសមាជិកគ្រប់ចៅក្រសួង ព្រមទាំងសហការីនៃក្នាក់ងារ
ពាណិជ្ជការ តាំងពីក្រុងខែត្រជាដើម រហូតទៅដល់ស្រុកឃុំជាទីបំផុតនោះ
បានចំនួន ៣០០.០០០រ, (បីសែនរៀល) ដែលបានចំណាយរួចទៅ
លើមន្ទីរពេទ្យនេះ ។ ឯការយើតដំណើរក្នុងការធ្វើឲ្យបានរួចរាល់ជាមន្ទីរ-
ពេទ្យនេះរួចស្រេចចាប់នោះ ដោយមកពីមានការផ្ទាស់ប្តូរនៃលោកដែល
ជាដើមគំនិតទាំងប៉ុន្មាន មានលោកអៀប - ហុងលឹម ជាចៅហ្វាយខែត្រ
ទឹងលោកបេ - កេង់ហ៊ានជាដើម ។ តែបើគុណាជាមានឧបសគ្គស្ងាត់
ឲ្យយឺតយ៉ាងណាក៏ដោយ ក្នុងជំនាន់នៃលោកឡា - ប៊ុនចាំ ទឹងលោក
គ្រូពេទ្យទាយក យិត - តាមសេង បច្ចុប្បន្ននេះ លោកបានពូតផ្គុំអស់លោក

ជាក្រុមសមាជិកចាប់ផ្តើមស្ថាបនា ត្រាតែហើយស្រេចជាស្ថាពរ ដូច
ព្រះតេជព្រះគុណអស់លោកជាបឃើញដោយច្បាស់ក្នុងពេលនេះ ។

គួរឱ្យរំភើបចិត្តយ៉ាងក្រៃលែង ចំពោះអស់លោកគណៈកម្មការ
ស្ថាបនាមន្ទីរពេទ្យព្រះសង្ឃនេះ ដែលតាំងពីកាលណាមកអស់លោក
តែងមមាញឹកក្នុងការណ៍យកចិត្តទុកដាក់ខ្ជាប់ខ្ជួនគឺការងារបស់ពុជការដ្ឋកិច្ចល ។
អស់លោកបានធ្វើតទុកាសផ្តើម ទ្វារឧត្តមកម្មដ៏វិសិដ្ឋនេះឱ្យកើតឡើង
ដែលជាគ្រឿងដោះបង្ហាញទ្វារឧត្តមគតិ របស់ពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់
លោតសន្ធឹងទ្វារគំនិតសប្បុរសស្មោះចំពោះប្រាកដជាពុទ្ធសាសនិកជន តាំង
នាមុនតាំងពីស្តេចសម្តែរវៀតាមព្រះពាជបំណង នៃព្រះករុណាជាអម្ចាស់
ជីវិត សម្តេចសហជីវិន នរោត្តម-សីហនុ ទុបយុវរាជ ដែលទ្រង់អំពាវ-
នាវដល់ប្រជាពលរដ្ឋគ្រប់ហ្មុនៈ ដើម្បីពួតដៃគ្នាធ្វើកិច្ចការកុំមើលបំណាំ ។
ប្រទេសកម្ពុជាមានក្តីមានមោទនភាពយ៉ាងធំ ជាតិ-សាសនា-ព្រះមហាក្សត្រិយ៍
ដែលបុព្វបុរសរបស់យើងទុកឱ្យ ។

ចំពោះព្រះពុទ្ធសាសនា ពលរដ្ឋខ្មែរគ្រាប់ខ្ជាប់ហើយលើកតំកើងជា
យូរអង្វែងតាំងណាស់មកហើយ, មន្ទីរពេទ្យព្រះសង្ឃនេះ គួរពាប់ថាជាសម្បត្តិ
របស់ប្រទេសកម្ពុជាផង ជាមហាកុសលយ៉ាងមហាស្ចារ្យចំពោះផ្លូវសា-
សនាផង ដោយចំពោះទៅតឹងជាកិត្តិយសដល់ខែត្តតាកែវយើងនេះឯង ។
សូមឱ្យព្រះករុណាគ្រប់ព្រះអង្គ អស់លោកជ្រាបថា បណ្តាមន្ទីរពេទ្យ
ព្រះសង្ឃពុទ្ធសាសនិកប្រទេសកម្ពុជា មន្ទីរពេទ្យនេះជាទី ៣ បន្ទាប់អំពី
គំនាទសង្គ្រោះចំពោះព្រះសង្ឃក្រុងភ្នំពេញ ទីឯខែត្រសៀមរាបមក,

ទៃគ្រានាងជាទៃទៀតមិនខាន់មានទៅឡើយទេ ។ ព័ពេលនេះទៅថ្ងៃមុខ កិក្ខុសាមណេរដែលមានអាពាធ គ្រូនៃមន្តមកព្យាបាលពេត លែងលំបាក លែងច្រឡូកច្រឡំដោយទុក្ខសុកទុក្ខសិការទៀតហើយ គឺយើងមានកន្ទែងជាប់ដោយឡែក ចាំនដល់ទីនេះឯង ។

ម្យ៉ាងទៀត មន្ទីរពេទ្យដែលធ្វើហើយរួចជាស្រេចនេះ ជាសាលសម្រាប់ព្រះសង្ឃមានអាពាធសឹង នៅខ្វះកេងថែវមួយទៀត ជាកន្ទែងសម្រាប់ស្នាក់នៃវេយ្យាវច្នកររបស់កិក្ខុ - សាមណេរអ្នកជម្ងឺ ។ ព្រោះថាកិក្ខុសាមណេរដែលមានអាពាធ ហើយនិមន្តមកសឹងព្យាបាលពេតក្នុងមន្ទីរពេទ្យ មិនលែងមានជាប់ដោយទុក្ខសុកទុក្ខសិការក្នុងមកជាមួយផងទេ ដើម្បីកុំឲ្យមានការច្រឡូកច្រឡំនោះ គ្រូវតែធ្វើកេងថែវមួយតួចល្មមទៅក្បែរគ្រឹះស្ថានធំនេះ ។

ទីស្តីជាកុសលម្យ៉ាងទៀត របស់លោកគ្រូពេទ្យនាយក យ៉ិត - គិម-សេង បច្ចុប្បន្ននេះថា អំណើះតទៅអនាគត បើហើយកិច្ចការដែលគ្រូវធ្វើរួចជាស្រេច ដើម្បីជួយបន្ទរការៈចំណាយនៃថវិកាជាតិខ្លះកុំឲ្យខ្លះខាត គ្រឿងសម្ភារៈផ្សេងៗសម្រាប់មន្ទីរពេទ្យនេះ មានថ្នាំព្យាបាលពេតជាដើមនោះ គ្រូវតួតដៃគ្នាមិនរើសមុខ ចែមួលបច្ច័យយកទៅទិញថ្នាំមកទុកបំរុងក្នុងទីនេះ ជាគ្រឿងជំនួយដល់ថ្នាំដែលរាជការចែកឲ្យមកកុំឲ្យខ្លះខាត ។ រឿងនេះព្រះតេជៈព្រះគុណ ខ្ញុំសូមលោកអ្នក សប្បុរសទាំងឡាយ តង់ជ្រាបថា: ព្រះសម្តេចបរមគ្រូរបស់យើង ព្រះអគ្គទ្រង់ប្រកាសសំដែងជាទុក្ខវាកថា: កិក្ខុសាមណេរណា ចានយកចិត្តទុកដាក់បំពេញជម្ងឺនៃកិក្ខុ

សាមណេរផង់គ្នាដែលមានជម្ងឺ កិក្ខុសាមណេរនោះឈ្មោះថា ជាន់ចំរើតថាគតផ្ទាល់ ។

ចុះពេលនេះយើងមិនជាន់មកចំរើផ្ទាល់ដោយខ្លួនយើងមែន តែកម្លាំងនៃចាតរចេតនាយើង ជាន់លះខ្យល់ត្តិដួយកសាង តាំងពីមន្ទីរពេទ្យរហូតដល់ផ្ទាំងជាដើមទៀត គង់ជាន់ឈ្មោះថាយើងដួងចំរើព្រះសម្ពុទ្ធ ឬព្រះពុទ្ធសាសនាដោយសព្វគ្រប់ ។ ហើយគេលនេះក៏ជាជោគវាសនារបស់យើងផង ទៅតែប៉ុន្មានខែទៀតទេ ទីដល់ពាក់កណ្តាលព្រះពុទ្ធសាសនា គំរប់ ២.៥០០ ឆ្នាំ ដែលពិភពលោកទាំងមូលជនអ្នកកាន់ព្រះពុទ្ធសាសនា ទីដ៏ធ្វើបុណ្យធំៗឡើង ដើម្បីគោរពទីដ៏ប្លងសួងឲ្យព្រះពុទ្ធសាសនារុងរឿងជាន់គ្រប់ ៥.០០០ ឆ្នាំ សរសើរតំពូជវិតដែលកើតមកហើយ សេនៅជាន់តាក់តណ្តាលព្រះពុទ្ធសាសនាទាំងមានសេចក្តីសង្ឃឹមជាទីបំផុតថា ព្រះពុទ្ធសាសនាក្នុងពេលគំរប់ ២.៥០០ ឆ្នាំនឹងសាយភាយ ឬស្រែកដង្ហោយហៅ ភាញចំបែរសន្ធានចិត្តពលលោកទាំងមូលឲ្យងាកឈមមុខឆ្ពោះទៅរកសន្តិភាព ឬបាសចាកការកំហែងគ្រោះមរណៈមនុស្ស មានមេត្តាករុណាចេះយោគយល់គ្នាចែកសុខចំរើនដល់គ្នានឹងគ្នា ដែលមានព្រះពុទ្ធសាសនាជាបន្ទាត់ ។

សេចក្តីដូចខ្ញុំលើនេះ ក្នុងនាមនៃព្រះមង្គលចិត្តលោកវិរ្យ មេគណខែត្តតាកែវ សូមចាត់ទុកថាជាសេចក្តីឃោសនាដល់ព្រះករុណាគ្រប់ព្រះអង្គ ទីពុទ្ធមាមក បរិស័ទទាំងឡាយទៅអនាគត ។ ហើយមានសេចក្តីសង្ឃឹមទុកជាមុនថា ព្រះករុណាគ្រប់ព្រះអង្គ ពុទ្ធបរិស័ទ

ទាំងឡាយមុខជាច្រើនជួយញុំាងកុសលកម្មនេះ ឲ្យឆាប់សម្រេចជាមាំមួនមិនខាន ។

ជាទីបញ្ចប់នេះ សូមថ្វាយព្រះពុទ្ធគុណលំពោះព្រះករុណាជាអម្ចាស់ជីវិត សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះនរោត្តម-សីហនុ ។បយុវរាជ ចិរាឯកវាជ្យ អស់លោកឥស្សរជន សប្បុរសទាំងឡាយ សូមទ្រទ្រង់ប្រកបដោយព្រះសុខមាលភាព ជានិច្ចនិរន្តរ៍តរៀងទៅ កុំបីឃ្លាតឡើយ ។

*
* *

ក្នុងពេលចប់សេចក្តីម្តង ។ គេឮសូរខ្ទេះដៃលាន់រំពងខ្ទួលអបអរសាទរ ។

ក្រោយដែលបានរោមខ្លីរពេទ្យតាមប្រពៃណីរួច លោក យ៉ិត-តំមសេង គ្រូពេទ្យនាយក បានអញ្ជើញលោកផ្ទះលេខាធិការក្រសួងធម្មការកាត់ខ្សែក្រហមបង់កាត់មាត់ថ្វាយរោមខ្លីរពេទ្យ ដែលជាទំនិញរូបនៃការបើកភ្នែកឲ្យព្រះសង្ឃដែលមានកេតុលាភបាលបាន ជាប់តាំងពីថ្ងៃនេះតទៅ ។

នាម៉ឺនសព្វមុខមន្ត្រី ព្រះសង្ឃនីកៈ ភិក្ខុ ភិក្ខុនី ដែលបានជួបជុំនៅពេលនោះ ក៏បានចូលទស្សនាមន្ទីរពេទ្យដែលមានបន្ទប់ ៥ មានគ្រែទឹងពួក ១៥; មានបន្ទប់ឯកត្តរបង់ ២, ព្រមទាំងមានបន្ទប់ ១ សំរាប់ជាកន្លែងសង ។ មន្ទីរពេទ្យនេះបានរៀបចំសាងយ៉ាងស្អាត គួរជាទីសំណាក់ផ្ទះកេតនៃព្រះសង្ឃមែន ។

ពិធីនេះបានចប់នៅម៉ោង ១០ កន្លះព្រឹក ។

សព្វថ្ងៃនេះ នៅព្រះពុទ្ធជាន់ក្នុងភ្នំពេញ មានមន្ទីរពេទ្យព្រះសង្ឃយ៉ាងធំ, នៅខែត្រសៀមរាបនឹងតាកែវ មានមន្ទីរពេទ្យគួរសមល្មមរក្សាជម្ងឺព្រះសង្ឃហើយ ឃើងសង្ឃឹមថា ពុទ្ធបរិស័ទនៅខែត្រឯទៀតៗ មុខជាពុំបណ្តាយឲ្យខេត្តរបស់ខ្លួនខ្វះខាតមន្ទីរពេទ្យព្រះសង្ឃយូរតទៅឡើយ ។

តាន្តជសទ្ទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៨ លេខ ៩ ខែកញ្ញា ព.ស.២៤៩៩ គ.ស.១៩៥៦



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— អនន្តរិយកម្ម	ព្រះវេតសត្ថា កិម-គួរ	៨០៣
— វិបីកថា	ព្រះមហា អ៊ុម-ផេង	៨១៣
— ច្បាប់លោកនឹងច្បាប់ធម៌	ឃុនបណ្ណាគុរ័ក្ស ប៊ូ-ប៊ី	៨២៤
ផ្នែកអក្សរសាស្ត្រ		
— អក្សរសាស្ត្រខ្មែរសង្ខេប	លោក ភ័យ-ប៊ុក	៨២៩
— រឿងភាំងដេនហ៊ូ	ឃុនអត្ថកោវិទ ជា-យូ ប្រែ	៨៣៨
— ពេជ្រព្រះរាជា (តមក)	លោក ស៊ុន-ហ៊ាន ប្រែ	៨៤៨
— រឿងសាមកុក (តមក)	នាយ៉ា ឆ្ង-កន	៨៦៥
— រឿងបល្ល័ង្កទីញូ (តមក)	លោក ភ័យ-ប៊ុក ប្រែ	៨៧៦
— រឿងព្រះបាទបរន្តប:	ព្រះមហា ឈឿក-អម៌	៨៨៦
កំណាត់ធឹងប្រវត្តិការណ៍		
— ពិធីបុណ្យផ្កានៃគណៈសិស្សសីលធម៌ វត្ត ឧណ្ណាលោម	លោក ញ៉ែម-ទិម	៨៩២

មួយឆ្នាំមាន ១២ លេខ — ដំឡៃដាវ ២៣០រ, ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Anantariyakamma.	*par vénérable KEM-TO . . .*	*803*
— Vachikatha	*par le vénérable OUM-PHENG..*	*813*
— Le loi civile et la loi morale .	*par M. BOU-PO . . . . . .*	*824*

PARTIE LITTÉRAIRE:

— Littérature Khmère	*par M. RAY-BUC . . . .*	*828*
— Histoire de Vang-Chen-Fou . .	*traduit par M. CHEA-YOU .*	*838*
— Conte "Le Diamant de Raja" (suite)	*traduit par M. SIN-HEAN*	*848*
— Histoire de Samkok (suite) .	*traduit par M. NOU-KAN*	*865*
— Les trente deux récits du Trône (suite)	*traduit par M. RAY-BUC*	*876*
— Histoire du Roi Parantapa . .	*par Vénérable DŒURK-AM*	*886*

NOTES ET CHRONIQUES:

— Fête de "Phkar des élèves Siladhamma" de vat Unnalom .	*par M. NHÈM-KHÉM . . .*	*892*

Prix d'abonnement annuel (comprenant 12 numéros) 230$00

អនន្តរិយកម្ម

ព្រះទេពសត្ថា កឹម-ត្អូរ បដ្ឋមង្គលោ

ក្រុមដំនុំព្រះត្រៃបិដកនៅតុន្លសាសនបណ្ឌិត្យ
រៀបរៀងតាមគម្ពីរ សម្មោហវិនោទនី អដ្ឋកថាព្រះអភិធម្ម

សួរ - ដូចម្តេចហៅថា អនន្តរិយកម្ម? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

ឆ្លើយ - បាបកម្មដែលបុគ្គលអ្នកធ្វើត្រូវទទួលផលភ្លាមៗជាតិជាបន្ទាប់អំពីបច្ចុប្បន្នជាតិ ឥតមានរំលងជាតិ ហៅថា អនន្តរិយកម្ម, មាន ៥ យ៉ាងគឺ

១-	មាតុឃាដ	*សម្លាប់មាតា*
២-	បិតុឃាដ	*សម្លាប់បិតា*
៣-	អរហន្តឃាដ	*សម្លាប់ព្រះអរហន្ត*
៤-	លោហិតុប្បាទ	*ធ្វើព្រះលោហិត (របស់ព្រះពុទ្ធ) ឲ្យពុះពង*
៥-	សង្ឃភេទ	*បំបែកសង្ឃ*

មាតុឃាដ - បិតុឃាដ

ស- កូនមានជាតិជាមនុស្ស សម្លាប់មាតាក្តី សម្លាប់បិតាក្តី របស់ខ្លួនដែលមានជាតិជាមនុស្សដូចគ្នាដែរ តើកម្មនោះចាត់ជាកម្មអ្វី?

ឆ- កម្មនោះចាត់ជាអនន្តរិយកម្ម ។

ស- បុះបើកូននោះ ដឹងថាខ្លួនប្រព្រឹត្តទាស់នឹងសីលហើយ កំពុង

រក។ ចាយនឹងការពារជៀសវាងវិបាក (ផល) នៃអនន្តរិយកម្មនោះ ដោយវិធីណាមួយ តើរួចទោសឬទេ?

ឆ- មិនរួចទេ, សូម្បីកូននោះធ្វើព្រះស្តូបសុទ្ធតែមាស ប្រមាណប៉ុនមហាចេតិយពេញចក្រវាឡ ទាំងមូលក្តី បរិច្ចាគមហាទានដល់តំកុសង្ឃ ដែលនិមន្តមកគង់ពេញចក្រវាឡ ទាំងមូលក្តី ពុំនោះសោតតាំងជាយសង្ឃដ៏វេបស់ព្រះពុទ្ធជាម្ចាស់ដើរតាមជាទិច្ចក្តី រាល់ថែកធ្វាយឆាងកាយអំពីលោកនេះទៅ កូននោះឯង ទៀងតែទៅកាន់អបាយភូមិគឺនរកដោយពិត ។

ស- ចុះបើ កូនណាខ្លួនឯងកើតជាមនុស្ស សម្លាប់មាតាបិតាដែលកើតជាសត្វតិរច្ឆាន ឬខ្លួនឯងកើតជាសត្វតិរច្ឆាន សម្លាប់មាតាបិតាដែលកើតជាមនុស្ស; ពុំនោះសោតខ្លួនឯងកើតជាតិរច្ឆាន សម្លាប់មាតាបិតាដែលកើតជាសត្វតិរច្ឆានដែរ តើកម្មរបស់កូននោះ ចាត់ជាអនន្តរិយកម្មឬទេ?

ឆ- មិនចាត់ជាអនន្តរិយកម្មទេ ប៉ុន្តែកម្មនោះមានទោសធ្ងន់ស្រដៀងគ្នានឹងអនន្តរិយកម្មដែរ ។

អរហន្តឃាដ

ស- សម្លាប់មាតាបិតា នឹងសម្លាប់ព្រះអរហន្ត មានទោសប៉ុនគ្នាឬផ្សេងគ្នា? ព្រោះហេតុអ្វី?

ឆ- មានទោសប៉ុនគ្នា មិនផ្សេងគ្នាទេ ព្រោះហេតុមាតាបិតាលោកចាត់ជាអាហុនេយ្យបុគ្គល ដូចព្រះអរហន្តដែរ ។

ស- បុគ្គលសម្លាប់មនុស្សជាព្រះអរហន្ត កម្មនោះចាត់ជាអនន្តរិ-យកម្ម កំសួរដែរហើយ ចុះបើសម្លាប់យក្សជាព្រះអរហន្ត ចាត់ជាកម្មអ្វីទៅវិញ ?

ឆ- បើសម្លាប់យក្សជាព្រះអរហន្ត មិនចាត់ជាអនន្តរិយកម្មទេ ប៉ុន្តែកម្មនោះមានទោសធ្ងន់ប្រហែលនឹងអនន្តរិយកម្មដែរ ។

ស- បុគ្គលណាប្រហារមនុស្សដោយគ្រឿងសស្ត្រាក្តី ដោយជាក់ថ្នាំពិសបំពុលក្តី តាំងពីកន្លងកាលដែលមនុស្សនោះជាបុថុជ្ជនទៅឡើយ តែប្រសិនបើមនុស្សនោះបានដល់ព្រះអរហន្តហើយ បរិនិព្វានទៅដោយសារតែរបួសនឹងគ្រឿងសស្ត្រា ឬថ្នាំពិសបំពុលនោះឯង តើបុគ្គលនោះចាត់ជាអរហន្តឃាដដែរឬទេ ?

ឆ- បុគ្គលនោះ ចាត់ជាអរហន្តឃាដ ត្រូវទទួលទោសអនន្តរិយ-កម្មពេញទី ។

ស- ចុះបើសម្លាប់អរិយបុគ្គលដ៏សេសក្រៅអំពីព្រះអរហន្ត តាំងពីត្រឹមអនាគាមិបុគ្គលចុះមកដល់សោតាបន្នបុគ្គល ចាត់ជាអនន្តរិយកម្មដែរឬទេ ?

ឆ- មិនចាត់ជាអនន្តរិយកម្មទេ ប៉ុន្តែកម្មនោះមានទោសធ្ងន់ប្រហែលគ្នានឹងអនន្តរិយកម្មដែរ ។

លោហិតុប្បាទ

ស- ពាក្យថា ញុំងព្រះលោហិតរបស់ព្រះពុទ្ធឲ្យពុះពងនោះ តើ

សំដៅដល់ការធ្វើព្រះកាយរបស់ព្រះពុទ្ធឲ្យបែកជាច់ស្បែកហូរស្រស់ព្រះលោហិតចេញមកខាងក្រៅឬ ?

ឆ - មិនមែនដូច្នោះទេ, បុគ្គលមានអកុសលចិត្តខុកជាព្យាយាមយ៉ាងណា ក៏មិនអាចធ្វើព្រះកាយរបស់ព្រះពុទ្ធឲ្យបែកធ្លាយ ហូរព្រះលោហិតស្រស់ចេញមកខាងក្រៅបានទេ ។

ស - ចុះព្រះកាយរបស់ព្រះពុទ្ធដែលត្រូវបួសដោយព្យាយាមនៃបុគ្គលដទៃហើយ ព្រះលោហិតនោះតាំងនៅឯណា ? សូមឆ្លើយតាមហេតុផល ។

ឆ - ព្រះលោហិតនោះ តាំងផ្តុំនៅក្នុងព្រះសរីរៈរបស់ព្រះអង្គ តែងតែខ្វែងដែលត្រូវដោយគ្រឿងប្រហារ តាមហេតុផលដូចខ្ញុំពន្យល់ដែលប្រមៀលដុំថ្មពីលើកំពូលភ្នំចុះមក ប៉ះនឹងសម្ងាប់ព្រះពុទ្ធ ប៉ុន្តែចំណែកដុំថ្មខ្លះតមកប៉ះបុងព្រះបាទរបស់ព្រះអង្គ ហាក់ដូចជាគេប្រហារដោយប៉ូវថៅ ឯព្រះលោហិតគ្រាន់តែផ្តុំតាំងនៅខាងក្នុងប៉ុណ្ណោះ ។

ស - ខ្ញុំពន្យល់ដែលធ្វើដូច្នោះ តើចាត់ជាកម្មអ្វី ? ព្រោះធ្វើដោយចិត្តបែបណា ?

ឆ - កម្មនោះ ចាត់ជាអនន្តរិយកម្ម ព្រោះធ្វើដោយទោសចិត្ត ។

ស - ចុះចំណែកខាងកុមារពេទ្យឈ្មោះជីវកៈ ដែលយកកាំបិតទៅរុះកាត់ស្បែកនៃព្រះសម្ងាសម្ពុទ្ធ ហើយបញ្ចេញព្រះលោហិតគំណាចអំពីកន្លែងរបួសនោះ ជាន់ធ្វើព្រះកាយរបស់ព្រះអង្គឲ្យជាសះស្បើយទៅ ចាត់ជាកម្មអ្វី ? ព្រោះធ្វើដោយចិត្តបែបណា ?

ច - កម្មនោះ ចាត់ជាបុញ្ញកម្ម ព្រោះធ្វើដោយកុសលចិត្ត ។

ស- កុដ្ឋកាលដែលព្រះសម្ពុទ្ធបរិនិព្វានហើយ បុគ្គលណាទៅ
ទំលាយចំពែកចំបាក់ព្រះចេតិយ (ព្រះចេតិយបញ្ចុះព្រះសារីរិកធាតុ) ក្តី
កាប់កាត់ខ្លូវពោធិព្រឹក្សក្តី ឬឲ្យាយាមបំផ្លាញព្រះសារីរិកធាតុឲ្យវិនាសក្តី
តើកម្មរបស់បុគ្គលនោះ ចាត់ជាកម្មអ្វី?

ច - កម្មរបស់បុគ្គលនោះ មិនចាត់ជាអនន្តរិយកម្មទេ ប៉ុន្តែជាកម្ម
មានទោសធ្ងន់ ប្រហែលគ្នានឹងអនន្តរិយកម្មដែរ ។

ស - ប៉ុនបើមែកពោធិព្រឹក្ស ដុះលូតលាស់ឆ្ងាយរាល់ចុះមកគ្របព្រះ
ស្តូប ឬ ព្រះបដិមាករ ព្រមទាំងព្រះសារីរិកធាតុ តើគួរកាត់មែកពោធិ-
ព្រឹក្សនោះចេញបានឬទេ?

ច - បើយល់ឃើញថា មែកពោធិព្រឹក្សនោះ កាលណាបើ
បណ្តាយទុកយូរទៅ ជាហេតុនាំឲ្យខូចដល់ព្រះស្តូប ឬ ព្រះបដិមាករព្រម
ទាំងព្រះសារីរិកធាតុនោះ តើគួរតែកាត់យកចេញឥតមានទោសឡើយ ។

ស- ប៉ុនបើមានពួកសត្វស្នាបទំសម្ងំនៅលើមែកពោធិព្រឹក្សនោះ
ហើយបន្ទោបង់វច្ចៈ (អាចម៍) ជាក់លើព្រះចេតិយ គួរកាត់មែកពោធិព្រឹក្ស
នោះចោលចេញបានឬទេ?

ច - បើដូច្នោះមែន, ក៏តែតែគួរឲ្យកាត់ចោលចេញណាស់ទៅ
ទៀតហើយ ។

ស- សារីរចេតិយ (ចេតិយដែលបញ្ចុះទុកនូវព្រះសារីរិកធាតុ)

ទឹងបរិភោគចេតិយ (ចេតិយបញ្ចុះគ្រឿងបរិក្ខារសម្រាប់ប្រើប្រាស់របស់ព្រះពុទ្ធ) ជាងពីរនេះណាមានប្រយោជន៍ជាង? ព្រោះអ្វី?

ឆ- សារីរចេតិយ មានប្រយោជន៍ធំជាងបរិភោគចេតិយ, ព្រោះគ្រឿងបរិក្ខារជារបស់ប្រើប្រាស់ខាងក្រៅ ឯព្រះសារីរិកធាតុជារបស់សំខាន់ ជាអវយវៈផ្ទាល់ព្រះអង្គតែម្តង ។

ស- បើឫសពោធិព្រឹក្សដុះលូតលាស់ចាក់ចំលាយខ្លួនចំនៃព្រះចេតិយមានឃឿនជាដើម គួរកាត់ចេញបានឬទេ?

ឆ- គួរកាត់ចេញបានឥតមានជាស់ទេ ព្រោះបណ្តាយពុកយួរ ៗ ជាហេតុនាំឲ្យអន្តរាយដល់តួព្រះចេតិយផងទៀត ។

ស- បើមែកពោធិព្រឹក្សណាទន់ធ្លាក់សំយោគចុះមកប៉ះឃឿននៃពោធិព្រឹក្ស គួរកាត់ចេញបានឬទេ? ព្រោះអ្វី?

ឆ- គួរកាត់ចេញបាន ព្រោះកាត់សំអាតឲ្យពោធិព្រឹក្សមានលំអ ។

ស- ព្រះធាតុដែលគេបញ្ចុះទុកលើឃឿន នៃពោធិព្រឹក្សណាហើយ គេកាត់មែកពោធិព្រឹក្សនោះចេញ ដើម្បីប្រយោជន៍ទឹងរក្សាការពារខ្លួរឃឿននោះកុំឲ្យរំខានសោះបានឬទេ?

ឆ- បើមានបំណងដូច្នោះ គួរកាត់ចេញបាន មិនតែប៉ុណ្ណោះសូម្បីមែកពោធិព្រឹក្សណាដែលស៊ុបទ្រុប ឬក៏មានមែកស្អុយពុកផុយ ក៏គួរតែកាត់ចោលចេញដែរ ដើម្បីទឹងធ្វើពោធិព្រឹក្សនោះឲ្យស្អាតបាត; ការដែលបានថែរក្សាសំអាតពោធិព្រឹក្ស ក៏ហាក់ដូចជាបានថែរក្សាសំអាត

ព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធដោយផ្លូវដែរ; អំពើដែលបាន
ពណ៌នាមកខាងដើមប៉ុន្មានទេនេះ ចាត់ជាបុណ្យជាកុសលដោយពិត ។

សង្ឃភេទ

ស- ដូចម្តេចហៅថា សង្ឃភេទ?

ឆ- សង្ឃដែលនៅកន្លែងសីមាមួយ បែកគ្នាជាពួកជាក្រុមមិនប្រជុំ
ធ្វើសង្ឃកម្មជាមួយគ្នា ទាំងបីស័ទផ្សេង។ គ្នាធ្វើនូវកម្មក្តី សំដែងនូវ
ឧទ្ទេសក្តី ហៅថា សង្ឃភេទ ។

ស- សង្ឃដែលបែកបាក់គ្នាជាពួកជាក្រុមដូច្នោះ លុះតែមានកិក្ខុ
ណាមួយជាអ្នកបង្កហេតុញុះញង់ ទើបសង្ឃនោះបែកគ្នាទៅជាពួក
ជាក្រុមកើត ពិតមែនឬ? បើពិតមែន ចុះអំពើរបស់កិក្ខុជាអ្នកញុះញង់
បង្កហេតុនោះ ទំងចាត់ទៅជាអ្វី?

ឆ- ពិតមែន, អំពើរបស់កិក្ខុនោះចាត់ជាសង្ឃភេទផង ជា
អនន្តរិយកម្មផង ។

ស- ចុះបើកិក្ខុនោះ ធ្វើដោយមានបំណងថាឲ្យសង្ឃព្រមព្រៀង
គ្នាទេ តែសង្ឃបែរទៅជាបែកគ្នាជាពួកជាក្រុមវិញ តើកិក្ខុនោះចាត់ជាអ្វី?

ឆ- បើធ្វើដោយមានបំណងថាឲ្យសង្ឃព្រមព្រៀងគ្នាដូច្នោះមែន
កិក្ខុនោះមិនចាត់ជាអ្នកធ្វើសង្ឃភេទ មិនចាត់ជាអ្នកធ្វើអនន្តរិយកម្មទេ ។

ស- សង្ឃភេទ (ការបំបែកសង្ឃ) កន្លងនេះ សំដៅយកកិក្ខុចំនួន
ប៉ុន្មានរូប ទើបហៅថា សង្ឃ?

ឆ- សំដៅយកកិកុយ៉ាងតិចត្រឹម ៤ រូប លើសពីនោះទៅមិនមានកំណត់ ទើបហៅថា សង្ឃ ក្នុងពីរនេះបាន ។

ស- ចុះបើកិកុកំណត់យ៉ាងតិចត្រឹម ៤ រូបដែលនៅក្នុងសីមាជាមួយគ្នា រំលាជល់បែកបាក់គ្នានោះ តើកំណត់ចំនួនកិកុប៉ុន្មានទើបហៅថា សង្ឃបែកគ្នា? ការចំបែកនោះដោយវិធីបែបណា?

ឆ- ក្នុងកិកុ ៤ រូបនោះកំណត់ចំនួនកិកុម្នាង ៤ រូប។ ហើយកិកុមួយរូបជាអ្នកបង្កហេតុចំបែកសង្ឃ គឺជាអ្នកប្រកាសសេចក្តីឲ្យកិកុពាក់ព័ន្ធអស់នោះបានឮហើយឲ្យចាប់ស្វាកដោយពាក្យថា ខាងនេះទើបជាធម៌, ទើបវិន័យ, ខាងនេះទើបជាសាសនៈនៃព្រះសាស្តា; លោកពាក់ព័ន្ធឲ្យចូរកាន់យកនូវធម៌ធីវិន័យនេះចុះ ចូរពេញចិត្តចំពោះធម៌ធីវិន័យនេះចុះ ជួរច្នេះជាដើម កាលណាសង្ឃពាក់ព័ន្ធនោះបែកគ្នាជាពួកហើយ កិកុអ្នកបង្កហេតុញុះញង់នោះ ចាត់ជាអ្នកធ្វើសង្ឃភេទផង ជាអ្នកធ្វើអនន្តរិយកម្មផង។

ស- ចុះបើកិកុអ្នកចំបែកសង្ឃ។ នោះមានចំនួនចាប់ពី ៤ រូបចុះមកទីឆ ចាត់ជាសង្ឃភេទ ជាអនន្តរិយកម្មដែរឬទេ?

ឆ- មិនចាត់ជាសង្ឃភេទ ជាអនន្តរិយកម្មទេ ព្រោះសង្ឃមិនគ្រប់ចំនួន ៤ រូបឡើងទៅ ។

ស- ចុះការចំបែកសង្ឃដែលហៅថាសង្ឃភេទក្នុងពីរនេះ ចំពោះបានតែកិកុដូចគ្នា ឬក៏មនុស្សជនក្រៅអំពីកិកុ ហៅថា សង្ឃភេទដែរ?

ឆ- មនុស្សជនក្រៅអំពីកិកុដូចជា កិកុនី, សិក្ខមានា, សាមណេរ, សាមណេរី, ឧបាសក, ឧបាសិកា មិនឈ្មោះថា ជាអ្នកធ្វើសង្ឃភេទ

ទេ, សង្ឃកេទមានចំពោះតែកិក្ខុដែលមានសំវាសស្មើគ្នា បិតនៅកន្លែងមាជាមួយគ្នាតែម្យ៉ាងប៉ុណ្ណោះ ។

ស– បណ្តាអនន្តរិយកម្មទាំង ៥ យ៉ាងដូចបានពោលមកហើយនោះ អនន្តរិយកម្មណាចាត់ជាវចីកម្ម, ណាចាត់ជាកាយកម្ម?

ឆ– សង្ឃកេទចាត់ជាវចីកម្ម ក្រៅពីនេះចាត់ជាកាយកម្ម ។

ស– ចុះអនន្តរិយកម្មណាតាំងឡើងដោយទ្វារអ្វី?

ឆ– អនន្តរិយកម្មទាំងអស់តាំងឡើងដោយកាយទ្វារក៏មាន ដោយវចីទ្វារក៏មាន ឯអនន្តរិយកម្ម ៤ ខាងដើម ពុកជាតាំងឡើងអំពីវចីទ្វារដោយអំណាចអាណត្តិកប្បយោគ ដល់ទីបំផុតក៏គង់បំពេញនូវកាយទ្វារដែរ ចំណែកខាងសង្ឃកេទ បើកិក្ខុធ្វើនូវការបំបែកសង្ឃដោយក្តាប់ដៃ ឈ្មោះថាតាំងឡើងអំពីកាយទ្វារ ដល់ទីបំផុតក៏គង់បំពេញនូវវចីទ្វារដែរ ។

ស– បណ្តាអនន្តរិយកម្មទាំង ៥ អនន្តរិយកម្មណា មានទោសធ្ងន់ជាងគេ? ចូរប្រាប់ទោសធ្ងន់ស្រាលឲ្យគ្រប់អនន្តរិយកម្មទាំង ៥ មកមើល!

ឆ– បុគ្គលណា បានធ្វើអនន្តរិយកម្មគ្រប់ទាំង ៥, ចំណែកខាងអនន្តរិយកម្មគឺសង្ឃកេទមានទោសធ្ងន់ជាង អាចឲ្យផលដល់បុគ្គលនោះដោយអំណាចបដិសន្ធិមុនគេ ឯអនន្តរិយកម្មដ៏សេសក្រៅពីនេះទៅជាអហោសិកម្ម មិនមានកម្មវិបាកឡើយ ។ បើសង្ឃកេទមិនបានធ្វើទេ, លោហិតុប្បាទឲ្យផលមុនគេ, បើលោហិតុប្បាទមិនបានធ្វើទេ, អរហន្តឃាដឲ្យផលមុនគេ, បើអរហន្តឃាដមិនបានធ្វើទេ, ធ្វើតែមាតុឃាដនឹងបិតុឃាដ ។ បើមាតាទ្រុស្តសីល ចំណែកបិតាមានសីល បិតុឃាដ

ឲ្យផលមុនគេ ។ បើមាតាមានសីលដូចគ្នាជាងពីរនាក់ មានុយោជឲ្យ
ផលមុនគេ ព្រោះមាតាមានឧបការៈច្រើនជាងបិតាលើកូនជាងគ្នា ។

ឯកមវចនៈ អនន្តរិយកម្ម

ព្រះពុទ្ធសត្ថា កិម្ហ ភ្ជុ ចន្ទូមគ្គល

ជាន់ពន្យល់អំពីកម្ម ៥ មាតិកា
ដែលឈ្មោះអនន្តរិយកម្មណា
ដោយពិស្តារស្តាប់ពីកេះពេកពណ្ណាយ ។
សេចក្តីខោះបើសង្ខេបបំព្រួញខ្លី
មកវិញខ្លីពុកដើម្បីចំណាំងាយ
គឺទី ១ កូនប្រុសស្រីសម្លាប់ម្តាយ,
ទី ២ ក្មាយក្មែងសម្លាប់ឪពុកពិត ។
កម្មទី ៣ គឺពិឃាដអរហន្តា,
ទី ៤ ណាគឺការធ្វើព្រះលោហិត
នៃព្រះពុទ្ធឲ្យពុះពងដោយចេសចិត្ត,
ទី ៥ ក្រែត្យគឺកិក្ខុបំបែកសង្ឃ ។
កម្មទាំង ៥ ដូចដែលពាប់មកនេះឯង
មានចេសស្តែងធ្ងន់ខ្លាំងវៃក្លាវៀរបង់
ព្រោះជាកម្មអាចឲ្យចេសគ្មានបង្អង់
ស្លាប់ហើយត្រង់ទៅអាចីពុំឃ្លាតឡើយ ។

ព្រះមហា អ៊ុម-ផេង វត្តសរាវ័ន

ចៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការចំពោះព្រះកតវន្តមុនី អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គ នោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

ឥលានេះ អាត្មាភាពសូមសំដែងអំពីវចីកថា តាមគួរដល់កាល វេលាដូចតទៅនេះ ៖

វិបីកថា ប្រែថា ការសំដែងអំពីវាចា, ការសំដែងអំពីសំដី ; សទ្ទជាតិ គឺសំឡេង ដែលលាន់ចេញមក កំសង្កត់ចូលក្នុងវាចា នេះ; អដ្ឋកថាលោកចង់វិគ្គហៈថា វិបុ[1]តីតិ វាចា (ធម្មជាតិណា) ដែលបុគ្គលពោល ធម្មជាតិនោះ ឈ្មោះថា វាចា (សំដី) ។

វាចា គឺ សំដីនេះ ជាធម្មជាតិដ៏វិសេស ១ ផ្នែក របស់មនុស្ស ជាតិ សម្រាប់ឲ្យស្តាប់គ្នាបានទៅវិញទៅមក ក្នុងការប្រកបកិច្ចការ អ្វី ។ តាមដំណើរដែលត្រូវប្រើថ្លែងបាន, ជនណាថ្លែងចាកសំដី គឺមិនមានសំដីហើយ ជនៈនោះ ពុកជាអកត្តូក្នុងការនិយាយស្តីថ្លែងប្រាស្រ័យ ទៅនឹងបុគ្គលណាមួយ ឬពុកដូចជាគ្មានហេតុបច្ចយ[2]សម្រាប់ប្រើថ្លែងប្រាស់ ផ្នែកខាងសំដី គេហៅថា មនុស្សគ ។ មនុស្សគនេះ កាលបើគ្មានសំដី សម្រាប់និយាយស្តី ប្រើថ្លែងប្រាស់ដូច្នេះហើយ តោងយកសរីរវយវៈមាន

ដៃឬជើងជាដើម ទៅត្រៃច្រាសដំនួសសំដី គឺថាបើសេចក្តីត្រូវការកើតឡើង ដោយចង់ច្រាស្រយ៉ៃទៅនឹងអ្នកណាមួយដោយសំដីនោះ ដើម្បីឲ្យស្តាប់គ្នាបាន ត្រូវវាសដៃវាសជើងឆ្កាល ចង្អុលនាយអាយតាមមុខការដែលត្រូវដំនួសសំដីនោះ តែត្រៃការបានមិនត្រង់គ្រាន់តាមសេចក្តីត្រូវការឡើយ ។ សំដីមានប្រយោជន៍សំខាន់ដូចថ្ងៃនេះ បានជាពាក្យបុពណាថា សំដីជាឯក លេខជាទោ ប្រែសេចក្តីថា

សំដីដែលបុគ្គលចេះនិយាយ ឯងវែកន្លងការនិយាយខុសជាលេខ ១, ការចេះអក្សរយ៉ាងស្អាតដំនាញឬចេះលេខនឹងគុណហារខុសជាលេខ ២ ។ សំដីដែលបុគ្គលពោលមាន ២ យ៉ាង គឺពោលល្អម្យ៉ាង, ពោលអាក្រក់ម្យ៉ាង ។ ឯអំពើដែលសម្រេចសំដី ហៅថា វចីកម្ម; ចែកចេញជា ២ យ៉ាងគឺ សំដីដែលបុគ្គលពោលអាក្រក់ ហៅថា វចីទុច្ចរិត ជាវាចាដែលបុគ្គលត្រូវលះបង់ ១; សំដីដែលបុគ្គលពោលល្អ ហៅថា វចីសុចរិត ជាវាចាដែលបុគ្គលត្រូវធ្វើឲ្យកើតឲ្យចំរើនមានឡើង ១ ។

សំដីអាក្រក់ដែលបុគ្គលមិនត្រូវពោល មិនត្រូវនិយាយ ហៅថា វចីទុច្ចរិតនេះ មាន ៤ យ៉ាងគឺ មុសាវាទ ១, បិសុណាវាចា ១, ផរុសវាចា ១, សម្ផប្បលាបៈ ១ ។

១— មុសាវាទ នោះ បានខាងសំដីដែលនិយាយវៀច, និយាយកុហក, គឺខ្លួនមិនឃើញថាឃើញ មិនឮថាឮ មិនដឹងថាដឹងដោយគំនិតប្រឆឹងឲ្យគេច្រឡំចិត្តខុស, ទោះបីអ្នកដែលស្តាប់នោះ គេជឿក្តីមិន

ដឿក្តី កំហៅថា សំដីរៀបចាំងអស់ ។ សំដីរៀបនេះ ធ្វើអ្នកដទៃឲ្យ
វិនាសដីវិតក៏មាន ឲ្យវិនាសទ្រព្យសម្បត្តិក៏មាន ឲ្យកើតសេចក្តីលំបាក
ផ្សេងៗក៏មាន ។ អ្នកនិយាយសំដីរៀប ជាហេតុនាំឲ្យអ្នកដទៃគេ
មិនដឿត្រង់ត្រាប់ស្តាប់ខ្លួន គឺបើគេដឹងថា អ្នកនោះឮប់និយាយមុសា
ហើយ ថ្ងៃក្រោយសូម្បីនិយាយត្រង់ក៏គេមិនដឿ, ទោះបីនិយាយកុហក
ដើម្បីឲ្យរួចកំយ ឬដើម្បីនឹងឲ្យអ្នកដទៃរួបរួមគ្នា ឲ្យមានសាមគ្គីព្រម
ព្រៀងគ្នា ដែលខ្លួនយល់ឃើញថា គួរនិយាយកូតផ្សំខ្លះផងនោះក៏មិនគួរ
ដែរ, តាមសេចក្តីពិត កុំកូតឲ្យសោះ; ព្រោះសំដីដែលគួរនឹងនិយាយឲ្យគេ
ស្តាប់ឮក៏មានច្រើនល្មមប្រើមិនខ្វះឡើយ, សូម្បីកូតលេងក៏មិនគួរដែរ
ព្រោះជាហេតុឲ្យគេនាំគ្នានិយាយកូតតៗ ទៅ ។ សំដីកូតកុហកនេះ បើ
មានកម្លាំងច្រើន ក៏អាចឲ្យខ្លួលទោសក្នុងបច្ចុប្បន្ន; សមដូចនិទានដែល
មានក្នុងគម្ពីរតេរសនិបាត សំដែងអំពីទោសនៃមុសាវាទថា ៖

ក្នុងកាលកន្លងទៅហើយ ព្រះសម្មាសម្ពុទ្ធរបស់យើង ទៅជាព្រះ
ពោធិសត្វទៅឡើយបានកើតក្នុងត្រកូលចណ្ឌាល ប៉ុន្តែជាបណ្ឌិត ចេះ
មន្តធ្វើឈើឲ្យមានផ្កាផ្លែ ក្នុងរដូវពុំដូកាល គឺធ្វើឲ្យមានផ្កាផ្លែទុំសរដូវ
បាន ។ ថ្ងៃមួយ ពោធិសត្វចេញទៅព្រៃតាំពីព្រឹក កាយមន្តធ្វើដើមស្វាយ
មួយដើម នៅចម្ងាយ ៧ដំហាន ពីកន្លែងដែលឈរ ទើបយកទឹកចំនួន
១០០ បំពង់ទៅស្រោចលើដើមស្វាយ១ដើម ស្វាយនោះក៏ជម្រុះស្លឹកចាស់
អស់ ១ រំពេច លាស់ស្លឹកខ្ចីឡើងបញ្ចេញផ្កាផ្លែទុំក្នុងពេលនោះភ្លាម

ពោធិសត្វបេះយកមកបរិភោគ កំមានទុក្ខវេទនាដូចជាវេទនាទុំឫ
ហើយបេះវែកយកទៅផ្ទះចែកបុត្រភរិយាបរិភោគផង លក់ដូរផង ។

គ្រានោះ មានព្រាហ្មណ៍ម្នាក់ បានសូមរៀនមន្តពីពោធិសត្វ។ កំ
ព្រមឲ្យរៀន តែឆ្លាំថា បើអ្នកណាមួយសួរថា ព្រាហ្មណ៍ឯងរៀនមន្ត
នេះពីសំណាក់អ្នកណា ? ចូរអ្នកឯងប្រាប់គេឲ្យត្រង់កុំកុហក, បើប្រាប់
ដោយមុសាវាទហើយ មន្តនេះ ខឹងវិនាសទៅវិញពុំខានឡើយ ។
ព្រាហ្មណ៍ទទួលបណ្តាំហើយក៏ធ្វើដំណើរ ទៅដល់ក្រុងពារាណសី បាន
ចូលទៅធ្វើជានាយច្បារ ក្នុងសំណាក់ព្រះបាទពារាណសី តែងប្រតិបត្តិ
តាមវិធីមន្តនោះ ស្មៅឈើតែងតែមានផ្លែឥតអាក់ មិនថារដូវណាជារដូវ
ណាទេ ។ ព្រាហ្មណ៍កំបានទ្រព្យជារង្វាន់យ៉ាងច្រើន ។

ថ្ងៃមួយ ព្រះបាទក្រុងពារាណសី មានព្រះពុទ្ធដីកាសួរថា ព្រាហ្មណ៍,
អ្នកឯងរៀនមន្តនេះមកពីសំណាក់អ្នកណា ? គ្រូដើមរបស់អ្នកឈ្មោះអ្វី ?
ព្រាហ្មណ៍អៀនខ្មាស មិនហ៊ានក្រាបទូលពីឈ្មោះពោធិសត្វជាគ្រូដើម
ព្រោះជាគ្រូលបណ្តាល តំបែរជាក្រាបទូលដោយពាក្យមុសាវាទថា
មន្តនេះខ្ញុំព្រះអង្គរៀនពីសំណាក់នៃអាចារ្យទិសាបាមោក្ខ ។ មន្តកំ
អន្តរធាន សាបសូន្យ ទៅក្នុងមួយរំពេចនោះ តែព្រាហ្មណ៍មិនដឹងជា
មន្តរបស់ខ្លួនវិនាសឡើយ ។ លុះដល់ព្រះបាទពារាណសីស្តេចយាង
ទៅប្រពាតទ្យាន ទ្រង់មានព្រះពុទ្ធដីកាថា "ចូរអ្នកឈមន្តធ្វើដើម
ស្មៅនេះឲ្យមានផ្លែមកមើល!" ។ ព្រាហ្មណ៍ឈមន្តទៅមិនបានកើត
ផ្លែស្មៅដូចបំណង ទើបដឹងជាក់ថា មន្តរបស់ខ្លួនវិនាសហើយ ។ ព្រះ

ពជាទ្រង់គ្រាស់សួរពីបើដឹង ទើបព្រាហ្មណ៍ក្រាបទូលតាមពិត ។ ព្រះបរមក្សត្រិយ៍ទ្រង់ព្រួយ ហើយមានព្រះពជបញ្ជាថា ត្រូវអ្នកឯងទៅសូមទោសគ្រូដើមវិញ ក្រែងបានមន្តនោះមកវិញ ទើបអ្នកឯងបានទៅក្នុងដែនទេតទៅទៀត បើអ្នកឯងមិនទៅសូមទោសទេ ចូរអ្នកឯងដើរចេញពីដែននេះឲ្យឆាប់ទៅ ។ ព្រាហ្មណ៍ឥតទីពឹង ទើបទៅកាន់សំណាក់គ្រូដើម សូមរៀនមន្តនោះម្តងទៀត គ្រូមិនព្រមឲ្យរៀន ថែមទាំងត្មះតិះដៀលស្តីបន្ទោសជាអនេក ។ ព្រាហ្មណ៍ដល់នូវទោសរកទីពឹងមិនបាន ទើបមកគិតក្នុងចិត្តថា «បើអាគ្នាអញរកទីពឹងមិនបានដូច្នេះ តើនឹងរស់នៅធ្វើអ្វី ស្លាប់ទៅវិញប្រសើរជាង» គិតហើយក៏ដើរចូលទៅក្នុងព្រៃ បានដល់នូវមរណកាលឥតទីពឹង ។

នាំរឿងនេះមកសំដែងដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថា បុគ្គលអ្នកពោលពាក្យមុសាវាទមិនដល់នូវទោសទុក្ខដូចរឿងព្រាហ្មណ៍នេះឯង ។

ដូច្នេះ ការពោលពាក្យមុសាវាទ លោកហៅថា វចីទុច្ចរិត ជាសំដីអាក្រក់ដែលសប្បុរសមិនត្រូវពោល មិនត្រូវនិយាយឡើយ ។

២- បិសុណាវាចា នោះ បានខាងសំដីដែលនិយាយញុះញង់គេរើសយករឿងអ្នកម្ខាងទៅប្រាប់ដល់អ្នកម្ខាង ដោយមានចំណងនឹងឲ្យគេស្អប់ខ្ពើមមនុស្សដែលខ្លួនមិនត្រូវចិត្ត បើរឿងនោះជាពាក្យញុះញង់មែនតែជារឿងពិត ក៏គ្រាន់តែជាចិសុណាវាចាប៉ុណ្ណោះ បើរឿងនោះជារឿងមិនពិតផង ក៏ជាមុសាវាទថែមទៀត ។

សំដីដែលនិយាយញុះញង់នេះ ជាដើមចម ជាមូលហេតុ ជាឫសគល់ នាំឲ្យអ្នកស្លាប់បែកចេញពីគ្នា ឈ្លោះវាទខងរឿងនឹងគ្នា ។ មិនតែប៉ុណ្ណោះ ធ្វើអ្នកនិយាយនោះ ឲ្យក្តៅក្រហាយឲ្យក្រៀមក្រំ ឲ្យបានសេចក្តីទុក្ខទោមនស្សខ្លួនឯងវិញផង កន្លងបច្ចុប្បន្នជាតិនេះតំមាន; សមដូចនិទានកន្លងមកខ្ញុំកនិយាយធម្មបទដ្ឋកថា សេចក្តីថា កន្លងសាសនាកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ, នៅកន្លងវត្តមួយមានព្រះថេរៈពីរអង្គ អង្គ ១ មានវស្សា ៦០ អង្គមួយទៀត មានវស្សា ៥៩, ព្រះថេរៈទាំងពីរអង្គនោះ មានសេចក្តីត្រមេត្រីឆ្អែងគ្នា ស្មោះសរភប់រកគ្នា ហាក់ដូចជាបងប្អូនរួមទរតែមួយ ។ លោកគ្រាយ មានភិក្ខុធម្មកថិក ១ អង្គមកសុំសំណាក់នៅកន្លងវត្តនោះដែរ តែភិក្ខុជាធម្មកថិកនោះ ជាមនុស្សមានគំនិតអាក្រក់ ចាប់តាំងពីចូលមកនៅកន្លងវត្តនោះថ្ងៃណា ចេះតែនាំយករឿងរ៉ាវមិនពិតប្រាកដមកកែងក្បាយនិយាយចាក់ចុចព្រះថេរៈទាំងពីរអង្គ ឲ្យលាស់តែលោកមានសេចក្តីរន្ធត់ស្រឡះ អត់ត្រាមិនបានបែកព្រះទ័យពីគ្នា និមន្តចេញពីវត្តនោះទៅកាន់ទីដទៃអំពីគ្នាទៅ ។

ចំណែកកាលមកខាងក្រោយ, ព្រះថេរៈទាំងពីរអង្គ បានទៅជួបគ្នានៅវត្តមួយ, ព្រះមហាថេរៈ គ្រាន់តែក្រឡេកឃើញអនុត្តរៈច្បាស់អត់ត្រាមិនបាន សំរក់ទឹកភ្នែកតក់ៗ, ឯអនុត្តរៈ ក៏ជោរជន់ពោរពេញដោយទឹកភ្នែកដែរ ។ ហើយបានសាកសួររកហេតុដែលបែកចាកគ្នាបានដឹងថា ភិក្ខុធម្មកថិកនោះញុះញង់ ហើយក៏ត្រឡប់ទៅវត្តខ្លួនវិញ ។ លុះទៅដល់ ព្រះថេរៈទាំងពីរអង្គបានបណ្តេញភិក្ខុធម្មកថិកថា អាវុសោ

ឯងចូរដើរចេញអំពីអាវាសនេះទៅ ។ ឯកិត្តិធម្មកថិក ក៏ចេញអំពីទីនោះឥត
មានទីពឹងអាស្រ័យឡើយ ហើយវង្វែតទុក្ខលំបាកលុះត្រាតែអស់ជីវិត ។

ដែលនាំរឿងនេះមកសំដែង ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថា បុគ្គល
អ្នកពោលពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ លោកហៅថា វាចីទុច្ចរិត
ជាសំដីអាក្រក់ដែលសប្បុរសមិនត្រូវពោល មិនត្រូវនិយាយឡើយ ។

៣– ផរុសវាចា នោះ បានខាងសំដីដែលនិយាយអាក្រក់
បោកបោះ ខ្ទេះខ្ទរ មិនគួរស្តាប់ ដូចជេរប្រទេចផ្តាសាផ្សេង ។ ដោយ
អកោសវត្ថុជាំងឡាយ មានគ្នុតិនិលៀលដល់ជាតិ ឬ ពូជអម្បូរជាដើម ។

បុគ្គលដែលមានចំណងឲ្យអ្នកដទៃអាប់យស ហើយនិយាយបន្ទះ
បន្ថាប់ថា "អាឯងជាជាតិតាល" ឬ និយាយចំអកថា "អើបាឯងជាជាតិ
បណ្ឌិតហើយ" ដូច្នេះជាដើម ហៅថា សំដីខ្ទេចខ្ទោះ ។ នេះជាកិរិយាតែង
ឆ្លងដល់អ្នកស្តាប់ឲ្យឆេះច្រឡោតខឹង ហើយនិយាយខ្ទេចខ្ទោះ បោកបោះ
ត្រឡប់មកវិញ, ជាមូលហេតុ ជាដើមចមឲ្យកើតទៅជាឈ្លោះទាស់ខែង
ដកបដល់បងពៀរនឹងគ្នាទៅ, ទ្រង់ជាព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា :

ផរុសវាចា នាម អនត្ថការិកា ។លៈ។ សហស្សូនបរាជិយេតិ

ផរុសវាចានេះ ជាវាចាអាចធ្វើឲ្យរោជន៍ឲ្យវិនាសទៅបាន, មួយទៀត
ជាវាចា ជូរ, ចត់, ហឺរ, ល្វីង, ក្តៅ, ផ្សា, កម្រែអ្នកណាទីងអត់ក្រៃ
បាន ដោយហោចទៅសូម្បីតែសត្វតិរច្ឆាន កំតង់មិនតាប់ចិត្ត នឹង
ផរុសវាចានោះដែរ ។

กลฺยาณมิตฺเต มุญฺเญยฺย ผรุสมฺปิ มุญฺเญยฺย ปาปกมฺปิ
เนว กลฺยาณิยา. สาธุ ภทฺทา ปฏิปตฺติ ปาปิกมฺปิ

“บุคคลสมควรเพื่อจะปล่อยวางซึ่งวาจาหยาบ แม้จากเวลาที่ ๔ ประการ มีเหตุสมควรเป็นต้น, ไม่สมควรเพื่อจะปล่อยวางซึ่งวาจาอันไพเราะ แม้ไม่เป็นไปตามข้อปฏิบัติของผู้ที่ตั้งอยู่ในศีล, การที่จะปล่อยวางซึ่งวาจาหยาบ เป็นคุณเครื่องให้ถึงซึ่งความสงบระงับได้, ถ้าบุคคลจะพึงปล่อยวางซึ่งวาจาอันไพเราะเสียแล้ว ก็จักมีแต่ความเดือดร้อนเป็นอันมาก” ดังนี้.

ที่ได้ยกเอาคาถานี้มาแสดงนี้ ก็เพื่อจะให้เห็นชัดว่า บุคคลควรที่จะกล่าวแต่วาจาไพเราะ ไม่สมควรที่จะกล่าววาจาหยาบคายเลย ไม่ว่าในกาลใดๆ ทั้งสิ้น.

ส่วนคำว่า ผรุสวาจา ที่ท่านกล่าวไว้ในที่นี้นั้น ท่านหมายเอาแต่เฉพาะคำหยาบที่ไม่ควรกล่าวเท่านั้น ไม่ได้หมายเอาคำหยาบที่ควรกล่าวด้วย. แต่ว่าคำหยาบที่ควรกล่าวนั้น ได้แก่คำหยาบอย่างไร? ได้แก่คำหยาบของบิดามารดา ครูอาจารย์ ที่กล่าวแก่ศิษย์ หรือแก่บุตรธิดาของตน เพื่อให้ศิษย์ได้รับความรู้ความฉลาด ให้บุตรธิดาได้รับความสุขความเจริญ ไม่ประกอบด้วยจิตคิดร้าย ดังนี้ ไม่เรียกว่าผรุสวาจา. สมดังที่ปุณณกาสิตกล่าวว่า:

ผ ภญฺเญตุ กมฺมกาโร กมฺมุ ยเถติ โสภณา
ผ ขิปตุ อปายเสฺว สิสฺสานุ วุฑฺฒิการณา

"នាយសូនឆ្នាំនដំឆ្នាំដតាំនឲ្យល្អ គ្រូនឹងតតាំងវាយសិស្សឲ្យសិក្សា
ទីនឲ្យភ្លាក់អប្បាយនោះកាលណា វាយប្បាប្បាជាហេតុចំរើនសិស្ស"។
ទៀតៈ នាយសូនឆ្នាំនដំឆ្នាំនតាំនប្បាប្បា ទីនឲ្យស្រែវាប្រែនានោះក៏ទេ
ដំគោះនោះប៉ងល្អលក់ឲ្យគេ ដូចអាចារ្យវាយដេរសិស្សសិក្សា។
ដេរវាយសិស្សនោះទីនឲ្យសិស្សអន្តរាយ ភ្លាក់ទៅអប្បាយក៏ទេណា
ដេរវាយនោះជាហេតុឲ្យវឌ្ឍនា មានវិជ្ជាចំរើនដល់កូនសិស្ស ។

សមដូចនិទាន កុនគម្ពីរមង្គលត្ថទីបនីថា ឯកោ កិរ ទារកោ
មាតុរិបតំ អនាទរិត្វា អវញ្ញំ គប្បតិ ដំណាលថា មានទារកម្នាក់ជា
អ្នកមិនយកចិត្តទុកដាក់ មិនស្តាប់បង្គាប់ពាក្យរបស់មាតា ក៏ដើរចូលទៅ
កាន់ព្រៃ។ មាតាកាលមិនអាចឃាត់កូននោះបានដូច្នោះក៏ដេរថា អាឯង
ទៅ ចូរឲ្យមេក្របីកាចដេញរំងអាឯងកុំបាន ។ ដូនជាកុនពេលនោះ
មានមេក្របីមួយ ចេញពីកុនព្រៃមកដេញរំងាវក ដូចសំដីដែលម្តាយ
ដេរនោះមែន, ទារកនោះ ក៏ធ្វើសច្ចកិរិយាថា បើមាតារបស់ខ្ញុំពោល
ពាក្យចំពោះហេតុណា គ្រឹមតែមាត់ប៉ុណ្ណោះ មិនប្រកបដោយចិត្តជាគ្រឿង
ប្រទុស្តផងទេ ហេតុនោះ ចូរកុំមានដល់ខ្ញុំឡើយ ! គ្រានោះ មេក្របីក៏
ឈប់ស្ងៀមភ្លាម ហាក់ដូចជាគេចងជាប់កុនពីនោះឯង ។

៤—សម្ងួប្បលាបៈ នោះ ជានខាងពាក្យដែលនិយាយលេះ
លោះប្តូពាក្យកេយកយឥតប្រយោជន៍ ដល់ខ្លួននឹងអ្នកដទៃ ដូចរឿងនាង
សិតាជាដើម ។

ក្នុងន័យខ្លះ លោកយាត់អ្នកប្រែតិបត្តិធម៌មិនឲ្យនិយាយពាក្យតិរច្ឆានកថា ៣២ យ៉ាង ឲ្យនិយាយតែពាក្យជាកថាវត្ថុ ១០ យ៉ាង មានអប្បិច្ឆកថាទីឥសន្តុដ្ឋិកថាជាដើមវិញ ព្រោះសម្ផប្បលាបៈនេះ ជាសំដីកេរ្តិ៍ កេរ្តិ៍ធ្វើទាំងអ្នកនិយាយទាំងអ្នកស្តាប់ឲ្យកេរ្តិ៍មាយចិត្ត មិនស្ងប់ស្ងាត់ ព្រមទាំងជាសំដីឥតផល ឥតប្រយោជន៍ផង ។

ដូច្នេះ សំដីដែលនិយាយលេះលោះ សំដីកេរ្តិ៍កេរ្តិ៍នោះ លោកហៅថា វចីទុច្ចរិត ជាសំដីអាក្រក់ដែលសប្បុរស មិនត្រូវពោលមិនត្រូវនិយាយឡើយ ។

ឯវចីសុចរិត ប្រព្រឹត្តល្អដោយវាចាចែកចេញជា ៤ យ៉ាង គឺ

១- ប្រព្រឹត្តមិននិយាយកុហក ហៅថា វៀរចាកមុសាវាទ;

២- ប្រព្រឹត្តមិននិយាយពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ហៅថា វៀរចាកបិសុណាវាចា;

៣- មិននិយាយពាក្យអាក្រក់មានដេរពោលពេលពត់អ្នកដទៃជាដើម ហៅថា វៀរចាកផរុសវាចា;

៤- មិននិយាយពាក្យលេះលោះកេរ្តិ៍កេរ្តិ៍ ឥតប្រយោជន៍ ហៅថា វៀរចាកសម្ផប្បលាបៈ ។

វចីសុចរិត ទាំង ៤ យ៉ាងនេះ បើបុរសបុគ្គលណាបានធ្វើឲ្យកើតមានពេញបរិបូណ៌ក្នុងខន្ធសន្តានហើយ បុរសបុគ្គលនោះ នឹងបានទទួលសេចក្តីសុខក្នុងលោកនេះ នឹងលោកខាងមុខពុំខានឡើយ ។

បើតាមព្រះពុទ្ធដីកា ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងមានក្នុងសុបុព្ពណ្ហសូត្រថា សុន្ទរកុត្តំ សុមធុរំ សុបភាតំ សុហុដ្ឋិតំ សុខណោ សុមុហុត្តោ ដែរថា (ពេលណាដែលសត្វចាំងឡាយប្រព្រឹត្តល្អដោយកាយ ពេលនោះ) ឈ្មោះថាជាទន្តគ្គហ្កល្អ ជាមង្គលល្អ ជាពេលក្លឹស្វាងល្អ ជាពេលនៃអុណោះល្អ ជាយាមល្អ; បទក្ខិណំ វិបាកម្មំ បណិធិ តេ បទក្ខិណា (ក្នុងថ្ងៃនោះ) វចីកម្ម កំឈ្មោះថាទាំងឡាយមានសេចក្តីចំរើន; បទក្ខិណាតិ កត្វាន លភន្តគ្គេ បទក្ខិណោ បុគ្គលដែលបានធ្វើនូវវចីកម្ម គួរដល់សេចក្តីចំរើន (យ៉ាងនេះ) ហើយ ក៏រមែងបាននូវប្រយោជន៍ដ៏ចំរើនទាំងឡាយ ។

អត្ថកាថាសំដែងមកអំពីវចីកថា ក៏សូមសន្មត់ថាចប់តាមសមគួរដល់កាលវេលាប៉ុណ្ណេះ ឯង ។

ដំណឹងល្អ

សូមជំរាបអស់លោក-អ្នក !

ក្នុងឆ្នាំ ១៩៥៦ នេះ មានអស់លោក-អ្នកជាច្រើនរយនាក់ដែលយឺតដំណើរក្នុងការផ្ញើឈ្មោះទៅជុះជាវកម្ពុជសុរិយា ហើយក៏មានបានអានទស្សនាវដ្តីនេះទៅ ។

តាំងឆ្នាំ ១៩៥៧ ដិតមកដល់ហើយ ឥឡូវនេះ លោក-អ្នកដែលស្ម័គ្រអានទស្សនាវដ្តីនេះ សូមផ្ញើតាមទៅពុទ្ធសាសនបណ្ឌិត្យ ក្នុងខែតុលានឹងវិច្ឆិកា ១៩៥៦ នេះ កុំខាន ។

ចប់លោកនឹងចប់ធម៌

ឃុនបណ្ឌាធុរកិច្ច ប៊ូ-ប៊ូ

នៅពុទ្ធសាសនបណ្ឌិត្យ ប៉ៃបង្អែង

តាមធម្មតារបស់ចិត្តមនុស្សគ្រប់រូបតែងចង់មាន, ចង់បាន, ចង់សុខសប្បាយដូចៗគ្នា ។ ប៉ុន្តែ បើអ្នកណាចេះតែបណ្តាយឲ្យចិត្តចង់មាន, ចង់បានហួសហេតុ ជ្រុលពេកទៅ អ្នកនោះឯងនឹងត្រូវប៉ះជាបានទុក្ខទោសវិនាសខ្លួនមិនសមតាមប្រាថ្នា ដូចជាសុភាសិតបុរាណថា "ចេះចើនចង់លាភ រែងបាត់ជនជាន" មួយទៀតថា "លោភលន់ឈ្នានភាន អន្តរាយខ្លួនបង់" ។ ហេតុនេះ អ្នកដែលចង់បានសេចក្តីសុខ, សេចក្តីចំរើនត្រូវតែទំនប់ចិត្ត, ទំហាត់ពត់ចិត្ត, កុំបណ្តាយខ្លួនឲ្យលង់ទៅតាមអំពើទុស្សាក្រក់លាមកឡើយ ។ បើអ្នកណាទប់ចិត្តបាន, ហាត់ពត់ចិត្តបានហើយ អ្នកនោះតែងបានសេចក្តីសុខ, សេចក្តីចំរើន សមដូចព្រះពុទ្ធភាសិតថា "បិត្តំ ទន្តំ សុខាវហំ ចិត្តដែលគេទូន្មានបានល្អហើយតែងនាំឲ្យបានសុខ" ។ ចុះហេតុអ្វីបានជាលោកឲ្យទំហាត់ពត់ចិត្ត? ហេតុថា "បណ្តាធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តជាធំសម្រេចបានដោយសារចិត្ត បើចិត្តអាក្រក់ហើយ ទង់ធ្វើអ្វី និយាយអ្វី គិតអ្វីក៏អាក្រក់ទៅផង សេចក្តីទុក្ខតែងជាប់តាមទៅ ដូចកង់រទេះរំលងទៅតាមស្នាមជើងគោ; បើចិត្តថ្លាស្អាតល្អហើយ ទង់ធ្វើអ្វី និយាយអ្វី គិតអ្វីក៏ល្អទៅផង សេចក្តីសុខតែងជាប់តាមទៅ ដូចស្រមោលអនុលតាម

ច្រើណា" ។ ដោយន័យនេះ មនុស្សយើង ទើសល្អឬអាក្រក់ ទើសបានសុខឬទុក្ខ ក៏ព្រោះតែចិត្ត ដ្បិតចិត្តជាធំបំផុតលើរូបកាយទាំងមូល ។ ចុះយើងត្រូវយកអ្វីមកធ្វើជាគ្រឿងទប់ចិត្ត, ហាត់ពត់ចិត្ត? ត្រូវយកច្បាប់មកទប់ចិត្ត, ហាត់ពត់ចិត្ត ទើបយើងមិនលង់ទៅតាមចិត្តចង់ ព្រោះច្បាប់ជាទាមធម្មដូចចិត្តដែរ ។ ចុះអ្វីទៅហៅថាច្បាប់? បទបញ្ញត្តិដែលហាមឃាត់មនុស្សមិនឲ្យធ្វើ ទើបទទួលយល់ព្រមឲ្យធ្វើ ហៅថា ច្បាប់ តាមភាសាបាលីហៅថា វិន័យ ។ ឯច្បាប់នោះមានច្រើនប្រការណាស់ ប៉ុន្តែបើសង្ខេបទុកមកវិញ នៅតែត្រឹមតែ ២ យ៉ាងគឺ ច្បាប់លោក ១ ច្បាប់ធម៌ ១ ។

ច្បាប់លោក

ច្បាប់សម្រាប់ប្រទេសមួយៗដែលប្រមុខរដ្ឋក្នុងប្រទេសនោះៗ បានបញ្ញត្តតែងតាំងឡើង ទុកឲ្យបណ្តាជនប្រតិបត្តិតាម ដើម្បីឲ្យបានសុខសាន្តត្រាណ ឲ្យមានរបៀបរៀបរយក្នុងប្រទេស ដូចបញ្ញត្តហាមប្រាមមិនឲ្យបណ្តាជនតាប់សម្លាប់គ្នា, មិនឲ្យលួចប្លន់គ្នាជាដើម ហៅថាច្បាប់លោក ។

ច្បាប់ធម៌

បទបញ្ញត្តិ ទើបទទួលយកក្នុងសាសនាមួយៗ ដែលព្រះជាម្ចាស់នៃសាសនានោះៗ បានប្រកាសតែងតាំងឡើង ទុកឲ្យពួកបរិស័ទប្រតិបត្តិតាម ដើម្បីឲ្យបានសេចក្តីសុខចំរើនដល់ខ្លួនទៅនាលោកនេះ

ទ្រង់លោកខាងមុខ ដូចប្រដៅឲ្យកាន់ចិត្តសុចរិតស្លូតត្រង់ល្អ, ឲ្យបរិច្ចាគទាន រក្សាសីលជាដើម ហៅថា ច្បាប់ធម៌ ។

ច្បាប់ទាំង ២ នេះត្រូវអាស្រ័យគ្នា

ច្បាប់លោកទ្រង់ច្បាប់ធម៌ទាំង ២ នេះជាគូទ្រង់គ្នា, ជាបច្ច័យអាស្រ័យគ្នាទៅវិញទៅមក ខ្លះច្បាប់ណាមួយមិនបាន ព្រោះក្នុងរូបមនុស្សម្នាក់ៗ បើកាន់តែច្បាប់លោកម្យ៉ាង មិនកាន់ច្បាប់ធម៌ផងទេ ទ្រង់ចូលរួមក្នុងចំប្រជុំពួកបរិស័ទខាងសាសនាណាមួយមិនបាន អ្នកនោះទ្រង់ទៅជាមនុស្សម្នាក់ឯង ឥតគ្នាជាមិត្តសំឡាញ់ ឥតពីពង; បើកាន់តែច្បាប់ធម៌ម្យ៉ាង មិនកាន់ច្បាប់លោកផងទេ ទ្រង់នៅក្នុងស្រុកទេសជាមួយគេពុំបាន គេទ្រង់ចាប់ធ្វើទោសតាមកំហុសរបស់ខ្លួន ដែលប្រព្រឹត្តកន្លង់ល្មើសច្បាប់ក្នុងប្រទេសនោះ ។ ហេតុនេះ មនុស្សម្នាក់ៗ ត្រូវតែកាន់ច្បាប់ទាំងពីរគឺច្បាប់លោកក៏ត្រូវកាន់ ច្បាប់ធម៌ក៏ត្រូវកាន់ ទើបអាចទ្រង់រក្សាខ្លួនឲ្យនៅជាសុខសាន្តបាន ។ ចំណែកប្រមុខរដ្ឋអ្នកគ្រប់គ្រងប្រទេស ក៏រមែងតែងតាំងច្បាប់សម្រាប់ប្រទេសឲ្យស្របទៅតាមច្បាប់ធម៌ដែរ មិនឲ្យទ្រង់ទាស់ផ្ទុយនឹងច្បាប់ធម៌ឡើយ ។

ច្បាប់ទាំង ២ នេះហើយជាបង្គោលរបស់ចិត្ត

មនុស្សដែលទ្រង់អាចទប់ចិត្ត ឬហាត់ពត់ចិត្តរបស់ខ្លួនឲ្យបានបទល្អត្រឹមត្រូវនោះ លុះតែយកច្បាប់លោកនឹងច្បាប់ធម៌ មកធ្វើជាបង្គោលរបស់ចិត្តទើបមិនហ៊ានធ្វើអ្វី។ ទាំងបំពានទៅបាន ដូចយើញប្រាក់របស់

គេនៅក្នុងទីស្ងាត់ល្មមនឹងលួចលាក់យកបាន ប៉ុន្តែបែរជាមិនហ៊ានលួចទៅវិញ ព្រោះខ្លាចទុស្សច្បាប់លោកផង ខ្លាចទុស្សច្បាប់ធម៌ឯង, អស្រ័យមានចិត្តខ្លាចទុស្សច្បាប់យ៉ាងនេះហើយ បានជាមិនលួចលាក់យកប្លែកគេនោះទៅវិញ ។ ហេតុនេះ ច្បាប់លោកនឹងច្បាប់ធម៌ជាបង្គោលរបស់ចិត្ត សម្រាប់ទប់ចិត្ត ឬហាត់ពត់ចិត្តឲ្យ បានល្អត្រឹមត្រូវជាយ៉ាងពិតប្រាកដ ។

អ្នកមិនកាន់ច្បាប់តែងបានទុក្ខទោស

ជនណាឃើញគេបានលាភ, យស, សរសើរ, សុខ ច្រើនលើសខ្លួនឬស្មើនឹងខ្លួន ហើយមានចិត្តច្រណែនទំនាស់ឈ្នានីះឫស្សាខឹងស្អប់គេតិតវាក្យ ឬយនឹងបំផ្លាញឲ្យខូចខាតលាភយសគេជាដើម អ្នកនោះឈ្មោះថាមិនកាន់ច្បាប់ធម៌ ជាអ្នកតែងបានទុក្ខទោសជានិច្ច គឺក្តៅក្រហាយចិត្តដេកមិនលក់, ចាយមិនឆ្ងាញ់ពាល់ពោល ព្រោះលោភធម៌គ្របសង្កត់; កាលបើវាក្យឬចាយកលបានហើយ ទៅជេរប្រមាថមើលងាយគេក្តី វាយដំគេក្តី កាប់សម្លាប់គេក្តី ជននោះឈ្មោះថាមិនកាន់ច្បាប់លោកជាអ្នកតែងបានខូចលុក្ខទោស តាមទំនងអំពើដែលខ្លួនប្រព្រឹត្តទុស្សនោះ ។

ហេតុនោះ ជនអ្នកក្រាថ្នាចង់មាន ចង់បានទ្រព្យធនធំធេងក្តី ឈ្មោះ ចង់បានសេចក្តីសុខចំរើនឲ្យកើតមានដល់ខ្លួន គួរបង្អោនចិត្តឲ្យអនុវត្តន៍ទៅតាមច្បាប់លោកនឹងច្បាប់ធម៌ ក្នុងពេលដែលប្រកបអាជីវកម្មគ្រប់មុខកុំបីលះបង់ឡើយ ដើម្បីសម្រេចឥដ្ឋមនុញ្ញផលសមតាមក្រាថ្នាឥតឃ្លៀងឃ្លាត ។

ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរសង្ខេប

លោក រ៉ាយ-ប៊ុក ក្រុមការងើមខ្សែលេខពីរ

ប្រែនិងរៀបរៀង

១— សញ្ញាណទូទៅ: យើងអាចស្គាល់ប្រទេសនីមួយ ៗ បានដោយទិដ្ឋភាព, លក្ខណៈទឹក្រុង, ទំនៀមទម្លាប់, ប្រពៃណី, ប្បធម៌, ប្រវត្តិសាស្ត្រ, អក្សរសាស្ត្រ, សិល្បៈ, ប្រាសាទបុរាណ, សមដ្ឋវិជ្ជា (ភូមិ, តូរ្យតន្ត្រី . . .), ភាសាសាស្ត្រ, ចម្រៀង ជាដើម ។

ប្រទេសកម្ពុជាដែលជាមាតុភូមិរបស់យើង, យើងអាចស្គាល់បានដោយសារទិដ្ឋភាពនៃបុរាណវត្ថុ ។ យើងគ្រាន់តែក្រឡេកមើលនៅសព្វទិសានុទិស, យើងនឹងបានឃើញអច្ឆរិយភាពនៃផែនសិលាធំតូចផុសសន្ធោសន្ធៅចេញពីផ្ទៃគោកដួក ដោយស្នាព្រះហស្តមហាកដក្នុងសន្ធតិ-វង្សវ័ន ។ នៅខាងជើងទន្លេសាប មានប្រាសាទជាច្រើន តឺប្រាសាទអង្គរធំ អង្គរវត្តជាដើម ដូចជាវិមានទេពនិករ លេចឡើងច្បងច្រាងគ្រោងគ្រាត ដូចជាមហាប្រាសាទ ក្នុងរឿងមួយតាន់មួយយប់ គួរឲ្យស្ញប់ស្ញែងរំភើបញាប់ញ័រក្នុងចិត្តជាអនេកប្បការ . . . ។ ប្រាសាទទាំងនេះបានធ្វើឲ្យប្រទេសកម្ពុជាយើង ល្បីល្បាញមានកិត្តិស័ព្ទខ្ចរខ្ចរ នៅនានាប្រទេស ក្នុងសកលលោក, ដែលជាហេតុធ្វើឲ្យពួកទេសចរនៃ

នានាប្រទេស មកទស្សនាជារៀងរាល់ យ៉ាងតិចតែមិនដាច់ ។ មិនតែប៉ុណ្ណោះ មានប្រាសាទជារៀងរាល់ដែលមានរូបក្បាចចម្លាក់ល្អៗ មានគំនូរគួរដែរចិត្ត, មានសិលាចារឹកផ្សេងៗ, មានបូជនីយដ្ឋាន ដែលបណ្ដិតខាងបុរាណវត្ថុវិជ្ជា តែងនាំគ្នាធ្វើដំណើរទៅកាន់តូមិភាគគ្រប់កន្លែង ដើម្បីទីធ្លាស្រាវជ្រាវនូវប្រវត្តិសាស្ត្រប្រទេសកម្ពុជាសន្ធឹងរឿយៗណាន, ចិនល្អ, អង្គរ, ព្រៃអក្សរសិលាចារឹក, រកហេតុផលក្បាច់សិល្បៈ, រូបចម្លាក់អាទិទេព, ទេវតាប្រពៃណី ទំនៀមទម្លាប់បុរាណខ្មែរ, ។ល។ ពិតមែនតែការសិក្សាខាងបុរាណវត្ថុវិជ្ជា គ្រាន់តែនាំឲ្យស្គាល់វិជ្ជាសិល្បៈរបស់ខ្មែរប៉ុណ្ណោះ តែមិនអាចស្គាល់ដល់ទៅអក្សរសាស្ត្រខ្មែរ សព្វគ្រប់បានសោះឡើយ ។

២ - សមាសភាព: អក្សរសាស្ត្រខ្មែរចែកជាបីសម័យ គឺ សម័យបុរាណ ១ សម័យទំនើប ១ សម័យបច្ចុប្បន្ន ១ ។

៣ - អភិវឌ្ឍន៍ (ពង្រីកសេចក្ដី) ក្នុងសម័យនីមួយៗ

ក) សម័យបុរាណ: (ពីសតវត្សទី ១ ទៅដល់សតវត្សទី ១៩)

អក្សរសាស្ត្រសម័យបុរាណ មានពីរបែប គឺ

១ - អក្សរសរសេរដៃ ដោយយកដីសសរសរសេរលើស្លឹកដែលលាបពណ៌ខ្មៅ ។ តែអក្សរបែបនេះមិនបានបិតរហូតមកដល់សម័យបច្ចុប្បន្ននេះទេ ។

២ - អក្សរដែលចារឹកទៅថ្មសិលា ឬទៅសសរថ្ម ដែលពណ៌នា

អំពីសិល្បៈ, ប្រវត្តិសាស្ត្រ ទំនៀមសាស្ត្រ ។ អក្សរចារឹកនោះ មានពីរបែប គឺ ជាភាសាសំស្ក្រឹតពាក្យកាព្យ ដែលជាភាសាវិញ្ញូជន នៃអារ្យធម៌ឥណ្ឌា ១ ជាភាសាខ្មែរបុរាណពាក្យរាយ ១ ។

អក្សរចារឹកជាភាសាខ្មែរច្រើនពណ៌នាអំពីប្រាសាទ, ជីវភាពបុគ្គល ដែលបរិតនៅក្នុងប្រាសាទ, ពិធីបុណ្យតាមលទ្ធិព្រហ្មញ្ញសាសនា ឬពុទ្ធ-សាសនា; កាលបរិច្ឆេទនៃការសាងប្រាសាទនោះៗ, ព្រឹត្តិការណ៍ផ្សេងៗ បញ្ជាក់ឃនាមភាសាសិល្បៈ ដែលមានទៅក្នុងបូជនីយដ្ឋានមួយៗ ។ អក្សរចារឹកជាភាសាសំស្ក្រឹតពាក្យកាព្យ ច្រើនសរសើរនូវគុណបំណាច់ ព្រះមហាក្សត្រិយ៍សម័យនោះ ព្រមទាំងព្រះរាជតេជានុភាពក្នុងការធ្វើ សង្គ្រាមតស៊ូនឹងពួកសាមន្តប្រទេស ហើយមានលក្ខណៈស្រដៀងនឹង អក្សរសាស្ត្រជាងអក្សរចារឹកខ្មែរបុរាណ ។

លោកសាស្ត្រ-សីដែស អតីតចាងហ្វាងសាលាបូព៌ាប្រទេស ធ្លាន ប្រែអក្សរចារឹកទាំងនោះជាច្រើន ឲ្យយើងធ្លានស្គាល់នូវអត្ថរសនៃអក្សរ ក្នុងសិលាចារឹក ដែលបរិតនៅពាសពេញទិគមជនបទនឹងភូមិភាគក្នុង ព្រះរាជអាណាចក្រកម្ពុជា ។ សិលាចារឹកនោះធ្លានបង្ហាញឲ្យយើង យើញជាក់ស្តែង នូវព្រះរាជតេជានុភាពនៃព្រះមហាក្សត្រិយ៍សម័យ ហ្នឹណានចំនួន ទឹងអង្គរ, ទំនៀមទម្លាប់, ប្រពៃណី, ភាសា, សង្គម ប្រជាកស្ត្រ, សាសនា, ប្រាសាទ, បូជនីយដ្ឋាន, សិល្បៈ, វប្បធម៌, ប្រវត្តិសាស្ត្រ . . . ។ល។ . . . មិនតែប៉ុណ្ណោះ សិលាចារឹកទាំង នោះធ្លានបញ្ជាក់ស្នើ មកឲ្យយើងយើញសន្តតិវង្សព្រះមហាក្សត្រិយ៍,

កាលនៃច្ចយវិជ្ជានៃប្រវត្តិការប្រាសរេ ឧទ្ធបូជនីយដ្ឋាន ព្រមទាំងចិត្តាសាសនានៃប្រទេសកម្ពុជាសម័យបុរាណ ។ សិលាចារឹកទាំងនោះខុសដូចជាវៀរគាថយន្ត ដែលបង្ហោញនូវរូបភាពឲ្យយើងឃើញច្បាស់ណាស់នូវលក្ខណៈ, ចរិយា, ត្រួសារ, សង្គមវិទ្យាបុរាណជាដើម ហើយឲ្យយើងស្គាល់នូវប្រទេសកម្ពុជា ទៅតាមទិដ្ឋភាព ៣ យ៉ាង គឺប្រវត្តិសាស្ត្រ, សាសនា ឧទ្ធអក្សរសាស្ត្រ ។

ទិដ្ឋភាពខាងប្រវត្តិសាស្ត្រ: នៅក្នុងសតវត្សទីមួយនៃ គ. ស. មានប្រទេសតិ៍សុទ្ធតែប្រកបដោយអារ្យធម៌ឥណ្ឌៀ គឺប្រទេសហ្វូណន ឧទ្ធប្រទេសចិនឡា ។ ប្រទេសហ្វូណន បិតនៅប្រទេសកម្ពុជាភាគខាងត្បូងសម័យបច្ចុប្បន្ន ព្រមទាំងប្រទេសកូសាំងស៊ីន; ប្រទេសនេះបានរាតត្បាតអាណាព្យាបាលរបស់ប្រទេសអណ្ណាមខាងត្បូង, ប្រទេសថៃឡង់មួយចំហៀង ឧទ្ធទ្បូជ្ជា ។ ប្រទេសចិនឡាបិតនៅប្រទេសកម្ពុជាភាគខាងជើងព្រមទាំងប្រទេសលាវ ភាគខាងត្បូង ។ នៅក្នុងប្រទេសចិនឡានេះឯង មានវង្សមួយ ហៅថា "កម្ពុជា" ដែលបានផ្លាស់នាមមកជា "ប្រទេសកម្ពុជា" របស់យើងសព្វថ្ងៃនេះ ។

តែលុះមកដល់ គ. ស. ៥៤០ ប្រទេសហ្វូណនក៏បានលើកកងទ័ពទៅវាយប្រទេសចិនឡា ។ ប្រទេសហ្វូណនបរាជ័យក៏ធ្លាក់មកនៅក្នុងអធិរាជភាពនៃប្រទេសចិនឡា ហើយប្រទេសទាំងពីរក៏បានរួមចូលគ្នាមកជាប្រទេសតែមួយ គឺនៅក្នុងអំណាចប្រទេសចិនឡា ដែលគេហៅថា "ប្រទេសកម្ពុជា" តាំងពីមុនសម័យអង្គរក្នុងសតវត្សទី ៦ - ៧ នៃ គ. ស. ។

ដល់មកសតវត្សទី ៨ ប្រទេសចំនួនឡា ចានបែងចែកជាប្រទេសពីរ គឺ ប្រទេសចំនួនឡាខោក ខាងជើង, ប្រទេសចំនួនឡាខ្ពក ខាងត្បូង ។

ដល់មកសតវត្សទី ៩ ព្រះចាទជយវរ្ម័នទី៧ ចានស្ថាបនាខ្លួនសន្តតិ-វង្សអង្គរ ។ ក្នុងសម័យនោះមានសិលាចារឹកជាច្រើន សរសើរអំពីតេជានុភាពព្រះមហាក្សត្រិយ៍ ព្រមទាំងពណ៌នាអំពីឈ្មោះពជនាទី ឈ្មោះប្រាសាទ ។ល។ ព្រះមហាក្សត្រិយ៍ក្នុងសម័យនោះ ព្រះអង្គជាអ្នករសាត់អណ្តែត ទ្រង់ចានតាំងពជនាទីជាច្រើនកន្លែងគឺក្រុង បរិហារាលយប្រៈ នៅទិសអគ្នេយ៍នៃតំរែសៀមរាបគឺស្រុករលួសសព្វថ្ងៃនេះ, ក្រុង យសោ-ធរប្រៈ ដែលព្រះចាទយសោវរ្ម័នទីមួយជាអ្នកស្ថាបនា ជាមួយនឹងប្រាសាទភ្នំប្រាំពីរ បិតនៅកណ្តាលពជនាទី, ក្រុង អង្គរធំ ដែលជាពជនាទីព្រះចាទជយវរ្ម័នទី ៧ មានប្រាសាទចាយ័ននៅកណ្តាលពជនាទ័ ។

តាំងពីសតវត្សទី ១២, សិលាចារឹកចានសរសើរព្រះមហាក្សត្រិយ៍នឹងប្រាសាទដែលព្រះអង្គកសាង គឺអង្គរវត្ត សាងឡើងសម្រាប់ជាពជថ្ងៃ-បង្គន់នៃព្រះចាទសូរិយវរ្ម័នទីពីរ ។ តែក្នុងចំណោមមហាពជតាំងអស់នេះមានតែព្រះចាទជយវរ្ម័នទី ៧ ទេ ដែលជាអ្នកស្ថាបនាខ្លួនប្រាសាទអង្គរធំ មានព្រះពជតេជានុភាពជាងគេ ទ្រង់ចានឈ្លះយកប្រទេសកម្ពុជាដែលធ្លាក់ចុះនៅក្នុងកណ្តាប់ដៃចាមពី គ. ស. ១១៧៧ ។ ព្រះមហាក្សត្រិយ៍អង្គនេះ ទ្រង់មិនគ្រាន់តែកសាងប្រាសាទអង្គរធំទេ ទ្រង់ថែមទាំងស្ថាបនាខ្លួនប្រាសាទចាយ័ន, ប្រាសាទបន្ទាយក្តី, តាព្រហ្ម, ព្រះខ័ន

ថែមទៀត, ទ្រង់ជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ ជានស្ថាបនាទូរមន្ទីរពេទ្យជាលក្ខណៈមួយរយពីរខ្នង ព្រមទាំងសាលាសំណាក់តាមផ្លូវថ្នល់ក្នុងប្រទេសកម្ពុជា ។

ក្នុងសម័យហ្វូណន សម័យចិនឡា នឹងសម័យអង្គរ, អារ្យធម៌ខ្មែរបានចំរើនឡើងខ្ពស់បំផុត តែក្រោយពីសម័យនោះមកអារ្យធម៌ខ្មែរក៏ចុះអន់ថយទៅវិញ ប្រៀបដូចជាព្រះអាទិត្យដែលរះពីទិសខាងកើតចេះតែខ្ពស់ឡើងជាលំដាប់ ហើយធ្លាក់ណើរថយចុះមកទាបវិញដរាបដល់ទីអស្តង្គតទៅទិសខាងលិច ។ ទៅសម័យនោះ ប្រទេសកម្ពុជាត្រូវសៀមនឹងយួនចូលមកលុកលុយជារឿនរំលើកព្រមទាំងមានសង្គ្រាមរាប់ឆ្នាំពេលវេលាក្នុងប្រទេសថែមទៀត, ព្រះមហាក្សត្រិយ៍ក៏បានចុះបង់ចោលនូវរាជធានីអង្គរ ក្នុងសតវត្សទី ១៥ មកសាងរាជធានីថ្មីនៅបន្ទាយលង្វែក ។

តាំងពីប្រទេសសៀមរយយកបានរាជធានីលង្វែក (១៩៩៩) មកគាប់ប្រទេសកម្ពុជាក៏មានសភាពស្រអាប់គ្មានរស្មី ឆង្ឆឹតអន្ធការជាដរាបរៀងរាបលុះមកដល់សព្វថ្ងៃនេះ ។

ទិដ្ឋភាពខាងសាសនា : ក្នុងប្រទេសកម្ពុជា មានសាសនាពីរគឺព្រហ្មញ្ញសាសនានឹងពុទ្ធសាសនា ។ ខាងព្រហ្មញ្ញសាសនា មានការគោរពព្រះសិវៈ នឹងព្រះវិស្ណុ ព្រមទាំងអាទិទេពហរិហរៈ ដែលគេរួមបញ្ចូលព្រះនាមព្រះសិវៈនឹងព្រះវិស្ណុឲ្យទៅជាអាទិទេពតែមួយអង្គ ។

លទ្ធិព្រហ្មញ្ញជាអង្គការសង្គម, នយោបាយ នឹងជាសាសនាដែលមានជាលំដាប់តាមគម្ពីរវេទ ។ លទ្ធិនេះកើតមានឡើងនៅប្រទេសឥណ្ឌា

ហើយពួកអារ្យៈដែលស្ថិតនៅភូមិភាគខន្ធគន្ធា ជាន់ខ្ពស់ជាតំណ
មកពីវណ្ណៈព្រាហ្មណ៍ ។ លទ្ធិព្រហ្មញ្ញនិយមកាន់តែមិតី (រតនៈបី)
គឺ ១ – ព្រះព្រហ្ម ជាអាទិទេពដំបូងគេ ដែលជានិមិត្តរូបនៃធម្មជាតុ
(Absolu), ហើយជាអ្នកស្ថាបនាខ្លួនវត្ថុ-ពិភពលោកដំបូង; ២ – ព្រះ-
នារាយណ៍ឬ វិស្ណុ ជាអ្នកអភិបាលពិភពលោក; ៣ – ព្រះសិវៈឬ
ព្រះឥស្សរ ជាអ្នកបង្កើនខ្លួនវិនាសកម្មនៃពិភពលោក ។ លទ្ធិនេះបានចូល
មកប្រតិស្ឋាននៅប្រទេសកម្ពុជាសម័យបុរាណ តាមពួកពាណិជដែល
ធ្វើដំណើរទៅមក, តាមមហាក្សត្រិយ៍ដែលនិយមគោរពបូជាលិង្គ
ព្រះឥស្សរ ឬ យោនីនាងឧមាភោគវតីជាដើម ។

ឯព្រះពុទ្ធសាសនាមានពីរយ៉ាង គឺព្រះពុទ្ធសាសនាមហាយានឬធំ
ព្រះពុទ្ធសាសនាហិនយាន ។ នៅសិលាចារឹកមានព្រះបរមនាមបីអង្គ
ដែលគេគោរពធ្វើសក្ការបូជាគឺ ព្រះបរមសម្ពុទ្ធជាម្ចាស់ ១ អង្គ, ព្រះ
លោធិសត្វលោកេស្វរៈ ១ អង្គ, ព្រះពោធិសត្វប្រាជ្ញាបារមីតា ១ អង្គ ។
នៅប្រទេសកម្ពុជាពីសម័យបុរាណ មានការគោរពមួយបែបទៀតហៅថា
" ការគោរពទេវរាជ " ព្រោះព្រះរាជបំណងនៃមហាក្សត្រាំងនោះ
ក្រោយដែលទ្រង់ព្រះទិវង្គតទៅ, ទ្រង់មានព្រះរាជបំណងរចនាព្រះរូប
ព្រះអង្គជារូបទេវរាជ ដើម្បីឲ្យប្រជារាស្ត្រគោរពបូជា ។ លទ្ធិទេវរាជ
ជាលទ្ធិដែលព្រះចាខជយវរ្ម័នទី៧ បានបង្កើតឡើងដើម្បីនឹងប្រតិស្ឋាន
ព្រះរូបព្រះអង្គទុកឲ្យគេគោរពធ្វើសក្ការបូជា, រូបទេវរាជគឺជារូបព្រះ

មហាក្សត្រិយ៍នោះឯង ដែលតាំងព្រះអង្គឯងថាជាទេវតា ឬអាទិទេព ដូចជាគេសាងព្រះបដិមាករព្រះបរមរូបព្រះសម្ពុទ្ធ ឲ្យពួកពុទ្ធសាសនិកជនគោរពសព្វថ្ងៃ, បានជាគេហៅថាលទ្ធិអាទិទេព - ក្សត្រិយ៍ (Dieu-Roi) ឬលទ្ធិទេវរាជ (Devarajà) ។

ព្រោះហេតុដូច្នេះ, ចើតាមលោកសង្ឃរាជ - សីដែស បានពោលថា "តាំងពីសម័យហ្វូណានមកដល់សតវត្សទី ១៤, មានសាសនាពីរ ចូលមកស្ថិតនៅប្រទេសកម្ពុជាគឺ ព្រហ្មញ្ញសាសនា ១ ពុទ្ធសាសនា ១ ។ នៅសម័យហ្វូណាននឹងសម័យចិនឡា, ព្រហ្មញ្ញសាសនា បានចូលមកប្រតិស្ឋានតាំងនៅ ហើយព្រះមហាក្សត្រិយ៍នឹងប្រជាជន បានគោរពព្រះហរិហរៈ ដែលរួបរួមព្រះសិវៈ: នឹងព្រះវិស្ណុជាអាទិទេពមួយអង្គ ។ នៅសម័យអង្គរសាសនាព្រះសិវៈ: ឬ ព្រះឥសូរនឹង ព្រះវិស្ណុ ឬ ព្រះនាយណ៍ ក៏ចូលមកស្ថិតនៅដោយសេចក្តីអនុគ្រោះព្រះមហាក្សត្រិយ៍ ។ ដល់មកសតវត្សទី ១២, ព្រះមហាក្សត្រិយ៍សម័យអង្គរ បានគោរពសាសនាព្រះវិស្ណុ ឬព្រះនាយណ៍, តែក៏ពេលនោះមានពុទ្ធសាសនាហិនយានខាងគាសាសំស្ក្រឹត បានមកបិតនៅប្រទេសកម្ពុជាដែរ ។ តាំងពីសតវត្សទី ៩ នៅដល់សតវត្សទី ១៣, តាមសិលាចារឹកនឹងតាមរូបក្បាច់ចំលាក់ព្រះពោធិសត្វ, យើងអាចយល់បានថា ប្រទេសកម្ពុជា ទំយមកាន់សាសនាព្រះនាយណ៍, ព្រះឥសូរ, ពុទ្ធសាសនាខាងហិនយានគាសាសំស្ក្រឹត, ពុទ្ធសាសនាខាងមហាយានឬទេវរាជ ។ ដល់មកសតវត្សទី ១៣, ព្រះពុទ្ធយោសាចារ្យបានតាំងម្តីរពុទ្ធសាសនា

ហិនយានជាភាសាបាលី មកពីកោះលង្កាតាមសមុទ្រ ចូលមកកាន់ប្រទេសកម្ពុជា ។ លទ្ធិពុទ្ធសាសនាហិនយានភាសាបាលីនេះ មានអានុភាពជាងគេ អាចរក្សកម្មភាពរហូតមកដល់សព្វថ្ងៃនេះ ។

ចំណែកឯ ទិដ្ឋភាពខាងអក្សរសាស្ត្រ នោះគឺ យើងឃើញនូវអត្ថបទខ្លះដែលគេបានរក្សាទុកមកដល់សព្វថ្ងៃនេះ ។ ឯអត្ថបទនោះគឺ ពាមក្រើ្ន ១ មហាភារត ១ នៃត្រកូមិ ១ ។

រាមក្រើ្ន នេះ ជារឿងដែលពណ៌នាអំពីសកម្មភាពដ៏ឧឡារិកនៃព្រះរាម ដែលជាអវតារនៃព្រះអាទិទេពក្រិស្ណៈ ។ មានព្រះអគ្គមហេសីនាមព្រះនាងសិតា, ដែលយក្សនាមរាពណ៌ចាប់យកទៅនគរលង្កាឯណោះ ។ ក្រោយដែលមានសង្គ្រាមជាច្រើនលើក, ព្រះរាមដោយមានព្រះអនុជគឺព្រះលក្ខ្មណ៌ជួយព្រះអង្គផង ទីឯហនុមានព្រមទាំងពលស្វាក៏ជានតុទ្ធទីឯស្តេចរាពណ៌នេះមានជោគជ័យ, ទ្រង់ក៏ដណ្តើមយកព្រះនាងសិតាពីរាពណ៌បានមកវិញ, ទៅអវសានទ្រង់វាយកំទេចនគរលង្កា ។ អត្ថបទនេះដូចគ្នាទីឯរឿងរាមាយណៈរបស់ប្រទេសឥណ្ឌា ។ រឿងនេះ, គេបានយកទៅធ្វើជាមូលដ្ឋានៃការច់ដញ្ជាំងដូចនៅវត្តព្រះកែវមរកត ឬប្រាសាទបុរាណ ឬយកមកលេងល្ខោនក៏មាន ។

មហាភារត ជារឿងមួយមានទំហំអស់ ១៨ សៀវភៅ, មានពាក្យកាព្យ ២១៤, ៧៧៨ ។ រឿងនេះពណ៌នាអំពីសង្គ្រាមពួកកុរុ ឬកៅរវៈទីឯពួកបណ្ឌុ ឬបាណ្ឌវៈ ។ ព្រះរាជបុត្រាទាំងមួយរយអង្គនៃព្រះបាទ

ឆ្លូសក្តកស្តែបានតយុទ្ធនឹងបុត្រទាំង[illegible]នាក់នៃបណ្តាទាំងអស់ ជាសន្តតិវង្សនៃព្រះបាទចន្ទកាជ ។ អត្ថបទនេះបានសរសើរនូវជោគជ័យរបស់អជ្ជុន:, នូវរឿងអាទិទេពរាប់នៃព្រះគ្រីស្ណ:, នូវរឿងលន់លិចសម្បើមអស្ចារ្យ កណ្តាលមហាសាគរនៃមនុ, នូវរឿងស្នេហាព្រះនាងសកុន្តលា នឹងព្រះបាទទុច្ចន្ត: នឹងរឿងស្នេហាព្រះនាងសាវិត្រីចំពោះព្រះស្វាមីសត្យាវណ្ណ ។ ល ។

ត្រៃយភូមិ ជាគម្ពីរមួយសំដែងអំពីភូមិ៣ គឺ កាមភូមិ, រូបភូមិ, អរូបភូមិ ។ ក្រៅពីនេះ នៅមានគម្ពីរត្រៃភេទ ឬត្រៃពេទ្យ ឬក៏ត្រៃវេទដែលពណ៌នាអំពីវេទទាំងបី, គម្ពីរត្រៃយុគ ឬត្រៃយុគដែលសំដែងអំពីយុគទាំងបី គឺយុគទី ១ ហៅ ក្រឹតាយុគ, យុគទី ២ ហៅ ទ្វាបរយុគ, យុគទី ៣ ហៅ កលិយុគ ។ គម្ពីរត្រៃតា ឬត្រៃតាយុគ សំដែងអំពីយុគទី ២ គឺ ត្រៃតយុគ ឬត្រៃតា ។

១) សម័យទំនើប : (ពីសតវត្សទី ១៩ មកដល់សតវត្សទី ១៩)

សម័យនេះ យើងឃើញមានអក្សរចាក់ទៅច្បាសាខអង្គរវត្ត តាលីសតវត្សទី ១៨ ជាភាសាខ្មែរលាយភាសាបាលី ដែលធ្លាក់ទឹងសរសេរច្បាសាខនោះ ។ យើងត្រូវថា ភាសាឬអក្សរដែលប្រើនៅពេលនោះ ជាភាសាឬអក្សរខ្មែរលាយចម្រុះទឹងភាសាបាលី មិនមែនជាភាសាសុទ្ធតែខ្មែរ ។ ភាសាបាលីដែលប្រើលាយទឹងអក្សរខ្មែរនេះ ជាភាសាវិញ្ញូជន ឬព្រះពុទ្ធសាសនាខាងខ្ពស់ណាទឹកាយដែលមហាជនហៅថាហិនយាន ។

(មានត)

ក្រឿងកុំង៉ដេនហ្គឺ

(រំណុតតិចិន)

ឃុនអត្តកោវិទ ជា - ឃ្លែរ ពុទ្ធសាសនបណ្ឌិត្យ

ខែច្រៀបរៀង

រឿងរកស៊ីខាងជាងកំបោរជាអាជីពដ៏ទន់ខ្សោយ តាំងជាការខ្វៃយកតន់ពិបាកយ៉ាងខ្លាំង ទោះបីដូច្នោះ ក៏នៅតែមានអ្នកច្រកាន់យកជារឿងរកខ្លួលគានយ៉ាងពេញចិត្ត ។ កុំង៉ដេនហ្គឺ ជាមនុស្សម្នាក់ ដែលចិញ្ចឹមជីវិតដោយរបរជាងកំបោរនេះ គេបានបរិយាយរឿងរបស់គេឲ្យហាន់ហ្គឺស្តាប់ដូចតទៅនេះ ៖

"ខ្ញុំឈ្មោះ កុំង៉ដេនហ្គឺ មាតាបិតារបស់ខ្ញុំជាអ្នកធ្វើស្រែនៅតម្បន់ឈិង៉នៅ ស្រុកតាង៉កាន ប្រទេសចិន ។ កាលស្រុកកើតចលាចលក្នុងរជ្ជសម័យព្រះចាវធៀនចុង៉ រដ្ឋាភិបាលបានចេញប្រកាសកេណ្តាល, ខ្ញុំជាមនុស្សម្នាក់ ដែលបានចុះឈ្មោះយកអាសាស្មគ្រធ្វើជាទាហាន, ខ្ញុំនៅកងកងទ័ពជ ជល់នៅ ៣០ឆ្នាំ ហើយខ្ញុំជាអ្នកយកចិត្តទុកដាក់កងកិច្ចការពារជាតិមុតមាំ នៅជាអ្នកមានឈ្មោះល្អក្នុងកងការពារទាហាន បានឡើងយសសក្តិជានាយទាហាន ។ តមកខ្ញុំបានលាចេញពីកងការពារទាហាន ត្រឡប់ទៅនៅនាភូមិលំនៅដើមរបស់ខ្ញុំវិញ តែមុខគួរឲ្យអាណោចអាធ័មខ្លាំងណាស់ គឺកាលខ្ញុំទៅដល់ភូមិលំនៅដើម បានឃើញនូវទីដីស្រែចំការរបស់ខ្ញុំ បានធ្លាក់ទៅនៅក្នុងកណ្តាប់ដៃអ្នកដទៃទាំងអស់*

ធ្វើឲ្យខ្ញុំអស់សង្ឃឹមក្នុងរបរកសិកម្ម ។ ខ្ញុំរំពឹងគិតគ្នាន់គ្នោកក្នុងការរកចិញ្ចឹមជីវិតតទៅទៀត ខ្ញុំគិតឃើញតែអាជីពខាងជាងកំបោរ ព្រោះខ្ញុំធ្លាប់បានរៀនធ្វើចាំងមានការចេះដឹងពីកាលនៅជាតាហានខ្លះហើយ ។ ខ្ញុំទើបកាន់យកអាជីវៈខាងជាងកំបោរតទៅ ហើយបានធ្វើបរនេះដំមុតមាំអស់កាលជាង ៣០ ឆ្នាំ ។ ខ្ញុំបានអាស្រ័យនៅជាមួយនឹងអ្នកលក់កន ដោយចេញថ្លៃអាហារនឹងថ្លៃផ្ទះឲ្យអ្នកម្ចាស់កនពាល់ ។ ខែ ខ្ញុំព្យាយាមរកលុយកាក់ប្រាក់កាស ដោយការងារដែលត្រូវធ្វើដោយដួតញើសតាងពីកនេះ សម្រាប់ឲ្យថ្លៃអាហារនឹងថ្លៃផ្ទះ ដើម្បីអាស្រ័យនៅតទៅ ។ បើមានលុយកាក់ដែលសល់ពីចាយវាយ ខ្ញុំបានឲ្យទានដល់មនុស្សពិការនឹងមនុស្សកំសត់ទុគ៌ត ” ។

ភ្លុំដេនហ៊ូបានពោលតទៅទៀតថា “ មនុស្សយើងបានជួយបរិភោគមកពីអ្នកតាប់តាស់កនដ៏ ក្លូវស្រែ, បានខោអាវស្លៀកតាក់មកពីជាងតំបាញនឹងអ្នកចិញ្ចឹមនាង ហើយបានសព្វវត្ថុដទៃទៀត ដែលជារបស់ចាំបាច់ក៏មានន័យដូចគ្នា បើយើងខ្វះការងារដែលត្រូវធ្វើដោយកម្លាំងរបស់មនុស្សទៅហើយ វត្តចាំងនោះនឹងសំរេចដូចចំណងមិនបាន ព្រោះក្នុងលោកនេះមិនមានអ្នកណាមួយ ដែលមានសមត្ថភាពអាចនិម្មិតបណ្តាលឲ្យវត្តអ្វី ។ តើតបានត្រង់ឬត្រង់ប្រការនោះទេ ព្រោះហេតុនោះយើងទើបគួរធ្វើរបស់ដែលល្មមធ្វើបាន ដើម្បីជួយជ្រោមជ្រែងដល់គ្នានឹងគ្នាក្នុងការចិញ្ចឹមជីវិតទៅ ។

ព្រះគុណជាអម្ចាស់ជីវិតលើតួង ត្រង់ត្រង់លើពួកសេនាមាត្យ

ពាជបរិពារ ទ្រង់គ្រាន់តែមានព្រះបរមពាជឱ្ការបង្គាប់បញ្ជាប៉ុណ្ណោះ សេ-
នាមាត្យទាំងនោះ ជាអ្នកសម្រេចពាជកិច្ចពាជការតាមមុខក្រសួងរបស់ខ្លួន
ហើយបានញ៉ាំងកិច្ចការផែនដីឲ្យសម្រេចដោយរៀបរយ ឬដូចជាមេផ្ទះ
ទំងគ្រឿងប្រើប្រាស់ក្នុងផ្ទះ គ្រឿងផ្ទះមួយ ៗ សោតសឹងមានប្រយោជន៍
ម្យ៉ាង ៗ ផ្សេង ៗ ពីគ្នា គ្រឿងខ្លះឲ្យសម្រេចកិច្ចយ៉ាងនេះ គ្រឿងខ្លះឲ្យ
សម្រេចកិច្ចយ៉ាងនោះ ទើបជាហេតុញ៉ាំងកិច្ចផ្ទះឲ្យសម្រេចបានដោយ
រៀបរយ រឿងនេះឧបមាយ៉ាងណា ឧបមេយ្យដូចអាជីវកម្មទាំងពួងគំយ៉ាង
នោះដែរ ចំណែកអ្នកមើលងាយការងារឬបោះបង់ចោលការងារមិនយក
ចិត្តទុកដាក់ អ្នកនោះមិនយូរប៉ុន្មានទេ គង់មានទេព្តាទេព្រ័ត្យអ្នករក្សា
មនុស្សលោក បណ្តាលឲ្យដល់ខ្លួនវិនាសក្នុងពេលមិនយូរប៉ុន្មាន
ខ្ញុំទើបមិនហ៊ានលះបង់អាជីវកម្មខាងជាងគំបោរ ខំធ្វើការគំបោរដើម្បីឲ្យ
កើតសេចក្តីសុខសំពន្ធតរៀងមក ។

ការជាងគំបោរជាវិជ្ជាដែលរៀនងាយធ្វើងាយ, ការហ្វឹកហាត់ឲ្យមាន
សេចក្តីស្ទាត់ជំនាញ ក៏មិនឃើញមានការពិបាកអ្វីឡើយ ហើយជាអាជីព
ដែលឲ្យគុណសម្បត្តិដល់ការហាត់ខ្លាំយ ព្រោះដូច្នោះខ្ញុំទើបមិនមាន
សេចក្តីអៀនខ្មាសក្នុងអាជីពដែលថោកទាបនេះឡើយ ។ មួយទៀតខំភ-
ន្លែងបានខ្លួលលុយកាក់ថ្លៃតំលាំងតែ ១ រៀល ។ នោះ ត្រូវបង្ហូរញើ
តំលាំងកាយធ្វើការទាល់តែហត់ខ្លាំយពេយស្រពន់ តែខ្ញុំបានខ្លួល
សេចក្តីសុខកាយសប្បាយចិត្តជានិច្ច ។

ការងារដែលធ្វើដោយកំលាំងកាយដើម្បីជាប្រយោជន៍ដល់ជនដទៃ

នោះ ច្រើនតែជាការងាយ តែការដែលធ្វើដោយសតិបញ្ញា ដើម្បីភាពជាអ្នកជ្រាបច្បាស់នោះជាការពិបាកដ៏ក្រៃលែង ហេតុនោះទើបឃើញថាជាការយុត្តិធម៌ច្រៃពេហើយ ដែលអ្នកលួងលំទៀត្រូវប្រើកំលាំងកាយនៅគ្រាមបង្គាប់បញ្ជារបស់អ្នកជ្រាបច្បាស់មានកោតខ្លាច ឋានន្តរឲ្យអ្នកពាំនោះប្រើច្បាស់ ចំណែកអ្នកមានកំលាំងបញ្ញាត្រូវប្រើច្បាស់អ្នកលួងលំទៀ ការដែលខ្ញុំស្រែកយកអាដីតាន់ជាងកំបោរនោះ ក៏ព្រោះឃើញថាជាការរៀនងាយធ្វើងាយ ហើយមិនឃើញថាជាការខ្ជិលកិត្តិយសកិត្តិគុណ ឬគួរអៀនខ្មាសអ្វីឡើយ ។

ដែលខ្ញុំធ្វើជាងកំបោរ ជាឧកាសឲ្យខ្ញុំបានធ្វើការស៊ីឈ្នួល នៅតាមផ្ទះអ្នកមានកោតខ្លាចនឹងផ្ទះមន្ត្រីជាច្រើនឆ្នាំ តែមុខតួរឲ្យអាណោចអាធ័មដ៏ក្រៃលែង ព្រោះផ្ទះ ១ ដែលខ្ញុំបានទៅលេងសួរសុខទុក្ខ គ្រាដំបូងឃើញនៅគង់រង់ដូចប្រក្រតី តែកាលខ្ញុំទៅលេងគ្រាទី ២ ឃើញសល់នៅតែដីទេ ហើយមានច្រើនផ្ទះទៀត ដែលខ្ញុំបានទៅលេងគ្រាដំបូងមិនឃើញមានរបស់អ្វីដែលចំឡែកភ្នែក តែកាលទៅលេងពេលក្រោយទៀត ក៏បានឃើញសភាពដូចពោលមកហើយ ខ្ញុំបានសួរគេដែលនៅផ្ទះជិតខាង គេក៏និយាយច្រាប់ខ្ញុំដូចតទៅនេះ: ម្ចាស់ផ្ទះនេះត្រូវគេបញ្ជូនទៅឃុំខាំងធ្វើទោសខណ្ឌកម្មទៅទីក្រៃ, ម្ចាស់ផ្ទះនោះដល់ទូវមរណភាព ហើយបុត្រធីតាបានបំផ្ងិចបំផ្លាញទ្រព្យសម្បត្តិដែលធ្លាក់មកជាមរតកខ្លាល់តែអស់រលីង, ម្ចាស់ផ្ទះនេះបានត្រូវរាជការផ្តន្ទាទោសប្រហារជីវិតចាំងទ្រព្យសម្បត្តិក៏ត្រូវរាជការរឹបជាន់យកអស់ ។

កាលបានពិចារណាមើលហេតុការណ៍របស់វាជនពាំងនោះ តើលោកពាំងនោះជាគួយ៉ាងដែលខ្ញុំបានពោលនាមខាងដើមថា ត្រូវខ្ពើមព្រឺក្បួនអ្នករក្សាមនុស្សលោកបណ្ដាលឲ្យដល់នូវសេចក្ដីវិនាសក្នុងពេលមិនយូរប៉ុន្មាន ព្រោះលោកពាំងនោះបានលះបង់ការងារប្ដូរមើលងាយការងាររបស់ខ្លួនមែនឬទេ ? ព្រោះលោកពាំងនោះជាអ្នកចេះតែម៉ើងចេះតែម្ដងបង្ហិតក្ដួនមិនសមនឹងហានៈរបស់ខ្លួន ហើយសំដែងខ្លួនជាអ្នកច្បាស់ក្បាលជាងគេមែនឬទេ ? ព្រោះលោកពាំងនោះមិនមែនជាអ្នកសម្បូណ៌ដោយសតិសម្បជញ្ញៈ ហើយបង្ហិតក្ដួនហាក់ដូចជាអ្នកមានសតិបញ្ញាដែលមុខគួរឲ្យអៀនខ្មាសដល់ជនដទៃមែនឬទេ ? ព្រោះគោតសម្ប៉ែចរវាសម្ប៉ែចនឹងហានន្តរាសក្កិជារបស់រក្សាឲ្យបិតថេរៈថេរគាលបានដោយត្រូវមែនឬទេ ? ជាប់មកពីតហេតុពាំងនោះជាអ្នកគ្មានបុណ្យក្នុងសាសនា ដែលល្មមនឹងសេពសោយនូវសេចក្ដីសុខដ៏ទូលាំទូលៃមែនឬទេ ? សេចក្ដីសម្បូរណ៌ដោយលាភ, យស, សរសើរ, សុខ នឹងសេចក្ដីសាបសូន្យចាកលាភ យសជាដើម ជារបស់អនិច្ចំតែងតែអស់ផុតរលត់ទៅមែនឬទេ ? ។

ខ្ញុំទៅជាមានសេចក្ដីខ្មេចខ្មាសនឹងនឹកអាណិតដល់លោកពាំងនោះដែលប្រទះគ្រោះកាចដ៏ខ្លាំងក្លា ហើយយកព្រឹត្តិការណ៍របស់លោកពាំងនោះមកជាមេរៀន នឹងនឹកពិចារណាខ្លួនឯងថា អាត្មាអញគួរប្រឹងសម្ដែងកាយ ដូចម្ដេច ទើបជាអ្នកមិនលោភលន់ពន់ប្រមាណក្នុងលាភ, យស, សរសើរ, សុខ ហើយមិនសោយសោកខ្មេចខ្មាសត្រូវចិត្ត ក្នុងកាលដែលលាភយសដើមវិនាសទៅ ដល់នូវភាពជាអ្នកតំសត់ខ្ពុតថោកថាបអាប់ខ្មៅក្នុងសាសនា" ។

ហើយកុំឯងដេនហ្គូគោលតទៅទៀតថា "អ្នកដែលមានចំណេះវិជ្ជាបានធ្វើជាធំគ្រប់គ្រងពពួកមនុស្ស លទ្ធផលទាំងនោះតែងតំនុកបំរុងគេឲ្យមានត្រឹងត្រូវគោលបំរាំគោល ចិញ្ចឹមជីវិតបានយ៉ាងឧត្តមសម្បូណ៌ ទាំងមានសមត្ថភាពអាចចិញ្ចឹមបុត្រកំរិយា ឲ្យបានសុខសប្បាយថ្កុំថ្កើងរុងរឿងតែចំណែកខ្លួនខ្ញុំជាមនុស្សអកិញ្ចូ ទាំងគ្មានសមត្ថភាពពុំអាចធ្វើដូច្នោះបានតែតិតឃើញថា ការនៅលីវដោយគ្មានគ្រួសារ ជាការប្រសើរទៅវិញសម្រាប់ខ្លួនខ្ញុំ" ។

ឯការមួយទៀត ខ្ញុំរកចិញ្ចឹមមាត់ចិញ្ចឹមពោះដោយកំឡាំងកាយចុះបើខ្ញុំមានបុត្រកំរិយាទៅ ហើយស្មើរកថ្ងៃក្រាក់ការដោយកំឡាំងកាយប្រសិនជារកបានមកមិនធ្ងន់ល្មមនឹងចិញ្ចឹមពោះចិញ្ចឹមបុត្រកំរិយាទេ ខ្ញុំមិនត្រូវរវៃទៅរកដោយកំលាំងបញ្ជាជួយថែមទៀតឬ? ធម្មតាអ្នករកចិញ្ចឹមជីវិតដោយអស់កំលាំងកាយផងកំលាំងបញ្ញាផង ខ្ញុំតិតឃើញថាជាការធ្ងន់ក្រៃលែង សូម្បីអ្នកនោះឯងជាអ្នកថ្កាជ្រក៏មិនងាយនឹងរើខ្លួនរួច" ។

កាលហាន់ហ៊ូបានស្តាប់ពាក្យពោលពេញនិយមរបស់កុំឯងដេនហ៊ូគ្រាដំបូង ក៏ទឹកឆ្អល់នឹងពាក្យរបស់គេជាពន្លឺក តែកាលមកពិគ្រោះពិចារណាមើល ក៏ឃើញប្រាកដថា កុំឯងដេនហ៊ូជាមនុស្សបរិសុទ្ធពិតថ្កាកជ តែជាមនុស្សដែលអកតថ្កាជ្រពោលថា អ្នកសង្ឃគុណធម៌សេចក្តីល្អតែចំពោះខ្លួនឯងប៉ុណ្ណោះ ។

ហាន់ហ៊ូឃើញថា កុំឯងដេនហ៊ូយកចិត្តទុកជាក់ច្រើយ័ត្នខ្លួនខ្លាំងពេកហួសការគួរ ជាអ្នកមិនខាំពាំយកចិត្តទុកជាក់ដល់ជនដទៃ បុគ្គលដូច្នេះ

មិនឈ្មោះថាជាសាវ័កបស់ព្រះជាម្ចាស់ យ៉ាងដូច ដែលជាម្ចាស់លទ្ធិនៃការសន្សំ មិនត្រមបរិភោគសូម្បីតែសក់ ១ សរសៃ ក៏ងាយដឹងហ៊ូឃើញថាបុត្តកវិយាជាការនាំឲ្យកើតសេចក្តីពិបាក, បើក៏ងាយដឹងហ៊ូមិនខ្វាចពិបាកក្នុងការចិញ្ចឹមបុត្តកវិយាទេ គេគង់មានសេចក្តីពេញចិត្តក្នុងការប្រែកំលាងបញ្ញា ដើម្បីជាគុណប្រយោជន៍ដល់ពួកមនុស្សផងគ្នា តែទោះបីដូចម្តេចក៏ដោយ គង់តែគ្រាន់បើជាងអ្នកដែលវង្វេងវិលវល់ក្នុងលោកយសសរសើរសុខ ហើយមានសេចក្តីរំតើបញ្ជាប់ញ័រ ខ្វាចក្រែងលោកយសរបស់ខ្លួនទឹងនិងរាសចាត់បង់ទៅវិញ ព្រោះអ្នកដែលច្របូកច្របល់ស៊ីវិងមួរមៅដោយលោកគ្រោងវង្វេង ដែលជារបស់លាមកមានប្រការផ្សេង ៗ នោះច្រើនណាស់ ហើយជនដែលគ្មានសីលធម៌ទៅក្នុងខ្លួន ក៏មានច្រើនជាអនេក ។

ហាន់ហ៊ូឃើញថាពាក្យរបស់ភ៌ុងជេនហ៊ូ ជាមេរៀន ១ ដែលល្អគ្រាន់បើដែរ ទើបត្រាទុកក្នុងសៀវភៅសំរាប់ជាគ្រឿងជាស់តឿនចិត្តតទៅ ។

ចំណែកយើងអ្នករៀបរៀងសេចក្តីនេះ យើងឃើញថាព្រឹត្តិការណ៍របស់ភ៌ុងជេនហ៊ូ ដើរតាមបទចុងនៃពាក្យចំនៃមចំលាប់បទក្នុងលោកនីតិថា "កើតមកជាមនុស្សត្រូវធ្វើប្រយោជន៍ដល់ខ្លួនទើងជនដទៃ, បើមិនអាចនេតប្បីធ្វើតែប្រយោជន៍ខ្លួន, បើមិនអាចទៀតកុំតែធ្វើបាប" ។ ក្នុងសេចក្តីនេះ លោកសរសើរបុគ្គលដែលប្រព្រឹត្តបានសម្រេចតាមសុភាសិតបទទី ១ ថាត់ជាបុគ្គលល្អលេខ ១, អ្នកប្រព្រឹត្តបានសម្រេចតាមសុភាសិតបទទី ២ ថាត់ជាបុគ្គលល្អលេខ ២, អ្នកប្រព្រឹត្តបាន

សម្រេចតាមសុភាសិតបទទី ៣ ចាត់ជាបុគ្គលល្អលេខ ៣ ។ អ្នកដែលធ្វើប្រយោជន៍ដល់ខ្លួនឯងប្រយោជន៍អ្នកដទៃនោះ គឺ អ្នកដែលបានរៀនសូត្រចេះដឹងច្បាស់ជាប់ថ្នាក់ជាន់ខ្ពស់តាំងបឋមរៀយ រកការធ្វើបានមានប្រាក់ខែប្រាក់ថ្ងៃសន្សំទ្រព្យសម្បត្តិបាន មានប្រពន្ធកូន ហើយបានប្រៀនប្រដៅកូនចៅតាំងនោះឲ្យរៀនសូត្រចេះដឹង ឲ្យមានផ្ទះសំបែងខែកក្តៅមានតកឲ្យ ត្រមាំងបានជាស់តឿនក្រែនរំលឹកជនដទៃ ឲ្យរៀនសូត្រចេះដឹង ឬទំនុកបំរុងដោយទ្រព្យសម្បត្តិឲ្យយកទៅប្រកបកិច្ចការងារជាវកម្មផ្សេង ។ ហួតដល់បានប្រព្រឹត្តព្រហ្មចរិយធម៌ បានសម្រេចមគ្គផល ឬគ្រាន់តែតាំងខ្លួនជាកល្យាណបុថុជ្ជនក៏ដោយ តាំងបានញ៉ាំងជនដទៃឲ្យប្រព្រឹត្តព្រហ្មចរិយធម៌ បានសម្រេចមគ្គផល ឬគ្រាន់តែឲ្យតាំងខ្លួនជាកល្យាណបុថុជ្ជនបានផង តែប៉ុណ្ណឹងចាត់ជាអ្នកប្រព្រឹត្តត្រូវតាមសុភាសិតបទទី ១ ។ បុគ្គលដែលបានរៀនសូត្រចេះដឹងតែចំពោះខ្លួនរកទ្រព្យសម្បត្តិបានល្មមបរិភោគខ្លួនហួត ១ ជីវិត មិនមែនពឹងតែស៊ីឈ្លសគេអស់ ១ ជីវិតនោះទេ ហួតដល់បានប្រព្រឹត្តព្រហ្មចរិយធម៌ បានសម្រេចមគ្គផលតែចំពោះខ្លួនដូច្នេះជាដើម ឈ្មោះថាអ្នកប្រព្រឹត្តត្រូវតាមសុភាសិតបទទី ២ ។ បុគ្គលដែលរៀនសូត្រចេះដឹងបន្តិចបន្តួចស៊ើរចេះស៊ើរទេ យកជាការងារមិនបាន គឺពឹងចំណេះខ្លួនមិនបាន ហើយពឹងផ្អែករកការធ្វើខាងស៊ីឈ្លសគេ តាំងមិនចេះសន្សំទ្រព្យសម្បត្តិសំចៃខុតចាយអាយបរិភោគ ដល់ពេលខ្លួនចាស់ លុះដល់គ្មានកំលាំងពឹងធ្វើការងារបរិញ្ចឹមខ្លួន អាងសូមបានគេបរិភោគ តែជនខ្លះមិនប្រព្រឹត្តខុចត្រង់ដោយ

កាយវាចាចិត្តឯណាមួយឡើយ បុគ្គលដូច្នេះឈ្មោះថាប្រព្រឹត្តត្រូវតាមសុភាសិតបទទី ៣ ។

ព្រឹត្តិការណ៍របស់កុំងជេនហ្គ៊ូ កំសត់ត្រង់ចូលក្នុងសុភាសិតបទទី ៣ នេះ ព្រោះកុំងជេនហ្គ៊ូរកចិញ្ចឹមមាត់ចិញ្ចឹម តាមតែដោយវិជ្ជាជីវៈ គឺ ការជាងកំបោរ ថ្មាសចាកលួចប្លន់ ទើបធ្វើបោកបញ្ឆោតជាដើម មិនធ្វើឲ្យចន្លៀតចង្ឋល់ដល់ជនដទៃ ត្រូវតាមសុភាសិត ១ បទទៀតថា "ធសិយា លោកវិឌ្ឍនោ ប្រែថា "កើតមកជាមនុស្សមិនគួរធ្វើខ្លួនឲ្យចន្លៀតលោក" ។ ពាក្យថា "មិនគួរធ្វើខ្លួនឲ្យចន្លៀត" គឺមិនគួរប្រព្រឹត្តបទល្មើសដោយកាយទ្វារ វចីទ្វារ មនោទ្វារ ។ ពាក្យថា "លោក" ចានដល់យមលោក, មនុស្សលោក, ទេវលោក, ព្រហ្មលោក តែក្នុងសុភាសិតនេះសំដៅយកមនុស្សលោក គឺលោកជាទីនៅនៃមនុស្សនិងសត្វតិរច្ឆានទូទៅ ដែលអាចារ្យខ្លះហៅថា សត្វលោក ប្រែថា "លោកគឺផែនដីជាទីលំនៅនៃសត្វនិងមនុស្ស" មានន័យដូចគ្នានឹងពាក្យដែលយើងហៅថា មនុស្សលោក ព្រោះមនុស្សដែលនៅក្នុងលោកនេះ លោកចាត់ថាជាធំជាងសត្វ មានអំណាចត្រួតត្រាលើសត្វទូទៅក្នុងលោករបស់ខ្លួនបាន សូម្បីក្នុងព្រះវិន័យក៏មានដំណាលថា កិក្ខុទៅលួចយកពាក្យមកចំអិនបរិភោគ មិនត្រូវអាបត្តិ ជាកដិកវេ ព្រោះសត្វគ្មានកម្មសិទ្ធ គឺគ្មានអំណាចសម្រេចក្នុងកិច្ចការទាំងពួង ទាំងគ្មានអំណាចប្រកាន់ថារបស់នេះជារបស់ខ្លួនផង ទាំងបញ្ជាប់អាណាចក្រទៀតសោត កំតែមិនព្រមឲ្យសត្វមានកម្មសិទ្ធដែរ ថែមទាំងពួកមនុស្សប្រកាន់យក

រូបសត្វ ដែលគេយើញថាជាកម្មសិទ្ធរបស់គេវែមទៀត ដូចគេដើរទៅ
យើញដំរីខ្លាត្រែសក្តាន់ជាដើម គេក៏ចាត់យកមកហ្វឹកហាត់ធ្វើជាពាហនៈ
របស់គេ ឬបាញ់សម្លាប់យកមកធ្វើជាចំណីអាហារ ឬគេដើរទៅយើញឃុំ
គេក៏ត្រួយចំណាំទុកថាជារបស់គេជាដើម ចប្បាប់ខាងពុទ្ធចក្រក៏អនុលោម
តាមរឿងនេះខ្លះដែរ ដូចបានពោលមកហើយ ។ ដែលអធិប្បាយមក
ខាងនេះ ដើម្បីឲ្យយើញពាក្យដែលថាមនុស្សលោក "លោកជាទីទៅ
របស់មនុស្ស" មានលក្ខណៈដូចម្តេច ហើយពាក្យថាមិនគួរធ្វើខ្លួនឲ្យ
ចង្អៀតលោកនោះ គឺមិនត្រូវបៀតបៀនប្រមាថពាជាដល់គ្នាទឹងគ្នា ដែល
ជាហេតុឲ្យចង្អៀតចង្អល់ទាស់ខែងខ្វែងគំនិតគ្នាទាំងឲ្យចងវៃទឹងគ្នាតទៅ ។

ចប់រឿងកុំងដេនហ្ស៊ីតែប៉ុណ្ណោះ

រឿងនេះទាញកតិថា :

រឿងដេនហ្ស៊ីជាគំរូយ៉ាងល្អមួយ
ដែលអាចជួយសួយទឹកចិត្តនៃអ្នកអាន
ឲ្យយើញថាការងារអ្វីទាំងប៉ុន្មាន
ដែលយើងបានរៀនចេះស្ទាត់ជ្រាកជាក់ ។
គួរយើងផ្ចង់តម្រង់កាន់តែការនោះ
កំប៉ោះប៉ោចបង់ចោលដោយពុំស្ទើគ្រែ
ព្រោះកាន់ការណាដែលខ្លួនចេះស្ទើរស្ទាក់
នោះនឹងធ្លាក់ជាក់ជាប់ស្កុនដោយលង់អីយ !

លោក ស៊ុន-ហាន ប្រែរៀបរៀង
លោក យ៉ូរ-អ៊ុន ពិនិត្យកែសម្រួល

(តមក)

— ៨ —

ព្រឹកឡើង អមាត្យចាលិតភ្ញាក់ពីនិទ្រា ចាន់ដឹងថាការអស់កម្លាំងកាលពីថ្ងៃម្សិលចាត់អស់ហើយ ក៏ក្រោកឡើងដូតទឹកដម្រេងកាយស្អាតចាត់បួចចេញមកកេមាណពចុន្ទិស័ត្យ ដែលកំពុងតែរៀបចំអីវ៉ាន់យ៉ាងប្រញាប់ប្រញាល់ ក៏នឹកឆ្ងល់ទើបសួរថា:

— " ចុះលោករៀបចំខ្លួនទឹងទៅណា ? " ។

ចុន្ទិស័ត្យបែរមកមើលមុខលោកចាលិត តបថា

— " ខ្ញុំនឹងលាលោកទៅផ្ទះក្នុងថ្ងៃនេះហើយ សូមលោកជួយក្រាបបង្គំទូលព្រះរាជាឲ្យខ្ញុំផង ", ថាហើយក៏ឈ្មោករៀបខុកជាក់អីវ៉ាន់ទៅក្នុងយាម ស្ពាយជាប់ប្រឹងនឹងចុះដើរទៅអំពីផ្ទះ ។

- " វង់បន្តិចសិន ចុន្ទិស័ត្យ " អមាត្យចាលិតឃាត់ដោយកិតក័យរួចសួរថា " មានការណ៍អ្វីចាន់ជាលោកប្រញាប់ម្ល៉េះ ? ។

— " ខ្ញុំក្តុកនឹកដល់ចិតាខ្ញុំភ្លាំងណាស់, កាលព័យប់មិញនេះ ខ្ញុំខ្លួលឥនដំណេកលក់ទៅយល់សប្តិឃើញថា បិតាខ្ញុំមកហៅខ្ញុំ, ដល់ខ្ញុំភ្ញាក់ឡើងចាន់សម្រេចចិត្តថាឧឹងទៅរកជួបឧឹងតាត់ ទើបខ្ញុំប្រញាប់ប្រញាល់

មកចាត់ចែងរៀបចំអីវ៉ាន់ទីឯចេញដំណើរ ទៅដូចដែលលោកបានឃើញនេះ មិនមែនមានហេតុអ្វីដទៃទេ" ឫទ្ធិស័ត្យតប ។

អមាត្យបាលិតក៏អស់សំណើចហើយតបថា "ខ្ញុំនឹកស្មានថែលោកបានសេចក្តីក្តៅក្រហាយចិត្តអំពីអ្នកណាម្នាក់ ទើបរៀបចំខ្លួនធំគេចវេះជាប្រញាប់ខ្លាំងម្ល៉េះ, បើដូច្នេះទេ សូមលោកធ្វើចាំខ្ញុំបន្តិចសិនចុះ ខ្ញុំក៏នឹកគិតដល់ផ្ទះណាស់ដែរ បើលោកទៅខ្ញុំក៏ទៅដែរ យើងនឹងទៅគ្រាបថ្វាយលាព្រះរាជាជាមួយគ្នាតែម្តង, លោកធ្វើចាំខ្ញុំមួយស្របក់សិនចុះ កុំប្រញាប់ពេក ចាំខ្ញុំរៀបចំខ្លួនសិន ខ្ញុំក៏មិនមានវបស់អ្វីច្រើនណាស់ទេ" ថាហើយក៏ប្រញាប់ប្រញាល់រៀបចំខ្លួនធំអីវ៉ាន់ រួចស្រេចបបួលឫទ្ធិស័ត្យទៅគាល់ព្រះរាជា ។

ខណៈនោះ ជាពេលព្រឹក ព្រះរាជាមិនទាន់ស្តេចចូលគាន់ព្រះកេតំនាល់នៅឡើយ ឫទ្ធិស័ត្យទើបបបួលអមាត្យបាលិតចងរំសេះទុកសិនហើយនាំគ្នាដើរចូលទៅក្នុងផ្សារកេអាហារខ្លួនឯង ។ អស់រយៈវេលា ៦ ថ្ងៃមកហើយ ដែលឫទ្ធិស័ត្យមកនៅក្នុងព្រៃនគរនេះ តែគេមិនបានចេញមកមើលខ្លួលំអទីក្រុងធំធាត់ដូចដៃ។ឡើយ ព្រោះវេលាតែផ្សុំនុសថ ។ ឯមនុស្សដែលកំពុងរំលង់ទ្រាយលក់ដូរគាំងនោះ លុះឃើញឫទ្ធិស័ត្យនឹងអមាត្យបាលិត ហើយក៏ស្គាល់ចាំបានយ៉ាងជាក់ច្បាស់ ។ បណ្តាមនុស្សគាំងនោះ មនុស្សខ្លះបានរួចផុតពាក្យសេចក្តីឈឺចាប់ ដោយសារថ្នាំរបស់ឫទ្ធិស័ត្យ កាលឃើញឫទ្ធិស័ត្យហើយក៏ប្រាប់គ្នាតៗថា លោកនេះហើយដែលខ្លួលាស់ព្រះរាជាមិនឲ្យធ្វើពិធីបូជាយ័ញ្ញ ព្រមទាំងឲ្យនុសថដល់

អ្នកមានភេតផ្សេង ។ មិនយូរប៉ុន្មាន មហាជនក៏ជ្រៀតជ្រែកមកមើលឫទ្ធិស័ត្យយ៉ាងណែនណាន់តាន់តាប់ត្រង់ផ្លូវ ដោយចិត្តរីករាយពន់ពេក, ប្រជាជនខ្លះចូលមកពាក់ពាក់ច្រវែស្រយែនឹងឫទ្ធិស័ត្យ ។ មានប្រជាជនច្រើននាក់ដែលនឹកដល់បុណ្យគុណរបស់ឫទ្ធិស័ត្យ ហើយបានចូលមកសាកសួរអំពីចំណងរបស់ឫទ្ធិស័ត្យ ប្រសិនបើបានដឹងអ្វី ហើយរបស់នោះមិនហួសកំឡាំងពួកគេៗនឹងរកមកជូន តែឫទ្ធិស័ត្យនឹងអមាត្យមិនព្រមទទួលរបស់ណាសោះ ។ កាលឫទ្ធិស័ត្យនឹងអមាត្យបាលិតដើរមើលមហាជនទើបទីក្រុង ដែលមានលំអដ៏រុងរឿងល្មមដល់វេលាព្រះពុទ្ធជាន់ឆ្ពស់មកហើយ ទើបលាប្រជាជនទាំងឡាយ ដែលជាប់តាមមកមើលនោះថា "គេសូមលាទៅសិន កាលបើមានឧកាសគេនឹងត្រឡប់មកវិញ" ។ ប្រជាជនទាំងនោះ ក៏មានសេចក្តីអាឡោះអាល័យឫទ្ធិស័ត្យនឹងអមាត្យពន់ពេក មនុស្សខ្លះបានទៅអង្វរសុំឲ្យនៅតទៅទៀត តែឫទ្ធិស័ត្យបានថ្លែងអំពីសេចក្តីចាំបាច់ថា "ចិត្តរបស់គេដកណាស់ហើយ គេមិនអាចនឹងលះបង់ចោលយូរបានទេ" ក្នុងទីបំផុតក៏ត្រឡប់ទៅគាល់ព្រះពុទ្ធ ។

ក្នុងវេលានោះ ព្រះពុទ្ធប្រថាប់លើកដបល្ង័ក្ខ ក្នុងដៃព្រះពុទ្ធនៃនគរវេសាលី កំពុងឲ្យវិនិច្ឆ័យព្រះពុទ្ធការណីយកិច្ចការផែនដី, គាលពហានរក្សាព្រះអង្គចូលមកក្រាបបង្គំទូលថា អមាត្យបាលិតជាពុទ្ធសាសនិកនៃនគរពាពាណសី ទើបមានព្រះឫទ្ធិស័ត្យសូមចូលគាល់, ព្រះអង្គក៏ទ្រង់មានព្រះបន្ទូលឲ្យនាំចូលមកគាល់ចំពោះព្រះភ័ក្ត្រ, កាលអមាត្យនឹងឫទ្ធិស័ត្យថ្វាយបង្គំហើយ ព្រះពុទ្ធទ្រង់ត្រាស់ព្រះតម្ការថា:

– អមាត្យទីឆ៍ប្ញទ្ធិសត្យ ! ចុះដែលលោកទៅក្នុងព្រៃនេតវរបស់យើង តើបានសេចក្តីសុខសប្បាយឬទេ ? បើមានបរិស់ណាខ្វះខាត សូមលោកអត័យទោសដល់យើងផង” ។

អមាត្យបាលិតទីឆ៍ប្ញទ្ធិសត្យ ក្រាបបង្គំទូលដោយសេចក្តីដូចគ្នាថា:

– “ព្រះមហាករុណាធិគុណ ! ខ្ញុំព្រះអង្គបានទទួលសេចក្តីសុខសប្បាយ មិនមានបរិស់ណាខ្វះខាតទេ សូមព្រះតេជះជំកល់លើត្បូង” ។

ព្រះពាជាទ្រង់ព្រះសម្រួលហើយត្រាស់សួរថា:

– “លោកចាំងពីរមានកិច្ចអ្វីមួយដែលប្រញាប់ណាស់ឬ ទើបមកគាល់យើងចាំងព្រឹកយ៉ាងនេះ ? មើលទៅគាត្រែងខ្លួនក៏ស្រួលបួលប្រហែលជាមកលាយើង ទីឆ៍ទៅពីណា ?” ។ ព្រះពាជាទ្រង់សង្កេតអាការមនុស្សចាំងពីរនាក់ ដោយព្រះប្រាជ្ញាដ៏មុះមុត ព្រះកូរមោ (ចិញ្ចឹម) ក៏ទាបួលគេគ្នា ។

– “ខ្ញុំព្រះអង្គចាំងពីរនាក់ដែលចូលមកគាល់នេះ ដើម្បីទីឆ៍ខ្លួសូរព្រះអង្គ អំពីហេតុអាក្រក់ ទីឆ៍អាគេចាំងឡាយដែលកើតក្នុងព្រៃនេតវនេះ តើបានសូប់រៀបរយហើយ ឬនៅទេ ព្រះករុណាថ្លៃពិសេស !” អមាត្យបាលិតក្រាបបង្គំទូលសួរ ។

– “បានរៀបរយសូប់ស្រួលបួលហើយ ធីតារបស់យើងបានបាត់ប្រឈួនហើយដោយសារថ្នាំបុទ្ធិសត្យ ធីតារបស់យើង មានអំណរគុណទីឆ៍បុទ្ធិសត្យជាខ្លាំង” ព្រះពាជាមានបន្ទូលត្រមាងមិចព្រះនេត្រទៅរកបុទ្ធិសត្យ ។

ឫទ្ធិស័ត្យគ្រាបបង្គំទូលថា "ខ្ញុំព្រះអង្គចង់ដឹង តើព្រះអង្គនឹងទ្រង់លើកលែងឈប់ធ្វើពិធីបូជាយ័ញ្ញរហូតទៅឬយ៉ាងណា ? ព្រះករុណាថ្លៃវិសេស" ។

- "អើ យើងនិយាយថាម៉េចហើយ យើងនឹងត្រឡប់ពាក្យវិញក៏ទេ" ព្រះពាជាមានព្រះបន្ទូលដោយព្រះសូរសៀងច្បាស់ ។ រួចទ្រង់ខតចំឫទ្ធិស័ត្យដោយមិនដាក់ព្រះនេត្រ ហើយត្រាស់សួរបញ្ជាក់ថា :

- "អើ តែងលោកបានជ្រាបយើងថា ព្រះសម្មាសម្ពុទ្ធព្រះអង្គមិនសរសើរនូវការសម្លាប់សត្វធ្វើពិធីបូជាយ័ញ្ញឬ" ។

- "ខ្ញុំព្រះអង្គគ្រាបទូលមែន ព្រះករុណាថ្លៃវិសេស" ឫទ្ធិស័ត្យគ្រាបទូល ។

- "យើងសូមអរគុណលោក ! លោកនៅរំយែកក្នុងសោះ មិនគួរនឹងមានជ្រាជ្រាអាចចេះប្រៀបធៀបឲ្យជាប្រយោជន៍ដល់យើង ; លោកប្រហែលមិនដឹងទេថា ត្រាយដែលយើងនឹកដល់ពាក្យរបស់លោកហើយ យើងបានសាកសួរពួកនាម៉ឺនរបស់យើង ដើម្បីចង់ដឹង តើអ្នកណាខ្លះបានចេះប្រវត្តិនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ មាននាម៉ឺនរបស់យើងត្រែនគ្នា បានទទួលព្រមថាចង់ដឹងថាខ្លួនគេបានចេះប្រវត្តិរបស់ព្រះពុទ្ធ ត្រមាំងបានដឹកាន់តាមពាក្យប្រៀបរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ដែរ តែមិនឆ្ងាយសំដែងខ្លួនឲ្យយើងដឹងរឿងខ្លះឡើយ យើងទើបអញ្ជើញនាម៉ឺនចាំងនោះ ឲ្យនិយាយអំពីការប្រព្រឹត្តិទៅនៃសាសនារបស់ព្រះពុទ្ធជាម្ចាស់ យើងក៏បានដឹងប្រវត្តិរបស់ព្រះអង្គដោយសារនោះឡើង, តាមដំណឹងថា ខគរបស់

យើងក៏ព្រះអង្គថ្នាប់ស្តេចមកដែរ តែគួរឲ្យស្តាយណាស់ ព្រោះសាសនា
របស់ព្រះអង្គត្រឡប់ជាសាបសូន្យគ្មានកន្លែងគោរយើង សូម្បីយើងមាន
ហាន:ជាព្រះពជាក៏មិនថ្នាប់ស្គាល់ព្រះអង្គ. ទើបតែនឹងបានដឹងក្នុងពេល
នេះ, ឥឡូវនេះ យើងមានសេចក្តីជ្រះថ្លាជឿមុតមាំនឹងពាប់អានចំពោះ
ព្រះអង្គ ដោយពាក្យប្រដៅរបស់ព្រះអង្គមានខ្លឹមសារ សមគួរដល់
មនុស្សត្រាប់ថ្នាក់ គឺកង់ហាន:នៃយើងជាព្រះពជា ព្រះសង្ឃាសម្ពុទ្ធជា
ម្ចាស់ក៏ចេះប្រាជ្ញាធម៌នៃព្រះពជា, កង់ហាន:ចេស់ប្រជាពស្តុទៅ
ព្រះអង្គចេះប្រាជ្ញាធម៌សមគួរដល់ប្រជាពស្តុ, មិនមានធម៌ដែលព្រះអង្គ
ត្រាស់ហើយមិនសមគួរដល់ជនណាឡើយ, តើកង់រយ:រលោងខ្លីនេះ
លោកជឿឬទេថា យើងបានចុះចិត្តសិប់កង់ព្រះធម៌របស់ព្រះពុទ្ធអង្គ
ដោយពិតប្រាកដ យើងជាពុទ្ធមាមក:ហើយ ? ។

ឫទ្ធិស័ត្យនឹងអមាត្យឫលិតនៅស្ងាក់ស្ងើរ មិនទាន់ជឿសិប់ទូព្រះ
តម្រាស់របស់ព្រះពជាឡើយ ព្រោះដូចជាហ៊ាសួសពន់ពេក, ឫទ្ធិស័ត្យ
ទើបក្រាបបង្គំទូលថា:

- "បើឫនតាំងព្រះទ័យកង់ព្រះធម៌ឫនមែន ជាបុណ្យរបស់ព្រះ
អង្គហើយ, មិនមែនតែខ្ញុំព្រះអង្គម្នាក់ឯងទេ ដែលត្រេកអរនឹងព្រះអង្គឫន
ចេះចេង់ធម៌ព្រះពុទ្ធជាម្ចាស់នេះ ។ ព្រះអង្គគង់ជ្រាបហើយថាព្រះសង្ឃា
សម្ពុទ្ធជាម្ចាស់ចេង់បរិនិព្វានទៅ តិតមកដល់សព្វថ្ងៃនេះ ចំនួនពីរពាន់
ឆ្នាំយូរឆ្ងាំមកហើយ, កង់មគធរដ្ឋឫនមានប្តីប ពុទ្ធបរិស័ទរបស់ព្រះសង្ឃា-
សម្ពុទ្ធជាម្ចាស់ឫនសាបសូន្យអន់ថយទៅជាច្រើន ចុះសម័យព្រះ

ចាំទទួលអាសោកមហាពជន្ធាយណាស់, សូម្បីផែនដីរបស់ព្រះអង្គក្តី ផែនដីពាក់ណាស័ក្តី ផែនដីទាំងពីរនេះឆ្ងាយជាអាណាចក្រដែលព្រះពុទ្ធអង្គទ្រង់ស្តេចទៅប្រាសវៀនយ៉ាសត្វ នៅមានអាកមសល់ចោលមកជាបដល់បច្ចុប្បន្ននេះ តែពលរដ្ឋកាប់អានសាសនាជាច្រើន; កាលបើព្រះអង្គកើតមានសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ ឈ្មោះថាព្រះអង្គទ្រង់សើរើពុទ្ធសាសនាឲ្យរុងរឿងឡើងវិញ សូមព្រះអង្គមានព្រះដន្ធយ៉ឺនយូរដោយព្រះទ័យដ៏បរិសុទ្ធនេះ សូមមានព្រះបុញ្ញាភិនិហារជាទង់ជ័យនៃពុទ្ធសាសនាចុះ" ។

ព្រះពជាទ្រង់សោមនស្សរីករេពក ត្រាស់ថា

- "ឫទ្ធិស័ត្យ ! យើងចង់ឲ្យរង្វាន់ដល់លោក តើលោកពេញចិត្តទទួលយសស័ក្តិ ឬក៏ពេញសម្បត្តិ, បើលោកប្រាថ្នាចង់បានអ្វី សូមប្រាប់យើង ។ នឹងឲ្យតាមប្រាថ្នា" ។

ខណៈនោះក្នុងវាំងព្រះពេងស្ងាត់ឈឹង, ពួកនាម៉ឺនតូចធំដែលតាល់ព្រះពជា នាំគ្នាអង្គុយប្រជុំចាំស្តាប់មាណពក្រាបបង្គំទូលតបព្រះពជាវិញ មនុស្សខ្លះស្មានថា ឫទ្ធិស័ត្យមុខជានឹងទូលសុំព្រះពជធីតារបស់ព្រះពជា ព្រោះព្រះពជាទ្រង់មេីលកន្ទុយសឲ្យហើយ ។ សំឡេងរបស់ឫទ្ធិស័ត្យដែលក្រាបបង្គំទូលឮសូរដល់អ្នកប្រជុំស្តាប់គ្រប់គ្នា ។

- "សូមព្រះតេជះដ៏ឥតលើសលុង ! ព្រះអង្គទ្រង់ជាព្រះមហាករុណាធិគុណចំពោះខ្ញុំព្រះអង្គយ៉ាងខ្លាំងខ្លាស់, ខ្ញុំព្រះអង្គមានសេចក្តីប្រាថ្នាតែមួយ៉ាងប៉ុណ្ណោះ . . ." ឫទ្ធិស័ត្យក្រាបបង្គំទូលដោយពាក្យរង្វើល ។

ព្រះពាជាទ្រង់ព្រះសម្រួលហើយត្រាស់ថា :

– " ចូរចាប់មកចុះ ឫទ្ធិស័ត្យ ! យើងបានឱយាយហើយ, មិនត្រូវគោតវៃកែងចិត្តយើងទេ " ។

ឫទ្ធិស័ត្យក្រាបបង្គំទូលថា :

– " បេះដែលខ្ញុំព្រះអង្គក្រាបថ្វាយ គឺការក្រាបបង្គំទូលលាត្រឡប់ទៅស្រុកកំណើតរបស់ខ្ញុំព្រះអង្គវិញក្នុងថ្ងៃនេះ ព្រះករុណាថ្ងៃពិសេស " ។

មនុស្សគ្រប់គ្នាដែលគិតស្មានថា ឫទ្ធិស័ត្យនឹងទូលសុំព្រះពរជាច្រើនោះ លុះបានស្តាប់ឫទ្ធិស័ត្យហើយ ក៏ទឹកមុខក្រុងចិត្តពន់ពេក ។

– " យី ! " ព្រះពាជាលាន់ព្រះឧស្ម ដោយសេចក្តីខ្ពើមនស្ស រួចមានព្រះបន្ទូលថា :

– " សុំអ្វីដទៃវិញទៅ ឫទ្ធិស័ត្យ ! យើងស្រឡាញ់លោកមែន រូបលោកខ្មុកដូចជាដួងកែវដែលក្តីស្វាធ៌ដ៏មានតម្លៃរបស់យើង ។ មិនចង់ឲ្យលោកចេញចោលយើងទៅឡើយ ឬលោកវង្វេសនឹងយើង ? " ។

ឫទ្ធិស័ត្យក្រាបបង្គំទូលតបវិញថា :

– " សូមព្រះពាជតេជះដំកល់លើត្បូង ខ្ញុំព្រះអង្គមានសេចក្តីស្រឡាញ់កក្តីចំពោះព្រះអង្គរកទីបំផុតគ្មាន ព្រោះព្រះអង្គមានព្រះទ័យប្រកបដោយព្រហ្មវិហារចំពោះប្រជាពស្ត្រ បើខ្ញុំព្រះអង្គមានបំណងឯណា ត្រេកអំពីការចង់ជួបនឹងបិតាហើយ ខ្ញុំព្រះអង្គត្រេកអរនឹងនៅផ្នែងព្រះតេជះព្រះគុណ, មួយទៀតខ្ញុំព្រះអង្គនៅមិនទាន់បានឧបសម្ប័ទ

ជាកំពូកគង់ព្រះពុទ្ធសាសនាតាមប្រពៃណី ដែលបុរសត្រង់គ្នាត្រូវបានឧបសម្ប័ទ ជាអ្នកមានសេរីភាពនៃសាក្យបុត្តនៅឡើយផង" ។

- "បើដូច្នោះ លោកនឹងត្រឡប់ទៅក្រុងពដ្ឋគឺរបាកដទេ?" ទ្រង់សួរថែមទៀត ។

- "ព្រះករុណាថ្លៃពិសេស" ។

- "ល្អណាស់មាណព ! បើលោកមានសេចក្តីជ្រាបថ្លាដូច្នោះ យើងក៏មិនអាចដឹងសង់លោកបានទេ តែយើងចង់សុំពរមួយ គឺបើកាលណាលោកនឹងឧបសម្ប័ទ សុំឲ្យមកឧបសម្ប័ទក្នុងទីនេះ យើងនឹងបានដំនុកបម្រុងក្នុងកិច្ចឧបសម្ប័ទនោះ ហើយខ្លួនយើងជាបិតាធម៌របស់លោក, លោកចូរជាបុត្តធម៌របស់យើង តើបានឬទេ?" ។

- "សូមព្រះតេជះដ៏កល់លើត្បូង, ខ្ញុំព្រះអង្គពេញចិត្តនឹងថ្វាយតាមព្រះទ័យព្រះអង្គ" ។ លុះទូលសេចក្តីនេះហើយ ឫទ្ធិស័ត្យមិនអាចនឹងទូលប្រការណាទៀតបានទេ ព្រោះគេដឹងក្នុងទឹកព្រះទ័យដ៏ពេញពោរពៅដោយព្រះករុណាគុណក្រៃពេក ។

- "លោកចាំងពីរនឹងទៅឥឡូវនេះឬ?" ព្រះពុទ្ធជាម្ចាស់សួរមានព្រះសូរសៀងញាប់ញ័រ ដោយសេចក្តីគាំងអាល័យ ។

- "ខ្ញុំព្រះអង្គនឹងទៅឥឡូវនេះត្រមង់តែម្តង ព្រះករុណាថ្លៃពិសេស" ឫទ្ធិស័ត្យក្រាបបង្គំទូល ។

- "បើដូច្នោះ យើងនឹងទៅជូនលោកដល់ទ្វារក្រុង" លុះព្រះពុទ្ធទ្រង់ត្រាស់ហើយ ទើបស្តេចយាងដួនដំណើរជនចាំងពីរនាក់ ដល់

ទ្វារក្រុងវេសាលី ជាមួយនឹងព្រះពុទ្ធបិតា ព្រមទាំងព្រះពុទ្ធានុការក្ខា ដោយឲ្យតាហានតាមជូនអមាត្យជ្បាលិត នឹងឫទ្ធិស័ត្យដល់ទីកន្លែង ។ អមាត្យជ្បាលិតនឹងឫទ្ធិស័ត្យ កាលក្រាបថ្វាយបង្គំលាព្រះពុទ្ធានឹងព្រះពុទ្ធបិតាហើយ ក៏ធ្វើដំណើរចេញដើរតាមផ្លូវទៅ ។ ព្រះពុទ្ធទ្រង់សម្លឹងមើលដរាបដល់ផុតក្រសែព្រះនេត្រ ទើបបានស្តេចយាងត្រឡប់មកទតវិញ ដោយព្រះទ័យដ៏ក្រៀមក្រំ ។

* * *

– ៩ –

ឥឡូវនេះ នឹងត្រឡប់និយាយអំពីអមាត្យនុង្ខិ, សុរពេល នឹងនាងកាញ្ចនាវិញ ។ អមាត្យនុង្ខិនឹងសុរពេលកាលបើព្រះពុទ្ធទ្រង់ឲ្យដោះលែងខ្លួនមកហើយក៏ដើរត្រង់ទៅផ្ទះដោយសេចក្តីអៀនខ្មាស ។ ឯពុកនឹងកូនបានច្រឹក្សាគ្នាទៅយល់ឃើញថា នឹងនៅកន្លែងក្រុងពុជគ្រឹះតទៅ ក៏មានតែសេចក្តីរន្ធត់ស្លន់ស្លោនឹងអំពីអ្នកជម្លៃ ព្រោះសេចក្តីស្មោះត្រង់ដែលខ្លួនបានធ្វើកាលពីទៅខូលកាន់តាវកុពុតារនោះ ជាទីមិនពេញចិត្តរបស់មនុស្សពួកឧច្ចរតនឹងពួកមិច្ឆាទិដ្ឋិជាច្រើន ហើយផ្ទះដែលខ្លួនទៅសព្វថ្ងៃនេះជាផ្ទះព្រះពុទ្ធទាន; ដោយសេចក្តីតូចចិត្តថា ខ្លួនមិនមានប្រពឹត្តខុសជាមនុស្សសុចរិតបរិសុទ្ធហើយ ព្រះអង្គបានជាក់ទោសមិនមានការយោគយល់ ឲ្យខ្លួនបានខូលសេចក្តីលំបាកវេទនា ទៅក្នុងគុកអស់វេលាជាយូរ ។ ចាំងពីរោងក់ឯពុកនឹងកូនយល់ឃើញថា គួរតែលប

ចេញចាកក្រុងពាជគ្រឹះទៅដោយរហ័ស កុំឲ្យនរណាឃើញសោះ, កាលប្រឹក្សាចុះសម្រេងគ្នាហើយ ក៏ហៅខាងកាញ្ចនាមកនិយាយឲ្យស្តាប់ រួចសាកសួរសុខទុក្ខថាន់ដឹងថា ឫទ្ធិស័ត្យធ្វើតាមពាក្យដែលសុរពលបានផ្តាំផ្ញើគ្រប់ប្រការ ក៏ឲ្យមានសេចក្តីអាឡោះអាល័យឫទ្ធិស័ត្យជាខ្លាំង ។ ខាងកាញ្ចនាថ្កាប់ចង្រៃសនិងបិតាឲ្យជ្រាប អំពីរឿងរ៉ាវរបស់ខ្លួននឹងឫទ្ធិស័ត្យដែលមានសេចក្តីស្រឡាញ់គ្នា ។ អមាត្យនឹងសុរពលមិនមានសេចក្តីវង្វេសចំពោះឫទ្ធិស័ត្យឡើយ តែព្រោះសេចក្តីអៀនខ្មាស ក៏មិនអាចនឹងនៅក្នុងក្រុងពាជគ្រឹះតទៅបាន ទើលះចោលកូនក្រមុំទុកឲ្យនៅតែម្នាក់ឯងក៏ក្រែងសេចក្តីគិតដៀលរំតែតែខ្លាំងឡើងទៀត ទើបសុំអង្វរកូនក្រមុំថា "នែកូនស្រី! បើព្រះពាជាបានជាបន្ទូរសេចក្តីបរិសុទ្ធិរបស់ខ្លួនពុកកាលណា ឥពុកនឹងត្រឡប់មកនៅក្រុងពាជគ្រឹះវិញ ហើយបើយើងមិនបានត្រឡប់មកនៅក្រុងពាជគ្រឹះទេ យើងក៏នឹងបញ្ជូនដំណឹងមកឲ្យឫទ្ធិស័ត្យដឹងពុំខាន" និយាយយកចិត្តថ្នមកូនក្រមុំរួចហើយ ក៏នាំគ្នាគៀសខ្លួនបញ្ជាប់ចេញចាកផ្ទះអំពីថ្ងៃនោះ សូម្បីតែយាយបំរើម្នាក់ជាអ្នកស្មោះត្រង់ ក៏ខ្លួនអមាត្យក៏មិនព្រមឲ្យដឹងរឿង លះចោលគាត់ឲ្យនៅតែម្នាក់ឯង ដរាបដល់ឫទ្ធិស័ត្យបានមកដួច, គាត់ខ្លួញយំកន្ទក់កន្ទេញតែម្នាក់ឯងនាជើងជណ្តើរផ្ទះ ។

ការដើរផ្លូវដោយប្រញាប់ប្រញាល់របស់នឫទ្ធិអមាត្យ នឹងបុត្តពាំងពីរមិនមាននរណាដឹងឡើយ ។ មានអ្នកដែលឆ្ងាប់ឃើញគុណសេចក្តីល្អរបស់នឫទ្ធិអមាត្យនឹងបុត្តបានមកសួរនាំជាច្រើនគ្នា ក្នុងកាលដែលបានដឹង

ថា អមាត្យផុតចាកទោសហើយ តែគេទៅពុំដួច ព្រោះទៅគ្រាយ ដែលលោកនទ្ធិនឹងបុត្រចេញផុតទៅហើយ នរណា ។ ដែលមកក៏គិតថា ប្រហែលជាអមាត្យនទ្ធិមានសេចក្តីអៀនខ្មាសខ្លុំឯង ទ្បានជាគេចចេញពីទីនេះ ហើយនាំគ្នាអាឡោះអាល័យអមាត្យនទ្ធិ ហើយនិយាយថា "អំណើះតទៅ បើមានអ្នកណាធ្វើការមិនប្រកបដោយធម៌ ក៏មិនមានអ្នកណាហ៊ានដំទាស់ដូចអមាត្យនទ្ធិ" ។ កាលជនទាំង ៣ នាក់ដើរផ្លូវចេញមកផុតខេត្តដែនកំពែងក្រែង នទ្ធិអមាត្យក៏ទ្បានសុំទិញសេះអំពីអ្នកស្រុកពៃ ទ្បាន ៣ ធ្វើឲ្យការដើរផ្លូវទ្បានសេចក្តីស្រួលច្រើនឡើង ព្រោះទ្បានសេះទាំង ៣ នេះជួយដឹកនាំអីវ៉ាន់ទឹងមាសពេជ្រដ៏ច្រើនលើសលាំលាជាច់ទីឆ្ងាយមកសុទ្ធតែជារបស់ចាំបាច់ ទើបមិនជាធ្ងន់ប៉ុន្មាន យប់ត្រង់ណាក៏ដេកត្រង់នោះ ដរាបដល់ទ្បានដល់ខេត្តដែនក្រែងពាក់ណាស៊ី ។ អមាត្យនទ្ធិបបួលសុរពេលស្នាក់នៅក្រៅក្រុង ហើយជ្រើសរើសទ្បានទីដ៏ជំសមគួរមួយសន្ធឹមល្មមនៅទ្បានប៉ន្មានថ្ងៃក្នុង ហើយជាជ័យមានជ័យជាតិល្អ អាចបណ្តុះដាំបន្ទែរធ្វើការលក់ដូរ រកស៊ីតទៅទ្បាន ។ អមាត្យនទ្ធិនឹងសុរពេលកាលតាំងទីលំនៅ ។ ទីនោះ ក៏ទ្បានសេចក្តីសុខសប្បាយ ។ សុរពេលក៏ព្យាយាមជួយជ្រោមជ្រែងកិច្ចការងារបស់ឪពុក ដោយគិតឃើញថា ជីវិតរបស់ខ្លួនទៅកាលជាខាងពុទ្ធិនឹងត្រូវរស់នៅតាមទំនងនេះ ។ បណ្តាជនទាំង ៣ នាក់ ជនដែលគេគួរអាណិត ព្រោះទ្បានខ្វះសេចក្តីវែងឆ្ងាយចិត្តច្រើនជាងគេ គឺនាងកាញ្ចនា នាងមានសេចក្តីកតញ្ញូចំពោះបិតានឹងបងប្រុស ជ្បានធ្វើខ្លួនឲ្យជាមេផ្ទះដ៏ល្អ គឺកិច្ចការផ្ទះ

មានស្ងួដណ្តាំអាហារចាស្រែចាសផ្ទះសម្បែងជារដេម មិនឲ្យបងនឹងឪពុកល្អក់ចិត្តទេ សូម្បីនាងមានសេចក្តីស្រឡាញ់ ព្រមទាំងមានសេចក្តីអាឡោះអាល័យឫទ្ធិស័ត្យជាប់ក្នុងចិត្តជានិច្ច ក៏នាងទំអត់ធន់មិនសំដែងអាការឲ្យបិតានឹងបងប្រុសដឹងឡើយ ។ លោកនន្ទិអមាត្យនឹងសុរពលកាលត្រឡប់មកអំពីចំការ ឡើងទៅលើផ្ទះម្តងណា តែងសម្លឹងឃើញម្ហូបដែលកាញ្ចនាដោះដូរសាំងខុកដោយត្រឹមត្រូវ ក៏នឹកសរសើរអំពីកិច្ចវត្តដែលនាងធ្វើ ដោយរៀបរយមិនមានខ្វះខ្វាំ ទាំងមិនឆ្ងាប់និយាយគួញត្អែរថាលំបាកយ៉ាងណាសោះ កាលនឹកសរសើរដូច្នេះហើយក៏កើតសេចក្តីអាណិតកូនក្រមុំ, ដោយហេតុលោកស្រឡាញ់កូន លោកតែងនិយាយសរសើរកូនក្រមុំដែលអង្គុយចាំលោកលើផ្ទះ ក្នុងពេលនាងដោះដូរសម្ហូបដាក់លើតុរួចស្រេចហើយ ។ មានថ្ងៃមួយលោកនន្ទិមិនឃើញនាងចេញមកអង្គុយតាមទម្លាប់ ក៏លបដើរចូលទៅខាងក្នុងរួមជាមួយស្មានថានាងដេកលក់ លោកសម្លឹងមើលទៅក្នុងបន្ទប់ ឃើញកូនក្រមុំកំពុងប្រណម្យដៃថ្វាយបង្គំព្រះ កាលនាងងើយមុខឡើង លោកឃើញទឹកភ្នែកនាងហូរជោកមុខ ជាសកាពដែលគួរញាប់ញ័រក្នុងចិត្តពន់ពេក ។

- "ពុទ្ធោ! កូនស្រីសំឡាញ់ឪពុក, វេលានេះឪពុកដឹងថានាងមិនសប្បាយចិត្តហើយ តែឪពុកមិនដឹងធ្វើយ៉ាងណាឲ្យនាងបាត់ទុក្ខទេ ព្រោះជាវេរកម្មរបស់យើង, ឥឡូវនេះឪពុកមិនដឹងថា តើចិត្តឫទ្ធិស័ត្យដូចម្តេចតាមឪពុកស្មានប្រហែលជាគេកូចកូនស្រីឯងហើយ" នន្ទិអមាត្យនិយាយបញ្ជោតឲ្យកូនក្រមុំលែងគិតដល់ឫទ្ធិស័ត្យ ។

នាងកាញ្ចនាកាលឃើញឥពុកត្រមាំងបានស្តាប់ពាក្យរបស់ឥពុកក៏តតាំយ នាងប្រញាប់តបថា:

— "ខ្ញុំគ្មានអត់សង្កត់មិនបានទេពុក! ព្រោះឫទ្ធិស័ត្យជាមនុស្សមានចិត្តគំនិតល្អណាស់ គេមិនធ្លាប់ប្រព្រឹត្តល្មើសលើកូនសោះ គេមានឫកពាសុភាពគួរឱ្យសរសើរ, ដែលកូនយំនេះមិនមែនកូនស្តាយសេចក្តីសុខសប្បាយកាលពីដើមទេ, គឺកាលកូនថ្ងាយបង្គំព្រះវណ្ណនេះស្រាប់តែក្នុងខឹតតិដល់ពេលដែលទៅក្នុងក្រុងពជ្រនេះ ឫទ្ធិស័ត្យធ្លាប់នាំផ្លាឈើមកឱ្យកូន ហើយយើងតាំង ២ នាក់ ចូលទៅបូជាព្រះក្នុងបន្ទប់អធិដ្ឋានថា សូមឱ្យលោកឥពុកឯង ទឹងបងសុវត្ថិភាពរួចពីភ័យឃ្លានខ្លួនអភ័យទោសត្រឡប់មកទៅទឹងខ្ញុំដូចដើមវិញ រឿងចាស់តាំងនេះឯងដែលគ្រឿនចិត្តខ្ញុំ ឃ្លានជាខ្លាំង" នាងកាញ្ចនានិយាយឱ្យឥពុកស្តាប់ តោះបីក្នុងខណៈដែលនិយាយ នាងមានសេចក្តីតតាំយញាប់ញ័រក្នុងចិត្តយ៉ាងដូចម្តេច នាងក៏ទៅចាំពាក្យរបស់ឫទ្ធិស័ត្យដែលថា សេចក្តីទុក្ខកើតឡើងដល់យើងចាត់ជាសេចក្តីមិនសប្បាយចិត្ត កាលបើសេចក្តីទុក្ខនោះកើតឡើងហើយ យើងត្រូវស្វែងរកល្បិចមួយថា ម្ចាស់ហេតុការណ៍អ្វីនីមួយវាធ្វើឱ្យយើងឈឺចាប់ ឱ្យយើងវេទនា ឥឡូវនេះ យើងកើតទុក្ខហើយដែលយើងកើតទុក្ខនេះ យើងទុក្ខខ្លួនឯង យើងវេទនាខ្លួនឯង ឥតមានខ្មាណាបង្ខំឱ្យយើងកើតទុក្ខវេទនាទេ" ពាក្យដែលឫទ្ធិស័ត្យធ្លាប់លួងលោមនាងតាំងនេះ ធ្វើឱ្យនាងរឹងប៉ឹងអាចរម្ងាប់ការឈឺចាប់ក្នុងចិត្តនាងបាន ។

— "ប្រពៃហើយកូនស្រីសំឡាញ់ឥពុក! ឥពុកយល់ថាមិនយូរ

ប៉ុន្មានទេ យើងតង់ទឹងបានដំណឹងរបស់ឫទ្ធិស័ក្តិខ្លះពុំខាន ម្យ៉ាងទៀត ឪពុកបានប្រាប់កូនឯងថា ទឹងផ្ញើដំណឹងទៅឲ្យឫទ្ធិស័ក្តិដឹង ក្នុងថ្ងៃណាមួយដែលឈ្មួញមកទិញអីវ៉ាន់អំពីយើង ហើយគេប្រាប់យើងថា មានមនុស្សក្រមុំដើរផ្លូវទៅក្រុងរាជគ្រឹះ ឪពុកទឹងប្រាប់ឲ្យកូនឯងដឹងភ្លាម, ក្នុងពេលនោះកូនឯងត្រូវផ្ញើដំណឹងទៅឲ្យឫទ្ធិស័ក្តិដឹង, បើគេនៅតិតជល់កូនឯង គេក៏ទឹងមករកកូនឯង, ទៅកូន ! យើងទៅបរិភោគអាហារជាមួយគ្នា" ។

ឪពុកទឹងកូនដែលជាអ្នកមានជាតាកម្មអាក្រក់ ចាន់ខំផ្គត់ផ្គង់ទូលាវិតរបស់ខ្លួនមិនរួញរា ដោយការបណ្តុះដាំតូជបន្ទែច្រើនបែប មានពួកឈ្មួញចូលមករកទិញយកទៅលក់ក្នុងទីក្រុងឯង។មិនបាច់ទៅដឹកនាំបបួលឡើយ ។ ជន ៣ នាក់ឪពុកទឹងកូន មានអធ្យាស្រ័យល្អទៅរកពួកឈ្មួញចរចាក់ទាក់ ក្រែកខ្លួលឈ្មួញមិនក្រអឺតក្រខមឆ្មើងឆ្មៃទេ មានវាចាខន់ផ្អែមពីរោះ ។ ពួកឈ្មួញប្រុស-ស្រី ក៏ស្និទ្ធស្នាលស្រឡាញ់រាប់អានពុំខុកចំរុងជាន់ច្រ បើមានអ្វីបន្តិចបន្តួចក៏គាន់យកមកផ្ញើរឿយ ។ ។ ខាងក្រោយដែលធ្វើសួនបន្ទែស្រេចហើយ សុរពលក៏ឈ្វៀតយកឧបាសកទំនេរទៅរើរកហាត់ព្យាមនូវវិជ្ជាប្រើអាវុធ ដែលខ្លួនធ្លាប់រៀនមក ឲ្យស្ទាត់ជំនាញឡើងវិញ ។ ទោះបីសុរពលដឹងថា កូនដីវិតរបស់គេទឹងមិនអាចខ្លួចកាន់ការពជការខាងវាហាន នៅខ្លាំណាទៀតបានឡើយ គេក៏មិនលះចោលនូវវិជ្ជាចម្បាំងចាំដរនោះ ។ កាលគេប្រឹក្សាហាត់រំលឹកវិជ្ជាចម្បាំងនេះរឿយ ។ ទៅ ក៏មានពួកជនមកសរសើរនូវកូនអាវុធ

របស់គេដោយច្រើន គឺពួកឯកស្រុកស្រែក្រែងដែលនៅជិតៗនោះ តមកក្មេងកម្លោះៗក្នុងស្រុកនោះ ចូលមកសុំជាសិស្សរៀនវិជ្ជាមន្តាំងផ្ទៀងខ្លួនឲ្យប្រើប្រាស់តាមតែវាការ ។ សុរពលយើញប្រយោជន៍ដែលគេនឹងបានខ្លួលសេចក្តីពាប់អាន ទឹងដើម្បីទុកចិត្តរបស់មនុស្សទាំងនោះ គេក៏ព្រមតាំងខ្លួនជាគ្រូបង្ហាត់បង្រៀន ដោយមិនបានគិតថ្លៃឈ្នួលអ្វីទាន់ឡើយ ចំបំពេញតែសេចក្តីត្រូវការរបស់មនុស្សទាំងនោះ ដើម្បីឲ្យកើតមានការពាប់អានគ្នាឆើតតែច្រើនឡើង ទាំងខ្លួនខ្លួអមាត្យជាមួយពួកបានសេចក្តីសុខសប្បាយឡើងជាងដើម ដោយមិនត្រូវដឹកដីកាប់ស្មៅដូចកាលមុនទេ ព្រោះបានពួកសិស្សរបស់សុរពលខ្លួលបំពេញមុខការនោះឲ្យគ្រប់សព្វហើយពួកសិស្សដែលជាក្មេងកម្លោះទាំងនោះ លុះឃើញសេចក្តីសប្បាយស្រួម ទឹងកងកាយល្អខន់ក្នុងរបស់នាងកាញ្ចនា ក៏មានសេចក្តីប្រតិព័ន្ធបំពោះនាងតែគ្រប់គ្នា បានសុំឲ្យមួយវៀងខ្លួនចូលមកជណ្តើងតាមប្រពៃណី តែអមាត្យខន្ធមិនព្រមឲ្យដោយប្រើពាក្យសុភាពទៅកគ្រប់គ្នា, លុះគ្រាចុងបំផុត ដើម្បីការពារកុំឲ្យក្មេងកម្លោះប្រព្រឹត្តរំលោភដោយសេចក្តីស្នេហា លោកបានប្រាប់ថា កាញ្ចនាមានគូហើយ ប្រសិនបើគូវាបែរជាព្រងើយកន្តើយវិញ លោកទឹងប្រាប់ឲ្យដឹងពុំខាន ។

នៅខនរពោពណាស៍ដែលជាប់ជាទីដែលព្រះសម្មាសម្ពុទ្ធ ស្តេចមកប្រោសវៃនេយ្យសត្វ នៅមានបូជនីយដ្ឋានសំខាន់ៗ ទឹងវត្តុសក្តីសិទ្ធិជាច្រើន, ការពាប់អានព្រះពុទ្ធសាសនារបស់ប្រជាជនទៅមាន តែត្រូវចុះអាប់ខន់ទៅជាខ្លាំង ព្រោះសាសនាដទៃដូចសាសនាអិស្លាម ទឹង

សាសនាព្រាហ្មណ៍ ជាសាសនាដែលធ្វើឲ្យមហាជនជឿកាប់អានងាយ ។ សូម្បីតែព្រះពុទ្ធជាដែលគ្រប់គ្រងនគរពោធិសាស៍ ព្រះអង្គក៏ទ្រង់កាន់សាសនាព្រាហ្មណ៍ ខ្លះផ្នែកខ្លះពីរយ៉ាង ។ ក៏ប្រែព្រាហ្មណ៍ឲ្យជាអ្នកប្រកប ។ ប្រជាជនដែលនៅក្រៅក្រុងពោធិសាស៍ក៏ដូចគ្នា ពួកខ្លះកាប់អានព្រះពុទ្ធសាសនា ពួកខ្លះកាប់អានសាសនាព្រាហ្មណ៍ ពួកខ្លះកាប់អានសាសនាឥណ្ឌូ ។ នៅស្រុកដែលអមាត្យនន្ទិតាំងទីលំនៅ ពួកអ្នកស្រុកជិតខាងផ្ទះនោះមានចំនួនអ្នកកាប់អានសាសនាព្រះពុទ្ធ ចំនួនអ្នកកាប់អានសាសនាព្រាហ្មណ៍ជាចំនួនប្រើន ។ សិស្សសុរពលកាលមានប្រើនហើយសេចក្តីលំបាកក៏កើតឡើង អ្នកខ្លះដែលមកនៅផ្ទះសុរពលមិនត្រមូវចិត្តអ្នកដែលកាន់សាសនាព្រះពុទ្ធ ព្រោះប្រកាន់ខ្លួនថាជាពួកព្រាហ្មណ៍ ពួកខ្លះក៏ប្រកាន់ខ្លួនថាជាអ័ស្លាម ។ សុរពលលុះដឹងរឿងនេះហើយ គេក៏រកឧកាសនឹងឲ្យជនចាំងនោះកាប់អាន ទ្រង់ព្រះពុទ្ធសាសនាចាំងអស់រៀងតែរកឧកាសដ៏ល្អមិនទាន់បាននៅឡើយ ។ ថ្ងៃមួយសុរពលចាត់ការធ្វើបុណ្យក្នុងផ្ទះ គេនិមន្តព្រះសង្ឃមកឆាន់អាហារក្នុងផ្ទះ, មុនថ្ងៃធ្វើបុណ្យគេប្រាប់ពួកសិស្សរបស់គេថា:

(មានត)

កណ្ឌទី ២៩

ឧកញ៉ាវិបុលរាជសេនា ឆ្លៀតប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឯខៀវហ៊ុយនោះតាំងពីបែកនឹងខ័ពចូឆៅ ក៏ទៅអាស្រ័យនៅលើភ្នំយ៉ងអៀងស័នប្រហែលជាង ១ ខែ លុះដឹងថាខ្លាពីបែកទៅខៀតខៀវហ៊ុយក៏លើកពួកតាហានដែលសល់នោះស្វែងដើរស៊ើបរកខ្លាពីលុះមកដល់ស្រុកសៅសៀ ខ្លួលជាប់អស់ស្បៀងក៏ចូលទៅសូមស្បៀងអាហារទៅហ្វាយស្រុក។ មិនឲ្យ ខៀវហ៊ុយខឹងណាស់ក៏ចូលទៅវាយជណ្តើមយកគ្រាំសំកប់ងារបាន ហើយសម្លាប់ទៅហ្វាយស្រុកនោះស្លាប់ទៅ ហើយតាំងគិតរៀបចំបង្ក្រាត់សេនាតាហាន ពុកថ្ងាន់ចាំស្តាប់ដំណឹងខ្លាពី បើដឹងឮថាទៅឯណាក៏ទឹងទៅតាមរក ឯខ្លួនខៀវហ៊ុយនោះក៏ជាពុក្ខសោកព្រួយរំខានគ្មានលោះវេលា ខ្លួលនាយគ្វារបាលយកដំណើរសេចក្តីនោះចូលទៅថ្វាយខៀវហ៊ុយថា មានតាហានម្នាក់ឈ្មោះ

ស៊ុនខៀនខឹងមកវាសណាស់ ។ ខៀវហ៊ុយឮដូច្នោះអរណាស់ ក៏ចេញទៅខួលស៊ុនខៀនទាំចូលមក ស៊ុនខៀនក៏និយាយច្រាប់ខៀវហ៊ុយថា ខ្ញុំពីបែកទៅនៅអាស្រ័យនឹងអ្នកសៀវភៅឯស្រុកគីជីវ ខ្ញុំតាមទៅគិតគូនឹងខ្ញុំពីក៏បានចេញទៅនៅស្រុកយ៉ឺឡាំហើយ ឥឡូវគួនអ៊ូនាំបងថ្លៃទាំង ២ មកឈប់នៅខាងក្រៅស្រុកនេះ ហើយឲ្យខ្ញុំចូលមកច្រាប់ដំណឹងដល់អ្នកឲ្យប្រញាប់ចេញទៅខួល ។

ខៀវហ៊ុយបានស្តាប់ដូច្នោះហើយក៏មានចិត្តត្រេកអរ ព្រោះបានដឹងដំណឹងខ្ញុំពី តែគិតខឹងនឹងគួនអ៊ូណាស់ ព្រោះឮថាចូលទៅនៅនឹងបូធូ ខៀវហ៊ុយក៏ពាក់ក្រឹះគាន់ខ្លួនហើយនាំស៊ុនខៀន ទឹងតាហានទាំង ១.០០០ ចេញទៅផុតព្រំមាត់ព្រំស្រុក ។ គួនអ៊ូក្រែឡេកឃើញខៀវហ៊ុយចេញមកក៏មានអំណរណាស់ ទើបប្រគល់ជាវេនវែនឲ្យទៅពីវេនហើយបរសេះចូលតម្រង់ទៅខៀវហ៊ុយដើម្បីនឹងខួលគំនាប់ ។ ខៀវហ៊ុយឃើញគួនអ៊ូបរសេះចូលមកទឹកខឹងណាស់ ក៏ស្រែកកំហែកដោយសំឡេងដ៏ខ្លាំង ហើយយកខ្លួនដេញចាក់គួនអ៊ូៗភ័យខ្លាំង ក៏បរសេះថយត្រឡប់មកនៅពីក្រោយរថបងថ្លៃហើយស្រែកថា ហេតុម្តេចក៏ខៀវហ៊ុយឯងធ្វើដូច្នេះ អ្នកមិនបង់ពាក្យស័ត្យទៅទេឬ ? ។ ខៀវហ៊ុយតបថា ហេតុម្តេចបានជាថាយើងបង់ពាក្យស័ត្យ ខ្ញុំនេះតើបង់ពាក្យស័ត្យមុនយើង វេលានេះទើបបែរមុខមករក យើងមិនដឿទេ ។ គួនអ៊ូតបថា ហេតុម្តេចបានជាថាយើងបង់ពាក្យស័ត្យ ? ។ ខៀវហ៊ុយតបថា: ខ្ញុំនេះពេលពាក្យស័ត្យដោះគេចទៅនៅមិនបូធូយកអាសាមានសេចក្តីគាប់ប្រសើរ បូធូក៏ចិញ្ចឹមរក្សាខ្លួល

ស្មើតាំងឲ្យមានឈ្មោះសំឡេងយសស័ក្តិជាធំដល់ខ្លួន ឥឡូវខ្លួនក្លែងតែងកលៗបាយចេញមកពាត៌អាទ័គិតច្រឡូសព័យដល់យើង ។ កំដឹងខ្លួនហើយ បើយើងនឹងស្លាប់ អ្នកត្រូវតែងំជីវិតរស់នៅចុះ បើខ្លួនអ្នកស្លាប់យើងក៏រស់នៅជាមនុស្ស ។ តួនអ៊ីតបថា អ្នកឯងនឹងបងពីព្រោះហេតុនោះខុសទេ, ថើបងច្រាប់តាមក្រែសដែលត្រង់កំតង់តែអ្នកមិនជឿដែរ, ការដែលរៀបនឹងត្រង់នោះ អ្នកបួលទៅសួរបងថៃយើងតាំងពីនោត់ ដែលបងនាំមកនៅលើរថនោះចុះ អ្នកសួរហើយតង់ឮដឹងសេចក្តីពិតរឿងត្រង់របស់បងមិនខាន ។

ឯខាងតាំង ២ លុះបានឮសំឡេងតួនអ៊ូ ទឹងរឿវហ៊ុយឆ្ងាស់ធ្វើយគ្នាដោយតំហឹងដូច្នោះហើយ កំព័យណាស់បើកវានាំងឡើង ហើយនិយាយទៅនឹងរឿវហ៊ុយថា ហេតុដូចម្តេចបានជាមកធ្វើកែវាគាស់ខែងគ្នានឹងបងដូច្នេះ ? ។ រឿវហ៊ុយធ្វើយថា បងតាំង ២ មិនខាន់ជាប កុំយាត់ហាមខ្ញុំឡើយ ត្រូវតែចាំមើលខ្ញុំនឹងសម្លាប់មនុស្សដែលបង់ពាក្យស័ត្យ ហើយនឹងអញ្ជើញបងតាំង ២ ចូលទៅក្នុងស្រុក ។ នាងតាំង ២ ក៏តបថា កាលខ្លាពីនឹងអ្នកបែកគ្នាទៅនោះ ចូរួលើកគាហានទៅព័ទ្ធតួនអ៊ូជុំវិញ តួនអ៊ូគាល់ចេញមិនរួចលើសកម្លាំង មិនអាចនឹងតតាំងប្លាំងបាន ខើបកាត់ចិត្តប្រថុយខ្លួនចូលទៅទៅនឹងចូរួ ឯសេចក្តីពិតត្រង់របស់តួនអ៊ូនោះមិនលះបង់ទេ តែងៗស្បាថ៌ប្រណិប័តន៍ក្បាយើងតាំង ២ ជាជាបមក ហើយយកអាសាចូរួចេញទៅធ្វើសង្គ្រាម ប្រាថ្នាទឹងស៊ើបដំណឹងខ្លាពីពាល់គ្រា លុះដឹងថាខ្លាពីទៅនៅទឹងអ្នឧសៀវហើយ ខើបនាំយើង

មកដល់កណ្តាលផ្លូវ ប្រទះនឹងស៊ុនខៀនមកប្រាប់ថា ឥឡូវខ្លៅពីដើរចេញពីអ្នកសៀវភៅនៅស្រុកយ៉ាំ គួនអ៊ូគឺនាំយើងមក, ការដែលអ្នកមិនដឹងដំណើរសេចក្តីឲ្យជាក់លាក់តាមពិត យកតែចិត្តគំនិតស្រាលរហ័សគុំគួនខឹងប្រទូសព្រាយនឹងគួនអ៊ូជាបង ដែលមានគុណដល់យើងមកនោះមិនគួរសមសោះ ។

ខៀវហ៊ុយតបថា: ដែលគួនអ៊ូធ្វើការជាកលឧបាយនាំបងទាំង ២ មកបងក៏មិនដឹងកលឧបាយគួនអ៊ូសោះ ទៅសំគាល់ឃើញថាគួនអ៊ូគាន់ពាក្យស័ត្យពិតត្រង់; ធម្មតាកើតមកជាកូនប្រុសជាតិពាហានបានចេញវាចាស្បថស្បាន់ខុកហើយ ទោះជីនឹងស្លាប់ក៏មិនឲ្យសាបសូន្យវាចាប្តូរស្តាយជីវិត ឯចិត្តថ្លើមគួនអ៊ូ លះបង់ពាក្យស័ត្យចោល ជាមនុស្សម្ចាស់ ២ នាយចៅហ្វាយ ២ ដូច្នេះ ខឹងធ្វើគាន់យកដូចម្តេចបាន ។

ស៊ុនខៀនក៏និយាយនឹងខៀវហ៊ុយថា ឯចិត្តថ្លើមគួនអ៊ូនោះប្រាកដជារក្សាសេចក្តីស័ត្យពិតត្រង់ណាស់ ខឹងគេខាណាមកផ្ទឹមឲ្យគ្រឹមស្មើគ្នាឧស្សាហ៍ខ្ជិនកាយមិនមានស្តាយជីវិតសោះ ទំនោះខ្លួនទាំងបងថ្លៃទាំង ២ មករកខ្លៅពី លុះត្រូដំណឹងថាអ្នកនៅកងទ័ព្រស្រុកនេះ ទើបឲ្យខ្ញុំប្អូលទៅអញ្ជើញចេញមក ហេតុដូចម្តេចបានជាអ្នកនៅសងឹ្ស័យទឹងគួនអ៊ូដូច្នេះខៀត ។ ខៀវហ៊ុយឮស៊ុនខៀនឱ្យាយដូច្នោះក៏ស្រែកគំហក ហើយថាគួនអ៊ូគិតកលឧបាយមករកពាប់ខ្លួនយើងទៅឲ្យចូលឆ្កួ ហេតុដូចម្តេចបានជាខ្លួនមករលើកសរសើរថាគួនអ៊ូនៅមានសេចក្តីស័ត្យពិតត្រង់វិញ ? ។

គួនអ៊ូថា បើយើងប៉ងនឹងធ្វើប្រទូសព្រាយដល់អ្នក យើងមិនចាំបាច់នាំ

បន់ថ្ងៃតាំងពីរមកទេ តាហានចូលក្តីមាន តន់តែយើងនឹងនាំយកមកខ្លះ ។ ខណៈនោះខ្លួលទៀវហ៊ុយក្រែងក្រៅយើញកងសេនាតាហានលើកតាមមកជាច្រើន ទៀវហ៊ុយក៏និយាយទៅនឹងគួនអ៊ូថា "នោះមិនមែនជាសេនាតាហានបៃស់ចូនួនទេឬ? លើកមកជាច្រើយខ្លួនទៀតហើយ ខ្លួនមកក្លែងតែងកលធ្វើជានាំបងថ្ងៃមកមុន ឲ្យកងទ័ពលើកតាមមកជាច្រើយច្បាស់ថ្នឹងចាប់យើង" ជាហើយទៀវហ៊ុយក៏ទាំងធ្វេញមាត់ស្រែកគំរាមហើយយកខ្លួនដេញចាក់គួនអ៊ូ។ តារោរតេជខ្លួមចេញបាន ហើយថាទៀវហ៊ុយកុំគាលធ្វើអន្តរាយដល់យើងសិន ដែលតាហានលើកមកនោះមិនមែនពួកបងទេ ចាំបងៈទៅគាត់យកក្បាលមេទ័ពនោះមកឲ្យអ្នកឃើញច្បាស់ឲ្យបាន ។ ទៀវហ៊ុយតបថា: បើខ្លួនធ្វើបានដូច្នោះទើបឃើញថាពិតត្រង់ដូចអ្នកថាមែន យើងនឹងជួយកាយស្គរជំយឲ្យច្បាំងគ្នាថែមទៀត ។

ឯស៊ួយ៉ុងដែលលើកទ័ពមកនោះ លុះនាំតាហានមកជិតហើយឃើញគួនអ៊ូក៏ទ្រិងណាស់ ស្រែកថា: ឯងនេះរត់ពីមហាឧបរាជចេញមកសម្លាប់ចៅហ្វាយស្រុកនឹងនាយតយល្បាតស្ងាប់ជាច្រើនអង្វែ ហើយថែមតាំងមកសម្លាប់ជនគីជាកូយអញទៀតផង ឥឡូវមហាឧបរាជច្រើកូយអញឲ្យលើកកងទ័ពមកចាប់យកខ្លួនឯងជាបញ្ជានៅ ។ គួនអ៊ូបានឮដូច្នោះក៏ទ្រិងណាស់ បរសេះកាន់ដាវចូលទៅច្បាំងនឹងស៊ួយ៉ុង, ទៀវហ៊ុយក៏ឲ្យកាយស្គរទ័ព ១ ក្លេង យើញគួនអ៊ូកាប់ស៊ួយ៉ុងដាច់កស្ងាប់, ចំណែកគួនអ៊ូកាលបើឈ្នះហើយ ក៏ដេញចាក់កាប់សម្លាប់កងទ័ពស៊ួយ៉ុងស្ងាប់វិនាសអស់ជាច្រើនណាស់ ហើយចាប់បានតាហានដែលកាន់ទង់ជ័យ

ដើរមុខទ័ពម្នាក់ទទឹងក្បាលស្ងួយ៉ឺងយកមកឲ្យខៀវហ៊ុយ ។ ឃើញដូច្នោះ កំ
ប្រគល់ខ្លួនឲ្យទៅពួកទាហាន ហើយចុះពីលើសេះវត់ទៅគំនាប់គួនអ៊ូ ។
ទទឹងខៀវហ៊ុយក៏នាំគ្នាចូលទៅទៅពីមុខរថបងថៃ ហើយខៀវហ៊ុយនិយាយ
សុំទោសគួនអ៊ូថា: ដែលខ្ញុំបាទបានប្រមាថមើលងាយបងនោះព្រោះចិត្ត
ស្រាលរហ័ស មិនបានស្តាប់ពាក្យសំដីឲ្យជាក់លាក់ ទោសខ្ញុំបាទខុស
ណាស់ហើយ ខ្ញុំបាទសូមឲ្យបងអនុញ្ញាតលើកទោសចុះ ។

ឯគួនអ៊ូក៏ព្រមលើកទោសឲ្យខៀវហ៊ុយ ហើយសួរទាហានដែល
ចាប់ខ្លួននោះថា: ហេតុដូចម្តេចបានជាស្ងួយ៉ឺងលើកទ័ពមក? ។ ទាហាន
ពាំងនោះក្រាបថា ព្រោះស្ងួយ៉ឺងឮដំណឹងថាលោកសម្ងាប់ជិនតីជាកូយ
បានជាសូមអាសាមហាឧបាជលើកទ័ពមកចាប់លោក មហាឧបាជថា
បានប្តេជ្ញាទីឯលោកហើយ ទីឯទៅចាប់ម្តេចបាន ខ្លួលឮដំណឹងថា
ឡៅផេកទីឯកុងតៅដែលជាមេចោរនោះ លើកបក្ខពួកត្រឡប់ទៅវិញ
យកស្រុកយើឡាំវិញ បានជាមហាឧបាជប្រើស្ងួយ៉ឺងឲ្យលើកទ័ពមកចាប់
ឡៅផេកទីឯកុងតៅ តែស្ងួយ៉ឺងនោះតាត់មានចិត្តអាឃាតព្យាបាទទីឯ
លោក ព្រោះថាលោកសម្ងាប់ជិនតីជាកូយ លុះមកជួបប្រទះលោកក៏
បង្គាប់ឲ្យចូលតយុទ្ធតាល់តែដល់ទូវសេចក្តីស្លាប់អស់រ ។ ខៀវហ៊ុយ
ឮដូច្នោះក៏សោមនស្សត្រេកអរអញ្ជើញបងថៃទាំងពីរ ទីឯគួនអ៊ូចូលទៅ
កុងស្រុក ។

ខ្លួលពេលនោះ នាយទ្វារបាលទិសខាងត្បូងមកប្តឹងខៀវហ៊ុយ
ថា: ឥឡូវបឹតុកទីឯបឹហាង ប្អូនប្រពន្ធឡៅពីនាំទាហានជិះសេះ ៤ -៥ ០

នាក់មកជ្រាប់ថានឹងចូលមកដួបនឹងលោក ។ ខ្ញៀវហ៊ុយបានឮក៏ចេញទៅដួបគ្នានឹងព្រះតុកប៊ីហង៉ហើយក៏គំនាប់សាកសួរគ្នាទៅវិញទៅមក ។ ប៊ីតុកនឹងប៊ីហង៉និយាយថា តាលេឡាពីប្រើខ្ញុំឲ្យនៅរក្សាស្រុកដ៏ជាវនោះ ខ្ញុំក៏ឃើញថាកម្លាំងនឹងខ្លះខ្លួនឯងមិនបាន ទើបនាំគ្នារត់ទៅនៅស្រុកដើមកំណើតវិញ ខ្ញុំឮដំណឹងថាឡាពីទៅនៅនឹងអ្នងសៀវ កន្លងយ៉ាងដំណឹងក៏តាមឡាពីជាក្រៃយ ឯគួនអ៊ូក៏ទៅនៅនឹងបួត្ង តែខ្លួនអ្នកមួយខ្ញុំឥតឮដំណឹងអ្វីសោះ អំណោះតមកបានប្រមាណប្រហែល ៥ ខែទ្វាយហើយ ទើបបានឮដំណឹងថា អ្នកបានមកធ្វើចៅហ្វាយស្រុកនៅខែត្រនេះ បានជាខ្ញុំនាំគ្នាមកវិញ ដើម្បីនឹងឲ្យដំណឹងពីឡាពីនឹងគួនអ៊ូឲ្យអ្នកជ្រាបតទៅ ។

ខ្ញៀវហ៊ុយថា: ឥឡូវនេះគួនអ៊ូនឹងស៊ុនខៀនបាននាំបងប្អូនមកដល់យើងហើយ ។ ប៊ីតុកប៊ីហង៉ឮដូច្នោះក៏មានសេចក្តីត្រេកអរពន់ប្រមាណណាស់, ខ្ញៀវហ៊ុយក៏នាំចូលទៅដួបនឹងគួនអ៊ូនឹងបងប្អូនថ្លៃស៊ីតាំងពីរ, នាងតាំងពីរក្រឡេកឃើញប្អូនក៏មានសេចក្តីត្រេកអរពន់ប្រមាណណាស់ លុះដួបជុំគ្នាហើយក៏ពណ៌នាសំណេះសំណាល ពីរឿងដែលនឹកសបែកពីស្រុកហៃហ្គឺ រហូតដល់គួនអ៊ូហែកទំលាយគយជានចេញមកបានឲ្យប្អូនតាំង ២ នាក់ស្តាប់ ។ ខ្ញៀវហ៊ុយនឹងប៊ីតុកប៊ីហង៉ឮរឿងក៏រំដែលកំសត់ព្រាត់ជ្រាសនឹកស្នាក់ គ្នាក៏នាំគ្នាយំសោកាកិលាបអាណិតអណាថ តាំងអស់គ្នាក៏សឹងតែយំកល់ខ្លួន ហើយកយកប់រឿងជ្រាប់គ្នាទៅវិញទៅមកតាមដែលបានខុសត្រូវខុសត្រូវបាត់ផ្សឹង ។ ។ ខ្ញៀវហ៊ុយក៏ឲ្យរៀបចំតាក់

តែងតុលៀងគោជនាហារ លុះវេលាព្រឹកកាលណាទៀវហ៊ុយក៏បបួលគួនអ៊ូថា យើងត្រូវទៅកេណ្តៅតាឯស្រុកយីឡាំតែ ២ នាក់សិន ។ គួនអ៊ូតបថា: អ្នកនៅរក្សាបងថ្លៃចាំង ២ ចុះ សឹមបងនឹងស៊ុនខៀនចាំគ្នាទៅរកមុន ទៀវហ៊ុយក៏ព្រម ។

គួនអ៊ូក៏លាបងថ្លៃនាំស៊ុនខៀនទឹងភហាន ១០ នាក់ស្រុតទៅស្រុកយីឡាំ ស៊ុនខៀនក៏នាំគួនអ៊ូបួលទៅជួបនឹងកេណ្តៅផេកកុងតៅ ហើយសួរថា កេណ្តៅពីទៅឯណា ? ។ កេណ្តៅផេក, កុងតៅថ្កាប់ថា: កេណ្តៅតាមកនៅស្រុកនេះប្រហែល ១៥ ថ្ងៃ ស្រាប់តែឃើញភហានតិចតួចស្លាចស្តើងក៏ត្រឡប់ទៅទៅនឹងអួនសៀវភៅញ្ចាំថ្នាន់ឆ្កឹកក្បាលវែលត្រលំបាក ។ គួនអ៊ូបានស្តាប់ក៏ដកដង្ហើមធំមិនសប្បាយ; ស៊ុនខៀនខឹងថា: អ្នកនឹងកើតទុក្ខព្រួយចិត្តធ្វើអ្វី ចាំយើងតាមទៅឲ្យជួបនឹងកេណ្តៅតា ។ គួនអ៊ូក៏លាកេណ្តៅផេក, កុងតៅត្រឡប់ទៅស្រុកវៅសៀវិញ ទើបនាំពត៌មាននោះទៅនិយាយថ្កាប់បងថ្លៃចាំង ២ ឲ្យស្តាប់សព្វគ្រប់ប្រការ ហើយថា: ខ្ញុំបានឮតាមកេណ្តៅពីទៅស្រុកដ៏ដីវខៀតនឹងបានគិតការតទៅ ។ ទៀវហ៊ុយថាខ្ញុំសូមទៅជាមួយផង គួនអ៊ូតបថា យើងយកបានស្រុកនេះពុតជាខំសំណាក់អាស្រ័យហើយ យើងនឹងដើរចោលឲ្យទៅខំនេរនោះមិនគួរទេ ប្អូនបួរទៅរក្សាស្រុកនេះចុះ ឲ្យបងនឹងស៊ុនខៀនចាំង ២ នាក់ទៅវិញ បើបានជួបប្រទះនឹងកេណ្តៅពីហើយនឹងបានមកអាស្រ័យនៅក្នុងស្រុកវេះ ។ ទៀវហ៊ុយថា បងបានសម្លាប់ន៏ងសៀងប៊ុនធីវ ជាភហានឯកអ្នួនសៀវ, ដែលបងនឹងទៅនោះ ខ្ញុំត្រូងអ្នួនសៀវនឹងធ្វើអន្តរាយដល់បង ។ គួនអ៊ូ

ថា "ខ្ញុំនេះអ្នកកុំរវៃតក្កជាទុក្ខព្រួយឡើយ បើបងទៅហើយអ្នកនៅសៀវនឹងប្រចូសក៏យូយ៉ាងណា បងក៏ល្មមតែខ្ញុំបាន" ។ ហើយគួនអ៊ូសួរដីវធងថា: ហ៊ុយដួនសៀវលើកពួកចោរទៅនៅលើភ្នំដោយដីវស័ខនោះប្រហែលប៉ុន្មានខាក់? ដីវធងឆ្លើយថា: ប័ក្ខពួកនោះប្រហែល ៥០០ ប្លាយខាក់ ។ គួនអ៊ូថា ខ្ញុំនេះយើងនឹងស៊ុនខ្មៅនឹងស្រួតទៅរកឡៅពីមុន ខ្ញុំនឹងអ្នកឯងចូលទៅប្រាប់ហ៊ុយដួនសៀវ ឲ្យលើកប័ក្ខពួកទៅចាំយើងនៅកណ្តាលផ្លូវ បើយើងនាំឡៅពីមក ក្រែងមានភ័យអន្តរាយនឹងបានជួយការពារគ្នា ។ ដីវធងទទួលត្រមើបលាចេញទៅ ។

គួនអ៊ូនឹងស៊ុនខ្មៅក៏នាំគ្នាហានប្រហែល ២០ ប្លាយខាក់ ទៅតាមផ្លូវទិសឯជើង លុះទៅដល់ស្រុកគីដីវ ស៊ុនខ្មៅនិយាយនឹងគួនអ៊ូថា: "អ្នកចូរនៅត្រង់ពីនេះសិនចុះ ខ្ញុំនឹងលបចូលទៅរកឡៅពី ស្តាប់ដំណឹងស្រួលមិនស្រួលមើលសិនរួចសឹមគិតអានត្រទៅ" ហើយស៊ុនខ្មៅក៏ចូលទៅក្នុងស្រុកនោះទៅ ។

ឯគួនអ៊ូឃើញភូមិមួយនៅក្នុងព្រៃ ក៏នាំគ្នាហានចូលទៅសុំអាស្រ័យនៅផ្ទះនោះ ។ គួនតេងម្ចាស់ផ្ទះនោះជាមនុស្សជរាណាស់ហើយ ឃើញគួនអ៊ូចូលមកក៏សាកសួរថា: អ្នកឈ្មោះអ្វី? ទៅណាមកណាមានការអ្វី? គួនអ៊ូប្រាប់ថា: ខ្ញុំឈ្មោះគួនអ៊ូ មកតាមរកឡៅពី ។ គួនតេងថា: លោកនឹងខ្ញុំជាសែតភូលជាមួយគ្នា កាលពីដើមខ្ញុំក៏បានឮថា លោកមានថ្លីដៃខ្លាំងពូកែ ព្រមទាំងមានសេចក្តីស័ត្យតត្បូលណាស់ ឥលូវនេះខ្ញុំ

ចានដួបកំដាបុណ្យកំព្រាបស់ខ្ញុំ" ហើយហៅគួនហ្វង់ធីងគួនប៉ែងជាកូនឲ្យ
ចេញមកគំនាប់គួនអ៊ូ ហើយចាត់ចែងទីដំណេកឲ្យគួនអ៊ូនៅអាស្រ័យ ។

ឯស៊ុនខៀនកាលចូលទៅដួបធីងឡៅពី កំពុងនិទានសេចក្តីដែល
ប្រទះធីងគួនអ៊ូ ខៀវហ៊ុយ ធីងក៏យោឡៅពីទាំង ២ ឲ្យឡៅពីស្តាប់គ្រប់
ប្រការ ។ ឡៅពីបានស្តាប់ដូច្នោះក៏សោមនស្សត្រេកអរណាស់ ទើប
ថ្លាប់ថា: ឥឡូវកាន់យ៉ុងមកនៅក្នុងស្រុកនេះហើយ តែធ្វើជាមិនស្គាល់
យើង។ គិតធីងប្រែមនុស្សស្និទ្ធស្នាលឲ្យលបទៅហៅមកធីងគិតការធីង
គ្នា ។ លុះដល់ពេលយប់ទួលកាន់យ៉ុងលបមកកេឡៅពី។ អញ្ជើញឲ្យ
អង្គុយ ហើយនិយាយថ្លាប់ថា ស៊ុនខៀនតាមមកកេយើង។គិតថាធីង
ឲ្យមនុស្សលបទៅហៅអ្នកធីងបានប្រឹក្សាការគ្នា ដើម្បីធីងរកឧបាសចេញ
ឲ្យរួចពីអ៊ូនសៀវហើយធីងបានគិតការតទៅ ។ កាន់យ៉ុងធ្វើយតបថា:
លោកគិតនេះគួរណាស់ ដល់ព្រឹកស្អែកលោកចូរទៅនិយាយធីងអ៊ូន-
សៀវថា: ធីងសូមអាសាចេញទៅបញ្ចុះបញ្ចូលឡោប៉ែវពៅហ្វាយ
ស្រុកកេងដីវ ។ ឡៅពីថា បើដូច្នោះអ្នកចូលទៅជាមួយធីងយើងបានឬ
ទេ? កាន់យ៉ុងធ្វើយថា: ឯចិត្តខ្ញុំបានខ្នះចង់ទៅជាមួយធីងលោក បើ
អ៊ូនសៀវធីងខឹងធីងាស់ដូចម្តេច ខ្ញុំបានធីងគិតដោះសារកេសេចក្តី
និយាយឲ្យបាន ។ ឡៅពីយល់ឃើញត្រូវ ឯកាន់យ៉ុងក៏លាឡៅពី
ត្រឡប់ទៅទីលំនៅវិញ ។

លុះពេលព្រឹកឡើង ឡៅពីក៏ចូលទៅនិយាយធីងអ៊ូនសៀវថា
ស្រុកកេងដីវដែលឡោប៉ែវនៅឈរកក្បាមកនៅះ សឹ្បងអាហារស្រូវ

អង្គរកំបរបូណ៌ ហើយមានអាណាខែត្រឡើងដល់ទៅ ៩ មណ្ឌល ខ្ញុំបាទ
នឹងសូមទៅនិយាយបញ្ចុះបញ្ចូលឡាប៉ៀរ ឲ្យមកចំណុះធ្វើការជាមួយនឹង
លោកនឹងបានរៃគិតការកំចាត់ចូរួចទេញ ។ អ្នកនៅវ៉ែនឡើយថា អ្នកគិតនេះ
ត្រូវចិត្តយើងណាស់ តែយើងបានទៅនិយាយបញ្ចុះបញ្ចូលជាច្រើនលើក
មកហើយ តែឡាប៉ៀរមិនព្រម ។ ឡាតីថា ឯឡាប៉ៀរមានសេតកូល
ជាមួយនឹងខ្ញុំបាទ បើខ្ញុំបាទទៅនិយាយបបួលមុខជាឡាប៉ៀរនឹងព្រមចុះ
ចូលមកវាកលោកជាប្រាកដ ។ អ្នកនៅវ៉ែនថា "ដែលអ្នកនឹងទៅនោះ
យើងគិតព្រមឲ្យអ្នកទៅ បើបញ្ចុះបញ្ចូលឡាប៉ៀរបានសមដូចសេចក្តី
ប្រាថ្នា គំលួងជាងបានឡាវែកមកតុក ១០ សួនទៅទៀត" ហើយថា
"យើងបានឮដំណឹងថា គួនអ៊ូបួនអ្នកដែលទៅយកអាសាចូរួច បានសម្លាប់
ធ័នលៀងប៊ុនធីវ៉ែនោះ ឥឡូវបានចេញពីចូរួមកវាកអ្នកវិញហើយ បើ
គួនអ៊ូមកដល់ យើងនឹងចាប់សម្លាប់ចេញទើបអស់កំហឹង ។

ឡាតីតបថា ពីដើមលោកបានឱយាយនឹងខ្ញុំថាចង់បានគួនអ៊ូមក
តុកជាកម្លាំង ខ្ញុំក៏បានផ្ញើសំបុត្រទៅគួនអ៊ូឲ្យមក ហេតុម្តេចលោកមាន
ប្រសាសន៍ដូច្នេះវិញ? អ្នកនៅវ៉ែថា ដែលគួនអ៊ូមកនោះ ខ្ញុំក៏មានចិត្ត
ត្រេកអរដែរ តែខ្ញុំនិយាយប៉ុណ្ណោះប្រយោជន៍ចង់ល្បងចិត្តលោកមើលទេ
តើអ្នកស្រឡាញ់គួនអ៊ូមែន ឬដូចម្តេច អ្នកបួរទៅប្រាប់គួនអ៊ូឲ្យចូលមកចុះ
យើងនឹងទទួលចិញ្ចឹមរក្សាដោយប្រក្រតី ។ ឡាតីក៏លាអ្នកនៅវ៉ែមក
ទីលំនៅវិញ ។

(មានត)

រឿងបល្ល័ង្កទិព្យ ភាគសំបតីរឿង

រឿងព្រេងឥណ្ឌៀ

លោកសមិន មួតូរ៉ែនជម: តែង

លោក រ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

ទិទានៃរូបទេពធីម្ដិត ទី ២៧

រូបទេពធីម្ដិតទី ២៧ ចានប្រែ។ ចាយលៃលក កុំឲ្យព្រះចាន់កោដ: ខ្ចីខ្ចើងគន់លើបល្ល័ង្កទិព្យចាន ដោយចានក្រាបបង្គំទូលព្រះអង្គថា: "បពិត្រព្រះចាន់កោដ:, បល្ល័ង្កទិព្យនេះ ជាព្រះពរជ័យនៃមហាពរវិក្រមាទិត្យ, ស្ដេចអង្គណាប្រកបដោយគុណធម៌ ដូចព្រះចាន់វិក្រមាទិត្យ ទើបអាចគន់លើបល្ល័ង្កទិព្យនេះចាន ដូច្នេះ សូមខ្ញុំចាំព្រះសណ្ដាប់អំពីព្រះពរគុណសម្បត្តិរបស់ព្រះចាន់វិក្រមាទិត្យ ដូចតទៅនេះ។

"មានកាលមួយថ្ងៃ, មហាពរវិក្រមាទិត្យ ខ្ញុំចានស្ដេចយាងកំសាន្តព្រះពរជ័ម្ពាទ័យតាមទំនៀមជនបទ ក្នុងព្រះពរអាណាចក្ររបស់ព្រះអង្គ។ នៅតាមផ្លូវនៃព្រះពរជំណើរ, មានអ្នកដំណើរម្នាក់ចានមកជួបខ្ញុំ ហើយក្រាបបង្គំទូលខ្ញុំថា "បពិត្រព្រះចមកព, នៅឫកាប្រទេសមានខតមួយ នាមថា វេតាលបុរ: (Vetalabura), នៅកន្លែងតវានោះមានឯកទេពធីតាមួយ ព្រះនាម សោភីតប្រិយា (conitapriyà), ក្នុងមួយថ្ងៃ។ គេចានយកបុរសម្នាក់ ទៅធ្វើទេវតាពលី ចំពោះនាង

ខេត្តធីតានៅបូជនីយដ្ឋាន, បើខ្ញុំស្តេចយាងទៅតាមផ្លូវនេះ ខ្ញុំនឹងស្តេចទៅដល់នគរនោះ, ពួកសេវាមាត្យនៃព្រះមហាក្សត្រិយ៍នៅប្រទេសនោះ នឹងចាប់ខ្ញុំយកទៅឃុំទាំង នៅពន្ធនាគារ ដោយមានបំណងនឹងយកខ្ញុំទៅបូជានាងទេពកញ្ញានោះឯង, តែបើខ្ញុំមានពលភាពរហ័សរហួនធ្លាក់ចុះ ដើម្បីឲ្យរួចពីកណ្តាប់ដៃនៃនាងទេពកញ្ញាបាន ទើបខ្ញុំស្រែចស្រែកឡើងព្រះជន្មខ្ញុំរួច" ។

មហាពលវិរកុមារិត្យខ្ញុំព្រះសណ្តាប់ឮវាក្យនោះ ខ្ញុំមានព្រះកដហ្ហឹយចង់ឃើញនាងទេពកញ្ញានោះពន់ពេក; ខ្ញុំក៏ស្តេចយាងទៅកាន់នគរភ្លាមឋុះ ។ កាលខ្ញុំស្តេចទៅដល់ ខ្ញុំបានព្រះកដមានខ្ញុំរុក្ខដល់ពួកសេវាមាត្យទៅទីនោះអំពីបទបញ្ញត្តិឲ្យាប់ថា "លោកទាំងឡាយ, យើងមានសេចក្តីងឿងឆ្ងល់ណាស់, តើលោកនាងដល់បញ្ញត្តិឲ្យាប់ណាបានជាលោកយកដីវិសត្តដ៏ខ្ពង់ខ្ពស់ មនុស្សជាតិមកធ្វើទេវតាពលីដូច្នេះ? តើលោកបានជ្រាបឬទេថាពិធីបូជានោះ នឹងនាំលោកឲ្យទៅសោយទុក្ខលំបាកក្នុងវដ្តសង្សារយ៉ាងយូរ? លោកប្រហែលមិនបានជ្រាបទេថា លោកជាអ្នកធ្វើអកុសល, ដោយពិធីបូជាបែបនេះនឹងនាំឲ្យលោកទៅសោយទុក្ខនៅស្ថាននរកអស់កាលយូរ? ចំណែកឯនាងទេវធីតានេះ, បើទុកជានាងបានធ្វើអំណោយដ៏ប្រសើរយ៉ាងណាឲ្យដល់លោក ដើម្បីនឹងតបស្នងចំពោះការណីយកិច្ច ដែលលោកបានប្រតិបត្តិតាមបទបញ្ញត្តិព្រះទាង, ក៏នាងគង់តែសោយទុក្ខវេទនាតាមកម្មនោះមិនខាន" ។

ក្រោយដែលព្រះអង្គទ្រង់បញ្ចប់នូវព្រះពុទ្ធសុន្ទរកថាទ ដើម្បីនឹងញុំាងពួកសេវកាមាត្យឲ្យលះបង់នូវអំពើដ៏លាមកនោះ, ទ្រង់ក៏ស្តេចយាងទៅកាន់ប្លង់ជនីយដ្ឋាន ទ្រង់ឃាតទៅឃើញនូវព្រាហ្មណ៍មួយនាក់ ។ ព្រាហ្មណ៍នេះក្រោយដែលបានផ្លូតទឹកនូវមនុស្សម្នាក់ រួចតុបតែងកាយ ដោយឲ្យស្លៀកពាក់ខោអាវពណ៌ក្រហម, ឲ្យពាក់ស្បែកជើងផ្ទាត់ក្រហម. បំពាក់កងបុប្ផាក្រហមហើយ, ក៏បានដាំមនុស្សនោះ យកទៅធ្វើទេវតាពលី ។ មហាជនដែលមានចិត្តទ្រង់បានឃាតឃើញស្ថានភាពបែបនេះ, ទ្រង់ក៏មានព្រះបន្ទូលថា: "នែអ្នកជាពួកមនុស្សពាលសាមាន្យ, ជាមនុស្សទុច្ចរិត, ចូរអ្នកលែងមនុស្សនោះទៅ ព្រោះគេមានចិត្តភ័យតក់ស្លុតនឹងសេចក្តីស្លាប់ជួចអ្នកឯងដែរ, បើអ្នកត្រូវការមនុស្សយកទៅបូជាយ័ញ្ញាដោយខានមិនបាន, យើងសូមឲ្យអ្នកយករូបយើងជំនួសវិញចុះ យើងមិនត្រូវឲ្យអ្នកយកមនុស្សដែលភ័យតក់ស្លុតនឹងសេចក្តីស្លាប់ ទៅធ្វើពលិកម្ម ដើម្បីចុះនរកខ្លួនឯងដូច្នេះទេ ។

ពួកសេវកាមាត្យកាលបានឮព្រះសូរសៀងមហាជនហើយ, ក៏មានសេចក្តីឆ្ងល់ខើបក្រាបបង្គំទូលថា: "បពិត្រព្រះមហាករុណាធិគុណ, ព្រះអង្គទ្រង់មានព្រះពុទ្ធហឫទ័យស្មោះស្ម័គ្រ ចំពោះព្រះពុទ្ធការណ៍យកចិត្តហួសប្រមាណ; គេមិនដែលឃើញមនុស្សណាដូចជាព្រះអង្គដែលហ៊ានយកជីវិតខ្លួនស្រោចស្រង់ជីវិតសត្វ ដែលមិនជាប់សាច់សាហិតសោះ ទ្រង់លះបង់ព្រះពុទ្ធជីវភាពរបស់ទ្រង់ ពុកស្មើនឹងតណ្ហាផាត; បើគេហង្ខានត្រូវក្ងេវក្ងាងនេះ, សេដ្ឋីមានភោគទ្រព្យច្រើនក្តី ការិយាដែលមាន

ចិត្តកក្តីនឹងស្វាមីក្តី បណ្ដិតក្តី មនុស្សដែលប្រកបដោយកណ្ដាយកំប្លុ
ដ៏ប្រសើរក្តី មិនដែលចោះបង់ចោលបុត្រាបុត្រី ទឹងវត្ថុដែលជាទី
ស្រឡាញ់ពេញចិត្ត ក្នុងពេលក្តៅនេះផ្លុះសោះឡើយ បុគ្គលទាំងនេះ
តែងកៀសខ្លួនរត់ចេញ ដើម្បីស្រោចស្រង់ជីវិតរបស់ខ្លួន ព្រមទាំង
ជញ្ជូននាំចេញនូវបរស់មានឰម្មសារដែលមានក្នុងផ្ទះនោះ; ដើម្បីទ្រង់
ជួយគាំពារដីវិតមនុស្ស ដែលទ្រង់មិនធ្លាប់ស្គាល់នូវស្រុកកំណើត, នូវ
ចំនៀមទម្លាប់ប្រពៃណី, នូវគ្រួសារ, ព្រះអង្គទ្រង់ផ្តន់ទុកស្រេចទឹងបូជា
ព្រះជន្មរបស់ទ្រង់ដោយមិនមានស្តាយ, កម្រណាស់ទឹងឃើញមនុស្ស
មានចរិយាដូចទ្រង់ ដែលអាចជួយអ្នកដទៃបានដូច្នេះ” ។

ពួកសេវកាមាត្យ លុះក្រាបបង្គំទូលព្រះបាទកជវិកមាទិត្យហើយ
ក៏នាំគ្នាទៅបានកាត់ចំណាងអំពីមនុស្ស ដែលបម្រើងទឹងយកទៅធ្វើទេវតា.
ពលីនោះ ហើយក៏ថ្វាយទៅព្រះអង្គ ។ ព្រះពាជាទ្រង់មានព្រះពាជហ្ឫទ័យ
ផ្តន់ទុកជាស្រេចចំពោះការណ៍យកប្លុដែលទឹងត្រូវបំពេញនោះ, ទ្រង់ក៏
ហូតព្រះខ័នថ្វា ។ ដើម្បីទឹងផ្តាច់ព្រះជន្មកន្លងពេលនោះ, នាងទេវធីតាមាន
ព្រះទ័យសោមនស្សពន់ពេក ក្រាបបង្គំទូលថា: “បពិត្រព្រះសម្មតិទេព,
នាងខ្ញុំមានចិត្តត្រេកអរណាស់, សូមព្រះអង្គទ្រង់មានព្រះបន្ទូលមកចុះ
តើទ្រង់មានព្រះពាជបំណងអ្វី ខ្ញុំម្ចាស់ទឹងបំពេញតាមព្រះពាជហ្ឫទ័យ” ។

មហាពាជវិកមាទិត្យទ្រង់មានព្រះបន្ទូលថា “ឧព្រះនាង, បើព្រះ
នាងសព្វព្រះទ័យទឹងយើង សូមព្រះនាងទទួលយល់ព្រមឲ្យនូវពរដែល
យើងទឹងសុំក្នុងពេលឥឡូវនេះ គឺ ១— សូមបំពេញនូវបំណងនៃពួក

សេវាគាមាត្យដែលមកកាន់ទីនេះ ដើម្បីធ្វើទេវតាពលី; ២ - តាំងពីថ្ងៃនេះតទៅ កុំឲ្យព្រះនាងទទួលមនុស្សដែលគេយកមកធ្វើទេវតាពលី" ។ យើងសូមពរពីព្រះនាងតែពីរប្រការនេះ" ។

ទេវធីតាក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យថា: "ខ្ញុំម្ចាស់យល់ព្រមថ្វាយពរតាំងពីរប្រការចំពោះព្រះអង្គ, សូមទ្រង់មេត្តាទទួលនូវពរនេះចុះ" ។ តាំងពីថ្ងៃនោះមក គឥតមានអ្នកណាយកមនុស្សមកធ្វើទេវតាពលីចំពោះទេវធីតានៅទីនេះទៀតឡើយ" ។

ព្រះបាទកោដៈទ្រង់បានព្រះសណ្តាប់នូវនិទានៃរូបទេពនិម្មិតទី ២៧ ហើយ ក៏ចោះបង់នូវព្រះពរជំណាងចង់ធ្វើមុត្តកិសេកក្នុងថ្ងៃនោះទៅ ។

* * *

និទានៃរូបទេពនិម្មិតទី ២៨

ដើម្បីទីឃាត់ខាំងកុំឲ្យព្រះបាទកោដៈធ្វើពជាកិសេក, រូបទេពនិម្មិតទី ២៨ ក៏បានថ្លែងរឿងមួយរៀបរាប់អំពីព្រះពរគុណសម្បត្តិ នៃមហាពជវិក្រមាទិត្យ ដូចតទៅនេះ ៖

"បពិត្រព្រះបាទកោដៈ, សូមទ្រង់ព្រះសណ្តាប់! មានកាលថ្ងៃមួយ មានបណ្ឌិតមួយនាក់ជាអ្នកដំនាញខាងសាស្ត្រកំនត់កាតរបស់មនុស្សបានធ្វើដំណើរទៅតាមផ្លូវ, កាលអស់កម្លាំងក៏ឈប់សម្រាកឲ្យបានល់ឈើ ១ ដើម ដ៏តក្កោងក្បាលចូលទៅព្រៃនគរ ។ បណ្ឌិតនេះ កាលបានពិនិត្យនូវកំនត់កាតប្តូលក្ខណៈនៃរូបបុរសស្ត្រីហើយ ក៏បានស្គាល់ទៅតាម

រឿងដ៏ជ្រាលជ្រៅដែលខ្ញុំបានរៀនមកថា អ្នកនេះនឹងបានជួបនូវលាភដ៏ប្រសើរ ឬ បានឮនូវសេចក្តីខុកខ្លែងជាក ។ កន្លងពេលនោះ, បណ្ឌិតបានក្រឡេកទៅឃើញស្នាមជើង នៃទត្តមហាបុរសម្នាក់ជាប់នៅនឹងដីមានសភាពដូចផ្កាឈូកហើយក៏គិតថា ស្នាមជើងដែលប្រកបដោយរូបបុប្ផជាតុមនេះ ប្រាកដជាស្នាមជើងនៃស្តេចចក្រពត្តិ រឿងការពាំងនេះមិនជាប់រឹងច្បិចយ៉ាងនេះ ! តែគួរឲ្យឆ្ងល់បើបុរសនោះជាស្តេចចក្រពត្តិជាតិជាមនុស្សម្តេចក៏អញ្ជើញមកកាន់ក្តារនេះដោយជើងទទេដូច្នេះ ? សេចក្តីសង្ស័យនេះធ្វើឲ្យក្មេងក្តីចិត្តបណ្ឌិតនេះពន់ពេក ។

កន្លងមួយរំពេចនោះ, ស្រាប់តែមានបុរសខ្មៅតម្កាក់ខ្លួនទុសដើរមកកាន់ទីនោះ ។ បណ្ឌិតនោះបានពិនិត្យស្នាមជើងទាំងពីរនៃបុរសខ្មៅតនេះ ធៀបនឹងស្នាមជើងដែលឃើញពីមុន ឃើញមានសណ្ឋានដូចគ្នាហើយក៏គិតថា ‘ ស្នាមជើងដែលអញឃើញពីពេលមុន ប្រាកដជាស្នាមជើងនៃបុរសកំសត់នេះឯង; តែគួរឲ្យឆ្ងល់ ម្តេចក៏ស្នាមជើងដែលមានសភាពថ្លៃបវរនេះ ជាស្នាមជើងបុរសខ្មៅតទៅវិញ ? បញ្ហានេះធ្វើឲ្យបណ្ឌិតនោះមានកង្វល់ចិត្តកាន់តែជាខ្លាំង ។

កន្លងពេលនោះ, មហាពលរដ្ឋក្រមាទិត្យក្នុងស្រុកយាងមកដល់ក្នុងស្រុកបូលទៅជិតបណ្ឌិតនោះ ហើយមានព្រះបន្ទូលសួរថា: “នែព្រាហ្មណ៍ អ្នកឯងជាអ្វី ? ហេតុម្តេចក៏អ្នកមកអង្គុយនៅទីនេះ ?” ។ បណ្ឌិតក៏ក្រាបបង្គំទូលថា: “ទូលព្រះបង្គំជាបណ្ឌិតមួយដែលបេះពាយលក្ខណៈរូបមនុស្ស; ទូលព្រះបង្គំបានធ្វើដំណើរមកពីឆ្ងាយអស់កំឡាំង

ពេកទើបសម្រាកនៅទីនេះ; ខ្ញុំលោកព្រះបង្គំកំពុងឃើញបុរសម្នាក់ក្រីក្រតែជាតជើងមានរូបជាបុជ្ជាបខុម; ខ្ញុំលោកព្រះបង្គំកំពុងពិនិត្យនូវសភាពមួកអស្ចារ្យនេះ ដែលមានន័យផ្សេងទៀតសាស្ត្រ: ។

ក្រោយដែលទ្រង់ព្រះសណ្តាប់នូវពាក្យនៃបណ្ឌិត, មហាជនទ្រង់មិនមានព្រះបន្ទូលតបវិញឡើយ ទ្រង់ស្តេចយាងវិលត្រឡប់ចូលព្រះរាជនិវេសនដ្ឋានវិញ, ហើយទ្រង់ត្រាស់បង្គាប់ឲ្យបែមូលពួកបណ្ឌិត ។ កាលណាក្រុមប្រឹក្សាបានប្រជុំរួចស្រេច ទ្រង់បានចាត់អមាត្យម្នាក់ឲ្យទៅហៅបណ្ឌិតនោះមក, ហើយទ្រង់មានព្រះបន្ទូលសួរថា: "បណ្ឌិត! មនុស្សពុតត ដែលលោកបានឃើញស្នាមជើងមានរូបគំនូរជាបុជ្ជាបខុម, តើអ្នកនោះជាអ្វី? ។ បណ្ឌិតក្រាបបង្គំទូលថា: "មនុស្សដែលខ្ញុំលោកសហើយចូលមកកាន់រាជធានីនេះ គឺមនុស្សពុតនោះឯង, ប្រហែលជាកាន់ពេលនេះ មនុស្សនោះនៅកាន់តែនេះនៅឡើយទេ" ។ មហាជនទ្រង់មានព្រះបន្ទូលសួរទៀតថា: "មនុស្សនោះឈ្មោះអ្វី?" ។ បណ្ឌិតក្រាបបង្គំទូលថា: "ខ្ញុំលោកព្រះបង្គំមិនស្គាល់ឈ្មោះទេ សូមទ្រង់ជ្រាប, តែមនុស្សនោះមានទឹកមុខ នឹងលក្ខណៈរូបរៃបនេះ" ។

ព្រះរាជាលុះទ្រង់ព្រះសណ្តាប់នូវពាក្យរបស់បណ្ឌិតហើយ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យស្វែងរកបុរសពុតត, កាលពួកបុរសរកឃើញហើយក៏នាំមកថ្វាយព្រះអង្គ ។ ព្រះរាជាទ្រង់បានពិនិត្យបុរសពុតតឃើញច្បាស់ជាមនុស្សមានលក្ខណៈដូចបណ្ឌិតនោះថាមែន, ហើយទ្រង់មានព្រះបន្ទូលថា: "បណ្ឌិត, ក្រៅពីការពិនិត្យប្រៀបធៀបនូវកំនត់ទៀងចាត់ទុក

កំនត់ពិសេស យើងមិនអាចរកយើញឲ្យជាក់ច្បាស់ ចំពោះន័យរបស់សាស្ត្រៈសោះឡើយ ដូច្នេះចូរលោករកន័យរបស់សាស្ត្រៈដោយយកកំនផ្សេង ។ មកពិនិត្យហើយប្រមូលកំនគាត់ងអស់ធៀបគ្នា រួចសឹមឲ្យយោបល់តាមកំនោះ, ប្រហែលជាបុគ្គលនេះមានកំនអ្វី មិនសមរម្យដែលមានអានុភាពអាចហាមឃាត់មិនឲ្យកំនដ៏សោភ័ណនោះ បរាញ្ញូវផលល្អបានទេដឹង" ។

កាលព្រះមហាកដ្ឋែងមានត្រះបន្ទូលដូច្នេះ, បណ្ឌិតក៏បានសែងកន័យរបស់សាស្ត្រៈ ហើយក្រាបបង្គំទូលថា "បពិត្រព្រះបវរកំព្រាជ-កដ, បើបុគ្គលណាមានរូបគំនូរប្លុកបុរសមុខទៅបានដើង បុគ្គលនោះមុខជាមានហានន្តរៈ ជាព្រះមហាក្សត្រិយ៍ពិតប្រាកដ នេះជាវិធានការណ៍ខ្លះ, តែបើទៅតស់អណ្តាតនៃបុគ្គលនោះមានរូបគំនូរដើងក្អែក(១) ផង បុគ្គលនោះនឹងត្រឡប់ទៅជាបុរសទុគ្គិតវិញបាន; នេះជាន័យប្លែកពីធម្មតា" ។

មហាកដ្ឋែងព្រះសណ្តាប់នូវបណ្ឌិតពណិនាខាងលើនេះ ហើយដែងកំបានពិនិត្យមនុស្សទុគ្គិតនោះ ឃើញមានរូបគំនូរកាកបានទៅតស់អណ្តាតដែលជាគ្រឿងសំគាល់នូវធម្មជាតិពិតមែន ទើបដែងមានព្រះបន្ទូលទៅកាន់បណ្ឌិតថា: "បណ្ឌិត យើងដឹងថាលោកជាអ្នកប្រាជ្ញមានចំណេះចេះដឹងខាងន័យសាស្ត្រៈកំនពិតប្រាកដមែន; ល្អហើយ! ហេតុនេះចូរលោកប្រាប់មកយើងថា យើងមានកំនជាមហាក្សត្រិយ៍នៅត្រង់ណាខ្លះ?" ។ បណ្ឌិតបានពិនិត្យព្រះលក្ខណៈព្រះរូបនៃមហាកដ

---

១ ន័យសម្គាល់មានស្នាមច្រង់ច្រាយ ដូចជាឈើឆ្កាងហៅថា:ពាកបាទ ។

សព្វគ្រប់ប្រការ ក៏ក្រាបបង្គំទូលថា "បពិត្រព្រះច្រៀយមហាក្សត្រិយ៍ ខ្ញុំព្រះបង្គំមិនបានឃើញនូវព្រះរូបព្រះអង្គ មានកំនត់សម្គាល់ជាមហាក្សត្រិយ៍នោះសោះឡើយ" ។ មហាកដក៏មានព្រះបន្ទូលថា: "បណ្ឌិតចូរអ្នកពិនិត្យមើលជាថ្នាមន័យសាស្ត្រ: ក្រែងលោមានកំនត់ប្លែកពីធម្មតា" ។

បណ្ឌិតក៏ក្រាបបង្គំទូលថា: "បពិត្រមហាកដ, បើបុរសណាគ្មានកំនដ៏សោភាឬមានកំនដ៏ណាមក តែនៅឆ្អឹងជំនីរឆ្អែងមានរូបគំនូរ "សំណាញ់មន្ត្រសុវ័ណ្ណ" (Réseau du Mantra d'or); កំនប្លែកពីធម្មតានេះ អាចធ្វើឲ្យសភាពដែលគ្មានសុភកំន ឬ មានកំនដ៏ណាមកស្ថិតនៅលើរូបបុរសនោះឲ្យទៅជាមោយ:ចាន, ហើយផលនៃកំនប្រែបដោយសេចក្តីអនុគ្រោះដ៏ប្រសើរ អាចនឹងបញ្ជូញរូបភាន់ឲ្យបើញពិតចាន, ខ្ញុំព្រះបង្គំយល់ថា នៅក្នុងព្រះរូបព្រះអង្គ មុនជាមានរូបគំនូរ សំណាញ់មន្ត្រសុវ័ណ្ណ មិនខាន" ។

មហាកដទ្រង់ព្រះសណ្តាប់នូវពាក្យបណ្ឌិតនោះហើយ, ដើម្បីនឹងបញ្ជូញឲ្យឃើញច្បាស់លាស់នូវន័យសាស្ត្រ:នោះ ក៏ទ្រង់លើកព្រះហស្តចាប់នៅគាំបិតកោរមួយ ដើម្បីនឹងអារស្បែកឆ្អឹងជំនីរព្រះអង្គខាងឆ្អែង ។ តែបណ្ឌិតនោះស្ទុះទៅចាប់ព្រះហស្តមហាកដជាប់ ហើយក្រាបបង្គំទូលថា: "បពិត្រព្រះសម្មតិទេព, សូមទ្រង់ព្រះមេត្តាប្រោស, សូមព្រះអង្គកុំច្រញាប់ពេក ព្រោះថាវត្ថុនេះមានសភាពបិតនៅពីលើអាយតន: ឬ ហួសនិស្ស័យមនុស្សមិនអាចដឹងជាល់, ហើយសភាពដែលមានដូច្នេះ ទឹង

អាចឃើញបានចំពោះតែផល ដែលបានអំណាយផាយាំងជាក់ស្តែងពី
អតីតជាតិ, ប្រៀបដូចជាព្រះឥសូរដែលជាដីរសត្វតែមួយប្រកបដោយ
ទិព្វចក្ខុបានបញ្ចេញអានុភាព ឲ្យឃើញរូបខ្ញុំគ្រាយកន្លងវដ្តសង្សារជាក់
ស្តែងដោយសំដែងខ្ញុំនូវធម្មទេសនាដែលជាវិសេសលោកិយ (ឥទ្ធិវិធី), ផល
របស់សុភកិនរបស់ព្រះអង្គ កំនឹងបញ្ចេញសណ្ឋានខ្ញុំគ្រាយឲ្យឃើញ
បាន តាមលំនាំខាងលើ, ទាំងនេះបញ្ជាក់ឲ្យឃើញថា នៅលើផ្នឹង
ជំនីរព្រះអង្គខាងក្រោមមុខជាមានរូបតំណូរ សំណាញ់មន្តស្ទុះណ្តា ដោយ
ពិត; ព្រះអង្គខ្ញុំមិនចាំបាច់ក់ស់ព្រះមំសៈទៀយ" ។ ក្រោយដែល
បណ្ឌិតបានថ្លែង, ព្រះមហាក្សត្រិយ៍ខ្ញុំជាបន្ទូរចំណងបណ្ឌិត, ខ្ញុំ
ក៏បានធ្វើព្រះពរអំណាយនូវតេនវត្ត នឹងគោគឲ្យជារឿនដល់បណ្ឌិត
នោះ រួចក៏ឲ្យបណ្ឌិតចេញពីព្រះបរមរាជវាំង" ។

រូបទេពនិម្មិតទី ២៨ ទូលបន្ថែមថា "បពិត្រព្រះមហាក្សត្រិយ៍
គោជៈ, បើខ្ញុំប្រកបដោយព្រះថាមភាពបែបនេះ, ខ្ញុំអាចនឹងគង់លើ
បល្ល័ង្កទិព្យនេះបាន" ។

ព្រះបាទគោជៈ ខ្ញុំព្រះសណ្តាប់នូវពាក្យនៃរូបទេពនិម្មិតទី ២៨
ហើយក៏ឈប់ទានធ្វើមុខភាគិសេកកន្លងពេលនោះ ។

*
* *

(មានត)

រឿងព្រះចាតុបរន្តបៈ

ព្រះមហា ឌឿក - អ៊ម៉ែរ រៀបរៀង

លោក ចាប - ពិន កែសម្រួល

បទភ្ជុំដង្គ

កាលនោះមានព្រះរាជា មួយអង្គនាមា បរន្តបៈក្សត្រ ។
ព្រះអង្គគ្រប់គ្រងរាស្ត្រជន មាននាមថ្កុតជ ក្រុងកោសម្ពី ។
ថ្ងៃមួយស្តេចនាំទេវី មានគតិចេញពី បន្ទូលទៅក្រៅ ។
ដើម្បីគង់អាងកំដៅ សុរិយាស្ទើរក្តៅ ទឹងស្ទើរត្រជាក់ ។
ថ្ងៃឆ័ពីទេពីរលេក្សណ៍ នាងទ្រង់ស្ទុកតាក់ ក្រហមឆើតឆាយ ។
ចរចាសើបលេងក្អាកក្តាយ ជាសុខសប្បាយ ទឹងព្រះកស្តា ។
ព្រះនាងគាប់ព្រះទ័យ ដោយត្រឹងសោភា យ៉ាងមានសម្រស់ ។
ឋានយកចិញ្ចៀនពេជ្រស្រស់ មកពាក់ព្រះហស្ត នៃអង្គក្សត្រី ។
កាលនោះមានសត្វហត្ថី - លិង្គៈបក្សី ហោះលើមេឃា ។
សត្វនោះឃើញព្រះជាយា សំគាល់ថាជា ដុំសាច់ពិតហើយ ។
យល់ច្នោះក៏មិនកន្តើយ សំឡុបស្ទាបហើយ ឆាបចុះមកខ្ទី ។
មហាក្សត្រយល់សត្វបក្សី ហោះចុះមកដី ភ័យរត់ចូលក្នុង ។
ទេវីនាងមានគោះពុង ពុំអាចចូលក្នុង តាមមហាក្សត្រឋាន ។
ត្រវកលសត្វឆាបឆក់ឆ្ពាណ នាំហោះទៅឋាន លើអាកាសា ។
ព្រះនាងកិតភ័យតក្កមា ខ្លាចក្រែងមរណា ចោលព្រះស្វាមី ។

ទើបគិតតាមបញ្ញាស្រី ថាអញស្រែកខ្លី ឬក៏យ៉ាងណា ។
ប្រសិនអញស្រែកភ្លាម៉ា មុខជាឮកូន លែងអញដោយគិត ។
មុខជាអញក្រែងជីវិត នៅពេលនេះពិត ខានឃើញមុខប្តី ។
ល្អើយចុះកុំអាលស្រែកអី ចាំមើលឮកូន រកឈើទំបាន ។
ហើយក៏ចុំរង៉ឹងចិត្តថា ចាំអញស្រែកភ្លាន ក្នុងនឹងហើរទៅ ។
ព្រះនាងអានថ្ងៃថ្ងាស្រៀ នេះចំជាផៅ ពួជពង្សបណ្ឌិត ។
ពេលនោះសត្វហើរមិនជិត គាត់មេឃឆ្ងីត ទៅរៃហេមពាន្ត ។
នាំនាងទៅទាំងស្រែកឃ្នាន ដល់លំនៅឋាន ដើមរៃធ្លុំមួយ ។
ព្រះនាងតែតែកន្ត្រក់ព្រួយ ព្រោះគ្មានគេជួយ ដោះទុក្ខអាត្មា ។
ក្បត្តិគិតក្នុងចិត្តា អញធ្វើយ៉ាងណា ឲ្យសត្វផ្តើលបាន ។
ទើបស្រែកខ្ទាំងពន់ប្រមាណ បក្សាផ្តើលថ្លាណ ស្ទុះហើរចោលស្រែ ។
គ្រានោះជាពេលភត្តិ ព្រះគភិទេវី កើតកម្មដូចឥត ។
ថែមមានក្មេងតាំងអធ្រាត្រ ទទឹកនាងនាថ សព្វសាពាំង្គកាយ ។
នាងនាថអត់ទឹកអត់ប៉ាយ កើតក្តៅក្រហាយ ទល់រុក្ខពុំស្បើយ ។
លុះដល់ភ្លឺស្វាងច្បាស់ហើយ ពុំលង់យូរឡើយ នាងប្រសូតបុត្រ ។
ក្បត្តិត្រែកអរបំផុត ទើបដាក់នាមបុត្រ "ទុខេន" កុមារ ។

បទពាក្យ ៧

ទៅកន្លែរដើមរៃក្នុងព្រៃធ្លាយ ដែលនាងជាម្តាយដែកនោះណា
មានឥសីមួយនៃលោកតា នាមថា "អលុកប្ប" ឥសីសិទ្ធិ ។
ព្រឹកនោះតាបសមិនទៅព្រៃ ចូលមកដើមរៃដែលទៅដិត

ដោយលោកប៉ុនប៉ងកូនគំនិត រិះគិតរើសឆ្នឹងសត្វស្មោរធាន់(១) ។
តាបសរើសឆ្នឹងពុំបានរួច ឮសូរគ្រលួចញាប់រន្ធាន់
តាបសឈរស្តាប់ដោយកាំងកន្ត ជ្រាបថាន់ថាប្លាស់ជាក្មេងយំ ។
ទើបលោកងើយមើលដោយស្មោះស្មាន ផ្លែងថ្លាណាបើកក្អែកយ៉ាងធំ ។
ងាកឡើងងាកចុះឃើញក្មេងយំ មានតាំងមនុស្សធំបីវាផង ។
តាបសសែសកសួរពីគ្រាមថា យើ ! នរណាមកនេះម្តង
ទេវតា ឬមនុស្ស ថ្លាប់ខ្ញុំផង តើមានបំណងមករកអ្វី ? ។
ទេវីតបថា ទុតានថ្លាស ! នាងខ្ញុំជាមនុស្ស ហើយកេទស៊ី
ត្រូវសត្វចាប់មកមួយភាគ្រី រួចកើតកូនខ្ចីនៅទីហ្នឹង ។
ទេវីរៀបរាប់រឿងតាំងអស់ ទូលព្រះតាបសឲ្យបានដឹង
តាបសថ្លាប់ថាបើអីចឹង សូមនាងទំប្រឹងចុះមកថ្លាន ។
ព្រះនាងទេវីស្រែដឹថា នុណាលោកតាខ្ញុំសូមាន
ឲ្យខ្ញុំចុះទៅជាមិនបាន តាំតថ្លាណានាងខ្ញុំជាតិក្សត្រី ។
តាបសឆ្លើយតបយ៉ាងច្បាស់ ថាយើចាំថ្លាប់គេធ្វើអី
តាំតតែខ្លួនឯងជាតិក្សត្រី មិនបង់ចុះដំណាងណា ។
ព្រះនាងឆ្លើងស្តាប់ពាក្យតាហើយ មិនទៅកន្តើយតបទៀតថា
ព្រោះខ្ញុំជាជាតិក្សត្រថ្លាថា ឯជាតិលោកតាក្តែអន់អាប់ ។
តាបសថា យើ ក្សត្រី ចាំស្តាប់ឥសីស្រែដីថ្លាប់

---

១ នៅក្រោមដើមត្រៃគោះមានឆ្អឹងសត្វផ្សេង ។ ផែលសត្វហត្ថិលិង្គស៊ីតែសាច់ ហើយទម្លាក់ឆ្អឹងចោលមកក្រោម ។

កុំអាលចេញមកលេងបង្អាប់ តាស្ទាប់ទៅចុះតាស្តេចដែរ ។
កាលដើមសោយពាជ្យគ្រងរាជ្ជា គ្រោយមកខើបតាតិតគូរបែរ
លះពាជសម្បត្តិមិនគួរញែរ តាបែរមកបួសទល់សព្វថ្ងៃ ។
ក្សត្រវេលក្សណ៍ធ្វងធ្វើយថា បើពិតជាតាជាតិក្សត្រថ្ងៃ
អរគុណលោកតាពន់ពេកក្រៃ សូមផ្ទៃមាយាស្តេចមើលល ។
តាបសសំដែងឲ្យនាងជ្រាប តាមភាពជាតិក្សត្រដែលមានមក
តាំងខ្លួនលោកសោតក៏ជាប់ល ពាវក៏គ្រាតែនាងជឿជាក់ ។
ខើបធ្វើយមកថាលោកតាអើយ ! នាងខ្ញុំជឿហើយឈប់ផ្តើលក្បាក់
ដូច្នេះនាងខ្ញុំសូមពឹងពាក់ សូមជាក់កូនខ្លីទៅដីផង ។
ឮថ្លោះតាបសមិនគ្នាន់ក្នាញ់ ក៏បាននស្រឡាញ់ដូចបង្កួនបង
តាំងមានមេត្តាចង់ចម្រូង ស្រោចស្រង់សត្វផងពីទុក្ខា ។
ខើបដើរតេះតេះទៅដើមឈើ គោនឹងឡើងទៅលើដោយទុស្សាហ៍
អ៊ុះអ៊ះ ! អិះអុះ ! សំឡេងតា ខោះហត់យ៉ាងណាឡើងបាល់បាន ។
ដល់ហើយឥសីស្រែកដីថ្កាប់ នែនាងកុំចាប់ឬពាល់ថ្ងាណា
តួរីតនាងជាស្រីស្រស់កល្យាណ ប៉ះតាមិនបានដាច់ឈានហើយ ។
ត្រូវនាងប្រឹងចុះដោយខ្លួនឯង កុំបីកោតក្រែងឲ្យសោះឡើយ
ទុកតែកូនតូចឲ្យតាហើយ នាងអើយចុះទៅឲ្យឆាប់ក៏ ។
នាកាលព្រះនាងចុះដល់ដី ខើបតាឥសីនាំយាត្រា
តម្រង់ឆ្ពោះទៅឯសាលា ឲ្យនៅសុខាមិនមានហ្មង ។
មិនតែប៉ុណ្ណោះលោកប្រឹងប្រែង ស្វែងរកខ្លួនឯងអាហារផង

ឲ្យនាងបរិភោគដូចបំណង កប់រង់ចាំញ៉ែមមិនឲ្យព្រួយ ។
ចំណែករូបលោកនៅកាន់សីល ល្អស្រស់ដូចដើមមិនរាយ្លួយ
ចំពោះកាមទឹងស្រីមួយ តាព្រួយតែនាងមិនសប្បាយ ។
ថ្ងៃឯពីព្រះនាងស្រស់គោមភ្លៅ ទិត្យនៅទឹងតាយូរខែថ្ងាយ
នាងរិះក្នុងចិត្តគិតវែងឆ្ងាយ ប្រែក្លាយខុសចាកបំណងតា ។
ព្រះនាងយល់ឃើញហេតុសព្វគ្រប់ តាំងថ្ងៃតាំងយប់ដូច្នេះថា
ប្រសិនថ្ងៃក្រោយរូបលោកតា យាគ្មានចោលនាងទៅណាទៅ ។
ច្បាស់ជាខ្លួនអញទឹងក្តួលព្រួយ វេទនាជាមួយទឹងកូនពៅ
ឈឺចាប់ស្ងាប់ច្បាណាមានរស់នៅ ក្នុងទីព្រៃជ្រៅអសារបង់ ។
ដូច្នេះត្រូវអញប្រឹងរកស្នៀត លៃធ្វើតាមច្បាជាល្អឆ្ងាំ
ដើម្បីឲ្យតាដែលគ្រឹមគ្រង់ ជាប់បង់ឈានសីលក្នុងពេលហ្នឹង ។
គ្រានោះស្តេចស្រីសាតលក្ខណ៍ ធ្វើហាក់ក្លែងខ្លួនមិនបានដឹង
របួតសំពត់ក្លៅសក្ដឹង ឈរធ្វើទ្រមឹងសំឡឹងតា ។
ពេលនោះតាបសគ្រាំមិនបាន ខកច្បាណាខូចចិត្តព្រោះកាម
ក្លែចសីលក្លែចឌានក្លែចវិយោ រួមរសាក់សនាទឹងទេវី ។
តមកពេលគ្រោយឥសីសិទ្ធិ ជ្រាបពិតដល់ក្រុងកោសម្ពី
ថាស្តេចបវរន្តបៈក្សត្រិយជាវី បានច្បាប់ទេវីជាជាយា ។
នាងឮដូច្នោះស្រីតលក្ខណា អត់ត្រាំពុំបានក្នុងអង្គា
ទឹកស្ពាយគួគាប់ធ្លាប់រួមគ្នា នាងសោកមហិមានាព្រៃជ្រៅ ។
ដ្បិតនាងទេវីយល់សព្វគ្រប់ ថាបុត្រសំណប់ពន្ធកពៅ

ប្លាស់ជាទុកទានមិនបានទៅ តាំងនៅគ្រងពស្ត្រឥតមិតា ។
ឥសីបានស្តាប់ពាក្យនោះហើយ បានធ្វើយប្រញាប់ប្រាប់នាងថា
រឿងនេះកុំភ័យណានាងណា ចាំតាជានាដួយក៏ប់វង ។
ថាហើយឥសីប្រាប់ហេតុផល ឲ្យនាងបានយល់គ្រប់ទំនង
ហើយឱ្យខេនរឿនមន្តចង ចិត្តដំរីផងកងហោមក ។
ឯគ្រឿងប្រដាប់តាំងប៉ុន្មាន វែលជាប់នឹងប្រាណនៃមាតា
នាងដោះតាំងអស់ឱ្យបុត្រា ទុកជាសញ្ញាទៅបង្ហើ ។
ស្រែចហើយខេនក៏ចេញចរ ផ្តោះទៅនគរយ៉ាងឃ្មាតខ្លី
ជាមួយនឹងហ្វូងក្អែងដំរី ដោយស្រែសួស្តីឥតភ័យឡើយ ។
នាគាលខេនចរយាត្រា ដល់ស្រុកមាតានៃខ្លួនហើយ
អ្នកស្រែកសាកសួរខេនធ្វើយ រួចហើយបង្ហាញមរគកម្តាយ ។
អ្នកស្រែកឃើញពិតរឹតរដ្ឋិជាក់ ទើបស្តុគ្រែលើកពស្ត្រថ្វាយ
អតិសេកជាស្តេចយ៉ាងសម្បើយ រុងរឿងវែងឆ្ងាយតទៅហោង ! ។

និគមវិបាក:

រឿងនេះជារឿងឡយល់ជាន គតិសត្តានចិត្តមនុស្សសត្វ
វែលមិនទាន់ដឹងធម៌អរហត្ត ត្រូវតែប្រយ័ត្នឲ្យគ្រប់ជ្រុង ។
បើមិនប្រយ័ត្នឹងអាប់យស ដូចជាតាបសចាស់ដាក
វែលក៏ត្តដោយកលស្រីមាយា ខ្លួចភេទបញ្ឆិតាជាតាបស ។
ហេតុនេះគ្រហស្ត្ថបព្វជិត គួរគិតរាល់យប់ថ្ងៃកាំងអស់
ប្រយ័ត្នកុំឲ្យខ្លួចកិត្តិយស ដោយសារភាគរសមាយាស្រី !

ជាតក - ពិធ

កំណាត់ដីនប្រវត្តិការណ៍

ពីដីបុណ្យឆ្នាំ

នៃគណៈសិស្សសីលធម៌វត្តខ្ណាលោម

លោកញ៉ែម-ខឹម, លេខាធិការនៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

កាលពីកន្ត្រៃលាចថ្ងៃសៅរ៍ ទី ៧ កក្កដា ១៩៥៦ នៅក្នុងបរិវេណកលមេរុខាងជើងព្រះបរមរាជវាំង គេឃើញមានភេនបុណ្យផ្កាមួយ ដែលតាក់តែងឡើងដោយគណៈសិស្សសីលធម៌វត្តខ្ណាលោម ។

ពន្លឺបុណ្យផ្កាក្រុមសិស្សសីលធម៌នេះ ក៏ដូចជាពន្លឺបុណ្យផ្កាឯទៀតដែលគេធ្លាប់បានធ្វើជាញឹកញយនៅក្នុងទីក្រុង ឬក្នុងជនបទនានាក្នុងប្រទេសកម្ពុជាដែរ ។ ការចំឡែក ដែលគួរកត់សំគាល់ខ្ពុកក្នុងចិត្តចាំគួរឲ្យសរសើរនោះ គឺត្រង់ពួកសិស្សដែលសំណាក់អាស្រ័យនៅក្នុងវត្តខ្ណាលោមនេះ សុទ្ធតែជាកូនអ្នកក្រីក្រហើយមានស្រុកកំណើតនៅឆ្ងាយ ។ មិនគួរឡើយទេដែលនាំគ្នាធ្វើជាអង្គឆ្លាមួយកើតដូច្នេះសោះ ។ បើសង្កេតតាមដីរភាពសិស្សចាំងនោះ សិស្សខ្លះស្ទើរតែរកលុយទិញត្រឹងចបគោគ, បរិភោគបន្តិចបន្តួចតុំចង់បានផង ។

កិច្ចជាកុសលនេះកើតឡើងដោយកម្លាំងសាមគ្គី ព្រមចាំងការក្សាក់រលឹករឿងខ្លួនរបស់សិស្សចាំងនោះ ដើម្បីកុំឲ្យត្រូវនឹងពាក្យគេថា: "សត្វ

កន្លែងរស់នៅគ្រែមដើមឈូក ពុំដឹងថាឈូកមានរសជាតិដូចម្តេច” ។

ក្នុងពិធីបុណ្យផ្កានេះ ដំបូងបានធ្វើឲ្យក្រុមសិស្សសិលធម៌មានសេចក្តីថ្លាម្តងវែកលែង មកពីបរិយាកាសពុំសូវល្អ ដោយមហាមេឃបានបង្អុរភ្លៀងចុះមកបន្តិច។ តាំងពីម៉ោង ៥ រសៀល រហូតទៅដល់ម៉ោងជាង ៩ យប់ទើបកំង, ជាហេតុនាំឲ្យខកដំណើរអស់លោកជាពុទ្ធបរិស័ទខ្លះ ដែលមានចំណងទឹកអញ្ជើញមកជួយចាប់មគ្គផលក្នុងបុណ្យផ្កានេះ ។

ប៉ុន្តែ ទោះជាមានភ្លៀងរលឹមយ៉ាងណាក៏ដោយ, ក៏នៅតែមានពុទ្ធសាសនិកជនអញ្ជើញមកជាច្រើន ។ ប្រហែលម៉ោងជាង ៧ យប់ប៉ុណ្ណោះ, គេសង្កេតឃើញអស់លោកអស់អ្នកជាពុទ្ធបរិស័ទចាំនឲ្យអញ្ជើញមកដល់ជាហូរហែ ហើយប្រកបដោយទឹកមុខស្រស់ស្រាយផង។ អស់លោកខ្លះកាលអញ្ជើញមកដល់ហើយ បានបញ្ចេញនូវមធុរកថាថា: “យើងធ្វើបុណ្យ បានជាខ្យល់តែតក់អត់មានទេ ធ្វើឲ្យយើងត្រជាក់ត្រដំដូច្នេះ” ។ នេះសឲ្យឃើញថា តែកាលណាលទ្ធិព្រះពុទ្ធសាសនាបានជ្រួតជ្រាបផ្សព្វផ្សាយពេញដួងចិត្តប្រជាជនណាហើយ ប្រជាជនោះតតួញកន្ធឹងទៅរួមធ្វើកិច្ចជាកុសលចាំនភ្លៀងរលឹមទេ ព្រោះអស់ពុទ្ធបរិស័ទចាំនោះបានយល់ច្បាស់ថា: “ការងារដោយត្រូវទឹកភ្លៀងយើងអាចទ្រាំបាន តែការងារដោយគ្មានអ្វីជាទីពឹងទៅជាតិមុខ យើងពុំអាចទ្រាំបានឡើយ” ។

ពិតបុណ្យផ្កានេះ ដើមឡើយហាក់ដូចជាពុំសូវរុងរឿងទេ ព្រោះភ្លៀងកាន់តែរលឹមគ្រាស់ឡើង។ ជាឧបស័គ្គស្ទាក់ដំណើរនៃអស់លោក

អ្នកពុទ្ធបរិស័ទដែលត្រូវអញ្ជើញមកជួយអនុមោទនា ឧទ្ទិសជាអធិបតីក្នុងពិធីបុណ្យផ្កានេះ ។ នៅពេលព្រះសង្ឃកំពុងចំរើនព្រះបរិត្ត, គេឃើញភ្ញៀវចំនួន ៣០-៤០ នាក់ប៉ុណ្ណោះ ។ លុះម៉ោងជាង ៨ យប់អស់លោកពុទ្ធបរិស័ទជិតឆ្ងាយកំបានអញ្ជើញមកដល់ជាច្រើននាក់ទៀត តែតែរកកន្លែងដូនអង្គុយពុំគ្រាន់ ។ ក្រុមសិស្សដែលរស្មៀកពាក់ជាឯកសណ្ឋានឈរជាជួរអមក្បោងទ្វារផ្លូវចូលពីខាងលិច, រង់ចាំទទួលភ្ញៀវកណ្តាលភ្ញៀងកំមានទឹកមុខរីករាយសប្បាយចិត្តឡើងវិញ ខំបំពេញមុខការរៀងខ្លួនដោយឥតគិតខ្ទើយហត់, ហើយដោយឫកពាសុភាពបសាទន់ភ្លន់ជាទីបំផុតផង ។

បដិសណ្ឋារកិច្ចនៃក្រុមសិស្សអ្នកដើមបុណ្យ ដែលបានធ្វើចំពោះភ្ញៀវកុងពេលនោះ, មានសភាពដ៏ប្រសើរណាស់ សមនាមថាជាសិស្សស្រីលធម៌មែន ។

ក្រោយពេលព្រះធម្មកថិកសំដែងធម៌ទេសនា ប្រហែលម៉ោងជាង ៩ យប់, ក្រុមភ្ញៀវកំចាប់លេងឡើង លាន់ឮកងរំពង ពីរោះគួរឲ្យចង់ស្តាប់ពន់ពេក ។

ក្រៅពីនោះ ខ្ញុំសូមសរសើរដល់ក្រុមសិស្សានុសិស្សខាងលើនេះដែលមានធម៌សាមគ្គីជាមុនមុត ខំបញ្ចេញកម្លាំងកាយនឹងកម្លាំងចិត្តសហគ្រប់ៗ គ្នា ដោយឥតគិតខ្ទើយហត់ឬស្អប់ខ្ពើមឡើយ អាចផ្តើមធ្វើបុណ្យផ្កានេះបាន ព្រោះគេពុំដែលនឹកស្មានថា ក្រុមសិស្សដែលសំណាក់អាស្រ័យនៅកុងវត្តអារាម អាចបបួលគ្នាធ្វើកិច្ចកុសលយ៉ាងធ្ងន់ធ្ងរកម្រិតអធិក

អធមដូច្នេះកើតសោះឡើយ ។ មិនត្រឹមតែបានធ្វើបុណ្យផ្កាប៉ុណ្ណោះទេ គណៈសិស្សវត្តឧណ្ណាលោម ថែមទាំងបានបង្កើតឲ្យមានជាល្ខោន, ជារបាំ ដែលជារឿងកំផ្ទេរចេតនាដូនអស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយ មើលកំសាន្តខ្លះតក្នុងពិធីបុណ្យផ្កានោះផង ។ ល្បែងដែលមានគេសរសើរច្រើន ក្នុងមហោស្រពនោះ គឺរបាំដូនតា ឱនរបាំសម័យជាន់ដើម ។ ឯរឿងកំណែមើលណាស់ដែរ, ជារឿងមានដំកៅ, មានខ្លឹមសារ, អ្នកស្តាប់អាចយកជាគំរូនុតតិបានខ្លះ ប៉ុន្តែមានបញ្ហាជាច្រើន ដែលអ្នកតែងរឿងគ្រាន់តែចោទឡើង, ឥតបានដោះស្រាយឲ្យអ្នកមើល បានយើញទំនែកនៅក្នុងពេលនោះផង ដូចជានៅក្នុងវគ្គថា: "....បញ្ហាស្ត្រីមានផ្ទៃពោះគ្មានស្វាមី . . . បុរសស្ទើនៅក្មេងសោះ ចេះស្រឡាញ់គ្នា . . ." ។ ឯរឿងកំផ្ទេរវិញ គឺធ្វើឲ្យអ្នកមើលសើចចុះដៃស្ទើរគ្រប់ធាកដែរ ។ នៅក្នុងផ្ទៃល្ខោន, ពោះមានសំដីខ្លះពុំសូវពីពោះដូចជា "បញ្ហាស្ត្រីដើមឥតប្តី" (តែនិនេះគួរសរសេរថា: "បញ្ហាស្ត្រីមានផ្ទៃពោះឬមានគតិ តែឥតស្វាមីឬប្តី" វិញ ទើបសមជាង) គឺខ្ញុំសរសើរថាល្អដែរ ព្រោះជាដំហានដំបូងក្នុងការនិពន្ធរឿងល្ខោនរបស់ក្រុមសិស្សវត្តឧណ្ណាលោម ។ ជាធម្មតា កិច្ចការអ្វីៗក៏ដោយ ដែលយើងធ្វើជាលើកដំបូង រមែងពុំសូវបានល្អសព្វគ្រប់ទេ ។

នៅក្នុងសង្គមខ្មែរយើងតាំងពីដើមមកហូតមកទល់សព្វថ្ងៃនេះ តែកាលណាគេចង់ស្តីប្តូបន្ទោសដល់ជនណាមួយ ដែលធ្វើការខ្វិចខ្វា, ធ្វើការពុំស្អាត, ធ្វើការពុំបានការថា: "យី! ធ្វើការមើលតែក្មេងវត្ត, ជជែកគ្នា

មើលតែក្មេងវត្ត ឈ្លោះគ្នាមើលតែក្មេងវត្ត . . . ។ ល ។" កិច្ចការណាអាក្រក់ កិច្ចការណាគ្មានខ្វីមសារ គេធ្វើយ៉ងម្ខាក់ជាក់ខោសទៅលើសិស្សវត្តទាំងអស់ ។ តែដោយតំណាងតំណើជាកុសលនៃសិស្សសីលធម៌នេះ ខ្ញុំសង្ឃឹមថា តាំងពីត្រឹមនេះតទៅមុខ ជនដែលបន្ទោស (ភាគតិច) មុខជាលែងពុកជាក់សិស្សវត្តថាជាជនមិនបានការទៀតហើយ ។

តាមពិត វត្តជាកន្លែងអាហារូបករណ៍មួយសម្រាប់កូនខ្មែរអ្នកគ្មានជនជាន សំណាក់អាស្រ័យសិក្សាវិជ្ជាផ្លូវលោកផ្លូវធម៌ ។ វត្តជាអគារពិសេសមួយ អាចជួយសម្រាលកិច្ចការរដ្ឋាភិបាលនឹងថវិកាជាតិជាច្រើនបាន បើកុំតែបានវត្តសម្រាប់សិស្សមួយចំនួនដែលជាកូនចៅពីរដ្ឋាភិបាលគ្រាន់នៅសំណាក់អាស្រ័យ, ម្ល៉ះសមពីរដ្ឋាភិបាលយើង លំបាកនឹងដោះស្រាយរកកន្លែងឲ្យសិស្សទាំងនោះនៅសំណាក់រៀនសូត្រនឹងគេណាស់ ។ ក្នុងមួយឆ្នាំ ។ មានសិស្សជាច្រើនដែលសំណាក់អាស្រ័យនៅក្នុងវត្តនានាក្នុងព្រះពុទ្ធសាសនា បានប្រឡងជាប់វិញ្ញាបនប័ត្រ នឹងមធ្យមសិក្សាបឋមត្រ ។ មានអ្នកពីរដ្ឋការជាច្រើននាក់ ដែលតែងតែមកទាប់សំណាក់អាស្រ័យនៅរៀនសូត្រក្នុងវត្តដែរ ហើយដែលសព្វថ្ងៃនេះ បានឡើងទៅជាមន្ត្រីគាន់តំណែងជាន់ខ្ពស់ក៏មាន ជាន់កណ្តាលក៏មាន ទៅតាមសមត្ថភាពរៀងខ្លួន ។ ដូច្នេះ ខ្ញុំយល់ថា សិស្សនៅវត្តមិនមែនជាសិស្សគ្មានទុគ្គមគតិ, ខ្សត់ខ្សោយខាងចំណេះវិជ្ជា ឬធ្វើការអ្វីពុំកើតនោះទេ ។ តស្តុតាងដូចជាក្រុមសិស្សវត្តទំណ្លាលោមនឹងវត្តលង្កាជាដើម ដែលបានធ្វើបុណ្យផ្កាកើតយ៉ាងទុក្ខវាកៃរួចមកហើយ ។ ដែលខ្ញុំពោលមកប៉ុណ្ណេះ

គឺខ្ញុំមិនមែនកាន់ជើង ឬ បញ្ហារសិស្សនៅវត្តទេ , គឺខ្ញុំពោលតែតាមក្តែក របស់ខ្ញុំមើលឃើញ ព្រោះសិស្សនៅវត្តក៏ជាចំណែកមួយនៃកម្លាំងរបស់ វត្តយើងដែរ ។

ម្យ៉ាងទៀត តាមដែលខ្ញុំបានធ្លឹងការណ៍ប្រាស់មកថា សម្តេចព្រះ មហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកបានដឹកនាំពួកសិស្សគ្រហស្ថ ចាំដ៏ប៉ុន្មាន ដែលនៅក្នុងវត្តច្រណ្តាលោមសព្វថ្ងៃនេះ ឲ្យរៀនធម៌នៅ ក្រោមមហាកុដនៃសម្តេច រៀងពាល់ល្ងាចថ្ងៃពុធនឹងថ្ងៃសៅរ៍ ដើម្បីឲ្យ សិស្សទាំងនោះទៅជាពលវន្តល្អ ចេះស្រឡាញ់ជាតិ សាសនា ព្រះ មហាក្សត្រិយ៍ ព្រោះជនម្នាក់ៗ មិនត្រឹមតែត្រូវចេះដឹងវិជ្ជាខាងផ្លូវ អាណាចក្រតែមួយមុខប៉ុណ្ណោះទេ គឺត្រូវចេះដឹងវិជ្ជាខាងផ្លូវពុទ្ធចក្រ ទៀតផងទើបចាត់ជាពាវន្តល្អបាន ដ្បិតផ្លូវលោកនឹងផ្លូវធម៌ជាគូនឹងគ្នា បើ ខ្វះផ្លូវណាមួយ ប្រទេសជាតិយើងក៏ពុំអាចដើរឲ្យទាន់សម័យនិយមបាន ឆាប់ហើយ ។ ហេតុនេះហើយ បានជាក្រុមសិស្សគ្រុសិស្សខាង លើនេះបានឈ្មោះថា "គណៈសិស្សសីលធម៌" ។

សេចក្តីសង្កេតជាខាងក្រោយបំផុតរបស់ខ្ញុំ គឺខ្ញុំបានឃើញជនជាតិ ខ្មែរយើងខ្លះ (ដែលមានភាគតិចទេ) ចូលលុយចាប់មគ្គផលក្នុងបុណ្យ ផ្កានោះ ដោយហុចតែនឹងដៃមួយទៅអ្នកទទួល, ហាក់ដូចជាហុចលុយ ទៅទិញសំបុត្រល្ខោនឬកុន ។ ការធ្វើកុសលបែបនេះ បានផលតុំ បរិបូណ៌ឡើយ ព្រោះពុំប្រកបព្រមដោយឥន្ទ្រិយនៃការធ្វើទាន ។ ធ្វើទាន

ដែលបានបុណ្យច្រើន លុះតែប្រកបដោយសេចក្តីគោរព ៣ យ៉ាង គឺ គោរពដោយកាយ វាចា ទំនឹងចិត្ត ។

តែអំណោះតទៅមុខ, យើងសង្ឃឹមយ៉ាងម៉ាំថា ពលរដ្ឋប្រកេទនេះ កងប្រទេសកម្ពុជា មុខជាទំនឹងចេះធ្វើទានឲ្យសមទៅតាមលទ្ធិព្រះពុទ្ធសាសនាជាពុំខាន ។

ភត្តិបុណ្យផ្កាបានចប់ទៅម៉ោង ១ ឃប់ ខ្លះ ១០ នាទី ។

អស់លោក - អ្នកជាពុទ្ធបរិស័ទទាំងឡាយ ក៏បានអញ្ជើញទៅកាន់គេហស្ថានវិញរៀងខ្លួន ។

ប្រាក់ចំណូលក្នុងបុណ្យផ្កានោះបានចំនួនជាង ៨ ០០០,០០ ។

* * *

សុន្ទរកថារបស់សិស្សសិល្បៈ

ថ្លែងក្នុងឱកាសបុណ្យផ្កាមុនព្រះធម្មកថិកសំដែងធម៌

សូមទូលថ្វាយ សូមដំណាប ឯកឧត្តម លោកអ្នកពុទ្ធបរិស័ទ ដែលស្តេចយាងនឹងអញ្ជើញមកជាអធិបតីក្នុងឧកាសបុណ្យផ្កានេះ

សូមថ្វាយជ័យ សូមមានជ័យ ។

ទូលព្រះបង្គំ ខ្ញុំបាទ កងនាមនៃសិស្សសិល្បៈ វត្តឧណ្ណាលោម សូមថ្លែងអំណរគុណយ៉ាងក្រៃលែង ចំពោះថ្វាយ ឯកឧត្តម ទំនឹងលោកអ្នកសប្បុរសទាំងឡាយ ដែលមានសោមនស្សចិត្តប្រកបដោយសម្បយុត្ត បានស្តេចយាងនឹងអញ្ជើញមកជាអធិបតី ក្នុងឧកាសបុណ្យផ្ការបស់ទូលព្រះបង្គំ យើងខ្ញុំនេះ ។

ទូលព្រះបង្គំ យើងខ្ញុំ មានបំតិសោមនស្សជាអនេក ដោយទូលព្រះបង្គំ យើងខ្ញុំយល់ឃើញថា កុងការដែលស្តេចយាង កុងការដែលលោកអ្នកអញ្ជើញមកនេះ គឺខ្ញែង - លោក - អ្នក បាននាំយកមកជាមួយនូវកិត្តិយសដ៏ខ្ពង់ខ្ពស់ ទីជមង្គលដ៏ល្អវិសេសដល់បុណ្យនេះយ៉ាងពិតប្រាជក ម្យ៉ាងទៀត អង្គនៃបុណ្យឆ្លានេះដែលអាចចំរើនឡើងនឹងសម្រេចទៅកើតកំដោយសារទឹកព្រះទ័យ ទឹកចិត្តប្រកបដោយមេត្តាគ្រប់ជាក់គ្រងដំនៃខ្ញែង ឯកទត្តម ទីលោកអ្នក ។

បន្ទាប់ពីនេះ ទូលព្រះបង្គំ ខ្ញុំបាទសូមខ្ញែង ឯកទត្តម លោក - អ្នក បើកទុកាសឲ្យទូលព្រះបង្គំ ខ្ញុំបាទ រៀបរាប់ថ្វាយ - ជូនជាទីសណ្តាប់នូវប្រវត្តិនៃបុណ្យឆ្លានេះ ។

បុព្វហេតុដែលទាំឲ្យកើតបុណ្យឆ្លានេះឡើង គឺទូលព្រះបង្គំ យើងខ្ញុំយល់ឃើញថា :

ទី១.- ការមើលបំណាំកុងកវណីយនៃអ្នកមានគុណ ដូចជាព្រះមហាក្សត្រ មាតាបិតា គ្រូបាធ្យាយមានទុក្ខព្រួយ ទុក្ខជាកំហុសមួយដ៏ធ្ងន់របស់បុគ្គល ។

ទី២.- ការតបគុណដល់មាតុភូមិ ដល់ទឹកដ្ឋដែលខ្លួនសំណាក់អាស្រ័យ ដោយជួយជ្រោមជ្រែងឲ្យខ្លះនោះថ្កុំថ្កើងរុងរឿងឡើងជាកិច្ចដែលមនុស្សម្នាក់ គ្រូតែបំពេញ ។

ដោយហេតុនេះ ទូលព្រះបង្គំ យើងខ្ញុំ ដែលសំណាក់អាស្រ័យនៅកុងវត្តនេះ ណាលោមបានព្រមព្រៀងគ្នាឡើងថា គ្រូតែផ្តើមធ្វើបុណ្យឆ្លា

មួយ ព្រោះខ្ញុំព្រះបង្គំ យើងខ្ញុំ បានឃើញខ្លួនការកសាងថែរក្សាបរិវេណ
ឈាបនដ្ឋានសាធារណៈ ដែលកំពុងធ្វើសព្វថ្ងៃក្នុងវត្តទាំងមូល
ក្រោមអធិបតីភាពនៃសម្តេចសង្ឃនាយក កំពុងតែជួបប្រទះនូវឧបសគ្គ
គឺការខ្វះបច្ច័យ ។ ខ្ញុំព្រះបង្គំ យើងខ្ញុំ រស់នៅក្នុងសង្គមកម្រិតពិតមែន
តែដែលហ៊ានធ្វើមធ្វើបុណ្យផ្កានេះ ព្រោះអាងយ៉ាងម៉ាំថា ឯកឧត្តម
លោក-អ្នកដែលចែកបដោយសប្បុរសចិត្ត ច្បាស់ជាជួយឈឺឆ្អាលជួយ
ឧបត្ថម្ភ មិនបណ្តោយឲ្យខ្ញុំព្រះបង្គំ យើងខ្ញុំ លិចលង់គ្មានទីពឹងទេ ។
ពេលនេះ បុណ្យផ្កាក៏បានសំរេចសមដូចក្តីប្រាថ្នារបស់ខ្ញុំព្រះបង្គំយើងខ្ញុំ
ដោយសារតែសេចក្តីប្រោសប្រណី របស់ព្រះមហាក្សត្រតាំងពីព្រះអង្គ
ទ្រង់ដោយសារការជួយឧបត្ថម្ភរបស់ទ្រង់ ឯកឧត្តម លោក-អ្នកទទឹងមិត្ត
គ្រប់រូប ។

នៅទីបញ្ចប់នៃសុន្ទរកថានេះ ខ្ញុំព្រះបង្គំ យើងខ្ញុំ សូមឧទ្ទិស
កុសលកុងការធ្វើបុណ្យផ្កានេះ ថ្វាយដល់ព្រះមហាក្សត្រតាំងពីព្រះអង្គ
ថ្វាយដល់សម្តេចព្រះឧបយុវរាជ ថ្វាយដល់ទ្រង់ ជូនដល់ឯកឧត្តម
លោក-អ្នកទទឹងមិត្តទាំងឡាយ សូមឲ្យព្រះអង្គ សម្តេច ទ្រង់ ឯកឧត្តម
លោក អ្នក ទទឹងមិត្ត បានប្រកបដោយព្រះជន្មាយុ - អាយុ វណ្ណៈ សុខៈ
ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ភាសាសន្ស្ក្រឹត

ទស្សនាវដ្តី ផ្សាយដំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៨ លេខ ១០ ខែតុលា ព.ស.២៤៩៩ គ.ស.១៩៥៦

CENTRE CULTUREL DU CAMBODGE
BIBLIOTHEQUE
Inventaire
8-S-63



ភ្នំពេញសនីយ៉ា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីភឿន	ទំព័រ
– ចិត្តភាក់តែងប្រែ	ឃុនបណ្ឌាឧប៉ាល្យ ប៊ូ-ប៉ូ	៩០៣
– ការុធមិ	ព្រះវេទសត្ថា កឹម-តួរ	៩១១
– កម្មបថកថា	ព្រះមហា ខៀវ-ដឹយ	៩២១
ផ្នែកអក្សរសាស្ត្រ		
– ប្រវត្តិការណ៍ខ្មែរបុរាណ	លោក មាស-ធាន់ ប្រែ	៩៣១
– អក្សរសាស្ត្រខ្មែរសង្ខេប (តមក)	លោក រ័យ-ប៊ុក	៩៣៤
– ពេទ្យព្រះរាជា (តមក)	លោក ស៊ុន-ហ៊ាន ប្រែ	៩៤៨
– រឿងសាមកុក (តមក)	ឧកញ៉ា ន-ក	៩៥៥
– រឿងបល្ល័ង្កទិព្យ (តមក)	លោក រ័យ-ប៊ុក ប្រែ	៩៦៥
– ការដាំដើមឈើយកផ្លែ	ឃុនអត្ថកោវិទ ជា-ឃួរ ប្រែ	៩៧២
កំណាត់នីតិប្រវត្តិការណ៍		
– ពិធីជុណ្ឌកឥញ្ជកឥតវេទិកានៃក្រុមសិស្ស ធ្វើចំពោះសម្តេចព្រះធម្មលិខិត ល្ង-ឯម វត្តលង្កា	ព្រះមហា សម-សុខ	៩៨២

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE: *Page*

— Formation des êtres et du monde . . . . . *par M. BOU-PO 903*
— Kurudharma . . . . . *par le Vén. . . KEM-TO . 911*
— Kammapathakatha . . . . *par le Vén. . MEACH-CHEY 921*

PARTIE LITTÉRAIRE:

— Chronique de l'Antiquité Khmère . . . . . *par M. MEAS-CHHAN . . 931*
— Littérature Khmère résumée (suite) . . . . . *par M. RAY-BUC 934*
— Conte "Le Diamant de Raja" (suite) . . . . . *Traduit par M. SIN-HEAN. 944*
— Histoire du Samkok (suite) . . *Traduit par M. NOU-KAN. 955*
— Les trente deux récits du Trône (suite) . . . . . *Traduit par M. RAY-BUC . 965*
— La culture des arbres fruitiers . . . . . *Traduit par M. CHEA-YOU . . 972*

NOTES ET CHRONIQUES:

— Fête organisée par les disciples en l'honneur de Samdech Preah Dhammalikheta Louis-Em . . . . . *par le Vénérable SAM-SOK . 982*

Prix d'abonnement annuel (comprenant 12 numéros) 230$00

ចិត្តតាក់តែងរូប(១)

ឃុនបណ្ណាឆ្នុរក្សូ ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ចិត្តជាអរូបធាតុ ជាធម្មជាតចំឡែកអស្ចារ្យណាស់ បើទុកជាចិត្តមានអវិជ្ជា តែការមិនចេះមិនដឹងក៏ដោយ ក៏គង់ចិត្តនោះអាចតាក់តែងខ្លួរូបបានយ៉ាងច្រើនលើសលុប ពាល់តែពាក់មិនអស់ ។ បណ្ដាវត្ថុតាំងកួង ដូចរថយន្ត, រថភ្លើង, កប៉ាល់ចម្បាំង, វិមាន, ផ្ទះធំៗ ខ្ពស់ច្រើនជាន់ ។ល។ តាំងអស់នេះកើតមានឡើងក្រោកដជារូបកាន់ប្រើប្រាស់បានផលប្រយោជន៍ផ្សេងៗគ្នា ក៏មកតែពីចិត្តជាអ្នកគិតប្រឌិតតាក់តែងឡើង គឺចិត្តបញ្ចេញស្រមោលជាធាតុគិតមុនរួចហើយ ទើបកើតផលជាធាតុដឹងខាងក្រៅយ ។ ធាតុដឹងដែលកើតក្រោកដឡើង ចាត់ជាលោកិយ-វិជ្ជា (គិតរួចចាំគូរ) ។ កាលចិត្តមានវិជ្ជាហើយ ទើបប្រើកាយឲ្យនាំធាតុផ្សេងៗដ៏ជារូបធាតុមកផ្សំផ្គុំរួមគ្នាឡើង សម្រេចជារូបសត្វវត្ថុផ្សេងៗ ។ រូបនោះល្អថ្លៃថ្លាខ្លះ អាក្រក់ខ្លះ ស្រេចតែការចេះដឹងនឹងសេចក្ដីអង់អាចរបស់ចិត្ត ។ ជនដែលមានចិត្តប្រកបដោយធាតុចេះដឹងបែបនេះ ហៅថា អ្នកឈ្លាសវៃ ឬអ្នកប៉ិនប្រសប់ ។ រឿងនេះ យើងអាចពិសោធឲ្យ

---

១ អធិប្បាយតាមន័យនៃព្រះអភិធម្មត្ថសង្គហៈ ក្នុងចិត្តសង្គហវិភាគ បរិច្ឆេទទី ១ ។

ឃើញច្បាស់ថា ចិត្តដែលមានធាតុចេះដឹងនោះ អាចចាត់ចែងកាយ
រូបយ៉ាងល្អស្រស់ថ្លៃថ្លាបានត្រឹមណា ខ្ញុំជឿខុកជាមុនថា លោកអ្នកពាំង
ឮយគន់ធ្លាប់បានចូលទៅកន្លែងវិហារព្រៃតែមរកត ដែលតាំងនៅទិស
ខាងត្បូងផ្ទាល់ព្រះចេមកជាំងចតុម្មុខក្រែងកុំពេញដែរ ។ រួចផ្សេង ។
ដែលភ្ញាកដល់ចក្ខុនៃអស់លោកអ្នក នៅវេលាចូលទៅក្នុងព្រះវិហារ
នោះ ជារូបដែលល្អស្រស់ឆើតឆាយត្រឹមណា ។ អស់លោកអ្នកឃើញ
ហើយមុខជាមិនបដិសេធថា រូបពាំងអស់ក្នុងខ្លីនោះជារបស់មិនគួរមើល
ឬមិនគួរសរសើរទេ សឹងតែយល់ឃើញត្រូវគ្នាថា វត្តមួយ ។ ជារបស់
ចំឡែកអស្ចារ្យណាស់ ដូចយ៉ាងតួព្រះវិហារដែលគ្រាលច្រាក់សុទ្ធជា
ដើម ។ គ្រាលបើឃើញហើយ ។ ស្រាវជ្រាវរកហេតុផលទៅ តង់
ឃើញថា វត្តដែលមើលឃើញពាំងអស់នោះ សុទ្ធតែជាផល ។ ផល
ពាំងនេះកើតឡើងអំពីអ្វីជាហេតុ? ផលពាំងនេះកើតឡើងពីកម្មជាហេតុ ។
ចុះកម្មនោះប្រែថាម៉េច? ប្រែថា ការធ្វើ ។ ចុះអ្នកណាធ្វើ? មនុស្ស
ជាន់ចាស់ធ្វើ ។ អ្នកណាប្រើឲ្យធ្វើ? ចិត្តនៃមនុស្សនោះឯងប្រើឲ្យធ្វើ ។
ប៉ុន្តែអស់លោកអ្នកដែលមានចិត្តច្រកបដោយការចេះដឹងពិតច្បាស់ជាហើយ
មុខជាឆ្ងើយថា ចិត្តដែលមានលោភៈយ៉ាងវិជ្ជាជាគុណសម្បត្តិប្រើឲ្យកាយធ្វើ
វត្តពាំងនោះឡើង ។ នេះបម្រើយជាត្រឹមត្រូវតាមសេចក្តីពិតរបស់ហេតុ
ផល ។ កាយនោះជាធាតុឥតដឹងអ្វីបន្តិចបន្តួចសោះ ធ្វើអ្វីខ្លួនឯងក៏ឥត
ដឹង ។ ចិត្តមានអំណាចលើកាយ មានសេចក្តីចេះដឹងជាគុណសម្បត្តិ
ទើបអាចបង្គាប់បញ្ជាកាយឲ្យធ្វើវត្តនោះ។ បាន ។ ប្រសិនបើចិត្តគ្មាន

តែមានអំណាចប្រែកាយប៉ុណ្ណោះ តែមិនបេះមិនដឹងទេ ចិត្តក៏ឆ្ងល់ប្រែកាយឲ្យធ្លើវត្ថុនោះមិនបានជាជាប់ខាត ដូចចិត្តប្រើដៃឲ្យសរសេរសំបុត្រ បើចិត្តមិនបេះអក្សរ ១ តួសោះ តើដៃសរសេរកើតដែរឬទេ? ប្រាស់ជាមិនកើតសោះឡើយ ។ នេះជាឧទាហរណ៍របស់ចិត្តល្ងង់ខ្លៅ ជាចិត្តមានតែអំណាចមឆ្គាំ ជាចិត្តឥតចំណេះវិជ្ជា ។ ឧទាហរណ៍មួយទៀត ដូចរូបគំនូរនៅតាមថែវជុំវិញព្រះវិហារ ជាគំនូរមានបែបភាពផ្ទែក ។ គ្នាល្អខ្លះ អាក្រក់ខ្លះ ។ ចិត្តត្រូវមានវិជ្ជាកង់ការគូរ ទើបអាចប្រើដៃឲ្យគូរជារូបយ៉ាងនោះ ។ ល្អកើត ។ ហេតុដូច្នោះចិត្តត្រូវតែមានគុណសម្បត្តិជាច្រើនប្រការ ទើបនឹងអាចតាក់តែងរូបឲ្យល្អល្អៅបាន ។

ចិត្តអ្នកតាក់តែងរូបនោះត្រូវមានគុណសម្បត្តិ ៤ យ៉ាងជាខាងដើមគឺ

១ - ត្រូវមានឆន្ទៈសេចក្តីស្រឡាញ់ពេញចិត្តក្នុងកិច្ចការដែលធ្វើនោះ,

២ - ត្រូវមានសេចក្តីព្យាយាមធ្វើកិច្ចនោះ ។,

៣ - ត្រូវយកចិត្តទុកដាក់ក្នុងកិច្ចការនោះ ។,

៤ - ត្រូវពិចារណារកហេតុផលក្នុងកិច្ចនោះ ។ ។

(ឥទ្ធិបាទ ៤ គឺ ឆន្ទៈ, វីរិយៈ, ចិត្តៈ, វិមំសា)

ក្រៅពីគុណសម្បត្តិ ៤ យ៉ាងនេះ នៅមានគុណសម្បត្តិផ្សេង ។ ទៀតជាច្រើនប្រការណាស់ មិនអាចយកមកពន្យល់ក្នុងទីនេះឲ្យចប់ជុំនេះទេ ។ សេចក្តីខាងដើមនេះចង្អុលឲ្យឃើញថា ចិត្តជាធម្មជាតិដ៏ខ្ពង់ខ្ពស់អស្ចារ្យ ។ ចិត្តជាអរូបធាតុ ប៉ុន្តែមានគុណសម្បត្តិច្រើនប្រការណាស់ ។ ចិត្តនឹងបញ្ចេញស្រមោលជាធាតុគិតបានប៉ុន្មាន ។, ។ ធាតុគិតនោះកើតឡើង

ហើយរលត់ទៅវិញជាធម្មតា ។ ប៉ុន្តែធាតុចេះដឹងជាផលរបស់ធាតុគិត តែងមានទៅជាគុណសម្បត្តិជាប់ជានិច្ច មិនបានសាបសូន្យបាត់ទៅណាទេ ។ ចិត្តរើសប្រមូលយកធាតុចេះដឹង ឬវិជ្ជាទាំងអស់នោះខុកឲ្យគង់នៅបាន ។ ចិត្តជាតែ ។ ដែលគ្មានវិជ្ជាបែបនោះទេ មិនអាចនឹងបែងចែកឬធ្វើជាណែមយកវិជ្ជារបស់ចិត្តដែលមានវិជ្ជានោះ ។ មកជាក់កងខ្លួនបានឡើយ ។ វិជ្ជាផ្សេង ។ ប្រៀបដូចទ្រព្យមានកម្មសិទ្ធិ, ចិត្តប្រើប្រាស់មិនចេះអស់, សមដូចសុភាសិតដែលលោកជាចិន្តកវីពោលទុកថា "មានវិជ្ជាដូចមានទ្រព្យរាប់មុនសែន ពោះឆ្កាក់ពីចង្អៀតណែនក៏មិនថប់ ព្រោះចិត្តមានវិជ្ជាប៉ុនប្រសប់ អាចត្រឡប់រើខ្លួនរួចពីទុក្ខទោស" ។ សូម្បីសម្តេចព្រះបរមសាស្តា ក៏ទ្រង់តាស់សរសើរគុណរបស់វិជ្ជាលោកិយ ទុកក្នុងមង្គលសូត្រថា "សិល្បៈជាមង្គលដ៏ឧត្តម" ។

ចិត្តមានវិជ្ជាយ៉ាងនេះហើយ អាចតាក់តែងរូបបែកខាងល្អឲ្យកើតឡើងបាន ដើម្បីថែរក្សាលោកគឺកាយ, កាយជាធាតុ ៤ ដែលតែងសាបសូន្យបាត់បង់ទៅវិញជាធម្មតា ។ ចិត្តអ្នកគ្រប់គ្រង ត្រូវគិតខំទុកបំរុងរូបកាយដោយចាយចំណីនឹងផ្លែឈើផ្សេង ។ ត្រូវរកសំពត់អាវបិទបាំងកាយ ការពារក្តៅត្រជាក់ មូសសុចស្រួយស្រាង នឹងត្រូវធ្វើលំនៅទុកសម្រាប់ឲ្យកាយសំណាក់អាស្រ័យ ។ កាលបើកាយមានអាពាធឈឺចាប់ ចិត្តក៏ត្រូវតែស្វះស្វែងរកពេទ្យគ្រូថ្នាំសង្កូវបំបាត់រោគនោះ ។ ដើម្បីឲ្យកាយរស់នៅបានយឺនយូរតទៅទៀត ។ ចិត្តទុកជាមេការឬជាមេជាងយ៉ាងសំខាន់ អាស្រ័យនៅក្នុងរូបកាយហើយខ្លួនពីជា

អ្នកត្រៃត្រង់កាយថែមទៀត, ត្រៃកាយ, ខំនុកបំរុងកាយ ជាអ្នកទទួលខុសត្រូវក្នុងមុខងារត្រៃប្រកាល ។ ប៉ុន្តែកិច្ចការទាំងអស់ដែលជាខាងក្រៅ ចិត្តជាអ្នកបង្គាប់ឲ្យកាយធ្វើ ទើបកាយធ្វើបាន ។ ចំណែកការងារដទៃផ្សេងទៀត ត្រូវអាយវៈខាងក្នុងកាយចាត់គ្នាធ្វើឡើងក៏មាន ដូចចិត្តត្រៃកាយឲ្យបរិភោគអាហារហើយ, អាហារកន្ទុងចូលទៅក្នុងក្រពះសិប់ហើយ, ទឹករំលាយអាហារ គឺក្លែងជាតុក៏ធ្វើនាទីរំលាយអាហារ រហូតដល់កើតទៅជាលោហិត, បេះដូងមាននាទីបញ្ជូនលោហិតទៅខំនុកបម្រុងអាយវៈពេញពាងកាយ, ចិត្តមិនបានបង្គាប់ឲ្យធ្វើទេ, អាយវៈខាងក្នុងទើបជារបស់ដែលនៅត្រៃអំណាចនៃចិត្ត, ចំណែកការដកដង្ហើមចូលចេញដែលចិត្តបង្គាប់បានក៏មានដែរ ដូចចិត្តត្រូវការឲ្យដកដង្ហើមញាប់ក៏បានឲ្យដកដង្ហើមរងើលក៏បានតាមប្រាថ្នា ។ ប៉ុន្តែតាមប្រកតីរបស់ចិត្តមិនបានបង្គាប់បញ្ជាក្នុងការដកដង្ហើមទេ ត្រូវកាយធ្វើនាទីរបស់ខ្លួនឯង ។

សកលកាយនេះ សូម្បីជាធាតុ ៤ ក៏ពិតមែនហើយ ប៉ុន្តែជាសរីរៈយន្តដែលវិចិត្រពិស្តារកៃលែងណាស់ តតវត្តុដទៃដែលជាគ្រឿងប្រើប្រាស់ដ៏សំខាន់កៃលែងជាងកាយឡើយ ។ វត្តុផ្សេង ៗ ដែលចិត្តគុបតែងឡើងឲ្យជារបស់ដ៏អស្ចារ្យយ៉ាងណាក៏ដោយ ក៏នៅតែមិនខាន់អស្ចារ្យឬមានគុណមានដម្លៃកៃលែងជាងកាយឡើយ ។ សម្បត្តិខាងក្រៅជាវត្តុដែលចិត្តនិយមថា មានដម្លៃច្រើន ទោះបីកាត់ថ្លៃវត្តុនោះដល់ម៉ឺនសែនក្តី បើប្រៀបធៀបនឹងកាយហើយ យើញថាកាយជាវត្តុមានដម្លៃច្រើនលើសលុបជាងវត្តុនោះ ។ យ៉ាងឆ្ងាយណាស់ ព្រោះហេតុអ្វី ព្រោះ

កាយជាទីសំណាក់អាស្រ័យរបស់ចិត្ត ជាគ្រឿងប្រើប្រាស់របស់ចិត្ត ដែលចិត្តត្រូវតែថ្នាក់ថ្នមថែរក្សាឲ្យយ៉ាងណាក្រែលែងជាន់វត្ថុដទៃៗទាំងអស់ ។ ឲ្យសម្បត្តិខាងក្រៅដែលចិត្តនិយមថាជារបស់ប្រសើរ ជារបស់ដែលនឹងឲ្យផលដល់ខ្លួនឲ្យបានសុខ តាមសំដីនិយាយគ្នាថាប្រាក់ឬធនច័ត្រនោះ ចិត្តប្រើឲ្យកាយធ្វើកិច្ចការហើយបានវត្ថុទាំងនោះមកពុកជាសម្បត្តិចិត្តរមែងរង្វើងភៅគោរពបូជាវត្ថុនោះ ។ ដោយរឹកកាយយ៉ាងខ្លាំង ប៉ុន្តែស្រឡាញ់វត្ថុទាំងនោះតើដើម្បីប្រយោជន៍អ្វី ? បើធ្វើយ៉ាងគ្រឹម ។ មុខជាធ្វើយថា ដើម្បីយកមកចាត់ចែងអាហារខ្លះ ដើម្បីធ្វើឬជួសជុលទីលំនៅខ្លះ ដើម្បីទិញសម្ភត់អាវនឹងគ្រឿងតែងខ្លួនខ្លះ ដើម្បីទិញថ្នាំកែរោគដែលកើតជាប់នឹងកាយខ្លះ ។ រឿងនេះបង្ហាញឲ្យឃើញថា សុទ្ធតែជារឿងចំនុកបម្រុងកាយទាំងអស់ ។ ចិត្តដែលអាស្រ័យនៅក្នុងកាយរមែងជឿជាថាកាយជាសម្បត្តិយ៉ាងឯករបស់ខ្លួន ។ ចិត្តសំគាល់ថា សរីរៈចំណែកតូច ។ ដូចក្អែក, ច្រមុះ, មាត់, ធ្មេញ, ក្រចក ទាំងនេះក្នុងមួយៗជារបស់ល្អប្រពៃ ចិត្តចង់ឲ្យតែតែល្អខ្លាំងឡើងទៀត ទើបស្វែងរកគ្រឿងប្រដាប់មកតាក់តែងពាក់កាយ ឲ្យល្អស្រស់រុងរឿងច្រើនឡើង ដូចការ, ទំហូ, ខ្សែក, ចិញ្ចៀន ជាដើម ។ ចិត្តត្រេកអរនឹងកាយ ប្រើកាយឲ្យតំណាក់តែង ។ ឯកាយវិញមិនដឹងខ្លួនថាត្រូវគេប្រើទេ ទាំងសរីរៈចំណែកនោះ ។ ដូចត្រចៀកក៏មិនដឹងថាត្រូវពាក់ទំហូ, ម្រាមដៃក៏មិនដឹងថាត្រូវពាក់ចិញ្ចៀន, កមិនដឹងថាត្រូវពាក់ខ្សែក, ចង្កេះមិនដឹងថាត្រូវពាក់ខ្សែក្រវាត់, មិនតែប៉ុណ្ណោះ ចិត្តនៅតែចង់ឲ្យកាយល្អលើសពីនោះទៅទៀត

ទើបចេះតែគិតតុបតែងឲ្យតែតែល្អខ្ចាំងឡើង ដូចជាធ្វើក្អែកឲ្យមានពែនគា, គួរចិញ្ចើមឲ្យខ្មៅហើយធំទូន់, លាបបបូរមាត់ទឹងក្រចកឲ្យក្រហម កាត់សក់ឲ្យសមរម្យ កាត់ភេមក្អែកឲ្យខ្លី តែចង្កេះឲ្យមូល ។ ទៅមានវិធីតុបតែងកាយដទៃទៀតជាយ៉ាងច្រើន ដែលចិត្តអ្នកប៉ុនប្រសប់ក្នុងរបៀបតុបតែងកាយ ចំណាយប្រាក់ទិញគ្រឿងប្រជាប់សម្រាប់តាក់តែងកាយ លះបង់ពេលវេលាព្យាយាមតែងកាយ ។ អាឃរៈគ្រប់ចំណែកដូចជាកន្ទឹងសក់ មិនបានដឹងសោះថា ត្រូវតាក់ឡៃឬត្រូវកាត់ ។ រឿងនេះ បើយើងពិនិត្យឲ្យសព្វគ្រប់ទៅហើយ គាចឃើញបានយ៉ាងជាក់ច្បាស់ថា កាយនោះជាធម្មជាតឥតដឹងក្លិនសោះមែន ។ ។ មានតែចិត្តទេទើបដឹង ប៉ុន្តែសូម្បីដូច្នោះ ចិត្តក៏នៅតែដឹងមិនត្រង់ មិនត្រគាមសភាវៈពិត ។ ព្រោះចិត្តមិនដឹងថា ការតាក់តែងកាយនេះប្រព្រឹត្តទៅដើម្បីសន្សំកងតំលៃសន្ធឹកឥន្ធនៈឲ្យច្រើនឡើង ។ ចិត្តនេះវង្វេងក្លើតក្លើនស្រើនស្រឡាញ់រូបឥតកាយដូច្នោះ មិនបានទឹកវិលឹកដល់សេចក្តីប្រែប្រួលរបស់ឥតកាយសោះ ។ កាយចាស់ទ្រុឌទ្រោមទៅគ្រប់ខណៈ ចិត្តក៏មិនត្រមទទួលដឹងថាកាយចាស់ សំគាល់ថានៅក្មេងនៅត្រម៉ុកំឡោះ ។ ចិត្តស្មុគស្មាញវង្វេងស្រើស សំឡឹងយកតេជង្គយគ្នាទៅវិញ ។ ចិត្តបែបនេះរមែងនិយមការគ្រប់គ្រងជីវិតជួយស្រឡះ ប្រទះបានតែសាមិសុខទុក្ខ សាមិសុខទុក្ខលាយឡំគ្នាជាដរាបទៅ ព្រោះថាកាមគុណ មានកាមសុខជាផល, កាមទោស មានកាមទុក្ខជាផល ។ ជីវិតបែបនេះមិនបានទទួលសន្តិសុខដ៏ពិតប្រាកដទេ ប៉ុន្តែ របស់ទាំងនេះ កាលបើមានគុណ

ជាអនន្តហើយ ក៏រមែងមានទោសជាមហន្តដែរ ។ កិច្ចពាំនេះ ជាវិធីការគ្រប់គ្រងដ៏វិសេសរបស់ចិត្ត ដែលប្រកបដោយអវិជ្ជាវង្វេងស្រឡាញ់រាងកាយ សំគាល់ថារាងកាយល្អ, ថាជាខ្លួនប្រាណ ។ ចំណែកចិត្តដែលប្រកបដោយវិជ្ជាវិញ ឃើញថាមិនល្អ គ្រាន់តែជាធាតុ ៤ ស្មើគ្នាមិនថារូបស្រីឬរូបប្រុសទេ ។ ចិត្តដែលឃើញយ៉ាងនេះទើបមិនត្រូវការរូបកាយដទៃ ។ ទៀត ព្រោះមានកាយតែមួយប៉ុណ្ណោះ ក៏ល្មមប្រើការបានគ្រប់គ្រាន់ហើយ ។ ចិត្តដែលមានសេចក្តីល្មមគ្រប់គ្រាន់ ទើបឈ្មោះថាជាអ្នកមានទ្រព្យសុភសុខ្ញ មិនខ្វល់ក្រ មិនខ្វះខាត ។ ចិត្តដែលដឹងស្គាល់កាយច្បាស់លាស់តាមសភាវៈពិត រមែងជាចិត្តថ្លៃថ្លារាងចិត្តគ្រប់គ្រងដ៏វិសេសយ៉ាងឯក មិនគិតបៀតបៀនគេ មិននិយាយពាក្យសំដីបៀតបៀនគេ មិនប្រើកាយឲ្យធ្វើការបៀតបៀនគេ ។ ជនអ្នកមានចិត្តវៀរចាកការបៀតបៀន រមែងមានសេចក្តីសុខយ៉ាងត្រជាក់ត្រដុំជានិច្ច ។

ចិត្តអាចតាក់តែងរូបនានាឲ្យល្អក៏បាន ឲ្យអាក្រក់ក៏បាន តាមកំឡាំងការចេះដឹងនឹងការស្ទាត់ទៀវបស់ខ្លួន ដូចបានបរិយាយមកនេះឯង។

ក្នុងកុរុធម្មជាតក តិកនិបាត

ព្រះទេពសត្ថា កិម-គ្ឃរ បន្ទមង្គលោ

ក្រុមដំនុំទ្រឹះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

មានបុរសពីរនាក់ជាសំឡាញ់ទឹងគ្នានៅក្នុងក្រុងសាវត្ថី. ព្រមគ្រៀងគ្នាទៅបួសក្នុងសំណាក់តិក្ខតាបសមួយ ។ អ្នកចាស់ពីរនាក់នោះវៀលបួសហើយទោះទៅកាន់ទីណាមួយ ក៏ច្រែនតែទៅជាមួយគ្នា ។ ថ្ងៃមួយ, តិក្ខតាបសពីរបួបនោះ នាំគ្នាទៅងូតទឹកក្នុងស្ទឹងអចិរវតី លុះងូតរួចហើយក៏ឡើងមកអែកដៅថ្ងៃលើផកខ្លាច់ អង្គុយនិយាយសំណេះសំណាលគ្នាពីរឿងនេះខ្លះនោះខ្លះតាមដែលនឹកឃើញ ។ ខណៈនោះមានបក្សីហង្សមួយគូហើរមកតាមអាកាស, តិក្ខុកំឡោះមួយរូបក្រឡេកទៅឃើញក៏ចាប់ដុំក្រួសច្រូនទឹងចោលបក្សីហង្សនោះ ហើយច្បាប់ទៅតិក្ខុជាសំឡាញ់ថា លោកចាំមើល, ខ្ញុំទឹងចោលក្អែកហង្សមួយដោយដុំក្រួសនេះ ។ – លោកមិនអាចចោលត្រូវទេ ។ – ឃើលោកហ៊ានមើលងាយ, នែ, ក្អែកខាងអាយនេះ ខ្ញុំមិនចោលទេ, ខ្ញុំចោលឲ្យត្រូវក្អែកខាងនាយឯណោះផង ។ – ខ្ញុំ, បើក្អែកខាងនាយនោះ ក៏តែតែមិនអាចទៅទៀតហើយ ។ – អើ លោកចាំមើលចុះ, ថាហើយក៏ចាប់ដុំក្រួសគ្រវែងចោលទៅពីខាងក្រោយហង្ស ។ ឯហង្សឮស្នូរសន្ធឹកដុំក្រួស ក៏ងាកក្បាលមើលមក, តិក្ខុកំឡោះនោះចាប់ក្រួសមួយដុំផ្សេងទៀត ចោលសំដៅក្អែកហង្សខាងនាយ

ត្រូវមុតធ្លុះលៀនចេញមកតាមក្បែកខាងអាយ ។ បក្សីហង្សនោះ ក៏
ស្រែកឡើងកាច់ស្លាប់ចុះមកដល់ដើងកិកុំតាំងពីរបូរនោះ ។ ចំណែកកិកុ
តាំងឡាយដែលបិតនៅក្នុងទីនោះដែរ ឃើញហើយក៏ពោលថា "នែ
អាវុសោ លោកបួសក្នុងព្រះពុទ្ធសាសនា មិនគួរមកធ្វើអំពើបាណាតិ-
បាតយ៉ាងនេះសោះ" លុះពោលដូច្នេះហើយក៏នាំកិកុកំឡោះនោះទៅទូល
បង្គាញព្រះ ។ ព្រះបរមសាស្តាទ្រង់ត្រាស់សួរថា នែកិកុ, អ្នកឯងធ្វើ
អំពើបាណាតិបាតពិតមែនឬ? កិកុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តា
ប្រោសពិតមែន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តទៅទៀតថា នែកិកុ,
អ្នកឯងបួសក្នុងនិយ្យានិកសាសនា (សាសនាដែលស្រោចស្រង់សត្វឲ្យ
ចេញផុតពីសេចក្តីទុក្ខ) មានសភាពយ៉ែបនេះ, ព្រោះហេតុអ្វីបានជា
ប្រព្រឹត្តធ្វើអំពើលាមកយ៉ាងនេះ, អំបាលដូចយ៉ាងបណ្ឌិតអំពីបុរាណ
សូម្បីព្រះពុទ្ធមិនមានន់កើតឡើងក្នុងលោកផង គង់តែមានសេចក្តីរង្កៀស
សង្ស័យចំពោះអំពើមិនសមគួរបន្តិចបន្តួច, ឯអ្នកឯងមកបួសក្នុងសាសនា
តថាគតត្រឡាំង មិនសមបើគ្មានសេចក្តីរង្កៀសវាអែនក្នុងចិត្តបន្តិច
សោះ ។ ធម្មតាធ្វើជាកិកុត្រូវតែប្រព្រឹត្តសង្រួមកាយវាចាចិត្តមែនឬ?
កិកុទាំងឡាយក្រាបទូលអាភធនាសូមឲ្យព្រះអង្គសំដែងអតីតនិទាន អំពី
ចោរណាកបណ្ឌិតទាំងឡាយ ដែលមានសេចក្តីរង្កៀសក្នុងហេតុដែលតូច
តប្បីបន្តិចបន្តួច ។

ព្រះសម្មាសម្ពុទ្ធទ្រង់នាំអតីតនិទាននោះមកសំដែងថា: កន្លងកាល
ដែលកន្លងទៅហើយ មានព្រះមហាក្សត្រិយ៍មួយព្រះអង្គទ្រង់ព្រះនាម

ធនញ្ជយកោរព្យៈ សោយរាជ្យក្នុងក្រុងឥន្ទបត្ថកន្លងដែនកុរុ, ព្រោធិសត្វ
ទៅចាប់បដិសន្ធិកើតក្នុងផ្ទៃនៃព្រះអគ្គមហេសីរបស់ព្រះរាជាអង្គនោះ លុះ
ប្រសូតមក បានដឹងក្តីមានវ័យចំរើនតាមលំដាប់ ហើយបានទៅសិក្សា
សិល្បសាស្ត្រទាំងពួងក្នុងក្រុងតក្កសិលា លុះចប់ការសិក្សាហើយត្រ-
ឡប់មកនគរវិញ, ព្រះបិតាទ្រង់តាំងព្រះពោធិសត្វក្នុងឋានៈជាឧបរាជ ។
លុះចំណេរកាលមកខាងក្រោយ អំណើះតតីព្រះបិតាទៅ, ព្រះ
ពោធិសត្វបានសោយរាជ្យ ទ្រង់រក្សាពាជធម្មិ (ធម្មិសម្រាប់ស្តេច)
១០ យ៉ាង ព្រមទាំងប្រព្រឹត្តក្សត្រធម្មិជាដ ។

ពាជធម្មិ ១០ យ៉ាងនោះ គឺ

១ – ទាន ទ្រង់ព្រះរាជទានទ្រព្យមានតំណាត់ចំពោះបុគ្គល,

២ – សីល ទ្រង់រក្សាកាយវាចាឲ្យមានសណ្តាប់រៀបរយល្អ,

៣ – បរិច្ចាគ ទ្រង់បរិច្ចាគព្រះរាជទ្រព្យជាសាធារណៈប្រយោជន៍,

៤ – អាជ្ជវ ទ្រង់មានព្រះអធ្យាស្រ័យដ៏ត្រឹមត្រង់ក្នុងសុចរិតធម៌,

៥ – មទ្ទវ ទ្រង់មានព្រះអធ្យាស្រ័យទន់ឆ្ងាយព្រះកាយដ៏ខ្ពង់ខ្ពស់សុភាព,

៦ – តបៈ ទ្រង់មានព្យាយាមកំចាត់សេចក្តីអាក្រក់ចេញ (រក្សា-
ឧបោសថ),

៧ – អក្កោធៈ ទ្រង់មិនក្រេវក្រោធដោយខុសខ្នង (មានមេត្តា),

៨ – អវិហឹសា ទ្រង់មិនបៀតបៀនអ្នកដទៃដោយអយុត្តិធម៌,

៩ – ខន្តិ ទ្រង់ចេះអត់ធន់ចំពោះហេតុការណ៍ផ្សេងៗ,

១០- អរិយោធន ទ្រង់មិនធ្វើឲ្យទុសចកហេតុដ៏គ្រឹមត្រូវ ឬមិនច្រឡាតទៅតាមលោកធម៌ ឬក៏មិនរំលោភបំពានលើច្បាប់ ។

ឯកុរុធម៌នោះបានដល់សីល ៥ គឺ

១- ការមិនសម្លាប់សត្វ,

២- ការមិនកាន់យូរទ្រព្យដែលគេមិនបានឲ្យ,

៣- ការមិនប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ

៤- ការមិនពោលពាក្យកុហក,

៥- ការមិនផឹកយូរទឹកស្រវឹង ។

ពោធិសត្វ រក្សាកុរុធម៌គឺសីល ៥ នោះឲ្យបរិសុទ្ធល្អយ៉ាងណា ឯជន ១០ នាក់ទៀតគឺ ព្រះមាតា, ព្រះអគ្គមហេសី, ឧបពជ្ឈាព្រះអនុជនៃព្រះពោធិសត្វ, ព្រាហ្មណ៍ជាបុរោហិត, រជ្ជគ្គាហៈ (អមាត្យអ្នកកាន់ខ្សែក់ដី), នាយសារថី (អ្នកបរពលរថ), សេដ្ឋី, មហាមាត្យអ្នករាល់ស្រែរដើម្បីហូតពន្ធ, នាយឆ្មាំទ្វារ, នគរសោភិនី (ស្រីពេស្យា) ក៏បានរក្សាសីល ៥ បរិសុទ្ធដូចជាព្រះពោធិសត្វយ៉ាងនោះដែរ ។ មិនត្រឹមតែប៉ុណ្ណោះ ពោធិសត្វបានឲ្យគេសាងទានសាលា (សាលាសម្រាប់ឲ្យទាន) ៦ខ្នងគឺ ត្រង់ទ្វារនគរ ៤, ត្រង់កណ្តាលនគរ ១ ត្រង់ទ្វារព្រះពជដំណាក់ ១ ទ្រង់ចំណាយព្រះពជទ្រព្យ ៦ សែនកហាបណៈពល់ៗថ្ងៃ ព្រះពជទានដល់សមគ្គជនក្នុងទីបចាំងមូល ។ ពោធិសត្វទ្រង់មានព្រះ

អជ្ឈាស្រ័យត្រែកអវតែកក្នងាន, ម្ល៉ោះហើយ កិត្តិស័ព្ទរបស់ព្រះអង្គកំល្បី
រន្ធឹពុជ្ឈាយទៅពេញជម្ពូទីបតាំងមូល ។

កាលនោះ កងដែនកាលិង្គ:, ព្រះបាទកាលិង្គ:ខ្លាំងសោយរាជ្យ
ក្នុងក្រុងទន្តបុរី ។ ក្នុងដែនរបស់ព្រះរាជាអង្គនោះ គ្មានក្ងែងសោះ,
ម្ល៉ោះហើយក៏កើតទុរភិក្សក្នុងដែនតំាងមូល ។ ភ័យតំាង ៣ គឺជាតភ័យ,
រោគភ័យ, ទុព្ភិក្ខភ័យ ក៏កើតឡើងដល់មនុស្សតំាងឡាយ ព្រោះវិបត្តិនៃ
អាហារ ។ មនុស្សតំាងនោះ កាលបើត្រូវភ័យតំាង ៣ មានជាតភ័យ
ជាដើមបៀតបៀនហើយ ក៏នាំគ្នាដឹកដៃកូនជញ្ជូនចៅត្រាច់ទៅកងទីនេះ
ខ្លះ ទីនោះខ្លះ ដើម្បីស្វែងរកអាហារនឹងសេចក្តីសុខរៀងៗខ្លួន ។ មិន
តែប៉ុណ្ណោះ ពួកប្រជាពលក្នុងដែនតំាងមូល ក៏កើតចលាចលលើកគ្នា
ទៅកាន់ក្រុងទន្តបុរី, សំដែងអាការហាក់ក្រៀវនៅជិតខ្លាវព្រះរាជ-
ដំណាក់នៃព្រះបាទកាលិង្គ: ។ ខណៈនោះ ព្រះរាជាខ្លាំងប្រហាប់ត្រង់
បង្ហួច ខ្លាំងឮសម្រែកដ៏សំបើមអស្ចារ្យនោះ ទើបត្រាស់សួរថា ពួក
មហាជនតំាងនោះ នាំគ្នាមកធ្វើអ្វីច្រើនម្ល៉ោះ? ជនតំាងឡាយក្រាបទូល
ថា បពិត្រមហារាជ ភ័យ ៣ យ៉ាងកើតឡើងក្នុងដែនតំាងមូល, ក្ងែង
មិនធ្លាក់ចុះមកសោះ, សំបូងស្លូតក្រៀមក្រោះវិនាសហិនហោចអស់,
ការអត់ឃ្លានក៏កើតឡើងត្រម, មនុស្សតំាងឡាយបរិភោគភោជនមិនល្អ
ត្រូវពេគបៀតបៀន ក៏នាំកូនចៅត្រាច់ទៅកាន់ទីផ្សេង។ កាលបើដូច្នេះ
សូមព្រះអង្គញ៉ាំងក្ងែងឲ្យធ្លាក់ចុះមក ។ ព្រះរាជាខ្លាំងត្រាស់សួរថា
ស្តេចពីបុពណាកាលបើគ្មានក្ងែងធ្លាក់ចុះមកទេ តើខ្លាំងធ្វើដូចម្តេច?

- បពិត្រព្រះមហាវជ, ស្តេចពីបុពណ កាលបើគ្មានភ្លៀងធ្លាក់ចុះមក តែងទ្រង់ចំណាយព្រះពជទ្រព្យឲ្យជាទាន ហើយទ្រង់អធិដ្ឋានឧបោសថ សមាទានសីល រួចហើយទ្រង់ចូលទៅគាប់បន្ទប់ដ៏មានសិរីផ្ទុអស់ ៧ថ្ងៃ លើកម្រាលស្នៅ ភ្លៀងក៏ចាប់ធ្លាក់ចុះមកក្នុងកាលនោះ ។ ព្រះពជាទ្រង់ទទួលធ្វើតាមមានឲ្យទានជាដើម ដោយសព្វគ្រប់ហើយ, ភ្លៀងក៏នៅតែមិនធ្លាក់ចុះមកសោះ, ទើបត្រាស់សួរទៅរអមាត្យទាំងឡាយថា កិច្ចដែលគួរធ្វើ យើងបានធ្វើរួចអស់ហើយ, ភ្លៀងក៏នៅតែមិនធ្លាក់ចុះមក តើឥឡូវនេះ ឲ្យយើងធ្វើដូចម្តេចទៀត ? អមាត្យទាំងឡាយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស, ព្រះចាតធនញ្ជយកោរព្យៈសោយរាជ្យក្នុងនគរឥន្ទបត្តដែនកុរុ មានដំរីជាមង្គលមួយឈ្មោះអញ្ជនសន្ទិកៈ កាលបើយើងនឹងទៅនាំយកដំរីនោះចូលមក, ភ្លៀងមុខតែនឹងធ្លាក់ចុះមកពុំខាន ។ - ឧ ព្រះពជាអង្គនោះទ្រង់សម្បូរដោយពលនឹងពាហនៈច្រើនណាស់ ទោះបីអ្នកណាក៏មិនអាចហ៊ានទៅតម្រាមកំហែងបានឡើយ កាលបើដូច្នេះ យើងនឹងទៅនាំយកដំរីរបស់ស្តេចនោះមកដូចម្តេចបាន ? - សូមទ្រង់ព្រះមេត្តាប្រោស, យើងមិនត្រូវទៅតម្រាមកំហែង ឬធ្វើចំបាំងជាមួយនឹងព្រះចាតធនញ្ជយកោរព្យៈនោះទេ ព្រោះថាព្រះពជាអង្គនោះ ទ្រង់មានព្រះអធ្យាស្រ័យរីករាយក្នុងការបរិច្ចាគទានណាស់ ប្រសិនបើមានគេសុំព្រះសីសៈក្តី សុំព្រះនេត្រក្តី ឬសុំព្រះរាជសម្បត្តិទាំងមូលក្តីរបស់ព្រះអង្គ ។ ក៏អាចកាត់ព្រះសីសៈ ខ្ពក់ព្រះនេត្រ ឬប្រគល់រាជសម្បត្តិឲ្យដល់សូមនោះបានដែរ ទើបចាប់ធ្វើយាយទៅថ្វាយតែម

ដំរីមួយប៉ុណ្ណោះ ដំរីនោះបើយើងសុំហើយ ព្រះពុទ្ធអង្គនោះប្រហែលជាមិនជូនព្រះឱយប៉ុន្មានទេ មុខតែនឹងព្រះពុទ្ធទានឲ្យដល់យើងពុំខាន ។

- អើបើដូច្នោះ តើអ្នកណាអាចទៅសុំដំរីនោះបាន? - សូមទាន មេត្តាប្រាប, ពួកព្រាហ្មណ៍ ។ ព្រះពុទ្ធក្រែងតែស់បង្គាប់ឲ្យអញ្ជើញពួកព្រាហ្មណ៍ចាំង ៨ នាក់មកដប់លៀង ដោយគ្រឿងសក្ការៈនឹងសេចក្តីកប់អាន រួចហើយក្រែងបញ្ជូនទៅឲ្យសុំដំរី ។ ព្រាហ្មណ៍ចាំងនោះ នាំយកស្បៀងទៅតាមខ្លួន គាំងតាន់យកតេទជាអ្នកដំណើរ ដើរទៅដោយស្មុគស្មាញ, សម្រាកទៅនាពាក់កណ្តាលផ្លូវតែមួយយប់ប៉ុណ្ណោះ ក៏បានដល់ទៅនគរវេន្ទបត្តកនឹងដែនកុរុ ហើយឈប់សម្រាកនៅខួលទានបរិភោគចំអែតតាយក្នុងសាលាទានទៀបទ្វារនគរអស់ពីរបីថ្ងៃ ហើយទើបសួរគេថា ថ្ងៃណាព្រះពុទ្ធក្រែងស្តេចមកគាន់ភោជនេះ? មនុស្សគាំងឆ្លើយបានប្រាប់ថា ព្រះពុទ្ធរបស់យើង ស្តេចតែងមកកន្លងមួយយប់ក្នុង ៣ ថ្ងៃ គឺថ្ងៃទី ១៤ ខ្ញុំង ថ្ងៃទី ១៥ ខ្ញុំង នឹងថ្ងៃទី ៨ ខ្ញុំង, តែថ្ងៃស្អែកជាថ្ងៃទី ១៥ ពេញបូណ៌មី, ព្រះពុទ្ធនឹងយាងមកកន្លងថ្ងៃស្អែកនេះពុំខាន ។ លុះដល់ថ្ងៃព្រឹកស្អែកឡើង ព្រាហ្មណ៍គាំង ៨ នាក់ក៏នាំគ្នាទៅឈរចាំត្រង់ទ្វារនគរខាងកើត ។ រោចិសត្វ, កន្លងវេលាព្រឹក ក្រែងស្រង់ព្រះគន្ធាលុបលាបព្រះអង្គរួចហើយ ក្រែងប្រដាប់ព្រះអង្គដោយគ្រឿងអលង្ការគាំងពួង ហើយក្រែងឡើងគង់លើដំរី ជាព្រះទីនាំងដ៏ប្រសើរដែលគេតាក់តែងថ្វាយ, ក្រែងស្តេចទៅគាន់សាលាទានតាមទ្វារនគរខាងកើត ដោយមានពួកជនចំរើរជារាប្រទក្សិនតាមដង្ហែព្រះអង្គ, លុះដល់

ហើយ ទ្រង់យាងចុះពីព្រះទីនាំងចូលទៅកាន់សាលាទាន, ទ្រង់ព្រះពរជាទានកត្តដល់ពួកសម្ភមចំនួនជា ៧ឬ៨ នាក់ ដោយផ្ទាល់ព្រះហស្ត រួចហើយទើបត្រាស់បង្គាប់ឲ្យគេឲ្យទានតាមចំនង់នេះ, លុះត្រាស់បង្គាប់ដូច្នេះហើយ ព្រះរាជាទ្រង់ឡើងគង់លើដំរីយាងទៅកាន់ទ្វារខាងត្បូង ។ ព្រាហ្មណ៍ទាំង ៨ នាក់នោះ កាលដែលទៅឈរចាំត្រង់ទ្វារខាងកើត មិនបានឧកាសសោះ ដោយមានពួកតម្រួតនៅការពារម៉ាំមួនពេក ទើបនាំគ្នាទៅចាំទ្វារខាងត្បូងទៀត ឈរលើដីខ្ពស់មិនឆ្ងាយប៉ុន្មានអំពីទ្វារវង់ចាំមើលព្រះរាជាទ្រង់ស្តេចមក, លុះឃើញព្រះរាជាទ្រង់យាងមកដល់ហើយ ក៏លើកដៃច្រងឡើងគ្រាបទូលថា ‘‘សូមព្រះរាជតេជះដំកល់លើត្បូង, សូមព្រះអង្គមានជ័យជំនះ’’ ។ ព្រះរាជាទ្រង់ទតទៅឃើញហើយក៏ត្រាស់បង្គាប់ឲ្យញ៉ាំងដំរីឲ្យដាក់បែរទៅរកព្រាហ្មណ៍ទាំងនោះ ហើយទ្រង់ត្រាស់សួរថា ម្នាលព្រាហ្មណ៍ទាំងឡាយ, អ្នករាល់គ្នាត្រូវការអ្វី? ព្រាហ្មណ៍ទាំងឡាយ គ្រាបទូលសរសើរគុណព្រះពោធិសត្វថា

បពិត្រព្រះជនាធិបតី ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា បានដឹងច្បាស់នូវវណ្ណៈគឺសទ្ធានឹងសីលរបស់ព្រះអង្គថា ព្រះរាជាដែលបរិបូណ៌ដោយសទ្ធានឹងសីលដ៏លើសលុបយ៉ាងនេះ ប្រសិនបើមានគេសូមជីវិត ក៏គង់តែទ្រង់ប្រទានឲ្យដែរ ឱនិងបាច់និយាយទៅថ្វីដល់ដំរីជាសត្វតិរច្ឆាន ព្រោះហេតុនេះ ទូលព្រះបង្គំជាខ្ញុំ មកគ្រាបបង្គំសុំដំរីរបស់ព្រះអង្គ ដែលមានសម្បុរដូចផ្កាអញ្ជ្ញនេះយកទៅថ្វាយព្រះបាទកាលិង្គៈ ឯដែនកាលិង្គៈ សូមព្រះអង្គទ្រង់ជ្រាបនូវដំណើររបស់ទូលព្រះបង្គំជាខ្ញុំ ដែលមកកាន់ទីនេះចុះ ។

ព្រះពោធិសត្វ ទ្រង់ព្រះសណ្ដាប់ពាក្យព្រាហ្មណ៍ទាំងនោះហើយ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ទាំងឡាយ យើងនឹងឲ្យដំរីនេះមួយអាទ្វី ដោយគ្រឿងអលង្ការទាំងប៉ុន្មាន ដែលតាក់តែងស្រេចស្រាប់ទៅជាប់ខ្លួនដំរីព្រមទាំងហ្វូងដំរីដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយនាំយកដំរីនេះព្រមទាំងហ្វូងដំរីទៅតាមសេចក្ដីប្រាថ្នាចុះ ។ ព្រះមហាសត្វកំពុងតែលើកដំរី ប្រទានដោយព្រះឋានៈដ៏ធំនេះហើយ ក៏ឃាត់ចុះអំពីកនៃដំរីទ្រង់ព្រះតម្រិះថា «បើកន្ទុងណាមិនទាន់មានគ្រឿងប្រដាប់តាក់តែងទៅឡើយទេ អាត្មាអញនឹងតាក់តែងដំរីនេះដោយគ្រឿងប្រដាប់ឲ្យមានសព្វគ្រប់រួចហើយសឹមឲ្យ» ក៏ទ្រង់ពិនិត្យមើលទៅមិនឃើញមានខ្វះត្រង់កន្ទុងណាមួយសោះ ទើបទ្រង់យាងប្រទក្សិណដំរីបីដុំហើយលើកប្រមោយដំរីជាក់លើដៃព្រាហ្មណ៍ទាំងឡាយ ហើយទ្រង់យកកុន្ទីមាសមកប្រួចទឹកដែលអប់ដោយក្លិនឆ្ងាយ ព្រះពរជាទដល់ព្រាហ្មណ៍ទាំងឡាយ ។ ព្រាហ្មណ៍ទាំង ៨ នាក់នោះ កាលបើបានខ្លួនដំរីព្រមទាំងហ្វូងដំរីហើយ ក៏នាំគ្នាឡើងជិះលើខ្នងដំរីនាំទៅថ្វាយព្រះពរជាក្រុងពារាណសីជាដែនកាលិង្គៈ ។ សូម្បីដំរីជាមង្គលនោះចូលមកដល់ហើយ ក្មេងក៏នៅតែមិនព្រមចុះមកតាមបំណងឡើយ ។ ព្រះពរជាទ្រង់ត្រាស់សួរគេទៀតថា «ព្រោះហេតុអ្វីបានជាដូច្នេះ?» ទើបទ្រង់ព្រះសណ្ដាប់ជ្រាបដំណឹងឆ្លាស់ថា «ព្រះបាទជនញ្ញយគោរព្យៈ ទ្រង់រក្សាក្សត្រធម៌ដោយឆាប់ខ្លួន ព្រោះហេតុនោះ បានជាកន្ទុងដែនរបស់ព្រះពរជាអង្គនោះ មានក្មេងព្រាហ្មណ៍ជាប់ចុះមករឿយ ។ កន្ទុងរាល់កន្ទុងទៅមុខ ប្រវែង ១០ ថ្ងៃ

ម្ដង ។ ឯក្ងែនដែលបង្អុរចុះមកនោះគឺដោយគុណានុភាពរបស់ព្រះ
ពាជាតែម្យ៉ាង មិនមែនដោយគុណានុភាពនៃសត្វតិរច្ឆាននេះប៉ុន្មានទេ"
លុះខ្ញុំជាបការណ៍ច្បាស់ហើយ ទើបគ្រាស់បញ្ជូនពួកព្រាហ្មណ៍ទាំង
អស់មាត្យទៅឯនគរវេនុបត្ថម្ភង្គខ្ញុំតដោយព្រះតម្រាស់ថា បើដូច្នេះទេ,
អ្នកទាំងឡាយចូរនាំដំរីដែលគាក់តែងដោយគ្រឿងអលង្ការ ព្រមទាំង
បរិវារនេះ ត្រឡប់ទៅថ្វាយព្រះបាទធនញ្ជយកោរព្យវិញ បើព្រះពាជាអង្គ
នោះខ្ញុំរក្សាកុរុធម្មណា, ចូរសុំកត់បម្ងន់កុរុធម្មនោះជាក់ច្បាស់ដំបាមាស
ហើយនាំមក ។ ពួកជនទាំងនោះ នាំដំរីទៅថ្វាយព្រះបាទធនញ្ជយ-
កោរព្យៈហើយក្រាបបង្គំទូលថា "បពិត្រព្រះសម្មតិទេព ដំរីនេះសូមទ្រី
ទៅដល់ហើយ ក្ងែនក៏នៅតែមិនជ្ងាក់ចុះមកក្នុងដែនរបស់យើង, តទ្បូវ
បានឮថាព្រះអង្គខ្ញុំរក្សាកុរុធម្ម ឯព្រះពាជារបស់យើងខ្ញុំចង់រក្សាកុរុ
ធម្មនោះដែរ បានជាខ្ញុំគ្រាស់បញ្ជូនឲ្យយើងមកសុំបម្ងន់កុរុធម្មនោះ
អំពីព្រះអង្គ ចុះទុកនឹងដំបាមាសនេះហើយនាំយកទៅ, ដោយហេតុ
នេះ សូមព្រះអង្គខ្ញុំព្រះមេត្តាប្រោសប្រទានកុរុធម្មនោះដល់យើង
ទាំងឡាយ" ។

ព្រះបាទធនញ្ជយកោរព្យៈខ្ញុំគ្រាស់ថា ម្នាលអ្នកទាំងឡាយ,
យើងរក្សាកុរុធម្មពិតមែន តែឥឡូវនេះ យើងមានសេចក្ដីរង្កៀសក្នុងកុរុធម្ម
ក្រែងកុរុធម្មរបស់យើងនោះមានការសាហ្មង, ដូច្នេះ យើងពុំអាចឲ្យកុរុធម្ម
ដល់អ្នកទាំងឡាយទេ ។

(មានត)

ព្រះមហា មៀប-ជ័យ វិគ្គសារ៉ាវ័ន

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមេ សេដ្ឋន្តិលោកគ្គំ នត្វា ធម្ម សគម្ភីរំ
វន្ទេ សង្ឃំ វិសុទ្ធញ្ច ទក្ខិណេយ្យំ ឥវង្គណំ ។

កន្លងាន់ដើមនៃធម៌ទេសនានេះ ខ្ញុំព្រះករុណាសូមថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គប្រសើរវិសេស ជាកំពូលនៃទេវតានឹងមនុស្សក្នុងត្រៃលោកផង ; សូមថ្វាយបង្គំចំពោះព្រះនវលោកុត្តរធម៌ដ៏មានគម្ភីរភាពផង សូមថ្វាយបង្គំចំពោះព្រះអរិយសង្ឃមានព្រះវិន័យដ៏ស្អាត ជាទក្ខិណេយ្យបុគ្គល ឥតមានទីទួលគឺពាក្យកិលេសផង ; ដោយអំណាចនៃវត្ថុនប្បញ្ញាមនេះ សូមសេចក្តីសុខសួស្តី ចូរមានដល់យើងខ្ញុំផង ដល់សាធុសប្បុរសទាំងឡាយផង សព្វកាលរៀងទៅ ។

ពីព្រោះ បើរំ ឋន្ទាប់អំពីបទនមស្សការនេះទៅ សូមលើកយកពុទ្ធកាសិតកន្លងមកក្នុងសូត្រ ដែលទេវតាទូលសួរអំពីហេតុជាប្រធាននៃសេចក្តីវិនាសរបស់បុគ្គល, ហើយព្រះបរមសាស្តាទ្រង់ត្រាស់ឆ្លើយតបដោយបទគាថាទី ១ ថា :

สุวิชาโน ภวึ ฮোติ สุวิชาโน ปราภวো
ธมฺมกาโม ภวึ ฮোติ ธมฺมเทฺวสฺยี ปราภวো

แปลว่า "บุรุษบุคคลผู้มีความเจริญ ผู้ฉลาดแต่ดีแต่ชั่ว ย่อมรู้ได้โดยง่าย, บุรุษบุคคลผู้มีความเสื่อม ก็ผู้ฉลาดแต่ดีแต่ชั่วย่อมรู้ได้โดยง่ายเหมือนกัน (ฉันนั้น) คนผู้รักธรรม ชื่อว่าผู้มีความเจริญ, คนผู้เกลียดธรรม ชื่อว่าผู้มีความเสื่อม" ฯ

พระบรมครูทรงตั้งสาระสำคัญในพุทธพจน์นี้ ว่าบุคคลเป็นที่ตั้ง, มิได้ทรงตั้งธรรมเป็นที่ตั้งเลย ฯ

ต่อจากนี้ไป จะได้อธิบายเรื่องบุคคล ๒ ประเภท คือ บุคคลดี (บุคคลที่ดี) ๑ บุคคลชั่ว (บุคคลที่ชั่ว) ๑ บุคคลผู้มีความดี ชื่อว่า บุคคลดี; ผู้มีความชั่ว ชื่อว่า บุคคลชั่ว ฯ บุคคลผู้รักสุจริตธรรม ชื่อว่าผู้มีความดี; ผู้เกลียดสุจริตธรรม ชื่อว่าผู้มีความชั่ว ฯ ความดีและความชั่วนี้ มีอะไรเป็นมูลเหตุ? ความดีมีสุจริต ๓ เป็นมูลเหตุ ฯ ความชั่ว มีทุจริต ๓ เป็นมูลเหตุ ฯ

สุจริตนั้นมี ๓ คือ กายสุจริต ๑, วจีสุจริต ๑, มโนสุจริต ๑ ฯ กายสุจริตมี ๓ อย่าง คือ เว้นจากฆ่าสัตว์ ด้วยตั้งใจไม่ฆ่าสัตว์ ๑, เว้นจากลักขโมยฉกชิงวิ่งราวของผู้อื่นด้วยตั้งใจไม่ลักขโมย ๑, เว้นจากการ

ប្រព្រឹត្តិខុសកន្លងតាមតំាងឡាយ គឺមិនសេពសម្ផុតជាមួយនឹងស្ត្រីដែលមានគេហួងរៃងារក្សា ១ ។ វិបុចរិតមាន ៤ យ៉ាងគឺ រឿរចាកពោលពាក្យកុហក ១, រឿរចាកពោលពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ១, រឿរចាកពោលពាក្យអាក្រក់ មានពាក្យខ្ទេងខ្ទោះបោះបោកដល់ប្រទេចអ្នកដទៃ ១, រឿរចាកពោលពាក្យពេយពាយឥតប្រយោជន៍ ១ ។ មនោសុចរិតមាន ៣ យ៉ាង គឺ មិនមានចិត្តគិតសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃដោយគិតបម្រុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ ១, មិនមានចិត្តចង់គំនុំគុំគួន គិតប៉ងឱ្យអ្នកដទៃដល់ខ្លួវសេចក្តីវិនាស ១, គំនិតយល់ឃើញត្រឹមត្រូវពិត (សម្មាទិដ្ឋិ) ហើយប្រកាន់ខ្ជឿឯថាជាត្រូវមែន ១ ។

បពិត្រអស់លោក - អ្នកសប្បុរសតំាងឡាយ ! សុចរិតតំាង ៣ ប្រការនេះ ជាប្រធាននៃសេចក្តីចំរើន ។ បើបុរសបុគ្គលណាស្រឡាញ់សុចរិតធម៌តំាងបីប្រការនេះ បុរសបុគ្គលនោះ តែងបាននូវសេចក្តីចំរើនក្នុងលោកនេះនឹងលោកខាងមុខ (ពុកដូចជាមានស្នេហ៍មុខយ៉ាងវិសេស)ម្យ៉ាងទៀតអ្នកប្រព្រឹត្តសុចរិតធម៌ តែងប្រកបដោយគុណ ៤ ប្រការគឺអាយុ, វណ្ណៈ, សុខៈ, ពលៈ រឿរលែងតែបុគ្គលនោះមានទុបបីឡើកកម្ចមកបៀត។

មានសេចក្តីដំណាលថា ព្រះបរមពោធិសត្វរបស់យើងកាលយោនយកកំណើតកន្លងតែកូលព្រាហ្មណ៍មួយ ទៅខ្ជឿបត្រុងពាកណសី មាននាមថ្លែងជាថា ធម្មប៉ាលមាណព, ឯតែកូលព្រាហ្មណ៍នោះតែងសមាទានប្រព្រឹត្តខ្លួវសុចរិតតំាង ៣ ឬកុសលធម៌តំាង ១០ ប្រការ ជាប់ប៉ាសុខ្លួមិនឱ្យបែកធ្លាយ តំាងមិនសៅហ្មងដល់តិចតួចឡើយ ។ ជាទំនៀមរបស់

គ្រកូលនោះ គេតែងបង្ហាត់បង្រៀនប្រៀនប្រដៅកូនចៅរបស់គេ ឲ្យចេះរក្សាសុចរិតធម៌គ្រប់គ្នាជាំងអស់ ។ កាលធម្មបាលបានអាយុ ១៦ ឆ្នាំ, មាតាបិតាបានបញ្ជូនឲ្យទៅរៀនចំណេះវិជ្ជាសិល្បសាស្ត្រ អំពីសំណាក់អាចារ្យទិសាបាមោក្ខនៅនាននគរតក្កសិលា ។ លុះទៅដល់សំណាក់អាចារ្យទិសាបាមោក្ខ ក៏ចូលទៅសូមរៀនចំណេះវិជ្ជា, អាចារ្យក៏បានសាកសួរសុកទុក្ខ, បានដឹងសព្វគ្រប់ហើយ ក៏ព្រមទទួលបង្រៀន ប៉ុន្តែគ្រាន់តែទទួលមិនទាន់បានបង្រៀននៅឡើយ ព្រោះមានកិច្ចធ្វើនឹងកូនឈើជាច្រើនមុន ។ កូននោះមានអាយុ ១៦ ឆ្នាំ ដំណាលគ្នានឹងធម្មបាលកុមារដែរ ។ លុះធម្មបាលកុមារនៅបាន ២-៣ ថ្ងៃ កូនអាចារ្យនោះក៏ធ្លាក់មរណកាលស្លាប់ទៅ ។ មាតាបិតានឹងញាតិទាំងឡាយរបស់កុមារនោះក៏យំសោកស្តាយអាឡោះអាល័យតែពាល់គ្នា ។ ធម្មបាលកុមារឃើញគេយំសោកស្តាយមនុស្សស្លាប់ពីក្មេងដូច្នោះ អត់ទ្រាំពុំបាន ក៏សើចតែម្នាក់ឯង ។ អាចារ្យឃើញធម្មបាលសើចខុសច្រើនដូច្នោះ ក៏សួរថា នែមាណព យើងតើតទុក្ខនឹងកូនស្លាប់ បានជាយំស្តាយអាឡោះអាល័យ, ម្តេចក៏ឯងសើចក្អាកក្អាយនឹងយើងទៅវិញ ? ។ ធម្មបាលមាណពជំរាបអាចារ្យថា: បពិត្រលោកអាចារ្យ ! គ្រកូលរបស់ខ្ញុំបាន មិនដែលមានមនុស្សណាមួយ ស្លាប់កន្លងបានអាយុ ១០០ ឆ្នាំឡើយ លុះតែដល់កំណត់ ១០០ ឆ្នាំទើបស្លាប់ ។ ហើយគេមិនដែលយំសោកអាឡោះអាល័យចំពោះអ្នកដែលស្លាប់ទៅដូច្នេះទេ, ហេតុនេះហើយបានជាខ្ញុំបានអត់សំណើចពុំបាន ។ អាចារ្យទិសាបាមោក្ខសួរថា ចុះគ្រកូល

ឯនរក្សាធម៌អ្វីបានជាមានអាយុតំណត់ ១០០ ឆ្នាំ ទើបស្លាប់ ហើយគេមិនយំសោកអាល័យគ្នាផង? ។ ធម្មបាលកុមារជំពាក់ថា: ត្រកូលរបស់ខ្ញុំបានរក្សាកុសលកម្មបថ ១០ តាំងពីបុរាណក្នុង មិនដែលកន្ទាយកម្មបថណាមួយឡើយ ។ អាចារ្យឮហើយក៏មៅស្ងៀម បានតាំងយកសពកូននោះទៅកាន់ព្រៃស្មសាន ។ លុះត្រឡប់មកវិញនិយាយថា: នែមាណព! យើងមិនដឿឹងពាក្យដែលឯងនិយាយតាំងប៉ុន្មាននោះទេ ព្រោះតែក្រងអាងតែយើងមិនស្គាល់ ។ ឯវិជ្ជាដែលឯងត្រូវការរៀនសូត្រនោះ បង្ហើរសិនចុះទំពាំយើងបាត់ទុក្ខព្រួយបន្តិចសិន ។ តពីនោះមក អាចារ្យក៏ចេញដំណើរតម្រង់ទៅកាន់ក្រុងពារាណសី ដើម្បីបញ្ជាក់ការណ៍នោះមើលជាពិតដូច្នោះមែន ឬពុំពិតទេ? លុះដើរទៅដល់ពាក់កណ្តាលផ្លូវ ឃើញខ្មោចសត្វពពែមួយ ក៏ដើរសើចសដូតខ្មោចពពែនោះលុះដូតសុសហើយ ក៏សើចឆ្អឺឆ្អែងខ្លាំងបាន១កញ្ចប់ ប្រហែលឆ្អឺឆ្អែងមនុស្សម្នាក់ ទើបដើរយ៉ាងប្រញាប់ទៅដល់ក្រុងពារាណសី ស៊ើបសួរកន្លែងផ្ទះធម្មបាលកុមារ លុះឃើញហើយក៏ឡើងទៅអង្គុយលើផ្ទះនោះ ។ មាតាបិតារបស់ធម្មបាលកុមារក៏សួរថា អ្នកអញ្ជើញមកពីណា? ។ – ខ្ញុំហ្នឹងឯងជាអាចារ្យទិសាបាមោក្ខ នៅឧតរគង្គស៊ីលា ។ – អើ! លោកអាចារ្យបានឃើញកូនខ្ញុំឈ្មោះធម្មបាលមាណពដែរឬទេ? ។ អាចារ្យលើកដៃសំពះហើយក៏យំខ្សឹកខ្សួល ។ មាតាបិតាធម្មបាលសួរថា ហេតុអ្វីបានជាលោកអាចារ្យយំខ្សឹកខ្សួលយ៉ាងនេះ? ។ – ម្នាលអ្នកអើយ! កូនអ្នកទៅកាន់សំណាក់ខ្ញុំ សុំរៀនសិល្បសាស្ត្រ នៅបានតែ ២ ៣ ថ្ងៃមិនទាន់

តាំងបានរៀនផង ស្រាប់តែឈឺស្លាប់ទៅហើយ" រួចគាត់បង្ហាញផ្ទាំងពាក្យប្រាប់ថា: នេះហើយផ្ទាំងកូនអ្នក ខ្ញុំយកមកជូន ។ មាតាបិតានិងញាតិធម្មជាលទិយាយថា លោកអាចារ្យគ្រូកូលរបស់យើង មិនដែលស្លាប់ពីក្មេងដូច្នេះទេ ធ្លាប់តែអាយុ ១០០ ឆ្នាំទើបឈឺស្លាប់។ ហើយក៏មិនដែលយំសោកដែរ ព្រោះគ្រូកូលយើង សុទ្ធតែជាអ្នករក្សាកុសលកម្មបថ ១០ ឥតមានបែកខ្ញាយកម្មបថណាមួយទេ ឲ្យានជាមានអានិសង្សឲ្យមានអាយុកំណត់ ១០០ ឆ្នាំទើបស្លាប់, ឯធម្មជាលមាណពកូនយើង ដែលលោកអាចារ្យថាស្លាប់នោះ យើងមិនជឿទេ ។ អាចារ្យទិសាបាមោក្ខ តិតថា: ពិតមែនហើយគ្រូកូលនេះ ត្រូវដូចតាក្យធម្មជាលមាណពប្រាប់មែន ។ អាចារ្យទិសាបាមោក្ខ ក៏សួរសមាទានរៀនយកកុសលកម្មបថទាំង ១០ អំពីសំណាក់បិតាធម្មជាលកុមារ ក្នុងគ្រានោះ ។ កុសលកម្មបថទាំង ១០ នោះ ដូចបានសំដែងរៀបរាប់ខាងលើមកសព្វគ្រប់ហើយ ។

សំដែងរឿងនេះមកដើម្បីបញ្ជាក់សេចក្តីឲ្យឃើញថា អ្នកដែលស្រឡាញ់ធម៌ គឺអ្នកប្រព្រឹត្តតាមសុចរិតធម៌ទាំង ៣ ប្រការនេះ តែងមានសេចក្តីចំរើន គឺចំរើនទាំងអាយុ · កំណើត បានកើតក្នុងជាតិណា ។ តែងបរិបូណ៌ដោយភោគសម្បត្តិ បរិវារសម្បត្តិ ឧត្តមយសសក្តិ ថែមទាំងមិនសូវមានពេតាព្យាធិមកបៀតបៀនផង មានអាយុក៏យឺនយូរ មិនដែលធ្លាក់ទៅកាន់កំណើតថោកទាបឡើយ ។ សមដូចព្រះសាស្តាតថា: ធម្មោ ហវេ

រក្ខតិ ធម្មចារិំ "ធម៌តែងរក្សាបុគ្គលអ្នកប្រព្រឹត្តទៀងធម៌ជាប្រក្រតី" ។
ពាក្យថាធម៌ក្នុងន៏នេះ គឺសំដៅយកសុចរិតធម៌នោះឯង ។

ម្យ៉ាងទៀត មានតុទ្ធកាសិតសំដែងថា បើបុរសបុគ្គលណាបាន
ប្រព្រឹត្តសុចរិតធម៌ត្រឹមត្រូវល្អហើយ រមែងបានអានិសង្ស ៥ យ៉ាងគឺ

១- អត្តាបិ អត្តានំ រក្ខតិ ខ្លួនឯងនឹងមិនតិះដៀលខ្លួនឯង ។

២- អនុវិច្ច វិញ្ញូ បសំសន្តិ វិញ្ញូជន គឺអ្នកដឹងការពិតចាំឯង
ល្អាយ កាលពិនិត្យទៅឃើញហើយ តែងសរសើរ ។

៣- កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កិត្តិសព្ទដ៏ល្អរមែង
ខ្ចរខ្ចាយសុសសាយទៅ ។

៤- អសម្មុឡ្ហោ កាលំ ករោតិ លុះអ្នកប្រព្រឹត្តសុចរិត ធ្វើ
មរណកាលទៅនឹងមិនវង្វេងវង្វាន់គាន់ច្រឡំស្មារតី ។

៥- សុគតិំ សគ្គំ លោកំ ឧបបជ្ជតិ ដល់ទំលាយខ្លួនទៅ
តែងទៅកាន់សុគតិសួគ៌ទេវលោក ។

ចើបុគ្គលណាបានសមាទានកាន់យកខ្លួនតុសលកម្មបថ ឬ សុចរិត
ចាំង ១០ ប្រការនេះហើយ ឈ្មោះថាបានវៀរចាក អកុសលកម្មបថ ឬ
ទុច្ចរិតចាំង ១០ ប្រការនោះដែរ ។

ឯទុច្ចរិតនោះមាន ៣ ប្រភេទ គឺ ១- កាយទុច្ចរិត, ២- វចីទុច្ចរិត,

៣ - មនោទុច្ចរិត ។ កាយទុច្ចរិតមាន ៣, វចីទុច្ចរិតមាន ៤, មនោទុច្ចរិតមាន ៣, រួមត្រូវជាទុច្ចរិតមាន ១០ ប្រការ ។

ឯកាយទុច្ចរិត ៣ នោះគឺ ១ - ការសម្លាប់សត្វដោយខ្លួនឯង ឬប្រើគេឲ្យសម្លាប់ ; ២ - ការលួចលាក់ឆក់ដណ្តើមទ្រព្យគេដោយខ្លួនឯង ឬ ក៏ប្រើគេឲ្យលួចលាក់ឆក់ដណ្តើម ; ៣ - ការប្រព្រឹត្តខុសកន្លងកាមទាំងឡាយ គឺសេពសមជាមួយនឹងស្ត្រីដែលមានគេហួងហែងរក្សា ។ វចីទុច្ចរិត ៤ នោះគឺ ១ ការពោលនូវពាក្យកុហក ; ២ និយាយពាក្យញុះញង់ បំបែកបំបាក់អ្នកដទៃ ; ៣ និយាយពាក្យអាក្រក់ ; ៤ និយាយពាក្យរោតរាយឥតប្រយោជន៍ ។ មនោទុច្ចរិត ៣ គឺ ១ ការសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ ដោយគិតចង់នឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ; ២ ចិត្តចង់គំនុំគុំគួន គិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្តីវិនាស ; ៣ គំនិតយល់ខុសហើយប្រកាន់ខ្ជាប់ជាគ្រូ ។ ទុច្ចរិតទាំង ៣ ប្រភេទនេះ ជាប្រធាននៃសេចក្តីវិនាស ។ បុរសបុគ្គលអ្នកប្រព្រឹត្តទុច្ចរិតហើយ ឈ្មោះថាជាអ្នកស្អប់សុចរិតធម៌វិញ, អ្នកដែលស្អប់ធម៌នោះ តែងតែប្រព្រឹត្តទុច្ចរិតទាំង ៣ ប្រភេទ គឺ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ។

បើបុរសបុគ្គលណាប្រព្រឹត្តទុច្ចរិតទាំង ៣ ប្រភេទនេះ ត្រង់ទុច្ចរិតណាមួយហើយ បុរសបុគ្គលនោះតែងបានសេចក្តីវិនាសពុំខាន ។

មានសេចក្តីដំណាលថា: កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ លោកសក្ការៈកើតឡើងក្នុងព្រះពុទ្ធសាសនាជាច្រើន ពួកអន្យតិរ្ថិយ៍កើតសេចក្តីច្រណែន ក៏ប្រើនាងចិញ្ចមាណវិកា ជាស្ត្រីមានរូប

ល្អ ឲ្យទៅពោលពាក្យបង្អាប់ព្រះបរមសាស្តា ។ នាងនោះបានយកឈើមកចង់វុំផ្លូវបន្ទឹងនោះ សំដែងអាការដូចជាស្ត្រីមានគតិ ។ កន្លងពេលដែលព្រះសម្ពុទ្ធកំពុងសំដែងធម៌ទេសនា ក៏ទៅសំដែងកិរិយាកន្ត័កណ្តាលបរិស័ទ ហើយពោលពាក្យមួលបង្កាច់ព្រះអង្គ ។ ពួកមហាជនកំពុងស្តាប់ធម៌ទេសនាស្រលាំងកាំងគ្រប់គ្នា ។ ពេលនោះ ក្តៅក្រហាយដល់ព្រះឥន្ទ្រ ។ បើកទិព្វចក្ខុមើលមកឃើញក៏គិតថា "យីអើ ! នាងចិញ្ចមាណវិកានេះ ចរិ្រ្តណាស់តើ ! ទៅនិយាយមួលបង្កាច់ដោយពាក្យអសទ្ធម្ម ចំពោះព្រះបរមសាស្តាដែលជាបុគ្គលមិនមានទីតួល គឺកិលេស" ។ ព្រះឥន្ទ្រនិម្មិតខ្លួនធ្វើជាសត្វកណ្តុរចុះមកកាត់វច្ចុលទៅកាត់ខ្សែចំណង ជាប់ជាន់ដុំឈើមកត្រូវលើខ្នងដើងបែកចេញឈាមក្នុងទីកណ្តាលពួកបរិស័ទ ពួកមហាជនឃើញអស្ចារ្យដូច្នោះហើយក៏នាំគ្នាដេញវាយនាងនោះ ខ្លះតើសបានដុំដី ខ្លះដំបង ដេញចោលតាមគ្រោយ ។ គ្រាន់តែរត់ឆ្ងាយបន្តិចទៅ ផែនដីក៏បែកសម្លាកជា ២ ភាគ ស្រូបនាងចិញ្ចមាណវិកា ធ្លាក់ទៅសោយទុក្ខក្នុងនរកឈ្មោះមហាអវីចិ ដរាបដល់សព្វថ្ងៃនេះ ។

សំដែងរឿងនេះមកដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថា បុរសបុគ្គលអ្នកប្រព្រឹត្តទុច្ចរិត កុំថាឡើយតែដល់ទៅវាយដំច្រឹងគាប់សម្លាប់ដោយកាយ សូម្បីគ្រាន់តែនិយាយពាក្យអាក្រក់ តិរវាចាទុច្ចរិតណាមួយ ក៏គង់បានរសជាតិនោសព្វំខាន ។

កាលបើសាធុសប្បុរសទាំងឡាយ ប្រាថ្នាចង់បានសេចក្តីសុខ
សេចក្តីចំរើន គួរតែស្រឡាញ់ធម៌ គឺប្រតិបត្តិតាមសុចរិតធម៌ ព្រោះ
សុចរិតធម៌ ជាឧបាយនៃសេចក្តីចំរើន, ទុច្ចរិតធម៌ជាប្រធាននៃសេចក្តី
វិនាស ។

សំដែងមកអំពីកវីបុគ្គលទំនឹងបកកវីបុគ្គលក៏ល្មមទំនឹងបញ្ចប់តាមគួរដល់
កាលវេលាហើយ តែមុនទំនឹងបញ្ចប់នេះ សូមថ្វាយព្រះពរជ័យសួស្តី
ចំពោះព្រះករុណាជាម្ចាស់ជីវិត ព្រះបិយមហាក្សត្រ ទ្រង់ជាប្រមុខ
របស់ប្រជាជន ក្នុងកម្ពុជរដ្ឋ នៅអស់លោកនាម៉ឺនសព្វមុខមន្ត្រីគ្រប់
តំណែង . សូមទ្រង់ជាន់ប្រកបទំនឹងសូមឲ្យជាន់ប្រកបដោយសិរីសុខ
មហាសម្បត្តិ ព្រមទាំងសូមឲ្យខេមរជនក្នុងកម្ពុជរដ្ឋទាំងមូល ដល់នូវ
សេចក្តីលូតលាស់ក្នុងអារ្យធម៌កុំបីអាក់ខានឡើយ ។

ប្រវត្តិការណ៍ខ្មែរមុនសម័យ

លោកមាស-ធាន់ ឃោសក:នៃក្រុមឃោសនាការកម្ពុជា

ជាកម្រងតំណែលៅ ភូមិសាស្ត្រ — ប្រវត្តិសាស្ត្រ ភាសាវៃ

"ក្នុងគ្រាដែលព្រះមហាក្សត្រីយ៍ខ្មែរ វង្សសុរិយវ៉ន្ទបានគ្រងរាជ-សម្បត្តិក្នុងប្រទេសកម្ពុជា រវាងពុទ្ធសករាជ ១៩៤៥-១៧២៩ ខម(ខ្មែរ) បានផ្សាយអំណាចចូលទៅគ្រប់គ្រងដែនដី ដែលជាប្រទេសយៃសព្វថ្ងៃនេះទាំងអស់ បានតាំងរាជធានីសម្រាប់ចាត់ការគ្រប់គ្រងទឹកក្រុងនានាក្នុងប្រទេសជារៀងរាល់ខែ គឺ

ក្រុងលពប៊ុរី សម្រាប់គ្រប់គ្រងបណ្តាទឹកក្រុងជវៃ ដែលនៅតាមកូមិភាគខាងត្បូងនៃពាជអាណាចក្រឌ្វារវតី,

ក្រុងសុខោទ័យ សម្រាប់គ្រប់គ្រងទឹកក្រុងនានា ដែលនៅតាមកូមិភាគខាងជើងនៃពាជអាណាចក្រឌ្វារវតី,

ក្រុងសិរីទេព សម្រាប់គ្រប់គ្រងទឹកក្រុងនានា ដែលនៅតាមកូមិភាគជួរភ្នំនាបដីខ្ទេសាក់,

ក្រុងភីម៉ាយ សម្រាប់គ្រប់គ្រងទឹកក្រុងនានា ដែលនៅលើទឹកដីខ្ពស់ភាគខាងត្បូង,

ក្រុងសាកលនគរ សម្រាប់គ្រប់គ្រងក្រុងនានា ដែលនៅលើ
ទីដីដ៏ខ្ពស់ភាគខាងជើង ។

បណ្តាទីក្រុងបុរាណរបស់ខ្មែរ (ខ្មែរ) ទាំងនេះ ទីក្រុងលពបូរីជាទី
ក្រុងសំខាន់បំផុតក្នុងសម័យនោះ ។ ខាងបូរាណគតិ គេហៅសម័យដែល
ខ្មែរមានអំណាចគ្រប់គ្រងប្រទេសនេះ ថា "សម័យលពបូរី" ។

ព្រះមហាក្សត្រិយ៍ ទឹងប្រជាជនខ្មែរកាន់ពុទ្ធសាសនាលទ្ធិមហា-
យាន ដែលបានចំឡងមកអំពីកោះសុមាត្រា ។

តែអំណោះតមកជាយូរអង្វែងផ្តាំ ខ្មែរបានផ្លាស់ប្តូរបន្តើតសិល្បកម្ម
របស់ខ្លួនឡើង ដែលមានលំនាំពុះអំពីបែបភាពដែលបានទទួលមកអំពី
ឥណ្ឌាទឹងកោះសុមាត្រា ទើបកើតរបៀបជាឯកមួយគ្រកូលឡើង ហៅ
ថា សម័យស្នាដៃខ្មែរ (ខ្មែរ) ។ កាលដែលខ្មែរបានគ្រប់គ្រងដែនដីដែលជា
ប្រទេស (ថៃសព្វថ្ងៃនេះទាំងអស់) ខ្មែរក៏បានកសាងវត្តអារាមទឹងទេវ-
ស្ថានជាច្រើន ដែលគេហៅថា ប្រាសាទ ដូចយ៉ាងប្រាសាទស្រុកគ្រីយ
ប្រាសាទភ្នំកុលេនជាដើម ។ វត្តអារាមក្នុងព្រះពុទ្ធសាសនា ដែលជាស្នា
ដៃរបស់ខ្មែរសាងឡើងក្នុងសម័យនោះ ច្រើនជារបៀបមហាយាន; គ្រែ
អំពីបុរាណស្ថានផ្សេង។ នៅមានបុរាណវត្ថុជាច្រើនបែបទៀត ដូចយ៉ាង
ព្រះពុទ្ធរូប, ព្រះពោធិសត្តរូបទឹងទេវរូបជាដើម" ។

ដែនដីក្នុងភូមិភាគដូចបានរៀបរាប់មកហើយនេះ គឺជាកេរ្តិ៍ដំណែល
របស់បុព្វបុរសខ្មែរយើងពិតជាន់ដើម ដែលលោកខំចំណាយសាច់ឈាម

ទឹងដ៏វិត ដើម្បីរួបរួមទុកឲ្យអនុជនគឺយើងកាល់គ្នាសព្វថ្ងៃនេះ ។ គួរជន ជាតិខ្មែរត្រែប់រួបចាំក្បើដំណែលនេះទុកក្នុងដួងចិត្តត្រែប់ៗ គ្នា កុំបីភ្លេច ឡើយ ។

តាមសេចក្តីកត់សៀវភៅនោះពោលថា: ប្រជាជនដែលជាម្ចាស់ ដែនដី ត្រង់នេះ មិនបានកាន់លទ្ធិមហាយានតាមរមាំងអស់ទេ មាន នៅកាន់លទ្ធិហីនយានដែលជាប់តមកពីសម័យទ្វារវតីនោះក៏ច្រើនណាស់ ដែរ គេបានឃើញសិលាចារឹកមួយនៅក្នុងអាណាខែត្រលពបុរី ដែល ចារឹកជាភាសាខ្មែរ បាននិយាយថា "កាលសម័យនោះ លពបុរីមាន ព្រះសង្ឃពីរនិកាយគឺ ស្ថិរៈ ជានិកាយដើមដែលតំណាមកអំពីសម័យ ទ្វារវតី, មហាយាន ជានិកាយដែលទើបនឹងរុងរឿងក្នុងសម័យដែលរាម បួលមកមានអំណាចត្រែប់ត្រង់លើដែនដីភូមិភាគត្រង់នេះ (គឺប្រទេសថៃ សព្វថ្ងៃនេះឯង)" ។ តាំងពីលទ្ធិមហាយានចំរើនរុងរឿងក្នុងប្រទេសនេះ កាលគ្រានោះ គេបានចារឹកធម្មវិន័យជាភាសាសំស្ក្រឹតជំនួសភាសាមគធៈ ដែលគេធ្លាប់ប្រើមក តាំងពីមុនលទ្ធិមហាយានបួលមកនោះ ។

អក្សរសាស្ត្រខ្មែរសង្ខេប

លោក ប៉ាយ-ប៊ុក ក្រុមការងើមខ្សែលេខពីរ

ប្រែនិងរៀបរៀង

(ត)

ព្រះពុទ្ធសាសនាខាងហីនយាននេះឯង ដែលផ្សាយចេញពីកោះសីឡង់ទៅកាន់ប្រទេសថៃ ហើយបានចូលមកប្រតិស្ឋាននៅប្រទេសកម្ពុជា រឥតសកម្មភាពទៅគ្រប់និគមជនបទស្រុកខែត្តកូម៉ិកាគ ពាល់តែព្រហ្មញ្ញសាសនាខ្លឹមព្រះពុទ្ធសាសនាខាងខត្តរនិកាយ (និកាយខាងដើង) ដែលហៅថា មហាយាន ប្រើភាសាសំស្ក្រឹត ខ្លឹមព្រះពុទ្ធសាសនាខាងហីនយាន ប្រើភាសាសំស្ក្រឹតចុះអន់ខ្លះខ្សោយតាមលំដាប់ ។ អក្សរចារឹកចំនើបនេះ គឺមានលក្ខណៈទៅតាមលំនាំ នៃអក្សរសាស្ត្រខ្មែរពិតៗ ដែលពណ៌នាអំពីបូជនីយដ្ឋាន, ពិធីបុណ្យព្រះពុទ្ធសាសនា, មហាជាតក ឬ ពុទ្ធប្រវត្តិ ជាដើម បានបញ្ជាក់ឲ្យយើងឃើញច្បាស់ពិតប្រាកដនូវវប្បធម៌អក្សរសាស្ត្រ ប្រទេសកម្ពុជាសម័យចំនើប ។ មានអក្សរចារឹកនៅសសរប្រាសាទអង្គរវត្តមួយនោះ មានកាលបរិច្ឆេទតាំងពី គ. ស. ១៧០២ ។

ក្រៅពីសិលាចារឹកអង្គរវត្តដែលលោក សរ្យ - សីដេស ជាន់ប្រមូលពីសតវត្សទី ១៩ ដល់សតវត្សទី ១៨, នៅមានអក្សរសាស្ត្រប្រភេទពាក្យកាព្យ និងប្រភេទពាក្យពេចន៍ផ្សេងគឺ

អក្សរសាស្ត្រប្រភេទពាក្យកាព្យ

១) រឿងខ្សែស័ង្ខ ទិពន្ធក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជយ-ជេដ្ឋា ពីថ្ងៃ ៩ ៗ ៦ ឆ្នាំរកា ម.ស. ១៦១៥ ត ស. ១៦៩៣ ជាបា្រប់សាស្ត្រស្នឹកតែ, អ្នកតែងមិនស្គាល់ឈ្មោះ ។

២) ប្រជុំភាកាព្យ អ្នកតែងមានឈ្មោះផ្សេងៗ មានព្រះពជ-ទិពន្ធព្រះបាទសម្តេចព្រះស្រីធម្មកជាព្រះពជសម្ភារជាដើម, អ្នកទិពន្ធ ឯទៀតមិនស្គាល់ឈ្មោះ, តែងក្នុងរវាងសតវត្សៃ ១៧ . ១៨;

៣) បា្រប់ចាស់ របស់ព្រះអង្គសង្ខ ទ្រង់ទិពន្ធក្នុង ព. ស. ២២៦៦ (គ. ស. ១៧២៣) ជាសាស្ត្រស្នឹកតែ;

៤) បា្រប់សុភាសិត របស់ទេកញ្ញាវង្សសោរតេជ្ញនង ទិពន្ធពីថ្ងៃ ២ ១៥ ៨ ឆ្នាំច ម. ស. ១៧១២ (គ ស ១៧៩០);

៥) លោកនេយ្យជាតក របស់ទេកញ្ញាវង្សាក្សត្រីនង រជ្ជកាល ព្រះនាកយណ៍កជាព្រះអង្គអេង, តែងក្នុងថ្ងៃ ៤ ៗ ១០ ឆ្នាំខាលសំរឹទ្ធិ-ស័ក ព. ស. ២៣៣៧, ម. ស. ១៧១៦, គ. ស. ១៧៩៤ ជាបា្រប់ សាស្ត្រស្នឹកតែ;

៦) រឿងបុញ្ញសិរិសោ របស់ទេកញ្ញាវង្សាក្សត្រីនង, រជ្ជ-កាលព្រះនាកយណ៍កជា (ព្រះអង្គអេង) តែងក្នុងថ្ងៃ ៦ ៗ ១១ ឆ្នាំ ម្សាញ់ ម. ស. ១៧១៩ គ. ស. ១៧៩៧ សាស្ត្រស្នឹកតែ;

៧) ប្រជុំពាក្យកាព្យ អ្នកនិពន្ធមិនស្គាល់ឈ្មោះ តែងរកឯ សតវត្សទី ១៨-១៩;

៨) រឿងភោគកុលកុមារ របស់ឧកញ៉ាព្រះឃ្លាំងខង តែងក្នុង ម.ស ១៧២៦ ព.ស. ២៣៤៧ គ.ស. ១៨០៤ ជាច្បាប់សាស្ត្រាស្វឹកវឹត;

៩) រឿងវីរធុជវីរនេត្រ របស់ឧកញ៉ាចៅហ្វាយ ឃ្លាំង-មៀច តែងក្នុងថ្ងៃ ១៥ ១២ ម.ស. ១៧២៨ ព.ស. ២៣៤៩ គ.ស.១៨០៦ ជាច្បាប់សាស្ត្រាស្វឹកវឹត;

១០) រឿងកាកី ព្រះពន្ធនិពន្ធព្រះបាទសម្តេចព្រះហរិរក្សាធម ព្រះអគ្គឧដ្ឋ ទ្រង់និពន្ធក្នុង ព.ស. ២៣៥៨ គ.ស. ១៨១៥ ជាច្បាប់ សាស្ត្រាស្វឹកវឹត;

១១) រឿងទេវីធ្វូ របស់លោកអម្ចូតក្សត្រីម៉ុក តែងក្នុង ព.ស. ២៤០២ - គ.ស. ១៨៥៨ ជាច្បាប់សាស្ត្រាស្វឹកវឹត;

១២) រឿងវិមានប័ទ្ម របស់ឧកញ៉ាបញ្ញាធិបតី យ៉ែម ចៅ ក្រមអាល័ក្ស តែងក្នុង ព.ស. ២៤០៨, គ ស ១៨៦៥ ជាច្បាប់ សាស្ត្រាស្វឹកវឹត;

១៣) រឿងបៅមាស របស់ឃុនសុន្ទរពិនិត្យ តែងក្នុងថ្ងៃ ៣ ១០ ឆ្នាំចសំរឹទ្ធិស័ក ព.ស. ២៤៣០, គ.ស. ១៨៨៧ ជាច្បាប់សាស្ត្រា ស្វឹកវឹត;

១៤) កាព្យសារវិលាសិនី ក្បួនតែងកាព្យឃ្លោងផ្សែង។ របស់ឧកញ៉ាសុតន្តប្រីជា ឥន្ទ្រ កាលនៅធ្វើការឯបាត់ដំបងក្នុងគោរម្យងារជាទីហ្វូងវិចិត្រវោហារ ឥន្ទ្រ តែងក្នុងរវាង ព. ស. ២៤៣២ (១៨៨៩) ។

១៥) រឿងសព្វសិទ្ធិ របស់ហ្មឹនកក្តីអក្សរ តន់ តែងក្នុងថ្ងៃ ៣ ១° ១ ឆ្នាំកុរ ឯកស័ក ព. ស. ២៤៦២ គ. ស. ១៨៩៩ ជាច្បាប់សាស្ត្រាស្ងឹកតែ (កាព្យពាក្យ ៧);

អក្សរសាស្ត្រប្រភេទពាក្យរាយ

១) ព្រះរាជក្រឹត្យក្រមផ្សេងៗ អ្នកនិពន្ធមិនស្គាល់ឈ្មោះតែងក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជ័យជេស្ដា រវាង ម. ស. ១៦១៥ ឬ ១៦១៩ - គ. ស. ១៦៩៣ ឬ ១៦៩៧ ជាច្បាប់សាស្ត្រាស្ងឹកតែ;

២) រឿងបឋមសម្ពោធិ អ្នកនិពន្ធមិនស្គាល់ឈ្មោះ តែងរវាងសតវត្សទី ១៨ - ១៩ ច្បាប់សាស្ត្រាស្ងឹកតែ ។

៣) រឿងទសជាតក អ្នកនិពន្ធមិនស្គាល់ឈ្មោះ តែងរវាងសតវត្សទី ១៨-១៩ ច្បាប់សាស្ត្រាស្ងឹកតែ ។

៤) ព្រះរាជក្រឹត្យក្រមបៅហ្វាយស្រុក អ្នកនិពន្ធមិនស្គាល់ឈ្មោះ តែងក្នុងរជ្ជកាលព្រះបាទសម្តេចព្រះទ័យពជាព្រះអង្គចន្ទ តែងក្នុង ព. ស. ២៣៧២ គ. ស. ១៨២៩ ជាច្បាប់សាស្ត្រាស្ងឹកតែ ។

៥) ព្រះរាជក្រឹត្យក្រមផ្សេង ។ អ្នកនិពន្ធមិនស្គាល់ឈ្មោះ,

តែងក្នុងរជ្ជកាលព្រះបាទសម្តេចព្រះហរីរក្សភមាព្រះអង្គឌួង, តែងរវាង ច.ស. ១២១២ ឬ ១២១៥ · គ. ស. ១៨៦៥ ឬ ១៨៧៣ ។

៦) ព្រះរាជក្រឹត្យក្រមផ្សេងៗ អ្នកនិពន្ធមិនស្គាល់ឈ្មោះតែងក្នុងរជ្ជកាលសម្តេចព្រះបាទនរោត្តម រវាង ច. ស. ១២៣៥ - ១២៣៨ គ. ស. ១៨៧៦ · ១៨៧៨ ។

៧) គតិលោក របស់លោកឧកញ៉ាសុគន្ធថ្រែជា "ឥន្ទ" តែងចប់នៅថ្ងៃ ៥ ។ ១១ ឆ្នាំរកាគោស័ក ព. ស. ២៤៦៤, គ. ស. ១៨២១ ។

ក្រៅពីនេះ, មានរឿងព្រៃផ, ប្រលោមលោក, ចម្រៀង, កាព្យនិពាន, កវីនិពន្ធ ។ ល ។

ក) សម័យបច្ចុប្បន្ន

ពី គ. ស. ១៨៦៣ មកដល់សព្វថ្ងៃ

សម័យបច្ចុប្បន្ន មានអក្សរសាស្ត្រជាភាសាបាលី, ខ្មែរ, ជាពាក្យកាយ ទឹង ជាពាក្យកាព្យ, ហើយមានចំរុះពាំងពាក្យកាយទឹងពាក្យកាព្យកំមាន, ហានអក្សរសាស្ត្រខាងពុទ្ធសាសនា, គុណការ, បរច្ចុកទេស, ប្រវត្តិសាស្ត្រ, ល្ខោនខ្មែរ, ចម្រៀង, រឿងព្រៃផ, ប្រលោមលោក ។ ល ។ ។

១ — អក្សរសាស្ត្រខាងពុទ្ធសាសនា, អក្សរសាស្ត្រនេះមាននិពន្ធពាំងភាសាបាលី ពាំងភាសាខ្មែរ, តែភាសាបាលីដែលគេសរសេរនៅប្រទេសកម្ពុជាជាគួ "អូល" ។ ភាសាបាលីដែលជាភាសាសាសនានៅកោះសីឡង់, ប្រទេសសៀម, ភូមា ទឹងលាវ គេ

សរសេរនិយមថៅតាមភាសាទំនើងអក្សរប្រែខេសនោះ។ ។ អក្សរសាស្ត្រ
ពុទ្ធសាសនា គឺព្រះត្រៃបិដក មានជាសេចក្តីប្រែទំនើងអត្ថាធិប្បាយជា
អក្សរខ្មែរ ត្រមតាំងជាភាសាបាលី ចំពោះត្រែងំអត្ថបទណាដែលគេនិយម
ចង់ដឹងជាងគេ ។ អត្ថបទទំនើងសៀវភៅខាងព្រះពុទ្ធសាសនាះត្រមតាំង
គម្ពីរស្ទឹកតែប្តូរកាំងជាច្រើន ព្រះសង្ឃបានរក្សាទុកនៅបណ្ណាល័យ
កងវត្ត; មានអត្ថបទខ្លះតែងតាំងពីបុងសតវត្សទី ១៨ ប្តូរដើមសតវត្ស
ទី ១៩ ។ ក្រៅពីព្រះត្រៃបិដក មានធម្មសម្រាប់សូត្រទំនើងគម្ពីរយ
ជាច្រើន ត្រមតាំងជាតក ។ កងចំណោមជាតកតាំងអស់, ជាតក
ដែលសំខាន់ជាងគេ គឺព្រះវេស្សន្តរដែលព្រះពោធិសត្វបានបំពេញ
ពុទ្ធការកធម៌ដោយធ្វើទានបរមត្ថបារមី គឺអំណោយព្រះអគ្គមហេសីព្រះ
នាងមទ្រី ទំនើងព្រះពជបុត្រាព្រះពជបុត្រីជាលី, កិស្ណា ។ ចំណែកខាង
និពន្ធបច្ចេកទេស, គឺសម្រែកបថៅទំនើងលក្ខិពុទ្ធសាសនាបឋមសម័យ
ដែលមានមូលដ្ឋានត្រែងំអនិច្ចំ, ទុក្ខំ, អនត្តា, ចតុរារិយសច្ច ។

អក្សរសាស្ត្រខាងព្រះពុទ្ធសាសនាសព្វថ្ងៃ កំពុងតែបម្រើនពេញ
លក្ខណៈ, មានសៀវភៅគ្រប់ប្រែបគ្រប់យ៉ាង ដែលអ្នកនិពន្ធបានយក
អត្ថបទកងព្រះពុទ្ធសាសនា គឺព្រះត្រៃបិដកមករចនាតាមកងធម៌, តាម
រឿងជាតក, តាមស៊ីល, សមាធិ, បញ្ញា . . . ។ ល ។

២— អក្សរសាស្ត្រខាងតុលាការ: មានការតែងច្បាប់ត្រម
ព្រហ្មណ្ឌ, ច្បាប់វេជ្ជវៀណ, ច្បាប់ត្រមពិភាក្សាព្រហ្មណ្ឌ, ច្បាប់
ពជនីតិ ។ ច្បាប់ទាំងអស់នេះ តែងឡើងប្រហែលមុនសតវត្សទី

១៧ ខ្នុះ តែគេបានយកមកកែសម្រួលថ្មីតាមសម័យ, តាមកាលៈទេសៈ, តាមនិយម ។ អត្ថបទនេះ ជាសេចក្តីដកស្រង់យកពីព្រះពុទ្ធក្រមនិងព្រះពុទ្ធកិត្យព្រះមហាក្សត្រិយ៍ តាមព្រះពុទ្ធសន្តតិវង្សជាតំណតមក ក្រោយដែលបានសម្រេចពីក្រមគុណការជាន់ខ្ពស់ ។ សេចក្តីពាំនេះ គេបានដកស្រង់យកពីធម្មសាស្ត្របុរាណសំស្រ្តតខ្នុះ, ស៊ីលធម៌បុរាណខ្មែរខ្នុះ, ច្បាប់ព្រះពុទ្ធសាសនាខ្នុះ ប្រមូលរួបរួមយកមកធ្វើអត្ថាធិប្បាយជាច្បាប់អនុវត្តន៍ថ្មីតាមគោលការណ៍ ។ ក្រៅពីនេះ, មានច្បាប់ក្រម, ក្បួនកាល, តិនេតិ, ពាក្យចាស់, វិធ្យបណ្ឌិត ។ ល ។ សម្រាប់ប្រដៅជនប្រុសស្រីឲ្យយល់ករណីយកិច្ចរបស់ខ្លួន, ស៊ីលធម៌, ការចម្រើន, កាតព្វកិច្ច ដែលជាពាក្យសុភាសិត ឬ ឋានន្តរ ។

៣— អក្សរសាស្ត្របង្កែបង្កែទេសៈ មានអត្ថបទគួរ។ ដែលពណ៌នាអំពីក្បួនវេជ្ជសាស្ត្រ, ហោរាសាស្ត្រ, តារាសាស្ត្រ, គម្ពីរសុបិន, និម្មិបនកម្ម, ភោគវិទ្យា, ចក្រវាឡវិទ្យា, លោកធាតុវិទ្យា, ជរណីសាស្ត្រ . . . ល . . ។ គេបានឃើញចំពោះអត្ថបទពាំនេះ មានតម្រាទុសថ ៨ភា យ៉ាង, ការបង្កើតលោក, រឿងទេវតា . . . ល . . . ។ ក្រៅពីនេះ មានរឿងទំនៀមទម្លាប់ប្រពៃណីនិយម, វេយ្យាករណ៍, គាថាសាស្ត្រ . . . ល . . . ។

៤ ប្រវត្តិសាស្ត្រ.— ប្រវត្តិសាស្ត្រជាឯកសារនៃគ្រួសារ, វត្តអារាម, ទឹងជាព្រះពុទ្ធពង្សាវតារព្រះបរមរាជាំង ។ ឯកសារនេះមាន

ច្រើនតែពិធីបុណ្យ, ចំណែកឯព្រឹត្តិការណ៍នយោបាយមិនសូវមាន, បើមានច្រើនតែធ្វើសង្កេបបីបួនបន្ទាត់ ។ ប្រវត្តិសាស្ត្រនេះ, បើតាមខ្ញុំពិនិត្យមើល, ឃើញមានពិពន្ធមកតាំងពី ព. ស. ២៣៩៥ គ. ស. ១៧៦២ ។ អ្នកពិពន្ធពេលនោះ គ្មានឯកសារអ្វីជាមូលដ្ឋានទេ គឺធ្វើតាមរឿងព្រេងបុរាណ តាមពាក្យដែលនិយាយពីមាត់មួយទៅមាត់មួយ ឥតមានគោលចាំកសោះ ។ លុះមកដល់រជ្ជកាលព្រះបាទសម្តេចព្រះអង្គឌួង ទ្រង់បានគ្រាស់បង្គាប់ក្រុមព្រះអាល័ក្សឲ្យធ្វើព្រះពាដពង្សាវតារ ប្រទេសកម្ពុជា ។ តែព្រះពាដពង្សាវតារនេះ គឺធ្វើពីរជ្ជកាលព្រះបាទសម្តេចព្រះបរមនិព្វានបទ មកដល់រជ្ជកាលព្រះបាទសម្តេចព្រះទន្លៃ ។ លំដាប់តមក, ព្រះបាទសម្តេចព្រះនរោត្តមទ្រង់មានព្រះពាដនុង្គារ ឲ្យ.កញ្ញា-បញ្ញាធិបតី យែម ទីឆ.កញ្ញាសន្ធរកៅហារ ម៉ុក ឲ្យធ្វើព្រះពាដពង្សាវតារខ្មែរ ។ លុះមកដល់ថ្ងៃ ១៤ កេច ខែមិគសិរ ឆ្នាំថោះ ព. ស ២៤៤៥ ត្រូវនឹងថ្ងៃទី ២៧ ម៉ីនា ១៩០៣ ទ្រង់គ្រាស់បង្គាប់ឲ្យ.កញ្ញាកំងវៀងជ័យ ជួន ប្រមូលឯកសារប្រវត្តិសាស្ត្រដែលមានទៅក្នុងក្រុមព្រះអាល័ក្សទីឆ.ក្រុមព្រះពាដពិពន្ធ, ហើយស្ថាបនាខ្លួនគណៈកម្មការមួយដើម្បីរៀបចំធ្វើព្រះពាដពង្សាវតារប្រទេសកម្ពុជា ។ តែក្នុងពេលនោះ, គណៈកម្មការមិនទាន់រៀបចំបូលដំនុំជាលើកដំបូងនៅឡើយ, ស្រាប់តែព្រះបាទនរោត្តមទ្រង់ព្រះទិវង្គតទៅ ។

លំដាប់តមក, ព្រះបាទសម្តេចព្រះស៊ីសុវត្ថិទ្រង់មានព្រះពាដនុង្គារខ្លួនព្រះបន្ទូលសូរសីហនាទចំពោះ.កញ្ញាវង្សាអគ្គពាជ ឌុច ឲ្យរៀបធ្វើព្រះពាដ-

ពង្សាវតារជាថ្មី ។ ក្រៅពីនេះ, ជាឧទាហរណ៍ មាស្ប៉ារ៉ូ អតីតរេស៊ីដង់ត៍សុប៉ែរីយ៉ែរ ប្រទេសកម្ពុជា បានសុំព្រះអង្គម្ចាស់កាឧវង្ស អគ្គមហាសេនាបតី ឲ្យលៃលកកែថែមសេចក្តីទៅតាមឯកសារដែលស្រាវជ្រាវបានមក ។ តែប្រវត្តិសាស្ត្រប្រទេសកម្ពុជា ក៏មិនទាន់មានសភាពពិតទៅឡើយ ។

យោបល់ខ្ញុំ ខ្ញុំយល់ថា ប្រវត្តិសាស្ត្រប្រទេសកម្ពុជា មានប្រភពចម៖

ប្រភពទី ១ – ប្រវត្តិសាស្ត្រខ្មែរបស់សម្តេចវ៉ៅហ្វាវ៉ាំង ជួន;

ប្រភពទី ២ - ប្រវត្តិសាស្ត្រខ្មែរជាអក្សរសៀមរបស់ព្រះពុទ្ធជយន្តាលីយ រដិរញ្ញាណ, អ្នកនិពន្ធនាមលោកចាវ៉ាហ្វាវ៉ាង្គតិព្រះយ៉ាវៃក្រៃតេជ្រវតន:សង្គ្រាមក្រែងទេព ជាឯកក (ប្រទេសថៃ);

ប្រភពទី ៣ គឺ សិលាចារឹកនឹងឯកសារប្រទេសចិន ពីសម័យបុរាណ ។

បើស្រាវជ្រាវឲ្យជ្រៅជ្រះយ៉ាងនេះទៅទៀតមាន ៧ ប្រភពទៀតគឺ

ក) ព្រះពុទ្ធពង្សាវតាររបស់ព្រាហ្មណ៍ ដែលជាអ្នករក្សាទុកមានន័យតាំងពីព្រះពុទ្ធទំនាយ តមកដល់ព្រះពុទ្ធវង្សព្រះមហាក្សត្រិយ៍ ទេវង្សអស្ចារ្យ, ព្រះកេតុមាលានឹងព្រះបទុមវរវង្ស;

ខ) ព្រះពុទ្ធពង្សាវតារជាតំថៃខាងជើង ដែលដកស្រង់យកមកពីទំនាយព្រះកែវ មានសេចក្តីពិស្តារអោលពីសន្តតិវង្សព្រះជាទេវយក-ពុទ្ធទៅដល់ព្រះជាទេវបទុមសុរិយវង្ស;

គ) សៀវភៅវេតនកិមវគ្ស ដែលមានសេចក្តីពោលពីព្រះពុទ្ធវង្ស ព្រះបាទធនញ្ជយកោរព្យ:ពុទ្ធ មកដល់រដ្ឋកាលព្រះបាទសេនកពុទ្ធទីន ព្រះសិង្ហកុមារ;

ឃ) "ឫស្សីទំនាយ" ដែលពោលតាំងពីព្រះពុទ្ធវង្ស ព្រះបាទសុទ្ធបក្ត, ព្រះចក្ត្រពត្តាធិពុទ្ធ ព្រះបាទបក្សីចាំក្រុង រហូតដល់ទៅព្រះបាទតាត្រសក់ផ្អែម;

ង) ព្រះពុទ្ធពង្សាវតារថៃខាងជើងទីណាវ ដែលអធិប្បាយតាំងពីព្រះពុទ្ធវង្សព្យាកែក ឬ ព្រះបាទដំបងក្រញូងទីន ព្រះបាទបក្សីចាំក្រុង;

ច) គម្ពីរបុរាណដែលពណ៌នាពីព្រះពុទ្ធពង្សាវតារនេះដែរ;

ឆ) តាមពាក្យចាស់បុរាណព្រឹទ្ធាចារ្យ, អ្នកដែលមានវ័យចេះទីន ឬអ្នកដែលចេះដឹងប្រវត្តិសាស្ត្របុរាណ ឬអ្នករៀនខ្ញុំញាំពីសៀវភៅផ្សេង ។ ។

បើយើងប្រៀបមើលប្រកពទាំងអស់, យើញតែប្រកពសិលាចារឹកមួយទេដែលគួរខ្ពុកជាបានការ ។

(មានត)

លោក សុន-ហាន ប្រែរៀបរៀង
លោក យូរ-អ៊ុន ពិនិត្យកែសម្រួល

(តមក)

"ថ្ងៃស្អែកខ្ញុំនឹងធ្វើពិធីបុណ្យប្រសិទ្ធីវិជ្ជាជល់ពួកអ្នក ដែលរៀនវិជ្ជានឹងខ្ញុំ ដូច្នេះ ខ្ញុំសូមឲ្យពួកអ្នកគ្រប់គ្នាជួយខ្វល់ខ្វាយផង ព្រោះព្រឹកនេះខ្ញុំនឹងនិមន្តភិក្ខុសង្ឃមកឆាន់អាហារនៅនឹងផ្ទះខ្ញុំនេះ ហើយយប់ឡើងសូត្រមន្តដើម្បីឲ្យជាសិរីមង្គលជល់ពួកអ្នកជាសិស្ស តែបើអ្នកណាមិនចង់បានទូវសិរីមង្គលជល់ខ្លួនទេ នឹងមិនមកក៏បាន" ។

បណ្តាសិស្សគាំងឡាយ ដែលបានឮពាក្យរបស់សុរពលជាអាចារ្យហើយ មិនមានសិស្សណាម្នាក់ហ៊ានដំណាស់ទេ ។

ព្រឹកឡើង ព្រះភិក្ខុសង្ឃនិមន្តមកដល់ផ្ទះសុរពល ។ សិស្សរបស់សុរពលដែលកាប់អានព្រះពុទ្ធសាសនា បានចាត់ចែងអាហារពីផ្ទះខ្លួនយកមកបូជារួមនឹងអាហាររបស់សុរពល ។ មានសិស្សរបស់សុរពលម្នាក់ឈ្មោះ សញ្ជ័យ ជាបុត្ររបស់ព្រាហ្មណ៍ មាត់អាក្រក់គាំងស្វាមីនឹងកិរិយា, សិស្សនេះបានលួចលាក់ផ្លែឈើមួយថាសធំផ្ញើនឹងមិត្រភ័ក្តិដោយមិនឲ្យមាតាបិតាដឹង ហើយសូមអនុញ្ញាតពីបិតាមាតាចេញមកជាងគ្រោយ ដោយដំបូងមាតាបិតាថា នឹងនាំអ្នកតូចម្នាក់ទៅដើរលេង, បិតាមាតាក៏អនុញ្ញាត តែហាមថាកុំឲ្យទៅរំលងដែនដីនឹងភិក្ខុសង្ឃដែល

សុវត្ថិនមន្តមក ។ សញ្ជ័យក៏ទទួលពាក្យមាតាបិតា តែដោយសេចក្តីគោរពអាចារ្យ ទើបដោយនិស្ស័យក៏សនាផ្ទួយតំបិតាមាតា ក៏ត្រឡប់ជាមិនធ្វើតាមបង្គាប់វិញបានលបដើរជាមួយនឹងមិត្តភក្តិមកផ្ទះសុវត្ថិ ហើយក៏យកថាសពេញដោយផ្លែឈើនោះទៅជូនសុវត្ថិ ហើយដំកបដោយសេចក្តីគោរពថា:

- "ខ្ញុំបាទនាំតែនេះមកថ្វាយបុណ្យផង លោកអាចារ្យ!" ។

សុវត្ថិស្គាល់ចិត្តថ្មើមសិស្សនេះថា ជាអ្នកកប់ពានសាសនាព្រាហ្មណ៍តាលយើញសិស្សនេះនាំថាសផ្លែឈើមកឲ្យនោះ ទឹកស្នាមថាត្រៃដ៏យកមកឲ្យតាំងខើសខាល់ ទើបត្រាប់ថា:

- "សញ្ជ័យ! ដែលអ្នកឯងយកផ្លែឈើមកឲ្យខ្ញុំនេះ ខ្ញុំត្រេកអរណាស់ហើយ តែអាហារបស់ខ្ញុំដែលសម្រាប់ប្រគេនព្រះតថាគតឯង នឹងសម្រាប់ជាប់លៀងពួកអ្នកឯងសឹងមានត្រប់គ្រាន់តែខ្លះទេ, ដូច្នេះផ្លែឈើនេះចូរអ្នកឯងយកទុកប្រគេនដល់សមណៈខាងក្រៅវិញចុះ" ។

សញ្ជ័យកាលបានឮសុវត្ថិនិយាយដូច្នោះ ក៏តូចចិត្តឈរបែរមុខមិនឱយាយតបវិញ ។

- "អ្នកឯងមិនពេញចិត្តឬ?" សុវត្ថិសួរបញ្ជាក់ដោយយើញកិរិយាស្ងៀមស្ងាត់របស់សញ្ជ័យ ។

- "បាទ លោកអាចារ្យ! លោកបានប្រាប់ខ្ញុំបាទថា ការធ្វើពិធីបុណ្យនេះ ដើម្បីជាសិរីមង្គលដល់ខ្ញុំ ។ ទើបបានប្រដាប់ប្រដែងផ្លែឈើនេះ

យកមកចូលបុណ្យផង ដូច្នេះ សូមលោកអាចារ្យទទួលវត្ថុបស់ខ្ញុំនេះ ដោយសេចក្តីអនុគ្រោះ" ។

សុរពលកាលបានស្តាប់ពាក្យសញ្ជ័យហើយ ក៏មានសេចក្តីពេញចិត្ត ទើបទទួលថាសផ្លែឈើនោះ យកទៅឲ្យចិតាចាត់ការបែងចាក់កាជន៍ ថ្វាយគេនព្រះកិក្ខុសង្ឃ ។ កាលព្រះកិក្ខុសង្ឃបានទទួលភោជនាហារស្រេចហើយ សុរពលបានបង្គាប់សិស្សគ្រប់គ្នា ឲ្យមករួមនៅត្រង់លានផ្ទះ ខ្លួនគេឈរនៅត្រង់កណ្តាលពួកសិស្ស ហើយប្រាប់សិស្សទាំងនោះថា:

- "ថ្ងៃនេះ ខ្ញុំមានចិត្តត្រេកអរពន់ពេកចំពោះពួកអ្នកជាសិស្ស ដែលបានព្រមព្រៀងគ្នាមកជួបជុំក្នុងទីនេះ; ខ្ញុំដែលតាំងផ្តើមធ្វើបុណ្យនេះឡើង ដើម្បីជាសិរីមង្គលដល់បណ្តាអ្នកជាសិស្ស ឥឡូវនេះ ខ្ញុំសូមឲ្យអ្នកជាសិស្សទាំងឡាយ ប្រុងប្រៀបរៀបចំខ្លួនទទួលនូវសិរីមង្គល ដែលខ្ញុំនឹងឲ្យ" ហើយសុរពលនិមន្តព្រះកិក្ខុសង្ឃឲ្យត្រោះត្រៃពីកមន្ត ដល់សិស្សគ្រប់គ្នា ។

កាលព្រះកិក្ខុសង្ឃត្រឡប់ទៅកាន់អាវាសរបស់លោកហើយ ពួកសិស្សរបស់សុរពល បានទទួលអញ្ជើញការដប់លៀងពីសុរពល លុះបរិភោគរួចហើយ ក៏នាំគ្នាអង្គុយជាពួកៗ ជជែកគ្នាយ៉ាងសប្បាយ ។ សុរពលចាំស្តាប់សំដី តើនឹងមាននរណានិយាយយ៉ាងដូចម្តេចខ្លះ ។ ក្នុងកាលនោះ សញ្ជ័យ បានចូលទៅជិតសុរពលហើយដំរកថាថា:

- "លោកអាចារ្យ! ឲ្យខ្ញុំបានសុំថាសវិញផង មួយទៀតខ្ញុំបាន

មានសេចក្តីសង្ស័យមួយ, សូមលោកអាចារ្យដោះស្រាយនោះឲ្យខ្ញុំបានជាត់ពិការ តើបានឬទេ?" ។

-"បាន, មានសេចក្តីសង្ស័យដូចម្តេចសួរមកខ្ញុំចុះ ខ្ញុំតបបានក៏ទឹងតបជូន បើតបមិនបានទេ ខ្ញុំក៏ប្រាប់ថាមិនបាន" និយាយហើយសុរពលក៏ចាប់ថាសហុបឲ្យ ។

-"លោកអាចារ្យ ដែលខ្ញុំសុំសួរលោកនេះ កុំថាខ្ញុំមើលងាយលោកឡើយ ព្រោះខ្ញុំបានមានសេចក្តីឆ្ងល់ភ្ញាំងភ្ញាស្មៀមពុំបាន ទើបសុំសួរ, ការណ៍ដែលខ្ញុំបានសង្ស័យនោះ គឺកាលពីម្សិលមិញ លោកអាចារ្យបានប្រាប់ពួកខ្ញុំបានថាទឹងឲ្យសិរីមង្គលដល់ពួកខ្ញុំបាន ដោយធ្វើពិធីបុណ្យនេះ ហើយលោកអាចារ្យបានឲ្យពួកខ្ញុំបានចាំខួលទឹកមន្តដែលព្រះកិត្តិសង្ឃប្រោះព្រំឲ្យ ខ្ញុំបានមានសេចក្តីសង្ស័យថា សិរីមង្គលតើដូចម្តេច?" ។

សុរពលបានស្តាប់ពាក្យសួរបស់សញ្ជ័យ ក៏មានសេចក្តីត្រេកអរព្រោះគេរៀបចំឲ្យតែមានអ្នកសួរ គេទឹងធ្វើយពន្យល់ឲ្យពួកសិស្សដឹងរឿងការដែលជាប់ទាក់ទងនឹងផ្លូវពុទ្ធសាសនា ដើម្បីឲ្យពួកសិស្សចុះចិត្តស៊ប់ចំពោះពុទ្ធសាសនា គេទើបតបថា:

-"អើ! សញ្ជ័យ អ្នកឯងសង្ស័យទឹងសិរីមង្គលនោះគួរណាស់ហើយ ខ្ញុំស្មានថាមិត្តភក្តិរបស់អ្នកច្រើនគ្នាទៀត ដែលសង្ស័យដូចអ្នកឯងដែរ ដូច្នេះខ្ញុំទឹងប្រាប់នូវសិរីមង្គលដល់អ្នកទឹងពួកមិត្តអ្នកឲ្យបានដឹងក្នុងពេលនេះ" ។

និយាយទំនងសញ្ជ័យដូច្នេះហើយ សុរពលក៏ប្រាប់សិស្សពាំងអស់ឲ្យបានឮគ្រប់គ្នា :

- "នែ! អ្នកគ្រប់គ្នា ចូរចាំស្តាប់! ខ្ញុំនឹងដោះស្រាយប្រស្នាដែលសញ្ជ័យសួរខ្ញុំ" ។

ពួកសិស្សដែលកំពុងសន្ធនាគ្នាជាពួក ។ កាលបានឮហើយក៏បែរមុខត្រង់មករកសុរពល ។

- "ខ្ញុំបានប្រាប់អ្នកពាំងអស់គ្នាកាលពីថ្ងៃត្រង់ថា ខ្ញុំនឹងឲ្យសិរីមង្គលដល់ពួកអ្នក ហើយព្រះភិក្ខុសង្ឃក៏បានប្រាប់ព្រំទឹកមន្តឲ្យដល់ពួកអ្នក, ទឹកមន្តដែលព្រះភិក្ខុសង្ឃប្រាប់ព្រំឲ្យនោះឯងជាសិរីមង្គល, ពួកអ្នកគង់មានសេចក្តីសង្ស័យថាដូចម្តេចហៅថាសិរីមង្គល តែមិនហ៊ានសួរខ្ញុំ, ខ្ញុំសូមសរសើរសេចក្តីសញ្ជ័យដែលមានសេចក្តីសង្ស័យហើយមិនបិទពុត, ការធ្វើដូច្នេះប្រពៃណាស់ ព្រោះកាលបើមិនពេញចិត្តរបស់ណាត្រូវប្រាប់ឬសង្ស័យរបស់ណាត្រូវតែសួរ ទើបមានប្រយោជន៍ច្រើន. តទៅនេះពួកអ្នកសង្ស័យអ្វីសួរមកខ្ញុំចុះ ឬមិនពេញចិត្តអ្វីប្រាប់មកខ្ញុំចុះ; មុនទំនងដោះស្រាយសិរីមង្គលដែលសញ្ជ័យសួរមកខ្ញុំ ខ្ញុំសុំសួរពួកអ្នកគ្រប់គ្នាតើបណ្តាអ្នកពាំងអស់គ្នា នរណាធ្លាប់បានឮពាក្យអាស្រូវគាសមកខ្លះទេ?" ។

ពួកសិស្សជំរាបថា ធ្លាប់ឮមកហើយ ។

សុរពលត្រឡប់សួរសិស្សពាំងនោះទៀតថា "ពាក្យអាស្រូវសគាពាំងនោះ ជាសិរីមង្គលឬទេ?" ។

-"មិនមែនទេ លោកអាចារ្យ" សម្ងេដ៏សិស្សគ្រប់គ្នាទទួលឡើង។ សុពេលទើបនិយាយតទៅទៀត:

-"បើដូច្នោះ ពាក្យរបស់ខ្ញុំដែលថា សេចក្តីសុខចូរមានដល់អ្នក, អ្នកចូរមានសតិបញ្ញា, កុំយកតំណឡាយកុំបីបៀតបៀនអ្នក, សូមឲ្យអ្នកបានជាទីស្រឡាញ់របស់មនុស្សគ្រប់ឡាយ, ពាក្យដែលខ្ញុំនិយាយមកគ្រប់នេះជាសិរីមង្គលឬទេ?" ។

-"ជាសិរីមង្គល លោកអាចារ្យ!" សម្ងេដ៏ពួកសិស្សតបត្រឡប់គ្នា។ សុពេលញញឹមដោយសេចក្តីត្រេកអរនឹងពួកសិស្ស ដែលយល់ត្រូវតាមការណ៍ពិត ទើបទឹកមុខភាក្យដែលប្រកបដោយសេចក្តីពិតមកនិយាយតទៀតទៅទៀត:

-"ព្រះភិក្ខុសង្ឃសូត្រពុទ្ធមន្តនោះ ដោយចេតនាប្រសិទ្ធិពរចុះក្នុងទឹកដែលជាក់ក្នុងធ្លុងឬក្នុងក្អម ហើយបាចទឹកមន្តនោះត្រោះព្រំដល់ពួកអ្នក, ការដែលព្រះសង្ឃត្រោះព្រំទឹកមន្តឲ្យដល់ពួកអ្នកនោះ ពុកស្មើពួកអ្នកបានទទួលនូវសិរីមង្គល ព្រោះព្រះសង្ឃដែលសូត្រសែកទឹកមន្ត គឺលោកស្រង់យកធម៌ជាពាក្យប្រៀនប្រដៅដ៏ល្អរបស់ព្រះសម្មាសម្ពុទ្ធមកសូត្រសែកចុះក្នុងទឹក ហាក់ដូចជាលោកប្រដៅយើងឲ្យធ្វើល្អ ឲ្យលះបង់អំពើអាក្រក់ ឲ្យផ្សាយមេត្តាដល់គ្នានឹងគ្នា កុំឲ្យបៀតបៀនគ្នា, ខ្ញុំដឿពាក្យប្រដៅដែលថាឲ្យបែងចែកចំណេះដល់ពួកមនុស្ស ខ្ញុំទើបប្រដៅពួកអ្នកដោយមិនមានអគតិ គឺមិនលំអៀង ព្រោះស្រឡាញ់ព្រោះស្អប់ ប្តូរជាន់ថ្នាក់វណ្ណៈដូចពួកអ្នកឃើញស្រាប់ហើយ ខ្ញុំត្រេកអរក្នុង

ការឲ្យ ព្រោះដឿថាអ្នកដែលបានទទួលអំណោយតែងត្រេកអរ មានសេចក្តីសុខដោយសារវត្ថុដែលទទួលពីយើងទៅ, កាលគេកើតមានសេចក្តីសុខ យើងក៏បានសុខដែរ ហើយយើងមិនមែនបានទទួលសេចក្តីសុខតែក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ ទៅក្នុងអនាគតយើងនឹងត្រូវទទួលសេចក្តីសុខដោយកម្រៃបុណ្យនោះទៀត ។ វិជ្ជាស្តាត់ជំនាញក្នុងក្រុងអារុងផ្សេង ។ ដែលពួកអ្នករៀនអំពីខ្ញុំជាវិជ្ជាធម្មតា ហើយនរណា ។ ក៏អាចរៀនបានដូចគ្នា តែវិជ្ជាមួយយ៉ាងទៀត ពួកអ្នកភាគច្រើននៅមិនទាន់ចេះដឹងនៅឡើយ វិជ្ជានោះហៅថាវិជ្ជារបស់បណ្ឌិត គឺវិជ្ជាខាងព្រះពុទ្ធសាសនា បើពួកអ្នកពេញចិត្តនឹងរៀនខ្ញុំក៏នឹងបង្រៀន" ។

ពួកសិស្សទាំងឡាយ កាលបានស្តាប់ពាក្យមានហេតុផលរបស់សុរពល ក៏នាំគ្នាប្រឹក្សាហើយដំណាលសុរពលថា ចាំសាកសួរឪពុកម្តាយសិន រួចណាសុរពលនាំគ្នាត្រឡប់ទៅផ្ទះរៀងខ្លួនវិញ ។

ចំណែកសញ្ជ័យបញ្ជាប់ប្រាប់នាំប្អូនត្រឡប់ទៅផ្ទះ ដោយខ្លាចក្រែងចិតាមាតាដឹងថាខ្លួននាំគាហារមកប្រគេនព្រះតិក្ខុសង្ឃនាផ្ទះសុរពលនឹងដេរាយ ។ ទទួលកន្ទៃនោះ មិត្រក័ក្តិខ្វះដែលនៅជិតផ្ទះសញ្ជ័យត្រឡប់ទៅដល់ផ្ទះមុនសញ្ជ័យ ។ មាតាបិតាសញ្ជ័យឃើញសញ្ជ័យមិនទាន់នាំប្អូនត្រឡប់ទៅផ្ទះក៏សង្ស័យ ទើបសួរមិត្រក័ក្តិសញ្ជ័យ ។ មិត្រក័ក្តិនោះប្រាប់ថាសញ្ជ័យនាំផ្លែឈើទៅប្រគេនព្រះតិក្ខុសង្ឃ កាលប្រាប់ហើយទើបនឹកឃើញថា សញ្ជ័យបានផ្តាំមិនឲ្យប្រាប់បិតាមាតា ។ ការធ្វើរបស់សញ្ជ័យដូច្នេះ ជាហេតុឲ្យឪពុកម្តាយក្រោធខឹងដូចភ្លើង

នេះឡើង ១ រំពេច ក្នុងពេលដែលបានដឹងរឿង តាំងចិត្តនឹងដេរក់យ
ឲ្យសមតាមកំហុស ។ លុះសញ្ជ័យត្រឡប់មកដល់ផ្ទះ ឪតាក៏ស្ទុះ
ទៅចាប់កដៃម្ខាង រាយរាត់ដោយរំពាត់ជាច្រើន ។ ក្មេងកម្លោះដូច
យ៉ាងសញ្ជ័យជាមនុស្សខ្លាំង ស្រឡាញ់ឪពុកម្តាយណាស់ បានឈរ
ស្ងៀមបណ្តោយឲ្យឪតារាយរាត់តាមចិត្ត ។ ឪតារបស់សញ្ជ័យរាយ
យ៉ាងច្រើនពាក់មិនបាន មាត់ក៏ដេរស្តីដោយពាក្យអាស្រូវគាស បន្ទោស
សញ្ជ័យដែលមិនធ្វើតាមពាក្យហាមប្រាម សញ្ជ័យក៏យំសុំទោសឪពុក
តែគាត្រាហ្មណ៍មិនអាណិតអាសូរសោះ គាត់រាយតាលែតអស់កម្លាំង
កាលបើមិនមានកម្លាំងនឹងរាយតទៅគាត់ក៏ស្រែកដេរ សម្លេងដែលគាត់
ដេរនោះបានឮទៅស្ទើរតែគ្រប់ផ្ទះ នៃសិស្សរបស់សុរពល គាត់ដេរ
ទៅដល់សុរពលផង :

—“មនុស្សប្រាកក្នុងខ្ទឹមសារថោកខាបអាក្រក់ លើកតំកើងខ្លួនជា
អាចារ្យ តែងធ្វើឲ្យមនុស្សអ្នកជឿស្តាប់បានសេចក្តីវិនាស មនុស្សយ៉ាង
ខ្ទេចខ្ទីមិនទៅគប់រកអាមនុស្សអាក្រក់នោះទេ ប្រយ័ត្នចុះ បើអញដើរកាត់
មុខផ្ទះវា អញនឹងដេរប្រាប់ចាក់គ្រប់ពេលដែលបានដើរទៅ” ។

ថ្ងៃក្រោយមក តាព្រាហ្មណ៍ធំយាយព្រាហ្មណី ក៏ធ្វើតាមពាក្យ
ដែលគាត់និយាយមែន គឺកាលគាត់ដើរកាត់មុខផ្ទះនក្ខិអមាត្យពេលណា
គាត់ក៏ដេរប្រាប់ប្រាប់ប្រាប់ប្រាប់ដោយពាក្យអាស្រូវគាសពេលនោះ ។

តាំងអំពីថ្ងៃនោះមក សញ្ជ័យក៏ត្រូវឪពុកម្តាយហាមមិនឲ្យមកផ្ទះ
សុរពលជាដាច់ខាត, ថ្ងៃខ្លះព្រាហ្មណ៍ឪតា ឬ ព្រាហ្មណីជាមាតានៃ

សញ្ជ័យ ដើរមកតាមផ្លូវកាត់មុខផ្ទះនន្ទិអមាត្យ ក៏ដេរដោយពាក្យអាស្រូវ
តាសផ្សេង។ សុរពលបានឮក៏នៅស្ងៀមគ្រប់ពេល ។ ការស្ងៀមរបស់
សុរពលជាហេតុធ្វើសេចក្តីក្រោធទ្រង់ រមស់ព្រាហ្មណ៍ឲ្យរឹងរឹតតែខ្លាំង
ឡើង ដូនតាលព្រាហ្មណ៍ដេរសុរពលដែលកំពុងបង្ហាត់សិស្ស ។ សុរ-
ពលបានហាមសិស្សគ្រប់គ្នា មិនឲ្យចែកូសក័យព្រាហ្មណ៍វិញ ដោយ
ឲ្យទុកដល់សិស្សថា

– "អ្នកទាំងឡាយចូរកាន់ចិត្តកុំឲ្យឆ្ងល់តបនឹងគេដែលដេរយើងដោយ
ពុតពាក្យដេរដូចជាវត្ថុសម្រាប់ទទួលក្បៀវ ធម្មតាអ្នកម្ចាស់ផ្ទះតែងមាន
វត្ថុសម្រាប់ទទួលក្បៀវ វត្ថុនោះមានឈ្មោះតែ ស្លា ម្ល ប៉ុន្តែជាដើម ចើក្បៀវ
មិនត្រូវការដោយវត្ថុដែលម្ចាស់ផ្ទះនាំមកទទួលទេ រមស់នោះក៏ជ្រាក់ទៅ
ជារបស់ម្ចាស់ផ្ទះវិញដដែល យ៉ាងណាមិញ ការដេរប្រទេចក៏យ៉ាងនោះ
ដែរ បើយើងមិនទទួលដោយមិនគ្រាជតបមិនយកចិត្តទុកជាក់ទេ
ពាក្យដេរនោះក៏ជ្រាក់ទៅជារបស់អ្នកដេរវិញ ដូច្នោះឯង" ។

ដោយបានស្តាប់ពាក្យសុរពលពន្យល់នេះ ពួកសិស្សក៏ជាត់ខឹង
ចាំងអស់គ្នា កាលណាគាព្រាហ្មណ៍ ឬ យាយព្រាហ្មណីមកដេរក៏នាំគ្នា
សើចសប្បាយទៅវិញ ។

ថ្ងៃមួយយាយព្រាហ្មណី ត្រូវដើរកាត់មុខផ្ទះសុរពលទៀតតាមធ្លាប់,
វេលាដែលគាត់ដើរមក សុរពលកំពុងបង្ហាត់សិស្ស បើយច្រាប់ឲ្យសិស្ស
ប្រឹងខ្លួនច្រយ៉ត្តវែងគោឆ្កួត ១ ដល់ ។ គោនោះពុំដឹងមកពីណាដើរ
វិលវល់នៅក្នុងបរិវេណផ្ទះសុរពល ។ លុះយាយព្រាហ្មណីមកដល់ផ្ទះ

សុរពលហើយ ក៏ឈរដេរសុរពលទៀត ។ សិស្សសុរពលលុះឃើញ
យាយព្រាហ្មណីដើរចូលមកហើយដេរសុរពល ក៏នាំគ្នាសើចសប្បាយ
ឮសម្លេងគឹកកងរៅឆ្ងាយ ។ ខណៈនោះគោឆ្កួតដើរចូលមកជិតផ្ទះសុរ-
ពល លុះរក្បានឮសម្លេងហ៊ោកំប៉ោលរៅរកសម្លេងនោះ ឯផ្លូវដែល
គោឆ្កួតនោះចោលមក គឺជាផ្លូវដែលនាងព្រាហ្មណីកំពុងឈរដេរសុរ-
ពល ។ សម្លេងគោឈឺត ។ មកជិតធ្វើឲ្យយាយព្រាហ្មណីបែរមើល
លុះគោឃើញយាយព្រាហ្មណីហើយ ក៏ប្រាលចូលរៅច្រឹងដល់យាយ
ព្រាហ្មណី ។ តិតភ័យឈប់ដេរ ក្អែកក្រឡឹតក្រឡាប់ រត់រៅត្រង់
ទីលានផ្ទះសុរពល ស្រែកសុំឲ្យពួកសិស្សសុរពលជួយ ។

ខណៈនោះ សិស្សរបស់សុរពលនាំគ្នារត់យ៉ាកព្រះអាយុតែរៀងខ្លួន
គេចចេញរៅអំពីបរិវេណនោះ សល់តែសុរពលឈរនៅដោយខ្នត់ចិត្ត ។
សិស្សខ្លះស្រែកប្រាប់ឲ្យសុរពលរត់ចេញមកជាប្រញាប់ ខ្លះក៏ប្រាប់ថា
បណ្តោយឲ្យយាយព្រាហ្មណីមាត់អាក្រក់នោះស្លាប់រៅចុះ ។ យាយ
ព្រាហ្មណីរត់មករកសុរពល, គោកាចនោះប្រាលមកជិតទន្ទឹងគាត់
ហើយ, យាយព្រាហ្មណីរត់មកដល់សុរពល ក៏ជំពប់ដើងទន្ទឹងឫស
ឈើដួលរៅ គោកាចនោះប្រាលរៅរកដល់យាយព្រាហ្មណី ។
សុរពលឃើញដូច្នោះ ក៏មានសេចក្តីអាណិតយាយព្រាហ្មណី ទើប
កាត់ចិត្តប្រថុយជីវិត រត់តម្រង់រៅផ្លូវមុខគោកាច ហើយបញ្ឆោតឲ្យវា
ដេញតាម ។ គោកាចឃើញដូច្នោះក៏ស្ទុះរៅរកដល់សុរពលដោយពេញ

ចំហឹង សុរពលគេចខ្លួនផុតវិសនឹងត្រែវដោយស្នែងស្រួចរបស់ក្ប គោ
កាចនោះក៏ដ្រុលខ្លួនហួសទៅ លុះវាធ្វើសុរពលមិនបាន វាក៏បែរ
ត្រឡប់ទៅជាថ្នាយ៉ាងរហ័ស រាបញ្ចូញសម្លេងឈឺត ។ ចោលទៅដល់
សុរពលទៀត ។ គ្រានេះសុរពលគេចមិនខាន់ ក៏ចាប់ស្នែងគោដោយ
ដៃទាំងពីរ យាយព្រាហ្មណ៍លុះបានរួចខ្លួនពីការស្លាប់ហើយ ក៏តេ
ឡើងទៅអង្គុយលើផ្ទះសុរពល ។

ខណៈនោះ នាងកាញ្ចនាអង្គុយយំលើផ្ទះ ហើយប្រាប់ឲ្យសិស្ស
របស់សុរពលជួយសុរពលផង តែមិនមានអ្នកណាម្នាក់ហ៊ានចេញទៅ
ជួយរសោះ ។ មុខតួរឲ្យស្រែវខ្លួនរៃត្រៃពេក គោកាចរុញសុរពលត្រែត
ទៅមក សុរពលចាប់សង្កត់ស្នែងវាមិនលែង ។ គោកាចក្រវីរលាស់ចោល
សុរពល។ របូតចេញពីស្នែងរបស់វាខ្លួតចេញទៅឆ្ងាយ, មួយរំពេចនោះ
គោកាចប្រាលតម្រង់ទៅរកសុរពល។ គ្រាកគេចខ្លួនយ៉ាងរហ័ស ។
គោកាចក៏ដល់ត្រែវដើ ធ្វើឲ្យកបរបស់វាត្រែចឈឺចាប់យ៉ាងខ្លាំង ទោះបី
ដូច្នោះវាក៏នៅតែប្រាលតម្រង់មករកសុរពលទៀត ។

(មានត)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
ទឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

កាន់យ៉ាងនិយាយទឹងអ្ងួនសៀវថា ដែលលោកប្រើឲ្យតីឲ្យទៅបញ្ចុះបញ្ចូលឲ្យប៉ៅនោះ ខ្ញុំបាទក្រែងឲ្យតីមិនព្រមត្រឡប់មកទៅទឹងលោកវិញ បើដូច្នោះខ្ញុំបាទទឹងសូមអាសាកាន់កាប់ឲ្យតីទៅផងហើយទឹងបានទៅយាយតឲ្យល់ឲ្យប៉ៅវិលចូលចិត្តមកនៅរួមធ្វើការជាមួយទឹងលោកឲ្យខាងតែបាន ។ អ្ងួនសៀមិនយល់តលៗបាយក៏ដឿថា កាន់យ៉ាងនិយាយត្រូវកំ ព្រមឲ្យកាន់យ៉ាងទៅ, កាន់យ៉ាងក៏លាអ្ងួនសៀវតាមឲ្យតីទៅដល់ទីលំនៅ ។

គួតៅនិយាយទឹងអ្ងួនសៀវថា: កាលគ្រាមុនលោកបានឲ្យឲ្យតីទៅបញ្ចុះបញ្ចូលឲ្យផែក តែមិនបានសមដូចប្រាថ្នា ឥឡូវនេះលោកឲ្យឲ្យតីទឹងកាន់យ៉ាងទៅបញ្ចុះបញ្ចូលឲ្យប៉ៅវិលវៀតនោះ ខ្ញុំបាទ

យល់យើញថាឡៅពីនឹងកាន់យ៉ុង ទឹងមិនត្រមត្រូវប់មករកលោកវិញ
ទេ ។ អ្នួនសៀវតបថា ឯកាន់យ៉ុងនោះមានសតិបញ្ញាខៀងត្រង់ទឹង
យើងណាស់ ពោះបីឡៅពិត្រងើយកន្តើយមិនមកយ៉ាងណា មុខជា
កាន់យ៉ុងទឹងរិះគិតនាំខ្លួនឡៅពីមកវិញពាល់តែបាន ។ គួរតៅបានស្តាប់
ហើយក៏ដកដង្ហើមធំមិនធ្វើយតបថាអ្វីសោះ ។

ឯឡៅពីក៏ប្រើស៊ុនខៀនឲ្យត្រឡប់ចេញទៅប្រាប់គួនអ៊ូថា ឥឡូវ
អ្នួនសៀវប្រើយើងទឹងកាន់យ៉ុង ឲ្យទៅបញ្ចុះបញ្ចូលឡៅប៉ៀវចេញហ្មាយ
ស្រុកកេងដ៏វ ដូច្នេះកុំឲ្យគួនអ៊ូចូលមកឡើយ ឲ្យនៅចាំនៅទីនោះចុះ ។
ស៊ុនខៀនក៏លាឡៅពីចេញទៅប្រាប់គួនអ៊ូតាមបង្គាប់ ។ ឯឡៅពីក៏នាំ
កាន់យ៉ុងចេញពីស្រុកគីដ៏វទៅ គួនអ៊ូបើញឡៅពីទៅដល់ក៏មានអំណរ
ណាស់ ចុះពីលើខ្នងសេះទោតំនាប់ឡៅពី ហើយក៏ពណិនារឿងក៏វ
ដែលត្រាត់ប្រាសនិងសត្នាតាំងពីដើមដល់ចប់ឲ្យឡៅពីស្តាប់គ្រប់ប្រការ
ហើយនាំឡៅពីចូលទៅកន្ទុងគួនតេង ទើបនិយាយទឹងគួនតេងថា ដែល
ខ្ញុំមកតាមដិតដោយដូច្នេះ ព្រោះសេចក្តីចាំបាច់ត្តគតអាល័យវិស័យជូចបង
ខ្ញុំបង្កើត ឥឡូវបានដួបទឹងឡៅពីជាបងខ្ញុំហើយ ។

គួនតេងក៏ហៅកូនចាំង ២ ឲ្យចេញមកតំនាប់ឡៅពីវ ក៏សួរថា
អ្នកទឹងកូនចាំង ២ នេះឈ្មោះអ្វី? គួនអ៊ូប្រាប់ថា: បិតាឈ្មោះគួនតេង
ជាសៃស្រឡាយជាមួយទឹងខ្ញុំ, ឯកូនចាំង ២ នោះ កូនច្បងឈ្មោះគួន
ហ្វេង ប្អូនឈ្មោះគួនប៉ង ។ គួនតេងដំកបឡៅពីថា: ខ្ញុំបានទឹង
ឲ្យគួនប៉ងជាកូនភៅខ្ញុំទៅនៅទឹងគួនអ៊ូ តែវិកងថាលោកមិនយល់ព្រម

ផង ។ ខ្មៅពីក៏សួរថា អាយុគួនប៉ែងប៉ុន្មានឆ្នាំហើយ? គួនតេងឆ្លើយ
ថា អាយុគួនប៉ែង ១៩ ឆ្នាំហើយ ។ ខ្មៅពីថាអ្នកឲ្យគួនប៉ែងទៅនៅនឹង
គួនអ៊ីនោះ យើងក៏មានសេចក្តីត្រេកអរណាស់ ព្រោះគួនអ៊ីគ្មានកូនសោះ
ចូរអ្នកតាំងចិត្តប្តេជ្ញាឲ្យគួនប៉ែងទៅជាកូនចិញ្ចឹមគួនអ៊ីចុះ ។ គួនតេងបាន
ស្តាប់ដូច្នោះក៏ពេញចិត្តណាស់ ទើបសូមអនុញ្ញាតឲ្យគួនប៉ែងធ្វើជាកូន
ចិញ្ចឹមគួនអ៊ី ហើយឲ្យហៅខ្មៅពីជាអាពុកធំ ។ ខ្មៅពីក៏និយាយនឹងគួន
តេងថា កាលបើយើងនឹងបង្អង់នៅទីនេះយូរទៅ ខ្លាចអ្នកស្រែវាជនឹងការណ៍
ទីឯគិតតែប្រែឡើងវិញ ឲ្យគាហានមកតាមយើងយកទៅ ដូច្នេះយើង
ត្រូវស្រែតចេញទៅឲ្យផុតទើបស្រួល ។ គួនអ៊ីយល់ត្រូវឯងក៏នាំគ្នាលា
គួនតេង នាំគួនប៉ែងនឹងគាហានតាំងពួនតម្រង់ទៅផ្ទះកំដោរជាវាស័ន គួន
អ៊ីដឹះសេះនាំមុខ ទទួលដួចនឹងដាវឆេងលើកគាហានក្រុមហែលជាង ៣០
នាក់ ឃើញគាយត្រូវអាវុធមុតអស់តាំងខ្លួន ឈាមគឹបលាក់ជោក
ពងគាយតាំងនាយតាំងកូនគាហាន គួនអ៊ីក៏នាំដាវឆេងចូលទៅតំនាប់
ខ្មៅពី ដាវឆេងតំនាប់ខ្មៅពីរួចហើយដំពាបថា កាលគួនអ៊ីប្រឡំបាទទៅ
រកហ៊ុយឆ្លួនសៀវនោះ មានគាហានម្នាក់ដឹះសេះមកតែម្នាក់ឯងសម្លាប់
ហ៊ុយឆ្លួនសៀវស្លាប់ ខ្ញុំបាទក៏ចូលទៅចាំតាំងតគ្នានឹងគាហាននោះ
ទៀត គាហាននោះពូកែណាស់ គាប់ចាក់ខ្ញុំបាទនឹងគាហានត្រូវរបួស
ពីគាត្រៃប់គ្នា ខ្ញុំបាទវេនតុំឈ្នះក៏ប្រាសរត់មក ឥឡូវគាហាននោះឃុំនាំ
គាហានហ៊ុយឆ្លួនសៀវទៅលើកំដោរជាវាស័ន ។ ខ្មៅពីសួរថា គាហាន
នោះរូបរាងមុខមាត់យ៉ាងដូចម្តេច អ្នកឯងស្គាល់ឬទេ? ដាវឆេងឆ្លើយថា:

ឈ្មោះនោះខ្ញុំបាទមិនស្គាល់ទេ តែឃើញរូបកាន់ខ្ពស់ធំម៉ាមួនណាស់ ។ ឡៅតន៍ធ៌គួនអ៊ូកឹទ្យាំាឡើងទៅលើភ្នំដោ៉ាជាវេន ហើយជាវេនទៅស្រែកជេរជៀលគ្នុះ ។

ខៀវដូឡុងបានឮដូច្នោះខឹងណាស់ ក៏ពាក់ក្រែរឡើងជិះសេះកាន់ខ្លួនចេញមកមុខភ្លាមៗ ឡៅតីក្រែរឡែកទៅឃើញក៏ស្គាល់ឡាស់ជាដូឡុង ឡៅតីក៏បរសេះចេញទៅបង្ហាញខ្លួនឲ្យខៀវដូឡុងឃើញ ខៀវដូឡុងក្រែរឡែកទៅស្គាស់ជាក់ជាឡៅតីក៏ត្រែកអរណាស់ លោតចុះពីលើសេះចោះខ្លួនចេញពីដៃ ហើយចូលទៅគំនាប់ឡាតី ។ គួនអ៊ូក្រែរឡែកឃើញខៀវដូឡុងចូលមក ក៏ចុះពីលើសេះទៅគំនាប់ហើយសួរខៀវដូឡុងថា ហេតុដូចម្តេចបានជាអ្នកមកនៅលើភ្នំនេះ? ខៀវដូឡុងឆ្លើយថា កាលខ្ញុំបាទនៅជាមួយកងស៊ុនចាន ។ ឯានឆ្លើសឆ្លាមមិនព្រមជឿស្តាប់ពាក្យទីប្រឹក្សាចាំងពួង ទើបថ្វាស់ការចាញ់អ៊ួនសៀវតាល់តែខ្លួនអនិច្ចកម្ម អួនសៀវឲ្យភាហានមកលួងលួនលោមខ្ញុំបាទជាច្រើនគ្រា ខ្ញុំបាទដឹងចិត្តអួនសៀវបានជាមិនព្រមទៅនៅជាមួយផង លុះខ្ញុំបាទដឹងថាលោកមកនៅស្រុកតីជីវនេះក៏ស្វែងនឹងទៅរកលោក លុះទៅដល់កណ្តាលផ្លូវឮដំណឹងថាលោកចាញ់ត័ពបួធូ ខ្លួនលោកក៏បែកទៅនៅនឹងអួនសៀវ ឮថាអ៊ួនសៀវក្វាត់ទៅនៅនឹងបួធូ លុះខ្ញុំបាទនឹងតាមលោកទៅស្រុកតីជីវក៏ខកខ្វាចអ៊ួនសៀវដើងនឹងនឹងខឹងបងគំនុំព្យាបាទធ្វើអន្តរាយខ្ញុំបាទ ។ ក៏ស្វែងមកជួបនឹងពួកចារនៅលើភ្នំនេះ ហ៊ុយដ្ឋនសៀវក៏លើកបក្ខពួកចេញមកនឹងដណ្តើមយកសេះខ្ញុំបាទ ។ បានច្បាំងគ្នាជាពន្ធឹក ខ្ញុំបាទក៏សម្លាប់

ហ៊ុយឆ្ងន់សៀវស្ងាប់ ស្រាប់តែពួកចោរបែកទៅខ្លះ ខ្ញុំបានកំឃុំពួកចោរ
នៅសំពាកលើភ្នំនេះ បានឮដំណឹងថាខ្មៅហ៊ុយមកធ្លើចាហ្វាយស្រុក
កៅសៀ ខ្ញុំបានគិចាំស្តាប់ដំណឹងឲ្យច្បាស់ជាមុនទើបទៅកេខ្មៅហ៊ុយ ។

ខ្ញៀតពីនឹងគួនអ៊ូ គាំងអស់គ្នាក៏តណិនារឿងព័ត៌ជែលបែកទៅនៅនឹង
អ្នងសៀនើងចូលនោះឲ្យខ្មៅដូឡឹងស្តាប់គ្រប់ប្រការ ហើយខ្ញៀតី ថា
យើងបានជួបនឹងអ្នកកាលគ្រាដែលអ្នកនៅនឹងគងស៊ុនចានោះ យើង
ក៏ជាប់ចិត្តស្រឡាញ់ពេកណាស់ តែដោយឥតបុណ្យវាសនា បានជាមិន
បានអ្នកមកជួយធ្វើការទេង ឥឡូវបុណ្យសំណាងយើងល្អត្រកាល ទើប
បណ្តាលឲ្យមកជួបប្រទះគ្នានៅទីនេះ គួរអ្នកនឹងរិះគិតទៅនៅធ្វើការជា
មួយនឹងយើងចុះ ។ ខ្មៅដូឡឹងធ្វើយថា : " ខ្ញុំបានសូវស្ងឹងគ្រប់
ស្រុកគ្រប់ដំបន់ច្រើនដំណាក់ ដើម្បីនឹងរកទីពឹងពំនាក់ឲ្យមានស្វាមីភក្តី
ស្មគ្រ ស្រឡាញ់ឲ្យអស់អញ ដូចខ្ញុំបានពាក់អានស្រឡាញ់លោកនោះ
គ្មានសោះ គ្រានេះជាបុណ្យវាសនារបស់ខ្ញុំបានបានមកជួបប្រទះនឹង
លោកហើយ ខ្ញុំបានក៏សូមផ្ញើរូបអង្គឫទ្ធិចិត្តទៅជាបាវលោកឲ្យលោក
ប្រើប្រាស់តាមការចុះ ទោះបីភ្លាប់រស់ឬទីបានសេចក្តីក្រៃលំបាក
ប្រការដូចម្តេចក៏ដោយ ខ្ញុំបានក៏សូមយកអាសាគ្រាតែរលត់ផុតជីវិតទៅ
ចុះ " លុះពណិនាប្រាប់ស្តីគ្រប់ប្រការដូច្នេះហើយ ខ្មៅដូឡឹង
ក៏នាំពួកគ្រឿនចាំងនោះតាមខ្ញៅតីទៅស្រុកកៅសៀ ។

ឯខ្មៅហ៊ុយនឹងបីតុកបីហាង ដឹងថាខ្ញៅតីមកដល់ស្រុកហើយ
មានអំណរណាស់នាំគ្នាចេញទៅទទួលខ្ញៅតីនាំចូលមក ។ ខណៈនោះ

នាងគាំហ៊ីយិន នាងប៊ីហ៊ូយិនក៏ចេញមកគំនាប់ឡៅពី ហើយតណិនា
រឿងដែលត្រាត់ប្រាសនិកសគ្នា តាំងពីដើមរហូតដល់គ្រាំបាក់បែកខូច
ស្រុកហែហ្ម៉ឺ ទឹងដែលគួនអ៊ូទៅនៅជាមួយទឹងចូនួសពុត្រប់ប្រការឲ្យឡៅ
ពីស្តាប់ ឡៅពីបានស្តាប់ហើយក៏សរសើរគួនអ៊ូ ថាជាមនុស្សមាន
សេចក្តីស័ត្យតត្ថញ្ញូទឹងរកនរណាស្មើគ្មាន ខ្លៀវហ៊ុយក៏ឲ្យតែងត្រឿនបួង
សួងដល់ទេពតា ហើយលៀងគោជនាហារ ។

លុះកន្លងមក ថ្ងៃមួយនោះឡៅព័ក៏ប្រជុំប្រឹក្សាទឹងគួនអ៊ូ ខ្លៀវហ៊ុយ
ទៅអស់សេនាឧហានចាំងពួងថា: ស្រុកកៅសៀនេះ ជាស្រុកចំការ
ដែលទឹងទៅជាទំមាំមួននោះមិនបានទេ ត្រូវយើងនាំគ្នាទៅនៅស្រុកយ៉ី-
ហ្វាំវិញ ព្រោះជាទីដែនស្រុកធំទឹងបានជាទីមាំមួនគិតការតទៅ ។ ខណ្ឌ
មានបំរើសេះម្នាក់កាន់សំបុត្រឡៅផេក មកជូនឡៅពី សេចក្តីថា:
ឥឡូវឡៅផេកដឹងថាឡៅពីមកនៅស្រុកកៅសៀនោះ មិនជាទីមាំមួនទេ
បានជាមានសំបុត្រមកសុំអញ្ជើញឡៅពីទៅតាំងនៅស្រុកយ៉ីហ្វាំវិញ" ។
លុះឡៅពីដឹងក្នុងសេចក្តីសំបុត្រដូច្នោះហើយក៏មានអំណរណាស់ ប្រឹក្សា
ឃើញព្រមគ្នា ទើបនាំគួនអ៊ូ ខ្លៀវហ៊ុយនូវអស់គ្រួសារទឹងឧហានឯក
ត្រមាំងពលសេនាឧហានចាំងពួងប្រហែល ៥០០ ជួយនាក់ ទៅ
នៅស្រុកយ៉ីហ្វាំ ។

ឯអ៊ូនសៀវដឹងច្បាស់ដូច្នោះក៏ខឹងណាស់ ទើបកេណ្ឌសេនាឧហាន
ទឹងលើកទ័ពទៅចាប់ឡៅពី ។ គួរតែដំកបថា: ដែលលោកនឹងលើក

ទ័ពទៅចាប់ខ្មៅពីនោះ ខ្ញុំបាទយើញថាមិនគួរសោះ ពោះបីខ្មៅពីមិនបានទៅបញ្ចុះបញ្ចូលខ្មៅជ្រៀមកជួយគិតការក៏មិនជាការអ្វី សព្វថ្ងៃនេះ ខ្ញុំបាទមានបារម្ភណ៍ខ្លាចតែចូធូជាសឹកសត្រូវនឹងស៊ុនសេីក ដែលតាំងនៅស្រុកកំងតាំងនោះ មានទាហានជាច្រេីន ស្បៀងអាហារចំណីគ្រឹះសាច់កំបិរបូណ៌ មានស្រុកខ្សែន ៦ មណ្ឌល សូមលោកនែគិតរកចាត់ច្រេីអ្នកណាដែលមានសតិបញ្ញា ឲ្យទៅនិយាយបញ្ចុះបញ្ចូលស៊ុនសេីកមកចុកឲ្យជួយគិតការកំចាត់ចូធូដែលជាសឹកសត្រូវធំចេញទេីបគួរ ឯខ្មៅពីនោះទាហានក៏តិច បេីលោកនឹងលេីកទ័ពទៅច្បាំងវេលាណាក៏ចេះតែបានដោយងាយណាស់ ។ អ្នកសៀវយល់ព្រមផង ទេីបធ្វេីសំបុត្រចាត់ច្រេីតាន់ជឺនឲ្យទៅបញ្ចុះបញ្ចូលស៊ុនសេីក តាន់ជឺនក៏ទទួលសំបុត្រហេីយលាអ្នកសៀវទៅ ។ ឯស៊ុនសេីកទៅហ្វាយស្រុកកំងតាំងនោះ កាលព្រះចៅហៀនតេសោយរាជ្យ ស្តេចយាងទៅទៅក្រុងហ្គីគោបាន ៤ ឆ្នាំនោះ ស៊ុនសេីកលេីកទ័ពទៅវាយស្រុកលោកំង ស្រុកអ៊ុចៀង បានហេីយៈកវិយកគ្រួមកចុកបានជាច្រេីន ។

* * *

កណ្ឌទី ២៦

តាំងពីស៊ុនសេីកវិយយកបានអាណាខែត្រមកជាចំណុះច្រេីន ហេីយមានចិត្តកំរេីបធ្វេីបុតម៉ាយក្រាបទូលព្រះចៅហៀនតេយកគុណតាប់ រហូតដល់អ្នកសៀវលេីកទ័ពទៅច្បាំងនឹងចូធូទៅដំបន់ចូរៀង ។

ស៊ុនសេីកមានចិត្តកំរេីប ទេីបធ្វេីបុតម៉ាយប្រៃខ្វៃវៃហៀនឲ្យកាន់ចូលទៅក្រាបទូលព្រះចៅហៀនតេ ក្រាថ្នាន់ឲ្យមានឈ្មោះសំឡេង

យសបណ្ដាសក្ដី សេចក្ដីសំបុត្រនោះវិញ្ញាណជារឿងក៏ថា: ស៊ុនសេកហៅ
ហ្វាយស្រុកគង់តាំងបានជ្រាបជ្រាមអាណាខែត្រជារបែនតំបន់ឲ្យរាបជាប
អស់ហើយ ។ ខៀវហៀនគំនាំបុតម៉ាយនោះទៅឲ្យចូលួ ។ ឃើញសេចក្ដី
បុតម៉ាយដូច្នោះគំជកដង្រើមធំ ហើយគិតថា "ធម្មតាជាតិកូនខ្វាវមែង
តែសាហាវ ខណានឹងប៉ងប្រាថ្នាទៅធ្វើអន្តរាយដល់កូនខ្វានោះ ក៏តម្រ
ឆឹងបាន បើដូច្នោះចាំយើងគិតលើកបុត្រីជាប្អូនឆាឆោយឲ្យជាកវិយា
ស៊ុនខឆងជាប្អូនស៊ុនសេក ទើបបានស្រួលជាងមួយឆឹងស៊ុនសេក"
ហើយចូលួកំយកខ្ជូនខៀវហៀនឲុតធ្វើជការនៅក្នុងហ្ស៊ីគោ ។ ឯស៊ុន-
សេកលុះដឹងដំណឹងថា ចូលួមិនបានយកសំបុត្រទៅថ្វាយព្រះចៅហៀនតេ
ហើយយកខ្ជូនខៀវហៀនឲុតធ្វើជការក្នុងគ្រួង ស៊ុនសេកក៏ឆឹតខឆឹងខ្លាំង
ណាស់គិតឆឹងលើកកងទ័ពទៅវាយកំចាត់ចូលួជារឿយ ។ ។

ឯទៅកងចៅហ្វាយស្រុកឆឹកុនដែលជាចំណុះស្រុកគង់តាំងនោះ លុះ
ដឹងថា ស៊ុនសេកធ្វើការប្រឲុសក៏យកគ្រក់ផ្សង ។ ក៏តែងសំបុត្របក
ប្តឹងចូលទៅដល់ចូលួ ជាសេចក្ដីថា: "ស៊ុនសេកធ្វើការអាគ្រក់ដល់គាណា
ខែត្រគាំងតួងខ្លាំងពេកណាស់ សព្វថ្ងៃនេះ អ្នកពាជការឆឹងបណ្ដាកស្ត
បានសេចក្ដីក្តៅក្រហាយគ្រប់ខែត្រខ័ណ្ឌ សូមមហាឧបពាជរិះគិតឲ្យមាន
ព្រះគម្រាស់ព្រះចៅហៀនតេ ឲ្យហៅយកខ្ជូនស៊ុនសេកចូលមកធ្វើ
ពាជការឯស្រុកគ្រួងវិញ បើឆឹងបង្អង់ខុកឲ្យស៊ុនសេកនៅធ្វើជាធំ ខាង
គ្រោយយូរទៅឆឹងវិប្រជាក្បត់ផែនដីមិនខាន" លុះតែងសំបុត្រហើយក៏
ប្រើគហានឲ្យកាន់ឆ្ងាងកាត់ជ្រោយសមុទ្រទៅ ។

លុះពាហានកងត្រែវិលស្រុកភ័ងតាំងឃើញប្អូក ក៏ចាប់យកខ្លួនពុក
ត្រែតឃើញសំបុត្រក៏បញ្ជូនខ្លួនទឹងសំបុត្រទៅដល់ស៊ុនសេីក ។ ឃើញ
សំបុត្រដូច្នោះក៏ខឹងណាស់ ទេីបឲ្យយកខ្លួនអ្នកកាន់សំបុត្រនោះទៅ
សម្លាប់ ហេីយស៊ុនសេីកក៏ធ្វេីជាកលឧបាយបញ្ឆោតឲ្យពាហានទៅ
អញ្ជេីញទៅកងទៅហ្វាយស្រុកឆីកុនមកស៊ុលៀង ទៅកងមិនមានសេចក្តី
មន្ទិលសង្ស័យ ក៏ចូលមកវាកស៊ុនសេីក។ ក៏យកសំបុត្រនោះមកបង្ហាញ
ឲ្យទៅកងមេីលហេីយវៃស្រែកគំរាមថា ហេតុម្តេចក៏ឯងក្បែងធ្វេីសំបុត្រថា
អញជាមនុស្សក្បត់ផែនដី ឲ្យចូរឲ្យហៅយកខ្លួនអញចូលទៅឯស្រុកត្រែង
វិញ, ទៅកងគាល់គំនិតឥតហ៊ានឆ្លេីយថាម្តេចសោះ, ស៊ុនសេីកក៏ឲ្យពាប់
ចងនាំយកខ្លួនទៅសម្លាប់ ។ ឯបណ្តាគ្រួសារទឹងចាវ៉ែវតាំងអស់បេះស់
ទៅកង លុះដឹងដូច្នោះក៏នាំគ្នារត់បែកខ្ចាត់ខ្ចាយទៅឥស្រុកឆីកុន ទៅ
សល់តែពាហាន ទៅកង ៣ នាក់ ពាហាននោះមានចិត្តព្យាបាទស៊ុនសេីក
គិតនឹងសងសឹកវិញឲ្យបាន ទេីបបរួលគ្នាទៅទៅក្នុងព្រៃជិតស្រុកភ័ងតាំង
ប្លាថ្នាឧដ្ឋលបលួចធ្វេីអន្តរាយស៊ុនសេីកវិញ ។

មានកាលថ្ងៃមួយ ស៊ុនសេីកនាំពាហានចេញទៅបបាញ់សត្វ
ក្នុងព្រៃ ឃើញប្រេីស ១ ក៏កន្ត្រាក់ដង្ហេីរសេះដេញតាមទៅតែម្នាក់
ឯង ខ្លួលឃើញពាហាន ៣ នាក់នោះកាន់ធនូឆ្លងឈរអែបប្រុបដេីម
ឈេី ស៊ុនសេីកក៏សួរថា: ខ្លួនជាបាវនរណា មកពីណា ? ពាហានតាំង
៣ នាក់នោះក៏ប្រែតុបាយឆ្លេីយថា: ខ្ញុំបាទជាបាវហ៊ានតុងដែលជាពាហាន
ឯកបេះស់លោក បបួលគ្នាចេញមកបបាញ់សត្វក្នុងព្រៃ ។ ស៊ុនសេីក

ចានស្តាប់ក៏ឥតមានចិត្តសង្ស័យ ហើយបរសេះត្រឡប់ចេញពីទីនោះទៅ ។ គហានទាំង ៣ នាក់នោះឃើញចានការ គហានម្នាក់យកខ្លួនចាក់ត្រូវដើមត្នោតស៊ុនសេីក ១ ផ្លែ ម្នាក់លេីកធ្នូបាញ់ទៅត្រូវមុតស៊ុនសេីក ៧ ក័យ ស្ទុតកន្ត្រាក់ដងត្រូវបាញ់ចាន ហើយបាញ់ទៅត្រូវគហាននោះស្លាប់ម្នាក់ ។ ឯគហាន ២ នាក់ក៏យកខ្លួនចូលមកចោមចាក់ស៊ុនសេីក ហើយសែកគំរាមថា: អញជាគហានទៅកង ដែលអញនាំគ្នាមកធ្វើដូច្នេះគ្រាថ្នាទឹងសងសឹកចៅហ្វាយអញ ។ ស៊ុនសេីកគ្មានអាវុធនៅដៃសោះ យកតែដងធ្នូចាត់ទះការពារខ្លួនមិនឲ្យគាប់ចាក់ត្រូវខ្លួន មានត្រូវបួសមុតជាច្រេីនអន្លេី ។

ខ្លួលទៀត ជិះសេះនាំគហានប្រហែល ៩ ឬ ១០ នាក់តម្រង់ចូលមកជិត, ស៊ុនសេីកក៏សែកហៅឲ្យជួយ ទៀតនឹងគហានឃើញដូច្នោះគិបរសេះចូលទៅកាប់គហានទាំង ២ នាក់ខោះដាច់ខ្លួចខ្លីអស់ទាំងខ្លួនតាល់តែស្លាប់ ហើយត្រឡប់ទៅមើលស៊ុនសេីកឃើញមុខត្រូវត្រូញមួយអន្លេី ពងកាយក៏ត្រូវបួសនឹងខ្លួនជាច្រេីនអន្លេី ទៀតក៏យកក្រមាត់ជាយអាវមកព្រុំបួសឲ្យស៊ុនសេីក ហើយគាប់នាំចូលមកស្រុកវិញ ស៊ុនសេីកក៏ប្រែបំរេីឲ្យទៅកខ្វក់ហ្ន៎គោជាតេវ្យឲ្យមកវក្សាបួសនោះ ។

(មានត)

រឿងព្រេងនិទាន

លោកសមិនមូត្យ៍នដម:តែង

លោក រ៉ាយ-ប៊ុក ក្រមការ ដើមខ្សែ ប្រែរៀបរៀង

(តទៅ)

និទានទៃរូបទេពធីម្មិតទី ២៩

មានកាលមួយថ្ងៃ, ព្រះបាទកោដ:ទ្រង់ស្តេចចូលទៅដិតបល្ល័ង្ក ធិព្យដើម្បីទំនឹងមកលិសកសោយរាជ្យ ។ រូបទេពធីម្មិតទី ២៩ បានឃើញ ព្រះបាទកោដ:មានព្រះរាជដំណាងដូច្នោះ ក៏ក្រាបទូលថា:

"មានកាលមួយថ្ងៃ, វៃតាលិក (Vaitalika) ម្នាក់ បានទៅដល់ មុខភ្លៅឯក្សត្រព្រះបរមរាជាំងនៃព្រះបាទវិក្រមាទិត្យហើយ និយាយទៅ កាន់នាយទ្វារថ្វាលថា: "នែនាយទ្វារថ្វាល ! ខ្ញុំបានឮនូវព្រះរាជកិត្តិសព្ទ នៃព្រះមហារាជដែលជាស្តេចចក្រពត្តិ ព្រះនាម ព្រះបាទវិក្រមាទិត្យ ខ្ញុំទើបមកអំពីប្រទេសឆ្ងាយកាត់ប្រទេសជាច្រើន ដើម្បីទំនឹងមកក្រាបបង្គំ គាល់ព្រះអង្គ, ដូច្នេះ សូមអ្នកអញ្ជើញទៅក្រាបបង្គំទូលព្រះអង្គឲ្យទ្រង់ ជ្រាបផង" ។ នាយទ្វារកាលបានស្តាប់នូវពាក្យវៃតាលិកហើយ ក៏យក ដំណឹងនេះទៅជំរាបអ្នកនាំព្រះរាជសារ ។ ក៏បានយកសេចក្តីក្រាបបង្គំទូល ព្រះនរបតី ។ ទ្រង់បានព្រះរាជានុញ្ញាតឲ្យវៃតាលិកនោះ ចូលក្រាបបង្គំ គាល់ព្រះអង្គ ។ វៃតាលិកនេះបានកាន់ដំបងមួយថ្ងៃមាស ២០០៨ ដំឡឹង

ដើរចូលទៅដល់ក្រុមព្រះពាជទីប្រឹក្សា ហើយក្រេឡេកមើលខ្លួនការរៀបចំ
កន្លែងនេះ ឃើញមានរបៀបរៀបរយល្អអស្ចារ្យ ។ គាត់ក៏បានចោល
កន្ទុយក្អែកទៅកាន់ព្រះចក្រពត្តិពាជ ព្រះនាម ព្រះបាទវិក្រមាទិត្យ
ដែលមានព្រះពាជទីប្រឹក្សាជាច្រើនរយ, រដ្ឋមន្ត្រីប៉ុនប្រសប់, ក្រុមវិញ្ញូ-
ជន ដូចជាកូលីទាស: ឧទិនបណ្ឌិតឯទៀត ដែលមានតិត្តិសព្ទល្បីល្បាញ
ជាងគេ ជាព្រះពាជបរិវារ ព្រមទាំងមានអ្នកកាន់ផ្ទៃតសធំ ។ ឧទិនក្លិតគួច ។
កាន់ព្រះគទាវុធមានលាបលនដោយទឹកមាសដាំស្វង់ដើរអមព្រះអង្គ គាត់
ក៏ធ្វើអញ្ជលីថ្វាយបង្គំ ហើយក្រាបទូលថា: "បពិត្រព្រះចមកព,
ទូលព្រះបង្គំបានមើលតិត្ថិទ្វារព្រះពាជទីប្រឹក្សាព្រះអង្គ ឧទិនព្រះពាជបរិវារ
ព្រះអង្គ ទូលព្រះបង្គំហាក់ដូចជាបានមើលតិរ៉ាបុណ្យអ្វីមួយដ៏ឧឡារិក
ដែលទូលព្រះបង្គំមិនធ្លាប់បានឃើញពីមុនមកសោះ" ។

ក្រោយដែលវៃតាលិកបានក្រាបបង្គំទូល ព្រះបាទវិក្រមាទិត្យ
ទ្រង់មានព្រះពាជបញ្ជាឲ្យវៃតាលិកថយចេញទៅខាងក្រៅ ។ ក្នុងវេលា
នោះ ស្រាប់តែមានបុរសថ្កាត់ដៃម្ខាងកាន់ដាវ, ដៃម្ខាងទៀតកាន់ដៃនារី
ម្នាក់ ដែលមានរូបឆោមលោមពិណស្រស់ច្រមុះច្រមាយ, នាំចូលមកដល់
ព្រះអង្គ ហើយក្រាបបង្គំទូលថា "បពិត្រព្រះនរបតី មានបុគ្គលជាច្រើន
បានយល់ឃើញថា នៅក្នុងវិជ្ជាសង្ឃរនេះ វិទ្យាសាស្ត្រជាវត្ថុដ៏សំខាន់បំផុត;
នេះមិនមែនជាសេចក្តីយល់នៃទូលព្រះបង្គំទេ ។ បើតាមយោបល់
ទូលព្រះបង្គំ គឺនារីប្រកបដោយលំអយ៉ាងក្រៃលែង ឧទិនការត្រេកត្រអាល
នៃបុរសចំពោះនារីនោះជាច្រើនលើក, នេះទើបគុណជាការសំខាន់បំផុត ។

វត្តចាំងពីរយ៉ាងនេះ ខ្ញុំលែងបានលះបង់ទៅឲ្យអ្នកដទៃទេ ។ តែកន្លងពេលឥឡូវនេះ ទៅលើមេឃ (នគរស័ក) មានភ្លៀងយុទ្ធរាំងទៅតាន់ធំណាស់ ។ ខ្ញុំលែងត្រូវចូលទៅយកអាសាព្រះឥន្ទ្រាធិរាជកន្លងស្រង្គ្រាមនោះ ។ ស្តែនេះជាកិរិយាខ្ញុំលែងព្រះបង្គំ ដែលខ្ញុំលែងព្រះបង្គំមានចិត្តស្នេហាស្មើជីវិតខ្ញុំលែងព្រះបង្គំ តែតាមពិត ការចូលទៅតយុទ្ធទៅសមរភូមិមិនត្រូវយកកិរិយាទៅផងទេ ។ បើខ្ញុំលែងព្រះបង្គំយកកិរិយានេះទៅផ្ញើនឹងអ្នកឯទៀតក្រៅអំពីព្រះអង្គ, ខ្ញុំលែងព្រះបង្គំមិនអាចទុកចិត្តបានឡើយ ។ តែខ្ញុំលែងព្រះបង្គំបានយល់ថា ព្រះអង្គទ្រង់មានព្រះពាជ្ញាដ៏ឃ្លាស្មោះត្រង់ចំពោះបទបញ្ជាក្តិច្បាប់, ទ្រង់ជាព្រះពាជ្ញាបុគ្គលចំពោះប្រជាជនទាំងអស់ព្រមទាំងព្រះពាជ្ញាសេវាគាមាត្យ, ទ្រង់ជាអ្នកឈ្នះខ្លួនវាគាចិត្តលេស, ទ្រង់ជាអ្នកប្រកបដោយព្រះមហាករុណាគុណ; គឺថាក្រោយដែលខ្ញុំលែងព្រះបង្គំយកកិរិយាមកផ្ញើនឹងព្រះអង្គ ទើបខ្ញុំលែងព្រះបង្គំទៅកាន់សមរភូមិបាន ។ នេះជាចំណាងរបស់ខ្ញុំលែងព្រះបង្គំ ។ ខ្ញុំលែងព្រះបង្គំធ្លាប់បានយកអាសាអ្នកដទៃជារឿនណាស់ម៉ាកហើយ; ហេតុនេះសូមទ្រង់ព្រះមេត្តាប្រោសទទួលកិរិយាខ្ញុំលែងព្រះបង្គំទុកឲ្យទៅជាមួយព្រះអង្គផង, ចំពោះខ្ញុំលែងព្រះបង្គំវិលត្រឡប់មកពីធ្វើសង្គ្រាមវិញ" ។

ព្រះបាទវិក្រមាទិត្យយល់ព្រមទទួលកិរិយាបុរសនោះយកទៅថែរក្សា ។ បុរសនោះក៏ធ្វើដំណើរទៅកាន់សមរភូមិតណ្ហាលអាកាស ។ ព្រះមហាក្សត្រិយ៍, ព្រះពាជ្ញាទីប្រឹក្សា មានចិត្តឆ្ងល់ពន់ពេកចំពោះ

អាកប្បកិរិយានៃបុរសនោះ កំឈរធើ្វមើលទៅបុរសនោះដែលកំពុងហោះទៅក្នុងអាកាសតាល់តែផុតកន្ទុយភ្នែក ។

កាលបុរសនោះបាត់ខ្លួន អ្នកណាលែងមើលឃើញហើយភ្លាម, ខាលំយុតាំងមួលពេញទៅដោយស័ព្ទស្រែកសំឡេងគឹកកងរំពងដូចជាមានកងច័ព្រួយទ្ធគ្នាលើទីនោះ។ ព្រះមហាក្សត្រិយ៍ព្រមទាំងព្រះពជទិប្រឹក្សាទីដ៏ជនាខ្មុជនឯទៀត, សឹងតែបានឮខ្លួវស្រួវស័ព្ទដែលលាន់ខ្ទរខ្ទារពាសពេញមេឃនោះ ហើយមានសេចក្តីសង្ស័យគ្រប់គ្នា ។ ក្នុងពេលនោះ, ស្រាប់តែដៃពីរនៃស្លាមីនាង ក៏ដាច់ធ្លាក់មកចំមាត់ខ្លារចូលទៅក្នុងទីក្រុមព្រះពជទិប្រឹក្សាអមព្រះអង្គ, លំដាប់តមក, ជើងពីរក៏ធ្លាក់មកទៀត, រួចក្បាលបុរសនោះក៏ដ្រុះមកជាលំដាប់ ។ កិរិយានៃបុរសដាច់ក្បាល គ្រឡែកទៅឃើញក្បាលស្លាមី ដាច់ធ្លាក់មកដូច្នោះ គំយំសោកស្តាយស្រណោះអាឡោះអាល័យជាខ្លាំង ហើយគ្រាបថង្គំទូលព្រះមហាក្សត្រិយ៍ថា: "ប្តីខ្ញុំមាស់ដូចជាព្រះចន្ទពេញបុណ្ណមីបិតទៅក្នុងអាកាសដែលមានពពកបិទបាំងឬដូចជាផ្កែកបន្ទោរក្តីហើយរលត់រលាយបាត់ទៅក្នុងពពក, ករណីយកិច្ចនៃកិរិយាត្រូវតែរស់នៅជាមួយស្លាមី គឺថាកិរិយាមិនត្រូវបោះបង់ចោលស្លាមី ខ្ញុំមាស់ទើមិនលះបង់ចោលស្លាមីទេ។ ដូច្នេះសូមព្រះអង្គទ្រង់គ្រាស់បង្គាប់ឲ្យគេបែមូលទុសទើរត្រឡប់ ។ មកតរសម្រាប់ធ្វើឈាបនកិច្ចនូវខ្លួនខ្ញុំមាស់ជាមួយនឹងសពប្តីនេះ" ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្តាប់ នូវពាក្យកិរិយានៃបុរសនោះ ក៏មានព្រះពជហ្ឫទ័យតក់ស្លុត ព្រមទាំងអាណិតអាសូរដល់នាងពន់ពេក

ហើយមានព្រះពុទ្ធដីកាថា: "នាង! មនុស្សរស់មានការធ្វើគមនាគមន៍ជាមួយគ្នា កន្លងវេលាដែលជីវិតរស់នៅ ។ បើស្វាមីនាងមានជីវិតរស់នៅ ស្វាមីនោះមានចំណងជាប់ទឹងនាងជាប្រពន្ធ ។ តែហេតុម្តេចកើនាងចង់លះបង់រូបនាង ដោយហេតុតែបុរសម្នាក់ដែលគ្មានធ្វើអ្វីល្មមឲ្យនាងសោកស្តាយ តើមានបទបញ្ញត្តិច្បាប់ណាដែលបង្ខំនាងឲ្យប្រព្រឹត្តតាមតួកិច្ចបែបនេះ ដែលនាងត្រូវធ្វើឥឡូវនេះ? ។ បើនាងខឿយណាយទឹងវត្តគ្រែ, ចូរនាងកុំព្រហ្មចរិយធម៌ឲ្យគន់វង់ហើយនាងខំគោរពបូជាព្រះឥសូរជានិរន្តរ៍ចុះ ។ បើនាងមានចិត្តសប្បាយក្នុងលោកាមិសនៅឡើយ ចូរនាងយកស្វាមីមួយទៀត ដែលនាងពេញចិត្ត ហើយត្រេកត្រអាលសប្បាយឲ្យបាននៅសុខដុំរមនាតទៅ ។ យើងនឹងប្រគល់ទូវកោគទៅឲ្យនាង ដើម្បីកុំឲ្យនាងមានទោសទុក្ខអ្វីសោះឡើយ" ។

នាងនោះលុះបានស្តាប់ទូវព្រះបន្ទូលសូរសីហនាទហើយ ក៏ទូលតបថា: "បពិត្រព្រះបរមគ្រូធម្ម ខ្ញុំម្ចាស់ជានិមិត្តរូបនៃការណីយកិច្ចគាំងឡាយចំពោះប្តីខ្ញុំម្ចាស់; ព្រោះហេតុដូច្នោះ ស្នាដៃរបស់ខ្ញុំម្ចាស់ គឺការគោរពតាមការណីយកិច្ចនេះ ។ ដោយគុណធម៌នៃខ្ញុំម្ចាស់, ខ្ញុំម្ចាស់អាចប្រព្រឹត្តព្រហ្មចរិយធម៌ ដែលមានគោលការណ៍ថា លះបង់តាមឆន្ទៈបាន ហើយខ្ញុំម្ចាស់ទឹងប្រព្រឹត្តការណីយកិច្ច ដែលញុំាងចិត្តខ្ញុំម្ចាស់ឲ្យស្មោះត្រង់ទឹងស្វាមី ។ តែបញ្ហានៃតណ្ហាដែលស្ថិតនៅក្នុងរូបមនុស្ស, សេចក្តីយល់ឃើញជាក់ច្បាស់ចំពោះបាមិត្ត ដែលមានអានុភាពអស្ចារ្យ, ការអនុវត្តន៍

ចំពោះបុណ្យកុសល, វត្ថុទាំងនេះត្រូវមានវិរិយភាពជាមូលដ្ឋាន ទើបប្រព្រឹត្តទៅបាន; ខ្ញុំម្ចាស់មានចិត្តទុព្វលភាពមិនអាចប្រព្រឹត្តបានទេ ។ ការប្រតិបត្តិតាមបទបញ្ញត្តិច្បាប់ សម្រាប់ស្ត្រីមេម៉ាយដែលមានសាស្ត្រៈបានតំណាត់ខុក មានសភាពលំបាកពន់ពេក ។ លក្ខខ័ណ្ឌនៃស្ត្រីមេម៉ាយនាំឲ្យស្ត្រីនោះប្រព្រឹត្តខុសឆ្គងឆ្គាំឆ្គង ។ ដូចជាកិរិយាត្រូវបានទទួលក្បែរមត៌កបស់ស្វាមី, មរណភាពនៃកិរិយា គឺមកពីមរណភាពនៃស្វាមីដូចគ្នាដែរ ។ បពិត្រព្រះមហាវីរៈ ក្នុងសាសនាព្រះពុទ្ធហេតុឆ្គង, កាលណាគេបានអុជភ្លើងក្រោយដែលបានសូត្រមន្តវេទ កាលនោះគឺជាអតិលទ្ធកាល ដែលគេធ្វើពិធីផ្សំដណ្តើមរវាងស្វាមីនឹងកិរិយា គឺចំពោះតែប្រពន្ធរវាងគ្នាទៅវិញទៅមក ដែលជាមូលដ្ឋាននៃព្រះពុទ្ធហេតុឆ្គង ។ ឧទាហរណ៍ ដូចស្ត្រីជាទម្រង់ក្រៃនៃថាមភាពបុរស ។ បិតនៅបានដោយគ្មានថាមភាព តែបើគ្មានបុរសថាមភាពក៏មិនអាចបិតនៅបាន ។ មួយទៀតដូចអគ្គីដែលគេយកមហាទុសធំ (ausadhis) ទឹងមន្តវិសេសយកមកអុជ អគ្គីអាចកើតមានបានដោយសារមានអាទុកាពនេះ, តែអាទុកាពនេះមិនអាចមានបានបើគ្មានអគ្គី ។ បពិត្រព្រះសម្មតិទេព គេអាចស្គាល់បានដោយសុភិតកន្លោកថា បុគ្គលណាច័ន្ទឹងឬជាជីវិតដល់វត្ថុណា បុគ្គលនោះឈ្មោះថាអ្នកធ្លាប់លះកម្មដោយជីវិត ដែលមានសេចក្តីពេញចិត្តទឹងវត្ថុនោះពេញលក្ខណៈ ។ ព្រោះហេតុដូច្នោះ, បពិត្រព្រះបមកព, តាមយោបល់លោកសន្ទិវាស, សាស្ត្រៈទឹងតក្កវិជ្ជាត្រូវតែប្រព្រឹត្តសកម្មភាពនេះ ជាជាប់ខាតខានមិនបាន ។ តើមានផលប្រយោជន៍អ្វីត្រង់ការ

ស្តាបនាទូរទៅបសគ្គមានចំនួនយ៉ាងនេះ ? កាលណាគ្រាជ្ញាបុគ្គលផ្តិតជាប់នៅនឹងវត្តមួយ បុគ្គលឯទៀតទៀតចំហាម តែជាការឥតប្រយោជន៍សោះ ។ ដូចជាទឹកហូរទៅកាន់ទីតាប បើអ្នកណាបង់ឃាត់ឲ្យទឹកនោះឈប់ហូរទៅវិញ ជាការឥតប្រយោជន៍ទាំងអស់" ។

ព្រះនរបតីទ្រង់ព្រះសណ្តាប់នូវពាក្យនៃនាងជាភរិយាបុរសនោះហើយទ្រង់ឈ្វេងយល់ថា "នារីនេះសម្រេចជាប់ខាតថានឹងខ្លួលអនិច្ចកម្មដើម្បីស្វាមីជាប្រាកដ", ទ្រង់ក៏មានព្រះបន្ទូលថា "ល្អហើយដែលនាងមានចិត្តស្មោះត្រង់នឹងស្វាមី ពាក្យដែលនាងពោលទាំងអម្បាលម៉ាន ជាពាក្យថ្លៃថ្លាបំផុត ! ។ ពាក្យដែលយើងពោល គឺជាពាក្យគ្មានដំរៀបឡើយ ; ពាក្យនេះគឺយើងគ្រាន់តែពិសោធមើលចិត្តនាងតែប៉ុណ្ណោះ" ។

ព្រះនរបតី, ក្រោយដែលឃាត់ទ្រង់ត្រាស់ទៅនឹងស្ត្រីដែលមានចិត្តស្មោះត្រង់នឹងស្វាមី, ទ្រង់ត្រាស់បង្គាប់ឲ្យគេធ្វើជាឈាបនដ្ឋាន ។ ដល់ពេលធ្វើពលិកម្មនាងជាភរិយាមានចិត្តក្តៅ ដោយសេចក្តីស្នេហាចំពោះស្វាមី ឃានដើរចូលទៅកន្លែងក្តក់ភ្លើង ដូចជាបុរសដែលមានសភាពក្តៅស្អុះបុះទៅកន្លែងទឹកត្រជាក់ដូច្នោះឯង ។ ព្រះមហាក្សត្រិយ៍នឹងព្រះពជនីប្រឹក្សាឃានសរសើរនូវក្តីគុណនៃនាងជាអនេកប្បការ ។

(មានត)

ការដាំដើមឈើយកផ្លែ

ឃុនអត្តកោវិទ ជ៉ា - ប៉ូរ៉ូ ពុទ្ធសាសនបណ្ឌិត្យ

ប្រែពីសៀវភៅកសិការ ឆ្នាំទី ១២ ភាសាចិន

ដើមឈើដែលគេចរិកោតផ្លែ គឺដើមឈើដែលមានអាយុយឺនយូរ ប៉ុន្តែចិនឆ្នាំ ដូចខ្នុរ ស្វាយ ក្រូចផ្សេង ។ រហូតដល់ក្រូចសើច ក្រូចឆ្មារជាដើម ។ បើភូមិលំនៅរបស់យើងមានទីដីទំនេរ យើងគួរដាំដើមឈើទាំងនោះទុក ព្រោះថាកាលយើងដាំទៅហើយ ឈើនោះក៏រស់នៅយូរអង្វែងជាច្រើនដល់កូនចៅ ជាមរតកសំខាន់សំរាប់ផ្ទេរឲ្យដល់អ្នកដែលតវ៉ាត្រកូល ។ ត្រង់អំពីយកផ្លែបរិភោគ ដើមឈើទាំងនោះនាំឲ្យមានមូលដ្ឋានជាក់ដល់ទីលំនៅរបស់យើង ហើយជាគ្រឿងលំអដល់ភូមិលំនៅខ្មែរផង ។ ដូច្នេះសូមលោកកុំខោលឧកាសដ៏ល្អនេះឲ្យសោះ បើប្រសិនជាមានទីដីទំនេរ ។ គោលទូទៅនៃការដាំដើមឈើទាំងនោះនឹងចាត់រៀបទុក ដូចតទៅនេះ :

ការជ្រើសពូជយកមកដាំ

ការជ្រើសពូជឈើយកមកដាំ ជាកិច្ចសំខាន់បំផុត ព្រោះដូច្នោះមុនដែលនឹងយកពូជឈើមួយមកដាំ ត្រូវជ្រើសពូជឲ្យល្អជាមុនសិន ។ គោលទូទៅនៃការជ្រើសពូជ គួរទឹកដល់បេចក្តីដូចនេះ :

១ – ជ្រើសយកពូជដែលគេនិយមរាប់អានច្រើន ,

២ – ជ្រើសយកពូជដែលមានរសជាតិល្អ ,

៣ - បើសិនជាដូចដែលមានពណ៌សម្បុរល្អ គួរស្រឡាញ់ គួរបរិភោគ

៤ - បើសិនជាដូចដែលលក់បានថ្លៃច្រើន,

៥ - បើសិនជាដូចដែលមានផ្លែតាន់ច្រើន,

៦ - បើសិនជាដូចដែលមិនមានរោគ,

៧ - បើសិនជាដូចដែលមានដើមជង់រឹងប៉ឹង (ដូច្នេះជាដើម) ។

ការត្រៀមដូចសំរាប់ដាំ

ឈើដែលគេចិះកោងផ្លែ ដោយច្រើនគេដាំដោយគ្រាប់ ហើយគ្រាប់ដែលទំនងយកទៅដាំនោះត្រូវបណ្តុះប្តូរផ្សាំជាមុនសិន ។ បណ្តុះប្តូរផ្សាំនេះល្អជាងការដាំដោយគ្រាប់ ព្រោះនាំឲ្យមានការថែរក្សាតិចជាងការដាំគ្រាប់ ហើយស្រួលក្នុងការថែរក្សា តាំងមានឧកាសរើសដើមដង់ដែលរឹងប៉ឹងបានពេញទី ។ ការបណ្តុះប្តូរផ្សាំដើមឈើដែលបានផលល្អនោះត្រូវធ្វើដូច្នេះ :

១ - ត្រូវយកគ្រាប់ដែលទំនងបណ្តុះនោះដាក់ចុះទៅក្នុងបំពង់ឫស្សីរួចហើយចោះរន្ធខាងបាតបំពង់ល្មមឲ្យទឹកជ្រាបចេញបាន ឬបណ្តុះក្នុងផើងតូច ។ ក៏បាន ។ បំពង់ឫស្សីឬផើងនោះត្រូវយកវត្ថុផ្សេង ។ រង់ពីក្រោមដូចជាក្បាច់បណ្តុះដែរ គឺយកដុំគ្រួសឬឥដ្ឋច្រែមមកដាក់រង់ខាងក្នុងបានត្រួចយកស្មៅស្តួតដាក់ឲ្យល្មមសមគួរ ហើយយកដីដាក់ពាល់តែពេញហើយទើបយកគ្រាប់ឈើដែលទំនងបណ្តុះដាក់បណ្តុះទៅ ។ កន្លះបំពង់ឫ ឬផើង គួរដាក់១គ្រាប់ឬ២គ្រាប់ឬច្រើនជាងនោះក៏បាន ហើយត្រូវស្រោចទឹកឲ្យជោកជាំជានិច្ច ។ កាលគ្រាប់នោះមានពន្លកដុះឡើងមក

ហើយ ត្រូវថែរក្សាឲ្យល្អកុំឲ្យមានអន្តរាយ លុះដល់ចូលរដូវក្តៀងក៏នាំយកទៅដាំ ។ កន្លងពេលដែលដាំ ត្រូវពុះចំពង់ចំបែក, បើជាដើងក៏ត្រូវកាយចំបែកចេញដែរ ។

២- ការបណ្តុះគ្រាប់កន្ទឹង ក៏ត្រូវធ្វើរនាងដូចរនាងដាំបន្លែផ្សេងៗ ហើយបណ្តុះក៏ដូចជាការបណ្តុះបន្លែផងដែរ ត្រូវធ្វើសប្បាយ៍ស្រោចទឹកពើយយកស្មៅស្ងួតមកគ្របពុំឲ្យដើមហើមទន់ជាទិច្ច ។ កាលគ្រាប់នោះមានពន្លកដុះឡើងមកហើយ ត្រូវគាស់យកទៅដាំផ្សាំពុកទៅរនាងផ្សាំ ។ ពេលដល់រដូវក្តៀងក៏គាស់យកទៅដាំកន្លែងណា ។ ធ្វើតាមរបៀបនេះ ដាយជាន់របៀបទី ១ តែពេលដែលដាំហើយនោះ ដើមឈើច្រើនអន់ខ្សោយស្រពោនស្ងួតរហូតដល់ទៅងាប់ក៏មាន ព្រោះដូច្នោះត្រូវប្រយ័ត្នកុំឲ្យប៉ះទង្គិចជាប់ឫសជាប់ដើមចេញដំរ ។

៣- ការបណ្តុះកន្ទឹងមានរបៀបដូចវិធីទី ២ ដែរ តែកាលដើមខ្លីនោះ ដុះឡើងមានសន្ទឹកប្រៃហួសពីរ-បីគូហើយ ត្រូវដកយកទៅដាំផ្សាំពុកក្នុងបំពង់ឫស្សីឬក្នុងធើងដូចរបៀបទី ១ ។

ដើមឈើចរិកោតផ្លែ ក្រៅពីដាំដោយគ្រាប់ហើយ នៅមានរបៀបដាំដោយវិធីសាកមែកមួយ៉ាងទៀត ដូចគ្រូចផ្សេងៗ គួរនេមៀនល្អតៗលៗ ការដាំដោយការសាកមែក ចាន់ផលល្អជាងដាំដោយគ្រាប់ គឺធ្វើឲ្យឆាប់មានផ្លែតាំងមានផ្លែកាន់ច្រើនផង ដើមក៏ខ្លីជាប មួយឲ្យចង់មើល ។ តែដើមឈើដែលដាំដោយមែកសាក ច្រើនតែមានអាយុមិនយឺនយូរ មិនដូចជាដាំដោយគ្រាប់ឬដោយដើមខ្លីទេ ។ បើពួជឈើណាល្មមដាំដោយមែក

សាកបានក៏គួរសាកទុកពីក្នុងរដូវក្រៀង ។ ពួជខ្លះចេញឫសទាប់ ដូច
ខ្ទឹមទឹងក្រូចផ្សេង។ គេសាកហើយដាំបានក្នុងឆ្នាំនោះឯង ។ មានពួជ
ខ្លះក្រចេញឫសត្រូវកាត់យកមកផ្សំទុកនៅក្នុងផើងឬក្នុងប៉ោតជាមុនសិន
ទំរាំយកទៅដាំក្នុងរណ្តាំ ។ លុះដល់ចូលរដូវក្រៀងឆ្នាំថ្មី ទើបគួរ
គាស់យកទៅដាំក្នុងរណ្តៅ ។

ពួជខ្លះមានរសជ្រួមឬមានរសធ្ងាញ់ល្ង មានផ្លែកាន់ច្រើនតាំងមាន
ដំរឿជងតែមិនសូវធន់ទឹកដីអាកាស ។ បើយើងយកមកដាំនៅទីកន្លែង
ដែលមានទឹកដីអាកាសខុសប្លែកពីកន្លែងដើម ពួជនោះច្រើនតែងាប់ឬ
មានរសជាតិក្លាយខុសពីរសជាតិដើម ។ មានវិធីមួយដែលនឹងនាំពួជ
តាំងនោះមកដាំឲ្យទៅជាឈើដែលធន់តាំងមានរសជាតិដូចដើម ហើយ
លក្ខណៈទឹងគុណសម្បត្តិក៏នៅតង់ផើដូចដើម ត្រូវក្រើវិធីបម្លែងឬវិធី
តមែក គឺដាំដើមឈើដែលធ្លាប់មាននៅក្នុងស្រុក ដែលជាពួជឬជាពួកជា
មួយគ្នាឲ្យជញ្ជក់យកអាហារ ព្រោះទឹកដីអាកាសនៅទីនោះ ឈ្មោះថាជា
ម្តាយនៃពុតរបស់ឈើនោះបានពេញទី អាចឲ្យចំណីអាហារដល់កូនបាន
ដោយបរិបូណ៌ ហើយទើបយកពកឬមែកឈើដែលពោលមកហើយ
នោះ មកភ្ជាប់ឬតដោយវិធីបម្លែងឬវិធីតមែក ។

ម្យ៉ាងទៀតទៀត ត្រូវលាក់មែកឈើ ដែលធ្លាប់ដាំនៅក្នុងស្រុកដូច
ពោលមកហើយ ដូចវិធីលាក់សសរជាក់វត តែលាក់ឲ្យឈៀងឡើងលើ
ហើយលាបដីត្រង់កន្លែងដែលលាក់ ទើបយកមែកឈើដែលសាកដុះឫស
ហើយ ដែលជាពួកជាមួយគ្នាមកប្រហាកត្រង់កន្លែងដែលលាក់ ហើយ

យកដីចំណុំវិញ យកស្រែកំដូងរុំស្រោប ហើយយកទឹកបំពងដាក់សម្រក់ពីលើ ។ កាលដុះសាច់ជាប់គ្នាស្រួលបួលហើយ ទើបកាត់មែកឈើដែលដាំនោះចោល ទុកតែមែកសាក ។ ធ្វើដូច្នេះ ហៅថាវិធីបម្លាប្តូរពីធ្លាតមែក ។ វិធីនោះយើញមានគេធ្វើដោយច្រើន តាំងបានលទ្ធផលដ៏ល្អ តែបានចំរើនដុះដាលរាលគុម្ពក្នុងប្រទេសយើង មានផ្លែផ្កាច្រើនរសជាតិគន់រឹងជូចដែល ។

ការត្រៀមដីនិងការដឹករណ្តៅដាំ

ដើមឈើបរិភោគផ្លែគ្រប់ចំពូក ត្រូវមានការត្រៀមដីនិងការដឹករណ្តៅឲ្យល្អ ។ ឯដីដែលដាំដើមឈើបរិភោគផ្លែ បើជាដីស្អិតហើយដាំដើមឈើខ្នាតធំ គួរដីកវង់បង្ហូរទឹកចូលនិងបង្ហូរទឹកចេញ, បើដីរតែស្អិតច្រើន ត្រូវដីកបង្ហូរទឹកចេញចូលឲ្យយ៉ាងច្រើន, កាលទឹកហូរចេញពីដីអស់ហើយ គប្រើយើងធ្វើដីនោះឲ្យល្អឡើងបានដោយងាយ ។

ហេតុនេះ ការដែលដាំដើមឈើបរិភោគផ្លែ គួរបំរុងដីឲ្យល្អល្មមសមគួរជាមុនសិន គឺត្រូវកាប់ឬកូរវាស់ឲ្យដីល្បាយកយល្អឬដាំបន្ថែមដែរ ។ មួយឆ្នាំពីឆ្នាំសិនក៏បាន ។ បើកន្លែងនោះមិនដែលដាំអ្វីទេ គួរដាំសណ្តែកបាយសណ្តែកអង្គុយ ១ ឆ្នាំ ឬ ២ ឆ្នាំសិន ។ សណ្តែកដែលដាំនោះបេះផ្លែស្រេចហើយ ត្រូវកូរលុបត្រឡប់ទៅក្នុងដដែ ។

ការត្រៀមរណ្តៅដាំ, រណ្តៅសម្រាប់ដាំឈើធំ គួរត្រៀមទុកជាមុនយ៉ាងតិចត្រឹមពីរអាទិត្យ, រណ្តៅនោះត្រូវដីកឲ្យទូលាយប្រហែល ១ ម៉ែត្រ,

ដំរៅក៏ត្រូវដីកឲ្យជ្រៅប្រហែល ១ ម៉ែត្រដែរ ស្មានមើលតាមតួដង-តួច
ខាង-ខ្ពស់ បើដីកវាណ្តៅឲ្យជ្រៅដូច្នេះជាហេតុឲ្យដីធ្លាំងំណាំល្អ,
ពេលដីកនោះត្រូវយកដីខាងលើតវាទុក ១ ផ្នែក យកដីខាងក្រោមតវាទុក
១ ផ្នែកទៀត, កាលដីកហើយត្រូវទុកវាណ្តៅនោះចោលហាលថ្ងៃ ១ អាទិត្យ
សិន ហើយទើបយកដីជាក់ខ្ចាប់ជាតអង្ករឆ្និចបន្តិចបន្តួចក៏បាន ហើយយក
ស្មៅស្ងួតជាក់ចុះទៅ យកដីខាងលើលុបជាមុនសិន ហើយទើបយកដី
ខាងក្រោមលុបបន្តែមទៀតទាល់តែពេញរណ្តៅ ហើយទុកចោល ១
អាទិត្យទៀតដើម្បីឲ្យស្មៅស្ងួយឲ្យដីស្រុតទៅបន្តិចសិនហើយទើបដាំ ។

រដូវដែលគួរដាំដើមឈើបរិភោគផ្លែ

ឈើបរិភោគផ្លែគ្រប់ចំពូក ត្រូវដាំនៅដើមរដូវក្តៅ ព្រោះមិនសូវ
កង្វល់ក្នុងការស្រោចទឹក, កាលអស់រដូវក្តៅហើយ ដើមឈើនោះក៏ធំ
ល្មមសមគួរអាចធន់ទឹងរដូវរងាកំងបាន, បើដាំក្នុងរដូវរងាត្រូវមានកង្វល់
ក្នុងការស្រោចទឹក ហើយដើមឈើក៏ច្រើនតែងាប់ ទោះបីមានវាស់ខ្លះក៏
មិនសូវលូតលាស់ល្អដែរ ។

រយៈដាំដើមឈើ

ដើមឈើបរិភោគផ្លែផ្សេង ។ ដែលទឹងដាក់គោលចារកែឲ្យច្បាស់ជាថា
ត្រូវដាំឲ្យឃ្លាតពីគ្នាប៉ុណ្ណោះប៉ុណ្ណោះពុំបានឡើយ ព្រោះដើមឈើ
មានឫស្សាតតូចធំជាងគ្នា ទាំងដីក៏មានដីជាតិមិនដូចគ្នា ព្រោះដូច្នោះយើង
ទឹងដាក់កំរិតទុកដើម្បីត្រៃរិះខ្លួនឯងដូចតទៅនេះ ៖

១- ស្រែចតែរបៀបរបស់ដី បើដីល្អគួរដាំឲ្យឃ្លាតគ្នាបន្តិច ព្រោះឈើនោះអាចដុះដាលវាលគុម្ព ពន្លឺកម្រែកជាងបានខ្លះខ្លាយ, បើដាំញឹកពេកឈើនោះនឹងលូតខ្ពស់មានស្លឹកច្រើនមិនសូវមានផ្លែ ទាំងមិនសូវធន់ធាំចំពោះពេលផ្សេងៗផង ។ កន្លងពេលដែលមានពេល ច្រើនឆ្នាំទៀតលើដើមឈើឯទៀតពេញទាំងចំការ ។ បើដីមិនសូវមានជីជាតិល្អទេ ត្រូវដាំឲ្យញឹកជាងដីដែលមានជីល្អបន្តិច ព្រោះដីមិនល្អដើមឈើតំមិនសូវដុះដាលវាលគុម្ព ពន្លឺកម្រែកតែខ្លី ។ ។

២- ស្រែចតែការពន្លឺកម្រែកជាងនឹងស្លឹក បើដើមឈើណាពន្លឺកម្រែកបានធ្ងាយហើយមានស្លឹកច្រើន គួរដាំឲ្យឃ្លាតពីគ្នា, បើដាំញឹកស្លឹកនឹងគ្របទៅលើគ្នា ពន្លឺថ្ងៃចាំងមិនដល់ផែនដី ។

៣- ទុកឃ្លៈឲ្យពន្លឺថ្ងៃចាំងដល់ផែនដី ត្រៀបដូចជាពូជឈើខ្លះពន្លឺកម្រែកបានត្រឹម ១ម,៥០ ឈើ ១ ទៀតក៏ពន្លឺកម្រែកបាន ១ម,៥០ដែរ ឈើចំពូកនេះ បើដាំឃ្លាតគ្នា ៣ម, ម្រែកនឹងលូតទៅដល់គ្នា ពន្លឺថ្ងៃចាំងមិនដល់ផែនដី ទើបគួរដាំឲ្យឃ្លាតគ្នាចំនួន ៤ម, ទុកទុកាសឲ្យពន្លឺថ្ងៃចាំងដល់ផែនដី ។

៤- ស្រែចនូវការចាក់ឫស ចើពូជឈើឫសវែង គួរដាំឲ្យឆ្ងាយពីគ្នាតាមពូកឈើ មានតំរិតជួចម្រែកនឹងស្លឹកជួច្នោះដែរ ។

ឥឡូវនេះនឹងតំរិតគោលក្នុងការដាំដើមឈើប្រភេទខ្លះដូចតទៅនេះ ៖

ចេក	ដាំឆ្ងាយពីគ្នា	៣ម,៥០ - ៤ម ម្រែក
ទំពឹម	- -	៣ម,៥០ - ៤ -

ខៀវ	ដាំឆ្ងាយពីគ្នា	៤, ៥០ – ៥ មែត្រ
ល្ហុង	– –	៣. ៥០ – ៤ –
ក្រែចឆ្នាំរ	– –	៥, – ៦ –
ក្រែចផ្សេង ៗ ខៀត	– –	៥, – ៧ –
ខ្ទះរេន	– –	១០ –
មៀន	– –	១០ –
ដូង	– –	៨, – ១០ –
ម៉ាក់ក្រាំង	– –	៧, – ៨ –
ស្វាយ	– –	១០ –
លត	– –	៤, – ៥ –
សាវម៉ាវ	– –	៧, – ៨ –

ធញ្ញជាតិ (ប៉ែកខាងបន្លែ)

សណ្តែក

សណ្តែកជាបន្លែដែលឲ្យប្រយោជន៍ដល់កាយយ៉ាងច្រើន ទាំងជាចំនិញដ៏សំខាន់ ៗ សណ្តែកផ្សេង ៗ នៅស្រុកយើង គឺសណ្តែកច្រែង សណ្តែកឡាន់តៅ សណ្តែកសៀង ទាំងបន្លែដែលមានដំឡៃដ៏ខៀត ដូចជាពពាយដ្រុង ពពាយស្បែកជាដើម ៗ សណ្តែកទាំងនោះ យើងអាចចែកចេញជាប្រភេទ ៗ ដូចតទៅនេះគឺ

១ – សណ្តែកដែលខ្នើងច្រែង

២- សណ្តែកដែលមិនឡើងទ្រែង ។

សណ្តែកគ្រប់ប្រភេទ ចូលចិត្តដីល្បាយហើយសើម គេត្រូវដាំដោយគ្រាប់ ដាំបានត្រប់រដូវ បេះផ្លែបានក្នុងរវាង ៨០ ថ្ងៃ ។ សំរាប់សណ្តែកគួរវែង, គួរដាំជាជួរ, កន្លែងមួយជួរឆ្ងាយពីគ្នាមួយម៉ែត្រ, ក្នុង ១ គុម្ពឆ្ងាយពីគ្នា ៥ តឹក, ក្នុង ១ រណ្តៅត្រូវដាំ ៣ គ្រាប់, កាលលូតលាស់ធំឡើងបំរុងនឹងចោះចង់ឡើងទ្រែង ត្រូវកែទ្រែងមកចោះទៅក្បែររណ្តៅឲ្យចុងទ្រែងទាំងពីរមកចូលគ្នាជាពួក ។ ក្នុង ១ ពួកបួនរណ្តៅ ។

សត្រូវមានគ្រានឹង ។ ដាដើមទ្រែងហើរមកស៊ីស្លឹកនឹងផ្កាមានច្រើនក្នុងរដូវភ្លៀង ។ ចំណែកសណ្តែកឡាន់តៅត្រូវកំណត់រយៈឲ្យមានផ្លែនៅរដូវរដោ, ត្រូវដាំជាជួរពេលគ្រាប់ឲ្យឆ្ងាយពីគ្នាក្នុងរវាង ១ តឹក ។, ធ្វើជួរឲ្យឆ្ងាយពីគ្នា ៣ តឹក, ពេលគ្រាប់ឲ្យដុះប្រមាណ ១ តឹក កុំឲ្យមានទឹកដក់ជោកជាំ, តែមានទឹកស្នឹកក៏នឹងលឿនធំឲ្យខុចដើម ។ ត្រូវការស្នូសំរាប់គោន, ត្រូវចោះបង្គោលចំងាយពីគ្នា ១ ម៉ែត្រ ហើយយកស្នូមកចងតាមបង្គោលនោះកំពស់ ១ ម៉ែត្រ, រយៈស្នូឆ្ងាយពីគ្នារវាងពីរតឹកកន្លះ ។

ចំណែកប្រភេទដែលធំដុះជាលបានតែក្នុងរដូវភ្លៀង ដល់រដូវក៏ងាប់ តែគល់មិនងាប់ទេ ឱនលូតលាស់បានក្នុងរដូវភ្លៀងម្តងទៀត ផ្លែវាគេធ្វើជាអាហារបានយ៉ាងល្អ គេដាំដោយគ្រាប់ឲ្យវាឡើងទ្រែងស្នូរបន្តក្នុងរវាង ៦០ ថ្ងៃ ឱនបានផ្លែបរិភោគ, ដាំចំងាយពីគ្នាប្រមាណ ១ ម៉ែត្រក្នុងមួយជួរ ។ ឬ ១ ដើម ។ ព្រោះវាវាបានឆ្ងាយ ដាំក្បែរបង្គប់បានដែរ ។

ឆ្ពាំជាតិមក៉ាំងខៀតស្រដៀងនឹងពួកសណ្តែកតីបុកគក់, គេដាំដោយគ្រាប់, ដាំទៅចុងរដូវក្តៅ, ដាំកន្លះជួរឆ្ងាយពីគ្នា ៥ តឹក, កូន ១ ដើមឆ្ងាយពីគ្នា ៣ តឹក, អាយុប្រមាណ ១៦០ ថ្ងៃ ទឹងបានមើមបរិភោគ ផ្លែចាស់មានពិសបរិភោគពុល បើចង់ឲ្យមើមល្អត្រូវកាត់ដើមចោលខ្លះ ។

ដំណឹង

សូមជ្រាបអស់លោក-អ្នក!

កន្លងទៅ ១៩៥៦ នេះ មានអស់លោក-អ្នកជាច្រើននាក់ផ្ញើរលុយតាំងពីកន្លងមកឬឆ្នើរឈ្មោះទៅចុះជាវកម្ពុជសុរិយាហើយក៏ខកខានមិនបានអានទស្សនាវដ្តីនេះទៅ ។

ឥឡូវឆ្នាំ ១៩៥៧ ជិតមកដល់ហើយ ដូច្នេះ អស់លោក អ្នកដែលស្នេហ៍អានទស្សនាវដ្តីនេះ សូមធ្វើខាមទៅពុទ្ធសាសនាបណ្ឌិត្យកន្លងមកនៃវិច្ចិកា ទឹង ខែធ្នូ ១៩៥៦ នេះ កុំខាន ។



តំណើរបុណ្យក្រុតញ្ញូកតវេទិតា

នៃក្រុមសិស្ស ធ្វើបំពោះសម្តែងព្រះធម្មលិខិត ល្វី-ឯម

ព្រះមហា សម-សុខ សុមនោ

អាចារ្យបង្រៀនសោណាតុរ្វែទបឋមសិក្សា

វត្តលង្កា ភ្នំពេញ

រៀបរៀង

ហោក ឯ-ប៉ង់ ពិនិត្យកែសម្រួល

អារម្ភកថា

កាលពីវេលាវេលាសៀលថ្ងៃទី ៩ មិថុនា ១៩៥៦, នៅធម្មកុដិក្នុងវត្តលង្កា សង្កាត់លេខ ៦ ភ្នំពេញ មានធ្វើពិធីបុណ្យមួយយ៉ាងឡូរឹក ដើម្បីឧទ្ទិសកុសលទានប្រសិទ្ធីពរជាគជ័យជាការតបព្រះគុណ ចំពោះសម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សាគណៈមហានិកាយ នៅអធិការវត្តលង្កា ក្រោមការចាត់ចែងនៃក្រុមសិស្សានុសិស្សចាស់ជាបព្វជិតទីនឹងគ្រហស្ថខ្លះ នៃពុទ្ធបរិស័ទចាស់ឡាយ ដែលជ្រះថ្លាចំពោះសម្តេចខ្លះ ។

លើលានខាងមុខហោរិត្រ ទីឆាងដើងធម្មកុដិនោះ គេតាក់តែងដ្ឋានទីសក្ការៈជាតិផ្សេង ។ ចាំងមានរបៀបបញ្ឈរក្តារខៀនធំមួយចារឹក

អក្សរធំៗថា "បុណ្យកឋិនវិទី" បំពោះសម្តេចព្រះធម្ម-លិខិតឧត្តមប្រីក្សា" ។

នៅម៉ោង ៨, ៣០ នាទី ក្រុមព្រះកិក្ខុសង្ឃក្នុងវត្តនោះ នាំគ្នាធ្វើការវិភិច្ចចំពោះបម្តេចៗ ក៏ឃាន ប្រថានទុកយ៉ាងខ្លីដោយឥតព្រាងទុកជាមុនថា "ខ្ញុំមានសេចក្តីត្រេកអរជាអនេកចំពោះលោកចាំងអស់អង្គ ដែលបានរួបរួមគ្នាធ្វើកិច្ចតបឧបការគុណដល់ខ្ញុំដែលជាគ្រូបាធ្យាយទ័ សូមឲ្យអស់លោកការក្សាអប្បមាទធម៌ រក្សាសាមគ្គីធម៌ ដើម្បីថែទាំរក្សាព្រះពុទ្ធសាសនាឲ្យបានវុឌ្ឍរឿងទៅអនាគត" សម្តេចមានថេរដីការតែប៉ុណ្ណោះ តំគង់ស្ងៀមទៅ ។

ក្នុងទុកាសនោះ យើងសង្កេតឃើញការនិមន្តមកនឹងការអញ្ជើញមកនៃព្រះកិក្ខុសង្ឃនិងគ្រហស្តចាំងឡាយ ចំណែកខាងព្រះសង្ឃគឺ សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយគណៈមហានិកាយ, ព្រះសុធម្មាធិបតី កុល - ទេស ស្តីទីសង្ឃនាយកគណៈធម្មយុត្តិ, ព្រះតេជ-ព្រះគុណ ព្រះពោធិវង្ស ហួត - តាតចាងហ្វាងតុទ្ធិកវិទ្យាល័យ ព្រះសុភទ្រមុនីងព្រះសង្ឃជាគណៈហានាទុក្រមឯទៀតជាច្រើន; ចំណែកខាងគ្រហស្តគឺ លោក អេង - សុទ្ធ ព្រះរាជអាជ្ញាសាលាដំបូងក្នុងភ្នំពេញ, លោក ឃិន - ផៃ ចាងហ្វាងអនុវិទ្យាល័យកម្ពុជបុត្រ, លោក ព៉ាយ - ប៊ុត អធិបតីមិត្តពុទ្ធិកវិទ្យាល័យព្រះសុភទ្រមុនី, លោកអ៊ូ - គង់, លោកមាស - ម៉ន, លោកពុត - អ៊ុំ អតីតទីប្រឹក្សាជាតិ, លោកម៉ម - យ៉ែម អធិបតីគណៈកម្ម-

ការវត្តលង្កា, លោកចាប . ពិន នាយការិយាល័យចំនៀមទម្លាប់ខ្មែរ និង
អស់លោក . អ្នកឯទៀតជាច្រើន ដែលយើងសូមអភ័យទោសដោយមិន
បានពាប់នាមតាំងអស់ក្នុងទីនេះ ។

ពេលដែលព្រះកិត្តិសង្ឃនីនាយកវិទ្យាល័យព្រះសុភ-
ម្រឹត តំណាងសិស្សានុសិស្សនីនាយកវិទ្យាល័យ ព្រះសុភ-
ម្រឹត តំណាងសិស្សានុសិស្សនីនាយកវិទ្យាល័យ ព្រះសុភ-
ចំពោះព្រះកត្តិសម្តេចព្រះធម្មលិខិត រួចព្រះគេជព្រះគុណព្រះពុទ្ធវង្ស
កៅ . សឹមតំណាងសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ថ្លែងសំវេគបញ្ចាស
តបសិស្សានុសិស្សវិញ ។ បន្ទាប់មកព្រះគេជព្រះគុណព្រះពុទ្ធវង្សថ្លែង
សង្ខ័ថារបស់លោកជាការបាលីដ៏ខ្លីចំពោះសម្តេចខៀត ។ តមកព្រះ
កិត្តិសង្ឃ ១០ រូបចំរើនព្រះបរិត្តជាជ័យមង្គលក្នុងទីចំពោះព្រះកត្តិសម្តេច,
រួចព្រះសង្ឃឯខៀត ៧៨ រូបចំរើនព្រះបរិត្តនៅកន្លែងវិហារ, រួចសម្តេចព្រះ
មហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយសំដែងធម៌ទេសនា ។

លុះចប់ធម៌ទេសនាហើយ សម្តេចបានថ្លែងសួរថា "ដោយអានុភាព
នៃធម៌ទេសនា ដែលខ្ញុំសំដែងប្រកបដោយទឹកចិត្តដ៏ថ្លៃវិសុទ្ធ ដោយមិន
ប្រាថ្នាលាភសក្ការៈឬបៀតបៀនអ្នកណាមួយនោះ សូមឲ្យជួយអភិបាល
សម្តេចព្រះធម្មលិខិតឲ្យបានជាសះស្បើយពីរោគ ខ្ញុំសូមគេជះនៃធម៌
នេះជួយបង្ហាញនូវថាំងចំណាន់ដល់គ្រូពេទ្យ ដែលកំពុងតែព្យាបាលសព្វថ្ងៃ ដើម្បីព្យាបាលឲ្យបានជាសះស្បើយក្នុងពេលដ៏ខ្លីខាងមុខនេះ" ។

ពេលាព្រឹកឡើងថ្ងៃទី ១០ ខែឆ្នាំជវដែលក្រុមសិស្សានុសិស្សខ្លះ និង

ពុទ្ធបរិស័ទចាំឯណាយខ្លះ បានរៀបចំតាក់តែងចង្ហាន់បិណ្ឌបាតជាក់ជូនព្រះកិក្ខុសង្ឃដែលគេនិមន្តពីវត្តមហាមន្ត្រី ៣០ រូប, វត្តកោះ ៣០ រូប, វត្តបទុមវតី ១៨ រូប ។ ប៉ុន្តែគេរៀបតាក់តែងកប់ជូតជាពីរកន្លែង ១ កន្លែងនៅលានខាងដើមធម្មកុដិនឹងហោរត្រៃ; ១ កន្លែងទៀតនៅលើយ៉ធម្មកុដិសម្រាប់សម្តេចតែមួយអង្គជាក់ជូត ។

នៅមុនពេលដែលសម្តេចជាក់ជូត សម្តេចមានថេរដីកាថា "ខ្ញុំសូមផ្សាយកុសលដែលកើតឡើងពីចង្ហាន់បិណ្ឌបាតនេះ ចំពោះសត្វក្នុងត្រៃលោក សូមឲ្យសត្វចាំឯនោះបានសេចក្តីសុខ ចំរើន កុំបីចងអាឃាតព្យាបាទគ្នា គប្បីរក្សាគ្នាទន្ទឹងគ្នាឲ្យបានសុខរៀងភពទៅ" ដូច្នេះហើយសម្តេចចាប់ចង្ហាន់ជាក់ជូតព្រះសង្ឃចាំឯណាយ ។

នៅពេលបញ្ចប់ការជាក់ជូត, ព្រះសង្ឃចាំឯណាយបានស្មូធ្យាយធម៌ប្រគេនសព្វសាធុការពរចំពោះសម្តេច ទន្ទឹងជូនពរដល់ទាយកទាយិកាចាំឯណាយគ្រប់ហាន: បន្ទាប់ពីនោះលោកម៉ម-ឃ៉ែម ប្រធានគណៈកម្មការវត្តបានថ្វាយសង្កថាមួយដ៏ខ្ជីខ្ជួលអំណរគុណតាមទំនៀមទម្លាប់នៃសព្វតាឯនាមនៃសិស្សានុសិស្សចាំឯណាយ ។

ពិធីបុណ្យនេះចប់ត្រឹមប៉ុណ្ណោះ ។

*
* *

រីសុខួរកថា, សំរេចប្រកាស ទន្ទឹងសង្កថា យើងស្រង់យកមកចុះដូចតទៅនេះ :

សុជ្ឈរកថា

របស់លោក ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៃតុទ្វិកវិទ្យាល័យសុរាម្រឹត តំណាងក្រុមស៊ស្សនៃតុទ្វបរិស័ទ

សូមគោរពចំពោះសម្តេចទាំងពីរព្រះអង្គជាសង្ឃបិតា !

សូមគោរពព្រះថេរានុត្ថេរទាំងឡាយ !

សូមឧកាសអស់លោក-អ្នកសប្បុរសទាំងឡាយ !

ខ្ញុំព្រះករុណា ខ្ញុំប្រចាទ ខ្ញុំចាទ ខ្ញុំ ជាតំណាងតុទ្វបរិស័ទនិងសិស្សានុសិស្សរបស់សម្តេច *សូមថ្លែងសេចក្តីពិតជាសច្ចវាចា ដើម្បីរំលើកយកគាគផល នៃការកុសលរបស់សម្តេច ដែលសម្តេចបានធ្វើកន្លងទៅហើយ យកមកពួតផ្ទុំផ្សំជាមួយគ្នានឹងផលនៃការកុសលបច្ចុប្បន្ននេះ ប្រគេនចំពោះសម្តេចជាសង្ឃបិតា ក្នុងវេលាដែលសម្តេចមានជរាពាធប្រចាំកាយនេះ ។*

បពិត្រសម្តេចជាទីគោរព ! យើងខ្ញុំទាំងឡាយ ទាំងគ្រហស្ថទាំងបព្វជិត ខ្លះជាសិស្សានុសិស្ស ខ្លះជាឧបាសកចំណុះវត្តនេះ ខ្លះជាញាតិមិត្រ មានសេចក្តីស្រឡាញ់នឹងសេចក្តីគោរពដោយពិត ចំពោះសម្តេច ដែលជាឧត្តមបុរសមួយអង្គ ក្នុងប្រទេសកម្ពុជា ព្រោះយើងខ្ញុំដឹងពិតថា សម្តេចប្រកបដោយព្រះគុណទាំងពីរប្រការគឺ ឧបការគុណ ១ នេមិត្តិកគុណ ១ ។

ព្រះគុណទី ១ ដែលហៅថាឧបការគុណ គឺសម្តេចប្រកបដោយព្រហ្មវិហារធម៌បានដល់មេត្តា , ករុណា មុទិតា , ឧបេក្ខា ។

យើងខ្ញុំចាំងឡាយ បានសង្កេតឃើញថាតាថា សម្តេចមានធម៌ចាំង ៤ ប្រការនេះពេញលេញក្នុងព្រះអង្គមែន ។ ព្រោះតាលដែលសម្តេចទើបនឹងបានឧបសម្បទា សម្តេចបានគ្រប់គ្រងកិក្ខុសង្ឃសាមណេរនៅវត្តស៊ុធរ តាំងពី ព.ស ២៤៥៤ ដរាបមកដល់ឥឡូវនេះក្តី សម្តេចបានគ្រប់គ្រងកិក្ខុសង្ឃសាមណេរក្នុងវត្តលង្កានេះ ដែលមានកិក្ខុសាមណេរជាច្រើនលើសលុបក្តី សេចក្តីគោរពកូសក្នុងសង្ឃមណ្ឌល តុំដែលមានដល់ម្តងសោះ ។ សេចក្តីសុខដ៏ធំធេលាយដែលកើតឡើងក្នុងមហាសង្គមយ៉ាងនេះ តាមរឿងក្នុងគម្ពីរថា ប្រាកដជាកើតឡើង ដោយសារព្រហ្មវិហារធម៌ នៃប្រមុខរបស់សង្គម ។

ខ នេះ បើនិយាយឲ្យចំ។ ទៅថា កាលដែលវត្តលង្កានៅក្នុងផ្លូវបឹងដំរៃ មានលំនៅកិក្ខុសង្ឃសុទ្ធតែតូចតូច ។ បន្តិចបន្តួច យើងខ្ញុំចាំងឡាយជាសិស្សក្នុងដំនាន់នោះ បានទទួលសេចក្តីប្រៀនប្រដៅអំពីសំណាក់សម្តេច គឺសម្តេចបានអនុញ្ញាតឲ្យយើងខ្ញុំគ្រប់គ្នាទៅក្នុងទីអាគមនេះដោយឥតរើសមុខ ថាកូនអ្នកមានឬអ្នកក្រ ថាកូនអ្នកក្រុងឬអ្នកស្រែ - ចំការឡើយ លើកលែងតែមនុស្សដែលជាទីរអ៊ូរទាសចេញ ។ សម្តេចបានប្រែឥរិយាបថកសាងវត្តនេះ ដើម្បីជាទីលំនៅយើងគ្រប់គ្នាដោយឥតសំចៃព្រះកាយពល ដរាបដល់វត្តនេះបានប្រាកដជាអាគមមួយដ៏ធំក្នុងកណ្តាលពាជធានីខែ្មរ ។ សព្វសព្វ កាលសម្តេចបានចែកសង្ឃលាភឲ្យកិក្ខុសាមណេរឥតរើសមុខមិនឲ្យលើសខ្វះ, រៀលជិតចេញវស្សា ក្រោយពេលដែលឲ្យយើងខ្ញុំជាសិស្ស សិក្សាធម្មវិន័យ

ច្រើនវែងហើយ សម្តេចតែងចាត់ការឲ្យប្រឡងសាកមើល ដើម្បីប្រមាន
ស្បង់ចំពោះធីងវត្តផ្សេង ។ ជារបស់ជាល់ព្រះអង្គ គោះថាកថ្លៃតិចច្រើន
ដល់សិស្សដែលប្រឡងជាប់លេខតាមចន្លះតាមលំដាប់, ពាល់ ។ ឆ្នាំរៀង
មក អស់រយៈកាលជាយូរអង្វែង ។ សម្តេចបានបង្ហាត់បង្រៀនគម្ពីរ
ចាលី ធម្មវិន័យ ព្រមទាំងប្រមាននូវជាប្រក្រតីជាល់ព្រះអង្គផង ចាត់
ឲ្យអាចារ្យ ។ ជួយបង្ហាត់បង្រៀនថែមទៀតផង ។

ករណីយកិច្ចដ៏ថ្លៃថ្លាទាំងនេះ ប្រាកដជាធ្លុះចេញអំពីព្រហ្មវិហារ
ធម៌ គឺថាព្រោះតែសម្តេចមានព្រហ្មវិហារធម៌ ទើបចំពេញករណីយ-
កិច្ចដ៏ប្រសើរទាំងនេះបាន ដែលចាត់ជាឧបការគុណដ៏ធ្ងន់ មកលើយើង
ខ្ញុំគ្រប់គ្នា ។

ទី ២— ដែលថាសម្តេចប្រកបដោយនេមិត្តិកគុណ គឺគុណដ៏អស្ចារ្យ
បានដល់កិត្តិស័ព្ទ កិត្តិនាមដ៏ល្បីល្បាញ ដែលធ្លុះធ្លុះចេញឮឮយ
ទៅអំពីសមត្ថភាពរបស់សម្តេច ដូចខ្ញុំព្រះករុណាវៀរភាប់តទៅ:

ក) កាលសម្តេចទើបទទួលឋានន្តរសក្តិ ក្នុង ព.ស ២៤៤៣
នោះ សម្តេចព្រះមហាសង្ឃរាជព្រះនាមខៀវ បានតាំងសម្តេចជា
អាចារ្យបង្ហាត់សូត្រធម្មិកគណករចាលី ឲ្យប្រើឲ្យល់ទីយៈវស្សៈវែងខ្លី
ត្រឹមត្រូវតាមវិធីការសាចាលី ក៏ព្រោះតែសម្តេចស្គាល់ជំនាញក្នុងការនេះ
គ្រាន់បើជាងគេ គោះបើបិតនៅក្នុងបឋមវ័យសោះទេ ។

ខ) កាលពី ព.ស. ២៤៤៩ សម្តេចព្រះមហាសង្ឃរាជ បានតាំង

សម្តេចជាចៅអធិការវត្តស៊ីធរ កំព្រែតែសម្តេចមានសមត្ថភាពខាងការបង្ហាត់បង្រៀនធម្មវិន័យផង ខាងការគ្រប់គ្រងគណៈសង្ឃផង ។

គ) គាលពី ព.ស. ២៤៥៤ ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស គាលនោះជាព្រះអគ្គម្ចាស់អធិបតីទៅឡើយ បានពីគ្រោះត្រមេត្រៀងជាមួយនឹងសម្តេចព្រះមហាសង្ឃរាជ នឹងព្រះសាត្រះមហាវិមលធម្មថេរ បានទំមន្តសម្តេចពីវត្តស៊ីធរ មកតាំងជាចៅអធិការវត្តឥណ្ហានេះ កំព្រែតែសម្តេចមានសមត្ថភាព ហើយបានធ្វើការមានថ្វីព្រះហស្ត តាំងពីខែបឋមនឹងបាន១បសម្បទាថ្មីៗមកម្ល៉ះ ។

ឃ) គាលពី ព.ស. ២៤៥៦ សម្តេចជុនសមណាស័ក្តិជាព្រះគ្រូវិមលបញ្ញា, គាលពី ព.ស ២៤៥៧ សម្តេចបានឡើងសមណាស័ក្តិជាព្រះញាណវរវិជ្ជា ពាជាគណៈកូនតំណែង កំព្រែតែសម្តេចមានសមត្ថភាព អាចជ្រោងវត្តលង្កាដែលបាត់នៅកូនផ្លែបឹងដំជ្រៃ មានសេនាសនៈរោកខោកឲ្យឡើងជាអាចមមួយដ៏រឹងរឿង តាំងជាវត្តដែលមានតិក្ខសាមណេរ បួនជ្រាំអគ្គិឲ្យបានក្បាយទៅជាអាចមមានតិក្ខសង្ឃ កុះករដល់ជ្រាំមួយ-ជ្រាំពីរយអគ្គ ។

ង) គាលពី ព.ស. ២៤៥៨ ពាជការបានតាំងសម្តេចជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ កំព្រែតែមានសមត្ថភាពខាងការចេះដឹងអាចប្រឡងយកឋានៈនោះបាន ។

ច) គាលពី ព.ស. ២៤៧២ ពាជការបានតាំងសម្តេចជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ ហើយតមកបានតាំងជាអធិបតីក្រុមជំទុំព្រះវិន្ត-

បំដកទៀត ក៏ព្រោះតែសម្តេច អាចត្រួតត្រាការសិក្សាផ្លូវពុទ្ធសាសនា ជាន ។

ខ) តាំងពីគ្រឹមណោះដរាបមក សម្តេចជានាំផ្តើមប្រែព្រះវិន័យបិដក ជាឧបត្ថាការឱ្យសរសេរចម្លងជាលើព្រះវិន័យបិដក, ជានរួមប្រជុំកងគណៈកម្មការបង្កើតពុទ្ធសាសនបណ្ឌិត្យ, ជានផ្តើមបង្កើតសាលាជាលើរងកងសកលកម្មជរដ្ឋព្រមភាំងជាគ្រូបង្រៀនក្នុងការបង្កើតពុទ្ធសាសនបណ្ឌិត្យរងនិងសាលាជាលើរង នៅប្រទេសលាវនិងប្រទេសកូសាំងស៊ីនផង, សម្តេចជានទួលបាត់ការឱ្យបង្ហាត់បង្រៀនពួកសមណនិស្សិតពីប្រទេសលាវនិងប្រទេសកូសាំងស៊ីនផង ។ ដោយហេតុមានការណ៍ដ៏ប្រសើរទាំងនេះ ទើបសម្តេចជានឡើងសមណសក្តិជាព្រះសិរីសម្ពត្តវង្ស, ជាព្រះធម្មលិខិត, ជាសម្តេចព្រះធម្មលិខិតឧត្តមប្រិក្សា ព្រមទាំងជានគ្រឿងឥស្សរិយយសដ៏ខ្ពង់ខ្ពស់តាំងពីមេដាយ មុនីសាភកំណ្ឌ រហូតដល់មេដាយអស្សរិទ្ធិក្រុមដូណ្ណីរ ដែលជាកាំងហៅថា សឺរ៉ាលីយ៉ាដឺឡាឡេស៊ីយ៉ុងដូណ្ណីរ ។

គុណសម្បត្តិដ៏អស្ចារ្យ ដែលជុំសដុះចេញអំពីសមត្ថភាពយ៉ាងនេះ ហៅថា នេមិត្តិកគុណ ។

សម្តេចប្រកបដោយព្រះគុណទាំងពីរប្រការ ដូចជានថ្លែងមកហើយនេះ ទើបជាទីស្រឡាញ់ជាទីគោរព នៃយើងខ្ញុំគ្រប់គ្នា ។ ជានយើងខ្ញុំគ្រប់គ្នា មានសេចក្តីសុខន្ទត់កងចិត្តយ៉ាងក្រៃលែង ក្នុងវេលាដែលសម្តេចមានព្រះជនពាធ ទើបនាំគ្នាធ្វើបុណ្យកុសលញាតិវេតាកិច្ច

នេះ ជានិមន្តព្រះសង្ឃចំពោះព្រះបរិត្ត និមន្តធម្មកថាសំដែងធម៌ទេសនា ប្រគេនកេសដ្ឋ: ប្រគេនគិលានភេសជ្ជៈចំពោះព្រះសង្ឃ ដើម្បីយកភាគផល ប្រគេនផ្កាលំចំពោះសម្តេច ។

មួយទៀត យើងខ្ញុំសូមអំពាវនាវដល់កុសលទាំងឡាយ ដែលសម្តេចបានធ្វើផ្កាលំព្រះអង្គ ជួចដែលបានរៀបចំមកតាំងដើម សូមកុសលទាំងនោះផុសផុលឡើងមករួមកម្លាំងជាមួយគ្នា នឹងការកុសលដែលយើងខ្ញុំធ្វើប្រគេនសម្តេចក្នុងគ្រាឥឡូវនេះ សូមអតីតកុសលរបស់សម្តេច នឹងបច្ចុប្បន្នកុសលរបស់យើងខ្ញុំពុំកម្លាំងគ្នាគាំពារសម្តេច កុំឲ្យមានទុក្ខវេទនា, សូមកុសលទាំងនោះក្លាយមកជាឧបនិស្ស័យ ស្រោចស្រប់រម្ងាប់រោគ ក្នុងព្រះកាយសម្តេចឲ្យបានសម្រេចជាសះស្បើយយ៉ាងឆាប់ ។ សូមសម្តេចប្រកបដោយព្រះជន្មាយុយឺនយូរវែងឆ្ងាយ ដើម្បីជាទីគោរពនៃយើងខ្ញុំតាំងឡាយអស់កាលជាអង្វែងតរៀងទៅ ។

*
* *

សំរេកឃ្លាសរបស់ព្រះពុទ្ធឆ្លៀ ភៀ - ស៊ីម សាស្ត្រាចារ្យ

នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត តំណាងសម្តេចថ្លៃងតបពួកសិស្សទំងពុទ្ធបរិស័ទ

សូមនមស្ការ

- សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក វត្តឧណ្ណាលោម,
- ព្រះតេជព្រះគុណ ព្រះគោជិវ័ង្សចាន់ហ្វាង ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត,

- ព្រះតេជព្រះគុណ ព្រះសុធម្មាធិបតីស្តីទីសង្ឃនាយក វត្តបទុមវតី,
- - ព្រះអរិយកសប្ប
- - ព្រះមុនីកោសល
- - ព្រះយោសធម្មនឹងព្រះថេរានុត្ថេរគ្រប់ព្រះអង្គ,

សូមអភ័យទោស ដោយខ្ញុំព្រះករុណាពុំបានចេញព្រះនាមសព្វគ្រប់ ។

សូមទានមេត្តាជ្រាប, ខ្ញុំព្រះករុណាសូមថ្វែងសំវេគប្បកាសជូនមានសេចក្តីតទៅនេះ :

សូមប្រកាសជូនដំណឹង ចំពោះក្រុមសិស្សានុសិស្សទាំងបព្វជិតទាំងគ្រហស្ថនឹងអស់លោក - អ្នក ឧបាសក ឧបាសិកា ដែលបានមិនបន្ត-អញ្ជើញមកធ្វើបុណ្យកតញ្ញូកតវេទិតាកិច្ចនេះប្រគេនចំពោះសម្តេច . . .

សូមជ្រាប ។

ខ្ញុំព្រះករុណាអាត្មាភាពសូមថ្វែងអំណរគុណចំពោះអស់លោក - អ្នកជាដំបូងសម្តេចតាមសំវេគប្បកាសជាអនុស្សរណីយភាព របស់សម្តេចដែលមានសេចក្តីដូចតទៅនេះ :

អស់លោក - អ្នក បព្វជិត - គ្រហស្ថទាំងឡាយ !

ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើងខ្ញុំបានសំដែងធម្មទេសនាណែនាំបំភ្លឺប្រជានិករឲ្យយល់ច្បាស់នូវពុទ្ធធម៌ ដែលជាសភាវៈពិតសភាវៈទៀងទាត់ សភាវៈមិនប្រែប្រួលទៅជាដទៃ ដែលផ្តាច់ចំមកលើរូបប្រជានិកគ្រប់ឋានៈជាអ្នកខ្វួលវាង ហើយខ្ញុំបានជ្រាប់អំពីលក្ខណៈជាគ្រឿងកំណត់កត់សំគាល់របស់រូប ដែលមានព្រឹត្តិការណ៍គួរដល់ការ

ចាក់ចែកខ្ចុះតាមវិនោសទៅដោយរូបប្បនលក្ខណៈ មានក្តៅនឹងត្រជាក់ ណាប់ជាដើមព្រោះថារូបនេះជាសម្បុកនៃរោគ ដែលចូលទៅជ្រកកោនទៅអាស្រ័យជាបច្ច័យញាក់ញ័រដីរោគវេទនារបស់រូបនោះ ឲ្យទន់ខ្សោយថយចុះតាមលំដាប់ថ្លៃថ្នូរតទៅទល់នឹងវិនាស ។ កាលបើរូបនេះជាខុឡូលហើយ ចុយុទ្ធតស៊ូនឹងរោគមិនឈ្នះហើយ សកម្មភាពវេទនារបស់រូបនោះនឹងប្រព្រឹត្តទៅដូចម្តេចហ្ន៎ ! គួរចាត់ទៅតាមផ្លូវណា ? អើ ! បើដូច្នេះ ! រូបដែលមានរោគធ្វើឲ្យឈឺចាប់នេះ គួរចាត់ក្នុងរូបសភាពក្រ ដូចមនុស្សក្រខ្សត់សម្បត្តិនោះដែរ ។ ម៉េចក៏ចាត់ជាសភាពក្រ ? ព្រោះថារោគនោះវាបំផ្លាញដីរោគវេទនាជាដួងព្រលឹងរបស់មនុស្ស ដែលកំពុងតែរស់នៅដោយសេចក្តីសុខសប្បាយ ក៏ធ្វើឲ្យអន្តរាយហិនហោចចាត់បង់នូវការមានការបានរបស់ដីរោគ ដែលជាសុខស្រួលរស់នៅនោះ ត្រឡប់ត្រឡិនបង្កើនជាឧទ្ធាននឹងលើនមានអ្វីតទៅមុខទៀត ឆ្ងាក់ទៅជាសភាពក្រមិនដាច់នឹងមានដីរោគារស់នៅស្រួលនោះទេ ។ នេះហើយហៅថាទុក្ខធម៌ មិនប្រែប្រួលទៅតាមសភាពដទៃ, ដល់ម្ល៉ឹងតើ ! គួរឲ្យនឹកស្តាយដល់ដីរោគវេទនាចាស់ជាជនប្រុសស្រី ដែលតែងតែស្រឡាញ់ស្នេហាជ្រាប់ជ្រួចនឹងសុខភាព រស់នៅអស់កាលយូរតអង្វែងទៅ តែពុំសូវបានកបរសោះបែរជាទុក្ខធម៌គ្រលុកអុកទៅជាប់ស្ថិតក្នុងសន្តានយើងទាំងអស់គ្នា ។ ព្រះពុទ្ធដីកាត្រាស់ថា ‹‹បើរូបនេះជាអត្តាខ្លួនជ្រាណាមែន, រូបនេះមិនប្រព្រឹត្តទៅដើម្បីជម្ងឺអាពាធទេ ព្រោះ

រូបនេះមិនមែនអត្តាហើយឬទេដាក់បិទាប់ស្ងាប់វិញ គឺរូបនេះជាអនត្តាមិនមែនខ្លួនយើងឬទេជាជម្ងឺមេរោគចូលទ្រុកនៅពេញក្នុងរូបនេះតើត ។

ចប់តាសសេចក្តីប៉ុណ្ណេះ ដើម្បីសម្រាលសេចក្តីខ្លួនព្រួយក្រុមសិស្សានុសិស្ស ព្រមទាំងអស់លោក-អ្នកសប្បុរសទាំងឡាយ ដែលមានសទ្ធានចិត្តមេត្តាករុណាអាត្មា ហើយឬទេព្រួតដៃគ្នាតយុទ្ធប្រយុទ្ធទឹងរោគនេះ ដោយខ្នះខ្នែងយ៉ាងដំនាញ ។ ផ្តាសផ្តាំរោគនេះឲ្យអន់ខន់កម្លាំងពុយរោយដោយអំណាចការៈព្យាបាល ទាល់តែរោគនេះរសាយដៃធ្វើអត្តភាពខ្ញុំករុណាអាត្មា ឲ្យបានស្រួលបន្ថិចនេះឡើង ។

លោក-អ្នក បពិត្រ គ្រហស្ថទាំងឡាយ!

គាល ព.ស. ២៤៧ គ. ស. ១៩៤៣ កន្លងទៅហើយ ជាគាលកំណើតរោគ ដែលចាប់តើតជាលើកដំបូងក្នុងតាជួតាយរបស់ខ្ញុំករុណាអាត្មា សំដែងអាការកំឡោះហួសហេតុ ចុះបញ្ជូញកំណាចការចយោរយៅដូចអាសីរពិស ចាប់ឈឺពីតចាកុំរកពេលដោលតងតាយនេះស្ទើរតែអត់ទ្រាំពុំបាន តែបានដោយអំណាចគេជាខ្មាតសម្តេចព្រះមហាក្សត្រិយានី មានព្រះសវរណ្ណីយ៍បញ្ជាឲ្យលោកអ្នកឧកញ៉ាសុខ្ញុំពេទ្យ អ៊ុន-អេម មកព្យាបាលជាលើកដំបូងប្រទាំងខប់ទឹងរោគនេះជាកល់ថ្ងៃ បន្ទាប់មកបានយកលោកវេជ្ជបណ្ឌិត ផ្វាស៊ូ មកប្រយុទ្ធទឹងរោគនេះទៀត ក៏បានគ្រាន់បើរហូតមកដល់ ព ស. ២៤៩៩ គ. ស. ១៩៥៦ រោគនេះក៏រើឡើងជាថ្មីវិញ, ចានយកលោកវេជ្ជបណ្ឌិតជួន.ជឿន ទឹងលោក លាង-សាន ពេទ្យនាយកមកព្យាបាលប្រយុទ្ធ

ទឹងកេតដដែលនេះចែមខែត ពាល់តែកេតនេះសាបរលាបខ្លាយ
តំលាំងទៅ នាំឲ្យខ្ញុំកុណាអាត្មាមានខ្យល់អស្សាសប្បស្សាសៈធូរស្រួល
ឡើងជាងពេល ។

ទុកាសនេះមស់លោក - អ្នកដែលជាត្រួមបពុជិត ទុជ្ជាសកទុជ្ជាសិ-
កាទាំងឡាយ ដែលមានសេចក្តីស្នេហាចំពោះខ្ញុំកុណាអាត្មា ជាមមួល-
មត្តិគ្នាមកធ្វើបុណ្យកតញ្ញូតាដើម្បីទុទ្ទិសតបបដិការគុណ ចំពោះខ្ញុំកុណា
អាត្មា ។ មានអំណរណាស់ សូមទទួលយកកុសលនេះដោយសេចក្តី
ពេញចិត្ត ។ ដោយអំណាចបុណ្យកតញ្ញូតានេះ សូមកុសលនេះជួយ
ទុបត្ថម្ភជាកម្លាំងបណ្តាញកេតាភាព ដែលមានក្នុងអង្គកាយរបស់ខ្ញុំកុណា
អាត្មាឲ្យរលាយបាត់ខ្ចាត់ខ្ចាយចេញពីសរីរៈតាំងពីថ្ងៃនោះតទៅ ។

បន្ទាប់អំពីនេះ ខ្ញុំកុណាអាត្មា សូមលើកកុសលដែលកើតអំពីបុណ្យ
កតញ្ញូតា របស់អស់លោក - អ្នកដែលបានប្រគេនខ្ញុំកុណាអាត្មានេះ
ថ្វាយជាព្រះពរជាលំចំពោះព្រះករុណាជាម្ចាស់ជីវិត, សម្តេចព្រះមហា-
ក្សត្រិយានី ទឹងសម្តេចព្រះទុបយុវរាជ សូមទ្រង់ប្រតិនៅក្នុងសិរីវរាជ-
សម្បត្តិ ទឹងសូមទ្រង់ប្រកបដោយសុខសួស្តីជយមង្គលត្រប់ប្រការអស់
កាលជាអង្វែងតទៅ ។

សូមទុទ្ទិសកាតដលនេះ ជូនចំពោះទេវតាទឹងមនុស្សទាំងឡាយ
ព្រមទាំងសត្វទាំងពួង សូមទទួលយកដោយសញ្ញាហើយ សូមឲ្យមាន
អាយុយឺនយូរអស់កាលជាដំរូង ។

សូមឧទ្ទិសកាតផលនេះ ជូនចំពោះក្រុមសិស្សានុសិស្ស បព្វជិត គ្រហស្ថ ឧបាសក ឧបាសិកាទាំងឡាយ ដែលជាអ្នកខ្វល់ខ្វាយធ្វើបុណ្យកតញ្ញូតាផ្ទាល់ខ្លួនជូនចំពោះខ្ញុំកុណាអាត្មា ដែលជាគ្រូបាធ្យាយរបស់អស់លោក - អ្នក សូមលោក - អ្នកទាំងនេះបានមូលមិត្តសំឡាញ់ មូលក្រុមគ្រួសារ កុំឲ្យបែកបាក់ចាកគ្នា កុំឲ្យមានពេតាបៀតបៀន សូមឲ្យបាសចាកទុក្ខភ័យឧបទ្រពវៃង្រៃគ្រប់យ៉ាង សូមឲ្យបានប្រកបដោយសេចក្តីសុខ ចំរើន អាយុយឺនយូរ សូមឲ្យមានសាមគ្គីរស់នៅរួមរាកគ្នា កុំមានពៀរពេចន៍គ្នាអស់កាលជានិរន្តរ៍ សូមឲ្យចំរើនក្នុងព្រះពុទ្ធសាសនាតរៀងទៅកុំប្រែប្រួតឡើយ ។

ទីបំផុតនៃសំវេគប្បាសរបស់សម្តេចនេះ ខ្ញុំព្រះករុណាអាត្មាភាព សូមបួងសួងប្រកបដោយមេត្តាករុណាចិត្តចំពោះសម្តេចធង ចំពោះពុទ្ធ-ចរិស័ទទាំងអស់ធង ជាភាសាបាលីដោយសង្ខេបថា:

អម្ហាកំ សម្តេចព្រះធម្មលិខិត ខុត្តមប្រឹក្សា មហាបវរស្ស ពោគា តត្ត នានាពាធគិលានាយ វិហេឋិយត្តា អម្ហាកំ កតញ្ញូតានុភាវេន តិតា បដ្ឋាយ មា អហេសុំ វិនស្សន្តុ អសេសតោ ។

ពុទ្ធរិង្គៃ នាម អហម្បន សព្វស្មិ លង្ការមេ វិសន្តានំ ភិក្ខុសាមណេរានំ ឧបាសកឧបាសិកានញ្ច សាមគ្គិករណត្ថាយ

ឥទំ វិបុលមច្ចរឹ សព្វេ តុម្ហេ មហាបុញ្ញា មហាបញ្ញា មហិទ្ធិកា មហាភោគា មហាយសា មហានុភាវា សច្ចធម្មេសុ ឋិតា សច្ចធរា ពុទ្ធសាសនមាមកា សីលវន្តោ ជនានញ្ចិយោ សមគ្គា ហោថ សព្វេ តុម្ហេ អញ្ញមញ្ញវិរោធិនោ, ឥទំ សព្ពំ លង្ការមំ នាម អញ្ញំ អទុំ ឯវ មា វិសុំ ហោតុ មេត្តាយោគ្គេកសម្ពន្ធំ សុខំ ចិរន្តិ ។

តេ តេ ភិក្ខុសាមណេរាទយោ អរិយា អរិកលហា អរិន្នា សម្មា សមគ្គា សាធុកំ សម្បដិបជ្ជិត្វា ពុទ្ធសាសនំ ធម្មវិនយសម្បន្នំ វិកុព្ពុ, ចិរំ តិដ្ឋន្តុ សកសកអារាមេសុ ច សកសកាចរិយគណេសុ ច សកសកគេហដ្ឋានេសុ ច សុវុត្តិភាវេន សព្ពទា ។

ព្រះមហាឧត្តមវង្ស សម - សុខ្យ ប្រែសំរួលជាភាសាខ្មែរៈ

"សូមពេនដែលកំពុងរៀនរៀនដោយធម្មដំកាត់ផ្សេង។ ក្នុងការជួកាយសម្ពន្ធព្រះធម្មលិខិត ឧត្តមប្រឹក្សា ជាមហាថេរយើង ជាសេរ៉ីយ តាំងពីថ្ងៃនេះទៅ ដោយអានុភាពនៃកតញ្ញូតាធម៌យើងទាល់តែ, ពេនតាំងនោះ ចូរនៅសាសនាញាតទៅ កុំបីសេសសល់ឡើយ ។

ខ្ញុំឈ្មោះពុទ្ធវង្ស - សុម ចង់ធ្វើសាមគ្គីធម៌រវាងពួកភិក្ខុសាមណេរ ដែលនៅក្នុងវត្តលង្កាតាំងមូល ទើងឧបាសក ឧបាសិកាតាំងឡាយ (ឲ្យកើត

មាន) ទើបពោលពាក្យនេះថា : អស់លោកចាំង់ឡាយ ជាអ្នក
មានបុណ្យច្រើន មានបញ្ញាច្រើន មានកម្លាំងច្រើន មានភោគៈច្រើន
មានយសច្រើន មានអានុភាពច្រើន សូមបិតនៅក្នុងសច្ចធម៌ ខ្ចប់ខ្ចន់
សច្ចៈ ពង្រឹកព្រះពុទ្ធសាសនា មានសិលជាទំស្រែឡាញ់នៃប្រជាជន មាន
សេចក្តីព្រមព្រៀងគ្នា, សូមអស់លោកកុំមានការគ្រោធខឹងដល់គ្នានឹង
គ្នា; ទីវត្តលង្កាចាំងនេះ ទោះឯណេះក្តី ឯណោះក្តី កុំបីបែកបាក់គ្នា
ឡើយ; សូមសេចក្តីសុខដែលជាប់ជាក់ខ្ជាប់ដោយចង្កាមមេគ្គាធម៌
(បិតនៅ) អស់កាលដ៏យូរ ។

ពួកកងកុសាមណេរជាដើមនោះ។ កុំទាស់ឈ្លោះបែកបាក់គ្នា ជា
អ្នកមានសាមគ្គីធម៌ដោយប្រពៃ ចូរព្រមទទួលថាសុ ហើយរក្សា
ព្រះពុទ្ធសាសនាដែលបរិបូណ៌ដោយធម៌វិន័យចុះ; សូមសហធម្មិក:
ចាំងឡាយ បិតនៅដោយភាពជាអ្នកមានសេរីសួស្តីអស់កាលដ៏យូរលង់
ក្តីអាតមរៀង។ ខ្ញុំ, ក្តីតកូលអាចារ្យរៀង។ ខ្ញុំ ទំងក្តីគេហដ្ឋាន
រៀង។ ខ្ញុំ សព្វកាលសព្វវេលា ។

* *

សង្ក្ថា

របស់លោកយោគ្បីត្រ ម៉ម-យ៉ែម

ថ្ងៃនេះ ជាតិថីមានបុណ្យ សន្ទុតថាជាអតិលក្ខិតសម័យដ៏ប្រសើរ
ដែលព្រះតេជព្រះគុណទំងអស់លោក-អ្នកចាំងឡាយ បានអញ្ជើញមក

ជួយអបអរបុណ្យកឋិនតាំងពីសម្តេច ជាគ្រូនៃយើងពាល់គ្នាក្នុងពេលនេះ ។ យើងខ្ញុំសូមថ្វាយអំណរគុណដ៏ជ្រាលជ្រៅចំពោះការអញ្ជើញមកនៃព្រះតេជព្រះគុណ ទីឯអស់លោកទាំងឡាយ ។ យើងទាំងអស់គ្នាដឹងហើយថា "សភាវៈកើតឡើងសន្ធឹកសាច់មួល តែងតែវិនាសទៅវិញជាធម្មតា គ្មានសភាវៈណាដែលមានឥទ្ធិពលមកជំទាស់ពាក់ព័ន្ធតាំងនឹងនិរន្តរ៍ណាមធម៌បានឡើយ តែយើងបានដឹងទៀតថា " គុណធម៌អាចជួយបង្កើនអាយុសត្វសត្វឱ្យចំរើនបានដោយអន្លើ ព្រោះហេតុនោះ ទើបយើងពាល់គ្នារួមគំនិតធ្វើបុណ្យកឋិនានេះឡើង ជាកិច្ចតបបុកាគុណផង ជាកិច្ចនៃអាយុវឌ្ឍនមង្គលផង ចំពោះសម្តេចជាគ្រូនៃយើងពាល់គ្នា " ។

បពិត្រសម្តេចជាទីគោរព!

បុកាគុណដ៏ធ្ងន់របស់សម្តេច ដែលផ្សាយមកគ្របដណ្តប់យើងខ្ញុំពាល់គ្នាដោយព្រះទ័យប្រោសប្រាណជាពន់ពេកនោះ យើងខ្ញុំគ្មានអ្វីតបឱ្យសមគួរទេ ក្រៅពីកុសលធម៌ចេញ ដូច្នេះ យើងខ្ញុំព្រះករុណាទាំងឡាយ សូមបង្អោនកាយវាចាចិត្ត លើកកម្រៃប្រណម្យផ្នងលើសិរសាទៅកុសលទាំងនេះប្រគេនចំពោះសម្តេច, សូមសម្តេចជាម្ចាស់មេត្តាប្រោសអនុគ្រោះទទួលយកកុសលដែលសិស្សគណៈទ្វិសប្រគេននេះ ដោយព្រះទ័យជ្រះថ្លាមនស្សចុះ ។

ដោយតេជានុភាពនៃកុសលចរិយាដែលកើតពីដួងចិត្តដ៏បរិសុទ្ធរបស់

យើងកាល់គ្នានេះ សូមសម្តែចចានសរសើរយថាកព្រះរេគាពាធ ដែលមានក្នុងព្រះរាជ្ជកាយសព្វថ្ងៃ ជាបន្ទាន់តាមរួសពន់តាមពាក្យបន់ស្រន់នៃយើងខ្ញុំនេះ, សូមសម្តែចមានព្រះជន្មាយុជាងរយវស្សា គ្រាន់ជាម្ចប់ជាទីជ្រកកោនៃយើងខ្ញុំព្រះករុណាជាងឡាយ ។

ម្យ៉ាងទៀត យើងសូមទូលុសកុសលនេះ ដល់សត្វក្នុងកាជនៈលោក សូមឲ្យមានបុញ្ញភាគីស្មើៗ គ្នាកុំបីឃ្លៀងឃ្លាត!

អស់លោកជាកល្យាណមិត្ត ជាសិស្សគណ, ជាទាសកទាសិកាជាងឡាយ! សូមឲ្យលោកបានប្រកបដោយសេចក្តីសុខក្សេមក្សាន្តពីរាងពីបច្ចុប្បន្ននេះ រហូតដល់អរសានជាតិ គឺព្រះនិព្វានកុំបីឃ្លាត ។

ពាក្យសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៨ លេខ ១១ ខែកញ្ញា ព.ស.២៥៥៩ គ.ស.១៩៥៦



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— ពុទ្ធសាសនានៅប្រទេសខ្មែរ	ព្រះភិក្ខុ ប៉ាង-ទាត់	១០០៣
— ករុណធម៌ (តមក)	ព្រះទេពសត្ថា កែម-តូរ	១០២០
— ត្រៃវិបនកថា	លោក ឯន-ប៊ន់	១០៣០
ផ្នែកអក្សរសាស្ត្រ		
— អក្សរសាស្ត្រខ្មែរសង្ខេប (តមក)	លោក ភ័ឃ-ប៊ុក	១០៣៩
— ពេជ្រព្រះរាជា (តមក)	លោក ស៊ុន-ហ៊ាន ...ប្រែ...	១០៥០
— រឿងសាមកុក (តមក)	ឧកញ៉ា ភូ-កន	១០៥៦
— រឿងបល្ល័ង្កទីព្យ (តមក)	លោក ភ័ឃ-ប៊ុក ...ប្រែ...	១០៦៣
— សាស្ត្រាបបាត	លោក ជាប-គីន	១០៦៩
— ក្តែសតូឡូហ្សែន	លោក ផេង-ស្រីវ ...ប្រែ...	១០៨២
កំណាត់ទឹតិប្រវត្តិការណ៍		
— ពិធីបុណ្យព្រះសពសម្តេចព្រះសុធម្មាធិបតី អ៊ុង-ស្រី សង្ឃរាយកគណៈធម្មយុត្តិ ..	លោក ឯន-ប៊ន់	១០៩២

មួយឆ្នាំមាន ១២ លេខ ក្រៅ - ដំឡៃជាវ ២៣០រ,០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE: *Page*

— Le bouddhisme au Cambodge . *par le Vén. . PANG-KHAT 1003*
— Kurudharma (suite) . . . . . *par le Vén. . SO-HAY . . 1029*
— Traivacanakatha . . . . . *par M. EN-PANG . . . 1030*

PARTIE LITTÉRAIRE:

— Littérature Khmère résumée (suite) . . . . . *par M. RAY-BUC 1039*
— Conte "Le Diamant de Raja" (suite) . . . . . *Traduit par M. SIN-HEAN. 1050*
— Histoire du Samkok (suite) . . *Traduit par M. NOU-KAN. 1056*
— Les trente deux récits du Trône (suite) . . . . . *Traduit par M. RAY-BUC . 1063*
— Histoire du loup . . . . . *par M. CHAP-PIN 1069*
— Histoire de chien blanc Tolozène *par M. PHENG - CHRIV . 1082*

NOTES ET CHRONIQUES:

— Fête d'incinération de S. E. OUNG - SREY, Chef de l'ordre Dhammayut . . . . . *par* M. EN - PANG *1092*

Prix d'abonnement annuel (comprenant 12 numéros) 230$00

ផ្នែកសាសនា

ពុទ្ធសាសនានៅប្រទេសខ្មែរ

ភិក្ខុ បណ្ឌិតោ ភិក្ខុ (ប៉ាង ខាត់)

ពុទ្ធសាសនាបានចាលពន្លឺមកលើដែនដីកម្ពុជាតាំងពីបុរាណកាល, ជនជាតិខ្មែរក៏បានទទួលយកពុទ្ធសាសនាពុកជាសរណៈដ៏ខ្ពង់ខ្ពស់ តាំងពីកាលនោះរៀងមក ដើម្បីបង្ហាញសេចក្តីត្រេកអរ ដើម្បីសម្រែចសេចក្តីប្រាថ្នា ទន្ទឹងសេចក្តីសង្ឃឹម ព្រមទាំងដើម្បីបញ្ជាក់ខ្លួនសេចក្តីខ្ពស់ចិត្តរបស់ខ្លួនទៅកន្លងអនាគត ។ ពុទ្ធសាសនា បានអប់រំចិត្តគំនិតប្រជាជនឲ្យឈ្នះខ្លួនជំនឿកូតនិយមនៃបុព្វជន គ្រាតែរសជាតិនៃព្រះធម៌ជ្រួតជ្រាបរហូតដល់ទៅដីរតែជាទិច្ចរៀងរាល់ថ្ងៃទៀតផង ។ តាំងតែពីបានចូលមកប្រតិស្ឋាននៅលើដែនដីខ្មែរហើយ ពុទ្ធសាសនាតាំងទៅស៊ប់ ឥតសាបសូន្យក្នុងវេលាណាមួយឡើយ គ្រាន់តែមិនចេញឈ្មោះជាផ្លូវការ ឬមិនបានទទួលប្រាសប្រាណពីរាជសំណាក់ក្នុងកាលខ្លះប៉ុណ្ណោះ ហើយបានផ្សាយអានុភាពមកលើសិល្បៈនិងអក្សរសាស្ត្រខ្មែរទៀតផង ។ ក្នុងសម័យអាប់ឧនព្រះពុទ្ធសាសនាអាចជ្រែតជ្រកនៅជាមួយសាសនាព្រាហ្មណ៍ ដែលជាសាសនាឥតមានសន្តោសដល់ដំនឿដទៃបាន ដូចប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ ខ្ញុំបង្ហាញឲ្យយើញដោយជាក់ស្តែងដូចតទៅនេះ :

សម័យមុនពង្សាវតារប្រទេសខ្មែរ.— ក្រោយពុទ្ធបរិនិព្វានកាលប្រមាណ ២១៨ ឆ្នាំ ព្រះបាទអសោកធ្វើឡើងសោយរាជ្យក្នុងរាជធានីបាតលិបុត្តនៃមគធរដ្ឋ ។ ក្រោយធ្វើសង្គ្រាមកលិង្គរដ្ឋហើយ ទ្រង់ឃើញសង្គ្រាមថាជាមហន្តរាយដល់មនុស្សជាតិយ៉ាងវិកៃលែង ទ្រង់ឈ្វេងយល់ថាមានតែព្រះធម៌ទេ ដែលអាចញុំាងសត្វលោកឲ្យរួចស្រឡះចាកទុក្ខបានសុខ ទើបទ្រង់ប្រកាសចូលកាន់ពុទ្ធសាសនា ។ ទ្រង់បានជាព្រះរាជូបត្ថម្ភក៍ក្នុងការធ្វើឥតិយសង្គាយនា ព.ស. ២៣៤ ។ ធ្វើឥតិយសង្គាយនាហើយ ទ្រង់បានបញ្ជូនសមណទូតទៅកាន់បច្ចន្តប្រទេសនានាផុតពីដែនដ៏មធ្យមប្រទេសមុនដំបូងបង្អស់ក្នុងប្រវត្តិពុទ្ធសាសនា ឈ្មោះថាបានបើកពុទ្ធសាសនាឲ្យសកលលោកបានស្គាល់តាំងពីកាលនោះមក ។

សមណទូតមួយអង្គ ។ បានទាំយកព្រះបរមសារីរិកធាតុ ឬព្រះអរហន្តធាតុជាប់ទៅជាមួយផង ទិមន្តទៅកាន់ប្រទេសណា ក៏ចាត់ការកសាងព្រះស្តូបចេតិយដំកល់ព្រះសារីរិកធាតុក្នុងប្រទេសនោះ ។ ទ្រង់បានបញ្ជូនព្រះមហិន្ទត្ថេរជាព្រះរាជបុត្រទៅកោះលង្កា ។ កោះលង្កានេះជាមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនាមួយដ៏សំខាន់ ក្នុងប្រវត្តិពុទ្ធសាសនាថែរវាទ ។ ទ្រង់បានបញ្ជូនព្រះសោណត្ថេរ ឧត្តរត្ថេរទៅសុវណ្ណភូមិ ។

សុវណ្ណភូមិនៅឯណា ?

សុវណ្ណភូមិជាដែនដីមានសម័យតាំងពីបរិនិព្វានក្នុងទក្ខិណទិសាភាគប្រទេសកូមា ឧត្តរប្រទេសថៃសព្វថ្ងៃនេះ ឬឧត្តរហៅរួមថា ដែនដីអាស៊ីភាគ

អាគ្នេយ៍កំបាន ។ នៅដែនដីសុវណ្ណភូមិដែលជាទីឋានបិតនៅឆ្ងាយពីប្រទេសឥណ្ឌា ហើយមានបុរាណដ្ឋានបុរាណវត្ថុនិងសិលាចារឹកច្រើនកន្លែង គួរនិងសន្និដ្ឋានថាទីនោះ។ ជាមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនាតាំងពីសតវត្សទី ៣ ព.ស. បាន ។

ដែនដីសុវណ្ណភូមិ ឬអាស៊ីភាគអាគ្នេយ៍នេះ មានមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនា ៣ កន្លែង គឺ ៖

១ – សុវណ្ណភូមិបច្ចិមទិសាភាគ គឺប្រទេសភូមាសព្វថ្ងៃ ។ ទីក្រុងបុរាណឈ្មោះសុធម្មវតី[1] ឬ សុធម្មបុរៈ សព្វថ្ងៃនេះហៅថា «ថាតុង» (THATON) សមជាទីឋានសមណទូតព្រះចន្ទអសោកកន្លងសតវត្សទី ៣ ព.ស. ។ ក្នុងតម្លាន់ប្រាំម[2] (Prome) អ្នកប្រាជ្ញបុរាណវត្ថុបានរកឃើញបន្ទះមាសចារឹកគោលពុទ្ធសាសនាថា យេ ធម្មា ហេតុបភវា ។ ល ។ នៅមោ៉ងគាន (Maurng gan) និងម៉ាហ្សា (Maza) ជាកសិកម្មតាំងកើតឡើងកន្លងសតវត្សទី១០ ព.ស. ។

២ – សុវណ្ណភូមិមជ្ឈិមភាគ គឺប្រទេសថៃសព្វថ្ងៃ ។ នៅភាគខាងក្រោមទន្លេមេណាម មានចេតិយ[3]និងកន្លែងបូជនីយដ្ឋានបុរាណជាច្រើន មានព្រះពុទ្ធរូបចនាអមរាតែ នៅពន្លឺក ជាកសិកម្មតាំងកើតឡើងកន្លងសតវត្សទី ៨ ព.ស. ។

៣ – សុវណ្ណភូមិបុព្វទិសាភាគ គឺប្រទេសវៀតណាមសព្វថ្ងៃ ។ លោកហ្សាំរ៉ាន់[4] សរសេរទុកថា មានជនជាតិឥណ្ឌាបាននាំយកវប្បធម៌មកផ្សាយតាំងពីសតវត្សទី ៣ ព.ស. ។ មានសិលាចារឹកពុទ្ធសាសនានៅ

វ៉ូកាញ់ (៥) (Vo-canh) ជាកស្តុតាងកើតឡើងក្នុងសតវត្សទី ៨ ព. ស. ទឹងពុទ្ធរូបឥណ្ឌូ(៦)គ្រឹកនៅវត្តរំលោកចាស់ជាងគេ រចនាមគធៈប្តមថុកប្ត អដន្ធា ជាកស្តុតាងកើតឡើងក្នុងសតវត្សទី ១០ ព.ស ព្រមទាំងមានបុរាណដ្ឋានពុទ្ធសាសនា ២ កន្លែងទៀតនៅអង្គរបូរីមួយកន្លែង ទឹងនៅវត្តត្រពាំងវែងខាងត្បូងខេត្តព្រៃត្រពាំង (រៀតណាមខាងត្បូង) មួយកន្លែង។

កូមិភាគទាំង ៣ កន្លែងនេះហើយ ជាទីឋានដែលព្រះថេរពុទ្ធគ្តោះទាំងឡាយមានព្រះសោណគ្តោ ទឹងព្រះឧត្តរគ្តោរជាដើម បានសាបព្រោះពូជពុទ្ធសាសនាបណ្តុះបណ្តាលឱ្យជ្រុះលូតលាស់ឡើង ត្រាតែកន្លងសម័យបច្ចុប្បន្នកាលនេះ មានប្រជាជនពាប់លាននាក់ចូលកាន់ពុទ្ធសាសនា ។

សម័យធ្វើរ្ជាំ .— ពីសតវត្សទី ៦ ទៅទី ១១ ព. ស. (៥៤៣-១០៩៣)។ អាស្រ័យដោយកូមិភាគនេះមានវប្បធម៌ឥណ្ឌាចូលមកហើយ ប្រទេសនគរភ្នំ (Founan) ក៏បានទទួលពុទ្ធសាសនាថេរវាទ តាំងពីបឋមកាល បានជាមានសិលាចារឹកពុទ្ធសាសនា(៧)សំស្ក្រឹតចាស់ជាងគេនៅឥណ្ឌូចិន (សិលាចារឹកវ៉ូកាញ់) កើតឡើងក្នុងសតវត្សទី ៨ ព.ស. ថ្ងៃទីពាជវង្សស្រីមារៈដែរថ្វាពុទ្ធសាសនា ឯព្រះពាជប្រកាសព្រះអង្គដែលធ្លាក់ខុកក្នុងសិលាចារឹកនោះ មានទំនងដូចព្រះពាជប្រកាសព្រះបាទអសោកនៅប្រទេសឥណ្ឌាដែរ ។ សម័យនគរភ្នំ ព្រះពាជាមន្ត្តីធំតូចរហូតដល់ប្រជាជន ភាគច្រើនកាន់សាសនាព្រាហ្មណ៍ គោរពព្រះមហេស្វរៈ (ព្រះឥស្សរ) ដល់សម័យតមក គោរពហរិហរៈ គឺព្រះឥស្សរនិងព្រះវិស្ណុរួម

ចូលគ្នា; ក្រៅពីសាសនាព្រាហ្មណ៍ ព្រះពាជាអង្គខ្ទុះទឹងច្រើជាជនកាន់ពុទ្ធសាសនាថេរវាទ ។

ខាងដើមសតវត្សទី ១១ ព.ស. ពង្សាវតារចិនខាងត្បូង(៣)ពណ៌នាថា ប្រទេសនគរភ្នំកាន់សាសនាព្រាហ្មណ៍ ឯពុទ្ធសាសនាក៏ចំរើនធំទូលាយណាស់ដែរ ។ ព្រះចាន់កៅណ្ឌិណ្យជយវរ្ម័ន(ទំពីរ)ឡើងសោយរាជ្យក្នុង ព.ស. ១០២១, កាលដើមទ្រង់កាន់សាសនាព្រាហ្មណ៍តមកទ្រង់កាន់ពុទ្ធសាសនា ហើយទ្រង់បានបញ្ជូនតិក្ខនាគសេន(៤) ជាតិឥណ្ឌៀជាបេសកជនទៅកាន់ព្រះចៅក្រុងចិន វូ - ឌី ទ្រង់បានបញ្ជូនព្រះសង្ឃប្រាប់ត្រឹមធ៌មន្តូរសេនត្រូវទៅកាន់ព្រះពាជសំណាក់ព្រះចៅក្រុងចិនដើម្បីជួយប្រែព្រះត្រៃបិដក ។ ព្រះថេរៈតាំងពីអង្គនេះមានឈ្មោះជាកដក្នុងព្រះត្រៃបិដកចិន ។ ទ្រង់បានបញ្ជូនតិក្ខវីរៈប្រើនអង្គទៀតទៅកាន់ព្រះពាជសំណាក់ព្រះចៅក្រុងចិន ។ ព្រះចាន់តុទ្ធវរ្ម័ន(៥)ឡើងសោយរាជ្យក្នុង ព.ស. ១០៥៧ ទ្រង់ជាមហាក្សត្រប៉ុន្មានក្រោយសម័យនគរភ្នំ សិលាចារឹកនៅប្រាសាទតាព្រហ្ម ទន្ទេចាទី(១០) ដំណាលថាទ្រង់កាន់សាសនាព្រាហ្មណ៍ តែទ្រង់គោរពព្រះបរមសារីរិកធាតុតាមបែបពុទ្ធសាសនាថេរវាទ ។ ទ្រង់បានថ្វាយព្រះពាជសារៈទៅកាន់ព្រះចៅក្រុងចិន ព.ស. ១០៨២ ថា ទ្រង់មានព្រះបរមសារីរិកធាតុ(១១) តិព្រះកេសមួយសរសៃ ។ គួរឲ្យទឹកថា ព្រះបរមសារីរិកធាតុនេះ ជាមរតកតបុស្សៈ ទឹងផលិកៈ ទុកឲ្យជាតិខ្មែរ ។ ក្នុងរជ្ជកាលព្រះចាន់កៅណ្ឌិណ្យជយវរ្ម័ន(១២) ទឹង

ព្រះបាទវុទ្ធីវរ្ម័ន សតវត្សទី ១១ ទីដំទី ១២ ព.ស. ព្រះពុទ្ធសាសនាចំរើនរុងរឿងណាស់ ។ តមកយើងមានសិលាចារឹកនៅវិទ្យាវិសេសមួយទៀតពី ព.ស. ១១៧០ ដំណាលពីពុទ្ធសាសនាសម័យនោះ ។

លោកយី-ត្ស៊ីង (Yi-Tsing) ដែលបានធ្វើដំណើរមកកាន់អាស៊ីគាគអាគ្នេយ៍កន្លងរាង ព.ស. ១២១៤-១២៣៨ បានសរសេរទុកថា(១៣) "នៅប្រទេសនគរកំពុង គាលមុនព្រះពុទ្ធសាសនាថេរវាទចំរើនរុងរឿងណាស់ ហើយផ្សាយទូទៅ" តមក "មានព្រះពាជាមួយព្រះអង្គមិនសព្វព្រះទ័យ ហើយចំបាត់ព្រះពុទ្ធសាសនាចោលអស់ទៅ ហើយឥឡូវនេះ សូម្បីតែភិក្ខុមួយអង្គក៏មិនសល់ផង" ។ សេចក្តីលោកយី-ត្ស៊ីងនេះ មិនមានហេតុផលសមរម្យល្មមឥតិចានទេ ព្រោះសម័យនោះមានសិលាចារឹកខ្លះនិយាយពីការកសាងវត្តតាមដងផ្លូវសោះឡើយ ។

សម័យបេងទ្បា.— សតវត្សទី ១១ ទៅទី ១៤ ព.ស. (១០៩៣-១៣៤៥) ។ ពុទ្ធសាសនាមហាយាន(១៤) ចូលមកដែនដីកម្ពុជាមុនដំបូងក្នុងពន្យារគ្រាប្រទេសខ្មែរ គឺខាងដើមសតវត្សទី ១២ ព.ស. ។ មានសិលាចារឹកមួយនៅខេត្តសៀមរាប កើតឡើងពី ព.ស. ១៣៣៤ ដំណាលពីការកសាងពោធិសត្វលោកេស្វរៈ(១៥)ដើម្បីគោរព ។ ឋូបទីយដ្ឋាននេះ សព្វថ្ងៃហៅថាប្រាសាទ តាកែម ។

សម័យមហាឥសិរ.— សតវត្សទី ១៤ ទៅទី ២០ ព.ស. (១៣៤៥-១៨៧៥) ។ ព្រះបាទជយវរ្ម័នទី ២ ទ្រង់ឡើងសោយរាជ្យ ព.ស. ១៣៤៥

ខ្ញុំតាំងព្រះពុទ្ធជានីលើមហេន្ទ្របវ៌ត គឺកុំគូលែន ។ ព្រះស្តេចអ័ញ
សិរីតែលក៏តាមស្តេចទៅនៅក្នុងព្រះពុទ្ធជានីនោះដែរ ។ កាលនោះ
មានព្រាហ្មណ៍ម្នាក់ឈ្មោះហិរណ្យភាម មករៀបចំពិធីបែកាសឯកភក្ត្រជា
បក្តីតាធិកជយប្រតិស្ឋទៅពុទ្ធជឡើង ។ ព្រះពុទ្ធអង្គនេះបានរួបរួម
ចេនឡាតាំងពីខ្សែទៅជាប្រទេសតែមួយ ហើយស្ថាបនាប្រទេសឲ្យ
បានរុងរឿងឡើង ។ ព្រះពុទ្ធអង្គនេះខ្ញុំកាន់សាសនាព្រាហ្មណ៍ គោរព
ហរិហរៈ តែពុទ្ធសាសនាតាំងពីនិកាយបិតរថវាជាមួយសាសនាព្រាហ្មណ៍
រហូតមក ។ តាំងពីសតវត្សទី ១៩ ព.ស. រៀងមក ព្រះពុទ្ធ(១៦) ខ្ញុំង
មន្ត្រីកាន់សាសនាមិនស្រុបគ្នាទេ ។ ព្រះបាទឥន្ទ្រវ៌ន្ទខ្ញុំងឡើង(១៧)
សោយរាជ្យក្នុង ព.ស. ១៤២០ តាំងព្រះពុទ្ធជានីទៅបាគង (តម្បន់ស្រុស
សព្វថ្ងៃនេះ) ។ ខ្ញុំកាន់សាសនាព្រាហ្មណ៍ គោរពព្រះហរិហរៈ
ប្រាសាទបាគងជាហរិហរាល័យ គឺជាឋានព្រះហរិហរៈ តែខ្ញុំរប្រាស
ប្រាណពុទ្ធសាសនាដែរ ។ ក្រោយខ្ញុំទីវង្គតទៅ ព្រះបាទយសោវ៌ន
(១៨) ជាព្រះពុទ្ធបុត្រឡើងសោយរាជ្យក្នុង ព.ស ១៤៣២ ហើយស្តេច
ទៅតាំងព្រះពុទ្ធជានីថ្មីឈ្មោះយសោធរបុរៈ គឺបរិវេណអង្គរធំមានកុំប្បាវែង
ជាមជ្ឈដ្ឋាន ។ ខ្ញុំទទួលស្គាល់ពុទ្ធសាសនាមហាយានជាជ្រកការមុនដំបូង
បន្តិចក្នុងពេលតែប្រទេសខ្មែរ ។ សាសនាព្រាហ្មណ៍និងពុទ្ធសាសនា
តាំងពីនិកាយមិនមានការប្រឹងប្រែងគ្នាទេ មានសិទ្ធិនឹងគ្នាដូចៗគ្នា
ហើយទៅជាសុខក្សេមក្សាន្តតរៀងមក ។ ខ្ញុំបានកសាងវត្តអារាម
ថ្វាយសាសនាតាំងពីនេះ ។ តមក ព្រះបាទជេដ្ឋវ៌ន(១៩) ខ្ញុំងឡើង

សោយរាជ្យក្នុង ព ស. ១៤៨៧ ទ្រង់កាន់សាសនាព្រាហ្មណ៍ តែងព្រះឥសូរ តែក្នុងរាជ្យព្រះអង្គ ការកសាងវត្តអារាមពុទ្ធសាសនា ឃើញមានកាន់តែច្រើនឡើង ហើយកាន់តែសសៀរចូលមកជិតព្រះរាជធានីថែមទៀត ។ មានមន្ត្រីជាន់ខ្ពស់ម្នាក់ឈ្មោះកវីន្ទ្រាវមថន: កាន់ពុទ្ធសាសនា បានកសាងទេវាល័យ ៣ ខ្នងនៅឋាតដុំ : មួយថ្វាយព្រះសម្មាសម្ពុទ្ធ, មួយថ្វាយព្រះវជ្រឋាណិ, មួយទៀតថ្វាយព្រះជ្រាជ្ញាឋារមិតា ។

តមកទៀត ព្រះបាទជយវរ្ម័នទី ៥(២៨) ជាព្រះរាជបុត្រព្រះបាទរាជេន្ទ្រវរ្ម័នឡើងសោយរាជ្យក្នុង ព.ស ១៩១១ ក្នុងរាជ្យព្រះអង្គនេះ មានសិលាចារឹកមួយនៅវត្តស្រីសន្ទរឱ្យដឹងថា(២៩) ទ្រង់មិនមែនជាពុទ្ធសាសនិកទេ តែរាជត្រកូលនឹងមន្ត្រីជាន់ខ្ពស់កាន់ពុទ្ធសាសនាមហាយានលទ្ធិយោគាចារ: គោរពព្រោធិសត្វលោកេស្វរ: មានមន្ត្រីជាន់ខ្ពស់ម្នាក់ឈ្មោះកវីន្ទ្រវិប្បណ្ឌិតជាអ្នកនាំ ។ ក្នុងសិលាចារឹកនេះ ពួកអ្នកប្រាជ្ញតាំងឡាយសង្កេតឃើញលទ្ធិសាសនាព្រាហ្មណ៍ចូលលាយឡំក្នុងព្រះពុទ្ធសាសនានៅប្រទេសខ្មែរមុនដំបូង ។ ព្រះបាទសូរ្យវរ្ម័នទី ១(៣២)ឡើងសោយរាជ្យក្នុង ព. ស. ១៥៤៥ ទ្រង់ជាពុទ្ធសាសនិក ទ្រង់ប្រាថ្នាឲ្យលួសស្គាល់ពុទ្ធសាសនាលទ្ធិមហាយានជាផ្លូវការ មិនមែនគ្រាន់តែប្រាសប្រាណប៉ុណ្ណោះទេ ទ្រង់ប្រាថ្នាឲបត្តម្ភពេញបន្ទុកថែមទៀតផង ។ ក្នុងរាជ្យព្រះអង្គ ព្រះពុទ្ធសាសនារុងរឿងណាស់ មានការកសាងពុទ្ធរូបប្រគល់នាគច្រើនអនេក

តែក្នុងព្រះបរមរាជវាំងនៅគោរត(២៣) ទេវរាជ តាមព្រះរាជប្រពៃណីដូចដើម ។ លុះទ្រង់ទិវង្គតទៅ គេថ្វាយព្រះបច្ចាមរណានាមថា "ព្រះនិព្វានបទ" ។

ដល់មកសតវត្សទី ១៨ មានព្រះរាជាមួយព្រះអង្គ មានព្រះកិត្តិនាមល្បីល្បាញក្នុងពន្ធព្រះរាជវង្ស ឡើងសោយរាជ្យក្នុង ព.ស ១៧២៤ ទ្រង់ព្រះនាមព្រះបាទជយវ៌ែនទី ៧(២៤) ទ្រង់ជ្រះថ្លាពុទ្ធសាសនាមហាយានគោរពលោកេស្វរៈ ព្រះប្រាជ្ញាបារមិតា ។ ក្នុងរាជ្យព្រះអង្គទ្រង់មិនទទួលទេវរាជទេ ទ្រង់ប្រតិស្ឋពុទ្ធរូបវិញ, ពុទ្ធសាសនារុងរឿងអស្ចារ្យ ។ ប្រាសាទរាជស្ថានប្រែនកន្លែង ដ៏ហើយដោយកំពូលសុទ្ធសឹងលោកេស្វរៈសមន្តមុខច្រើនច្រាន ព្រះនេត្រាសំឡឹងចុះមកក្រោមព្រះកត្តញ្ញូមពន្យល់ លើកតំកើងព្រះកិត្តិយសពុកជាដំណតមក ។ ទ្រង់សាងព្រះរាជវិហារ(២៥)សព្វថ្ងៃហៅ តាព្រហ្ម កាល ព.ស. ១៧២៨ ដើម្បីដំកល់បដិមាករព្រះនាងជយរាជទេវីមាតា ជាព្រះវរៈរាជមាតា ពុកជាអង្គប្រាជ្ញាបារមិតា គឺជាធម្មមាតានៃព្រះពុទ្ធ ទើបបដិមាកវនៃព្រះរាជគ្រួយទៀតឈ្មោះ ជយមង្គលថៈ ។ ក្រោយពីសាងព្រះរាជវិហារមក ៩ឆ្នាំ គឺក្នុង ព.ស. ១៧៣៤ ទ្រង់សាងប្រាសាទជយស្រី(២៥) សព្វថ្ងៃហៅព្រះខាន់ ដើម្បីដំកល់បដិមាករព្រះបាទធរណីន្ទ្រវ៌ែន (ឥន្ទ្រវ៌ែនទី ២) ជាព្រះវរៈបិតា ពុកជាអង្គសោធិសត្វលោកេស្វរៈ ហើយថ្វាយព្រះនាមថា ជយវរមេស្វរៈ ។ ក្នុងបច្ចុប្បន្នកាល ទ្រង់សាងប្រាសាទបាយ័ន(២៥) ដើម្បីតំកល់បដិមាករព្រះអង្គជាពុទ្ធរូប ព្រមទាំងប្រតិស្ឋានពោធិសត្វលោកេ

ស្ងួរ:សមន្តមុខដែលទុកដូចជាព្រះអង្គនៅលើកំពូលភាំងឡាយនៃប្រាសាទ
ប្រាយ័ននោះផង ។ សិលាចារឹកនៅប្រាសាទតាព្រហ្ម(២៦) សរសើរព្រះ
រាជសាសន៍របស់ព្រះអង្គទុកថា: "មានតាំងដ៏ប្រសើរដែលនាំទៅកាន់សេចក្តី
ត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ជាមាគ៌ាឯក ឥតមានមន្ទិលសៅហ្មង
ដើម្បីឲ្យបានយល់ធម៌ពិត គឺជាធម៌ដែលអមតបុគ្គលកន្លងផុតគ្រប់គ្រង គួរគោរព
បូជាទុកជាព្រះទាន់ពេជ្រ សម្រាប់តាប់ចំផ្លាញនូវបណ្តាញបន្ទាត់
តណ្ហា" ។ សិលាចារឹកនៅមន្ទីរពេទ្យ(២៧) សរសើរព្រះកិត្តិយសគុណ
ព្រះអង្គទុកថា "ខ្ញុំមានព្រះទ័យខ្ញោចផ្សា ចំពោះជម្ងឺប្រជាជនខ្លាំង
ជាងព្រះអាពាធព្រះអង្គ ព្រោះថាសេចក្តីទុក្ខនៃប្រជាជន ជាសេចក្តីទុក្ខ
នៃព្រះរាជាតាំងឡាយ តុំមែនចំពោះទុក្ខផ្ទាល់ព្រះអង្គទេ" ។

មានព្រឹត្តិការណ៍មួយចំឡែក គួរកត់សំគាល់ទុកក្នុងរាជ្យព្រះអង្គគឺ
ខ្ញុំបានបញ្ជូនព្រះរាជបុត្រទៅសិក្សាព្រះពុទ្ធសាសនា ហើយបញ្ជូនទៅ
វត្តមហាវិហារនាកោះលង្កា ។ តាមពង្សាវតារកូមានិយាយថា(២៨) មាន
សាមណេរជាតិមនមួយអង្គឈ្មោះធបតៈ អាយុ ២០ ឆ្នាំ ទៅរៀននៅកោះ
លង្កា ១០ ឆ្នាំ ហើយត្រឡប់មកកាន់ប្រទេសកូមាវិញ ព.ស. ១៧៣២
ជាមួយនឹងភិក្ខុឯទៀត ៤ អង្គ មួយអង្គឈ្មោះតាមលិន្ទៈ ជាព្រះរាជបុត្រ
មហាក្សត្រប្រទេសកម្ពុជា ។ ភិក្ខុ តាមលិន្ទៈ នេះពិតជាបានជា
ព្រះរាជបុត្រព្រះបាទជយវរ្ម័នទី ៧ ។ សេចក្តីប៉ុណ្ណេះជាដើម ដែលនាំ
ឲ្យអ្នកប្រាជ្ញពង្សាវតានឹងអ្នកប្រាជ្ញបុរាណវត្ថុយល់ថា ភិក្ខុតាមលិន្ទៈជា

ព្រះពជបុត្រ ព្រះបាទជយវរ្ម័នេះ ដែលនាំពុទ្ធសាសនាថេរវាទលង្កាវង្ស ចូលមកផ្សាយក្នុងប្រទេសខ្មែរមុនដំបូងក្នុងឥស្សរតាវខ្មែរ ។

ក្រោយរជ្ជកាលព្រះបាទជយវរ្ម័នទី ៧ ទៅ ព្រះពជាសោយកជ្ជជា តំណព្រះវង្សត្រឡប់មកកាន់សាសនាព្រាហ្មណ៍វិញ សាសនាព្រាហ្មណ រុងរឿងបុរីក្រោយបំផុតម្តងទៀត ។ ឯពុទ្ធសាសនាថេរវាទក៏ចំរើនខ្លាំង តាំងពីកាលនោះមកដែរ ។ លោកចៀវ តាកួន(២៩) ជាពជនុតព្រះ ចៅក្រុងចិនដែលបានមកកាន់មហានគរប្រទេសខ្មែរ ក្នុង ព.ស. ១៨៣៩ បានធ្លើសេចក្តីពិពណ៌នាមកដូច្នេះថា "យើញាមានតិក្ខុកោព្រះគេស ប្រជាប់ត្រៃចីវរពណ៌លឿង គ្រងចីវរធ្វើងស្មាម្ខាង នៅស្មាស្តាំទំនេរ ដើរដើងទេ វិហារប្រក់ក្បឿង ក្នុងព្រះវិហារមានព្រះពុទ្ធរូបសាក្យមុនី ហៅថាបោធ្យាយ "ព្រះ" ព្រះពុទ្ធរូបនៅក្នុងថ្ងាសធ្វើពីសំរឹទ្ធិ មិនមានដួងស្គរទេ ធាន់ត្រីសាប់ មិនធាន់សុពទេ ធាន់មួយថ្ងៃតែម្តង ក្នុងវត្តមិនមានផ្ទះបាយទេ តិក្ខុសាមណេរនិមន្តបិណ្ឌបាត សូត្រធម៌ គម្ពីរដីកាចារជាក់ស្តឹតរឹត ព្រះពជាទ្រង់ពិគ្រោះកិច្ចការធំៗ ទីធ៌តិក្ខុសង្ឃ មិនមានតិក្ខុនីទេ" ។ សេចក្តីពិពណ៌នេះសំដែងឲ្យឃើញថា ពុទ្ធសាសនាថេរវាទលូតលាស់ដុះដាលគេញបរិបូណ៌ ហើយបានទទួលស្គាល់ព័ត៌ព្រះពជា មុខមន្ត្រី រហូតដល់ប្រជាជនទូទៅ សមដូចសិលាចារឹកថ្ម(៣០) មុនដំបូងក្នុងប្រវត្តិពុទ្ធសាសនាហីនយានទៅប្រទេសខ្មែរចែងទុកថា "ព្រះបាទសិរិសិរិន្ទវរ្ម័ (គឺឥន្ទ្រវរ្ម័នទី ៣) ឡើងសោយរាជ្យក្នុងមហានគរយសោធរបុរៈក្នុង ព.ស. ១៨៤១ ទ្រង់បានថ្វាយសិរិសិរិន្ទ្រគ្រាមជាព្រះ

អាគមចំពោះព្រះមហាថេរសិរិសិរិវន្ទមោលិ ក្នុង ព.ស.១៨៩១ ហើយ
ទ្រង់មានព្រះរាជឧត្តារគ្រាស់បង្គាប់ឲ្យព្រះនាងសិរិមាលិនីលក្តីកសាងព្រះ
វិហារព្រមទាំងពុទ្ធរូបដំគល់ទុកក្នុងព្រះវិហារវត្តនោះក្នុង ព.ស.១៨៩២"។

ចំណែរថេរគាលតមក ព្រះពុទ្ធសាសនាថេរវាទតែតែចំរើនវុឌ្ឍិនឹង
ឡើងៗជាលំដាប់ សមតាមព្រះរាជបំណងព្រះបាទស្រីមារៈសម័យ
នគរភ្នំ តែព្រះរាជពិធីគ្មានសមាសទ្ធិនឹងព្រះរាជពិធីផ្សេងៗ ក្នុងព្រះបរម.
រាជវាំងបិតថេរខ្មៅតាមប្រពៃណើដើម ដែលមានមកតាំងពីបុរាណកាល ។
តពីរជ្ជកាលព្រះបាទសិរិសិរិវន្ទ (ឥន្ទ្រវ័ន្ទទី ៣) ពាក់កណ្តាលសតវត្ស
ទី ១៩ (ព.ស. ១៨៥២) មក ប្រទេសខ្មែរមានគ្រោះថ្នាក់សង្រៀវចុះ
មកកាន់សេចក្តីអាប់ឧន ព្រោះកើតមានចម្បាំងរាំរ៉ាដល់មិនដាច់ សិលា
ចារឹកដំណាលពីព្រះរាជវង្សត្រូវ មកក៏មិនមាន ពង្សាវតារបុរាណក៏អន្តរ-
ធានបាត់បង់ទៅបន្តិចម្តងៗ តាមកាលវេលា រហូតមកដល់រជ្ជកាល
ព្រះបាទពញាយ៉ត ពាក់កណ្តាលសតវត្សទី ២០ រៀង ព. ស.១៩៧៥ ។

សម័យបច្ចុប្បន្ន.— សតវត្សទី ២០ ទៅទី ២៥ ព.ស. (១៩៧៥-
២៥០០) ។ ក្រោយសម័យមហានគរមក ព្រះពុទ្ធសាសនាថេរវាទ
ប្រតិស្ឋានលើដែនដីខ្មែរជាប់ស៊ីឈ្នាត់តែប្រែប្រួល ចាក់ឫសគល់ជាស្ថាពរ
រៀងរហូតមកដល់បច្ចុប្បន្នកាលនេះ សមដូចពាក្យលោកវ៉ាំងតាយួន[៣១]
(Wang Ta-Yuan) សរសេរសរសើរប្រទេសខ្មែរទុកពីសតវត្សទី ១៩ នៃ
ព.ស. ថា ប្រទេសខ្មែរ ជាចេនឡាមានទ្រព្យសម្បត្តិ ទឹងជាចេនឡា
មួយរយវត្ត ។ ឯសាសនាព្រាហ្មណ៍ទឹងពុទ្ធសាសនាមហាយានមិនសូវ

មានសារ៉ាក កំសាបសូន្យបន្តិចម្តងៗ រហូតដល់អាសានចាត់ឈ្មោះចោះ
សម្ងួតសូន្យឈឹង នៅសល់តែបូរាណដ្ឋានដែរដាសពាសពេញប្រទេស។

ពុទ្ធសាសនាថេរវាទឡើងកាន់សេចក្តីចំរើន យកវត្តសាសនា
ព្រាហ្មណ៍មកធ្វើជាវត្តពុទ្ធសាសនាវិញ ចាត់សិរីលិង្គនៅលើស្នាន
ព្រះណាំទៅ លេចឃើញព្រះពុទ្ធរូបដំកល់នៅលើស្នានព្រះណាំជំនួស
វិញ។ មានវត្តច្រើនណាស់ដែលតាំងនៅលើកខ្ទមវត្តសាសនាព្រាហ្មណ៍
ឈ្មោះនៅជាឈ្មោះវត្តសាសនាព្រាហ្មណ៍ដដែល តែគួរវត្តជាពុទ្ធ-
សាសនា។ វត្តណាមួយដែលតាំងនៅលើវត្តសាសនាព្រាហ្មណ៍ វត្ត
នោះមិនមែននៅសល់តែឈ្មោះទេ នៅមានសល់ស្នាមដំណែលសាសនា
ព្រាហ្មណ៍ដដែល ដូចជាហានកែលាសជាដើម។ ឯទំនៀមស្រុកប្ល
ពិធីផ្សេង។ ដែលលាយឡំដោយលទ្ធិសាសនាព្រាហ្មណ៍នឹងពុទ្ធសាសនា
មហាយាន តើតទៅជាទំនៀមទំលាប់ស្រុកទេសជាប់រហូតមកដល់សព្វ
ថ្ងៃនេះ។ ក្នុងព្រះបរមកដ៏ធំ ព្រះពុទ្ធពិធីផ្សេង។ ដែលជាប់ដោយ
លទ្ធិសាសនាព្រាហ្មណ៍ តាំងពីបុរាណសម័យមកក៏នៅធ្វើតាមប្រពៃណី
ដើមដដែល។ សព្វថ្ងៃនេះ មើលទៅឃើញតែវត្តអារាម កុដិ វិហារ
សាលាដ៏ហ៊ាយដោយកំពូលច្រួចច្រាច តិក្ខ សាមណេរគ្រងចីវរពណ៌
លឿងសព្វទីកន្លែងពាសពេញព្រះពុទ្ធអាណាចក្រ "សមនធិពាក្យអ្នក
បរទេសខ្លះសរសេរទុកថា "ប្រទេសខ្មែរជាប្រទេសតិក្ខសង្ឃ"។

ពុទ្ធសាសនានឹងប្រជាជន.— សម័យអាប់ឧន ប្រជាជនខ្មែរ
ពាំងប្រទេស ជាន់ជួបប្រទះនឹងសេចក្តីទុក្ខវេទនាធំបំផុត ថមថយកម្លាំង

ទឹងកសាងសេចក្តីចំរើនដូចសម័យព្រៃងនាយពុំបាន តែគោះបីជាក់ចុះ
ខ្លាំងបុណ្ណឹងក៏ដោយ ប្រជាជនខ្មែរដែលបានស្គាល់រសជាតិព្រះធម៌ថ្លៃ
វិសេសហើយ ឧបសាសនានេះជាប់ទឹងខ្លួនតុកតមក ស៊ូស្ងាប់មិនព្រមលះ
បង់ចោល ។ បុណ្យទក្ខិណព្រះបរមសារីរិកធាតុទឹងព្រះអរហន្តធាតុព្រះ
សារីបុត្រទឹងព្រះមហាមោគ្គល្លានពីខែតុលា ព.ស. ២៤៩៤ ជាកស្តី
តាងឲ្យឃើញច្បាស់ថា ប្រជាជនខ្មែរពាំងប្រទេសមានចិត្តភក្តីចំពោះព្រះ
ពុទ្ធសាសនាស្រាប់ហើយ ។ ពុទ្ធសាសនាថេរវាទដែលធ្លាប់មានមកពី
សម័យព្រៃងនាយហើយស្រាប់ តែជួតជាបាំសហើយធ្លាយខ្លាយ
ចូលទៅដល់ចិត្តថ្លើមប្រជាជនគ្រប់ជាន់គ្រប់ថ្នាក់ ។ អស់លោកអ្នកនាំ
ប្រទេសខ្មែរ ព្រះមហាក្សត្រមន្ត្រីតូចធំ ដែលបានយល់តម្លៃពុទ្ធសាសនា
ថាមានហេតុផលគ្រប់គ្រាន់ល្មមនាំខ្លួនទៅកាន់សេចក្តីសុខក្សេមក្សាន្តបាន
ក៏ព្រមលះបង់សាសនាដទៃចោលទៅ ដើរសសម្រាំងយកតែពុទ្ធសាសនា
ថេរវាទមួយប៉ុណ្ណោះ ទុកជាសម្បត្តិវប្បធម៌ប្រចាំប្រទេសខ្មែរហូតដល់
មកបច្ចុប្បន្នកាលនេះ ។ ក្នុងសម័យអាប់ឧន ប្រជាជនខ្មែរបានពុទ្ធ-
សាសនានេះហើយជាសរណៈដ៏ខ្ពង់ខ្ពស់ ជួយកម្ចាយភ័យ ជួយសម្រាល
លំហែទុក្ខ ដោយដឿកម្មផលច្បាស់ថា ធ្វើល្អ បានល្អ, ធ្វើអាក្រក់ បាន
អាក្រក់, ហើយខ្លួនបានកូនចៅនៅឯក្រោយឲ្យខំកសាងល្អ ដើម្បី
កសាងអនាគតឲ្យបានរុងរឿងដូចសម័យព្រៃងនាយវិញ គោះជាលំបាក
យ៉ាងណា ក៏ពេញចិត្តរួមសុខទុក្ខជាមួយពុទ្ធសាសនា គាល់តែកើតទៅ
ជាសុភាសិតប្រចាំជាតិថា "ស៊ូស្ងាប់ទៅជា រសធម៌កុំបីបង់" ។

វត្តអារាម :- ប្រជុំភូមិខ្នែនមួយៗ តែងមានវត្តមួយជាដំបូង សម្រាប់តំកុសាមណេរអាស្រ័យនៅ ។ ក្នុងព្រះរាជអាណាចក្រកំពង់មូល មានប្រជាជនចំនួន៥លាននាក់ មានវត្តចំនួន២៨១៨វត្ត មានតំកុសាមណេរ ៦៨.១៤៥ អង្គ ។ ប្រជាជនខ្នែមិនមានឱកាសសម្បត្តិស្តុកស្តម្ភទេ អ្នកដែលគ្រីគ្រែ ធ្វើផ្ទះនៅពីឫស្សីប្រក់ស្លឹក តែមានសទ្ធាខ្លាំងក្លាណាស់ ព្រតគ្នាធ្វើបុណ្យផ្តា ក្បែរបច្ច័យគ្នាកសាងវត្តអារាម ធ្វើកុដិសាលាដោយគ្រឿងឈើឫឥដ្ឋប្រក់ក្បឿង ធ្វើវិហារដោយឥដ្ឋដែកស៊ីម៉ង់ត៍ដោយច្រើន ។ សំណង់ទាំងនេះមានការរចនាវិសេសធ្វើតធាយជាលក្ខណៈការរចនាខ្នែ ។ វត្តនីមួយៗតែងមានកុដិប៉ប្អូនយ៉ាងតិច មានសាលាបុណ្យ សាលារៀនសម្រាប់តំកុសាមណេរ សាលារៀនសម្រាប់កុមារកុមារី មានវិហារដ៏តល់ព្រះពុទ្ធរូបឥតថ្លៃ ។ វិហារនេះធំឧត្តមជាងសំណង់ឯទៀត តំពូលខ្ពស់ ម៉ើលពីចម្ងាយឃើញច្បាស់ នាំឱ្យអ្នកផងស្គាល់ភ្លាមថា នេះជាវត្តអារាមនៃព្រះតំកុសង្ឃព្រះពុទ្ធសាសនា ។ ការកសាងវត្តអារាមក្តី ការឧត្តន្តធ្ងន់អាហារគោជនក្តី ជាការៈនៃឥយកថាយិកាផើងវត្ត ទោះបីអត់ឃ្លានមានគ្រ ទោះបីស្រុកទេសកើតចលាចលប្លន់តតុំក្តី កំតំកុសាមណេរមិនខ្វះខាតអាហារគោជនទេ ។

សូម្បីប្រជាជនសាមញ្ញជាអ្នកដំណើរ ជួនជាខ្វះខាតអាហារ អាចសុំអាហារផ្ទះណាមួយតាមផ្លូវបានបរិភោគឆ្អែតស្កប់ស្កល់ ។ តាមផ្លូវធំៗ មានចំខៃមកសាងសាលាជ្រកមួយ ឬជាដើមពោធិជ្រកមួយដើមវែ ។ តាមផ្លូវ មានតាឆ័ត មានអណ្តូងឬស្រះសម្រាប់អ្នកដំណើរ ។ ចំខៃមក

នេះ កើតមានតាំងពីសម័យព្រះចៅឧដ័យភ័ន្ធទី ៧ ម្ល៉ះ ។ ប្រពៃណីជាកុសលនេះសំដែងឲ្យយើញថា ប្រជាជនខ្មែរមានចិត្តខ្ពស់ជាចិត្តអ្នកកាន់ព្រះពុទ្ធសាសនា ប្រព្រឹត្តប្រយោជន៍ខ្លួននឹងសត្វសត្វខ្លួនៗមានបាតប្រតិបាថ្នាតាន មានមេត្តាករុណាផ្សាយដល់មនុស្សសត្វមិនរើសមុខ ប្រាថ្នាឲ្យមនុស្សសត្វដែលកើតមកកន្លងលោកនេះបានសេចក្តីសុខ ហើយនៅរួមទុក្ខរួមសុខជាមួយគ្នាជាអង្វែងតទៅ ។

ព្រះសង្ឃ.— ភិក្ខុសាមណេរជាបុគ្គលគួរគោរព នរជនណាមួយនឹងប្រមាទមើលងាយពុំបាន មានការគ្រប់គ្រងដោយឡែកពីប្រជាជនសាមញ្ញ ។ ព្រះសង្ឃនៅប្រទេសខ្មែរមានពីរនិកាយគឺ គណៈមហានិកាយ ១ គណៈធម្មយុត្តិកនិកាយ ១ ។ ពេលព្រឹក ភិក្ខុសាមណេរតើនពីព្រលឹម ចូលទៅក្នុងព្រះវិហារ នមស្ការគុណព្រះរតនត្រ័យ បកសកពាជពុទ្ធសាសនា សូត្រសំលឹកបច្ចុមពុទ្ធវចនៈ ហើយផ្សាយមេត្តានេះហៅថាវត្តព្រឹក, តមក ចោសសំអាតថែរក្សាវត្តអារាម បរិណ្ហបាត ធ្វើភត្តកិច្ចពេលព្រឹក ហើយចូលទៅសាលារៀន, ថ្ងៃត្រង់ធ្វើភត្តកិច្ចថ្ងៃរសៀលចូលសាលារៀន ពេលយប់ចូលវិហារទៀត នមស្ការគុណព្រះរតនត្រ័យ ចំរើនព្រះបរិក្តនឹងព្រះសូត្រផ្សេង ។ មានធម្មបក្ខប្បវត្តនៈសូត្រជាដើម តាមកាលគួរ ហើយផ្សាយមេត្តានេះហៅថាវត្តល្ងាច ។ មានភិក្ខុតាមវាសីច្រើនអង្គ លះបង់ចលិតោធក្នុងវត្ត ដាន់តែមួយថ្ងៃម្តងចេញទៅធ្វើជាអញ្ជាវាសី រកទីស្ងាត់ក្នុងព្រៃស្មសានឬព្រៃភ្នំកែវ ធ្វើជាអាស្រមជ្រកគោនបំពេញសមណធម៌ ។ អាស្រមសម្រាប់ភិក្ខុធ្វើសមណៈ-

ធម៌នេះមានច្រើន មានគ្រប់ខេត្តកងត្រៃរាជអាណាចក្រ ដទៃពីនេះ កិច្ចសាមណេរមានការៈបង្រៀនកុមារកុមារីអ្នកស្រុកដើងវត្តទៅសាលាកងវត្ត ទីឯមានកិច្ចខ្លួនច្រើនច្រែងច្រើនច្រែងដោយពុទ្ធសាសនិកជន ឲ្យតាំងនៅក្នុងធម៌កុំឲ្យធ្វើបាប ឲ្យបំពេញកុសល ឲ្យធ្វើចិត្តបរិសុទ្ធដែលជាគោលពុទ្ធសាសនា ។ ហេតុដូច្នេះហើយ ចានជាប្រជាជនខ្វែរគោរពព្រះសង្ឃណាស់ ដរាបតែព្រះសង្ឃទីឯអ្នកស្រុករមែសុខទុក្ខជាមួយគ្នា ។

ការគ្រប់គ្រងព្រះសង្ឃ.— និកាយទាំងពីរខាងលើនេះ មានព្រះមហាក្សត្រគ្រងជាព្រះពុទ្ធសាសនូបត្ថម្ភក៍ ។ និកាយមួយៗ មានត្រួតការគ្រប់គ្រងដោយឡែកពីគ្នា មានសង្ឃនាយក មេគណ អនុគណ ចៅអធិការ សម្រាប់ត្រួតត្រាកិច្ចសាមណេរឲ្យប្រព្រឹត្តទៅ តាមវិន័យបញ្ញត្តិព្រះពុទ្ធសាសនា ទៀងទៅតែសូងធម្មការ ។ មានព្រះពុទ្ធគ្រមួយស្តីពីការគ្រប់គ្រងព្រះសង្ឃ ។

គណៈមហានិកាយ មានព្រះមហាថេរមួយអង្គខ្ពស់ជុត ជាសង្ឃនាយក មានសមណសក្តិជាសម្តេចព្រះមហាសុមេធាធិបតីជាត្រួតការទីស្តីការនៅវត្តឧណ្ណាលោម ព្រះពុទ្ធធានីក្រុងភ្នំពេញ មានព្រះមហាថេរមួយអង្គ នាទីជាសម្តេចឧត្តមប្រឹក្សា មានថេរសភាមួយនៅអមស្តីការត្រួតត្រាព្រះសង្ឃគណៈមហានិកាយទូទៅពេញព្រះពុទ្ធអាណាចក្រទាំងមូល ។

ក្នុងកុរុធម្មជាតក តិកនិបាត

ព្រះទេពសត្ថា កិមិ - ឆ្លូវ ចន្ទមង្គលោ

ក្រុមដំណុះព្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ប្រែរៀបរៀង

(តមក)

---

១ — រឿងព្រះពោធិសត្វ

ព្រោះហេតុអ្វីបានជាព្រះបាទធនញ្ជយកោរព្យៈមានព្រះទ័យរន្ធត់ស្ទុះក្នុងកុរុធម្មរបស់ព្រះអង្គ ?

តាមសេចក្តីដំណាលថា: កាលនោះ ស្តេចតាំងឡាយតែងគ្រសាលមហោស្រពនៅខែកត្តិក ក្នុងរវាង ៣ ឆ្នាំ ទ្រង់គ្រសាលម្តង រវាង ៣ ឆ្នាំ ទ្រង់គ្រសាលម្តង ។ ព្រះរាជាតាំងឡាយ កាលដែលទ្រង់គ្រសាលមហោស្រពនោះ ទ្រង់ប្រដាប់ដោយគ្រឿងអលង្ការតាំងពួន, ទ្រង់គាន់យកទ្យូកេរជាទៅតាបឹតនៅក្នុងសំណាក់នៃយក្សឈ្មោះចិត្តរាជ, ទ្រង់ចាញ់សរដែលវិចិត្រប្រដាប់ដោយផ្កាទៅក្នុងទិសតាំង ៤ ។ ឯព្រះបាទធនញ្ជយកោរព្យៈ កាលដែលទ្រង់គ្រសាលមហោស្រពនោះ ក៏ទ្រង់បឹតនៅក្នុងសំណាក់នៃយក្សឈ្មោះចិត្តរាជ ហើយចាញ់សរដែលប្រដាប់ដោយផ្កាទៅក្នុងទិសតាំង ៤ ។ សរដែលចាញ់ទៅក្នុងទិសតាំង ៤នោះ ធ្លាក់ចុះទៅក្នុងទិសតាំង ៤នោះ ព្រះរាជាទ្រង់រកឃើញតែសរ ៣ ដែលធ្លាក់ចុះទៅក្នុងទិសដទៃ ឯសរដែលចាញ់ធ្លាក់ចុះទៅក្នុងទឹក ទ្រង់រកពុំឃើញ ។ ព្រះរាជាទ្រង់រន្ធត់ស្ទុះក្នុងព្រះទ័យថា "សរមួយដែលអាត្មាអញ

ចាញ់ទៅហើយឆ្ងាក់ចុះទៅក្នុងទឹក ប្រហែលត្រូវសម្លាប់នៃត្រីខ្លាំង” ។ ព្រះពជាទ្រង់រំពឹងថ្ងៃវត្ថុនូវការបែកធ្លាយនៃសីលរបស់ព្រះអគ្គ ដោយអំពើចាណាតិចាតយ៉ាងនេះ ព្រោះហេតុនោះបានជាទ្រង់ត្រាស់ថា “ម្នាលអ្នកចាំងឡាយ, យើងមានសេចក្តីរន្ធត់ក្នុងកុរុធម្មដោយហេតុនេះឯង, ឯព្រះមាតារបស់យើងទ្រង់រក្សាកុរុធម្មនោះបរិសុទ្ធល្អ, ចូរអ្នកចាំងឡាយទៅសុំបម្លងកុរុធម្មនោះ អំពីសំណាក់នៃព្រះមាតារបស់យើងចុះ” ។ ពួកព្រាហ្មណ៍ទីងអមាត្យចាំងនោះក្រាបទូលថា “បពិត្រមហារាជ, ចេតនារបស់ព្រះអគ្គឥតមានបំណងថានឹងសម្លាប់សត្វទេ បើដូច្នេះនឹងឲ្យឈ្មោះថាព្រះអគ្គធ្វើអំពើចាណាតិចាតពុំបានឡើយ សូមព្រះអង្គប្រទានកុរុធម្មនោះដល់យើងចាំងឡាយចុះ” ។ ព្រះបាទធនញ្ជយកោរព្យៈត្រាស់ថា “បើដូច្នោះ ចូរអ្នកចាំងឡាយកត់ចុះ” ហើយទ្រង់ញ៉ាំងពួកព្រាហ្មណ៍ទីងអមាត្យចាំងនោះ ឲ្យសរសេរកុរុធម្មនោះភ្លាមនឹងដំបាមសថា បាណោ ង បាន្តព្វោ (គេមិនត្រូវសម្លាប់សត្វ), អទិន្នំ ន ទាតព្វំ (គេមិនត្រូវកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ), កាមេសុ មិច្ឆាចារោ ន បវត្តព្វោ (គេមិនត្រូវប្រព្រឹត្តកាមេសុមិច្ឆាចារៈ), មុសាវាទោ ន ភាសិតព្វោ (គេមិនត្រូវពោលមុសាវាទ), មជ្ជបានំ ន បាតព្វំ (គេមិនត្រូវផឹកនូវទឹកស្រវឹង)” លុះទ្រង់បង្គាប់ឲ្យកត់រួចហើយ ទើបត្រាស់បន្ថែមទៀតថា “បើទុកជាយ៉ាងនេះក៏ដោយ សីលរបស់យើងហាក់ដូចជាពុំសូវស្អាតល្អ

ពុំសូវតេញចិត្តយើងប៉ុន្មានទេ, បងអ្នកតាំងឡាយ ទៅសុំបម្ងន់កុរុធម
នោះកុងសំណាក់ព្រះមាតារបស់យើងខ្ញុំតចុះ" ។

ឮតទូតាំងនោះគ្រាបបង្គំលាព្រះរាជាហើយ ទៅកាន់សំណាក់ព្រះ
មាតានៃព្រះពោធិសត្វគ្រាបទូលថា "បពិត្រព្រះរាជទេវី, ឮថា ព្រះអង្គ
ទ្រង់រក្សាកុរុធម៌, សូមទ្រង់ព្រះមេត្តាប្រោសប្រទានកុរុធម៌នោះដល់ទូល
ព្រះបង្គំជាខ្ញុំតាំងឡាយ" ។ ព្រះរាជទេវី ទ្រង់ត្រាស់ថា "ម្នាលអ្នក
តាំងឡាយ, យើងរក្សាកុរុធម៌ពិតមែន ប៉ុន្តែឥឡូវនេះ យើងតើតសេចក្តី
រង្គៀសកុងកុរុធម៌, កុរុធម៌របស់យើងនោះហាក់ដូចជាពុំសូវហ្មត់ចត់ប៉ុន្មាន
ព្រោះហេតុនោះ យើងពុំហ៊ានឲ្យដល់អ្នកតាំងឡាយឡើយ" ។

២– រឿងព្រះមាតានៃពោធិសត្វ

តាមសេចក្តីដំណាលថា: បណ្តាព្រះរាជបុត្តតាំងពីព្រះអង្គរបស់
ព្រះរាជទេវីនោះ, ព្រះរាជបុត្តបងសោយរាជ្យជាស្តេច, ព្រះរាជបុត្តបួន
ជាឧបរាជ ។ គ្រានោះ មានព្រះរាជាមួយព្រះអង្គផ្ញើទ្វីមចន្ទន៍តម្លៃមួយ
សែនកហាបណៈ ទំនិតម្រងផ្កាមាសតម្លៃមួយសែនកហាបណៈដែរមក
ថ្វាយព្រះពោធិសត្វ។ កំយកទៅថ្វាយព្រះមាតាតាំងអស់ទៅ ។ ព្រះមាតា
នោះទ្រង់តិតថា "អាត្មាអញមិនសមទំនិលុបលាបទ្វីមចន្ទន៍ប្រជាប់តាក់
តែងដោយកម្រងផ្កាមាសនេះទេ គួរតែឲ្យទៅកូនប្រសាតាំងឡាយ" ។
ម្នុនទើបព្រះមាតាទ្រង់តិតទៀតថា "នាងកូនប្រសាបង គេបានជាធំ
តាំងនៅកងឥន្ទ:ជាអគ្គមហេសី អាត្មាអញគួរឲ្យកម្រងផ្កាមាសដល់នាង
កូនប្រសាបង, ឯនាងកូនប្រសាប្អូន មិនសូវមានបុណ្យទំលែកជាង គួរ

ឲ្យខ្ញុំមចន្ទន៍ដល់នាងកូនប្រសាបួនចុះ" លុះគិតយ៉ាងនេះហើយ ក៏ប្រទានកម្រងផ្កាមាសទៅនាងកូនប្រសាបង, ប្រទានខ្ញុំមចន្ទន៍ទៅនាងកូនប្រសាបួន ។ លុះដែលប្រទានរួចហើយ ព្រះនាងកើតសេចក្តីរន្ធត់សៅហ្មងក្នុងចិត្តថា "អាត្មាអញរក្សាកុរុធម៌ មិនសមបើទៅគិតយកទុគ្គតភាព(១)នឹងអទុគ្គតភាព(២)របស់កូនប្រសាទាំងពីរនោះមកជាប្រមាណសោះ បើធ្វើលៃលកទៅតាមផ្លូវបាបយកកម្មវិញ ទើបជាការដ៏សមគួរដល់អាត្មាអញ, កាលបើដូច្នោះសីលរបស់អាត្មាអញ ប្រហែលជាបែកធ្លាយដោយគំនិតនេះទៅហើយទេដឹង" ។ ព្រះរាជទេវីទ្រង់ដំណាលរឿងនោះថ្វាយដល់ខ្ញុំតាំងឮរាយនោះយ៉ាងនេះឯង ។ ខ្ញុំតាំងឮរាយបានស្តាប់ហើយ ក៏ក្រាបទូលថា "បពិត្រព្រះរាជទេវី, ធម្មតាទេព្យរបស់ព្រះអង្គ។ ទ្រង់នឹងអាចប្រទានដល់អ្នកណា។ បានតាមព្រះទ័យ, ទ្រង់មិនគួរធ្វើសេចក្តីរន្ធត់សៅហ្មងដោយសព្វបើហេតុប៉ុណ្ណោះទេ ព្រះអង្គនឹងឲ្យឈ្មោះថាទ្រង់ធ្វើថ្វាយកម្មដូចម្តេចបាន ឯសីលរបស់ព្រះអង្គមិនមែនបែកធ្លាយដោយសារហេតុមានសភាពដូច្នេះឡើយ, សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស ប្រទានកុរុធម៌ដល់ខ្ញុំ ព្រះបង្គំតាំងឮរាយចុះ" លុះក្រាបទូលយ៉ាងនេះហើយ ក៏សូមកត់កុរុធម្មកថាសំណាក់ព្រះរាជទេវី ដាក់កថាដំបាមាសរបស់ខ្លួន ។ ព្រះរាជទេវីទ្រង់ត្រាស់ថែមទៀតថា "បើខុកជាយ៉ាងនេះក៏ដោយ កុរុធម៌របស់យើងមិនសូវជាហ្មត់ចត់ប៉ុន្មានទេ, ព្រែកនឹតែកូនប្រសាបួនរបស់យើងទើបរក្សាកុរុធម៌នោះបរិសុទ្ធល្អ ចូរអ្នកតាំងឮរាយទៅសុំបម្រុងយកកុរុធម្មកថា

---

១ ភាពជាអ្នកទ័លក្រ ។ ២ ភាពជាអ្នកមិនទ័លក្រ ។

សំណាក់នៃកូនប្រសាច្បងនោះទៀតចុះ” ។ ពួកខ្ញុតទាំងនោះចូលទៅគាល់ព្រះអគ្គមហេសីជាកូនប្រសាច្បង ហើយទូលសុំក្បុរធម៌តាមន័យដូចមុនដែរ ។ ព្រះអគ្គមហេសីទ្រង់មានព្រះសារទីយ៍ត្បូញត្អែរថា “យើងរក្សាក្បុរធម៌ពិតមែន តែឥឡូវនេះ សីលរបស់យើងមិនសូវជាពេញចិត្តយើងប៉ុន្មានទេ ព្រោះហេតុនោះ យើងពុំអាចឲ្យដល់អ្នកទាំងឡាយបានឡើយ” ។

៣— រឿងព្រះអគ្គមហេសីនៃពោធិសត្វ

តាមសេចក្តីដំណាលថា: ថ្ងៃមួយ ព្រះអគ្គមហេសីនោះទ្រង់ឋិតនៅត្រង់សីហបញ្ជរ ទតទៅឃើញព្រះឧបាសគន់លើខ្នងដំរី ជាខាងក្រោយនៃព្រះពុទ្ធជាព្រះស្វាមីរបស់ព្រះនាង ដែលកំពុងយាងមកប្រទក្សិណព្រះនគរ លុះទតទៅឃើញហើយក៏កើតសេចក្តីសោកតិតថា “ប្រសិនបើអញធ្វើសន្ធិវិជាមួយនឹងព្រះឧបាសជាប្អូននេះ ការបំរើរណៃឥតពីស្តេចបងទៅ, ព្រះឧបាសបាននេះសោយរាជ្យឡើង ទ្រង់ទិន្នសន្តែ្លះអញទៀតពុំខាន” ។ បន្ទាប់មក ព្រះនាងកើតសេចក្តីរន្ធៀសក្នុងចិត្តថា “អញរក្សាក្បុរធម៌ទាំងមានស្វាមីផង ទៅគ្រឡែកមើលបុរសជាខៃដោយរំណាចកិលេសដូច្នេះ ស៊ីរបស់អញប្រហែលជាបែកធ្លាយទៅហើយទេដឹង” ។ ព្រះអគ្គមហេសីទ្រង់ដំណាលសេចក្តីនោះប្រាប់ខ្ញុតទាំងឡាយនោះ យ៉ាងនេះឯង ។ ខ្ញុតទាំងឡាយក្រាបបង្គំទូលថា “បពិត្រព្រះនាង ការប្រព្រឹត្តិក្បត់ មិនមែនដោយហេតុត្រាតែចិត្តកើតឡើងប៉ុណ្ណោះទេ ព្រះនាងធ្វើសេចក្តីរន្ធៀសដោយសព្វបើហេតុប៉ុណ្ណោះ ទើនឲ្យឈ្មោះថាទ្រង់

ធ្វើខ្លួនវិការប្រែប្រួលក្នុងសីលដូចម្តេចបាន, សីលរបស់ព្រះនាងមិនបែកធ្លាយដោយសារហេតុប៉ុណ្ណោះទេ, សូមទ្រង់ព្រះមេត្តាប្រោសប្រទានកុរុធម៌ដល់ខ្ញុំព្រះបង្គំផង ឬយ៉ាងណាសូមទ្រង់ត្រាស់ប្រាប់ផង" ។ ពួកខ្ញុំតាំងនោះ លុះត្រាបង្គំយ៉ាងនេះហើយ ក៏សូមកត់កុរុធម៌ក្នុងសំណាក់នៃព្រះអគ្គមហេសីជាក់ក្នុងដំបូងមាស ប៉ុន្តែព្រះអគ្គមហេសីនោះ ទ្រង់ត្រាស់ឆ្លើតថា "បើខុតជាយ៉ាងនេះក៏ដោយ សីលរបស់យើងមិនសូវបរិសុទ្ធពេញចិត្តយើងប៉ុន្មានទេ ឯព្រះបាទព្រះបាទរក្សាកុរុធម៌បរិសុទ្ធល្អ សូមអ្នកតាំងឡាយទៅសុំកត់ក្នុងសំណាក់ព្រះបាទនោះឆ្លើតចុះ" ។ ខ្ញុតតាំងឡាយនោះចូលទៅគាល់ព្រះបាទ ទូលសុំកុរុធម៌តាមន័យដូចមុន ។

៤— រឿងព្រះវិបរាជ

សេចក្តីដំណាលថា: ព្រះបាទនោះយាងទៅគាល់ព្រះរាជាក្នុងវេលាល្ងាច តែងទ្រង់យាងទៅដោយរាជរថ លុះដល់លានព្រះរាជវាំងហើយ បើមានព្រះរាជបំណងនឹងសោយព្រះក្រយាស្ងោយហើយផ្ទុកព្រះរាជដំណាក់នៃព្រះរាជានោះ ទ្រង់តែងជាក់ខ្សែបន្ទឹងជន្លួញចោលត្រង់បន្ទោះទ្វូតព្រះរាជរថ ។ ពួកមហាជនជាបរិវារដឹងដោយសញ្ញានោះហើយក៏នាំគ្នាថយចេញទៅ លុះដល់ថ្ងៃស្អែកឡើងពេលព្រឹក ទើបនាំគ្នាទៅទៀរធំចាំមើលព្រះរាជដំណើរនៃព្រះបាទនោះដែលទ្រង់ទឹង យាងចេញមកវិញ ឯនាយសារថីក៏ដូច្នោះដែរ ។ តែបើព្រះបាទមានព្រះបំណងនឹងយាងចេញមកកន្លះណៈនោះវិញ ទ្រង់ជាក់ខ្សែបន្ទឹងជន្លួញលើបន្ទោះតួរាជរថហើយ ទើបយាងចូលទៅគាល់ព្រះរាជា ។ ពួកមហាជន

ចាន់ដឹងដោយសញ្ញានោះហើយ ក៏នាំគ្នាទៅរង់ចាំគន់ព្រះពាជទ្វារដោយគិតថា ព្រះទេបពាជនឹងយាងចេញមកឥឡូវនេះវិញ ។ ថ្ងៃមួយ, ព្រះទេបពាជទ្រង់ធ្វើយ៉ាងនេះហើយ ក៏យាងចូលទៅកាន់ព្រះពាជនិវេសន៍, កន្លងវេលាដែលទ្រង់យាងចូលផុតទៅ ក្មេងក៏បង្អុរចុះមក ។ ព្រះពាជាទ្រង់យល់ថា នៅកំពុងក្មេង មិនបើកនុកាសឲ្យព្រះទេបពាជនោះចេញមកវិញ, ព្រះទេបពាជទ្រង់សោយក្រយាស្ងោយរួចហើយ ក៏ផ្ទំក្នុងព្រះពាជនិវេសន៍នោះទៅ ។ ឯពួកមហាជន ទៅឈរគ្រៀមចាំហាលក្មេងអស់មួយយប់ដោយគិតថា ព្រះទេបពាជនឹងយាងចេញមកឥឡូវនេះ ។ លុះដល់ថ្ងៃទីពីរព្រលឹមឡើង, ព្រះទេបពាជ ទ្រង់យាងចេញមក ឃើញមហាជនទៅគ្រៀមចាំទទឹកសើមដោយទឹកក្មេង ក៏តើតសេចក្តីរង្កៀសថា "នុ, អញរក្សាកុរុធម៌ធ្វើឲ្យគេបានសេចក្តីលំបាកដោយសារខ្លួនយ៉ាងនេះ សីលរបស់អញប្រហែលបែកធ្លាយទៅហើយដឹង" ។ ព្រះទេបពាជលុះដំណាលរឿងនោះប្រាប់ខ្ញុតចាំងឡាយទើបត្រាស់ថា "យើងរក្សាកុរុធម៌ពិតមែន ប៉ុន្តែឥឡូវនេះយើងមានសេចក្តីរង្កៀសចិត្តក្នុងកុរុធម៌ដោយហេតុនេះឯង យើងពុំអាចឲ្យដល់អ្នកចាំងឡាយបានឡើយ" ។ ខណៈនោះ ខ្ញុតចាំងឡាយក្រាបទូលថា "សូមទ្រង់ព្រះមេត្តាប្រោស, បើព្រះទ័យរបស់ព្រះអង្គមិនមានបំណងចង់ឲ្យគេលំបាកសោះទេ តើនឹងឲ្យឈ្មោះថាព្រះអង្គទ្រង់ប្រតិត្តល្មើសក្នុងសីលដូចម្តេចបាន", លុះក្រាបទូលដូច្នេះហើយក៏សូមកត់កុរុធម៌ក្នុងសំណាក់ព្រះទេបពាជនោះខុកក្នុងដំបាមាស ។ ព្រះទេបពាជទ្រង់ត្រាស់ថែមទៀតថា "បើខុកដាយ៉ាងនេះក៏ដោយ សីលរបស់យើង

មើលទៅមិនសូវជាពេញលេញប៉ុន្មានទេ, ចំណែកខាងបុរោហិតឯណោះ ទើបរក្សាកុរុធម៌បរិសុទ្ធល្អ ចូរអ្នកទាំងឡាយទៅកត់យកអំពីបុរោហិតនោះចុះ" ។ ពួកទូតទាំងនោះចូលទៅរកបុរោហិត សួរកុរុធម៌តាមន័យដូចមុន ។

៥— រឿងបុរោហិត

តាមសេចក្តីដំណាលថា: ថ្ងៃមួយ បុរោហិតនោះទៅគាល់ព្រះរាជាលុះទៅដល់ពាក់កណ្តាលផ្លូវ បានឃើញរថមានពណ៌ក្រហមស្រស់ដែលស្តេចមួយព្រះអង្គបានផ្ញើមកថ្វាយព្រះរាជារបស់ខ្លួននោះ ហើយសួរគេថា រថនេះជារបស់អ្នកណា? គេក៏ឆ្លើយថា រថនេះគឺព្រះរាជារបស់យើងឲ្យនាំមកថ្វាយព្រះរាជារបស់លោក ។ បុរោហិតនោះបានស្តាប់ហើយក៏គិតថា "អញចាស់, ប្រសិនបើព្រះរាជាទ្រង់ប្រទានរថនេះមកអញ។ ជិះរថនេះធ្វើដំណើរទៅមក ប្រហែលជាបានសុខស្រួលណាស់", លុះគិតយ៉ាងនេះហើយ ក៏ហួសទៅគាល់ព្រះរាជាទៅ ។ ក្នុងខណៈដែលបុរោហិតកំពុងអង្គុយគាល់, ជនទាំងឡាយនាំយករថទៅថ្វាយព្រះរាជា ។ ទ្រង់ទតឃើញក៏ត្រាស់ថា "រថនេះល្អណាស់, ចូរអ្នកទាំងឡាយឲ្យរថនេះទៅបុរោហិតជាអាចារ្យរបស់យើងចុះ" ។ បុរោហិតប្រកែកមិនព្រមទទួលយក គោះបីព្រះរាជាទ្រង់ត្រាស់ជាញឹកញាយយ៉ាងណា ក៏នៅតែមិនព្រមទទួលយក ដោយដាច់ខាត ព្រោះបុរោហិតនោះគិតយ៉ាងនេះថា "អាត្មាអញកំពុងរក្សាកុរុធម៌ តើតសេចក្តីលោភក្នុងទ្រព្យជារបស់អ្នកដទៃ, ស័លរបស់អាត្មាអញមែកធ្វើយទៅហើយទេដឹង" ។ បុរោហិតជ្រាបសេចក្តីនោះដល់ទូតទាំងឡាយយ៉ាងនេះហើយទើបនិយាយថា "ខ្ញុំមានសេចក្តីរង្គៀសក្នុង

កុរុធម៌ ។ រមស់ខ្ញុំប្រហែលជាមិនសូវហ្មត់ចត់ប៉ុន្មានទេ ព្រោះហេតុនោះ ខ្ញុំពុំអាចឲ្យដល់អ្នកចាំង ឡាយបានឡើយ" ។ ទូតចាំង ឡាយពោលនឹងបុរោហិតនោះថា "សីលរបស់លោកមិនចែកធ្លាយដោយគ្រាន់តែកើតលោភចិត្តប៉ុណ្ណោះទេ លោកមានសេចក្តីរង្កៀសដោយសព្វបើហេតុប៉ុណ្ណោះនឹងឲ្យឈ្មោះថា ប្រតិត្តកន្ទ្ងសីលដូចម្តេចបាន", លុះពោលយ៉ាងនេះហើយ ក៏សុំកត់កុរុធម៌ក្នុងសំណាក់នៃបុរោហិតនោះគុកក្នុងដំបាមាស ។ ថើគុកដាយ៉ាងនេះក៏ដោយបុរោហិតក៏នៅតែគួញផ្សែវថា "សីលរបស់ខ្ញុំមិនសូវជាហ្មត់ចត់ណាស់ណាទេ ឯរដ្ឋគ្រាហៈអមាត្យ (អមាត្យកាន់គ្រួងវាស់ដី) ទើបរក្សាកុរុធម៌ហរិសុទ្ធល្អ, ចូរអ្នកចាំង ឡាយ ទៅសុំយកកុរុធម៌ក្នុងសំណាក់នៃរដ្ឋគ្រាហៈអមាត្យនោះចុះ" ។ ពួកទូតចាំងនោះចូលទៅរករដ្ឋគ្រាហៈអមាត្យសូមកុរុធម៌តាមន័យដូចមុនដែរ ។

៦ - រឿងរដ្ឋគ្រាហៈអមាត្យ

សេចក្តីដំណាលថាថ្ងៃមួយ, រដ្ឋគ្រាហៈអមាត្យចេញទៅវាស់ដីស្រែកងជនបទ ចងខ្សែនឹងបង្គោល ឲ្យអ្នកម្ចាស់ស្រែកាន់ចុងខ្សែម្ខាង ខ្លួនឯងកាន់ចុងខ្សែម្ខាង, បង្គោលដែលចងដោយចុងខ្សែម្ខាងដែលរដ្ឋគ្រាហៈអមាត្យកាន់ចោះចុះទៅនោះ ត្រូវចំពាក់កណ្តាលរូងក្តាមមួយ ។ រដ្ឋគ្រាហៈអមាត្យគិតថា "បើអញនឹងចោះបង្គោលលើរូងក្តាមនេះ, ក្តាមដែលនៅខាងក្នុងរូងមុខជានឹងវិនាស, តែបើនឹងចោះហួសទៅខាងមុខ, ប្រយោជន៍របស់ស្តេចនឹងខូចខាត, បើនឹងចោះថយមកខាងអាយ, ប្រយោជន៍របស់អ្នកម្ចាស់ស្រែនឹងខូចខាត; កាលបើដូច្នេះ តើអញគួរលែលក

យ៉ាងណា” ។ វដ្ដគ្គាហៈអមាត្យគិតទៀតថា “បើក្តាមមានទៅកងរូងមែន មុខជាឲ្យដឹងដោយហេតុណាមួយ”, លុះគិតហើយក៏ចុះបង្គោលនោះចំទៅលើរូងក្តាម។ ក៏ធ្វើសំឡេងត្រឹង ។ វដ្ដគ្គាហៈអមាត្យលុះឮហើយក៏គិតថា បើបង្គោលនេះលិចចុះទៅលើខ្នងក្តាម។ មុខជាទន្ទឹងស្លាប់ ឯអញកំពុងរក្សាកុរុធម៌ កាលបើដូច្នេះសីលរបស់អញប្រហែលជាបែកធ្លាយហើយ” ទើបផ្ទាប់សេចក្តីនេះដល់ខូតចាំងនោះថា “ខ្ញុំមានសេចក្តីរង្កៀសក្នុងកុរុធម៌ដោយហេតុនេះឯង, ដូច្នេះខ្ញុំពុំឲ្យកុរុធម៌ដល់អ្នកចាំងឡាយទេ” ។ ខូតចាំងឡាយពោលថា “បើចិត្តរបស់លោកគ្មានបំណងនឹងឲ្យក្តាមនោះស្លាប់ទេ, អំពើដែលធ្វើដោយឥតចេតនាដូច្នេះមិនមែនឈ្មោះថាបាណាតិបាតកម្មទេ, លោកគ្រាន់តែមានសេចក្តីរង្កៀសចិត្តដោយហេតុប៉ុណ្ណេះ ទើឲ្យឈ្មោះថាប្រព្រឹត្តកន្ទុងសីលដូចម្តេចបាន” លុះពោលដូច្នេះហើយក៏សុំកត់កុរុធម៌កងសំណាក់នៃវដ្ដគ្គាហៈអមាត្យនោះទុកក្នុងដំបាមាស ។ វដ្ដគ្គាហៈអមាត្យក៏ពោលថែមទៀតថា “បើទុកជាយ៉ាងនេះក៏ដោយសីលរបស់ខ្ញុំមិនស្លាជាហត់ចត់ប៉ុន្មានទេ, ឯនាយសារថីទើបរក្សាកុរុធម៌បរិសុទ្ធល្អ, ចូរអ្នកចាំងឡាយទៅចំឡងយកកងសំណាក់នៃនាយសារថីនោះទៀតចុះ” ។ ពួកខូតចាំងនោះក៏ចូលទៅរកនាយសារថីសូមកុរុធម៌តាមទំនងដូចមុនដែរ។

(មានត)

លោក ឯន-ប៉ង់ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ចាបគឺអ្វី? កុសលគឺអ្វី? ចិត្តគឺអ្វី?

អំពើអាក្រក់ដែលកើតអំពីកាយ វាចា ចិត្ត ហៅថា ចាប ។

ធម៌ដែលជាគ្រឿងកំចាត់បង់អំពើអាក្រក់ ហើយញុំាងសេចក្តីល្អខាងផ្លូវកាយ វាចា ចិត្ត ឲ្យកើតមានឡើង ហៅថា កុសល ។

ធម្មជាតសម្រាប់សន្សំនូវអារម្មណ៍ ឬ សម្រាប់គិត ហៅថា ចិត្ត ។

ខ្ញុំសូមអធិប្បាយអំពីធម៌ទាំង ៣ នេះ ដូចតទៅនេះ ៖

តាមទំរបស់អ្នកប្រាជ្ញទាំងឡាយតាំងពីអតីតកាលរហូតមកក្នុងបច្ចុប្បន្ននេះ សឹងរួបរួមក្នុងពាក្យថា "**ចាប, កុសល, ចិត្ត**" នេះឯង; ដែលមានប្លែកគ្នាតែត្រង់តូចខ្លះសង្កេប, ខ្លះពិស្តារ, ខ្លះពាក់, ខ្លះល្អិតជ្រាលជ្រៅប៉ុណ្ណោះ; បើសង្កេបមកនៅត្រង់មិនឲ្យធ្វើចាប ឲ្យសន្សំតែបុណ្យកុសល ឲ្យមប់រំចិត្តឲ្យល្អ សមដូចគាថាក្នុងទំនុកថា:

សព្វបាបស្ស អករណំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ

"**ការមិនធ្វើចាបទាំងពួង ១ ការបំពេញកុសល ១ ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ ១ ទាំង ៣ នេះជាពុទ្ធសាសន:**" ។

អធិប្បាយ: ១– ប៉ាប គឺធម៌ដ៏លាមក ដែលជាហេតុញ៉ាំងអ្នកប្រព្រឹត្ត ឲ្យទៅកាន់អបាយ ទុគ្គតិ ហៅថា បាប ។ **បាបនោះ** បើសំដែងតាមឫសគល់បាននាំឲ្យកើត: (សេចក្តីជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ), **ទោសៈ** (សេចក្តីក្រោធចិត្តប្រទុស្តដល់សត្វទិន្ទសង្ខារ). **មោហៈ** (សេចក្តីវង្វេងភាន់ច្រឡំមិនដឹងសេចក្តីពិត) ។ ពាក្យទាំងនេះ ជាមូលហេតុគឺជាឫសគល់នៃបាប ។ **ភាហារណ៍** ដូចបុគ្គលធ្វើទូវែងពាំង ៥ គឺសម្លាប់សត្វ, លួចប្លន់ទ្រព្យគេ, ប្រព្រឹត្តខុសក្នុងកាម, និយាយកុហក, ផឹកសុរាទិន្ទមេរ័យ ក៏ព្រោះតែលោភៈទោសៈទិន្ទមោហៈ ។

បើសំដែងតាមកម្មមាន ៣ គឺកាយកម្ម (អំពើដែលកើតឡើងដោយកាយ), វចីកម្ម (អំពើដែលកើតឡើងដោយវាចា), មនោកម្ម (អំពើដែលកើតឡើងដោយចិត្ត) ។ កម្មទាំង ៣ នេះចែកជា ២ គឺជាកុសលទិន្ទអកុសល, ចំណែកកម្មជាអកុសលគឺអំពើអាក្រក់អាចឲ្យទោសក្នុងអនាគតក៏មាន, ឲ្យទោសឃើញប្បាស់ខាន់ក្នុងក្នុងជាតិនេះក៏មាន ដូចសម្លាប់មនុស្សឬសត្វតិរច្ឆាន, បើសម្លាប់យូរខែយូរឆ្នាំទៅ ក៏អាចឲ្យផលអាក្រក់ក្នុងជាតិនេះ ដូចបុរសម្នាក់ឈ្មោះបុន្ធសូករិកៈ ដែលមានជីវភាពដោយការសម្លាប់ជ្រូកលក់, សូមនាំរឿងនោះមកសំដែងដោយសេចក្តីសង្ខេប ជាសំអាងដូចតទៅនេះ ៖

សម័យមួយក្នុងនគរពជគ្រឹះ មានបុរសម្នាក់ឈ្មោះបុន្ធសូករិកៈជាអ្នកសម្លាប់ជ្រូកយកសាច់លក់ ចិញ្ចឹមជីវិតរៀងរាល ៥៥ ឆ្នាំ ។ កាលដែលសម្លាប់ម្តងៗ គាត់យកទឹកកំពុងពុះទៅចាក់បង្ហូរក្នុងមាត់ជ្រូក ។ លុះជ្រូក

នោះស្លាប់ហើយ គាត់យកដំបងដ៏ធំ ៤ ដ្រុងទៅវាយសំពងដុំសាច់ឲ្យណែន ដើម្បីចិញ្ចឹមឲ្យមានទម្ងន់លក់បានថ្លៃ ។ ដល់សម័យគាត់មានជម្ងឺ អំពើនោះកំបណ្តាលឲ្យក្តៅអំពីអវិចីមហានរកនេះឡើងមក ដុតពេលគាត់ឲ្យក្តៅអន្ទះអន្ទែងស្ទុះបម្រះនេឿលទ្រេទ្រោវរកៅមកដោយក្បាលជង្គង់ ស្រែកយំមានសំឡេងដូចជ្រូក រងទុក្ខវេទនាអស់ ៧ ថ្ងៃ ទើបស្លាប់ទៅកើតក្នុងនរកមហាអវិចី នេះមកអំពីធ្វើអំពើអាក្រក់ ។

២ - កុសល បានដល់ធម៌ជាគ្រឿងកំចាត់បង់សេចក្តីអាក្រក់, ការពារយាមធ្វើសេចក្តីល្អនោះឲ្យកើតមានឡើង ហៅថា បំពេញកុសលឲ្យបរិបូណ៌ ។ បើសំដែងដោយសង្ខេប កុសលនោះមានលក្ខណៈប្លែកពីគ្នាចំឡែកឡើង មាន ៣ គឺ ទាំង: ការបរិច្ចាគវត្ថុឲ្យដល់បុគ្គលដទៃដែលគួរឲ្យ ១, សីល: ការរក្សាកាយវាចាឲ្យរៀបរយ ១, ភាវនា ការចំរើនឬទឹកចំពោះគ្រឿងអារម្មណ៍ដ៏ល្អ១ ។

បើនិយាយដោយពិស្តារបានដល់ បុញ្ញកិរិយាវត្ថុ ១០ យ៉ាង គឺ ១ - បុណ្យកើតមានព្រោះការឲ្យទាន, ២ - ព្រោះការរក្សាសីល, ៣ - ព្រោះការចំរើនធម៌ដែលគួរចំរើនឲ្យកើតមានក្នុងចិត្ត, ៤ - ព្រោះការគោរពកោតក្រែងនូនលំទោន ដើម្បីស្តាប់បុគ្គលដែលគួរគោរព, ៥ - ព្រោះការខ្នះខ្នែងខ្ជាប់ខ្ជួយចាត់កិច្ចការបុណ្យ ឬ បំពេញការធ្វើបុណ្យ, ៦ - ព្រោះការសំដែង ឬពន្យល់ធម៌ឲ្យគេស្តាប់ ឬបង្រៀនឲ្យគេបានចេះដឹងធម៌ផង, ៧ - ព្រោះការស្តាប់ធម៌ដោយគោរព, ៨ - ព្រោះការឲ្យចំណែកបុណ្យគេជូន ឬនិស្សចំណែកបុណ្យដែលខ្លួនបានហើយ ឲ្យទៅអ្នក

ដល់ខ្ញុំ, ៩- ព្រោះការត្រេកអរនឹងលះបង់ចំណែកបុណ្យដែលគេឲ្យមកខ្ញុំ, ១០- ព្រោះការធ្វើសេចក្តីយល់ឃើញរបស់ខ្លួនឲ្យត្រូវត្រង់តាមផ្លូវពិត គឺធ្វើប្រាជ្ញាជាសម្មាទិដ្ឋិឲ្យកើតមានក្នុងសន្តាន ។

កុសលនេះ អាចឲ្យសម្រេចនូវលទ្ធផលដ៏ល្អក្នុងបច្ចុប្បន្ននេះក៏មាន, ក្នុងអនាគតក៏មាន ដូចទេវធម្មិកាម្នាក់ឈ្មោះឧដ្ឋភ ជាន់ជាអាចារ្យធំក្នុងព្រះពុទ្ធសាសនារបស់ព្រះបាទពិម្ពិសារ សូមនាំរឿងនោះមកសំដែងដោយសង្ខេបជាឧទាហរណ៍ដូចតទៅនេះ ៖

ក្នុងកាលដ៏កន្លងទៅហើយ មានព្រះពុទ្ធជាម្ចាស់ព្រះអង្គធំព្រះនាមព្រហ្មទត្ត សោយព្រះជន្មក្នុងនគរពារាណសី, មានព្រះបច្ចេកពុទ្ធជាច្រើនអង្គនៅក្នុងនគរនោះ, ក្នុងចំណោមព្រះបច្ចេកពុទ្ធទាំងនោះមានព្រះបច្ចេកពុទ្ធមួយព្រះអង្គព្រះនាមបិដ្ឋគម (ខ្នងគម) ។

ថ្ងៃមួយ គេទម្លាប់ព្រះបច្ចេកពុទ្ធទាំងនោះ ឲ្យតង់ក្នុងព្រះពុទ្ធដំណាក់, មុនដំបូងគេដាក់ឆ្នាយសម្រាប់ ។ ជាត្រូវ ហើយប្រគេនផ្ការីព្រះហស្តឥតមានវត្ថុអ្វីជាទីទាប់សោះ ។ ដោយឆ្នាយស្តៅ ។ ពេញជាត្រូវពេក ព្រះបច្ចេកពុទ្ធទាំងនោះក៏ប្រែចិត្តវិលជាត្រឡប់ ។, ស្ត្រីម្នាក់ជាអ្នកបំរើព្រះបច្ចេកពុទ្ធទាំងនោះបានឃើញដូច្នោះ ក៏ប្រគេនរង្វេលក្នុង ៨ របស់ខ្លួនចំពោះព្រះបច្ចេកពុទ្ធទាំងនោះ ឲ្យលោកដាក់ជាត្រលើរង្វេលនោះ ហើយកាន់ទឹមន្តនៅឯក្បែរកន្ទុនទូលូ ។ លុះនាងវិលមកវិញ, ដោយផលនៃកុសលគឺការប្រគេនរង្វេលក្នុងឲ្យជាទីទាប់ជាត្រដល់ព្រះបច្ចេកពុទ្ធ

ពាំងនោះ បណ្តាលឲ្យនាងបានទៅកើតក្នុងក្រុមនៃព្រះនាងសាមាវតី(១) ជាធីតានៃយោសកសេដ្ឋី ជាអគ្គមហេសីនៃព្រះបាទឧទេនក្នុងនគរកោសម្ពី ។ គ្រាន់តែបានស្តាប់ធម្មទេសនានៃព្រះសាស្តាប៉ុណ្ណោះ នាងក៏បានសម្រេចសោតាបត្តិផលព្រមពាំងបដិសម្ភិទា ចេះចាំព្រះត្រៃបិដកពាំងមូល ហើយបានជាអាចារ្យសំដែងធម៌ឲ្យពួកស្ត្រីក្នុងព្រះរាជពាំងស្តាប់ជាឯតទគ្គៈខាងពហុស្សុតៃ, នេះជាគុណនៃកុសលធម៌ដែលសំដែងមកហើយខាងដើមនេះឯង ។

៣ - បិត្តិ គឺធម្មជាតដែលតិតន្ទូរអារម្មណ៍ផ្សេងៗ; ការដែលធ្វើចិត្តរបស់ខ្លួនឲ្យល្អបរិសុទ្ធដោយសព្វគ្រប់ ដកចង់ចាំបានសម្រេចមគ្គផលមានអរហត្តជាទីបំផុត ហៅថា ការធ្វើចិត្តឲ្យផូរផង់ ។ ចិត្តជាធម្មជាតដ៏ល្អិតមិនមានរូបកាយសណ្ឋានទ្រង់ទ្រាយពណ៌យ៉ាងណាទេ គ្រាន់តែជានាមម្យ៉ាង ។ ចិត្តជារបស់ប្រែប្រួលយ្រូងយ្រោងរហ័សណាស់ ដូនគាលជាយ៉ាងនោះ ដូនគាលជាយ៉ាងនេះ ។ ព្រោះហេតុនោះបានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា បិត្តំ ភិក្ខវេ អទន្តំ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានទូន្មាន មិនបានត្រប់ត្រង់ជាដើម រមែងប្រព្រឹត្តទៅដើម្បីវិនាសយ៉ាងធំ បិត្តំ ភិក្ខវេ ទន្តំ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះ បើបុគ្គលបានទូន្មានបានត្រប់ត្រង់ជាដើម តែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ធំ ។

---

(១) នាងសាមាវតីនេះ បិតារបស់នាងគឺភទ្ទវតិយសេដ្ឋី នៅក្នុងភទ្ទវតិយនគរ, រីឯស្រុកកើតអហិឆត្តភោគ បិតាមាតានឹងនាងរត់ចេញពីនគរនោះមកស៊ីឈ្នាក់នូវទីដិតផ្ទះយោសកសេដ្ឋី ។ លុះបិតាមាតាធ្វើមរណកាលហើយ យោសកសេដ្ឋីក៏យកនាងទៅចិញ្ចឹម ទុកដូចធីតាបង្កើតរបស់ខ្លួន ។

ទុក្ខនិងសុខដែលកើតឡើងក៏ព្រោះចិត្តដែរ, បុគ្គលធ្វើកិច្ចការអ្វី ៗ ដោយកាយក្តី ដោយវាចាក្តី ក៏ព្រោះចិត្តរិះគិតធ្វើមុនឡើងជាមុនទើបធ្វើបាន, កាលបើចិត្តរិះគិតត្រូវហើយ កិច្ចការនោះក៏បានលទ្ធផលល្អ ថែមទាំងមានសេចក្តីចំរើនដល់ខ្លួនផង, បើចិត្តរិះគិតខុសហើយ កិច្ចការនោះក៏មិនសម្រេចលទ្ធផលល្អ ថែមទាំងមានសេចក្តីទុក្ខដល់ខ្លួនផង ។ ចិត្តនេះជាធម្មជាតដឹកនាំលោកគឺសត្វឲ្យប្រព្រឹត្តអាក្រក់ ឬឲ្យប្រព្រឹត្តល្អបាន សមដូចសុភាសិតថា:

បិត្តេន នីយតិ លោកោ បិត្តេន បរិកស្សតិ
បិត្តស្ស ឯកធម្មស្ស សព្ពេ វសមន្វគូ

សេចក្តីថា: "សត្វលោកគឺចិត្តដឹកនាំទៅបាន ចិត្តចុះញ្ជូសត្វលោកទៅបាន លោកទាំងអស់ទៅកន្លែងណាបានដោយធម៌ ១ គឺចិត្ត" ។

ព្រោះហេតុនោះ បណ្ឌិតជនគប្បីធ្វើចិត្តឲ្យមានសមាធិ គឺបង្ខាំងចិត្តឲ្យនឹងនឹងកុំឲ្យស្ទុះទៅតាមអារម្មណ៍ដ៏អាក្រក់ ឲ្យយើញថាសង្ខារទាំងពួងសុទ្ធតែមិនទៀង ជាទុក្ខជាអនត្តា ឲ្យកើតសេចក្តីខ្នើយណាយចាកសេចក្តីសៅហ្មង, ដ្បិតថាចិត្តនេះមិនមែននឹងនឹងឯងបានទេ លុះតែទំពត់ខ្ជួនានវិបនឹងនឹងបាន ។ សមដូចពុទ្ធភាសិតថា:

សុទុទ្ទសំ សុនិបុណំ យត្ថកាមនិបាតិនំ
បិត្តំ រក្ខេថ មេធាវី បិត្តំ គុត្តំ សុខាវហំ

សេចក្តីថា: "មេដាវដែនតួរខំបីចាប់ក្បាច់ត្តិ ដែលយើញចាន់ដោយ
តម្រែ ដែលល្អិតពន់ពេក ដែលលង់ទៅកន្លែងអារម្មណ៍ឯណាមួយហើយ
មិនងាយនឹងតាញឲ្យដាកចេញមកវិញបាន, ចិត្តដែលអ្នកមានប្រាជ្ញ
បានថែរក្សាហើយ តែងនាំសុខមកឲ្យ" ។

កម្មគឺអំពើល្អនឹងអាក្រក់គ្រប់យ៉ាង ដែលធ្វើញសត្វឲ្យបានសុគតិ
នឹងទុគ្គតិក៏ដោយសារចិត្ត, ព្រោះចិត្តជាធំក្នុងរូបកាយតាំងអស់ ដូចជា
ព្រះចាទអសោកមហាពជទ្រង់ធ្វើបុណ្យកុសលច្រើនជាអនេក គ្មានអ្នក
ណាធ្វើប្រហែលនឹងព្រះអង្គទេ គ្រាន់តែខ្វិចព្រះទ័យបន្តិចក៏នាំឲ្យទៅកើត
ក្នុងទុគ្គតិ, សូមនាំយកវឿនេាះមកសំដែងដោយសេចក្តីសង្ខេបដូច
តទៅនេះ ៖

សម័យមួយនេាះក្នុងក្រុងជាតលិបុត្រ គឺប្រទេសឥណ្ឌាសព្វថ្ងៃនេះ
មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមវិន្ទុសារ មានអំណាចគ្របដណ្តប់
លើទ្វីបតូច · ធំ ជាច្រើន ទ្រង់មានព្រះរាជនុរសច្រើនព្រះអង្គ តែ
ទ្រង់សព្វព្រះទ័យនឹងព្រះរាជនុរសមួយព្រះអង្គ ទ្រង់ព្រះនាមអសោក:
ដែលមានសេចក្តីអន់អាចជាងព្រះរាជនុរសឯទៀត ក៏ទ្រង់តាំងដំណែង
ជាឲ្យជាឧបរាជ, ដំបូងទ្រង់ឲ្យទៅគ្រប់គ្រងក្រុងតក្ខសិលា តែខាង
ក្រោយមកទ្រង់ឲ្យទៅគ្រប់គ្រងស្រុកមាលវៈ ។ គ្រាកាលព្រះរាជ-
បិតាទ្រង់ទិវង្គតហើយ ព្រះអសោកជារាជនុរសក៏បានជាស្តេចសោយរាជ្យ
ស្នងព្រះអង្គទៀត ក្នុងពុទ្ធសករាជ ២៧៤ ឆ្នាំ គឺ ៤ ឆ្នាំខាងក្រោយព្រះចាទ
វិន្ទុសារទិវង្គត ។ ព្រះចាទអសោកនេាះ តាំងពីបានសោយរាជ្យទៀត

កាលណាខ្ញុំធ្វើសង្គ្រាមជាច្រើនដង ផ្សាយអំណាចតេជានុភាពរបស់ព្រះអង្គចេញទៅ ព្រះអង្គជាស្តេចមានបុណ្យធំបំផុតក្រៃលែងជាងស្តេចឯទៀត ។ ខ្ញុំផ្សាយអំណាចចេញទៅគ្រប់ប្រទេសក្នុងឥណ្ឌាទាំងមូលរហូតដល់ទន្លេគាជារី ។

ព្រះបាទអសោកៈ មិនគ្រាន់តែផ្សាយអាណាចក្រទៅលើអាណាខ្លែត្បុ៉ណ្ណោះទេ ថែមទាំងបានផ្សាយព្រះពុទ្ធសាសនាដោយសេចក្តីជ្រះថ្លា ដែលជាកិត្តិគុណដល់ខ្លួនអាស៊ីទាំងមូលទៀតផង ។

ក្នុងគម្ពីរមហាវង្ស សំដែងថា ព្រះបាទអសោក កាលដែលព្រះអង្គបានពាជាភិសេកជាស្តេចក្នុងក្រុងបាតលិបុត្រហើយ ខ្ញុំមានឫទ្ធានុភាពផ្សាយទៅលើមួយយោជន៍, ទៅក្រោមមួយយោជន៍ មានពួកទេវតា, នាគ, យក្ស, មនុស្ស, សត្វចតុប្បាទនឹងខ្លួចាទចូលគាល់បំរើខ្ញុំជានិច្ច ខ្ញុំបានសោយរាជ្យ ជាស្តេចចក្រពត្តិសម្បូណ៌សេចក្តីសុខ ដោយពាជបរិស័ទទាំងអស់ទំនុកបំរុងមិនឱ្យត្អូញត្អែរព្រះហឫទ័យ ។

ព្រះបាទអសោកនោះខ្ញុំបានបរិច្ចាគនិច្ចកត្តជល់ព្រះតិក្ខុសង្ឃទាំងឡាយ ខ្ញុំបរិច្ចាគព្រះពាជខ្ទម ៨៦ កោដិសាងព្រះវិហារ ៨៤.០០០, ខ្ញុំបានអញ្ជើញកាឡនាគពាជឲ្យទិម្មិតខ្លួនធ្វើជាព្រះពុទ្ធឡើង មានរូបកាយដូចជាព្រះពុទ្ធសុទ្ធសាធ ហើយខ្ញុំឧទ្ទិសឆ្ពោះទៅព្រះពុទ្ធនិម្មិតនោះមិនប៉ះប៉ិចព្រះនេត្រ ហាក់ដូចជានឹងដកព្រះនេត្រពីព្រះអង្គទៅដាក់ឯព្រះពុទ្ធនិម្មិតនោះ ដោយខ្ញុំមិនសោយព្រះក្រយាស្នាយរហូត

ដល់ ៧ ថ្ងៃ, មិនតែប៉ុណ្ណោះ ទ្រង់មានព្រះពាជសទ្ធាបានបំពេញកុសល
ក្នុងព្រះពុទ្ធសាសនាដោយកិច្ចឯទៀតច្រើនជាអនេក ។

ព្រះបាទអសោកនោះទ្រង់មានព្រះពាជសទ្ធា ទោះបីទ្រង់ធ្វើព្រះ
ពាជកុសលជាច្រើន ក៏ទ្រង់មិនស្កប់ព្រះហឫទ័យសោះ, កាលទៀបទ្រង់
ព្រះទិវង្គត ទ្រង់បង្គាប់ឲ្យពួកសេវកាមាត្យយកព្រះពាជទ្រព្យទៅប្រគេន
ព្រះសង្ឃឯវត្តកុក្កដារាម ។ ពួកពាជសេវកាមាត្យមិនព្រមប្រគេនតាម
ព្រះពាជហឫទ័យ, ព្រះពាជាក៏ទ្រង់ព្រះកន្សែងស្រក់ទឹកព្រះនេត្រជោក
ព្រះភក្ត្រ ទ្រង់ព្រះពិរោធជាពន្លឺក, កំពុងតែព្រះពិរោធដូច្នោះក៏ទ្រង់
ព្រះទិវង្គតទៅភើតកង់ទុគ្គតិភព សមគួរតាមយថាកម្ម ។ ទាំងនេះក៏
ព្រោះចិត្តក្រោធទំងសេវកាមាត្យ ។

សេចក្តីដែលសំដែងមកនេះ សឲ្យឃើញថា ការមិនធ្វើបាប បាន
សុខ, ការធ្វើបាបបានទុក្ខ ការដំកល់ចិត្តឲ្យទន់ធន់បានសុខ, ការដំកល់
ចិត្តឲ្យសបានទុក្ខ, សេចក្តីសុខទំងទុក្ខរមែងជាប់តាមបុគ្គលអ្នកប្រព្រឹត្ត
សមដូចបុរាណសុភាសិតថា

វិបុណ្យទំងបាប អំពើសុភាព ទោះកើតទំងតាម
បីដូចស្រមោល អនុលាមតាមច្បាណ ពុំដែលចៀសបាន
ទំងក្តីទុក្ខសុខ ។

អក្សរសាស្ត្រខ្មែរសង្ខេប

លោក រ៉ាយ-ប៊ុក ក្រមការជើមខ្សែរៀបរៀង

(តមក)

៥— រឿងល្ខោនខ្មែរ.— ល្ខោនខ្មែរមានបួនបែប:

ក) ល្ខោនព្រះរាជទ្រព្យច្រើនខំយកយកសិល្បៈបុរាណ មកជាមូលដ្ឋាន, - សូម្បីតែគ្រឿងប្រដាប់តំជាលំនាំបុរាណ; ឯរឿងគេច្រើនយករឿងបុរាណមកលេងដែរ ដូចជារឿងវេស្សន្តរ, ខ្សែស័ង្ខ, ព្រះលក្ស្មណាវង្ស, រឿងអោរ ។ល។ ;

ខ) ល្ខោនចាស័កស្ទើកពាក់រវៀបចំនួនហើយច្រៀងលាយខ្មែរ-ចិន។

គ) ល្ខោនសាម័ញ្ញ ស្ទើកពាក់បែបសាម័ញ្ញប្លែកតាមប្រពៃណីជាតិនីមួយ។, ច្រើនលេងរឿងសាម័ញ្ញ;

ឃ) ល្ខោនជាតិ ជាល្ខោនពួកកូនសិស្ស ន៏ដ៏ទិស្សតសាលា, ច្រើនលេងរឿងសម័យ មានស្ងាប់ព្រោះជាតិជាដើម ។

ក្នុងរឿងល្ខោននេះមានរបាំ ១ ភ្លេង ១ បម្រៀង ១ ។

៦— រឿងប្រលោមលោក.— រឿងនេះ មានច្រើនបែប ។ មានរឿងខ្លះ គេយករឿងក្នុងសៀវភៅចាក់ដំមកបកនាជារឿងខ្មែរក៏មាន យករឿងបុរាណខ្មែរ ឬរឿងប្រឌិតឡើងទៅតាមសម័យនិយមក៏មាន ។

រឿងប្រលោមលោកខ្មែរបើតាមសាតខ្លួនៅ, ច្រើនរៀងណាស់, ដូចគាលជាពាក្យកាព្យ, ដូចគាលជាពាក្យកាយ ។ រឿងនោះជាអក្សរសាស្ត្រផង ជាអារ្យធម៌ផង ជារឿងប្រពៃណីចំនៀមមកម្ចាប់ខ្មែរផង ។ មានរឿងប្រលោមលោកខាងការដើរទេសប្តូរផ្សង់ត្រង ។ ដោយអំណាចនៃស្នេហាយកទៅបញ្ចូលក្នុងក្របខ័ណ្ឌប្រវត្តិសាស្ត្រ ឬរឿងព្រងដែលដកស្រង់យកពីរឿងភមាយណៈខ្លះ, ជាតកខ្លះ ។

ប៉ុន្តែទុកជារឿងប្រលោមលោកនោះ គេតុបតែងឡើងឲ្យមានសេចក្តីថ្លែកអស្ចារ្យយ៉ាងណាក៏ដោយ ក៏គង់ភ្ជាប់ក្នុងគន្ធនៃកម្មគឺការប្រព្រឹត្តកុសលឬអកុសលជាតិអតីតជាតិ ដែលអាចឲ្យផលល្អឬអាក្រក់ក្នុងបច្ចុប្បន្នជាតិ; ការប្រព្រឹត្តបុណ្យជាបច្ចុប្បន្នជាតិ នឹងឲ្យផលល្អឬអាក្រក់ក្នុងអនាគតជាតិជាមិនខាន ។ ក្នុងរឿងនេះ, មានតែកម្មមួយទេជាខ្សែបន្ទាត់ ។ រឿងវែងៗអស់អាចនឹងមានមក ឬត្រូវតែមានខានមិនបាន, ព្រោះដីវភាពតាមអតីតជាតិបានកំណត់ទុកជាស្រេចដូចពាក្យបុរាណខ្មែរពោលថា: "ផ្លែកម្មខុំហើយ" ។ ក្នុងចំណោមនៃការតយុទ្ធ, ការចាប់យកព្រះអង្គម្ចាស់ក្សត្រី, មហន្តរាយ, យុទ្ធោបករណ៍ដែលប្រតិស្ថានដោយមន្តអាគម, ការចម្បាំង, ការធ្វើសង្គ្រាមណិជាន, ការស្វែងរកព្រះនាងដែលយកៗចាប់ទៅ, ព្រះអង្គម្ចាស់ស្តេចទៅសិក្សារៀនសូត្រឯខូមតាបសឬស៊ី, . . ។ល។ . . ច្រើនមានអកម្មភាពឬការខ្ជិលទៅតាមផលកម្មដែលមានរួញរា ដែលជាហេតុឲ្យរឿងនោះមានលំនាំគួរឲ្យចង់អាន តែសរុបរឿងនោះមកបានន័យថា: "ស្ត្រីឲ្យទុក្ខ

ទោសច្រើនច្រកាដល់បុរស" ។ ស្តេចខ្លះបានមកជាកំយោហើយ, មានយក្សចាប់យកទៅ ។ ស្វាមីខំដើរស្វែងរកក្នុងព្រៃផ្សៃ ទៅដួបពួលយក្សច្បាំងជាច្រើនលើក-គ្រា ជាហេតុឲ្យលំបាកវេទនាជាខ្លាំង ។ សញ្ញាណអរូបី នៃការបែងចែកធាតុ, ចំពោះរឿងប្រលោមលោកប្រកបដោយមនោសញ្ចេតនា, មានសភាវៈអស្ចារ្យ ហើយធ្វើឲ្យសេចក្តីស្នេហានោះឆ្ងាក់ទៅក្នុងអន្ទង់ផ្សៃនៃពាក្យកំសៃ... ផ្សៃនៃក្រលែង ។ ពាក្យកំសៃនេះជាមូលដ្ឋាននៃនិទាន ហើយជាហេតុឲ្យរឿងនោះឧប្បត្តិឡើងដោយជាក់ស្តែង ។

រឿងប្រលោមលោកខ្មែរបុរាណគឺ ស្ទាត់ជាសៈឥណ្ឌៀលាយចម្រុះនឹងរស្មីពុទ្ធសាសនាត្រមាំងប្រពៃណីទំនៀមទម្លាប់ ។ ក្នុងចំណោមរឿងនេះ មានរឿងវេស្សន្តរ សុវណ្ណ, ព្រះលក្ខណវង្ស, ឧត្តរសិទ្ធ, នោរ, ព្រះចន្ទគោរពភាជ, ព្រះរេនាវង្ស, សុខពេក, ព្រាហ្មណ៍កេសរ, លិខថោង, . . . ។ ល ។

រឿងប្រលោមលោកដែលគេតែងក្នុងសម័យបច្ចុប្បន្ននេះច្រើនតែផ្ទុះរឿងមានប្រកពផ្សេង ។ គ្នា ខ្លះយកពីប្រវត្តិសាស្ត្រចិន, ខ្លះដកស្រង់ពីប្រវត្តិសាស្ត្រឥណ្ឌៀ, ពង្សាវតារខ្មែរ, ខ្លះដកស្រង់ពីសៀវភៅជាតិអើរ៉ូបប្លុសៀវភៅសៀម ។ ល ។

ពិ— រឿងព្រេង .— រឿងព្រេងបើពិនិត្យទៅតាមផ្ទៃនៃរឿងឬតាមជីវភាព ជារឿងមានតម្លៃពន់ពេកត្រមាំងធ្វើឲ្យមនុស្សត្រេកចិត្តអានតាំងពីអ្នកជាន់ខ្ពស់រហូតដល់អ្នកជាន់ទាប ។ រឿងព្រេងបានឲ្យ

ខ័យចំពោះនិមិត្តរូបនឹងមនោសញ្ចេតនា ដែលមនុស្សជាតិទាំងអស់បាន
ឃើញគ្រប់ៗគ្នា ដោយប្រើនូវមេធ្យោបាយតាមធម្មតា ។

រឿងព្រៃឥណ្ឌាខ្លះយើង, មានរឿងព្រៃខ្លះបានដកស្រង់យកពីរឿង
ព្រៃឥណ្ឌា, ព្រះពុទ្ធសាសនា, ប្រវត្តិណាំនៀមទម្ងាប់, ប្រវត្តិ
សាស្ត្រខ្មែរសម័យបុរាណ, ព្រហ្មញ្ញសាសនា . . . . ល . . . . ។
រឿងព្រៃនោះមានពណ៌នាអំពីអ្នកក្សេត្រតវៃខ្លះ, ជីវភាពរស់នៅ,
ការរស់នៅក្នុងវត្តអារាម, ការដែលព្រះសង្ឃឱ្យទាន, អាកប្បកិរិយា
នៃប្តីប្រពៃ, កិច្ចការរបស់ភរិយា, កិច្ចការរបស់ប្តី, ដំនៀងផ្សេងៗ, ការប្រែស័ព្ទ
ទំនងអារក្ស, អ្នកតា, បិសាច, អមនុស្ស ទេវតា, ការគាន់ខន្តី
ចំពោះសេចក្តីទុក្ខលំបាកគ្រប់យ៉ាង, ការធ្វើចិត្តល្អឬអាក្រក់ចំពោះអ្នក
ដទៃ, ការមិនយល់នូវលក្ខណៈមនុស្សប្តូចរិយាបុគ្គលត្រឹមបំណងទឹង
ចោកជ្រាសខ្លួន, ការទទួលផលកម្មទឹងលាភសក្ការៈជារឿងថ្មីក ។ ។
នៅក្នុងរឿងព្រៃតែងតែមានចៅក្រមព្រះមហាក្សត្រិយ៍, ព្រះរាជិនី, ហោរា,
មេធ្មប់, ឋេអាឋ, គ្រូមន្តអាគម, មេមត់, តារាសាស្ត្របណ្ឌិត, ប្រជាពលស្ត្រ
ភូមិស្រុក, នគរ, ជនបទ ។ ក្រៅពីនេះ, មានការពាក់ព័ន្ធរុក្ខជាត ។
នៅក្រមខ័ណ្ឌនៃរឿងព្រៃ គេច្រើនពណ៌នាអំពីខ្លួម, គេហដ្ឋានមាន
ជណ្តើរឡើង, មានចោរពួនទៅក្រោមជណ្តើរនោះ ឬ ស្វាមីលបចាំ
ស្តាប់ប្រពន្ធមានសហាយស្នន, គេបានឃើញក្នុងគេហដ្ឋាន, មានពាន
ពេញទៅដោយទឹកត្រី ហើយពាន់នោះធំល្មមឱ្យស្ត្រីដែលមានសហាយ
ស្នន យកសហាយនោះទៅដាក់លាក់បំពួនក្នុងពាន់បាន ។ មាន

អ្នកនេសាទយកសំណាញ់ទៅបង់ត្រី, តំឡង់ច្រាំពីរសន្ធាន, តាចាស់ធ្វើចុបកូនប្រសាទ្យទៅក្លែវស្រែ, តាចាស់ចាន់ទន្យាយមួយយក អង្រែតគ្រប, អាទំពែកចាំងបួន, អាចាស់ស្គុតជាប់នៅលើចុងត្នោតជាដើម ។

ក្នុងដែនសាសនា, មិនមានពណ៌នាអំពីលទ្ធិប្រជាមិអ្វីឡើយ គ្រាន់តែមានអ្នកបួងសួងដល់ព្រះពុទ្ធ ឬទេវតា ។ ព្រះឥន្ទ្រាធិរាជតែងបើកទិព្វចក្ខុឥតមកស្ថានមនុស្សលោក, មានការកម្រើកដល់អាសនាព្រះឥន្ទ្រាធិរាជ, ដូនតាលព្រះអង្គចុះមកជួយស្រោចស្រង់បុគ្គលណា ដែលមានបុណ្យហើយតំពុងដេកក្តុលច្បាក, ស្ត្រីទំលែកតែមានចរិយាសម្គាល់ថាជាបញ្ញវន្តកល្យាណ តែងទៅជាស្ត្រី អ្នកមានគោគ្រឿង ស្តុកស្តម្ភបាន ។

ដីវិកាពនៅវត្តអាចារ្យបានបញ្ជាក់ឲ្យយើងយើញថា ព្រះតិក្ខុសង្ឃជាអ្នកទស្សាហ៍រៀនសូត្រព្រះវិន័យបិដក, ពិតមែនតែមានព្រះតិក្ខុសង្ឃខ្លះមានគេរិះគន់ តំតង់យល់បានថាព្រះសង្ឃជាទីគោរពនៃជនទាំងឡាយទាំងបុរសស្ត្រី, ពិធីបុណ្យនៃព្រះពុទ្ធសាសនាមានគ្រប់បែបគ្រប់យ៉ាង, អារក្សអ្នកតាបញ្ជោញឲ្យយើញរូបកាត ស្ថិតនៅតាមភ្នំមនៅក់លវស្រែស្ត្រីចិត្តមិនត្រង់នឹងស្វាមីបានទៅបន់អ្នកតា ឲ្យធ្វើស្វាមីខ្លួនឲ្យអនិច្ចកម្មទៅខ្លួនឯងថ្វាយជ្រកវិញមួយ ។ អ្នកតាខ្លះធ្វើក្អែកឡាក់ឲ្យទៅជាភ្លើ ដូចជាមានរឿងក្មេងកំសត់ម្នាក់ដែលសហជីវិនខ្លួនធ្វើបាប ។ អារក្សទេវតាបម្រុងជាក់ខ្លាំងមកអ្នកណាតាប់លំពឹងក្សជាតិ ដែលជាវិមានរបស់លោក,

ក្នុងរឿងចាំងអស់នោះ, គេសង្កេតឃើញព្រះពុទ្ធសាសនា, ព្រហ្មញ្ញ-សាសនា, លទ្ធិកូតថសាច ជាន់លាយច្របូកច្របល់គ្នា ។

បើមានការដណ្តឹងប្រពន្ធឬរៀបការអាពាហ៍ពិពាហ៍ បុរសដែលចង់ជាន់ប្រពន្ធត្រូវមកនៅគេហដ្ឋានបិតាមាតាក្មេក ដើម្បីនឹងឲ្យគាត់ពិសោធកូនប្រសាមើល ។ រីឯហង្គលការនីមួយ ។ ត្រូវមានហោរាកំណត់ថ្ងៃពិធី, ទើបធ្វើជាមានការចង់ដៃជាអំពោះពិសិដ្ឋដើម្បីដំឃមង្គលសិរីសួស្តី ព្រមទាំងការណីយកិច្ចពាល់ថ្ងៃ ដែលការិយាត្រូវធ្វើចំពោះស្វាមី ។ ពិធីបុណ្យបូជាសព មានតាណិនាខៅក្នុងថ្ងៃរឿងនោះដែរដូចជាពិធីឈាបនកិច្ច ។

ពួកមេធ្មប់, មេអាបសុទ្ធតែមានមន្តអាគមសូត្រ ព្រមទាំងមានកូនកន្សែងយ័ន្តមានរូបផ្សែង ។ ។ មានមេធ្មប់ខ្លះដឹងថាមានគង្គាពិសិដ្ឋមួយបែបដែលតាំពែកទាំងបួនត្រូវដែមុជក្បាលគាត់ខៅក្នុងនោះដើម្បីឲ្យសក់ដុះឡើងវិញ ។ តែមេធ្មប់នេះច្រើនមានមុខការខាងខាយខៅអនាគតខាយគូព្រែង, គ្រែះថ្នាក់ផ្សែង ។ ; កិច្ចការក្នុងគ្រួសារ គឺការបរិភោគអាហារ, ការអេស៊ីយទឹក, ជក់ថ្នាំ, ចោសសំអាតគេហដ្ឋានក៏មានពាណិនាខ្លះដែរ, មានអ្នកស្រែខ្លះជាអ្នកគ្រាញកញ្ជើ, ខ្លះជាជាងធ្វើខង្គិល, ខ្លះជាអ្នកនេសាទ, ខ្លះចាំចាបកុំឲ្យស៊ីស្រូវគុំ, ខ្លះដេញចាប៉ីឬបន់ទេវតាឬបរទេះគោ ។ បើរឿងព្រៃនោះមានជនជាតិចិន, ច្បាកជាមានគ្រឿងនៃពាណិជ្ជចិនមិនខាន ។ បើមានផ្លា គឺផ្លាជាអ្នកចិញ្ចឹមមាន់ជល់ឬអ្នកស្រមាញ់ ។

សេនាបតី, នាយគាហាន, ព្រះពជសេវកាមាត្យ, សុទ្ធតែមុខ-ស្ទឹតស្ទាំងជាអ្នកមិនសូវមានគំនិតទេ ។ ពួកមន្ត្រីនេះជាក្អែកបៃស់ស្តេច, តែងយកសេចក្តីក្រាបបង្គំទូលព្រះអង្គន្ទូវដំណឹងផ្សេង ។ ព្រោះមហាក្សត្រិយ៍, ដូនកាល ទ្រង់ជាប់ចិត្តមកាត់ក្តី ចំពោះក្តីណាដែលចៅក្រមសម្រេចមិនទាន់ជាប់ស្រេច ។ ទ្រង់ប្រកបដោយព្រះប្រាជ្ញាដ៏ជ្រាលជ្រៅអាចរកឃើញចំណោទក្បិទមុខ, ប្រវត្តិដែលលាក់កំបាំងដោយចោរ មនុស្សពាលខ្លួចតែលួច, រឿងលែងតែប្រាជ្ញាធនញ័យទើបប្រកបញ្ជោតព្រះអង្គបាន ។ ការកើតក្តីនឹងសត្វព្រមទាំងរបស់តំមានខ្លះដែរ ដូចជាក្នុងរឿងចៅគាំបិតបង្ខោះ រឿងក្តីអំពីដណ្តើរដែលគេអូសយកមកជាកស្តុតាងហើយគេយកដណ្តើរនោះទៅដាក់ឃ្នាង, ក្អែកដែលតាំងជំបុតត្រែ ហើរទៅទំលើជំបូលផ្ទះនេះផ្ទះគេ, មេមាន់ទៅប្តឹងខ្លាថាសត្វស្លាស៊ីកូនមាន់ . . . ល . . . ។

មានបុគ្គលិកលក្សណៈជាច្រើនបែប ដែលមានទៅក្នុងរឿងព្រៃឯតំ ព្រះមហាពជ, ពជនី, ចៅក្រែ, ព្រះសង្ឃ, ចៅហ្វាយខែត្រ, ភរិយាត្រូវពិនិត្យទៅតាមលក្ខណៈថាខាងជាភរិយាគុតិតបុរស ឬភរិយាសេដ្ឋី, កុដុម្ពីក៍, គហបតិ៍, ឬភរិយាទាហ៊ីនជំ-ភូច, អ្នកសហាយស្នង, ចោរ, ត្រូវធ្វើឬត្រូវគាយតាមហោរាសាស្ត្រ, ត្រូវគាយតាមតារាសាស្ត្រ, អ្នកក្រ, ខឹងអ្នកមាន, បងប្អូនប្រុសកំព្រាពីនោក់, តាបស់, ប្រជាកស្តេនៅក្នុងភូមិ, ញាតិសន្តានត្រង់ណាន . . . ល . . . ។ ក្នុងបុគ្គលនីមួយៗមានលក្ខណៈប្រុ, លក្ខណៈសម្បត្តិ, គុណវិឆ្ឆិ, គុណវិបត្តិតាមប្រភេទ

ផ្សេង ។ ; ដូចគាលបុគ្គលម្នាក់ មានគុណសម្បត្តិនឹងគុណវិបត្តិចម្រុះគ្នា តែកងចរិយាមួយ ។

បុគ្គលជាអមនុស្ស គឺមិនមែនត្រាន់តែមានត្រឹមតែទេវបុត្រ, ទេវតា, នាងទេវធីតា, ព្រះឥន្ទ, ព្រះព្រហ្ម, យក្ខ គន្ធព្វ, នាគ, ប្រព្រឹត្តអាទិទេតដែលជាប្រពៃណីនៃប្រទេសតំណែ ជាន់ក្រងពុកមកជាគ្រឹមតិក ស្រាប់តែខោះទេ, ថែមទាំងមានអ្នកតា, អារក្ស, កូត, បិសាច ផង ,,.ល. .។ មានអ្នកតាខ្លះមានសត្វជាអ្នកបម្រើជាប្រក្រតីផង ដូចជាត្រពើកក្នុងរឿងអាសុក្រស្វគអាសុក្រកាច ។ ក្រៅពីនេះមៅមានរឿងខ្មោច ដូចជារឿងគ្រូប៉ន់ទឹងខាងខ្ញី នាងកញ្ញាខ្មោច ដែលជាន់ស្វាមីទៅកាន់គ្រួសារឯស្រុកខ្មោច ទឹងរឿងខាងយុវតីប្រកបដោយរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ លាក់បំពួនខ្លួនទៅកងស្មែង ឬ កងកុយស្ពេចរមាស ឬកងក្អកស្ពេចហត្ថី កងរឿងបងប្អូនប្រុសពាន់ទឹងមានប្រមាញ់ ។ ឯលក្ខណៈមាន់ប្រមាញ់នោះ មាន់ពិសិដ្ឋប្លែកពីធម្មតា ព្រោះបាកាលណាមាន់នោះរងាវប៉ដង ឃ្លាកដជាស្លេះទៅកងព្រះពជអាណាចក្រទាំងមូល សូម្បីតែព្រះអគ្គមហេសីក៏មិនអាចស្ងិតនៅទឹងខ្លួនបាន ត្រូវតែដើរខានមិនបាន តម្រង់មកកាន់ទីដែលមាន់ពិសិដ្ឋនោះរងាវ ដោយសំឡេងមាន់នោះ មានអានុភាពអស្ចារ្យណាស់ ប្រៀបដូចជាមេដែកដែលទាញដែកទាំងអស់ ឲ្យចូលមកជិតខ្លួនដូច្នោះ ។ កងរឿងសង្ខសិល្បជ័យ ឬ ខ្សែសង្ខ, សង្ខតូចនឹងសង្ខ ដែលជាមគ្គុទ្ទេសក៍ព្រះបាទសង្ខសិល្បជ័យក៏មានសភាពប្លែកពីធម្មតាដែរ ។

ចំណែកខាងសត្វតិរច្ឆាន, ត្រូវតែពិនិត្យឲ្យជាក់លាក់ ។ សត្វតិរច្ឆានខ្លះមានឧិយមព្រះពុទ្ធសាសនា ឬ ព្រហ្មញ្ញសាសនា ហើយសត្វនេះជាបឋមបុនសាច់ញាតិនឹងមនុស្សជិតស្និទ្ធ ដូចជាកង្កើងរឿងចៅក្តាំងចាយដែលក្តែងនឹងឆ្នា ដែលទៅអរសោនបទ ទៅជាតែងតាំងជាសេនាបតីវិញ ។ សត្វទាំងនោះមានមនោ អធ្យាស្រ័យគួរឲ្យចង់ពិនិត្យដូចរឿងណ្ឌសត្វ នៃទ្យាហ្វុងតែនចាក់ដំដូច្នោះ ។

រឿងជាតកបានបញ្ចេញប្រាជ្ញាដ៏ផ្សាលផ្សៅ ។ រឿងព្រៃងធម្មតាបានបង្ហាញនូវទំនៀមនៃធម្មជាតិខ្មែរ ទំនៀមធម្មជាតិមនុស្សទាំងអស់ហើយមានលក្ខណៈសត្វតិរច្ឆានខ្លះ ដែលបញ្ជាក់ឲ្យយើងឃើញថាមានបុគ្គលអ្នកចេះវិទ្យាពិនិត្យកិរិយា, ចរិតអធ្យាស្រ័យរបស់សត្វ; មានរឿងព្រៃងខ្លះបានពណ៌នាអំពីភាពភាពដែលមានវង់ងសត្វនោះ ទំនៀមអ្នកស្រុកខ្មែរ ។ តំនិតអធ្យាស្រ័យរបស់សត្វនោះ មិនមែនអ្នកណាចេះតែយល់បាននោះទេ លុះត្រាតែអ្នកនោះប្រកបដោយប្រាជ្ញាដ៏មោះមុតទើបបានស្គាល់តំនិតអធ្យាស្រ័យសត្វនោះបាន ។ គេអាចយល់បានថា ក្នុងរឿងទាំងអម្បាលម៉ានសេចក្តីជិតស្និទ្ធតែងមានវង់ងមនុស្សទ្រង់សត្វតិរច្ឆាន ព្រោះថាមនុស្សទ្រង់សត្វតិរច្ឆានមានសភាពមិនខុសគ្នាគឺ កើត, ស្លាប់, កើតទៀត, ដូចគ្នា ចំណែកឯចរិតនិស្ស័យដូចជាសត្វខន្យាយជាបឋម, ក្អែ, ឆ្នា, ខ្លាត្រី, ដំរី, អណ្តើក, ក្រពើជាលំដាប់ត ។ មកសុទ្ធតែមានខុស ។ គ្នា ។

នេះជាលំនាំផ្សេង ។ នៃរឿងព្រៃងនោះ ។ មានរឿងព្រៃងខ្លះជាសេចក្តីរិះគន់ចំពោះសង្គម, ជាលក្ខណសត្វ, ឬជាអច្ឆរិយភាពបង្ហាញ

ខ្លួនបុគ្គលិកលក្ខណៈផ្ទែកពីជម្មតា, ហើយបានយកវត្ថុជាតុនៃអក្សរសាស្ត្រនិទានសាកល ឬជាវត្ថុជាតុប្រជាមានិតជាមូលដ្ឋាននៃរឿងនោះ ។

បើគេចង់ញែករឿងព្រៃងនោះ តាមក្រមមានជាច្រើនយ៉ាងគឺ:

១ - រឿងព្រៃងគុណាការ ដូចសេចក្តីដកស្រង់នៃសាស្ត្រាគឺងកម្ពុជ្ជ ដែលមានសេចក្តីប្រៃទៅប្រទេសកូមា, លាវនឹងសៀម, ឬដូចរឿងសកាទន្យាយ;

២ - រឿងព្រៃងមហាសាគតិ ដូចជារឿងទំពែកទាំងបួនដែលដើរស្វែងរកភរិយា ឬទឹកអម្រឹតធ្វើឲ្យជុះសេកវិញបាន, រឿងធនញ្ជ័យជារឿងកំផ្លែងសើច ដែលមានរឿងដូចគ្នាតែខាមខុសគ្នា, រឿងសាងមៀងទៅប្រទេសថៃ ទំនងរឿងឆ្នងថៃទៅប្រទេសលាវ;

៣ - រឿងព្រៃងដែលស្វែងរកបុព្វហេតុ ឬពន្យល់អំពីបុព្វហេតុផ្សេងៗ ដូចជារឿងដើមកំណើតសត្វទា, សត្វមូស, ឬរឿងមិត្តសំឡាញ់ពីរនាក់ដែលចង់ចាប់ទឹកសមុទ្រឲ្យរីង;

៤ - រឿងព្រៃងប្រកបដោយអច្ឆរិយភាព ដូចជារឿងនាងកាកីដែលពណ៌នាអំពីព្រះអង្គម្ចាស់ក្សត្រី ដែលគ្មានបានយកទៅ ឬរឿងអាធុងអាសាញ់ ឬរឿងកង្កែបយំសុំភ្លៀង, រឿងនាងកែវមនោភ, រឿងព្រះពុទ្ធសេនទឹងនាងកងរី, រឿងពជកុលទឹងនាងរំសាយសក់, រឿងនាងសក់ក្រអូបថា . . . . . ;

៥ - រឿងព្រៃងអ្នកស្រែចម្ការ ដូចជារឿងតាចាស់យាយចាស់ដែលទៅបរបាញ់ . . . . . ;

៦ - រឿងព្រៃឆ្កបដោយប្រាជ្ញា ដូចជារឿងទន្សាយនឹងខ្លែង ដែលទន្សាយចាញ់ប្រាជ្ញាខ្លែង, រឿងកុកចង់ចោកក្តាមស៊ីស្ងាប់ខ្លួនឯង, រឿងអាឥសិអាខូច, រឿងតន់ហាន . . . . ល . . . ។

៧ - រឿងព្រៃឆ្កួនគ្រែសារ ដូចជារឿងអាពុកក្មេកធ្វើចាបកូនប្រសា, រឿងកូនប្រសាចោកអាពុកក្មេក . . . . ល . . . ។

ក្រៅពីនេះនៅមានរឿងជាច្រើនទៀតច្រើនជាអនេកប្បការ ។

(មានត)

អក្សរសាស្ត្រខ្មែរ ជាជីវិតរបស់ខ្មែរ

អក្សរសាស្ត្រខ្មែរ នាំជាតិខ្មែរឲ្យថ្កុំថ្កែ
ឲ្យខ្ពើងថ្កានពេកលៃ ឲ្យស៊ីវិល្យនៅកន្លែង!

បាប-ពិន.

លោក សុីន-ហាន ប្រៃរៀបរៀង

លោក យូរ-អ៊ុន ពិនិត្យកែសម្រួល

(តមក)

ខណៈនេះ សុរពលហត់ជិតដាច់ឫស្យល់ ទ្រែតខ្លួនទៅដល់ទីធំលំពែង ១ ដែលសិស្សប្រោះមកឲ្យ ទើបតុនចុះចាប់លំពែងនោះភ្លាម ដោយមានសេចក្តីសង្ឃឹមក្នុងខ្លួន ។ គោគាចសុះចូលមកប៉ងទីធំដល់សុរពលទៀត លុះដិតដល់ពក៏ឆ្អៀងក្បាលដល់សុរពស ។ ថយក្រោយ ២-៣ ជំហាន ល្មមបានការហើយ ក៏ពួយលំពែងទៅត្រូវភ្លៅមុខរបស់ព្រ គ្រាន់តែសុរពលគាញក្រឡាត់លំពែងចេញមក គោក៏ដួលស្រុបទៅ សូម្បីរបួសទៅភ្លៅរបស់ព្រមិនដាំខ្លាំងប៉ុន្មាន ក៏ពុសក្តាំងលែងមានឫទ្ធិតទៅទៀត ។ សិស្សរបស់សុរពលក៏ស្រែកហោរឡើងដោយសេចក្តីត្រេកអរខ្លាំង ដែលឃើញអាចារ្យរបស់ខ្លួនមិនមានអន្តរាយ ។ នាងកាញ្ចនាដែលអង្គុយយំនៅជិតអមាត្យនឹង មិនហ៊ានបែរមុខមើលទៅបង្ក្រុសដែលកំពុងតស៊ូគ្នាឆ្លងទេ លុះបានឮសម្លេងសិស្សហោនាងក៏បែរមើលទៅ ។ ខណៈនោះ សុរពលងងឹតមុខ ទើបថ្កាច់ឲ្យសិស្សជួយទប់ខ្លួន កាញ្ចនាប្រញាប់ចុះពីផ្ទះរត់ទៅរកបង្ក្រុស ។ ឯយាយព្រាហ្មណីក៏អៀនខ្មាស ហើយដឹងខ្លួនថាដែលរួចផុតមកបាន ក៏ព្រោះសុរពលជួយ តែវិស័យពាលរបស់យាយព្រាហ្មណីនៅមិនទាន់អស់

ក្រែងខ្ញុំដឹងប្តូចដឹងអាឃាតនឹងគាត់ដោយប្រការណា ក៏កើតសេចក្តីថ្មែកក្នុងចិត្តទឹកអៀនខ្មាសក្រៃពេក ។ សុរពលយើញយាយព្រាហ្មណីឈប់គំទឹកស្មានថា ប្រហែលយាយនេះមិនហ៊ានទៅ ទើបថ្កាប់ថា:

- "យាយចង់ត្រឡប់ទៅផ្ទះវិញ ក៏ត្រឡប់ទៅចុះ កុំភ្លាចអ្វីគោនោះអស់ធើបរួចហើយ" ។

យាយព្រាហ្មណីទ្រហោយំ ដោយទឹកភ្លូចចិត្តនឹងខ្លួនឯង ដែលធ្វើអាក្រក់ជ្រុលទៅលើសុរពល ដែលជាមនុស្សល្អ មិនចេះក្រោធតបវិញ ត្រមាំងបានជួយខ្លួនឲ្យរួចពាក់សេចក្តីអន្តរាយជីវិតទៀតផង យំហើយនិយាយអង្វរសុំទោសសុរពលថា:

- "លោកទៅសូមលើកទោសឲ្យយាយផងចុះ លោកទៅបានជួយជីវិតមនុស្សអាក្រក់ ដូចយ៉ាងយាយដែលធ្លាប់ដេរលោកទៅ ។ ទឹងធ្វើទោសយាយដូចម្តេចក៏ចេះតែបាន តែសូមលោកទៅលើកទោសឲ្យយាយផងចុះ" ។

នាងកាញ្ចនាឃើញហើយអាណិតយាយព្រាហ្មណីពន់ពេក ទើបចូលទៅរកគាត់ហើយថ្កាប់ថា:

- "យាយកុំភ្លូចចិត្តឡើយ បងខ្ញុំនឹងមនុស្សក្នុងផ្ទះខ្ញុំគ្មានអ្នកណាខឹងនឹងយាយទេ តទៅបើយាយមានទុក្ខធុរៈអ្វីកើតឡើង សូមយាយមករកខ្ញុំចុះ បើខ្ញុំនឹងបងខ្ញុំអាចជួយយាយបានក៏នឹងជួយយាយ មនុស្សយើងដែលធ្លាប់ជាមិត្តសន្ទនឹងគ្នាបាន ក៏ដោយចេះជួយគ្នាកង្គែរកើតទុក្ខក្តៅ-

ក្រហាយ, ល្អហើយដែលយាយដឹងខ្លួនថាខ្លួនប្រព្រឹត្តខុសនេះ សូមយាយត្រឡប់ទៅផ្ទះចុះ" ។

យាយព្រាហ្មណី កាលស្តាប់ពាក្យនាងកាញ្ចនាក៏តែតែតូចចិត្តខ្លួនឯងខ្លាំងឡើង ទើបក្រាបសំពះពោលសរសើរគុណសុរពលទឹងនាងកាញ្ចនាហើយក៏លាត្រឡប់ទៅផ្ទះ ។

ខណៈដែលមនុស្សកំពុងចោមមើលយាយព្រាហ្មណ៍នោះ មានបុរសម្នាក់ដើរសេះមកដល់ កាលឃើញមនុស្សកំពុងចោមរោមមើលយាយនោះ គេក៏ចុះចាកខ្នងសេះមែបចូលមកមើល កាលឃាន់ឃើញហេតុការណ៍ប្លែកដូច្នោះ ក៏សាកសួរមនុស្សដែលនៅកន្លែងនោះអំពីរឿងរ៉ាវដែលកើតឡើង កំពុងដឹងសេចក្តីសព្វគ្រប់ គេក៏ទឹកប្លែកក្នុងចិត្តជាខ្លាំងទឹងមនុស្សដែលជាអ្នកប្រកបដោយគុណធម៌ខ្ពង់ខ្ពស់ ហើយមកនៅក្រៅភូមិ មានដំរែតស់នៅកន្លែងចំណោមមនុស្សដែលឃ្លាតឆ្ងាយពីសេចក្តីចំរើន តែត្រឡប់តាំងខ្លួនឲ្យមានអ្នកពាប់អាន ហើយប្រៀនប្រដៅអ្នកពាប់អានឲ្យតាំងខ្លួនទៅកន្លែងសេចក្តីល្អ សេចក្តីចំរើន ។ បុរសដើរសេះគាលទឹកអស្ចារ្យយ៉ាងនេះហើយ ក៏ចង់ស្គាល់ឈ្មោះគេ ទើបដឹកសេះទៅចង់ទុក ហើយដើរចូលទៅរកសុរពល ខណៈនោះយាយព្រាហ្មណីបានត្រឡប់ទៅហើយ សុរពលកំពុងឈរសម្រាកឲ្យបាត់ហត់ឲ្យបាត់អស់កម្លាំង អំពីការតស៊ូទឹងគោអម្បាញ់មិញ ។

សុវោលឃើញមនុស្សប្លែកមុខស្គាយយាម ដើរតែងចូលមកកន្លែងផ្ទះខ្លួនក៏ឆ្ងល់ក្នុងចិត្ត ទើបលើកដៃឡើងធ្វើសេចក្តីគោរព ចាំងនាងកាញ្ចនាក៏លើកដៃសំពះបុរសនោះដែរ ។

បុរសនោះ ប្រញាប់លើកដៃតំនាប់សុវោលនឹងនាងកាញ្ចនាវិញ ហើយពោលថា:

– "សូមជំពាក់លោក ខ្ញុំបាទជាអ្នកដើរផ្លូវឆ្ងាយបានមកឃើញលោកអម្បាញ់មិញនេះ ហើយដឹងច្បាស់នូវគុណធម៌របស់លោកអំពីអ្នកដែលនៅឈរជុំវិញ ទើបខ្ញុំចង់ស្គាល់ឈ្មោះលោក មួយទៀតខ្ញុំបាទសូមឈប់សម្រាកនៅទីនេះ១ស្រេបក់សិន តើលោកអាចប្រាប់ឈ្មោះនឹងអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកបានឬទេ? " ។ អាការគោរពរបស់បុរសនេះធ្វើឲ្យសុវោលនឹកសង្ស័យ សុវោលបានប្រាប់ឲ្យពួកសិស្សត្រឡប់ទៅផ្ទះរៀងៗខ្លួន ហើយអញ្ជើញបុរសនោះឲ្យឡើងលើផ្ទះ:

–"អញ្ជើញលោកឡើងទៅសម្រាកលើផ្ទះតាមសប្បាយចុះ ខ្ញុំនឹងប្រាប់ឈ្មោះខ្ញុំដល់លោកបាន តែចាំខ្ញុំទៅចង់គោនោះសិន ព្រោះវាមិនទាន់ស្ងាប់ ក្រែងវាក្រោកឡើងដល់មនុស្សម្នាទៅដិតខាងទៀត" ។

នាងកាញ្ចនាបាននាំបុរសនោះឡើងទៅលើផ្ទះ ហើយយកទឹកតែខឹងស្ងោចារមកជូនភ្ញៀវពិសា ។ បុរសនោះឡើងទៅអង្គុយលើផ្ទះ ឃើញលោកអមាត្យនៃកំពុងអង្គុយ គេសង្កេតកិរិយាលោកក៏ដឹងថា ជាអ្នកល្អមានបុគ្គាម្យទម្ម្យ ទើបកើតសេចក្តីសង្ស័យ ខាំឲ្យតែចង់ដឹងនូវករប្រព្រឹត្តរបស់គ្រួសារនេះ គេសំពះលោកអមាត្យនៃហើយជំពាក់ថា:

"ខ្ញុំបាទចេញពីក្រុងតាពណាស៊ីមកអស់រយៈពេលច្រើនខែហើយ តាលតែឡប់ដើរមកតាមផ្លូវនេះ បានឃើញបុត្តរបស់លោកមានមនុស្សព្រមព្រៀងច្រើន ទើបខ្ញុំចង់ស្គាល់គ្រួសាររបស់លោក: សូមលោកមេត្តាទាំងខ្លួនកូនរបស់លោកមកឲ្យខ្ញុំស្គាល់ផង" ។

អមាត្យនម្ចិ បានស្តាប់ពាក្យរបស់បុរសនោះហើយ ក៏តបថា: "ខ្លួនខ្ញុំនេះឯងឈ្មោះនន្ទិ, បុត្តប្រុសដែលនៅខាងក្រោមឈ្មោះសុរតស, នាងនេះជាកូនស្រីរបស់ខ្ញុំឈ្មោះគោញ្ញា ចុះអ្នកឯងឈ្មោះអ្វី ម្តេចមិនប្រាប់ឲ្យខ្ញុំស្គាល់ឈ្មោះផង លោកម្ចាស់ជាដើរផ្លូវមកឆ្ងាយណាស់ ទើបមើលទៅសម្បុរសាច់ឈាមត្រូវកំដៅថ្ងៃខ្មៅត្រឡែងអស់ ខ្លួនឯងជាអស់កម្លាំងណាស់ហើយ" ! ។

"ត្រូវហើយ ខ្ញុំដើរផ្លូវមកឆ្ងាយណាស់ ចេញចាកក្រុងវេសាលីជាឯកទៀ តាំងពីទៅតាំងមក ខ្ញុំបានឈ្មោះថាលិត ជាអមាត្យរបស់ព្រះរាជានគរពាពណាសី ខ្ញុំបានត្រែកអរណាស់ ដែលលោកប្រាប់ឈ្មោះឲ្យស្គាល់ ខ្ញុំបានចង់ស្គាល់លោកអស់រយៈពេលច្រើនខែមកហើយ ព្រោះខ្ញុំបានឮនាមនឹងកិត្តិគុណរបស់លោកអំពីបុរសម្នាក់ ហើយបុរសនោះបានតាមរកលោកដោយលំបាក តែមិនបានជួបនឹងលោកសោះ" ។

អមាត្យនន្ទិកិតក័យស្ទើរសន្លប់ ព្រោះលោកមិនចង់ឲ្យអ្នកណាស្គាល់លោកថាជាអមាត្យ ដែលព្រះរាជានៃនគរពាពគ្រីងច្រង់ព្រះរាជឫទ្ធិឲ្យធ្វើខណ្ឌកម្មមកហើយដូច្នេះទេ លុះបានឮថាអមាត្យចាលិតស្គាល់លោក

អំពីបុរសម្នាក់ ដែលតាមរកលោកដោយសេចក្តីលំបាកគំនឹកចង់ដឹងថា នរណាជាអ្នកតាមរក ទើបសួរថា :

- "នរណាដែលថាស្គាល់ខ្ញុំ ហើយតាមរកខ្ញុំ សូមលោកជ្រាបឈ្មោះឲ្យខ្ញុំដឹងផង" ។

- "ឈ្មោះបុត្តិស័ត្យ, លោកគង់ស្គាល់ច្បាស់ហើយ ខ្ញុំបាននៅជួបនឹងបុត្តិស័ត្យនោះក្នុងនគរវៃសាលី នៅខណៈដែលគេតែងអាកេខ្មៅឯកក្នុងនគរនោះ គេជាមនុស្សល្អណាស់ មានសេចក្តីករុណាដល់សត្វដែលព្រះពជាន់ធ្វើការបូជាយ័ញ្ញ ហើយបានទូលទាស់ព្រះពជាមិនឲ្យធ្វើការបូជាយ័ញ្ញដោយការុណកម្មដ៏អាក្រក់, គេហ៊ានយកជីវិតទៅទូលអាសាដល់ពួកអ្នកស្រុក" ។ (មានត)

ប្រយោជន៍នៃការឧស្សាហ៍អាន

អ្នកណាសង្វាតហាត់មើលអាន
ខ្លួរឿងបុរាណល្អសោភា
ប្តូរឿងទំនើបផងនានា
អ្នកនោះមុខជាដឹងរឿងច្រើន !

បាប-ពិន

កណ្ឌទី ៤៦

ឧកញ៉ាវិបុលរាជសេនា ន្ង-កន ប្រៃរៀបរៀង

(ត្រមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវៀងវៃឆ្លាសបើបានអាន
ធឹងបេះឧបាយកលបំណាន
ទាំងមានសង្គ្រាមស្នេហាជាតិ ។

ខណៈនោះគ្រែពេទ្យហ៊ូតាមិនទៅ ព្រោះមានកិច្ចវល់ចូលទៅមើលជម្ងឺឯស្រុកក្រុង, បានតែសិស្សហ៊ូតាម្នាក់មក ពេទ្យនោះមើលហើយក៏ជំរាបស៊ុនសេកថា ឯរបួសដោយដួងនោះខ្ញុំបានមើលឲ្យជាជាប់បាន តែរបួសដោយធ្នោះព្រួញមុតដល់ឆ្អឹង ហើយព្រួញនោះមានជាក់ថ្នាំពិសផង បើនឹងរក្សាសូមអញ្ជើញលោកទៅរកទីស្ងាត់ទៅ កុំឲ្យមនុស្សចូលទៅមកអ៊ូអរ ហើយឲ្យលោករំលត់សេចក្តីក្រែធខឹងឲ្យអស់ផង លុះត្រាចំណាត់ ១០០ ថ្ងៃទើបជាជាប់ស្រួល ; ប៉ើរំងាប់កំហឹងមិនបានទេថ្នាំពិសក៏តែតែកំរើកខ្លាំងឡើង ។ ស៊ុនសេកក៏ធ្វើតាម ខណៈនោះពេទ្យរក្សាបានប្រហែល ២០ ថ្ងៃ ស៊ុនសេកនោះជាមនុស្សចិត្តហ៊ានធ្វើអ្វីចង់ឲ្យបានតាមចិត្តក្លាម ។

ខណៈពេលនោះ មានបំរើខ្ញុំវៃហ្នឹងម្នាក់ដែលទៅនៅស្រុកក្រុងហ៊ូតោនោះឲ្យចូលមកដាក់បង្ហាញសេចក្តី លុះស៊ុនសើកដឹងហើយក៏ឲ្យហៅអ្នកបំរើនោះចូលទៅហើយសួរថា: ខ្ញុំវៃហ្នឹងប្រែអ្នកមកដោយហេតុដូចម្តេច? អ្នកបំរើជ្រាបថា ខ្ញុំវៃហ្នឹងប្រើខ្ញុំចាឲ្យមកដាក់បង្ហាញលោកថា: ខ្ញុំវៃហ្នឹងដែលបានទៅនៅក្នុងស្រុកក្រុងនោះ បានឃើញចូឆូនឹងម៉ីប្រឹក្សាព្រមទាំងសេនាបាហានទាំងពួងនោះ បើនឹងនិយាយគ្នាពីកិច្ចការពាក់ព័ន្ធអ្វីក៏មានសេចក្តីកោតញញើតថ្វីដៃលោកជាច្រើនដងហ្ន៎ តែកុយកែនោះបើនឹងពោលនិយាយពីកិច្ចការអ្វីក៏ឥតគិតខ្លាចក្រែងលោកសោះ ។ ស៊ុនសើកសួរថា ចុះដែលកុយកែមើលងាយយើងនោះបាននិយាយថាម្តេចខ្លះ? អ្នកបំរើនោះទៅស្ងៀមមិនឆ្លើយ ស៊ុនសើកឃើញអ្នកបំរើនោះនៅស្ងៀមដូច្នោះក៏ខឹងណាស់ថា: ខ្ញុំវៃហ្នឹងប្រើឲ្យមកឲ្យជ្រាបដំណឹងយើង ។ សួរអ្វីទៅក៏នៅស្ងៀមដូច្នេះ ។ ឯអ្នកបំរើនោះឃើញស៊ុនសើកខឹងខ្លាំងក៏ខឹកខ្លាច ទើបឆ្លើយថា: កុយកែបាននិយាយនឹងចូឆូថា: ហេតុម្តេចបានជាខ្លាចស៊ុនសើក ឯស៊ុនសើកនោះជាមនុស្សគ្មានជ្រាជ្រាសោះ បានតែចិត្តរហ័ស ទោះនឹងគិតការអ្វីក៏រមែងមើលងាយប្រមាថ គិតសង្ឃឹតតែអួតបេះហើយតំកើងខ្លួនធ្វើធំ យូរទៅគង់តែនឹងស្លាប់ដោយថ្វីដៃកូនចាហាន ។

ឯស៊ុនសើកបានស្តាប់ដូច្នោះ ក៏ដើរតែតែក្រោធខឹងខ្លាំងពន់ប្រមាណណាស់ទៅទៀត និយាយថា "កុយកែនោះវាមានសតិជ្រាជ្រាយ៉ាងណាខ្លះ ទើបបានអាចហានិយាយមើលងាយប្រមាថយើងជាពាក្យអាក្រក់ដូច្នេះ ចាំយើងនឹងលើកទ័ពទៅវាយយកស្រុកហ៊ូតោឲ្យបាល់តែ

ជាន ហើយនឹងចាប់យកទាំងខ្លួនកុយតែសម្លាប់ចោលចេញ រួចឲ្យ
ជញ្ជាំសាច់ឲ្យស្អិតខ្លួចកុំឲ្យក្អែកចឹកស៊ីជាន" និយាយហើយក៏ឲ្យហៅ
ទ័ពក្បាទាំងពួងមកប្រឹក្សាការថា "កុយតែនិយាយមើយនាំយប្រមាថ
យើងដូច្នេះ ត្រូវតែយើងបង្ខំដុំដុះសេនាគហានឲ្យជានព្រមទុកជាស្រេចរួច
យើងនឹងលើកកងទ័ពទៅវាយយកស្រុកហ្វីតា ចាប់យកទាំងកុយតែទៅ
សម្លាប់ចោលចេញឲ្យជានទើបជាត់ចិត្ត" ។ ទៀតបើវាថា: កាលពីថ្ងៃមុន
ត្រូវឲ្យជានមកថែរក្សារបួសព្រួញនោះ ក៏ជានហាមជ្រាមលោកថាកុំ
ឲ្យមានសេចក្តីក្រែងចិត្តលុះត្រាប់ ១០០ ថ្ងៃ តែឥឡូវនេះទើបនឹងជានតែ ២០ ថ្ងៃ
ប៉ុណ្ណោះ ហើយលោកមានគោរសាបំរុងនឹងលើកកងទ័ពទៅច្បាំងប្រណាំង
នឹងភាក្យកុយតែនោះឃើញថាមិនគួរទេ ។

ខណៈនោះទេពួលមានបំណើរសេរម្នាក់មកដំរាបស៊ុនសេីកថា តែឥឡូវ
គាន់ជិនគាហានអ៊ូនសៀវមានការចង់ចូលមកគាលោក ។ ស៊ុនសេីកក៏
ឲ្យហៅខ្លួនចូលទៅ គាន់ជិនគំនាប់ហើយក៏ហុចសំបុត្រទៅឲ្យស៊ុនសេីក។
ទេពួលយកសំបុត្រអ៊ូនសៀវទៅមើលឃើញសេចក្តីថា: ចូចូជាសត្រូវពេជ-
សម្បត្តិ សូមឲ្យស៊ុនសេីកតាំងចិត្តជាមួយនឹងយើងលើកកងទ័ពទៅវាយ
ចូប់ស្រុកហ្វីតាតីទិសខាងត្បូង ។ យើងនឹងលើកចូលទៅពីទិសខាងជើង
នឹងកំចាត់ចូចូចេញ ។ ស៊ុនសេីកឃើញច្បាស់ក្នុងសំបុត្រដូច្នោះក៏មាន
អំណរណាស់ ទើបឲ្យរៀតុះលៀងគោជនាហារ អញ្ជើញតាន់ជិនឲ្យ
បរិភោគជាមួយនឹងសេនាគហានតាំងពួងលើសើន ។

ខណៈកាលកៀរកំពុងសេពសុរាខោះ ស៊ុនសេកឃើញគាហានតាំងពួនដែលកំពុងបរិភោគនោះនិយាយខ្សឹបគ្នា ហើយយកដៃចង្អុលចុះពីលើសើនគ្រមគ្នា ។ ស៊ុនសេកមានសេចក្តីសង្ស័យក៏សួរអ្នកបំរើថា ហេតុម្តេចបានជានាម៉ឺននឹងគាហានតាំងពួននិយាយខ្សឹបគ្នា ហើយចង្អុលចុះលើគ្រែសើនដូច្នោះ? ។ អ្នកបំរើដំណាងថា: អ៊ីកៀតដែលជាអ្នកស្រុកតាំងអស់គ្នាធ្លាប់និយមរាប់អានថា ជាមនុស្សមានសេចក្តីចេះដឹងស័ក្តិសិទ្ធិនោះ ឥឡូវដើរមកតាមផ្លូវពីទិសខាងត្បូងចូលឈប់ត្រង់គ្រែសើនគាហានតាំងពួនឃើញហើយក៏មានសេចក្តីត្រេកអរ ទើបបបួលគ្នាចុះលើគំនាប់ ។ ស៊ុនសេកបានស្តាប់ដូច្នោះក៏អើតមើលទៅតាមបង្អួចសើនឃើញមីកៀតតែង៦ខ្លួនតាក់អាវសម្បុរសដូចខៅតា ដៃកាន់ឈើច្រត់ដើរទៅតាមផ្លូវ អ្នកស្រុកតាំងពួនបបួលគ្នាគាន់ផ្តាក្តីនឹងខៀនឆ្លុបចូលទៅគំនាប់ដោយគោរពដល់អ៊ីកៀត ស៊ុនសេកឮដំណាស់ដេរអ៊ីកៀតថាក់ធ្វើដូច្នេះជាការកុហកបញ្ឆោតឲ្យគេដឿ ហើយក៏បង្គាប់ឲ្យគាហានដេញចាប់ខ្លួនអ៊ីកៀតយកទៅសម្លាប់ ។

គាហានតាំងពួនដំណាងថា: អ៊ីកៀតនេះខៅគ្រែស្រុកមកពីទិសឯកើត ធ្លាប់យកទឹកមន្តមកឲ្យអ្នកស្រុកដែលមានជម្ងឺឈឺថ្កាត់ បើធឹកស្រោចឆ្លងទៅគាលណា ហើយក៏ជាសះស្បើយពេតជារឿយ ។ ហើយអ្នកស្រុកនិយមរាប់អានថា អ៊ីកៀតជាមនុស្សគាល់គ្រមានចិត្តបុណ្យអាណិតអាសូរគ្រប់ស្តាណាស់ ដែលលោកនឹងបង្គាប់ឲ្យគាហានចាប់យកទៅសម្លាប់ចេញនោះជាការមិនគួរទេ ។ ស៊ុនសេកបានស្តាប់ដូច្នោះធឹតតែខឹង

ខ្លាំងណាស់ឡើងទៀត កំបង្គាប់ឲ្យគាហានប្រញាប់ទៅចាប់ខ្លួនឲ្យខាងតែបានហើយគោលថា បើនរណាមួយរឹងទទឹង អញនឹងឲ្យកាត់ក្បាលអ្នកនោះវិញ ។ គាហានខាំងញ័រកំភិតភ័យខ្លាចមិនអាចរឹងទទឹងទំរាំនាំគ្នាទៅរកចាប់ខ្លួនអ៊ីកៀតនាំទៅឲ្យស៊ុនសេីកលើសេីន ។ ស៊ុនសេីកក៏ស្រែកគំរាមហើយសួរថា: ខ្លួនមកពីណា ? ហេតុម្តេចមកធ្វើកិរិយាកុហកបញ្ឆោតឲ្យគេដឿរង្វេងខាំងអស់គ្នាដូច្នេះ? ។

អ៊ីកៀតធ្វើយតបថា: ខ្ញុំបាទនៅស្រុកឈុងសៀ, តាលព្រះចៅស៊ុនតេសោយពជ្រនោះ ខ្ញុំបាទបានទៅស្វែងរកថ្នាំសេីកុំឲយ៉ុកយ៉ងបានតម្លាក្នុងរូងភ្នំប្រហែល ១០០ ប្លាប់សម្រាប់ធ្វើការសែកទឹកមន្តរក្សាជម្ងឺឈឺថ្កាត់ផ្សេង ។ ខ្ញុំបាទប្រាថ្នាយកតែបុណ្យកុសលប៉ុណ្ណោះ ដែលទឹងបានធ្វើកលល្បិចបញ្ឆោតគេឲ្យវង្វេងដឿស្តាប់ដាការពុតប្លែកខេសោះ ។ ស៊ុនសេីកសួរថា: "បើខ្លួនមិនបានយកថ្លៃឈ្នួលពីឈ្មោះណាទេ ហេតុម្តេចខ្លួនក៏បានចំណីអាហារបរិភោគចិញ្ចឹមដរាតមក ហើយទឹងបានគ្រឿងបរិភោគប្រដាប់ស្លៀកពាក់ដូច្នេះ? ខ្លួនឯងនេះគឺជាពួកជាមួយទឹងទៀវកុក បើអញមិនសម្លាប់ឯងចេញទេ ឯងទឹងមានចិត្តកំរើបតិតប្រទូសព៌យដល់អញវិញ" ថាហើយក៏បង្គាប់គាហានឲ្យនាំខ្លួនអ៊ីកៀតយកទៅសម្លាប់ចោល ។

ទៀវចៀនិយាយឃាត់ថា: តាំងពីអ៊ីកៀតមកនៅស្រុកតាំងតាំងនេះជាង ៣ ឆ្នាំហើយ មិនដែលឮថាអ៊ីកៀតទៅកូតកុហកបញ្ឆោតអ្នកណាមួយសោះ ដែលលោកឲ្យយកខ្លួនទៅសម្លាប់នោះឃើញថាមិន

គួរទេ ។ ស៊ុនសើកនិយាយនឹងទៀវចៀវថា : អ្នកមកពាក់អាន់កៀត ថាជាមនុស្សចិត្តបុណ្យនោះឬសោះ អ៊ីកៀតនេះជាមនុស្សចោកកុហក ប៉ដូចសត្វតិរច្ឆាន តាហានតាំងតួងចូរនាំអ៊ីកៀតទៅសម្លាប់ចុះ ។ ប៉ុន្តែ លុះនាម៉ឺនតាំងតួងនឹងតាន់ជិន នាំគ្នាចូលទៅអង្វរយោគ់ស៊ុនសើកសុំដីវិត អ៊ីកៀតពុកបាន ។ ស៊ុនសើកក៏ឲ្យយកខ្លួនអ៊ីកៀតទៅឃុំជាក់គុកពុកវិញ ហើយស៊ុនសើកត្រឡប់មកនៅក្នុងគេហដ្ឋាន ។ អ្នកបំរើស៊ុនសើកក៏នាំយករឿងដែលធ្វើទោសអ៊ីកៀតនោះ ទៅដំកបដល់នាងនឹហ៊ូ-យិន ជាមាតាស៊ុនសើកសព្វគ្រប់ប្រការ ។

នាងនឹហ៊ូយិនបានស្តាប់ដូច្នោះ ក៏ឲ្យហៅស៊ុនសើកចូលទៅនិយាយថា : អ៊ីកៀតនោះជាមនុស្សចិត្តបុណ្យ អាណិតអាសូរដល់បណ្តាកស្តេណាស់ ហេតុម្តេចក៏កូនឲ្យយកអ៊ីកៀតមកធ្វើទោសដូច្នេះ ។ ស៊ុនសើកទ្វើយថា : "អ៊ីកៀតនោះជាមនុស្សចោកកុហក បើនឹងពុកឲ្យយូរទៅគង់នឹងមានចិត្តកំរើបធំឡើងទៀត បើនឹងពុកកាត់ន៏ងមានភ័យអន្តរាយដល់ខ្លួនខ្ញុំបាទ មាតាកុំគប្បីជឿស្តាប់ពាក្យដែលគេមកដំកបនោះឡើយ មាតាជ្រាបស្រាប់ហើយកុំពាក់អានកាន់អ៊ីកៀតនោះធ្វើអ្វី" ហើយស៊ុន-សើកក៏លាមាតាត្រឡប់ចេញមកវិញ ។

ខណៈនោះ ទៀវចៀវនឹងនាម៉ឺន ១១-១២ នាក់ នាំគ្នាចុះឈ្មោះធ្វើរឿងរ៉ាវចូលមកប្តឹងស៊ុនសើក ជាសេចក្តីថា: សូមឲ្យលោកដោះលែងអ៊ីកៀតចេញទៅ បើដំណាតទៅមុខអ៊ីកៀតមានចិត្តកំរើបគិតប្រទូសរ៉ាយដល់លោកយ៉ាងណា សូមឲ្យលោកកាត់ក្បាលយើងខ្ញុំចាំងអស់គ្នាចេញ

ចុះ ។ ស៊ុនសេកឃើញពាក្យបណ្តឹងជាក់ច្បាស់ដូច្នោះ ក៏និយាយថាអ្នកទាំងអស់គ្នាមិនដឹងទេឬ? កាលគ្រាខ្ញុំកុកនឹងពួកគឿនធ្វើជាចោរនោះ ខ្ញុំវិលចេញទៅហ្វាយស្រុកសៀដីវ៉ា ពប់អានថាជាហ្គូថាវបញ្ជូលខ្មោចសំក្តីសំទ្ធី បើខ្ញុំវិលនឹងលើកខ្លួនទៅណាក៏យកព្រៃកហម ឲ្យហ្គូថាវចុះលេខយន្តមន្តគាថាឲ្យ ហើយឲ្យទាហានទាំងពួងដួតក្បាលធ្វើការសង្គ្រាមក៏កាន់យកអាវុធមិនបាន, ខ្ញុំវិលនឹងទាហានទាំងពួងធ្វើសង្គ្រាមក៏បរាជ័យចាញ់ក្នុងទីចម្បាំង, ឯអ្នកពាល់គ្នាមកពប់អានអីគឿតដែលជាមនុស្សប្រកបកុហក ដឿកាន់ខ្មោចបីសាចនោះមិនសមគួរសោះ យើងនឹងឲ្យសម្លាប់អីគឿតចេញ ស្រុកយើងក៏នឹងបានសេចក្តីសុខក្សេមក្សាន្តតទៅ ។

លីហ៊ួយហាននិយាយនឹងស៊ុនសេកថា: ខ្ញុំបានបានឮកិត្តិសព្ទថាអីគឿតមានការចេះដឹងហៅខ្យល់ហៅភ្លៀងបាន ឥឡូវស្រុកយើងកំពុងភ្លៀង បណ្តាកស្តេធ្វើស្រែមិនបានសោះ សូមលោកឲ្យអីគឿតហៅភ្លៀងបើអីគឿតហៅភ្លៀងឲ្យធ្លាក់ចុះមកបានហើយ ឲ្យលោកបើកលែងអីគឿតចេញចុះ ។ ស៊ុនសេកយល់ឃើញត្រូវក៏ឲ្យទាហានសង់កេងពិធីសុំទឹកភ្លៀងខ្ពស់ប្រមែល ១០ ព្យាម (៤០ម) ទើបឲ្យទៅយកខ្លួនអីគឿតចេញមកហើយប្រាប់ថា: ខ្លួនមានសេចក្តីចេះដឹងខាងមានចិត្តអាណិតអាសូរពស្តេខាងពួង ឥឡូវស្រុកយើងកំពុងភ្លៀង ពស្តេធ្វើស្រែមិនបានខ្លួនចូរហៅទឹកភ្លៀងឲ្យធ្លាក់មកចុះ យើងនឹងដោះខ្លួនចេញ ។

(មានត)

រឿងបល្ល័ង្កធំព្យ ភាមសិបពីររឿង

ឬរឿងព្រេងនិទាន

លោកសមិទ្ធ ម្ចាស់ផ្ទះ តែង

លោក រ៉ាយ-ប៊ុក ក្រមការដើមខ្សែ ប្រែរៀបរៀង

(តមក)

កន្លងពេលនោះ ស្ងាមីនាគ៏បុរសដែលគេយើញមានដើនជាប់ឆ្អាក់មកកន្លងសមក្ខេមិ ស្រាប់តែបញ្ចេញរូបពន្លឺដែលប្រឡាក់ដោយលោហិតមកនៅចំពោះមុខក្រុមប្រឹក្សាអមព្រះអង្គ ។ ព្រះមហាក្សត្រិយ៍នីនព្រះពន្ធប្រឹក្សាមានសេចក្តីឆ្ងល់សង្ស័យជាខ្លាំង ។ បុរសនោះក្រាបបង្គំទូលថា: "បពិត្រព្រះចក្រពត្តាធិរាជ, ទូលព្រះបង្គំបានបំពេញការណ៍យកិច្ចសព្វគ្រប់ហើយ, ឥឡូវនេះ សូមព្រះអង្គមានព្រះរាជបញ្ជាឲ្យគេយកប្រាន្តទូលព្រះបង្គំមកប្រគល់ឲ្យទូលព្រះបង្គំ ទូលព្រះបង្គំនឹងវិលទៅប្រទេសវិញ" ។

ព្រះនរបតី, ក្រោយដែលទ្រង់បានព្រះសណ្តាប់ន្ធវាក្យបុរសនោះ, ទ្រង់ក៏មានព្រះតម្រិះរកឧបាយនឹងឆ្លើយតបទៅបុរសនោះវិញ, តែមិនឃើញតាក្យអ្វីល្មមគោលឲ្យសមនឹងព្រះរាជហ្ឫទ័យសោះឡើយ ។ ដោយទ្រង់មានព្រះរាជហ្ឫទ័យខ្វល់ពន់ពេក, ទ្រង់ក៏ឈ្នើងព្រះនេត្រទៅចំព្រះពក្ត្រប្រឹក្សា ។ យល់ន្ធវាព្រះរាជហ្ឫទ័យព្រះអង្គ ក៏ជំរាបបុរសនោះថា: "នែអ្នកជាវីរបុរស! ក្រោយដែលអ្នកអញ្ជើញទៅបាត់ ស្រាប់

តែឃើញក្បាលមួយដូចជាក្បាលអ្នក ឆ្លាក់មកនៅចំមុខយើង ។ ដោយ
ឃើញក្បាលនោះឆ្លាក់មក, ក៏យោអ្នកឯងក៏ស្រែកខ្លាំងរៀបរាប់
ច្រើនយ៉ាង, ហើយនាងមិនត្រេមស្តាប់ព្រះពាជនុវាចដែលខ្លួនទំនាស់
គ្នីនាង ។ ក៏ខ្លួលមរណភាពក្នុងមួយរំពេច តឹមរណភាពជាមួយនឹង
ស្វាម៉ីនាង ។

កាលណា ព្រះពាជទ័ប្រឹក្សាឃើញដំណឹង នៅបុរសដែលជាស្វាម៉ី
នាងសព្វគ្រប់ប្រការ, បុរសនោះក៏ស្ងិតនៅស្ងៀមមួយស្របក់, ហើយ
ដកដង្ហើមធំថ្លង់វែង ហើយក៏ក្រាបបង្គំខ្លួលព្រះអង្គថា "បពិត្រព្រះ
មហាពាជ, ប្រជាជនក្នុងលោកសន្ទឹងសនេះបានសរសើរព្រះអង្គ ចំពោះ
ព្រះពាជប្បាទ័យស្មោះស្ម័គ្រក្នុងការប្រតិត្តិព្រះពាជករណីយកិច្ច ព្រមទាំង
ព្រះពាជគុណសម្បត្តិជាច្រើនរបស់ព្រះអង្គ ។ ហេតុដូចម្តេច តឹព្រះពាជ
គុណសម្បត្តិនោះជាវត្តុតតអំពើចំពោះខ្លួលព្រះបង្គំ ដោយខ្លួលព្រះបង្គំ
គ្មានប្រតិត្តខុស ចំពោះព្រះអង្គសោះឡើយ ? បពិត្រព្រះមហាពាជ,
សូមខ្ញុំជាបថា ព្រះអង្គជ្រាបស្រាប់នូវចំណុចដ៏ខ្លាំងដែលខ្លួលព្រះ
បង្គំមានចិត្តស្នេហាចំពោះប្រពន្ធ, ប្រហែលជាខ្ញុំសព្វព្រះពាជប្បាទ័យ
ចំពោះនាងដែរ តែខ្ញុំមិនត្រូវបណ្តោយតាមព្រះពាជប្បាទ័យសោះ
ឡើយ ។ ខ្លួលព្រះបង្គំមិនបានឃើញនាង, ខ្លួលព្រះបង្គំមានទុក្ខពន់ពេក ។
ព្រះនរបតីខ្ញុំព្រះសណ្តាប់នូវពាក្យនៃបុរសនោះខ្ញុំក៏មានព្រះបន្ទូលថា:
"យើងមិនមានចិត្តប្រតិព័ទ្ធនឹងការយោអ្នកឯងទេ" ។ បុរសនោះក្រាប
បង្គំខ្លួលថា: "បពិត្រព្រះមហាពាជ, ខ្លួលព្រះបង្គំបានឃើញនូវព្រះ

ពជប្ញាទ័យដ៏ស្មោះស្ម័គ្រ ចំពោះការប្រតិត្តិនូវព្រះពជករណីយកិច្ច ។
ឥឡូវនេះសូមទ្រង់ប្រគល់ភរិយាខ្ញុំលព្រះបង្គំមកឲ្យខ្ញុំលព្រះបង្គំវិញ: ឬ
ព្រះពជឥន្ទព្រះអគ្គមហេសីទ្រង់មកឲ្យខ្ញុំលព្រះបង្គំក៏បាន ។

មហាពជទ្រង់ព្រះសណ្តាប់នូវពាក្យបុរសនោះ ដោយទ្រង់ខ្វាចក្សត់
ព្រះពជករណីយកិច្ចរបស់ព្រះអង្គ, ទ្រង់ស្តេចយាងទៅកាន់ប្រាសាទ
ខាងក្នុងព្រះបរមពជវាំងទ្រង់បានចាប់ព្រះហស្តព្រះអគ្គមហេសី, ដឹកនាំ
ចូលទៅក្នុងទីក្រុមប្រឹក្សាអមព្រះអង្គ ហើយទ្រង់ទតទៅចំបុរស។ នោះ
ក៏បាត់ខ្លួនពីទីនោះទៅ ។

ក្នុងពេលនោះវៃតាលិកបានចូលមកក្រាបបង្គំគាល់ព្រះមហាពជហើយ
ក្រាបបង្គំទូលថា: បពិត្រព្រះបរមកត, ដោយអានុភាពនៃវិទ្យាស្តួ
"ឥន្ទ្រជាល" (Indrajàla) ទូលព្រះបង្គំបានប្រសិទ្ធិនូវមន្តសាស្តួ
ឬ មាយាវិទ្យា (Màyàvidyà) ដែលព្រះអង្គទ្រង់បានទតឃើញអម្បាញ់
មិញនេះ, ពាំងអស់នេះជាការមិនពិតសោះឡើយ ។ ព្រះមហាបពិត្រ,
ទ្រង់កុំព្រួយព្រះពជប្ញាទ័យ សូមទ្រង់គង់ទៅជាសុខក្នុងសិរីពជ
សម្បត្តិចុះ ។

ព្រះមហាក្សត្រិយ៍, ក្រោយដែលទ្រង់ព្រះសណ្តាប់នូវពាក្យរបស់
វៃតាលិក, ទ្រង់មានព្រះពជប្ញាទ័យសោមនស្សឥតឧបមា, ទ្រង់បាន
ទាំព្រះអគ្គមហេសីទៅកាន់ប្រាសាទខាងក្នុងព្រះបរមពជវាំង, ហើយទ្រង់
វិលត្រឡប់មកកាន់ទីប្រជុំក្រុមប្រឹក្សាអមព្រះអង្គវិញ ។ ក្នុងពេលនោះ
ព្រះមហាក្សត្រិយ៍នៃប្រទេសបន្ទិយ (pandya), បានទាំសួយសាអាករ

ជាច្រើន គឺព្រះទីនាំងតជសាមួយរយ, អស្សតរមួយរយ ទំនិងព្រះពជ
សារតុងទៀតមកថ្វាយព្រះអង្គ ។ ព្រះបាទវិកមាទិត្យទ្រង់បានយក
រតនតុតាំងអស់នោះប្រទានទៅវិតាលិក ។ ចេញពីព្រះបរមពជកំងទៅ
ជាត់ទៅ ។

រូបទេពនិម្មិតទី ២៩ ទូលបន្ទូលថា: "បពិត្រព្រះបាទកោជ:, ព្រះ
បាទវិកមាទិត្យដែលទ្រង់បានបព្រឹត្តព្រះរាជតណ័យកិច្ចជាសុកិតដូច្នេះ
ទើបទ្រង់អាចតង់លើបល្ង័ង្កទិត្យនេះបាន ។

ត្រាយដែលទ្រង់ព្រះសណ្ដាប់ធ្វើរឿងនេះ, ព្រះបាទតោជ:ទ្រង់
សែងធ្វើមុខាភិសេកកងពេលនោះ ។

*

* *

ធិទាងនៃរូបទេពធិម្មិត ទី ៣០

មានតាលមួយថ្ងៃ, រូបទេពនិម្មិតទី ៣០ បានត្រាបបង្គំទូលព្រះ
បាទកោជ:ថា "បពិត្រព្រះបាទកោជ: មានតែព្រះមហាក្សត្រិយ៍
វិកមាទិត្យ ទើបអាចតង់ទៅលើបល្ង័ង្កទិត្យនេះបាន; សូមទ្រង់ព្រះ
សណ្ដាប់អំពីព្រះពជចរិយា ជាព្រះមហាសប្បុរសនៃព្រះមហាក្សត្រិយ៍
នោះដូចតទៅនេះ ។

ទៅនគរអវន្តី, មានមន្ត្រីធំមួយនាក់ឈ្មោះស្រីទត្ត (Cridatta) ជា
អ្នកមានទ្រព្យសម្បត្តិច្រើនឥតគណនា. តាលតែខ្លួនលោកមិនអាចដឹង
ខ្លួវចំនួនទ្រព្យនោះបាន ។ មន្ត្រីធំនោះមានបុត្រម្នាក់ឈ្មោះសោមទត្ត
(Somadatta) ។ មានតាលមួយថ្ងៃ, បុត្រនោះមានបំណងចង់សង់

ប្រាសាទមួយ កំពៅប្រឹក្សាជាមួយនឹងបិតាអំពីរឿងនេះ ។ បិតា
យល់ព្រមតាមបំណងបុត្រ ។ គាត់ប្រាប់ប្រាសាទនោះក្នុងពេល
គាត់ប៉ុស (Pusha) ធ្វើដំណើរមកជួបគ្នានឹងព្រះសុរិយា ។ ដល់ថ្ងៃ
កំណត់, សោមទត្តក៏តាំងផ្តើមសាងប្រាសាទ, ថ្ងៃស្អែក, ប្រាសាទ
នោះក៏ហើយស្រេច ។ សោមទត្តក៏បានជ្រើសរកថ្ងៃពិសិដ្ឋដែលល្អមសម
រួនឹងចូលទៅនៅក្នុងប្រាសាទនោះ ។ លុះពេលយប់, សោមទត្ត
ក្រាទៅលើគ្រែស្នែងក្នុងប្រាសាទនោះ ក៏បានឮសូរសំឡេងខ្លាំងថា:
"បតិ, បតិ, (ប្រែថាអ្នក, ឯង) ។ ដល់បានឮសំឡេងដូច្នេះ,
សោមទត្ត, ក៏សង្ស័យកិតក័យ ខ្លាចមិនលក់សោយសេចជាខ្លាំង ។

ថ្ងៃស្អែកឡើងដោយមានចិត្តធ្ងន់ពន់ពេក, សោមទត្តក៏ចូលទៅ
ក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យអំពីរឿងនេះ ។

ព្រះមហាបតី, ក្រែយដែលខ្ញុំព្រះសណ្តាប់ឮវាចាបុរសនោះ ខ្ញុំ
បានវិញប្រាសាទនោះពីសោមទត្ត, រួចដល់ពេលយប់ខ្ញុំយាងទៅ
កណ្តាលប្រាសាទនោះ ស្រាប់តែមានសំឡេងមួយឮចេញមកពីក្នុង
ប្រាសាទថា "បតិ, បតិ" ។ ដល់ខ្ញុំព្រះសណ្តាប់ឮសំឡេងនោះ,
ហាក់ដូចខ្ញុំមានបន្ទូលតបទៅវិញថា "បតតុ" "ចូរឆ្ងាក់មកចុះ" ។
ដំណាលមួយរំពេចនោះ, ស្រាប់តែក្អែងមាសឆ្ងាក់មកក្នុងប្រាសាទតាំងពី
ព្រលប់រហូតដល់ភ្លឺ ។ នៅត្រង់ក្រោយព្រះបន្ទូលព្រះអង្គមានក្អែងឆ្ងាក់មក ។

ដល់ពេលបច្ចូសសម័យ, ព្រះមហាក្សត្រិយ៍ទ្រង់បានព្រះកដ្ឋានទៅ
សោយទត្តវិញនូវប្រាសាទនឹងមាស ដែលភ្លាក់ពេញប្រាសាទគាំងអស់ ។
រួចទ្រង់ក៏ស្តេចយាងទៅកាន់មហាសន្និបាតនៃក្រុមប្រឹក្សាអមព្រះអង្គ ។
រួចទេពនិម្មិតទីសាមសិបក្រាបទូលបន្ទូលថា: "បពិត្រព្រះបាទ
គោជ:, បើទ្រង់មានព្រះតេជានុភាពត្រមាំងមហាសប្បុរសធម៌ដែលនេះ,
ទ្រង់អាចគង់លើបល្ល័ង្កទិព្យនេះបាន, បើមិនដូច្នោះទេ, ទ្រង់មិនអាចគង់
លើបល្ល័ង្កទិព្យនេះបានឡើយ ។ ព្រះបាទគោជ:, ក្រោយដែលទ្រង់
ព្រះសណ្តាប់នូវរឿងខាងលើនេះ ទ្រង់ក៏លែងធ្វើពជាតិសេកកង់ពេល
នោះទៅ ។

(មានត)

ប្រយោជន៍របស់រឿង

រឿងបល្ល័ង្កទិព្វនេះកល្យាណ ជារឿងដ៏បានគតិពិត
ខាងអប់រំមនុស្សឲ្យប្រតិត្ត នូវធម៌សុចរិតជាសប្បុរស ។
មានគុណប្រយោជន៍ដ៏ប្រសើរ ដល់លោកអ្នកមើលយល់សម្ងួស្ប
ចាំរឿងសព្វគ្រប់ចប់គាំងអស់ ឲ្យធ្វើសប្បុរសតាមយ៉ាងល្អ!

បាប - ពិន

សាស្ត្រាចចក

ជាគតិដំបូន្មានមិនឲ្យលោភ

លោក ជាប - ពិន ពិនិត្យកែសម្រួល

ចំពោះពាក្យដែលភ្ជាំងភ្ជាត់ឲ្យត្រូវសេចក្តីនឹងល្អនភាក្យឡើងវិញ

នេះបទគាថា - គតិចរចា ចែងចងរឿងកាយ តាមពាក្យព័ត្រែង តតែងនិយាយ ដំណើរអកិច្ចាយ ពីសត្វចចក ។ យោនយកកំណើត កំណត់កាលកើត ពីដំពូនជ្រៃតជ្រក ក្នុងរូងថ្កុំ ជាវធុំសៀតសិក សត្វថ្លៃចចក ស្មែងកេកោជនា ។ ប្រុបន្ទោអូរស្ងួត តែពាំងបួចឹង ជ្រោះជ្រាយបឫតា លុះយប់ផ្ងាល់ផ្ងាប់ ចុះចាប់មច្ឆា តែងបរិភោគ្គា សត្វថ្លៃប្រកែតី ។ រួបគាបក្រញីញ ចាខប្លួនគ្រឿខេញ គ្រឿតូចអច្រិយ តែងដើរលោកលះ ស្មែងស្វះរកស៊ី ព្រួយខ្សោយតន្ទ្រិយ ស្តាំងស្គមអាត្មា ។ ពីកាលក្មេងខៅ មេស្លាប់ចោលខ្ញុំ ខៅតែនឹងចា ទាំដើររកស៊ី ប្រុបចីជលសា លុះធំកាលណា ចាស្លាប់បង់ចាត់ ។ ចចកនោះខៅ ខល់ខ្លុកក្លាត់ក្តៅ ក្នុងថ្ងើមប្រមាត់ ឥតមេឥតចា កំព្រាព្រាកព្រាត់ ស្ងប់ស្ងួតស្ងៀមស្ងាត់ គ្រមោចម្នាក់ឯង ។ ចចកគន់គិត រំពឹងក្នុងចិត្ត រឹងតែចំបែង ដើរកេកោជនា កោក្តាកណ្តែង កណ្តេចឯកឯង ឥតមានគ្នីគ្នា ។ លោចូលដេក ក្នុងរូងដំណេក ត្រូវក្លៀងរោ ខ្យល់បក់ស្ងប់ស្ងួត ថ្ងើមសួតគ្រាំគ្រា គ្រែកៀមកំព្រា កំប្រុនពេកពន់ ។ ចចករិះគិត ចាន់ឃើញគំគិត មួយខោះជាលន់ ថាអញត្រូវរក ត្រូវយកប្រពន្ធ ទើបចាន់ទន់ស្រួត ខឹងស្រាលខ្លួតា ។ គ្រាន់ជាគួរដៅ ស្នេហានៃបខៅ

ក្នុងរូងបព្វតា ចចកគិតខ្មោះ ក្រែកស្មោះយកគ្រា គ្រាចក្នុងត្រីក្បា
ស្រងូតស្រងាត់ ។ ដើរគ្រាចតែឯង កណ្តោចកណ្តែង កំព្រាព្រាតព្រាត់
តែមោចតែមង់ នៅក្នុងវាលស្ងាត់ ប្រទះហ្វូងសត្វ គោតគោមហឹង្សា ។
ទន្សោងទន្សាយ ដំរីប្រើសត្រាយ ឈ្លូសក្តាន់សូកក រមាសមាំង
ខ្លីងខ្លាំងខ្លោងខ្លា ដើរវាតគោក្តា សឹងសត្វយង់ឃ្នង ។ ចចកឃើញសត្វ
សាហាវវង្គាត់ ខ្លែចខ្លែកខ្លូង កៀងគាល់គូរ ខ្លៀវខ្លាអីងកង
កិតក័យកន្ទូង ស្ទើរចាត់ស្មារតី ។ ទំដើរវាលង ចៀសសត្វយង់ឃ្នង
ជានដល់នទី ស្ទឹងមួយថ្ងាជ្រះ ត្រចះយេលដី ចចកចាប់ត្រី
ចំអែតកាយា ។ ហើយហែលឆ្ងាស់ឆ្ងូង ស្ទឹងខោះវាលង ដល់ត្រើយគង្គា
គ្រាចក្នុងរបោះ ចន្ទោះអង្គា មានរូងគូហា ដំតដើងគីរី ។
ចចកចូលដំត ប្រុងប្រាណមូលមំត្ត មៀងមើលរកញ៉ី នុនចុះធើបធើត
ចំអើតមើលទី ក្បាណោះមានញ៉ី ចចកមួយណា ។ នៅក្នុងរូងថ្ម
សិលាដ៏ល្អ ក្បាលសមកាយា ចចកឈ្មោលគំត ក្នុងចិត្តថែថា
គួរអញសួរសា បន្តិចខើបជាន ។ ខើបឈ្មោលហារក ថាប្អូនពន្ធុក
មិត្តម៉ុមកល្បាណ នៅក្នុងរូងថ្ម ល្អះល្អើងឯជាន សត្វថ្លៃតើមាន
ប្តីថាគូគ្រង ។ ឬនៅឯកឯង ប្អូនអើយចូរថ្លែង ប្រាប់ចាប់បង់ផង
ឲ្យបងវិសាយ កុងកាយនេះហោង បើឥតគូគ្រង បងសុំស្នេហា ។
ចចកញ៉ីស្តាប់ ងាកហើយថ្លែងប្រាប់ ថាអ្នកសោតា ប្អូននៅសត្វថ្ម
អាស្រ័យគូហា មិនមាននរណា ជាគូឡើយនៃ ។ កាលដើមមានមេ
មានប្តាំពេ នុបក្រុងសត្វថ្ម ឥឡូវមេថ្ម មរណាក្បាណក្បាយ

ប្អូនទៅសត្វថ្លៃ កំព្រាពេកពន់ ។ ឈ្មោលឮដូច្នោះ ត្រិះត្រួចពង់ពោះ
ហ្អែយគោរខន់ ទើបឆ្លើយតបវិញ ថាប្អូនក្លាស្ងួនតន់ ប្អូនអើយបងគន់
បងគិតអនិច្ចា ។ អាស្រូវប្អូនស្ងួន មាសមិត្តខ្ញុំមខ្លួន កំព្រាឯកា
ដួចកល់ខ្លួនបង សៅហ្មងចិត្តា សត្វថ្លៃបងមហា ព្រួយណាស់ប្អូន
អើយ ។ ចចកញ៉ីស្តាប់ ពាក្យឈ្មោលថ្លែងច្បាប់ ឆ្លើយថាអ្នកអើយ
ប្អូនស្តាប់ពាក្យអ្នក ដៀងជាត់ទៅហើយ ក្នុងចិត្តឥតស្បើយ កើតទុក្ខ
ខ្លៃតថ្មី ។ ប្អូនបងសូមសួរ ហៅមហាមិនគួរ ដ្បិតខ្លួនជាស្រី
អ្នកថាព្រួយចិត្ត ព្រោះគិតរឿងអ្វី ប្រុសច្បាស់ច្បែមច្បែយ ច្បាយ-
ច្បាប់ប្អូនវ៉ា ។ ឈ្មោលថាមាសមិត្ត បងព្រួយព្រោះគិត ដល់គូស្នេហា
គ្មានគ្នាជាពីរ ចំណែកអនា – គតបងហៅមហា ថប់ណាស់មាសបង ។
ញ៉ីថាប្រុសអើយ កុំថប់អ្វីឡើយ ប្អូនជានារើ រិះរកជួយគិត តាមចិត្ត-
អ្នកបង ត្រង់តាមបំណង ចិត្តអ្នកច្បាស់ថា ។ ឈ្មោលថាមាសមិត្ត
បងប៉ងផ្ញើចិត្ត ផ្ញើដួងដ៏ក៏ ទៅលើប្អូនស្ងួន សូមខ្លួនមេត្តា
បងមិនច្បាស់ថា ដរៃពីរៅ ។ ញ៉ីឆ្លើយថាអ្នក ចិត្តបងរំភើបក្ស
មួលមួយលំទៅ ផ្ញើដួងចិត្តា ស្នេហាតទៅ ឱងប្អូននេះកូវ ពេញ
មហាអរពេក ។ ប៉ុន្តែប្អូនយល់ ប្អូនគិតទៅដល់ ឆ្ងល់ឆ្ងាយចំឡែក
ស្ថានអ្នកឯនាយ សប្បាយអនេក មានញ៉ីយ៉ាងឯក គួរគូស្នេហា ។
ម្តេចអ្នកមិនមាន ចិត្តចាប់ចង់ប្តាន ជាគូដ៏ក៏ ហើយត្រៃលោកលះ
ស្វែងសូរតុះតា ត្រាប់ត្រៃអាត្មា មកដល់ស្ថានអាយ ។ ឈ្មោល
ស្តាប់ឆ្លើយឆ្លាស់ ថាហៃប្អូនមាស មានរូបឆោមឆាយ ឆោមឆើតទង្វង

ស្តេចបង្គងាយ មែនហើយសប្បាយ ដូចពាក្យប្អូនថា ។ គឺមោះ
បង្រក គួគាប់ចិត្តយក ជាតិជាពន្ធិគា ទឹងទើចិត្តខ្លួន ដូចសួនខែណា
គ្មានសោះបង្គមហា ថប់ពេកនាងអាយ ។ ហេតុនោះបង្ហូះ
បង្រសែងលាកលះ មកដល់ស្តេចអាយ បង្ហាងើខ្លួន លើទ្លួន
ធោមនាយ ព្រួយខ្លៀយអង្គកាយ ម្តេច ។ មិនតិត ។ សែង
តែប្អូនស្រី មាសមានមេត្តី មេត្តាមូលមិត្ត មូលមួយកំពូ
ស្នេហាដូចដឹត ដូចចាប់ប្រពិត្ត ជាគួរសនា ។ ញ៉ីស្តាប់ធ្វើយ
ទ្វៀត ធ្វើយធ្វងវិញទៀត ថាប្រុសស្នេហា ពាក្យត្រៃល្អល្អះ គួរ
សរសង្កា លួងលោមចិត្តា ឃានហើយឃោះដង ។ ឈ្មោលធ្វើយថា
ហៃ ប្អូនមាសថ្មើមថ្លៃ បណ្តូលសាច់ស. ង្ឃាសេមសោតា តាយា.
វរវង្ស វរវាសអស់អង្គ អស់ឥតសង្ស័យ ។ បង្គមហាស្រឡាញ់
ប្អូនមាសឈ្មួយឆ្លាញ់ ចិត្តចាប់តាលើយ អាំលោះលើសលន់ ពេកពន់
ត្រាស់ត្រៃ ពុំបានបង្គក្បួយ ដឹរតែជាម្តង ។ ឈ្មោលថាតែម្ចាំ
ចូលដឹតចំពោះ ផ្ទឹមផ្ចាប់ហើយហោង ថើបថ្ពាល់ឰខ្លឹត ចំកឹតឆ្អឹងខ្នង
ថាហៃមាសបង នាងកុំខេវខឹង ។ បំណាច់បង្គមក រកប្អូនពន្ធុក ក្នុង
អូរឆ្នងស្ទឹង មិនស្តាយជីវិត ព្រោះចិត្តរំពឹង ឧកប្អូនព្រលឹង ជាដួង
ស្នេហា ។ ញ៉ីអៀនអន់អាត់ ខ្មុនមុខខុកគ្នុ ចូលចិត្តចិន្តា
សេពសុខក្សេមក្សាន្ត ក្នុងស្តានគូហា ទើបឈ្មោលលោមថា
ព្រលឹងបង្គអាយ ។ បង្គចង់នាំពៅ វិលវិនចរពៅ ស្តេចបង្គងាយ
តើនាងនឹងថា ម្តេចម្តាប្អូនអាយ ញ៉ីធ្វើយប្រាប់ប្រាយ ថាតាមចិត្តា ។

អ្នកនាំប្អូនទៅ ទីស្ថានលំនៅ ម្តេច ។ មិនថា ឈ្មោលឮដូច្នោះ
នាំស្មោះយាត្រា បណ្តើរភេទិតា ចរចាន្ទស្ថានស្ថិត ។ លុះបានដល់ទី
លំនៅនាំញី ចរចូលមូលមិត្ត មូលមួយកន្លងស្ថាន ក្សេមក្សាន្តនៃបនិត្ស
តមានភ័យកិត បៀតបៀនឡើយណា ។ លុះនៅយូរទៅ ចចកញីក្តៅ
គាប់កើតគភ៌ា ទំមុន់ពេញពោះ ចិត្តស្មោះច្រើបច្ចា ចង់ចរកោក្តា
ត្រីកន្លងសមុទ្រ ។ ញីលោមឈ្មោលថា អ្នកប្រុសស្នេហា ថ្លាថ្លៃវិសុទ្ធ
វិសេសវិសាល ស្នេហ៍ស្មាលចំផុត ដ្បិតប្អូនមានបុត្រ ពេញ
ផ្ទៃហើយណា ។ ឥឡូវប្អូនចង់ បរិភោគចំណង់ សមុទ្រមច្ឆា សូម
អ្នកច្រោសច្រាណ ស្មោះស្មានចិត្តា រកឲ្យប្អូនភ័ បរិភោគសោះចង់ ។
ឈ្មោលឮដូច្នោះ ញីប្រើចំពោះ ត្រែកត្រែសត្រៃចត្រង់ ទៅរកម៉ច្ឆា
ដោយនាចំណង់ រៀលាវៃត្រង់ ចែងចាំងវេហាស៍ ។ ត្រែកត្រែស
ឮប្រាប់ក្តៅ លុះដើរតិចទៅ សង្កេតឃើញ ពុតពងឆៅឈាម រអាម
រអា លុះលាន់មាត់ថា យើក្តៅម្តេចម្ល៉ះ ។ បើជាខ្លួនអញ
ចង់ស៊ីឲ្យឆ្ងាញ់ មាត់តាមសំណៃ អញមិនត្រួយច្រាណ រុក
កនដល់ម្ល៉ះ ព្រោះតែវាខេះ វាប្រើអញបាន ។ លុះដើរទៀតទៅ
រ៉ែតតែក្តាត់ក្តៅ រន្ទត់កន្លងច្រាណ បែកញើសហូរហាត់ ខំអត់ធ្មេីកឮន្ត
ន៏ធ៌រៀលគ្រាយខាន ខ្លាចញីបន្ទោស ។ ម្ល៉ោះហើយប្រឹងមិត ប្រឹង
ចោលរ៉ែតែ ក្តៅដល់ដួលស្រួស ប្រឹងត្រែសត្រៃកឡើង ស្រមើង
ប្រឡួស មើលមុខស្រមួស ស្រមួញមាត់ស្ងៀញ ។ ខំចោលទៀតទៅ
រ៉ែតកាត់ក្តៅ កន្លងថ្មើមអម្ចេញ អន្ទាស់អន្ទែង ខំខែងចោលញ្ជាញ់

វិលត្រឡប់ត្រែងចាញ់ ច្រាជ្រាញនោះ ។ ម្ចាស់ទំលោលោត ចោលម្ជុចភ្លាមផ្ទាត ម្ខាងទៅខ្មៀតស្តុះ រើងក្តៅចាតដើង ដូចភ្លើងតោរពុះ ដួលខ្មៀតនៅនោះ បម្រាស់ច្រាស់ច្រាណ ។ ក្តៅអស់ឥន្ទ្រិយ ដូចកល់អគ្គី ដុតពេលពុំក្សាន្ត ញាំរអង្គុយន្ទត់ ប្រឹងអត់ពុំក្សាន្ត ត្រាកខ្លើងឈរឈាន បែរចោលខ្មៀតទៅ ។ រីតរើងក្តៅណាស់ លាន់មាត់ថាអះ ទុះទុពេញក្តៅ អញចង់តែអត់ សង្កត់ខ្យល់នៅ ឲ្យស្ងាប់នាប់ទៅ កុំឲ្យវេទនា ។ ដល់គិតវើងទៅ ត្រែងកើតហ្មងសៅ កើតក្តៅនិន្ទា ថាឧបបត កំព្រាតមោហា ក្សិណក្សយជន្មា ព្រោះញើបញ្ជោត ។ បើនឹងស្ងាប់រស់ ឲ្យឆ្អែក្តើយស គេមានតំណោត មាំនពាក្យសរសើរ ថាអើអញកោត បបកនេះសោត តេញហៅហានក្នា ។ គិតហើយចោលទៅ ជិតចឹករណ្តៅ ថាយើនរណាបង្កើតជាក្តៅ ហ្មងសៅចិន្តា ដើយមើលមេឃថា យើក្តៅព្រោះថ្ងៃ ។ អើអញជាតិនេះ លំបាកពាំងម្ល៉ះ ព្រោះតឿពាបត្រៃ កើតជាបបក កំព្រាកបង្កែ ជាតិក្រោយអញឆ្នៃ អញសូមសច្ចា ។ ទោះបីកបកើត យោនយកកំណើត ជាតិណាកពណា អញសូមសម្រេច សេចក្តីច្រាថ្នា កើតជាសុរិយា រុងរឿងរស្មី ។

កាលនោះមានយក្ស ប្រែតមួយសំណាក់ ស្ថិតស្ថានច្រកតី ទៅលើបព្វតា ទៀបនាវិថី យក្សឮសំដី បបកច្រាថ្នា ។ យក្សគិតថា អើ មហាលាភប្រសើរ ទឹងបានអាហារ ត្រកាលចំណី ល្អក្រៃថ្ងៃថ្នូ ទឹងបរិភោគ្នា ខ្ទូសាច់បបក ។ គួរអញក្រឡា ជាអង្គុតន្ទ្រា

ម្ចុំបាវឲ្យយក សាច់ឈាមជាគាន នឹងបានរ៉ែរក កំណើតបានមក
កើតជាសុរិយោ ។ យក្សគិតដូច្នោះ កាឡាចំពោះ ជាអគ្គិតន្ធ្នា
រំពេចហោះហើរ ស្ថិតលើវេហាស៍ ហើយមានវាចា សាកសួរ
មេត្តិ ។ ថាវៃហាចបាក អ្នកត្រែចដើរមក ពីណាវាកអ្វី បាកក្រែឡាក
ឈ្នៀងក្អែកវាំពៃ ស្មានអគ្គិកោសី ទើបទូលទៅថា ។ បពិត្រព្រះតន្ធ្នា
ខ្ញែសនរន្ធ ឥសូរសុជាតា ខ្ញុំមកស្មានស្មោះ ចំពោះច្បាថ្នា រកចាប់មច្ចា
ទៅកន្ធជលធី ។ បើបានមច្ចា ដូចប៉ងច្បាថ្នា យកទៅឲ្យញី ជួរតមាន
ផ្លែពោះ ចិត្តស្មោះចង់ស៊ី ត្រីកន្ធជលធី ទើបឆ្ងាញ់ណាស់ណា ។ ហេតុ
ទោះខ្ញុំមក រុកវានរ៉ែរក សម្ដុំមច្ចា ដើរជាន់ត្រែសត្តៅ ហ្នឹងសៅចិន្តា
តុរេងឆ្ងាយ រន្ធត់អគ្គិច្បាណ ។ បែកញើសហូរហាត់ ត្តៅណាស់ច្បាកដ
អាចអត់ពុំបាន ព្រោះថ្ងៃចាំងចែង សូរ្យសែងថ្កើងថ្កាន ទើបខ្ញុំប្រណាំងាន
អធិដ្ឋានថា ។ បើខ្ញុំនឹងកើត យកជាតិកំណើត ក្រែយខ្ញុំច្បាថ្នា
តាំងចិត្តចង់បាន ដូចក្តានចិន្តា កើតជាសុរិយោ ច្បាកដដូចប៉ង ។
បពិត្រតន្ធ្នា សូមស្តេចមេត្តា ជួយខ្ញុំនខ្ញុំផង ធ្វើម្តេចនឹងបាន ដូច
ក្តានបំណង ប្រែតយក្សធ្វើយឆួង ថាងាយណាស់ណា ។ បើចៅ
ចង់បាន ដូចចិត្តបំណាង បំណងច្បាថ្នា ចូរចៅផ្តិលផ្តាច់ សំរេចជន្ម
យកសាច់ឲ្យជា គានយក្សបិសាច ។ ហេតុផលអានិសង្ស ជួយជូន
ខ្ញុំខ្ញែង កើតមានអំណាច ជាសែងសួរយ៍ រស្មីចិញ្ចាច ចិញ្ចែងត្រដាច
ដូចចិត្តច្បាថ្នា ។ បាកស្តាប់តិត ដឿជាក់ចូលចិត្ត ទើបទូល
ទៅថា ខ្ញុំចង់ឲ្យគាន សាច់ច្បាណាហ៊ើយណា ប្រែតយក្សធ្វើយថា

សាធុព័រដង ។ ប្រែតយក្សថាម្ល៉ោះ ទិមិត្តចំពោះ ចាំងចាត់ទៅហោងឺ
ចចកវត់ចេញ ចោលខ្មាញ់ជាម្ហូន គិតថាអញបង ចានដូចសេចក្តី ។
ចចកគិតឆ្នោះ ចោលដល់ទឹកចុះ លុយលបចាប់ត្រី លុះចាប់ត្រីចាន
ដូចគ្មានសេចក្តី ក្រាថ្នាពាំត្រី ឲ្យញ៉ាំគោក្តា ។ ញីឃើញឈ្មោល
ដល់ ចានត្រីខ្លាយខ្លះ ខ្លួលមច្ចា បរិភោគផ្សាយផ្សព្វ ស្កល់ស្កប់
ចិន្តា ទើបឈ្មោលប្រាប់ថា ឯហ្អូនតីសី ។ កាលបង់ទៅយក
មច្ចានាំមក ឲ្យហ្អូនប្រឹមប្រិយ ហៅមហាត្រួយប្រាណ ពុំក្សាន្តណាស្រី
ស្ទើរខានចានត្រី មកឆ្អើហ្អូនគ្នា ។ ហ្អូនអើយថ្ងៃក្តៅ ដើងបងពងនៅ
រោមអង្គា ក្តៅដល់កង់ថ្ងើម ដង្កើមខ្វៃយា ដល់ដួលក្រៃនគ្រា
ស្ទើរវិលក្រៃយខាន ។ បងចំចោលទៅ ហ្អូនអើយរឹងក្តៅ ខ្នុត់អង្គប្រាណ
បងចោលហើយគិត កុងចិត្តថាស្មាន ប្រហែលតាហាន ចង្ការសឹកមួយ
សោះ ។ តេជះសំណាង សំណូមសូមសាង ពីមុនមកនោះ ចានជួបឥន្ទ្រា
យាត្រាចំពោះ ហើយស្តេចអនុគ្រោះ ស្មោះស្មានមេត្តី ។
ប្រដៅពួន្ទាន នាំដានិទាន ឲ្យដឹងសេចក្តី បុណ្យចាបត្រៃវុស
ហើយហោះចេញខ្ចី បងចេញចាកទី រកចាប់មច្ចា ។ ចចកប្រាប់ញី
សុះសត្វសេចក្តី គ្មានខ្វះត្រង់ណា ហើយលោមថាហ្អូន ខ្ចឹមខ្ចូនស្នេហា
អញបងចង់លា ទៅកន្លែងដ៏វិត ។ យកសាច់ជាចាន ប្រាថ្នាឲ្យចាន
ជាព្រះអាទិត្យ តើហ្អូនទទឹងថា ម្តេចម្ហាមាសមិត្ត ញីស្តាប់ហើយគិត
ធុញថៅវង់ថា ។ អ្នកមាសហ្អូនអើយ ហ្អូនថាម្តេចអើយ ចិត្តអ្នកប្រាថ្នា
មិនហ៊ានខាំងយាត់ ឲ្យភ្លាត់សច្ចា ក្រែងកើតគោសា ងាបដិតដល់ប្រាណ ។

គឺមោះប្អូនទៅ គ្រោយអ្នកប្រុសទៅ ចោះបង់ចោលស្ថាន ប្អូនកើតទុក្ខគ្រួតពីរគ្រួតពុំក្សាន្ត ទុក្ខមួយគ្រោះមាន ទម្ងន់ពេញពោះ ។ ទុក្ខមួយគ្រោះក្រាត់ គ្រោះប្រាសសូន្យស្ងាត់ សូន្យស្ងៀមគ្រៀមគ្រោះ គ្រៀមក្រែងចិត្ត ខ្លែតឆ្លុតអាលោះ អាល័យស្រណោះ អ្នកប្រុសប្រាសទៅ ។ សត្វថ្លៃរំពើង អ្នកមាសព្រលឹង ស្ថានថាអ្នកទៅ នៃបង់ត្បូងទុក ស្នេហាតទៅ ប្អូនឥតញាតិដៅ សង្ឃឹមតែអ្នក ។ ជាគូស្នេហា ទុកស្មើបិតា មាតារួមក្សេ រួមសេស្នេហ៍ស្មង់ ប្អូនច័ន្ទទុក្ខដាក់ ធ្លើខ្លួនលើអ្នក លុះអស់ជន្ម ។ ហេតុនោះប្អូនស្ងួន ប្អូនស្ងួនលាកលះ ចោលទឹកនោហា ដឹតដោយតាមអ្នក វាលក្តណ៌សោកាម្តេចឡើយឃ្លាតឃ្យា ពីទ្រូងប្អូនទៅ ។ ញ៉ែថាតែម្ល៉ោះ ទុនមុខទុក្ខចុះទុកធួលក្តៅ ហាក់ដូចអគ្គី ឆេះពីពោះទៅ ទល់ទុក្ខហ្មង់សៅដោរដល់នេត្រា ។ ស្ងៀមសូតស្ងាត់សូប ពុំចេញសាវសូសាវសង់ពាក្យ រឹងក្តៅគន់ថ្ងៃម ដង្ហើមទុក ខើបឈ្លោលលោមថាសំឡាញ់បង់អើយ ។ កុំខាងអាលោះ អាល័យសោកសោះ សោកសោតឥតគ្រៃយ បើបង់ចាន់កើត កំណើតម្ល៉ោះហើយ បង់មិនគោះគ្រៃយ ទីទៃចោលទៅ ។ សឹមបង់មកយក ប្អូនស្ងួនពន្ធុក បីបរមថ្មមទៅ ដាក់លើពិមាន ទិព្វស្ថានឆ្ពិនឆ្ពៅ មូលមួយលំទៅ នៃបង់ត្បូងស្នេហា ។ ចូរប្អូនស្រីស្រួល ស្រីស្រស់ទន្លួល អនុមោទនាព្រមព្រឹសទឹងបង ដូចប៉ង់ជ្រាបថ្លា កុំខាងរួញរា បើកបង់តាមចិត្ត ។ ញ៉ែរភ្លក់ឈ្លោលថា ហាក់ជូរទុក សោកាស្បើយស្បិត បន្ទោទុក្ខស្រាល

ស្រយោលក្នុងចិត្ត ទើបធ្វើយប្រឌិត ថាតាមចិន្តា ។ អ្នកទំនិងផ្តិលផ្តាច់ ដរិតយកសាច់ ជាខាន់ប្រាថ្នា យោនយកកំណើត កើតជាសុរិយា ប្អូនសោតសព្ទ សាធុទំនងអ្នក ។

ដំណើរចចក មោហាកំព្រក ឈប់ស្ងេរដៀងជាក់ ខេះទំនងចាប់ន័-ខាន់ពីប្រែតយក្ស ស្ថិតស្ថានសំណាក់ ទៅលើបព្វតា ។ យក្សនិម្មិតមក លបមើលចចក យក្សស្តាប់ឮថា ចចកផ្តិលផ្តាច់ សម្រែចជន្មា យក្សអរ-ហើយថា បរមលាភពេក ។ ហើយយក្សនិម្មិត បញ្ចូលក្នុងចិត្ត ចចកឲ្យ ត្រេក កាត់ចិត្តឲ្យខាន សាច់គ្មានអស់ឯក ហើយប្រែតយក្សស្រែក ឲ្យសាធុការ ។ ចចកឈ្មោលញី លុះឮសំដី ប្រែតយក្សឲ្យសា-ធុការដូច្នោះ ស្រួលស្រុះចិន្តា លង់លុះសុរិយា អាប់អស្តង្គត ។ នាំញីចូលដេក ក្នុងរូងដំណេក ដូចដើមកំណត់ ទំនងថ្ងៃឯព្រៃ ធំព្រៃជ្រៅជាដ ប្រែបន្តេះសម្ងុត គាប់កាលនោះណា ។ មានយក្ខិ-នី ប្រែតប្លាសឥតប្តី ទៅក្នុងព្រឹក្សា យក្សត្រែចរកប្តី ឃ្លាតខ្លីយោត្រា ជាន់ដល់បព្វតា ដែលយក្សប្រុសទៅ ។ យក្សស្រែយើញម្ចាស់ ត្រជាក់ចូលឈប់ បន្តិចចាត់ក្តៅ យក្សស្រែថាអញ ឃ្លាតខ្លួញ៉ាំរលត់ក្តៅ ដើរហាលថ្ងៃក្តៅ សៅហ្មងកក្តាំ ។ យក្សស្រែគិតក្នុង ដើរកេងកំភ្លោះ ទ្រុះមើលមុខា យើញហើយផ្តៀងផ្តង ឈ្មៀងឈ្មងនេត្រា យក្សស្រែចហើយថា ទៅល្អដែរទេ ។ អញឯងកំលាប លាងក្អែលន្លះផ្តាប ឲ្យត្រាន់ជាងគេ ថាស្រែចយក្សស្រី ឃ្លាតខ្លីឯាកកេ រកភ្លោះឯងវិញ ដុសសព្វកាយា ។ ហើយយក្សខ្សឹងយក សំពត់ជាន

មក ស្ទៀកហើយយាគ្រា ដើរទៅហើយគិត ក្នុងចិត្តយក្សថា ចង់
ច្រៀងសិនក៏ ឲ្យបានស្ទើយខ្លួន ។ យក្សស្រីគិតឮះ ចាប់ក្បិនចង
ចុះ រកស្បាលើយមុខ គន់មើលរូបកាង ដូចតាងច្រហុក ម្ល៉ោះខំញីក-
ញ៉ុក ញាំញើដើរលេង ។ រោវរែកកំ ជាតខ្ទាំ ខន្ធើរខន្ធេង
អង្គុយក្លាមចុះ ដើងគោះជាក្លេង ខះដៃច្រៀងលេង ងើកដោកសិរសោ ។
ក្រែខ្សែកស្តាំខ្នេង ស្តាប់ទៅសំខ្សេង ដូចហ៊ឹងសោកា គន្ធោកគន្ធោក់
រលាក់ញាក់ស្មា ឮដល់យក្ស ប្រែតស្ងិតលើកូ ។ យក្សថាសំខ្សេង
នរណាច្រៀងលេង លាន់ឮរំងំ ថាហើយយក្សប្រុស ចរចុះ
ដើងកូ ហើយយក្សសំងំ លបលួចមើលមៀង ។ មើលមិញស្គាល់
ជាក់ ថាអនុយក្ស ស្រីទៅស្រែកច្រៀង យក្សប្រុសចង់ស្ងួច
បៀតជិតបញ្ជៀង ផ្ទឹមផ្ងាប់ផ្ងាល់ផ្ទៀង សាកសួរទៅថា ។
នាងស្រីកែមុំ រូបកាងឧត្តម នាងមកពីណា យក្សស្រីថាខ្ញុំ ខិតខំ
យាគ្រា ចេញព្រំព្រៃក្សា ដើររកចំណី ។ យក្សប្រុសថាអើ លាក
លន់លុះលើ បំណាងសេចក្តី ច្បាថ្នាអញប៉ង ចង់ចងមេត្រី
នឹងនាងអ្នកស្រី ជាគូស្នេហា ។ យក្សស្រីថាកុំ លេងសុំនពេកខំ
ហៅមែអញណា យើងមិនជាស្រី អប្រិយខ្លាំណា យើងមានមេប្តា
តូជតាឯគ្រាន់បើ ។ យក្សប្រុសថាឧ អញចង់តែក៏ ពុំខ្លាចតើ
នរណាធ្វើអ្វី ប្អូនស្រីគ្រាន់បើ យក្សស្រីថាអើ គ្មានធ្វើអ្វីទេ ។
ប៉ុន្តែមាក់ងាយ ហ៊ានហានិយាយ ស្រដីចង់ចែ ខំលេងពាក្យផ្តៅ
អញទៅប្រាប់មែ យក្សស្រីគិតកែ ការក្តៅចិត្តខ្លួន ។ ប្រុសថា

ថ្ងៃអញ្ជើ ព្រោះបងស្រឡាញ់ ទើបបងហ៊ានលេង ប៉ុន្តែស្ត្រី
សេចក្តីច្នៃឯង មានសមត្ថមិនឈ្លូង សង្ឃរាសោះឬ ។ យក្សស្រី
ថាស្អប់ តាក្សប្រុសប្រសប់ ស្រដីគោលលើ ថ្មោងថ្មីស្រឡាញ់
អស់អញឥតស្មើ ចានហើយធ្លុះធ្លើ តើយគោះចោះបង់ ។
ឯយក្សប្រុសនោះ ចានឮដូច្នោះ សោមនស្សអស់អង្គ អារឯងស្រួលសើច
សំណើចចំណង់ ថាប្អូនវង្វែ កែវកុំសង្ស័យ ។ ចិត្តបងស្រឡាញ់
ពិត ។ ពេកពេញ ចិត្តដួងតិស្យម័យ បងឆ្លើយបន្ទូន លើន្ទូនថ្នើមថ្លៃ
លង់លុះក្បាលក្បាយ មរណ៍ម្ខួយមួលមិត្ត ។ ហើយយក្សប្រុសនោះ
ចរចូលដឹតចុះ កៀកកន្ត្រកឹត ដៃដល់ថនា ឃ្លួយាទឹមដ្ឋឹត យក្ស
ស្រីតាំងកិត អៀនខ្មៅកក្តា ។ ពិព្រួចព្រមច្បាណ រួមរសស្នោះ
ស្នាន ដឹតដំដឹងបត្ថតា អស្ចារ្យកន្ធំ ត្រែចត្រដំត្រែបផ្តា រសាយ
បុប្ផា តេសរវីកុះ ។ ព្យុះសង្ឃរា ពិរុណរំលា ស្រក់ស្រោចចម្រុះ
នាគពដពេនពន់ ក្រួញអង្គត្រដុះ ខុនក្បាលលួនចុះ ចូលរូងបត្ថតា ។
ព្រួសពិសអង់អាច សំដែងអំណាច ឥតខ្លាចនរណា ក្អែពិសពោរ
ពាស ទីសាសត្រៀបត្រា ពេញរូងបត្ថតា ហើយសម្ងំដែក ។

ស្នេរឿងយក្សខ្ទុក ថ្ងៃឆតសៅមុខ អំពីចចក ដេកកន្ត្រាគោហា
ដូចពណ៌ាមក ភ្ញាក់ខ្លើងរ៉ែរក គិតក្នុងចិត្តថា ។ បើអញជាស់ញី
ច្បាយច្បាប់អំពី ដំណើរអញណា ត្រែងញ៉ាយាត់ច្បាណ រំខានអាត្មា
នាំស្ពុនយាត្រា មិនដូចចំណង់ ។ ត្រូវអញលបរត់ ចេញចាកច្បា-

កដ សោះតើតសៅហ្មង ចចកគិតច្នោះ លបស្ទុះចេញហោង
ដើរស្រែតរំលង ដល់ជ្រោះបឡាត ។ ឃើញយក្ខិនី ប្រែច្បាណតន្ទ្រិយ
ជាខ្មោចមាយា កិតញ៉ែរចំប្រប់ សែងសប់ពេមា ចចកម្ចីម្នា ឡើង
លើថ្នាង ។ ឆ្មេចក្អែកលោតចុះ ធ្លាក់ក្នុងបាតជ្រោះ បាក់កអាត្មា
ក្សណក្សយដីវ៉ែ យក្សស្រីខោះណា ឃើញហើយផ្ទះថ្ងា ក្រែក
ឈរឡើងពំ ។ (មានត)

រឿងនេះបានគតិដូចម្តេច ?

រឿងព្រៃឥនេះឯងកំផ្លែងមែន តែមានត្រាំដែនល្អណាស់ណា
ហើយបានគតិគួរផ្ទះថ្ងា លោកអ្នកទស្សនាគួរកាន់យក ។
សម្រាប់កំពាត់សេចក្តីលោក កុំឲ្យចិត្តល្មោកដូចចចក
ព្រោះអ្នកលោកលន់តតស្រុតស្រក តែងខកខូចខ្លួនខានបានល្អ !

ចាប - ពិន

ក្លែសតូឡូហ្សែន

រឿងព្រេងប្រទេសរ៉ូម៉ានី

លោក ផេង-ជ្រើរ នៅក្រសួងយោសនាការជាតិ

ប្រែចាកសៀវភៅ កុង អេ ឡេ សង់ដ៍ ដឺរ៉ូម៉ានី

(Contes et légendes de Romanie)

រឿងនេះជាដីរបៃវត្តិនៃបុរសកំសត់ម្នាក់ឈ្មោះ តូឡូហ្សែន ។

កន្លងកាលកន្លងទៅហើយ គេដំណាលថា មានតាចាស់ម្នាក់មានតែកូនប្រុសមួយ ។ ថ្ងៃមួយ តាចាស់និយាយទៅកូនថា:

– នែកូន! ឥឡូវត្រែវតែកូនរកគូស្រករឲ្យហើយ ។

ការណ៍ហ្នឹងពិតណាស់ ដ្បិតមាណពនោះមានអាយុកាន់តែចំនួនហើយ ។

កូនឆ្លើយថា:

– ន៎! បើឪចង់រកប្រពន្ធឲ្យខ្ញុំ ក៏រកចុះ ប៉ុន្តែ ខ្ញុំនឹងទៅរកជណ្តឹងនាវណាឲ្យសមគួរ?

– រឿងហ្នឹង កុំព្រួយកូន? មានគេនិយាយច្បាប់ឪថា នៅភូមិឯណោះ មានកូនស្រីរបស់ត្រកូលមួយជាធីតាខោល ហើយមុខជាខ្ជាប់ចិត្តដល់កូនឯងជាក្បាកដ ។

– ប្រហែលមែនហើយឪ! ប៉ុន្តែ ដែលនឹងទៅរកជណ្តឹងនាងនោះតើនឹងទៅភ្លាមដោយដៃទទេឬ?

— កូន ! ចូរឯងកុំបារម្ភ យើងតាំងពីនោះទៅដណ្តឹងជាមួយគ្នា ។

ហើយតាចាស់ទឹងកូនទាំងគ្នាទៅកូមិនោះ ចូលក្នុងផ្ទះនិយាយការ ។ ឥតុកម្តាយខាងស្រីយល់ព្រមឲ្យ ។ មិនយូរប៉ុន្មានអាពាហមង្គលក៏មានធ្វើឡើង ។ ចំណែកកូនប្រសាស្រីមកនៅជាមួយតាចាស់ ។ ប៉ុន្តែខាងកុមារីកានេះមិនមែនជាការសុចរិតឡើយ គឺបានតែអាការខាងក្រៅ ត្រង់ចិត្តគំនិតជាស្រីក្បត់ ។

ចំណែកតាចាស់ជាអ្នកមានសម្បត្តិឲ្យ គឺមានសត្វពាហនៈកំប្រើនប្រាក់កំប្រើន ។ ថ្ងៃមួយ កូនប្រុសគាត់សំគាល់ឃើញរំពាត់ខ្សែតែមួយ ព្យួរនៅទឹងជែកគោលត្រង់ក្បាលដំណេកឥតុក ។ រំពាត់នេះឪកជាគ្រឿងលំអផងទឹងជាការពិតផង ។ គឺជាវត្ថុមានប្រយោជន៍ដ៏សំខាន់ក្នុងផ្ទះ ។ ហើយរឿងរំពាត់នេះមិនមែនមកស្តែតែម្តុំណេះទេ អ្នកអានទឹងឃើញទៅមានតទៅទៀត ។

កូនសួរឥតុកថា :

— លោកឥតុក ! ខ្ញុំបានឮដំណឹង តើរំពាត់នេះឪកសម្រាប់ធ្វើអ្វី ?

— ម្នាលកូនប្រុស ! រំពាត់នេះ ជារំពាត់មន្ត ។ ឥមិនបាននិយាយរឿងនេះប្រាប់កូនឯងតាំងពីនោះដល់នេះ ។ ឥឡូវនឹងប្រាប់ឲ្យកូនដឹងព្រោះឥឡូវនៅតែចាស់ណាស់ហើយ ឯអាយុសង្ខារក៏មិនទៀង ។

« នែកូន ! រំពាត់នេះ កូនត្រាន់តែលើកឡើងរលាស់ ៣ ដង កូនចង់ប្រាថ្នាយ៉ាងណា ទឹងសម្រេចយ៉ាងនោះ ។ កូនចង់បានប្រាក់ តើតប្រាក់, ចង់បានសត្វពាហនៈ តើតសត្វពាហនៈមួយរំពេចនៅចំពោះមុខ

ហាក់ដូចជាវត្ថុតាំងនោះចេញមកពីផែនដី ។ កូនឃើញគាត់រលាស់លើមនុស្សដោយមានគំនិតចង់ឲ្យក្លាយជាខ្មែ មនុស្សក្លាយទៅជាខ្មែក្លាម ។ កូនចង់ឲ្យខ្មែនោះក្លាយជាមនុស្សវិញ ? ចូររលាស់ក្លាម ។ ពន្លឺឆ្លុះចេញដូចចិត្តចង់ ។

" ឥឡូវ ខ្ញុំត្រូវច្រៀបចំណោះមួយទៀត តែកូនឯងកុំនិយាយរឿងនេះច្រៀបច្រពន្ធឯងឲ្យដឹង ។ តែច្រៀប ទោះបីច្រពន្ធកូនឯងជាស្រីមានអាការជាអ្នកសុចរិតក៏ដោយ ក៏គង់តែទោរទន់ទៅរកអំពើទុច្ចរិតបានហើយកុំសង្ស័យអំពីគ្រោះថ្នាក់ គឺមុខជាកូនឯងនឹងបានជួបច្រទះ . . . ។

" នេះជាបណ្ដាំចុងក្រោយ ហើយនេះគេញស្ទុះតែមាសនឹងច្រាក់ ចូរកុំឲ្យកូនសោទៅច្រពន្ធកូនឯងឲ្យសោះ " ។

មិនបានប៉ុន្មានថ្ងៃ តាចាស់ក៏បិទភ្នែក ហើយចែកស្ថានទៅកាន់បរលោក ។ កូនគាត់ធឹងកូនច្រសាយកខ្មោចតាចាស់ទៅកប់ទុកដាក់តាមច្រពៃណី ។ រួចស្វាមីកាយោទៅគប់គ្រងផ្ទះតែពីរនាក់ ។ ប្តីតែងទៅធ្វើការងារច្រកបដោយសកម្មភាពជានិច្ចកាល គឺទៅរកកាប់ឫសក្នុងព្រៃ មកឯផ្ទះកិនស្រូវបុកអង្ករ គឺថាគ្មានទៅនឹងមួយកន្លែងឡើយធ្វើការដូចខឹកកំពុងហូរ ។ ចំណែកច្រពន្ធក៏ធ្វើការទៅឯផ្ទះណាស់ដែរ ។ ប៉ុន្តែ ទោះបីដូច្នោះ ក៏គង់ឥតទៅជាស្រីចំកួត តែងមានគំនិតអាក្រក់ក្នុងខ្លួរក្បាល ។ ឥតែងនឹកថាអាជីវកម្មរបស់ឥតឆ្លុះពេក ហើយប្តីមិនដែលនឹកនាឆ្លងទាំទៅកំសាន្តចិត្តត្រង់កន្លែងណាបានម្តងសោះ ។

មានមួយថ្ងៃ នាងកាយោនិយាយគ្នាញ៉ែនច្រៀបអ្នកជិតខាងម្នាក់ដែលឈ្មោះ

ជាមនុស្សចិត្តអាក្រក់ ហើយឈ្មោះនិះដល់ទៅឮសម្បត្តិអ្នកជាទៃ ។ ឮនាងនោះនិយាយដូច្នោះ មិនគិតពោលបង្អាបឲ្យផង ក៏គិតតែចាក់រុកឲ្យជុតឲ្យកាន់តែឆេះច្រើនៗឡើង ។ គ្រាន់តែប្តីឯងចេញ អានោះមកវល់ភ្លាម ក៏ចាំងពីនោក់ទាំគ្នាគិតតែដេរប្រទេចនឹងប្រពឹត្តអំពើក្បត់ ។

ចំណែកប្តីគិតតែពីធ្វើការងារ មានគំនិតសុចរិត មិនបានដឹងថាប្រពន្ធអាត្មាបែកចិត្ត មិនវល់ទឹងខ្លួន ហើយធ្វើការកន្ដឹងផ្ទះចាំងបង្គំទេ ។

ថ្ងៃមួយ ប្តីទៅចំការ អានោះក៏មក ឃើញរំពាត់ខ្សែតីព្យរនាំនឹងដែកគោល ។ ក៏សួរថា :

— ចុះរំពាត់ហ្នឹង គេទុកសម្រាប់ធ្វើអ្វី ?

— អើ ! ខ្ញុំមិនដឹង ។

— ចូរសួរប្តីនាងមើល គាត់ទៀងតែដឹងរឿងជាពិតប្រាកដ ។ ហើយប្រសិនបើគាត់មិនប្រាប់ នាងឯងធ្វើជាខឹងហើយតេះទៅផ្ទះទុតកាយនាង នោះនាងប្រាកដជានឹងបានដឹងរឿងអ្វីមួយជាមិនខាន ។

លោលួចប្តីត្រឡប់មកផ្ទះវិញ ឃើញប្រពន្ធកំពុងធ្វើការរៀបចំឲ្យប្តី ជាការដែលក៏មិនដែលធ្វើសោះពីដើម ព្រមទាំងនិយាយបង្គន់លោមបំពេញទឹកចិត្តយ៉ាងអស្ចារ្យ ។ ជាទីបំផុតប្រពន្ធសួរប្តីថា :

— អ្នកបងសំណាញ់ ! សូមស្តាប់ប្អូន។ បងសួរបន្តិច រំពាត់ព្យរនាំងដែកគោល សម្រាប់ប្រើការដូចម្តេច ?

— នុះគ្នាអើយ ! អីចឹងក៏ចាំសួរដែរ រំពាត់ជារំពាត់ទេតើ . . . ។

— ចុះហេតុអ្វីក៏អ្នកមិនបងាប់ប្រាប់ប្អូន ?

— នែនាង ! ចុះបង់ឲ្យបង់ប្រាប់អូនដូចម្តេច ? គឺជារំពាត់ដែលបង់គ្រាន់តែរក្សាខ្មុកប៉ុណ្ណោះទេតើ ព្រោះជារបស់កេរ្តិ៍ពីឪពុកបង់មក ។

— បង់ប្រាកដជាមិនព្រមប្រាប់ខ្ញុំឬ ?

— ចុះឲ្យបង់យកអ្វីប្រាប់អូន ? អូនឯង់ឆ្គួតទេឬ ?

មីចោរត្រាយ ឃាលបានដឹង់ថាវាមិនបានសម្រេចដូចសេចក្តីប្រាថ្នាក៏ឆ្កួជាខឹង់ ហើយវត់ទៅទៅឯផ្ទះឪពុកម្តាយវិញ ។ ប៉ីថ្ងៃក្រោយមកដោយគ្មានអ្នកណាជួយមើលសូវណាំ ជួយមើលកិច្ចការក្នុង់ផ្ទះ ប៉ុរសប្តីក៏ផ្ញាស់ឥរិយាថ្មី ហើយទៅតាមអន្ទឹរប្រពន្ធឲ្យត្រឡប់មកផ្ទះវិញ រួចនឹង មិយាយប្រាប់រឿង់សព្វគ្រប់ ។ លុះស្វាមីឥរិយាត្រឡប់មកដល់ផ្ទះហើយ ប្រពន្ធសួរថា :

— អ្នកបង់និយាយប្រាប់មក ។

— នែនាង ! រឿង់នោះដូច្នេះ រំពាត់នេះមានការណ៍សំងាត់មួយ ប្អូនាង់លើកឡើង់ហើយរលាស់ នាង់មានចំណង់យ៉ាង់ណានឹង់បានសម្រេចយ៉ាង់នោះ ។ ប៉ើនាង់បង់ឲ្យបង់ក្លាយទៅជាឆ្កែ លើករំពាត់រលាស់ឡើង់ បង់ទៅជាឆ្កែភ្លាម ។ ម្យ៉ាង់ទៀត ហឹបនេះពេញសុទ្ធតែមាស ។ នេះកូនសោ ! ប្អូនាង់ចាត់យកប្រើតាមត្រូវការចុះ ។

ប្រពន្ធឥតមានព់ចាថាអ្វីសោះ ហើយប្តីក៏គ្មានសង្ស័យអំពីបំណងអាក្រក់នៃឥរិយាខ្លួន ។ ព្រឹកឡើង់គ្រាន់តែប្តីចេញទៅធ្វើការសឹង់មិនទាន់ផុត អាសហាយមកដល់ក្នុង់ទីធ្លាភ្លាម ហើយសួរថា :

— ម៉េចទៅ អូន មានបានដឹង់ការណ៍អ្វីខ្លះដែរឬទេ ?

– ចាន់ដីន្រស្រេចអស់ បង ! ចូរបងឯងគិតចុះ ។

អាប្រុសនិយាយថា :

– ម្ដងនេះ ចូរអូនឈប់ព្រួយ យើងនឹងដាក់ឱសថឲ្យស្រឡះជាយ៉ាងឆាប់ ដើម្បីកុំឲ្យមានឧបសគ្គដល់បំណងរបស់យើង ។

ដនតាំងពីធ្វើការតស៊ូជាមួយគ្នាមក ហើយគេបានឃើញក្បែរនោះ បានក្លាយមកជាមនុស្សដោយឥតពីបាក រួចគេធ្វើឲ្យក្លាយទៅជាក្បែរវិញ ។ លុះបុរសប្ដីត្រឡប់មកផ្ទះវិញ ។ ក្រោយដែលបានដោះគេចេញពីទីម ទីឯបញ្ហាលនេះទុកក្រោមផ្ទះ គាត់បានឃើញបច្ចាមិត្តឈរនៅមាត់ទ្វារគោះគោះតែងខោដៃហើយស្រែកថា :

– ឯងពីដើមមកដល់ពេលនេះជាមនុស្សយ៉ាងណា ពីថ្ងៃនេះតទៅឯងត្រូវទៅជាក្បែរមួយឈ្មោះតូឡូហ្សែនយ៉ាងនោះ ។ រួចលោះគោះផ្ទាប់ បុរសកំសត់ក៏ក្លាយទៅជាក្បែរភ្លាម ។

បុរសកំសត់គិតតែពីត្រាស ដោយមានគំនិតគិតថា : ធ្វើដូច្នេះ គេមិនបណ្ដេញខ្លួនចេញពីផ្ទះដែលជាកេរ្ដិ៍របស់ខ្លួន ។ អាសហាយនៅក្នុងខ្ទមនោះធ្វើជាម្ចាស់កម្មសិទ្ធិធ្វើជាប្ដីដំណើរ ហើយគិតធ្វើដូចម្ដេច ឲ្យតែដីវាគាត់ក្បែរនោះប្រព្រឹត្តទៅដោយសេចក្ដីខ្នុះខ្នែនា ។

ទៅចុងបំផុត មានមួយថ្ងៃ មេគាឡាក់ណ្ដើរដាំទឹកមួយធ្នាំធំខ្លះ ហើយទៅចាក់ដុះលើក្បែរតូឡូហ្សែនកំសត់ដែលកំពុងដេកនៅមុខផ្ទះ ឲ្យបានដល់សេចក្ដីវេទនាស្ទើរខ្ទើងស្លាប់ ។

គ្រានោះ សុនខកំសត់ស្ទុះឡើងគ្រវែញខ្លួន គ្រវីក្បាលដូចឆ្កែមែន ។ ដែលគ្រវែទឹក ហើយក៏រត់ចេញបាតផ្ទះអាត្មា ។

ប៉ុន្តែ តើនឹងទៅកន្លែងណា ? តូឡូហ្សែនដើរតាមចំការតែ ទៅគ្រង់រហូតដល់កំពូលភ្នំមួយ ដែលជាកន្លែងវាលស្មៅរបស់ព្រះអង្គម្ចាស់មួយអង្គ ។ ឆ្កែអស់កំឡាំង ឃ្លានបាយ ដើរស៊ីវាតែមិនរួច ។ វាមិនហ៊ានទៅជិតផ្ទះអ្នកស្រុក ខ្លាចគេវាយទៀត ប៉ុន្តែធ្វើដូចម្តេច បើឃ្លានយ៉ាងនេះ ។

ឯណោះវិញ សំឡេងនោះ គួរឱ្យស្រងើចស្រងោចស្ទើរលួយថ្ងើមច្រមាត់ ។ អ្នកគង្វាលចៀមម្នាក់ដែលនៅថែចៀមរបស់ព្រះអង្គម្ចាស់ក្បែរនោះ ឮហើយក៏មានចិត្តរំភើបជាពន់ពេក:

— ចុះហេតុដូចម្តេច កំឆ្កែនេះលូបែកពីគេដូច្នេះ ?

អ្នកគង្វាលចៀមដេញសត្វរបស់ខ្លួនទៅត្រង់ទីនោះ ឃើញឆ្កែកំពុងលូ ហើយស្រែកស្ងួថា :

— នែ ! ឆ្កែស នែឆ្កែស !

ឮសំឡេងគេហៅ ឆ្កែសដើរចូលបន្តិច មិនហ៊ានស្ទុះចូលមកដល់ភ្លាមទេ ដើរចូលមួយដំហាន ថយចេញដំហាន ។ អ្នកគង្វាលដឹងក៏ចេះតែហៅដោយសំដីល្ងីរលោម :

— នែឆ្កែសកំសត់ ! នែឆ្កែសកំសត់ ! កុំភ័យ ចូរចូលមកគាយ មកនេះ ឆ្កែសល្អ មក ! មក ! . . . ។

ដឹងថា គេជ្រុកដជាមិនបំរុងទុរ្ខធ្វើបាបអាត្មាហើយ ឆ្កែសក៏ចូលមក ប៉ុន្តែលូនចូលដោយសន្សឹម ។ ហើយបក់កន្ទុយវិញ ដូចជាឆ្កែតាំងពួនដែល

ខ្លាចគេវាយ ។ គ្រានោះអ្នកគង្វាលចៀម យកនោតបុកមួយដុំតិចក្នុងស្បាន់ហើយចុះទៅឲ្យ ។ នោតនោះធ្លាក់ទៅប្រឡាក់ជីបន្តិច តូឡូ-ហ្សែនគ្រាន់តែហិត តែមិនស៊ី ដោយចោលក្អែកមករក ដូចជាចង់ប្រាប់ថាស៊ីមិនកើត ។ អ្នកគង្វាលឆ្ងាតដែរ ក៏យល់សេចក្តីបំណងនៃសុនខ រួចលាតស្បាន់ទៅដី ជាក់នោតបុកមួយដុំទំនិចប្រហុកមួយកន់ពីលើ (ប្រហុកជ្រាំង) ។ ឆ្កែកំសត់ ដោយសារខ្លួនជាជាតិមនុស្ស ក៏ស៊ីដូចជាមនុស្សមួយរំពេច គឺស៊ីនោតបុកមួយម៉ាត់ទំនិចប្រហុកមួយម៉ាត់ជាមួយគ្នា រួចទើបទំនាលេបទៅ ។ អ្នកគង្វាលចៀមកាត់នោតបុកទំនិចប្រហុកជាកន់ ។ រួចហុចឲ្យស៊ីទៅដែលតែឆ្កែត ។ រួចគេនាំឆ្កែទៅឲ្យដឹកទឹកឯទីជ្រោះប៉ុន្តែសុនខនេះមិនមែនលិខ ។ ដូចឆ្កែធម្មតាឡើយ គឺដឹកដូចមនុស្ស ។ រីឯល្ងាច គេនាំគាំងចៀមគាំងឆ្កែសធំល្អមកផ្ទះ ។

គេជំណាលថា ព្រះអគ្គម្ចាស់ដែលយើងនោលមកព័ទ្ធាន៍លើនេះ មានទ្រព្យសម្បត្តិច្រើនណាស់ ហើយហ្វូងចៀមក៏ច្រើន ។

ប៉ុន្តែគាំងពីប៉ុន្មានឆ្នាំមក ចចកតែងតែធ្វើទុក្ខកល់ឆ្នាំខ្លះដូរចៀមកើតកូន គឺវេលាយប់ ក៏នាំគ្នាមកស៊ីកូនចៀមអស់ ។

រឿងដូច្នេះមានមកជាយូរឆ្នាំហើយ ។ ពួកអ្នកគង្វាលចៀមនាំគ្នាឃ្លាំចាំយាមជាមួយនឹងឆ្កែគាំងឡាយក៏ឥតអំពើ ម្ល៉ោះហើយគេមិនដែលមានកូនចៀមមួយខ្លះក្នុងវេលាសោះ ។

ល្ងាចមួយ គឺជាវេនរបស់អ្នកគង្វាលចៀមដែលមានតូឡូហ្សែន ត្រូវនាំចៀមឲ្យទៅស៊ីស្មៅយប់ ។ គេយកនោតបុកវៀចមួយឆ្នាំងខ្លះ យក

ប្រហុកពីរដុំដែលដាក់សំងួតនៅលើកន រួចហៅគូកនម្នាក់ទិនថ្ពែចេញ
ទៅ ។ ចានដល់កន្លែងវាលស្មៅហើយ គេយកសម្បៀងចេញមកធ្វើជា
ចំណែកបី: សុីមួយចំណែកម្នាក់ រួចខុកមួយចំណែកឲ្យថ្ពែ ។

ថ្ងៃលិចសឹងមិនទាន់ គេឮសូរសម្រែកលូពីចម្ងាយ គឺចចកធំកូនចៀម ។ សុទ្ធតែ បណ្តោយឲ្យម្ចាស់ទិនហ្វូងចៀមទៅតែឯង ហើយ
សុះសំដៅបច្ចាមិត្ត ។

សូមអ្នកអានគាំងឡាយជ្រាប តែចចកណាមួយអើតក្បាលមក
គូឡូហ្សែនទាំត្រង់តែពាត់ម្តងឬពីរដងទម្លាក់ចោលទៅដីស្លាប់ ។ ក៏ទាំ
តែម្នាក់វាសម្លាប់អស់ចចកពាប់រយពាប់ពាន់ ។

ក្នុងនុកាសនោះ កូនចៀមគាំងឡាយនាំគ្នាសុីស្មៅជាសុខ ចំណែក
អ្នកគង្វាលដេកលក់ព្រងើយ ។ លុះពេលសងកើត អ្នកគង្វាលភ្ញាក់ឡើង
ស្រាប់តែរកថ្ពែមិនឃើញ ។ ថ្ពែមានគ្រេះថ្នាក់ដូចម្តេចទៅ? ប៉ុន្តែគ្មានអ្វី
សោះ កូនចៀមនៅគាំងអស់ សូម្បីតែមួយក៏គ្មានបាត់ផង! ហើយអ្នក
គង្វាលច្រឹកភ្នាត្នា ពុំដឹងហេតុអ្វីក៏ដូច្នេះឆ្ងើងឆ្ងល់ពេក ។ លុះថ្ងៃរះ គេ
ឃើញអ្នកគង្វាលតម្រែតមកដល់ហើយសួរថា:

- ដូចម្តេចទៅ! ឯណាកូនចៀម? ចចកសុីអស់ទៀតទៅហើយ
មែនឬទេ?

- គ្មានអ្វីទេ! សូមលោកមើលចុះ! ក់តំពុងសម្រាកដេកចំពាអៀង ។
ប៉ុន្តែ ខ្ញុំព្រួយពេកអំពីថ្ពែខ្ញុំ ក៏ទៅចាត់តាំងពីល្ងាចម្សិលម្ង៉ៃ ហើយខ្ញុំ
ចាំមើលមិនឃើញវាមកវិញសោះ ។

កំពុងតែនិយាយគ្នា អ្នកគង្វាសចៀមស្តាប់ឮសំរែកលូព័ចម្ងាយ ។ ទំនៀងស្តាប់ស្រួលបួល ម្ចាស់សុនខឆ្លើយថា:

- ហ្នឹងហើយឆ្កែរបស់ខ្ញុំ ។

រួចអ្នកចាំងពីរដើរឆ្ពោះទៅទីនោះ ។

តើគេបានឃើញអ្វី? តូឡូហ្សែនឆ្កែសបានសម្លាប់ចចកងាប់គរលើគ្នា ហើយឡើងទំព័លើស្រែកហៅម្ចាស់ ។ លុះឃើញដូច្នោះ អ្នកគង្វាលជាម្ចាស់មានចិត្តត្រេកអរកម្រៃប្រៀបគ្មាន ។

អ្នកគង្វាលជាទៃក៏មានសេចក្តីស្រួលចិត្តដែរ ដោយឃើញថាតាំងពីពេលនេះទៅ មានឆ្កែធំយ៉ាងពូកែ ដើម្បីការពារហ្វូងចៀមរបស់ពួកគេបន្តិច ហើយគេនាំឆ្កែសកំសត់នេះរហូតដល់ទីក្រោលធំ ។ ម្ចាស់ឆ្កែនិយាយថា "ឆ្កែនេះមិនមែនដូចជាឆ្កែឆន្ទាំងពួនលើផែនដីទេ" ហើយបោលថែមទៀតថា: ឆ្កែនេះមិនត្រូវចិញ្ចឹមដោយម្សៅតែតឹមប្រហុកទេ បើតាមសុចរិត ត្រូវចិញ្ចឹមវាដោយខ្លឹកដោះខាប់ ។ ចំណែកអ្នកគង្វាលទាំងប្អូនថែរក្សាឆ្កែនោះតែរៀង ។ ខួន ។

ចំណែកព្រះអង្គម្ចាស់ជានាយចៀវហ្វាយនៃអ្នកគង្វាលទាំងឡាយមានអាថ៌កំបាំងមួយក្នុងដំណាក់ជាធម្មតា ។ ពាល់ឆ្នាំតរៀងរាល់ខួងតែងប្រសូតកូវកមួយមានរូបឆោមយ៉ាងល្អ ទៅវិលាគណ្ណាលអធ្រាត្រ ។ ប៉ុន្តែលុះត្រឹកឡើងកូវកទៅណាបាត់ ព្រះនាងជាតរិយានឹងព្រះអង្គម្ចាស់មានព្រះហឫទ័យព្រួយកេរិ៍ចំផុតគ្មាន ។

(មានត)

កំណត់ធំធ្វើប្រវត្តិការណ៍

តំណើរបុណ្យឆ្លងជាព្រះសព

សម្តេចព្រះសុធម្មាធិបតី អ៊ុំ - ស្រ៊ី សង្ឃនាយកគណៈធម្មយុត្តិ

លោក ឯន - ប៉ង់ រៀបរៀង

តំណើរបុណ្យនេះ មានកម្មវិធីច្រើនបែប តែយើងមិនបានរៀបរៀងតាំងអស់ទេ យើងរៀបរៀងជាសេចក្តីសង្ខេបដូចតទៅនេះ៖

ក្នុងថ្ងៃទី ៦ តុលា ១៩៥៦, នៅយ៉ាសាលាបណ្ឌិត ក្នុងវត្តបទុមវតីរាជវរាម សង្កាត់លេខ ៤ ក្រុង មានធ្វើពិធីបុណ្យរំកិលព្រះសពសម្តេចព្រះសុធម្មាធិបតី សង្ឃនាយក គណៈធម្មយុត្តិ ព្រះនាម អ៊ុន - ស្រ៊ី ដើម្បីហែទៅបូជានៅព្រះមេរុ ឮដំណឹងដើរព្រះបរមរាជវាំង ។

ក្នុងឧកាសនោះ យើងសង្កេតឃើញការជួបជុំនៃឥស្សរជនជាន់ខ្ពស់ដែលមានលោកប្រធានសភាតំណាងពីរ, សមាជិកពហុរដ្ឋាភិបាល, អនុរដ្ឋលេខាធិការជាដើម ព្រមទាំងឧបាសកឧបាសិកាក្នុងក្រុងទឹងត្រែក្រៅជាច្រើន ឈរតាំងចាំជូនព្រះសពសម្តេច ។

នៅម៉ោង ១៤ គត់ សម្តេចចៅហ្វាវាំងវរៈវៀងជ័យអធិបតីស្រង់វ៉ែន - ឌុត ក្នុងឋានៈជាព្រះពាជតំណាងព្រះករុណាជាអម្ចាស់ជីវិតលើត្បូងអញ្ជើញមកដល់ ។ ឯកឧត្តមញ៉ឹក - ឌូវ ចាន់ហ្វាង៉ពិធីការនៅក្នុងព្រះបរម-

ពជ្រាំង ក៏បានចាត់ចែងពិធីរកិលព្រះសពចេញពីសាលាបិណ្ឌ មកដំកល់នៅលើរថយន្តដ៏វិចិត្រ ហើយចាត់ក្បួនហែជាសង្ខាត់ជាជ្រួយ៉ាងល្អឥតខ្ចោះតាមលំដាប់លំដោយ ហើយជង្រែកៅតាមវិថីបទុមរតី, មហាវិថីព្រះបាទសុភម្រឹត, មហាវិថីព្រះបាទនរោត្តម, វិថីព្រះអង្គមឃរ័ន ទំនឹងមហាវិថីសុធាវាស បត់ចូលមកកាន់ព្រះមេរុ ហើយលើកព្រះគោដ្ឋសែងជង្រែប្រទក្សិណព្រះមេរុ ៣ ដុំ រួចនិមន្តព្រះសពកៅដំកល់លើបញ្ជា ៥ ជាន់ ។

ដល់ម៉ោង ១៦, ៤០ នាទី សម្តេចក្រុមព្រះស៊ីសុវត្ថិ - មុនីរ័តទេសរដ្ឋមន្ត្រីទទួលការៈខាងក្រសួងការពារប្រទេស ទំនំសំអាតពជ្រាំងខួងកៅតាមទាំងព្រះពជ្រាង្គទុង្ស, គណៈរដ្ឋមន្ត្រី, អនុរដ្ឋលេខាធិការ, ប្រធានសភាទាំងពីរ ទំនងាម៉ឺនសព្វមុខមន្ត្រីខ្មែរ-បរទេស ស្តេចយាងទំនំអញ្ជើញមកវេរចាំទទួលព្រះសពនៅឯព្រះពន្លាខាងត្បូងព្រះមេរុ ។

លុះដល់ម៉ោង ១៦, ៥០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទំនំសម្តេចព្រះទេបយុវរាជ ខ្ចប់ស្តេចយាងមកដល់ ។ គណៈខោះពួកឥស្សរជនបានស្តេចយាងទំនំអញ្ជើញកៅទទួលព្រះអង្គ ។ រួចហើយមហាន្តក្រមរក្សាព្រះអង្គទំនំកងវរមក្ងូមទ្ធឈរវ៉ាខ្ញាគោរព ទាំងក្រមក្ងើតបន្ទូបទនគរពជគោរពថ្វាយជាព្រះកិត្តិយស ។ បន្ទាប់មកគេនិមន្តសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកធាក រួចនិមន្តព្រះសង្ឃវត្ត-ខណ្ឌាសោម ៨៩ អង្គចំរើនសត្តបរិកវណ៌ ។

តមក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សមាជិកខត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ, ប្រធានសភាទាំងពីរ, សមាជិករដ្ឋាភិបាល, អនុរដ្ឋ-

ធិការ, មន្ត្រីតាហានទំនង់មន្ត្រីស៊ីវិលខ្មែរ-ចរៈទេសឯទៀតជាច្រើន ជាន
ទ្រង់ស្តេចយាងទំនង់អញ្ជើញឡើងទៅលើព្រះមេរុ ដើម្បីគោរពព្រះសព ។
រួចកិច្ចសព្វគប់តាមកម្មវិធីហើយ ទ្រង់ស្តេចយាងទៅកាន់ព្រះបរមរាជវាំង,
ព្រះរាជតំណាក់ ទំនង អញ្ជើញទៅកាន់គេហដ្ឋានរៀងខ្លួនវិញ ។

ក្នុងថ្ងៃទី ៧ តុលា ១៩៥៦ ជាថ្ងៃទី ២ នៃពិធីបុណ្យព្រះសព មាន
ការនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត ក្នុងវេលាយប់, ទំនងព្រឹកឡើងវេរ-
កត្តាហារប្រគេនព្រះសង្ឃ ។

ក្នុងថ្ងៃទី ៨ តុលា ១៩៥៦ នៅថ្ងៃទី ៣ នៃពិធីបុណ្យព្រះសព នៅ
វេលាយប់ជានិមន្តព្រះសង្ឃចំរើនព្រះបរិត្ត ព្រឹកឡើងវេរកត្តាហារដូច
ថ្ងៃទី ២, ប៉ុន្តែពេលព្រឹកនោះ មានធ្វើពិធីរំលឹកព្រះសពជុំចាក់ទឹកបញ្ចា
ទៅដាក់នៅថែវាងលិច ហើយរៀបបញ្ចាសម្រាប់បូជាព្រះសព រួច
និមន្តឡូតគោដង្កាំលើបញ្ចាព្រះមេរុវិញ ។

នៅម៉ោង ១៦, ៣០ នាទី មន្ត្រីព្រះសង្ឃគាំង៣រូប, ព្រះភជ-
វង្សាទុវង្សដែលមានសម្តេចក្រុមព្រះមុនីរ៉ែតជាដើម ទំនងវេនខ្មែរបរទេស
ព្រមទាំង១ជាសក១ជាសិកាជាច្រើនពាន់នាក់ ជានិមន្តជាន់ស្តេចយាង
ទំនងអញ្ជើញមកណែនណាន់តាន់តាប់កំពង់ឈ្លាលព្រះមេរុ ។

ដល់ម៉ោង ១៧ គត់ ព្រះករុណាជាអម្ចាស់ដ៏វិតលើត្បូង, សម្តេច
ព្រះមហាក្សត្រិយានី ទំនងសម្តេចព្រះនរបយុវភជ ជានិមន្តស្តេចយាងមក
ដល់ព្រះមេរុ ។ ឯកនុគ្គម ញឹក-នូវ ចាង់ហ្វាង ព្រះភជពិធីការព្រះបរម-
រាជវាំង ជានិមន្តថ្វាយសុន្ទរកថាមួយ តាងនាមនៃព្រះភជវង្សាគិបាល ស្តីអំពី

ប្រវត្តិរូបនៃសម្តេចព្រះសុធម្មាធិបតី អ៊ុង - ស្រី, ព័ស្ថាព្រះមហាស្តូកឯកកិច្ច ឧបត្ថម្ភព្រះពុទ្ធសាសនារបស់សម្តេច ។

លុះចប់សុន្ទរកថាហើយ ព្រះគុណាជាអម្ចាស់ដ៏វិតលើត្បូង, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជ ទើងសម្តេចក្រុមព្រះមុនីរ៉ែត ចាន់ខែង់ស្តេចយាង់ទៅកាន់បញ្ជាសម្រាប់បូជាព្រះសព ដើម្បីខែង់ស្តេចប្រគេនផ្កាខ្ទឹមចន្ទន៍ ។ ឯវេជនឯទៀតមានប្រធានសភាទាំង ពីរជាដើម ចាន់អញ្ជើញប្រគេនផ្កាខ្ទឹមចន្ទន៍ជាបន្តបន្ទាប់មក ។

កន្លងថ្ងៃទី ៨ តុលា ១៩៥៦ ជាថ្ងៃទី ៤ នៃពិធីបុណ្យព្រះសព, វេលាម៉ោង ៦, ៤០ នាទី មានការនិមន្តព្រះសង្ឃ ៤ អង្គចំរើនសត្តបរិកណ៌ ប្រែព្រះរូបប្រែគេនពរទឹកស្រែព្រះអដ្ឋិ ដែលមានវេជនព្រះសង្ឃទើងគហស្តឯទៀតជាច្រើន ចាន់និមន្ត - ស្តេចយាង់ទើងអញ្ជើញទៅស្រែព្រះអដ្ឋិដែរ ។ កន្លងពេលចប់កិច្ចស្រែព្រះអដ្ឋិតាមប្រពៃណីហើយ, វេលាម៉ោង ១០ មានការវេរគ្គាហារប្រគេនព្រះសង្ឃចំរើនព្រះបរិត្ត រួចនិមន្តធម្មចិកមួយអង្គសំដែងបឋមត្រាស់ ទាំងនិមន្តព្រះសង្ឃ ៤ អង្គសូត្រពុទ្ធាភិសេករហូតដល់ថ្ងៃ ។

កន្លងថ្ងៃទី ១០ តុលា ១៩៥៦ ជាថ្ងៃទី ៥ នៃពិធីបុណ្យព្រះសព, មានធ្វើពិធីនិមន្តព្រះឆាតុប្ទិសចាកបញ្ជា ហើយដង្ហែរឆ្ពោះទៅកាន់វត្តបទុមវតី ដើម្បីបញ្ចុះក្នង់ព្រះចេតិយធំ ដែលមានវេជនជាបព្វជិតនឹងគហស្តទាំងឡាយចាន់និមន្ត, ស្តេចយាង់, អញ្ជើញទៅដួបជុំក្នុងពេលខោះផង ។

នៅម៉ោង ៨,៣០ នាទី ព្រះគុណាជាអម្ចាស់ដ៏វិតលើត្បូង ទើង

សម្តេចព្រះមហាក្សត្រិយានីបានស្តេចយាងមកដល់ ដោយមានសម្តេចព្រះឧបយុវរាជ, សម្តេចទៅហ្វាំងវ៉ាវៀងដ័យ, ប៉ែន-ខុត សមាជិកឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រជាដើមហែហមព្រះអង្គផង ។

ក្រោយដែលព្រះមហាក្សត្រ ទាំងពីរព្រះអង្គទ្រង់ស្តេចគោរពក្បែងជាតិ, សម្តេចព្រះឧបយុវរាជលើកព្រះធាតុយកទៅបញ្ចុះក្នុងព្រះចេតិយធំហើយនិមន្តព្រះសង្ឃ ៨ អង្គនាក, ៨៥ អង្គទៀតចំរើនសត្តបរិត្តរណ៍ ។ ព្រះកុណាជាអម្ចាស់ដីតែលើកប្លង់ ទឹងសម្តេចព្រះមហាក្សត្រិយានី បានទ្រង់ស្តេចយាងឡើងទៅថ្វាយបង្គំព្រះធាតុ, ទៅកាន់ព្រះចេតិយតាមប្រពៃណីព្រះពុទ្ធសាសនា ។ លុះចប់កិច្ចសព្វគ្រប់ហើយ ព្រះមហាក្សត្រទាំងពីរព្រះអង្គបានស្តេចយាងចូលព្រះបរមពដាំងវិញ ។

ដល់វេលាម៉ោង ១០ តត់ មានការរៀបចំតែប្រគេនព្រះសង្ឃ, វេលាម៉ោង ១៣ និមន្តធម្មចិក ៣ អង្គសំដែងធម៌ទៅកាន់វិហារវត្តបទុមវតី ជាកិច្ចបញ្ចប់ពិធីបុណ្យតែប៉ុណ្ណោះ ។

ពិធីបុណ្យព្រះសពនេះ ក្រោមព្រះពាជាធិបតីភាពនៃសម្តេចព្រះមហាក្សត្រទាំងពីរព្រះអង្គ មានសេចក្តីរុងរឿងសមរម្យតាមប្រពៃណីព្រះពុទ្ធសាសនាយ៉ាងក្រៃលែង ។

ឯសុន្ទរកថានៃឯកឧត្តម ញឹក-ខូវ យើងបានដកស្រង់យកមកបុកគង់ទីនេះ ដោយឥតមានកែប្រែទេ ដូចតទៅនេះ ៖

សុន្ទរកថា ឯកឧត្តម ញឹក - ឆ្លឺរ

ជាតំណាងព្រះរាជពិធីការនៅព្រះបរមរាជវាំង

សូមព្រះតេជះដ៏ពេលលើសល្បឿន !

សូមព្រះពរជាន់ក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ជីវិតលើសល្បឿន !

- ជ - សម្តេចព្រះមហាក្សត្រិយានី !

- ជ - សម្តេចព្រះទេបយុវរាជ !

សូមទ្រង់ជ្រាបគ្រាមល្អន់ធួលីព្រះបាទ ។

តាងនាមនៃព្រះរាជវង្សានុវង្ស ខ្ញុំព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយនូវអំណរដ៏ជ្រាលជ្រៅ ដែលទ្រង់ព្រះមេត្តាប្រោសស្តេចយាងមកជាព្រះរាជាធិបតីក្នុងពិធីបូជាព្រះសពនៃសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកព្រះនាម អ៊ុង - ស្រី ក្នុងវេលានេះ ។

បន្ទាប់ពីនេះ ខ្ញុំព្រះបង្គំជាខ្ញុំសូមព្រះពរជាន់ព្រះបរមរាជវាចាសូមថ្វាយដោយសង្ខេបនូវប្រវត្តិរូបនៃសម្តេច អ៊ុង ស្រី ដូចមានសេចក្តីតទៅ៖

សម្តេចព្រះសុធម្មាធិបតីសង្ឃនាយកព្រះនាម អ៊ុង - ស្រី ប្រសូតនៅថ្ងៃព្រហស្បតិ៍ ១៣ កើត ខែមិគសិរ ឆ្នាំមមែ តិស័ក ព. ស. ២៤១៤ ក្នុងភូមិស្វាយ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មាតានាម ណៃ បិតា នាម អ៊ុង ។ កាលពីអាយុ ១៣ ឆ្នាំ កុមារ អ៊ុង - ស្រី បានទៅសិក្សាអក្សរសាស្ត្រនៅវត្តស្វាយ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ក្នុងសំណាក់លោកគ្រូចៅអធិការព្រះនាម ឃួន លុះដល់អាយុ ១៩ ឆ្នាំបាន

ជួសជាសាមណេរកូនសំណាក់លោកគ្រូចៅអធិការដដែលនេះ អស់រយៈ
កាល ១ ឆ្នាំ ។ ដល់អាយុ ២២ ឆ្នាំ ចានបំពេញឧបសម្បទាជាភិក្ខុ
ការៈនៅវត្តបទុមវតីពជវរាពាម កូនសំណាក់សម្តេចព្រះសុគន្ធាធិបតី
ព្រះនាម ចាន ។

លុះឧបសម្បទហើយ ភិក្ខុ អ៊ុង-ស្រី ចានទិមន្តទៅគង់នៅវត្តស្វាយ
ឃុំគោកត្រប់ ជាស្រុកកំណើតរបស់លោកវិញ គឺវត្តស្វាយនេះហើយ
ដែលលោកចានចាប់ផ្តើមជាបឋមទ្វារការសិក្សាព្រះវិន័យបិដក កូនសំណាក់
លោកអាចារ្យ ពៅ គេនត្រូហស្ត ។ ក្រោយការសិក្សាអស់រយៈវេលា
៤ ឆ្នាំកូនវត្តស្វាយ ភិក្ខុ អ៊ុង-ស្រី ចានទិមន្តមកគង់នៅវត្តបទុមវតី-
ពជវរាពាមនេះវិញ ដើម្បីបន្តការសិក្សាព្រះវិន័យបិដកថែមទៀត ។

កូនរយៈកំពុងសិក្សានេះ ភិក្ខុអ៊ុង-ស្រី រមែងមានព្យាយាមជំរុញ
មុតចានទំនៀតទុកាសខ្លះ បង្រៀនព្រះវិន័យបិដកដល់សមណសិស្សពាំង
ឡាយជាច្រើនរូប រហូតដល់អស់កំណត់កាល ៣០ ឆ្នាំ ។ អាស្រ័យវិរិ-
យសម្បត្តិនេះហើយ ទើបព្រះកុណាជាអម្ចាស់ដ៏វិតលើគ្បូង ទ្រង់
សព្វព្រះពជ្ឈទ័យចោសព្រះពជ្ឈាន ទ្រង់សមណសក្តិជាលំដាប់ដូច
តទៅនេះ :

– ជាព្រះគ្រូវិន័យធម្ម ទ្រឹហានា កូន គ. ស. ១៩១០ ;
– ជាព្រះធម្មទុត្តម ទ្រឹកជាគណៈ នៅថ្ងៃទី ១ មិថុនា ១៩៤០ ;
– ជាព្រះធម្មវិរិយត្រឹទ្ធ ទ្រឹកជាគណៈ នៅថ្ងៃទី ១ វិច្ឆិកា ១៩៤០ ;
– ជាព្រះសង្ឃនាយកស្តីទី នៅថ្ងៃទី ៣០ មេសា ១៩៤២ ;

— ជាសម្តេចព្រះសុធម្មាធិបតីសង្ឃនាយក នៅថ្ងៃទី ១៩ មិថុនា ឆ្នាំ ១៩៥១ ។

ក្នុងដំរាលនៃសម្តេច, សម្តេចបានស្ថាបនាឡើងនូវអសង្ខារិមវត្ត ចាំងឡាយជាច្រើន ដូចជា: ទីប៉ាង, សាលាខួលក្បៀវ ២ ខ្នងនៅជិតទីប៉ាង ខឹងធ្វើចំញើមថ្មល់មុខវត្ត, សាលាកេសដួង ១ ខ្នងនៅជិតប៉ាង, សាលាបរិយត្តិធម្មនៃយ, សាលាចិណ្ណ ខឹងជាវរវត្តផ្សេង ១ ទៀត ដែលខួលព្រះបង្គំជាខ្ញុំ ពុំអាចនឹងរៀបរាប់ថ្វាយបានដោយសព្វគ្រប់នៅទីនេះ ។

ដោយទ្រង់ឈ្វេងយល់ខ្វះខ្តួតមប្រយោជន៍នេះហើយ ទើបសម្តេចព្រះឧបយុវរាជ កាលទ្រង់គង់នៅក្នុងសិរីរាជបល្ង័ង្កនៅឡើយ ទ្រង់សព្វព្រះរាជហឫទ័យប្រគេនចំពោះសម្តេចព្រះសង្ឃនាយក អ៊ុង - ស្រី នូវគ្រឿងឥស្សរិយយសចាំងឡាយ មានមេដាយធិបតិនូវនឹងមេដាយមាសវដ្ដកាលជាដើម ជាកិត្តិនាមដ៏វិសេស ។

សូមទ្រង់ព្រះមេត្តាប្រោស !

នៅថ្ងៃទី ២៣ វិច្ឆិកា ១៩៥៥ ជាតាពបានចូលមកញ៉ាំញីព្រះអង្គនៃសម្តេច ធ្វើឲ្យគ្រាំគ្រាទ្រុះទ្រាមទៅជាលំដាប់ពាល់ខាងី ។

បណ្តាបរិស័ទជាសិស្សានុសិស្សចាំងឡាយ ចំណែកស្នែងរកគេឲ្យហ្មដ៏វិសេសវិសាលយ៉ាងណា មកព្យាបាលរោគក៏ពុំអាចជាសះស្បើយបានឡើយ ។ ជាដំណាចនេះបានដឹកនាំព្យាធិនឹងមរណៈឲ្យចូលមកឆ្អែលផ្ចាប់ព្រះជន្មាយុសង្ខារនៃសម្តេចទៅ នៅថ្ងៃទី ៣០ មករា ១៩៥៦ ក្នុងព្រះជន្មាយុ ៨៥ ឆ្នាំ, វស្សា ៦២ ។

๔ ! មច្ចុភជដ៏ឃោរឃៅ, តុំគួរសោះឡើយអ្នកមកកាត់យកជួនវិញ្ញាណនៃសម្តេចទៅ ដោយឥតមេត្តាដល់តិចសោះ ធ្វើឲ្យយើងខំាង-អស់គ្នាជាសិស្សានុសិស្សបានទទួលទុក្ខដ៏ក្រៃលែង ទំាងសេចក្តីសោកស្តាយរកទីបំផុតគ្មានដូច្នេះឡើយ ។

ចរិយាសម្បត្តិដ៏ថ្លៃថ្លានឹងគុណប្រយោជន៍ដ៏ធំធំទាំងឡាយ ដែលសម្តេចបានបំពេញសព្វគ្រប់ដោយបរិបូណ៌ក្នុងព្រះពុទ្ធសាសនា ខ្ញុំព្រះករុណាសង្ឃឹមថា សម្តេចទទួលដោយសោមនស្សនូវផលបុញ្ញកម្មទំាងនោះតុំខាន គឺឋានសួគ៌និព្វានជាអវសាន ។

យើងខ្ញុំព្រះករុណាទំាងអស់គ្នានេះ បានជូនដំណើរសម្តេចមកដល់ព្រះមេរុនេះហើយ ។ សូមក្រាបថ្វាយបង្គំលាសម្តេចជាបច្ឆិមកាលដោយគោរព ។

សូមសម្តេចទទួលឥដ្ឋមនុញ្ញផល ដែលព្រះករុណាជាអម្ចាស់ដ៏រឹតលើសួង, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជ ព្រមទំាងព្រះពជវង្សានុវង្ស នាហ៊ុនសព្វមុខមន្ត្រី សិស្សានុសិស្សទំាងព្រះសង្ឃទីឯគ្រហស្ថ បានធ្វើបុណ្យទុទ្ទិសប្រគេនទៅ ។

ជាអវសានកថា, តាងនាមនៃព្រះពជវង្សាគតិបាល, ខ្ញុំព្រះករុណាខ្ញុំសូមព្រះបង្គំ ខ្ញុំបាទសូមអរគុណចំពោះព្រះថេរានុត្ថេរៈ ព្រះពជវង្សានុវង្សទំាងអស់លោកអ្នកដែលបានទទួលយាងអញ្ជើញមកកាន់ពិធីនេះ ។

ភ្នំពេញ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៨ លេខ ១២ ខែធ្នូ ព. ស. ២៤៩៩ គ. ស. ១៩៥៦

BIBLIOTHEQUE
Inventaire
CD

ភ័ទ្ធសុនទរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	*បញ្ជីរឿង*	*ទំព័រ*
— ពុទ្ធសាសនាសៅប្រទេសខ្មែរ (តចប់) ..	ព្រះភិក្ខុ ប៉ាង-ខាត់	១១០៣
— ក្បុរធម៌ (តចប់)	ព្រះទេពសង្គា ភ័ម-តូរ	១១២៣
— មេត្តានិសង្សកថា	ឃុនបណ្ណាគុរ័ក្ស ប៊ូ-ប៊ូ	១១៣២
ផ្នែកអក្សរសាស្ត្រ		
— អក្សរសាស្ត្រខ្មែរសង្ខេប (តចប់)	លោក វ័ណ-ប៊ុក	១១៣៧
— ពេជ្រព្រះរាជា (តមក)	លោក សុំន-ហ៊ាន ...ប្រែ...	១១៤៥
— ប្រឹងសាមកុក (តមក)	ឧកញ៉ា ន្ហូ-ហន	១១៥៣
— ប្រឹងបស្ល័ង្កទិព្យ (តចប់)	លោក វ័ណ-ប៊ុក ....ប្រែ...	១១៦១
— ឆ្កែសតុម្ភហ្សែន (តចប់)	លោក ផេង-ត្រីវ ....ប្រែ...	១១៧៨
— សាស្ត្រាបបក (តចប់)	លោក ចាប-ពិន	១១៨០
កំណាត់ទឹនប្រវត្តិការណ៍		
— បញ្ជីរាយនាមចៅអធិការវិលត់ាងថ្មី ..	ក្រសួងធម្មការ	១២០០

មួយឆ្នាំមាន ១២ សៀវភៅ - ដំឡៃជាវ ២៣០រ,០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

Page

— Le bouddhisme au Cambodge (suite et fin) . . . . . *par le Vén. . PANG-KHAT 1103*
— Kurudharma (suite et fin) . . *par le Vén. . KEM-TO . . 1123*
— Mettanisansakatha . . . . *par M. BOU-PO 1132*

PARTIE LITTÉRAIRE:

— Littérature Khmère résumée (suite et fin) . . . . . *par M. RAY-BUC 1137*
— Conte "Le Diamant de Raja" (suite) . . . . . *Traduit par M. SIN-HEAN. 1145*
— Histoire du Samkok (suite) . . *Traduit par M. NOU-KAN. 1153*
— Les trente deux récits du Trône (suite) . . . . . *Traduit par M. RAY-BUC . 1161*
— Le Chien blanc TOLOZENE (suite et fin) . . . . . *Traduit M. PHENG-CHRIV 1178*
— Histoire du loup (suite et fin) . *par M. CHAP-PIN 1190*

NOTES ET CHRONIQUES:

— Nomination des nouveaux Chau-Adhikars . . . . . Ministère des cultes *1200*

Prix d abonnement annuel (comprenant 12 numéros) 230,00

អំពីទស្សនាវដ្តីកម្ពុជសុរិយា ផ្សាយចេញអំពីពុទ្ធសាសនបណ្ឌិត្យ

ទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៥៦ ដែលអស់លោក-អ្នក បានជាវ នឹងចប់ត្រឹមវគ្គលេខ ១២ នេះហើយ ។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអស់លោក-អ្នកជាវទាំងនោះ ព្រមទាំងអស់លោក-អ្នកអានដទៃទៀតទាំងប៉ុន្មាន ។ យើងសង្ឃឹមថា អស់លោក-អ្នកនឹងចុះឈ្មោះជាវទស្សនាវដ្តីនេះក្នុងឆ្នាំ ១៩៥៧ តទៅទៀត មានចំនួនច្រើនលើសពីឆ្នាំនេះជាពុំខាន ។ កិច្ចដែលអស់លោក-អ្នកបានចុះឈ្មោះជាវទស្សនាវដ្តីនេះ ឈ្មោះថាអស់លោក-អ្នកបានជួយលើកតម្កើងប្រទេសជាតិមាតុភូមិ ផ្នែកខាងសាសនានឹងអក្សរសាស្ត្រ ឲ្យភ្លើងរុងរឿងតទៅអនាគត ។ ·

ឯអត្ថបទសម្រាប់ចុះក្នុង ទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ ១៩៥៧ ទាំងផ្នែកសាសនា ទាំងផ្នែកអក្សរសាស្ត្រ ដូចមានមាតិកាខាងក្រោមស្រាប់ ។ អត្ថបទទាំងនោះ យើងបានរើសសម្រាំងយកសុទ្ធតែល្អៗមានខ្លឹមសារជាងមុន ។ ដើម្បីជាប្រយោជន៍ក្នុងការបង្កើនវិញ្ញាទនឹងការអប់រំកាយវាចាចិត្តរបស់អស់លោក-អ្នក ។

ផ្នែកសាសនា

១ – ដំណឹងផ្សេងៗខាងព្រះពុទ្ធសាសនា ;

២ – ធម្មទេសនា ដែលមានអត្ថរសប្លែកៗ ;

៣ – សីលធម៌របស់ព្រះពុទ្ធសាសនា ;

៤ – ការជ្រើសរើសសេចក្តីប្រែក្នុងព្រះត្រៃបិដក ដែលមានសេចក្តីគួរជំនឿនឹងជាផ្លូវប្រតិបត្តិ ។

ផ្នែកអក្សរសាស្ត្រ

១ – គោលចារឹកខាងអក្សរសាស្ត្រខ្មែរ ព្រមទាំងការសិក្សាយោងចាស់ៗ ឬថ្មីនេះ ;

២ – ឯកសារ រឿងព្រាវសំខាន់ៗ ដូចសិលាចារឹកជាដើម ;

៣ – រឿងសាមកុក ទៅតែបោះពុម្ពតទៅទៀតគ្រាតែចប់ ;

៤ – សុភាសិតផ្សេងៗ របស់ជាតិយើងនឹងនានាជាតិ ;

៥ – រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់នានាជាតិ ;

៦ – រឿងទំនៀមទម្លាប់ខ្មែរ របស់គណៈកម្មការទំនៀមទម្លាប់ខ្មែរ ។ល។

ដូច្នេះអស់លោក-អ្នកដែលត្រូវការជាវ ទស្សនាវដ្តី កម្ពុជសុរិយា ប្រចាំឆ្នាំ ១៩៥៧ សូមប្រញាប់ផ្ញើទាមទារមកខាន់ក្នុងខែធ្នូ ១៩៥៦ នេះ ទៅអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព្រមទាំងដីខ្សែជាវប្រចាំឆ្នាំ បំណួន ២៣០ រៀលផង ដើម្បីពុទ្ធសាសនបណ្ឌិត្យនឹងលៃបោះពុម្ពឲ្យគ្រប់គ្រាន់តាមចំនួនដែលអស់លោក-អ្នកត្រូវការជាវ ។

ពុទ្ធសាសនបណ្ឌិត្យ

ពុទ្ធសាសនានៅប្រទេសខ្មែរ

រ៉ែយបណ្ដៅតោភិក្ខុ (ប៉ាង-ខាត់)

(ត-ចប់)

កន្លែងព្រះពុទ្ធអាណាចក្រមាន ១៤ ខេត្ត ខេត្តមួយៗ មានព្រះថេរៈមួយអគ្គជាមេគណ មានគណៈកម្មការសង្ឃគឺព្រះចៅឡាត់ ព្រះវិន័យធរ ព្រះសមុហ៍ ទទួលបន្ទុកលើសម្ដេចព្រះសង្ឃនាយក ហើយត្រួតត្រាសង្ឃក្នុងខេត្តរបស់ខ្លួន ។ ក្នុងខេត្តមានច្រើនស្រុក ស្រុកមួយៗ មានព្រះថេរៈមួយអគ្គនាទីជាអនុគណ មានគណៈកម្មការសង្ឃគឺ ព្រះវិន័យធរ ព្រះសមុហ៍ ទទួលបន្ទុកលើមេគណក្នុងខេត្ត ហើយត្រួតត្រាសង្ឃក្នុងស្រុករបស់ខ្លួន ។ ក្នុងស្រុកមានវត្តច្រើន វត្តមួយៗ មានចៅអធិការជាប្រធាន មានគ្រូសូត្រ ពីរអង្គ សម្រាប់ត្រួតត្រាកិច្ចការក្នុងវត្តរបស់ខ្លួន ទទួលបន្ទុកលើព្រះថេរៈជាអនុគណក្នុងស្រុក មានអាចារ្យគ្រហស្ថមួយរូបសម្រាប់ធ្វើការងារទាក់ទងចំពោះព្រះពុទ្ធបដិមាលើឆ័ត្រ ។ គណៈមហានិកាយនេះ ជានិកាយធំ មានវត្ត ២៧១៥ មានកិច្ចសាមណេរ ៦៦០៤២ អង្គ កន្លែង ព.ស. ២៤៩៩ ។

គណៈធម្មយុត្តិកនិកាយ មានព្រះមហាថេរមួយអង្គ ឧស្សុត ជាសង្ឃនាយក សមណសក្តិជា ព្រះសុធម្មាធិបតី ជាតួរការ ទីស្តីការ

នៅវត្តបទុមវតីរាជធានីក្រុងភ្នំពេញ មានព្រះមហាថេរមួយអង្គនាម័ជា សម្តេចឧត្តមប្រីក្សា ទ្រង់មានថេរសកាមួយនៅអមស្តីការគ្រួតគ្រាសង្ឃ-គណៈធម្មយុត្តិកនិកាយខួងទៀ ក្នុងព្រះពុទ្ធអាណាចក្រកំពង់មួល តែមិនមានមេគណអនុគណដូចគណៈមហានិកាយទេ មានតែចៅអធិការនឹងគណៈកម្មការសង្ឃ ខ្លួលស្តាប់បង្គាប់ត្រង់ពីព្រះសង្ឃនាយកជាត្បូងការហើយគ្រួតគ្រាគិតុសាមណេរក្នុងវត្តរបស់ខ្លួន ។ គណៈធម្មយុត្តិកនិកាយនេះជានិកាយតូច មានវត្ត ១០៣ វត្ត មានភិក្ខុសាមណេរ ២០៥៣ ក្នុង ព.ស. ២៤៩៩ ។

ព្រះសង្ឃទាំងពីរនិកាយនេះ មានការគ្រប់គ្រងផ្សេងដោយឡែកពីគ្នាក៏ពិតមែន តែមានការប្រាស្រ័យទៅវិញទៅមកគ្នា ប្រជុំពិគ្រោះគ្នាក្នុងកិច្ចការណាមួយធំៗ ដែលត្រូវធ្វើក្នុងពុទ្ធសាសនា ធ្វើការជាមួយគ្នា រៀនសូត្រក្នុងសាលាជាមួយគ្នា ។

ដើម្បីទំនងឲ្យការគ្រប់គ្រងព្រះសង្ឃប្រពៃថែមទៀត មានព្រះពុទ្ធ-ក្រមមួយតម្រូវឲ្យនិកាយទាំងពីរនេះ ធ្វើមហាសន្និបាតអនុស្សាវរីយ៍មួយឆ្នាំម្តង ក្នុងមួយដងបីៗថ្ងៃនៅក្រុងភ្នំពេញ ។ ក្រសួងធម្មការចាត់ចែងការនេះក្រោមព្រះរាជសាសនូបត្ថម្ភក៍ ។ ក្នុងពេលប្រជុំ សម្តេចព្រះសង្ឃនាយកប្រធានទាំងអស់រំមន្ត្រីសង្ឃត្រមទាំងភិក្ខុសាមណេរ ឲ្យចេះដឹងកិច្ចវត្តតាមពុទ្ធបញ្ញត្តិ ទំនងកិច្ចការដែលទាក់ទងនឹងពុទ្ធចក្រនឹងអាណាចក្រ ។ គណៈមហានិកាយ ធ្វើនៅវត្តឧណ្ណាលោម ក្រោមអធិបតីភាពសម្តេចព្រះសង្ឃនាយកគណៈមហានិកាយ ។ គណៈធម្មយុត្តិកនិកាយ

ឆ្ពោះទៅវត្តបទុមវតី ក្រោមអធិបតីភាពសម្តេចព្រះសង្ឃនាយកគណៈធម្ម-
យុត្ត ។ មន្ត្រីសង្ឃកងខេត្ត កងស្រុក ចៅអធិការគ្រប់វត្តត្រូវបួលមក
កាន់មហាសន្និបាតនេះ ។ ក្នុងមហាសន្និបាតអនុសំវច្ឆរៈនេះ មានប្រជុំ
ធំមួងជាផ្លូវការ គណៈសង្ឃទាំងពីរនិកាយ គណៈវជ្ជមន្ត្រីត្រូវជួបជុំនៅ
វត្តព្រះកែវមរកតពជវិហារ ក្រោមព្រះពុទ្ធជិនតិតាពនៃព្រះមហាក្សត្រ
ដើម្បីចែងដែលជាសាសនូបត្ថម្ភក៍ ជាន់ជ្រាស្រយ៉ៃរមួយព្រះសង្ឃផ្ទាល់
ព្រះអង្គ ។ ដោយការគ្រប់គ្រងសង្ឃដូចពោលមកនេះ ភិក្ខុសាមណេរ
មានអភិសមាចារវត្តសមគួរៈទៅតាមនៃន័យបញ្ញត្តិ គួរជាទីជ្រះថ្លា គួរជា
បុញ្ញក្ខេត្តពុទ្ធបរិស័ទទូទៅ ។

ការអប់រំកូនចៅ.— ប្រជាជនខ្មែរអប់រំកូនចៅតាមប្រពៃណីពី
បូពណ គឺឲ្យកូនចៅទៅរៀនទៅវត្ត ។ កូនខ្មែរៗជាព្រះពុទ្ធបុត្តក្តី
បុត្តមន្ត្រីក្តី កូនចៅប្រជាខ្មុកស្តួកក្តី ទាំងអស់តែងតែទៅរៀនទៅវត្ត
ឃត់វត្តជាសាលារៀន វត្តមួយ ។ ត្រូវបង្រៀនមុខវិជ្ជាបានគ្រប់យ៉ាង
បង្រៀនអក្សរ, នព្វន្ត, ការវេទនា, ការស្មាបនាចប្បាប់ស័ល្លធម៌ទំនឹងធម្មិកវិ
ញ្ញូសាសនា ។ កូនខ្មែរដែលបានរៀនចេះដឹងគួរសមហើយ ត្រូវបួស
ជាសាមណេរ ជាភិក្ខុ តើតទៅជាទំនៀមថា "កូនប្រុសអាយុ ១២ ឆ្នាំ
ត្រូវបួសជាសាមណេរសងគុណមាតា, អាយុ ២១ ឆ្នាំត្រូវបួសជាភិក្ខុសង
គុណបិតា" ។ បួសរហើយត្រូវរៀនសូត្រវិជ្ជាខ្ពង់ខ្ពស់តទៅទៀត រៀន
ចាស រៀនធម៌អាថព្វុទ្ធវចនៈ ។ល។ បើបានបួសជាសាមណេរជាភិក្ខុ
ហើយសឹកមកវិញ ទើបគេកាប់ថាជាមនុស្សពេញអង្គ ។ លុះសឹកមក

វិញក្នុង គេលែងហៅ អា មិន ដូចពីដើមហើយ គេឲ្យនាមថា បណ្ឌិត ប្រែថា អ្នកប្រាជ្ញ តបន្តិចមកគេហៅថា ជ្ញឹ ប្រែថា អ្នកចាស់ទុំ ប៉ើសឹកពីសាមណេរ, ប៉ើសឹកពីតិក្ខុ គេហៅថា អ្នកឃ្លាំ ប្រែថា អ្នកធ្ងំ ។ ប៉ើមិនបានបួសទេ គេហៅថា អា មិន មួយជាតិ ហើយគេមិនពាប់ជាត្រីមុខទេ ។ ប៉ើបានបួសហើយ តែខ្ជិលរៀនសូត្រ ច្បាប់ក្រមខ្មែរ បន្ទោសថា "តំដិលអៀនប្រឿន បួសហើយមិនរៀន បន្ទោសថាខ្លៅ" ។ នរណាមួយបានបួសរៀនហើយ មានចំណេះវិជ្ជាចេះដឹងច្រើនផ្ទៃ សឹកមកវិញ ព្រះពជរាជ្ញាកិច្ចាល ព្រមឲ្យកាន់មុខតំណែងសមគួរតាមការចេះដឹងរបស់ខ្លួន ធ្វើជាបណ្ឌិតភរិ ជាមន្ត្រីខាងរាជ្ញាកិច្ចាលខាងតុលាការ ។ល។ អាស្រ័យដោយការអប់រំប្រៃសើរនេះហើយ ទើបបានជាប្រជាជនខ្មែរមានចរិយាសុភាពរាបសាស្លូតត្រង់ ចិត្តថ្លៃមល្អ មិនសូវចេះបៀតបៀនញុះញង់គ្នាទេ ។

ការអប់រំប្រជាជន :– ចាស់ទុំបរមបូពណាខ្មែរ ដឹកនាំកូនចៅប្រុសស្រីឲ្យចូលដល់ទីសាលាក្នុងវត្តអារាម ឲ្យសិក្សាក្នុងព្រះពុទ្ធសាសនា មានវត្តនត្រៃយ៍ជាទំពឹងទីរឭក ឲ្យរក្សាសីល ៥ ចាំសីល ៨ ឲ្យចេះដឹង គុណូបការៈ អ្នកដ៏មានគុណមានមាតាបិតាជីដូនជីតាជាដើម ឲ្យធ្វើទក្ខិណានុប្បទានទុទ្ធិសកុសលជូនទៅបុព្វបុរសតាមកាលគួរ ។

ដើម្បីអនុវត្តទៅតាមការដឹកនាំនេះ ចាស់ទុំបានបង្កើតបុណ្យចំនៀមមួយ ហៅថា បុណ្យកាន់បិណ្ឌ ក្នុងមួយឆ្នាំម្តង ។ បុណ្យនេះធ្វើអស់ថ្ងៃវេលាកន្លះខែគិតពីថ្ងៃ ១ រោចខែកត្តិកទៅដល់ថ្ងៃ ១៥ រោច ។ តម្លៃវិធី

បុណ្យនេះ មានសមាទានសីល ៥ សីល ៨ តាមថ្ងៃ, ព្រឹក ប្រគេនយាគូ ដាក់ចូត្រវែកត្តបាយសង្ឃ, ពេលរសៀល ស្តាប់ធម៌ទេសនា ពេលយប់ ចំរើនព្រះបរិត្តមានមង្គលសូត្រជាដើម, បច្ចុសម័យ ទំមន្តព្រះសង្ឃ ស្វាធ្យាយបាកវៃសូត្រ ជាសូត្រដែលព្រះបរមគ្រូទ្រង់សំដែងឥតប្រែកពី ដែលនាំឲ្យកើតសេចក្តីវិនាស ។ ថ្ងៃសំខាន់ក្នុងបុណ្យនេះគឺថ្ងៃ ១៥ រោច ជាថ្ងៃចុងបំផុត គេហៅថា ប្រៃភ្ជុំបិណ្ឌ ។ ដល់ថ្ងៃនេះ ប្រជាជនខ្មែរទាំង ប្រទេសត្រូវទៅវត្តវៀងច្រើន ទោះបីអ្នកកើតជួបម្តេចម្តា ទីធ្លាន់ទៅវត្ត ពុំបាន បើមិនបានទៅវត្តទេ ពាក្យទំនៀមជាស់សតិថា "ដល់ថ្ងៃភ្ជុំបិណ្ឌ នេះហើយ នាយនេរិយបាលលែងសត្វនរកឲ្យមកទទួលយកចំណែក កុសល បើមាតាបិតាញាតិ ៧ សន្ធានណាមួយដែលភ្លាត់គតិទៅកើតជា សត្វនរកមករកកូនចៅគ្រប់ ៧ វត្តមិនឃើញទេ ទីធ្លាក់បណ្តាសាដល់ កូនចៅ" ។ ហេតុនេះ កូនចៅទាំងអស់មិនហ៊ានទាន់ទៅវត្តទេក្នុង ថ្ងៃនោះ ខ្លាចមាតាបិតាញាតិតាមករកមិនឃើញទីធ្លាក់បណ្តាសាឲ្យ ។ ដូច្នេះ តែដល់អាលកូតសម័យនេះហើយ ប្រជាជនខ្មែរទាំងប្រទេសទៅ បំពេញកុសលទាំងអស់នៅវត្តគ្រប់គ្នា ។

ដើម្បីឲ្យប្រជាជនចេះដឹងទសបារមីធម៌ ជាចរិយាដែលព្រះបរម-ពោធិសត្វប្រតិបត្តិកន្លងអតីតជាតិឲ្យបានត្រាស់ដឹងធម៌ ទុកជាពន្លឺកន្លងដីវិត ខ្លួនគ្រប់ៗគ្នា សម្រាប់ប្រតិបត្តិយកសេចក្តីសុខនៅនាលោកនេះ ទីលំ បរលោក ឬដើម្បីនឹងឲ្យពុទ្ធសាសនាជាបច្ចុលទៅដល់ច្បើមប្រមាត់ ប្រជាជនថែមទៀត ចាស់ទុំបានបង្កើតបុណ្យទំនៀមមួយទៀត ហៅថា

បុណ្យទេសនាមហាជាតក ។ បុណ្យនេះធ្វើទៅវៃមិគសិរគ្រែបរំភ្លឺ
តាំងអស់ ហើយធ្វើតែមួយថ្ងៃតាំងពីព្រលឹមទល់ព្រលប់ ។ ចំនៀមនេះ
គឺនិមន្តធម្មកថិកទេសនាទសជាតក គឺតិមិយជាតក មហាជនកជាតក
សុវណ្ណសាមជាតក នីមរាជជាតក កូវិទ្ទជាតក មហោសធជាតក
ចន្ទកុមារជាតក ព្រហ្មនារទជាតក វិធូរបណ្ឌិតជាតក នឹងវេស្សន្តរជាតក ។
ដោយអាស្រ័យការអប់រំធំប្រសើរនេះ ប្រជាជនខ្មែរចេះដឹងពុទ្ធចរិយា
ដែលព្រះបរមគោធិសត្វកាលព្រះអង្គចុះបំពេញទសជាតិ ហើយប្រតិបត្តិ
តាមពុទ្ធចរិយា ចេកពុទ្ធចរិយានេះជាគតិប្រចាំជីវិត ដើម្បីខ្នាន់ខ្នងឲ្យ
ប្រតិបត្តិឲ្យមានសីលធម៌ខ្ពង់ខ្ពស់ ឲ្យមានចិត្តធ្ងន់ក្នុងធម៌ ។

ចាស់ទុំចាន់ដឹកនាំឲ្យធ្វើបុណ្យដទៃទៀត មានបុណ្យស្រង់ព្រះ
នឹងបុណ្យស្រោចស្រង់មាតាបិតាត្រមាំងចាស់ទុំជាដើម ។ គេប្រែន
ធ្វើបុណ្យនេះក្នុងពិធីបុណ្យចូលឆ្នាំ ស្រីប្រុសអប់ធឹកហើយទៅស្រង់ព្រះ
ពុទ្ធរូបនៅវត្តនានាដែលទៅជិតទីលំនៅខ្លួន រួចហើយទៅស្រោចស្រង់
មាតាបិតា ជីដូនជីតារៀងខ្លួនទៀត ។ ចាស់ទុំបង្កើតបុណ្យនេះឡើង
ដើម្បីឲ្យប្រជាជនខ្មែរ ចេះគោរពដល់អង្គព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់
ដែលបង្កើតពុទ្ធសាសនានេះឡើង នាំឲ្យសត្វលោកយល់ផ្លូវទៅកាន់សេចក្តី
សុខ មគ្គ ផល សួគ៌ និព្វាន ទើបឲ្យចេះគោរពបុព្វបុរសមាតាបិតាត្រកូល
រៀមច្បង តាំងអស់នេះជាអរិយធម៌ខ្មែរដ៏ប្រសើរ តើតទៅជាចំនៀមខ្មែរ
គ្រប់រូប កាលណាដើរទៅជួបព្រះសង្ឃក្តី ទៅមុខវិហារ ចេតិយដំកល់

ព្រះពុទ្ធបូជាក្តី ត្រូវតែសំដែងអាការៈគោរព ដោះមួកលើកដៃប្រណម្យ ឬទឹកវត្តកដល់ពុទ្ធគុណ ។

ការបំពេញកុសល ... វត្តអាគមមិនមែនគ្រាន់តែជាសាលារៀនប៉ុណ្ណោះទេ ជាទីប្រជុំធ្វើបុណ្យផង ។ បុណ្យធំៗ បុណ្យតាមប្រពៃណីពុទ្ធសាសនាក្តី បុណ្យតាមទំនៀមស្រុកក្តី តែងធ្វើនៅវត្ត ព្រោះទីធំទូលាយអាចទទួលមនុស្សពាន់ពាន់បាន ។ តាមប្រពៃណីពុទ្ធសាសនា ប្រជាជនខ្មែរធ្វើមាឃបូជា វិសាខបូជា បុណ្យបំបួស បុណ្យចូលវស្សា បុណ្យចេញវស្សា បុណ្យកឋិនទាន ទីធំបុណ្យបច្ចុះសីមា ។

បុណ្យបំបួសនាគមានពាល់ឆ្នាំ ។ បុណ្យនេះត្រូវធ្វើមុនពេលចូលវស្សាគ្រប់វត្ត ។ កូនខ្មែរគ្រប់រូបត្រូវបួស ។ ព្រះមហាក្សត្រក៏ទ្រង់បំពេញព្រះជន្មសដែរ ដូចអគ្គសម្តេចព្រះឧបយុវរាជ នរោត្តម-សីហនុនេះ កាលទ្រង់នៅកុមារភាព ទ្រង់ក៏លះបង់ភាពសម្បត្តិ ៣ ខែក្នុងវេលាចូលវស្សា បួលទ្រង់ព្រះជន្មតាមប្រពៃណីពីបុពណកាលមក ។ តាមទំនៀមបុពណ ព្រះភជ-រដ្ឋកិច្ចលបានអនុញ្ញាតឲ្យមន្ត្រីភូបង់ បួលបួសកង់សំណាក់ពុទ្ធសាសនាអស់ថវិលា ៣ ខែ ដើម្បីអប់រំមន្ត្រីឲ្យស្គាល់ពុទ្ធសាសនា ដែលជាសាសនារដ្ឋនាំទៅកាន់សេចក្តីសុខក្សេមក្សាន្ត ប្រៀបដូចទំនៀមខ្មែរមិនមែនគ្រាន់តែនាំជនជាតិខ្មែរឲ្យបានសេចក្តីសុខនៅនាលោកនេះទេ នាំឲ្យជនជាតិខ្មែរមានឧបនិស្ស័យលះលោកនេះ ទៅយកសេចក្តីសុខកន្លងបរលោក ត្រូវតាំងមគ្គផលនិព្វានទៀតផង ។ កឋិនទានជាបុណ្យធំមួយ តែដល់ពេលចេញវស្សាហើយ ឃើញក្បួនហែកឋិនទាន តាមវេយ្យាវច្ច តាមកប៉ាល់

មានក្មេងលេងរាំរាល់ថ្ងៃពេញមួយវែង ។ វត្តមួយៗត្រូវមានកម្ចីនគាន មួយ, ២៨១៨ វត្ត ត្រូវមានកម្ចីនគាន ២៨១៨ ដែរ ។ បុណ្យសីមាកំពុងដែរ តែមិនសូវមានធ្វើញឹកញាប់ទេ ព្រោះមិនសូវមានវិហារកើតឡើងថ្មី ។

ព្រះមហាក្សត្រខ្មែរបំពេញព្រះរាជកុសល ក្នុងព្រះបរមរាជវាំងដូច ប្រជាជន, ខែរំសីលរាល់ថ្ងៃសីល. ខែព្រះសណ្តាប់ព្រះធម៌ទេសនា ថ្វាយសង្ឃទាន បំបួសនាគ មាឃបូជា វិសាខបូជា ចូលវស្សា ចេញវស្សា ។ បុណ្យចូលវស្សា ខែបូជាគ្រឿងសក្ការៈទៅគប់វត្ត ក្នុងព្រះរាជធានី, ចេញវស្សា ខែថ្វាយកម្ចីនគាន ខែរំស្តេចយាង ព្រមមួយអង្គៈដោយមន្ត្រីធំ-តូចទៅកាន់វត្តធំៗថ្វាយកម្ចីនចីវរ ។ ជាងពីនេះ ព្រះមហាក្សត្រខែរំបំពេញព្រះរាជកុសលតាមបុណ្យទានសមាសទៀត ដូចបុណ្យចំរើនព្រះជន្មវស្សា បុណ្យឆ្នុំចិណ្ឌ ពិធីបញ្ជាន់ត្រែស្តេ បុណ្យសំពះព្រែវែ បុណ្យចូលឆ្នាំថ្មី ។ល។

តាមទំនៀមស្រុក ដូចបុណ្យខ្ចោច ពិធីមង្គលរៀបកូនប្រុសស្រី ជាស្វាមីភរិយា បុណ្យចូលឆ្នាំថ្មីជាដើម ប្រជាជនខ្មែរធ្វើតបំពេញ កុសលទៀត ទំមន្តព្រះសង្ឃចំរើនព្រះបរិត្ត ប្រគេនភត្តាហារ ។ នៅមានបុណ្យធម្មតាទៀត ដូចទក្ខិណានុប្បទាន ចំរើនព្រះបរិត្ត ទំមន្ត ធម្មកថិកទេសនាជូនគ្នាន ។ បុណ្យទាំងនេះមានធ្វើញឹកញាប់ណាស់ ធ្វើស្ទើរតែគ្រប់ផ្ទះ ។ បុណ្យទំនៀមទំមួយៗ មានលទ្ធិពុទ្ធសាសនាជាមង្គលទាំងអស់ គឺមានសមាទានសីល ៥ ចំរើនព្រះបរិត្ត ទេសនាគ្រប់បុណ្យ ។ ប្រជាជនខ្មែរក្រីក្រទេ តែពេញចិត្តនឹងបំពេញកុសលណាស់ ទាល់តែ

មានពាក្យអ្នកបរទេសតេនិយាយថា ខ្មែរបានជាក្រមកពីធ្វើបុណ្យច្រើនពេក ។ បានជាជនជាតិខ្មែរពេញចិត្តនឹងធ្វើបុណ្យយ៉ាងនេះ មកពីយល់ថា ក្រែកចុះឲ្យតែមាន គឺមានអារ៉ែឲ្យឮៗ ។

ការលះកង្វល់.— ជនជាតិខ្មែរដល់បច្ចុប្បន្នវ័យហើយ មិនមានការប្រកបអាជីព នៅទំនេរ តែងតែពេញចិត្តលះកង្វល់ ការក្សាលស្ងៀកពាក់ស ទៅវត្តមួយខែបួនដង ដើម្បីរក្សាទុបោសឋស័ល ឬលាក្បូនទៅទៅនៅវត្តតែម្តង ឬក៏ទៅនៅព្រៃស្ងាត់ ដើម្បីចំរើនភាវនាធម៌ ។ អ្នកលះកង្វល់បែបនេះ មានច្រើនក្រាស់ក្រែលណាស់ដែរ ។ ធុរៈតាំងពីរគឺគន្ថធុរៈ ទឹងវិបស្សនាធុរៈ ប្រជាជនខ្មែរតាំងបព្វជិតតាំងគ្រហស្ថ បានបំពេញកុងបវរពុទ្ធសាសនា រកកល់ដូចសម័យពុទ្ធកាល ។ ដូច្នេះប្រជាជនខ្មែរបានបំពេញប្រយោជន៍ខ្លួន ទឹងប្រយោជន៍ជនដទៃ កងវ័យខ្លួនគ្រប់កាលតាំង ៣ គឺបឋមវ័យ រៀនសូត្រ, មជ្ឈិមវ័យ ស្វែងរកឲ្យ, បច្ចិមវ័យ ស្វែងរកកុសលធម៌ សមជាពុទ្ធសាសនិកពិតៗកុងបវរពុទ្ធសាសនា ។

ការសិក្សាព្រះពុទ្ធសាសនា.— ការសិក្សាព្រះពុទ្ធសាសនានៅប្រទេសខ្មែរមានតាំងពីបុរាណសម័យមក វត្តធំៗមានអាចារ្យបង្រៀនវេយ្យាករណ៍, គម្ពីរធម្មបទដ្ឋកថា, មង្គលត្ថទីបនី ទឹងគម្ពីរវិនយបិដកខ្លះទៀត ។ មានកិត្តិសាមណេរអ្នកសិក្សាជាច្រើនអង្គ បានសម្រេចការចេះដឹងជាន់ខ្ពស់ខាងពុទ្ធសាសនា ឡើងទៅជាព្រះមហាថេរ ជាប់ជា

តំណាតគ្នាមករហូតដល់សព្វថ្ងៃនេះ ។ ព្រះពុទ្ធសាសនាបានរៀបចំផ្នាស់ប្តូរការសិក្សាជាលំដាប់ ។ សម្រាប់តំតុសាមណេរជាសិក្ខាកាមបុគ្គលនៅក្រោមព្រះពុទ្ធបត្តម្ភគាំងអស់ដូចតទៅនេះ ៖

១- សាលាបាលីវង.- បានរៀបចំការសិក្សាទៅតាមវត្តពីដើមឲ្យទៅជាសាលាវង ជាសាលាសម្រាប់ការសិក្សាជាន់បឋម ប៉ារវេលារៀន ៣ ឆ្នាំ រៀនវេយ្យាករណ៍, ធម្មបទដ្ឋកថា, រៀនធម៌នៃយវត្រៃសិក្ខា, រៀនចំណេះវិជ្ជាផ្សេងទៀត ដូចជាគណិតសាស្ត្រ, ភូមិសាស្ត្រ ។ ល ។ សាលាបាលីវងនេះ ក្នុងព្រះពុទ្ធអាណាចក្រគាំងមូលមានចំនួន ៤២០ ។ ក្នុងមួយឆ្នាំ ។ សិស្សដែលបានរៀនគ្រប់ ៣ ឆ្នាំ ហើយប្រឡងចេញពីសាលាបាលីវងនេះមានចំនួន ២៥០០ ។

២- វិទ្យាល័យ.- សាលារៀននេះ សម្រាប់ទទួលសិស្សដែលបានប្រឡងចេញពីសាលៈបាលីវង មានវិញ្ញាបនប័ត្រ ជាសាលាសម្រាប់ការសិក្សាជាន់មធ្យម ប៉ារវេលារៀន ៤ ឆ្នាំ ។ សាលារៀននេះមានតែមួយ តាំងនៅព្រះពុទ្ធធានីក្រុងភ្នំពេញ ឈ្មោះ ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត ។ មានសិស្សរៀនចំនួន ៥០០ អង្គ រៀនមង្គលត្ថទីបនី, វិសុទ្ធិមគ្គ, បឋមសាមន្ត, កង្ខាវិតរណី, អភិធម្មសង្គហៈ រៀនវិជ្ជាផ្សេងៗ គណិតសាស្ត្រ ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ទឹនវិទ្យាសាស្ត្រ ។ ល ។ ដទៃពីនេះ មានរៀនភាសាបារាំងសែស-អង់គ្លេស-សំស្ក្រឹត ។ សិស្សដែលប្រឡងចេញពីសាលានេះ មានសញ្ញាប័ត្រចំនួនពាក់ពាន់នាក់

ហើយ ។ តទៅអនាគតនឹងមានបង្កើតវិទ្យាល័យនេះឲ្យមានគ្រប់ទាំង ១៤ ខេត្ត ក្នុងព្រះពុទ្ធអាណាចក្រ ដើម្បីពង្រីកការសិក្សាព្រះពុទ្ធ-សាសនាឲ្យធំទូលាយទៅតាមកាលសម័យ ។

៣- មហាវិទ្យាល័យ.- សាលានេះទើបនឹងបង្កើតថ្មី នៅព្រះពុទ្ធជាតិក្រុងភ្នំពេញ ពី ព ស ២៤៧៧ ឈ្មោះ ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ជាសាលាសម្រាប់ការសិក្សាជាន់ឧត្តម សម្រាប់ទទួលសិស្សដែលបានទទួលការសិក្សាពីវិទ្យាល័យមកហើយ ។ បីរវាលការសិក្សា ១០ ឆ្នាំ ។ ការសិក្សាឧត្តមសិក្សានេះ ពុំទាន់បានធ្វើនៅឡើយទេ កំពុងរៀបចំ ដើម្បីនឹងចាប់ផ្តើមរៀនឲ្យទាន់ក្នុង ព ស. ២៥០១ ខាងមុខនេះ ។

៤- សាលាធម្មវិន័យ... ព្រះពុទ្ធរដ្ឋាភិបាលបានបង្កើតសាលាធម្មវិន័យសម្រាប់កុមារសាមណេរសិក្សាព្រះពុទ្ធសាសនា នៅក្រោមការត្រួតត្រាសម្តេចសង្ឃនាយក ។ សាលានេះ សម្រាប់រៀនចំពោះធម៌និងវិន័យព្រះពុទ្ធសាសនា តែមានមុខវិជ្ជាផ្សេងខ្លះទៀត ។ សាលាធម្មវិន័យនេះ ត្រូវមានគ្រប់វត្តក្នុងព្រះពុទ្ធអាណាចក្រ ។ កុមារសាមណេរគ្រប់រូប ឬសហើយត្រូវតែរៀនខាងពុំបាន ។

ជាងនេះ ព្រះពុទ្ធរដ្ឋាភិបាលបានបង្កើតអង្គការផ្សេង ។ ទៀតសម្រាប់ជួយទំនុកបំរុងនឹងផ្សាយព្រះពុទ្ធសាសនាគឺ ព្រះរាជបណ្ណាល័យមួយ ពី ព. ស. ២៤៦៨ សម្រាប់ដំកល់គម្ពីរដីកាជាព្រះពុទ្ធវចនៈ នឹង

សៀវភៅផ្សេង ។ សម្រាប់ការសិក្សាពុទ្ធសាសនា ទឹង ពុទ្ធសាសន-
បណ្ឌិត្យ ព.ស ២៤៧៣ សម្រាប់ផ្សាយពុទ្ធសាសនា ទឹងធ្វើការ
ទាក់ទងទៅកាន់ប្រទេសពុទ្ធសាសនា ព្រមទាំងបោះពុម្ពគម្ពីរដ៏កាធមិ
អាថិផ្សេង ។ ។ ពុទ្ធសាសនបណ្ឌិត្យនេះ មានព្រះរាជក្រមមួយបង្កើត
ក្រុមដំទុំព្រឹត្តិបិដកមួយក្រុម ព.ស. ២៤៧២ ហៅថា "ក្រុមព្រះសង្ឃ-
តិកាចារ្យ" សុទ្ធសឹងព្រះមហាថេរានុត្តរ ប្រដុំរៀបចំប្រែព្រះត្រៃបិដក
ជាភាសាខ្មែរ ។ ការសង្គាយនាក្នុងគ្រានេះ ព្រះសង្ឃតិកាចារ្យឲ្យ
ឈ្មោះថា ឧត្តមសង្គាយនា ព្រោះសង្គាយនាចាំងឡាយដែលមាន
មកហើយក្នុងអតីតកាល មិនដែលមានប្រែជាសម្រាយទេ ទើបតែមាន
ក្នុងប្រទេសខ្មែរមុនដំបូងបង្អស់ក្នុងប្រវត្តិពុទ្ធសាសនាថេរវាទ ។ ដូច្នេះ
ព្រះសង្ឃតិកាចារ្យសូមទុកឧត្តមសង្គាយនានេះ ជាបដិបត្តិបូជាដ៏ខ្ពង់ខ្ពស់
ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធ ក្នុងគម្រប់សាសនាយុកាល ២៥០០ វស្សា ។

មានអង្គការផ្សេងទៀត ជាអង្គការឯកជនគឺ ពុទ្ធិកសមាគម
ពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ, មិត្តពុទ្ធិកសមាគម
វិទ្យាល័យព្រះសុរាម្រិត,សមាគមគិលានសង្គ្រោះបំពោះព្រះសង្ឃ
ចាំងអស់នេះ ជាអង្គការខំទុកបំរុងព្រះពុទ្ធសាសនា ពង្រីកផ្សាយការ
សិក្សា ទឹងធ្វើការទាក់ទងទៅកាន់ប្រទេសពុទ្ធសាសនាផ្សេង ។ សម្រាប់
ប្តូរកិច្ចការពុទ្ធសាសនាប្តូរការសិក្សា ទឹងជួយគ្នាទៅវិញទៅមក ។

ពុទ្ធសាសនាយុកាល ២៥០០ វិស្សា — ព្រះពុទ្ធសាសនា

គ្រប់ជា ២៥០០ វស្សាហើយ ប្រជាជនខ្មែរប្រឹងប្រែងតែមខ្លួនរៀបចំ
ទីធ្លើបុណ្យរំលឹកពុទ្ធសាសនាគម្រប់ ២៥០០ វស្សានេះយ៉ាងខ្លាំង
ដូចប្រជាជនរួមសាសនា នៃប្រទេសនានាដែរ ។ ដោយហេតុអ្វី ហើយ
ព្រោះហេតុអ្វី ក៏ជាប្រជាជនសាកលលោកពុទ្ធសាសនា ធ្វើបុណ្យ
រំលឹកឆ្នាំនេះ ទុកជាបុណ្យយ៉ាងធំមួយក្នុងព្រះពុទ្ធសាសនា? នេះជា
ប្រស្នាគួរជញ្ជឹងគិត ។

ចំណែកប្រជាជនខ្មែរតែងរង់ចាំនូវអតិលក្ខិតសម័យនេះ យូរយារ
ណាស់ហើយដោយសោមនស្សជាបំផុត ព្រោះចាស់ទុំរមែងជាស់តឿន
ប្រដៅកូនចៅទុកតៗគ្នាថា "តាចាស់ហើយចៅអើយ! ទំធ្លើបុណ្យទាន
រក្សាស៊ីលចៅ ឲ្យបានឆាន់សាសនា ២៥០០ វស្សាទំនឹងគេ" ប្រដៅកូន
ចៅដដែរទំប្រព្រឹត្តធ្លើល្អខ្លួនឯងផង ព្រោះខ្លួនដល់វ័យចាស់ជរាណាស់ទៅ
ហើយ ក្រែងតុំបានឆាន់ពេលវេលាដ៏ប្រសើរនេះទំនឹងគេ ដែលទំនៀម
ចាត់ទុកថាជាអភ័ព្វមួយយ៉ាងក្រៃលែង ។ អាស្រ័យដោយហេតុនេះហើយ
បានជាប្រជាជនខ្មែរតាំងក្តេងតាំងចាស់ ទន្ទឹងរង់ចាំវេកាសនេះណាស់
ព្រោះក្នុងទំនាយនានា ដែលអាចារ្យជាន់ដើមបានពោលទុកមកនោះបាន
សេចក្តីបញ្ជាក់ថា "លុះដឹតដល់ ២៥០០ វស្សាហើយ ប្រទេសខ្មែរ
ទំនឹងកើតកល់យុគវិតវៃខ្លាំងណាស់ រហូតដល់សាសនាគ្រប់បរិបូណ៌ជា
២៥០០ វស្សា ទើបព្រះបាទធម្មិកមកលើកពុទ្ធសាសនា បានសេចក្តី
សុខសប្បាយក្សេមក្សាន្តខ្លះៗទៅតាំងប្រទេស តែមានទុក្ខសោកភេតភ័យអ្វី

មួយបៀតបៀនឡើយ ប្រទេសកម្ពុជាខ្ញុំសម្បុរណ៌សប្បាយហាក់ដូចជាឋានសួគ៌ ។

ទំនាយទាំងនេះកើតកន្លងពេលដែលខ្មែរធ្លាក់ក្នុងវេទនានៃពន្ធាគារខ្មែរបានធ្វើចិត្តខ្មេរជនគ្រប់រូបឲ្យមានសេចក្តីសង្ឃឹមជានិច្ច មិនឲ្យលះបង់សេចក្តីប្រឹងប្រែង ឲ្យចេះអត់ធ្មត់តស៊ូចំពោះទុក្ខលំបាកគ្រប់ប្រការ ហើយឲ្យស្ទុះសម្លឹងទៅរកអនាគតដ៏រុងរឿងភ្លេចន៍ តុំមែនឲ្យដេកចាំព្រឹងសំណាងដោយទឹកស្រមៃរំពេចដល់ជាតថាស្នាដ៏ថ្លៃថ្នូនោះទេ គឺត្រូវឲ្យខិតខំព្យាយាមកសាងអនាគតនោះ ឲ្យកើតជារូបភាពថ្មីជាក់ច្បាស់ឡើង ព្រោះពុទ្ធសាសនាជាសាសនាហេតុផល មិនមែនឲ្យខ្មែរខ្សោយចេះតែដេកចាំព្រឹងសំណាងតែឯកសនាទេ ។ រូបភាពគាយគ្រឿងសម្បត្តិយើងជាវត្ថុអាចធ្លាក់ទៅក្នុងភាពសកាពបាន តែចិត្តគំនិតធ្លាក់ទៅតុំបានទេ តែងតែអណ្តែតខ្ពស់ផុតពីភាពសកាពជាដរាប ទឹកចិត្តបែបនេះ បានសំដែងឲ្យឃើញជាក់ច្បាស់ក្នុងពន្ធាគារខ្មែរច្រើនលើកច្រើនគ្រាមកហើយ ។ ទឹកចិត្តបែបនេះហើយ ដែលអាចញ៉ាំងប្រជាជនខ្មែរទាំងមូលៗឲ្យមានខ្នឹមសារមិនឲ្យសាបសូន្យទៅតាមកាលវិបត្តិបានឡើយ ។

បើពិនិត្យទៅតាមទំនាយ ខ្លឹមតាមស្ថានការណ៍ក្នុងសកលលោកបច្ចុប្បន្ន ក៏ឃើញថាទំនាយខ្មែរនេះ ហាក់ដូចមិនឃ្លាតចាកសេចក្តីពិតប៉ុន្មានទេ ប្រទេសខ្មែរបានចំរុងចំរើនក្នុងពេលនេះមែន ឯពុទ្ធសាសនាទៀត ក៏ជួតជាបទៅតាំងប្រទេសខ្លាំងជាងសម័យមុន ដោយការផ្សាយព្រះបរមពុទ្ធាភ្លាក់ទេញទំហឹង តាមការទេសនា ការបន្ទឿន

ធម៌វិន័យ ការបង្រៀនភាសាថ្មីៗ តាមការផ្សាយរបស់ពុទ្ធសាសន-បណ្ឌិត្យ នឹងការបង្កើតពុទ្ធិកមហាវិទ្យាល័យ ។

បើពោលតាមវង់ការនានាប្រទេសវិញ យើងឃើញថាទំនាយរបស់វ្នៃ ក៏មានទំនងស្របគ្នានឹងទំនាយនៃប្រទេសពុទ្ធសាសនានានា ក្នុងសកលលោកដែរ ជាន់មានការធ្វើបុណ្យរំលឹកពុទ្ធសាសនាគ្រប់ ២៥០០ ព្រះវស្សាដូចគ្នា ។ ឯស្ថានការណ៍ក្នុងសកលលោក យើងសង្កេតឃើញមានការប្រែប្រួលច្រើន គឺប្រែពីសភាពតឹងតែងបែរវេរទៅរកសភាពធូរស្រួល មិនសូវនាំឲ្យកើតភ្ញាក់ផ្អើលនឹងការគំរាមញែញសង្គ្រាមថ្មីនឹងផលអាក្រក់ចាំងឡាយនៃសង្គ្រាមនេះពេក ។ យើងសង្កេតឃើញមួយទៀតថា វិវឌ្ឍនភាពខាងសម្ភារនិយមក្នុងយុគបរមាណូ ពុំអាចនឹងបន្ទរបន្ទុយនូវស្ថានការណ៍តឹងតែងអន្តរជាតិបានដោយងាយទេ ផ្ទុយពីនេះ មានវែងនាំឲ្យកកើតជាអ្នកតស៊ូតវ៉ាន់ចំពោះអាវុធថ្មីនេះថែមទៀត ជាន់ជាប្រទេសចាំងឡាយបបួលគ្នាតែរិះរកមធ្យោបាយ ស្វែងរកសន្តិភាពខាងចិត្តនិយមវិញ ហើយកំពុងរិះរកវិបមន្តថ្មីមួយ ដើម្បីរួបរួមគ្នាជាមិត្តភក្តិដួយគ្នាទៅវិញទៅមកឲ្យផុតចាកទុក្ខវេទនា ឲ្យផុតចាកការព្យាបាទគ្នា រួបមន្តថ្មីនេះពិតជាកដ ‥ជាកុសលោបាយនៃព្រះពុទ្ធសាសនាសុទ្ធ។ ‥ ។

ដូច្នេះ យើងអាចសន្និដ្ឋានបានថា ធម្មិកកថ៍ព្យាករណ៍ចាំងឡាយពុំមែនជាតួបុគ្គលមានបុណ្យណាមួយ ចុះមករៀបចំប្រទេសនានាក្នុងសកលលោក ឲ្យបានសុខសប្បាយសាន្តត្រាណនោះទេ គឺជានិមិត្តរូបនៃការស្រុះស្រួលគ្នាក្នុងលោក ដោយការរកពឹងធម៌ ដើម្បីសន្តិសុខ

ទឹងការរួមចិត្តគំនិតមូលតែមួយ ដើម្បីធ្វើបុណ្យគោរពព្រះសាសនាយុកាលគំរប់ ២៥០០ វស្សា រំលឹកដល់ពាក្យទុកចំនៃព្រះបរមគ្រូដែលជាអាវុធដ៏មុតថ្លា អាចកាប់ឆ្ការខ្ទរមោហន្ធការក្នុងលោក ចំណែកបងខ្ញុំវិញតើតែបៀតបៀនតំរោលយោរយៅ ខ្ញុំវិតច្បាណ្ឌានិះសាហាវយង់ឃ្នង ទឹងខ្ញុំអំពើបងតៀរព្យាបាទគំទុំគុំគួន ដែលជាគំនរភ្លើងអសន្តិសុខឲ្យបែកក្តៅយ សាតាតអស់រ ទៅជាសតាតសំរាន្ត ហើយផ្សាយប្រគល់ខ្ញុំវិសន្តិសុខ ដែលជាទឹកអម្រិតដ៏ពិសេស ស្រោចស្រពជាជនសកលលោកតតរើសមុខ រើសពូជតង្ស រើសពណ៌សម្បុរឡើយ ។ បរិយាកាសប្រទៃដែលបានអប់ប្រែជាតរាលពី ២៥០០ ឆ្នាំ កន្ទងមកហើយនោះ ក៏ដូចជាមកប្រមកម្ញ៉ង់គ្នាតតើតខ្លើនថ្កើងពេលនេះ ម្តងនេះតុំមែនមានតែខេត្តខ្លះណាត្រឹមតែព្រំប្រទល់មធ្យមប្រទេសប៉ុណ្ណោះទេ អាចរាតលាតសន្ធឹងផ្សព្វផ្សាយខ្ទរទៅគ្រប់ទ្វីបកន្លះភ្លូគោលដ៏ពិភពលោក ដែលមានពុទ្ធបរិស័ទចំនួនប្រមាណ ៥ រយលាននាក់តំពូនសោមនស្សរីករាយគោរពបូជាព្រះសម្មាសម្ពុទ្ធផ្សាយទូវមេត្តាធម៌គ្រប់ទិសតម្បន់ ត្រូវការតែតត្តមគតិតែមួយគឺ "សន្តិសុខ" តែប៉ុណ្ណោះ ។

ប្រទេសខ្មែរយុកជាមានកំពូលប្រសើរណាស់ ដែលបានទទួលពន្លឺព្រះពុទ្ធសាសនាតាំងព័ប្ទភាលរៀងមក ហើយទំលែរក្សាទុកមិនឲ្យបាត់បង់ទៅវិញ ពន្លឺនេះរុងរឿងចំញាចចំណែងក្នុងបច្ចុប្បន្នកាលនេះជាគំរូមួយឲ្យសាកលលោកមើល ទុកដូចជាព្រះពុទ្ធសាសនា មានជីវិតទៅរស់រើកក្នុងដែនដីខ្មែរ ហាក់ដូចសម័យពុទ្ធកាល ។ ប្រទេស

ខ្មែរដែលបានរក្សាព្រះពុទ្ធសាសនាតុកមកដោយប្រពៃដូច្នេះ តុកជាបានរក្សាតុកនូវគំនិតអធ្យាស្រ័យវិសេស សម្រាប់ជួយរំលែកកើនទុក្ខសកលលោកឲ្យរលត់ ហើយឲ្យបានសេចក្តីសុខពិតឈ្មោះថាបានបូជាដោយពិសេសចំពោះអង្គព្រះសម្មាសម្ពុទ្ធបរមគ្រូដោយបដិបត្តិបូជាដ៏ខ្ពង់ខ្ពស់ ។

ចំណែកកិច្ចសាមណេរនៅប្រទេសខ្មែរ ទិតរំនែកែទង់ធ្លុះទាំងពីរក្នុងពុទ្ធសាសនា ត្រមទាំងផ្សាយពុទ្ធសាសនាឲ្យបានជ្រួតជ្រាបខ្ជួនៅឥតកំណត់កាលវេលាឡើយ មានបំណងតែមួយ ចង់ឲ្យតែសាសនាព្រះសម្មាសម្ពុទ្ធបិតចេះចេរកាលអង្វែងតទៅ តែងតែនមស្ការគុណព្រះរតនត្រ័យពាល់ទឹកត្រី ស្វាធ្យាយពុទ្ធគាសិតោវាទ រួចហើយសូត្រលើកពុទ្ធសាសនាថា:

— សូមគោរពលើកដល់កាលដែលព្រះបរមមុនីសព្វញ្ញុពុទ្ធ ព្រះអង្គចូលនិព្វានទៅដោយអនុបាទិសេសនិព្វានធាតុ ក្នុងថ្ងៃប្រកបដោយអនុរាធនក្ខត្តឫក្ស នាយាមអគ្គារ ថ្ងៃអង្គារ ១៥ កើតខែពិសាខ គិម្ហរដូវឆ្នាំម្សាញ់ ត្រែមចន្ទោរមែកសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារ ក្នុងបច្ចុសសម័យ ។ រាប់ចាប់ដើមតាំងពីថ្ងៃ ខែ ឆ្នាំ នោះមកដល់ឥឡូវនេះពុទ្ធសករាជកន្លងទៅបាន២៤៩៣ឆ្នាំ ២ ខែ ១៥ ថ្ងៃ ថ្ងៃអាទិត្យ ១ កើតខែទុតិយាសាធ ឆ្នាំវកអដ្ឋស័ក គឺ ព.ស. ២៥០០ នេះ តុកជាបច្ចុប្បន្នកាល ។

— សូត្រលើកពុទ្ធសាសនាដោយជំរះថា ត្រែងបានត្រែងទង់ធ្លុះក្នុង

ព្រះសាសនាឲ្យគង់វង្សបរិបូរណ៍ តរៀងរាល់ថ្ងៃអស់រាត្រីនិងមួយថ្ងៃហើយមួយថ្ងៃទៀត ដាប់ដាន់ដូច្នេះរួចហើយក៏ស្តាយប្រដៅព្រះធម្មវិន័យបញ្ចប់ថា:

<ម្នាលអានន្ទ! ធម៌ក្តី វិន័យក្តី ដែលតថាគតបានទេសនាហើយ បានបញ្ញត្តិហើយ ដល់អ្នកទាំងឡាយ ធម៌ទាំងវិន័យនោះ ឥតអំពីតថាគតទៅ ទាំងជាគ្រូអាចារ្យនៃអ្នកទាំងឡាយ;

<អ្នកណាមួយ ជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី បើបានប្រតិបត្តិធម៌សមគួរដល់ធម៌ហើយ អ្នកនោះឈ្មោះថាបានធ្វើសក្ការៈគោរព · រាប់អាន · បូជាតថាគតដោយការបូជាដ៏ខ្ពង់ខ្ពស់;

<ម្នាលភិក្ខុទាំងឡាយ! ឥឡូវនេះ តថាគតដាស់តឿនអ្នកទាំងឡាយពាល់គ្នាថា "សង្ខារទាំងឡាយមានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយ ចូរបំពេញកិច្ចទាំងពួងរបស់អ្នក ឲ្យបានពេញបរិបូណ៌ ដោយសេចក្តីមិនប្រមាទចុះ" ។

ក្នុងកុរុធម្មជាតក តិកនិបាត

ព្រះទេពសង្ឃ កឹម - ភ្លឹរ ចន្ទមង្គលោ

ប្រមូលដំនុំព្រះវៃប្រចិនកនៅពុទ្ធសាសនបណ្ឌិត្យ ប្រែរៀបរៀង

(តទៅ)

---

៣ _ រឿងនាយសារថី

សេចក្តីដំណាលថា ថ្ងៃមួយ, នាយសារថីនោះបរពាជវៈនាំព្រះពជាទៅកាន់ឧទ្យាន, ព្រះពជាទ្រង់ក្រសាលអស់មួយថ្ងៃក្នុងឧទ្យាននោះ លុះល្ងាចទ្រង់យាងចេញមកគង់លើពាជវៈត្រឡប់មកព្រះនគរវិញ, ពាជវៈនោះមិនទាន់ចូលដល់ព្រះនគរ, មេឃក៏បង្អុរភ្លៀងធ្លាក់មកក្នុងវេលាជ្រលត់ព្រះអាទិត្យជិតអស្តង្គត ។ នាយសារថី ដោយខ្លាចភ្លៀងទទឹកព្រះពជា ក៏បានឲ្យសញ្ញាដល់សេះសិន្ធវៈទាំងឡាយដោយជន្លួញ, សេះសិន្ធវៈទាំងឡាយនោះ ក៏ស្ទុះបោលទៅដោយសន្ទុះដ៏លឿន ។ ចាប់តាំងពីថ្ងៃនោះមក, សេះសិន្ធវៈទាំងនោះ កាលទៅកាន់ឧទ្យានវិញក្តី ត្រឡប់មកពីឧទ្យាននោះវិញក្តី តែដល់ត្រង់កន្លែងដែលនាយសារថីឲ្យសញ្ញាដោយជន្លួញមុននោះ តែងស្ទុះបោលខ្លាំងដោយរហ័ស, ព្រោះអ្វី? ព្រោះសេះសិន្ធវៈទាំងនោះគិតថា ត្រង់កន្លែងនេះឯងមានសេចក្តីអន្តរាយ ព្រោះហេតុនោះបានជានាយសារថីឲ្យសញ្ញាដោយជន្លួញដល់យើងកាលនោះ ។ ចំណែកខាងនាយសារថីគិតថា ព្រះពជាទ្រង់ទទឹកភ្លៀងមិនទទឹកភ្លៀង ក៏មិនមានទោសពៃរ៍អ្វីដល់អញដែរ តែអញបានឲ្យសញ្ញាដោយ

ជន្ធញដល់សេះតាំងឡាយក្នុងទីមិនគួរ ឬានជាសេះតាំងនេះស្ទុះចាល តាំងទៅតាំងមក ឬានសេចក្តីលំបាកដោយសារតែអញ, អញជាអ្នក រក្សាកុរុធម៌, ស្បែរបស់អញប្រហែលជាបែកធ្លាយទៅហើយទេដឹង ទើបប្រាប់សេចក្តីនោះដល់ទូតតាំងឡាយថា ខ្ញុំមានសេចក្តីរង្កៀសក្នុង កុរុធម៌ដោយហេតុនេះឯង ព្រោះហេតុនោះខ្ញុំពុំអាចឲ្យដល់អ្នកតាំងឡាយ ឬានឡើយ ។ ទូតតាំងឡាយពោលថា ចិត្តរបស់អ្នកគ្មានបំណងចង់ ឲ្យសេះតាំងឡាយលំបាកទេ ឯការធ្វើដោយឥតចេតនាដូច្នេះគឺមិនជាការអ្វី ឡើយ លោកគ្រាន់តែមានសេចក្តីរង្កៀសដោយហេតុបុណ្ណោះ ទំនងឲ្យ ឈ្មោះថាប្រតិត្តកន្ធសីលដូចម្តេចបាន, លុះពោលយ៉ាងនេះហើយក៏ សុំកត់កុរុធម៌ក្នុងសំណាក់នៃនាយសារថីកុក្កដ៏ជំបាមាស ។ នាយសារថី ពោលថែមទៀតថា បើទុកជាយ៉ាងនេះក៏ដោយ, ខ្ញុំក៏នៅតែមិនសូវ ពេញចិត្តនឹងសីលរបស់ខ្ញុំប៉ុន្មានទេ, សេដ្ឋីឯណោះទើបរក្សាកុរុធម៌ បរិសុទ្ធល្អ សូមអ្នកតាំងឡាយទៅចម្ងឹយកក្នុងសំណាក់នៃសេដ្ឋីនោះចុះ។ ទូតតាំងឡាយ ចូលទៅរកសេដ្ឋី សុំកុរុធម៌តាមន័យដូចមុនទៀត ។

៨ - រឿងសេដ្ឋី

សេចក្តីដំណាលថា ថ្ងៃមួយ, សេដ្ឋីនោះទៅស្រែ ឃើញគួរស្រូវ ដែលទើបនឹងលូតចេញមកអំពីគក, ក៏គិតថានឹងឲ្យគេកាត់យកមកចង់ធ្វើ ជាគ្រែងផ្តាស្រូវ លុះគិតហើយក៏ប្រើឲ្យគេកាត់គួរស្រូវមួយក្តាប់យក មកឲ្យគេធ្វើជាគ្រែងហើយចងនឹងកងសក់ ។ គ្រានោះសេដ្ឋីគិតថា

គាតគានរបស់ស្តេចដែលអញត្រូវបង់ពន្ធថ្វាយអំពីស្រែនេះ, អញមិនទាន់ បានចែកចំណែកបង់ពន្ធថ្វាយទៅឡើយទេ, ឥឡូវអញឲ្យគេកាត់គួរស្រូវ មួយក្តាប់អំពីស្រែនេះទៅហើយ, ឯខ្លួនអញជាអ្នករក្សាកុរុធម៌, បើដូច្នេះ សីលរបស់អញប្រហែលជាបែកធ្លាយទៅហើយ, ទើបថ្កាប់សេចក្តីនោះ ដល់ខ្ញុតតាំងឡាយថា ខ្ញុំមានសេចក្តីរន្ធត់ក្នុងកុរុធម៌ដោយហេតុនេះឯង ព្រោះហេតុនោះ ខ្ញុំពុំអាចឲ្យដល់អ្នកតាំងឡាយបានឡើយ ។ ខ្ញុតតាំង ឡាយទោលថា ចេយ្យចិត្តរបស់លោកគ្មានទេ, មិនមានអ្នកណាអាច បញ្ជាក្តថា អំពើនេះជាអទិន្នាទានបានឡើយ, លោកធ្វើសេចក្តី រន្ធត់ដោយហេតុប៉ុណ្ណោះទើងឲ្យឈ្មោះថាលោកលួចយកទ្រព្យរបស់ អ្នកដទៃដូចម្តេចបាន, លុះពោលយ៉ាងនេះហើយ ក៏សុំកត់សីលក្នុង សំណាក់នៃសេដ្ឋីនោះទុកក្នុងដំបូងាស ។ សេដ្ឋីបានពោលថែមទៀតថា បើខ្ញុតជាដូច្នេះក៏ដោយ, ខ្ញុំក៏នៅតែមិនសូវពេញចិត្តនឹងសីលរបស់ខ្ញុំប៉ុន្មាន ទេ, ឯមហាមាត្យអ្នកវាល់ស្រូវហូតតន្ត ទើបរក្សាកុរុធម៌បរិសុទ្ធល្អ, ចូរអ្នកតាំងឡាយទៅសុំចម្ងល់យកអំពីមហាមាត្យនោះពុះ ។ ខ្ញុតតាំង-ឡាយនោះ ចូលទៅរកមហាមាត្យ សូមកុរុធម៌ តាមន័យដូចមុនទៀត ។

៩.— រឿងមហាមាត្យ

សេចក្តីដំណាលថា ថ្ងៃមួយ, មហាមាត្យនោះអង្គុយក្បែរទ្វារផ្ទះក ស្រូវ បង្គាប់ឲ្យគេវាល់ស្រូវ ហើយកាន់យកគ្រាប់ស្រូវអំពីគំនរស្រូវ ដែលពុំទាន់បានវាល់ មកដាក់ធ្វើជាខ្នាប់សម្រាប់ពាប់ ។ ក្នុងខណៈ

ដែលកំពុងវាល់នោះ ក្មេងកំបង្អុរធ្លាក់ចុះមក ។ មហាមាត្យអ្នកដាក់ខ្នាប់គ្រាប់ស្រូវធ្វើជាប់ថា ស្រូវដែលបានវាល់រួចហើយមានចំនួនប៉ុណ្ណេះ, លុះធ្វើជាប់ហើយក៏ចែមួលខ្នាប់គ្រាប់ស្រូវ ដាក់ទៅលើគំនរស្រូវដែលវាល់ហើយ ក៏ស្ទុះចូលទៅខេត្តដ៏ទូរាជង្រែកស្រូវ ហើយគិតថា អំបាញ់មិញ អញដាក់ខ្នាប់គ្រាប់ស្រូវទៅលើគំនរស្រូវដែលវាល់ហើយ ឬដាក់ទៅលើគំនរស្រូវដែលមិនទាន់វាល់ទេ, បើអញដាក់ទៅលើគំនរដែលវាល់រួចហើយ, ប្រយោជន៍ជារបស់ស្តេចនឹងបានចំរើនដោយមិនសមហេតុ ឯប្រយោជន៍ជារបស់គហបតីជាម្ចាស់ស្រូវនឹងត្រូវខាតបង់, ខ្លួនអញជាអ្នករក្សាកុរុធម៌, ស័លរបស់នញ្ញប្រហែលជាបែកធ្លាយទៅហើយទេដឹង ។ មហាមាត្យបានដំណាលសេចក្តីនោះធ្វើជាប់ខ្លួតាំងឡាយ ហើយនិយាយតបវិញថែរថា ខ្ញុំមានសេចក្តីរង្កើសក្នុងកុរុធម៌ដោយហេតុនេះឯង ព្រោះហេតុនោះ ខ្ញុំពុំអាចឲ្យដល់អ្នកតាំងឡាយបានឡើយ ។ ខ្លួតាំងឡាយបានពោលនឹងមហាមាត្យនោះថា ថេយ្យចិត្តរបស់លោកគ្មានទេ ឥតមានអ្នកណាអាចបញ្ជាក្តថាអំពើនេះជាអទិន្នាទានបានឡើយ, លោកធ្វើសេចក្តីរង្កើសដោយហេតុប៉ុណ្ណេះនេះ ទីឯឲ្យឈ្មោះថាលួចយកទ្រព្យអ្នកដទៃដូចម្តេចបាន, លុះពោលដូច្នេះហើយ ក៏សុំកត់ស័លអំពីសំណាក់មហាមាត្យនោះទុកក្នុងដំបាមាស ។ មហាមាត្យបានឆ្លើយតបវិញថែមទៀតថា បើខ្លួកជាយ៉ាងនេះក៏ដោយ, ខ្ញុំក៏នៅតែមិនសូវពេញចិត្តនឹងស័លរបស់ខ្ញុំប៉ុន្មានដែរ, ហ្ន៎! អ្នកឆ្មាំទ្វារឯណោះ ទើបតែរក្សាកុរុធម៌ហ្មត់ចត់ល្អ, ចូរអ្នកតាំងឡាយ ទៅសុំយកអំពីសំណាក់អ្នកឆ្មាំ

ទ្វារនោះទៀតចុះ ។ ទូតចាំងឡាយ ក៏ចូលទៅរកអ្នកឆ្មាំទ្វារនោះហើយ សូមក្បុរធម៌ដូចន័យមុនទៀត ។

១០ —រឿងអ្នកឆ្មាំទ្វារ

សេចក្តីដំណាលថា ថ្ងៃមួយ, អ្នកឆ្មាំទ្វារនោះ បានបន្ទូលសំឡេងឲ្យលាន់ឮអស់ពាក្យ: ៣ ដងក្នុងវេលាមុនដែលចំទ្វារព្រះនគរ ។ គ្រានោះ មានបុរសអ្នកចំលែកម្នាក់ ទៅដៃព្រមកនូវសន្ទឹងបន្ទែជាមួយនឹងប្អូនស្រីរបស់ខ្លួន, លុះត្រឡប់មកវិញបានឮសូរសំឡេងអ្នកឆ្មាំទ្វារស្រែកឲ្យសញ្ញា ក៏នាំប្អូនស្រីប្រញាប់ប្រញាល់មកឲ្យទាន់ ។ ឯអ្នកឆ្មាំទ្វារបានឃើញបុរសនោះក៏និយាយសួរថា អ្នកឯងមិនដឹងជាមានស្តេចកន្លងព្រះនគរទេឬ? អ្នកឯងមិនដឹងថាទ្វារនគរនេះ គេតែងបិទតាមកាលគួរទេឬ? អ្នកឯងនាំមាតុគ្រាមរបស់ខ្លួន ត្រាច់ទៅក្នុងព្រៃលេងស៊ើចសប្បាយដោយកាមពាគអស់មួយថ្ងៃ ។ បុរសនោះនិយាយតបវិញថា នុលោកអ៊ីយ, ស្រីនេះមិនមែនជាប្រពន្ធខ្ញុំទេ, វាជាប្អូនខ្ញុំទេតើ ។ អ្នកឆ្មាំទ្វារបានឮបុរសនោះនិយាយដូច្នោះ ក៏គិតថា អញមិនសមបើទៅនិយាយថាទម្លុះប្អូនស្រីគេថាជាប្រពន្ធគេដូច្នេះសោះ, ខ្លួនអញជាអ្នករក្សាក្បុរធម៌, សីលរបស់អញប្រហែលជាបែកធ្លាយហើយ, ទើបដំណាលសេចក្តីនោះថ្វាយទូតចាំងឡាយ ហើយក៏និយាយថា ខ្ញុំមានសេចក្តីរន្ធត់ស្តុកស្តម្ភក្បុរធម៌ដោយហេតុនេះឯង ព្រោះហេតុនោះ ខ្ញុំពុំអាចឲ្យដល់អ្នកចាំងឡាយបាន:ឡើយ ។ ទូតចាំងឡាយនិយាយនឹងអ្នកឆ្មាំទ្វារនោះថា ពាក្យនុ:លោកបាននិយាយដោយសេចក្តីសំគាល់ដូច្នោះ ក៏មិនមែនបែកធ្លាយនៃសីលរបស់លោក

ព្រោះពាក្យខ្ញុំនេះ, ម្យ៉ាងទៀត លោកមានសេចក្តីរវល់ក្នុងការសិក្សាធម៌ដោយហេតុប៉ុណ្ណេះនេះ ទើបឲ្យឈ្មោះថាធ្វើសម្បជានមុសាវាទដូចម្តេចបាន, លុះពោលយ៉ាងនេះហើយ ក៏សុំកត់កុរុធម៌អំពីសំណាក់នៃអ្នកធ្វើការក្នុងដំបូមាស ។ អ្នកធ្វើការបាននិយាយទៀតថា បើខុសដាយ៉ាងនេះក៏ដោយ, ខ្ញុំគ្រាន់តែមិនសូវពេញចិត្តនឹងសីលរបស់ខ្ញុំសោះ, ចំណែកនាងវណ្ណទាសី (ស្ត្រីពេស្យា) ឯណោះ ទើបគេរក្សាកុរុធម៌បរិសុទ្ធល្អ សូមអ្នកចាំងឡាយ ទៅសុំយកអំពីសំណាក់នៃនាងវណ្ណទាសីនោះចុះ ។

១១ - រឿងវណ្ណទាសី

ខួតចាំងឡាយ បានចូលទៅកាន់នាងវណ្ណទាសីនោះ សូមកត់កុរុធម៌។ ឯនាងវណ្ណទាសីនោះ បាននិយាយយាត់ដោយន័យដូចមុនដែរ, ព្រោះអ្វី? ព្រោះមានសេចក្តីតំណាលថា សក្កទេវរាជ ចង់ល្បងសីលនៃនាងវណ្ណទាសីនោះហើយតំណែងកេដាមាណពម្នាក់ នាំយកថ្ងាក់មួយពាន់មកហុចឲ្យនាងហើយថ្លែងថា "ខ្ញុំនឹងមកវិញ" លុះថ្លែងហើយក៏ត្រឡប់ទៅឋានទេវលោកវិញ ឈប់មកអស់រាង ៣ ឆ្នាំ ។ នាងវណ្ណទាសីនោះមិនហ៊ានទទួលយកទ្រព្យអ្វីអំពីបុរសដទៃទេ សូម្បីតែស្លាមួយម៉ាត់ក៏ពុំត្រូវទទួលយកដែរអស់រាង ៣ ឆ្នាំ ព្រោះខ្លាចដាច់សីលរបស់ខ្លួន, ម្ល៉ោះហើយនាងទៅជាអ្នកខ្ចីតក្រអោមរោម ក៏គិតថា បុរសដែលឲ្យថ្ងាក់មួយពាន់ដល់អញហើយទៅបាត់ មិនឃើញមកវិញអស់ ៣ ឆ្នាំ, ឥឡូវអញខ្វល់ក្រណាស់ មិនអាចនឹងបន្ទោរបង់ការឲ្យប្រព្រឹត្តទៅបាន, ពីថ្ងៃ

នេះទៅ គួរអញ្ជើញមហាមាត្យអ្នកវិនិច្ឆ័យក្តីឲ្យបានជាមុនហើយទើបទទួលយកស្បៀងអំពីបុរសជាខែគ្រាន់ទើបញ្ចឹមជីវិត ។ នាងវណ្ណាសីនោះ លុះគិតយ៉ាងនេះហើយក៏ទៅសាលាវិនិច្ឆ័យជម្រាបលោកមហាមាត្យថា សូមជម្រាបលោក, មានបុរសម្នាក់យកប្លាក់មួយពាន់មកឲ្យខ្ញុំហើយទៅបាត់ មិនឃើញមកសោះអស់ ៣ ឆ្នាំហើយ, ខ្ញុំក៏មិនដឹងជាបុរសនោះទៅរស់ឬស្លាប់ទៅហើយទេ, ឥឡូវខ្ញុំខ្វល់ត្រណាស់មិនអាចទទឹងបន្តជីវិតទៅបានទេ តាលបើដូច្នេះ តើលោកឲ្យខ្ញុំធ្វើដូចម្តេច? មហាមាត្យប្រាប់ថា អើ, បើបុរសនោះមិនមកអស់ ៣ ឆ្នាំទៅហើយ. ស្រេចតែនាងឯងធ្វើដូចម្តេចក៏បាន, ចាប់ដើមពីថ្ងៃនេះទៅ នាងឯងចូរទទួលយកស្បៀងអំពីបុរសជាខែតាមត្រូវការចុះ ។ នាងវណ្ណាសីនោះ កាលដែលចេញពីសាលាវិនិច្ឆ័យទៅវិញ មានបុរសម្នាក់យកប្លាក់មួយពាន់មកហុចឲ្យ, នាងវណ្ណាសីទើបតែលូកដៃទៅទទួលយកប្លាក់នោះស្រាប់តែសក្កទេវរាជតំណែងជាបុរសមកបង្ហាញខ្លួនឲ្យឃើញ, នាងក្រឡេកឃើញភ្លាមក៏ដកដៃថយចេញទាំយាយថា ឱបុរសដែលឲ្យប្លាក់មួយពាន់ដល់ខ្ញុំឥឡូវគាត់មកដល់ហើយ, ម្ចាលអ្នក ខ្ញុំមិនត្រូវការដោយប្លាក់របស់អ្នកទេ សូមអ្នកយកទៅវិញចុះ ។ ខណៈនោះព្រះឥន្ទ្រាធិរាជតំណែងកាយរបស់ខ្លួនដូចដើមវិញ ទៅឋិតនៅឰដ៏អាកាសដោយដំណើរដ៏រុងរឿងដូចជាព្រះអាទិត្យទើបនឹងរះ ។ ឯអ្នកនគរទាំងមូលមកប្រជុំគ្នាចាំមើល, ព្រះឥន្ទ្រាធិរាជ ទ្រង់ឋិតនៅនាកណ្តាលនៃមហាជនឲ្យឧវាទថា យើងបានឲ្យប្លាក់មួយពាន់ដល់នាងវណ្ណាសីនេះហើយមិន

ដែលមកអស់ជាង ៣ ឆ្នាំ ដោយអំណាចចង់ល្បងស័លរបស់នាងមើល, ឥឡូវឃើញថានាងនេះឯងរក្សាស៊ីលបរិសុទ្ធល្អមែន ព្រោះហេតុនោះអ្នកទាំងឡាយ កាលដែលទឹងរក្សាទូរស៊ីល ចូររក្សាឲ្យបានបរិសុទ្ធដូចជានាងវណ្ណាសីនេះចុះ, លុះឲ្យឧត់ទរូបហើយ ក៏ញ៉ាំងទិវេសនដ្ឋានរបស់នាងវណ្ណាសីឲ្យពេញដោយភែតែរាំង ៧ ហើយប្រែបៀនប្រដៅនាងវណ្ណាសីនោះថែមទៀតថា ចាប់ដើមពីថ្ងៃនេះទៅបួនាងកុំធ្វេសប្រហែសនឹងការកុសលឡើយ ហើយក៏ត្រឡប់ទៅកាន់ឋានទេវលោកវិញទៅ ។ ដោយហេតុនេះ បានជានាងវណ្ណាសីនោះនិយាយថា ដកឋណាខ្ញុំខ្ចីលយកថ្លៃឈ្នួលពីគេហើយមិនធ្វើឲ្យសាបសូន្យឫងាត់បង់ទេ ដកឋនោះ ទើបហ៊ានលូកដៃទៅខ្ចីលយកទូរថ្លៃឈ្នួលដែលបុរសឯទៃឲ្យ, ស៊ីលរបស់ខ្ញុំប្រហែលជាមិនសូវហ្មត់ចត់ដោយហេតុនេះទេដឹង, ព្រោះហេតុនោះ ខ្ញុំពុំអាចឲ្យដល់អ្នកទាំងឡាយបានឡើយ ។ ទូតទាំងឡាយបានតោលតបនឹងនាងវណ្ណាសីនោះថា ស៊ីលរបស់នាងមិនបែកធ្លាយដោយគ្រាន់តែលូកដៃទៅខ្ចីលប៉ុណ្ណោះទេ, ស៊ីលនេះឈ្មោះថាជាស៊ីលដ៏បរិសុទ្ធយ៉ាងក្រៃលែង, លុះតោលយ៉ាងនេះហើយក៏សូមកត់យកស៊ីលពីសំណាក់នៃនាងវណ្ណាសីនោះចុះទុកក្នុងដំបូមាស ។

ទូតទាំងឡាយ បានកត់បម្លងកុរុធម្មតិស៊ីល ៨អំពីជនទាំង ១១នាក់មានព្រះបូពធនញ្ញាយកោវ្យៈពោធិសត្វជាដើមនោះ ដាក់ក្នុងដំបូមាសហើយត្រឡប់ទៅឯនគរទន្តបុរី ក្នុងដែនកាលិង្គៈវិញ, ទាំងដំបូមាសនោះទៅថ្វាយព្រះបូកាលិង្គៈ ហើយក្រាបទូលតាមដំណើររឿងពីរនោះដោយសព្វ

គ្រប់ ។ ព្រះពុទ្ធជាម្ចាស់សមាទានកាន់ប្រតិបត្តិក្នុងធម៌តឹញ្ចាំងសិល ៥ឲ្យ
ពេញបរិបូណ៌ដោយឥតមានសេចក្តីសៅហ្មងឡើយ, ភ្លៀងក៏បង្អុរធ្លាក់ចុះ
មក, កំយ៉ាងនេះ មានធាតុកកំយ៉ាងដើម្បីសូបរម្ងាប់ថ្នាក់ទៅ, ដែនទាំងមូល
ក៏មានសេចក្តីក្សេមសម្បូរសប្បាយដោយគ្រាជន ក្នុងកាលនោះឯង ។ ពោធិ
សត្វព្រមទាំងជនជាបរិវារបានបំពេញបុណ្យកុសលផ្សេង ។ មានមានជា
ដើម ជាបដល់អស់ជន្មាយុ ហើយក៏បានទៅកាន់សគ្គបុរីតាវតិង្សហោង ។

ព្រះបរមសាស្តា លុះទ្រង់នាំធម្មទេសនានេះមកសំដែងរួចហើយ,
ក៏ទ្រង់សំដែងសច្ចធម៌ទាំង ៤ ទៀត, លុះចប់សច្ចធម៌នោះហើយ, ពួក
ជនខ្លះ បានជាសោតាបន្នបុគ្គល, ពួកជនខ្លះ បានជាសកទាគាមិបុគ្គល,
ពួកជនខ្លះ បានជាអនាគាមិបុគ្គល, ពួកជនខ្លះ បានជាអរហន្ត; ទើប
ទ្រង់សំដែងប្រដុំជាតកថា:

អ្នកទាំងឡាយ ចូរចាំជាតកយ៉ាងនេះគឺ នាងវណ្ណទាសីជាស្ត្រីទេស្យា
កាលណោះ បានមកជានាងខុជ្ជុត្តរាថេរី, អ្នកនាំទូវ កាលណោះបាន
មកជាបុណ្ណត្ថេរ, វដ្ឌគាហៈអមាត្យ កាលណោះ បានមកជាកច្ចាយនត្ថេរ,
មហាមាត្យអ្នកបង្គាប់ឲ្យគេវាល់ស្រូវ កាលណោះ បានមកជាមហា
មោគ្គល្លានត្ថេរ, សេដ្ឋី កាលណោះ បានមកជាសារីបុត្តត្ថេរ, នាយសារថី
កាលណោះ បានមកជាអនុរុទ្ធត្ថេរ, ព្រាហ្មណ៍បុរោហិតកាលណោះ
បានមកជាកស្សបត្ថេរ, ព្រះឧបរាជ កាលណោះ បានមកជានន្ទបណ្ឌិត,
ព្រះអគ្គមហេសី កាលណោះ បានមកជាព្រះមហាមាយាទេវី, ពោធិសត្វ
ជាស្តេចសោយរាជ្យក្នុងដែនកុរុ កាលណោះ បានមកជាតថាគតហ្នឹងឯង ។

មេត្តាធំសន្ធរកថា

និយាយអំពីអានិសង្សនៃមេត្តាចិត្ត

ឃុនបណ្ឌាសុរ៉ក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ ប្រៃរៀបរៀង

ការមិនប្រទូសរ៉ាយ សំដៅយកការមិនមានមនោបទោសចិត្តគឺ គ្មានចិត្តទុំស្គុចំពោះមនុស្សផងគ្នារហូតដល់សត្វតិរច្ឆាន មានទឹកចិត្តប្រកបដោយមេត្តា ។ មេត្តាបានដល់មេត្រីចិត្ត គឺសេចក្តីស្រឡាញ់ស្និទ្ធស្នាលខ្ជិនគ្នាដោយស្មោះត្រង់ មិនមានចិត្តឫស្យាឈ្នានីនគ្នា ដូចមាតាបិតាដែលស្រឡាញ់បុត្រធីតា ឬព្រះមហាក្សត្រទ្រង់ផ្សាយព្រះទ័យមេត្តាដល់ប្រជាពលស្តេចឲ្យនៅជាសុខសប្បាយ ។ មេត្តា ជាគុណធម៌ដ៏សំខាន់ក្នុងផ្លូវលោកិយ ។ មនុស្សគាំងឡាយក្នុងលោកមែងរួបរួមគ្នានៅជាពួកក្រុមមិនអាចនៅតែម្នាក់ឯងបានទេ ត្រូវតែអាស្រ័យកម្លាំងមនុស្សផងគ្នា ដួយធ្វើកិច្ចការដែលហួសវិស័យឯកជនធ្វើបាន ឬកាលមានទុក្ខភ័យកើតឡើងក៏ត្រូវទាំគ្នាជួយការពារគាល់តែដល់ទីបំផុត ។ កាលបើមនុស្សជាតិសុទ្ធតែមានការខិតខំពាក់អាស្រ័យគ្នាដូច្នេះហើយ បើមនុស្សជាតិនោះខ្វះគុណសម្បត្តិគឺមេត្តាដល់គ្នាហើយ សេចក្តីវិនាសនឹងកើតមានឡើងគ្រឹមណានោះមិនចាំពណ៌នាក្នុងទីនេះឡើយ ។

ហេតុដូច្នោះ មេត្តាទើបចាត់ថាជាគុណធម៌ដ៏សំខាន់មួយ ដែលផ្តួយឧបត្ថម្ភលោកឲ្យចំរើន ត្រូវនឹងសុភាសិតថា លោកោបត្ថម្ភិតា មេត្តា "មេត្តាមែនទំនុកបំរុងគាំពារលោក" ។ សម្តេចព្រះបរមសាស្តា ទ្រង់ប្រទានពុទ្ធបរិស័ទក្នុងផ្លូវប្រតិបត្តិ ដើម្បីឲ្យបានសម្រេចលោកុត្តរធម៌ ក៏ទ្រង់ដឹកនាំឲ្យបណ្តុះមេត្តាចិត្តជាបដិបាដិហារិយដើម ដូចមានព្រះពុទ្ធដីកាក្នុងគម្ពីរព្រះធម្មបទថា:

មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ

"តិក្ខុអ្នកមានមេត្តាជាអារម្មណ៍ ជ្រះថ្លាហើយក្នុងព្រះពុទ្ធសាសនា រមែងបានសម្រេចព្រះនិព្វាន ជាស្ថានបរមសុខដែលរម្ងាប់បង់នូវសង្ខារ" ។

អធិប្បាយថា មេត្តាបានដល់ការផ្សាយមេត្រីចិត្ត ជាគុណធម៌ដ៏ស័ក្តិសិទ្ធិអាចធ្វើអ្នកប្រតិបត្តិឲ្យបានសម្រេចឥដ្ឋវិបុលផល ជាធម៌វិសេសជាងការស្តោះត្បាះដោយវេមន្តអាគមគាថា ។ មេត្តាជាធម៌ធ្វើមនុស្សឲ្យទៅជាព្រហ្ម ។ មេត្តាពប់ពូលជាអង្គមួយក្នុងបារមី ៣០ ដែលព្រះពោធិសត្វត្រូវប្រព័ន្ធសន្ធឹកសាងដើម្បីឲ្យបានត្រាស់ជាព្រះអង្គសព្វញ្ញូ ។ មេត្តាលោកចាត់ជាព្រហ្មវិហារធម៌ គឺជាធម៌របស់អ្នកធំ ។ ព្រោះហេតុនោះអ្នកដែលស្វែងរកសេចក្តីសុខ ចង់ដឹងចង់ឮអំពីទុក្ខក័យ គួរតែតាំងមេត្តាចិត្តឲ្យមានជានិច្ចចុះ ។

ការសំដែងមេត្តាចិត្តដល់គ្នានឹងគ្នាលោកចែកជា ៣ យ៉ាង តាមភូមិ ទាំង ៣ គឺ

๑ - សំដែងមេត្តាដោយកាយ ជាន់ដល់ការជួយធ្វើកិច្ចការគ្នាដោយចិត្តដ៏ប៉ិសុទ្ធមានមេត្តាចិត្តជាអារម្មណ៍ គឺយកកំឡាំងកាយជួយសម្រួចកិច្ចការគ្នាដែលគួរគប្បីទោស ខ្ពស់ការធ្វើប្រយោជន៍របស់គ្នានឹងគ្នាឲ្យជាន់សម្រួចដោយកាយក្តី ដូចជួយព្យាបាលមនុស្សឈឺចាប់ ជួយស្រង់មនុស្សលង់ទឹក ជួយទំនុកបំរុងមនុស្សដែលមានទុក្ខកំសត ឬជួយលះបង់ទ្រព្យសម្បត្តិជាបច្ច័យទុបត្ថម្ភដល់កិច្ចការនោះ។ ដូចជាអ្នកបំពេញគ្រូដើម្បីទំនុកបំរុងសាលាបង្រៀនសិស្ស ឬកេងព្យាបាលភេត ជាការចំរើនដល់ព្រះពុទ្ធការណីយកិច្ចទុកិច្ចទាំងឡាយ ដើម្បីឲ្យជាន់សុខ ជាន់ចំរើនដល់សាធារណជនជាដើម បើនិយាយដោយបំប្រួញឲ្យងាយយល់ថា កាលបើយល់ឃើញថាគួរធ្វើទុបការដល់គ្នាជាន់ដោយប្រការឯណា ក៏ធ្វើដោយប្រការនោះទៅ មិនមើលបំណាំគ្នា មិនធ្វើព្រងើយកន្តើយ យ៉ាងនេះហៅថា មេត្តាកាយកម្ម ។

๒ - សំដែងមេត្តាដោយវាចា ជាន់ដល់ការធ្វើទុបការដល់មនុស្សផងគ្នាដោយវាចា ដូចជាឃើញអ្នកដទៃប្រមាទប្រព្រឹត្តការទុច្ចរិតកាលបើមានឧកាសគួរនឹងនិយាយរំឭកជាន់ ក៏និយាយខ្ជាន់ឲ្យលះបង់អំពើអាក្រក់នោះចេញឬមួយជួយបង្រៀនគេឲ្យជាន់ចេះដឹងក្តី ជួយពន្យល់ប្រាប់ផ្លូវដោយហេតុឲ្យជាន់សម្រួចផលប្រយោជន៍ ក្នុងលោកនេះនឹងលោកមុខក្តី យ៉ាងនេះហៅថា មេត្តាវចីកម្ម ។

๓_ សំដែងមេត្តាដោយចិត្ត ចានដល់ការតាំងចិត្តប្រកបដោយមេត្តា មិនមានរំហឹសាព្យាចាទដែលជាអកុសលធម៌ដល់គ្នានឹងគ្នា សំដែងសេចក្តីស្រឡាញ់ពប់អានគ្នា ប្រថ្នាឲ្យតែចានសុខនឹងឲ្យចានផលប្រយោជន៍ដល់គ្នា ដោយចំពោះរូបមនុស្សប្តីមិនចំពោះ យ៉ាងនេះហៅថា មេត្តាមនោកម្ម ។ មេត្តាមនោកម្មនេះជាគុណធម៌ដ៏សំខាន់ ដែលបុគ្គលគួរសន្សំឲ្យមានបរិបូណ៌ក្នុងខ្លួន ព្រោះជាកុសលមូលដែលនឹងឲ្យកើតមេត្តាកាយកម្មនឹងមេត្តាវចីកម្មដូចចានពោលហើយក្នុងខាងដើម ។

អានិសង្សរបស់អ្នកចំរើនមេត្តា មាន ๑๑ ប្រការ គឺ

๑- សុខំ សុបតិ ដេកលក់ស្រួល

๒- សុខំ បដិពុជ្ឈតិ ភ្ញាក់ឡើងស្រួល

๓- ន បាបកំ សុបិនំ បស្សតិ មិនយល់សប្តិឃើញអាក្រក់

๔- មនុស្សានំ បិយោ ហោតិ ជាទីស្រឡាញ់របស់ពួកមនុស្ស

๕- អមនុស្សានំ បិយោ ហោតិ ជាទីស្រឡាញ់របស់ពួកអមនុស្ស

๖- ទេវតា រក្ខន្តិ ទេវតាតាំងព្យាយរមែងរក្សា

๗- ឥស្សុ អគ្គិ វា វិសំ វា សត្ថំ វា កមតិ ភ្លើងប្តូចាំពិសប្តូគ្រឿងសស្ត្រាបទូសព៌យមិនចានឡើយ

๘- តុវដំ បិត្តំ សមាធិយតិ ចិត្តជាសមាធិធាប់រហ័ស

๙- មុខវណ្ណោ វិប្បសីទតិ សម្បុរមុខស្អាតផូរផង់ល្អ

១០. អសម្ភវ្ហោ កាលំ កយោតិ មិនអាចធ្វើមរណកាល

១១. ឧត្តរិ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ កាលមើ
មិនទាន់បានសម្រេចធម៌ដ៏ខ្ពស់ទេ រមែងទៅកើតក្នុងព្រហ្មលោក ។

មេត្តាជាធម៌អ្នកណា?

ធម៌មេត្តាគឺពិតជាធម៌អ្នកធំ
នៃពួកក្រែមនៃសង្គមនៃគ្រួសារ
ដែលជាអ្នកមានអ្នកតូចទាបវាស្មា
ខៅដោយសារពឹងអាស្រ័យកោនជែកផង ។
អ្នកធំខោរដោយចំពោះត្រូវមានចិត្ត
ផ្សាយអាណិតគិតអាណោចតុំប៉ិចង-
តំខុំធ្វើឱ្យគ្នាមានទុក្ខសៅហ្មង
ឱ្យគ្នាវង់លំបាកចិត្តឥតមានឈប់ ។
អ្នកធំណា គ្មានមេត្តាដល់អ្នកតូច
លោកប្រៀបដូចដើមឈើធំគ្មានម្លប់
ពួកមនុស្សសត្វមិនអាចកាត់ខៅជែកឈប់
មិនហ៊ានគប់ព្រោះផ្តាច់ផ្តុំណាគុណមិនឡើង ។

យូរ - អ៊ុង

អក្សរសាស្ត្រខ្មែរសង្ខេប

លោក រ៉ាយ-ប៊ុក ក្រមការដើមខ្សែលេខមួយរៀបរៀង

(តពីលេខ)

---

៤ យោបល់អ្នកនិពន្ធ .— *អក្សរសាស្ត្រខ្មែរដែលនឹងចម្រើនរុងរឿងទៅបាន មកពីមានអ្នកអានច្រើន, មានអ្នកអានច្រើនជាហេតុឲ្យមានអ្នកនិពន្ធច្រើន, អ្នកនិពន្ធច្រើនជាហេតុឲ្យមានបណ្ដិតខាងអក្សរសាស្ត្រច្រើន, មានបណ្ដិតច្រើនជាហេតុឲ្យនេះយោធាយប្រទេសធ្លាប់ដំណើរទៅបានស្រួល ។ បើយើងពិនិត្យមើលអក្សរសាស្ត្រប្រទេសយើងទៅតាមឋានៈដែលគេប្រជាពស្ត្រខ្មែរ ឃើញថាអក្សរសាស្ត្រយើងស្ថិតនៅតាបណាស់ ព្រោះជនជាតិខ្មែរដោយភាគច្រើនមិនសូវពេញចិត្តអានការសែត, ទស្សនាវដ្ដី, សៀវភៅទេ ជាហេតុឲ្យមនុស្សស្ថិតនៅក្នុងអវិជ្ជាដោយភាគច្រើន ព្រោះថាអ្នកណាអានច្រើន, អ្នកនោះចេះដឹងច្រើន; បើមិនអានសោះបានអ្វីនឹងចេះ ដូចពាក្យសុភាសិតថា: "សិល្បសាស្ត្រមានពីណាដល់មនុស្សខ្វិល" ។ សេចក្ដីល្ងង់ស្ថិតនៅក្នុងមនុស្សខ្វិល ។ តែងជួបនឹងសេចក្ដីវិនាសអន្តរាយគ្រប់យ៉ាង; នៅកពានេះបើមនុស្សល្ងង់ចូលទៅកាន់ទីណា គ្មានអ្នកឃាត់អានបួជាទេ ។ ប៉ើក្នុងប្រទេសមានតែមនុស្សមិនសូវអានសៀវភៅ, តើវឌ្ឍនធម៌ជាតិមានមកពីណា? ឋាន*

ជាបណ្ដិតសម័យបច្ចុប្បន្នគោលថា "នៅប្រទេសដែលវឌ្ឍនធម៌មិនទាន់ចំរើន អ្នករកស៊ីដោយជង្គីកកា ឈ្មោះថាពន្ធិចខ្លួនឯង" ។ ការរកទទួលទានដោយជង្គីកកានៅប្រទេសកម្ពុជា, បើប្រៀបធៀបទៅនឹងប្រទេសនានាក្នុងសាកលលោក យើញថាស្ថិតនៅទន់អន់ខ្សោយជាងគេ។

អក្សរសាស្ត្រចែកចេញតាមថ្នាក់មាន ៧ ថ្នាក់គឺ

๑ – សៀវភៅធម៌ (livres religieux)

๒ – សៀវភៅប្រលោមលោក (Roman)

๓ – សៀវភៅសុភាសិតនិងសៀវភៅវិនិសាលា (proverbes, maximes, classiques)

๔ – សៀវភៅនយោបាយ (politique)

๕ – សៀវភៅតក្កវិជ្ជា (logique)

๖ – សៀវភៅទស្សនវិជ្ជា (philosophie)

๗ – សៀវភៅបរមត្ថវិជ្ជា (Métaphysique) ។

ក្នុងប្រទេសយើង ចែកតាមថ្នាក់ទាំង ៧, អក្សរសាស្ត្រស្ថិតនៅតែនិងទី ๑ ๒ ដោយច្រើន, ឯក្រៅពីនោះមានតិច ។

បណ្ដាសៀវភៅទាំង ៧ ប្រភេទ, ជនជាតិខ្មែរយើងបានវិវត្តន៍ ដោយភាគច្រើនមកតឹមសៀវភៅប្រលោមលោក ។ ពិតមែនតែជនជាតិខ្មែរទាំងបុរស - ស្ត្រី ជាអ្នកកាន់ព្រះពុទ្ធសាសនាដោយភាគច្រើន, តម្រូវយើញអ្នកទាំងនេះអានសៀវភៅព្រះពុទ្ធសាសនា; បើយើងពិនិត្យដោយជាក់លាក់ទៅ ទើងយើញថា ឧបាសកឧបាសិកានោះ ច្រើនជាអ្នក

ញាណវិប្បយុត្ត, ដែលជាអកញ្ញាណសម្បយុត្តមានភាគតិច ហើយ
ជាអ្នកគ្រាន់តែធ្វើនូវក្បាលីល ក្នុងព្រះពុទ្ធសាសនាតាមទម្លាប់ដែល
មានតៗមកប៉ុណ្ណោះ ។

ព្រោះហេតុនេះ, កិច្ចការដែលត្រូវធ្វើជាបឋមក្នុងប្រទេសយើង
គឺការអប់រំមនុស្សឲ្យពេញចិត្តខាងការអានសារពត៌មាន, ទស្សនាវដ្តី,
សៀវភៅផ្សេងៗ ។ ទៅមហាប្រទេស ដូចប្រទេសរុស្ស៊ីជនជាតិគេឈប់
ច្រូតស្រូវសុទ្ធមកអានសារពត៌មាន, ពួកជនជាតិអាមេរិកទៅប្រទេសដែល
ជាជាយដែនដូចតេកសាស៍ កាលត្រឡប់ពីឃ្លាលបស្មុសត្ងមកគេហដ្ឋាន
វិញ គេអានសារពត៌មានទើបទស្សនាវដ្តី ។ ព្រោះជនជាតិនោះ ។
គេយល់ថា បើគ្មានការអាន ក៏គ្មានដឹងអ្វីសោះឡើយ, ការដែលមិន
ដឹងហៅថាល្ងង់ មនុស្សល្ងង់ជាបុគ្គលថោកទាប ។

សៀវភៅជាកណ្ឌញាណមិត្តទៅជិតខ្លួន សៀវភៅជាមគ្គទេសក៍ដឹក
នាំខ្លួនទៅកាន់សេចក្តីសុខសេចក្តីចម្រើន, សៀវភៅជាឃ្មាំងធ្ងាជ្ញា,
ព្រោះហេតុនោះ សៀវភៅអាចធ្វើមនុស្សឲ្យទៅជាអ្នកធ្ងាជ្ញធ្ងាន ។

បើប្រសិនជាក្នុងវត្តអារាមមានបង្កើតបណ្ណាល័យ ឬកន្លែងសម្រាប់
អានសៀវភៅ ប្រហែលជាបុរសនឹងស្ទើរធ្វើតពេលទំនាស់ទៅវត្តអារាម
ចូលទៅអានគំនូរទៅទីនោះមិនខាន ។ ទៅមន្ទីរកាត់សក់ក៏ត្រូវឲ្យ
មានសៀវភៅសម្រាប់អាន, ទៅឱសថ្នាន ឬទីនានា គួរឲ្យមានកន្លែង
មួយសម្រាប់អាន ។ បើកងភូមិទីមួយៗ បង្កើតឲ្យមានទីកន្លែងសម្រាប់
អានក៏ជាការល្អដែរ ។

អ្នកអាន គាល់បើខ្ញុំបាទអានបន្តិចម្តងៗ យូរៗទៅនឹងទៅជាអ្នកពេញចិត្តខាងការអាន គឺអប់រំអានតាល់តែអ្នកដែលយើញសៀវភៅ ដូចជាយើញម្ហូបអាហារមានរស់ឆ្ងាញ់ហើយទឹក ។

តើហេតុអ្វី បានជាមនុស្សមិនពេញចិត្តអានសារពិតមាន, ទស្សនាវដ្តី, សៀវភៅផ្សេង ? គឺមកពីមិនចេះអក្សរ១, មិនយល់ខ្លួប្រយោជន៍ក្នុងការអាន១, ខ្ជិលច្រអូស១, មិនសេពគប់បណ្ឌិតសប្បុរស១, ខ្វះការសិក្សានៅសាលារៀន ឬនៅវត្តអារាម១, ខ្វះការអប់រំ ១, ខ្វះការយោសនាឬខ្វះអាជ្ញាបន្ទុំ១ ។

១— មិនចេះអក្សរ.— ធម្មតាមនុស្សតែមិនចេះអក្សរហើយគេហៅថាមនុស្សខ្វាក់ ។ ដើម្បីនឹងរាថាមនុស្សឲ្យចេះអក្សរ, គួរតែរដ្ឋាភិបាលបង្កើតសាលាមួយពិសេសហៅថា "សាលារៀនមនុស្សធំ" ដូចជាមហាប្រទេសនានាក្នុងសាកលលោក ។ ពិតមែនតែមានកិច្ចវល់ធ្ងើស្រែចម្ការ តែគង់ធ្វើតទុកាស ១ ម៉ោង ដើម្បីនឹងសិក្សារៀនសូត្រឲ្យចេះដឹងចេះយ៉ាងហោចណាស់តែមតែឲ្យចេះអានសៀវភៅបាន ។ បើចេះអានហើយ, ត្រូវព្យាយាមអានមួយថ្ងៃមួយយប់ ១ ម៉ោងក៏បានហើយ ។

២ _ មិនយល់ប្រយោជន៍ក្នុងការអាន.— ការអានសារពិតមានទស្សនាវដ្តីសៀវភៅមានប្រយោជន៍ដ៏សំខាន់ គឺយើងបានចេះដឹងនយោបាយ ក្នុងប្រទេសនឹងគ្រប់ប្រទេស, មធ្យោបាយដែលធ្វើប្រទេសឲ្យបានចម្រើន, ដំណើរនយោបាយប្រទេសដល់ត្រឹមណា ? ដំណឹងក្នុង

ស្រុកនឹងក្រៅស្រុក, កូមិសាស្ត្រ, ប្រវត្តិសាស្ត្រ, រឿងព្រៃង រឿងកំរ
គ្រប់យ៉ាង ដែលគេហៅថាអក្សរសាស្ត្រ, សារុបមកថា ការអានតាំងឲ្យ
យើងចេះដឹង ឲ្យយើងមានវិជ្ជាគ្រប់យ៉ាង ។

៣- ខ្វិលប្រអូស.- ខ្វិលនេះជាអកុសលមួយដែលតាំមនុស្សមិន
ឲ្យចេះដឹង ព្រោះថា: "សិល្បសាស្ត្រមានតំណាជល់អ្នកខ្វិល" ហើយ
ខ្វិលនេះតាំមនុស្សទៅកាន់សេចក្តីល្ងង់ អាប់អោន, គ្មានគេកប់អាន;
ខ្វិលនេះមិនមែនឲ្យផល់អក្រក់តឹមតែខ្លួនឯងម្នាក់នោះទេ, ឲ្យផលវិនាស
រហូតដល់ជាតិ, សាសនា, មាតុភូមិ; ខ្វិលស្ថិតទៅនឹងមនុស្សណា,
តាំមនុស្សនោះឲ្យថោកទាប ឲ្យវិនាសអន្តរាយ ។ ព្រោះហេតុដូច្នេះ,
យើងត្រូវតស៊ូនឹង "ខ្វិល", បំផ្លាញវាឲ្យខ្ចាត់ចេញពីសន្តានចិត្តឲ្យអស់
ព្រោះខ្វិលនេះជាសត្រូវនឹងវឌ្ឍនធម៌គ្រប់យ៉ាង ។

៤- មិនបានសេពគប់បណ្ឌិតសប្បុរស.- បើមានការ
សេពគប់បណ្ឌិត, មុខជាបណ្ឌិតនោះខ្ជូនាន ជាស់តឿន ក្រែនរំពុកយើង
ឲ្យចំអានសៀវភៅ, សារពត៌មាន, កុំឲ្យខ្វិលច្រអូស, ឲ្យចំសិក្សារៀនសូត្រ
ជាដើម ។ បើសេពគប់នឹងពួកពាលទុច្ចរិត, ពាលនឹងដឹកនាំទៅរកសេចក្តី
វិនាសអន្តរាយ មនុស្សណាសេពគប់នឹងមនុស្សពាល គេហៅថាមនុស្ស
ស្វាប់ ។

៥- ខ្វះការសិក្សានៅសាលារៀន ឬនៅវត្តអារាម.- មាន
បិតាមាតាដែលជាប់ក្តែលបុពណ្ណខ្លះ មិនឲ្យកូនចូលទៅសិក្សារៀន

សូត្រនៅសាលារៀនទេ ឪកឲ្យនៅឃ្វាលគោ-ក្របី ឪកឲ្យនៅលក់ខ្ទៅ; បើជាកូនស្ត្រីវិញ មាតាបិតាមិនឲ្យទៅរៀនអក្សរទេ ហើយមានខ្លះថា "ស្ត្រីចេះអក្សរជាស្ត្រីខូច" ថែមទៀត ។ គំនិតថាកថាបនេះយើងត្រូវផ្ទាស់ចេញឲ្យឆាប់, ត្រូវឲ្យបុត្រធីតាចូលទៅរៀនសាលាយកដំរេរដ្ឋាគ្រប់យ៉ាង ។

៩— ខ្វះការអប់រំ.— នៅមហាប្រទេសនានា, គេបានស្ថាបនាសាលាមួយហៅថាមត្តេយ្យសាលា គឺសាលាបង្រៀនគារកគារិកា មានគ្រូស្រីដូចមាតា ។ គារកគារិកាតាំងពីអាយុ ៣ ឆ្នាំទៅដល់ទឹង ៦ ឆ្នាំ, គេយកទៅប្រគល់ឲ្យគ្រូស្រីនៅមត្តេយ្យសាលាអប់រំកាយ, វាចា, ចិត្ត ឲ្យដួលទៅក្នុងការរៀនសូត្រដើម្បីទទឹងដល់អាយុចូលសាលារៀន, សាលាពុជការខ្លួលបាន, ធ្វើដូច្នេះដើម្បីឲ្យអធ្យាស្រ័យចិត្ត, គំនិតរបស់ពាក់ទៅតែខាងការសិក្សាប៉ុណ្ណោះ ។

ក្រៅពីនេះ នៅមានឧទ្យានសម្រាប់កុមារលេង ដែលគេផ្សាំពួជជាអ្នកពេញចិត្តខាងការសិក្សា គឺកុមារចូលចិត្តខាងលេងលេង ។ ព្រោះហេតុដូច្នេះ សៀវភៅដែលឲ្យកុមារៀនត្រូវមានគួរបគ្រប់យ៉ាង, ជាហេតុឲ្យកុមារសប្បាយទឹងរូបផង រៀនផង ។

៧— ខ្វះការយោសនា ឬ ខ្វះអាជ្ញាបណ្ឌិ.— ត្រូវមានគ្រូអប់រំចេះយោសនាពន្យល់បំភ្លឺប្រជាពលរដ្ឋប្រុសស្រីឲ្យពេញចិត្តខាងការរៀនសូត្របង្ហាញនូវប្រយោជន៍កុងការអានសារពត៌មាន, ទស្សនាវដ្តី, សៀវភៅផ្សេង ។, ធ្វើសន្និសិទអំពីការសេពគប់នឹងបណ្ឌិត, សប្បុរស ដែល

មានវិជ្ជា ចំណេះចេះដឹងគ្រប់យ៉ាង ។ សូមបញ្ជាក់ឲ្យដឹងថា ភាសា, អក្សរ ជាតិនីធ្លាជាតិ គ្រូវមានហេតុ មានបច្ច័យ រវាងគ្នាខ្លួនគ្នា គឺថា បើភាសា ឬ អក្សរជាតិស្ងាប់, ជាតិក៏ស្ងាប់, បើភាសា ឬ អក្សរជាតិរស់, ជាតិក៏រស់ ។

ចំណែកឯអាជ្ញាបង្ខំនោះ នីធ្លប្រើប្រាស់លុះត្រាតែពេជរដ្ឋាភិបាល ឬ រដ្ឋសភា ឬក្រុមប្រឹក្សាព្រះពុទ្ធអាណាចក្រ តែងបានបញ្ញត្តិច្បាប់ បង្ខំឲ្យប្រជាពលរដ្ឋប្រុសស្រីសិក្សារៀនសូត្រ មានជាក់ខណ្ឌកម្មស្រាលធ្ងន់ជាដើម ។

ខាងលើនេះ បើយកទៅអនុវត្តន៍ក្នុងសង្គម មុខជាសង្គមនីធ្លបានចម្រើនដុះដាលណាស់ ។ ព្រោះហេតុដូច្នេះ ការអប់រំពលរដ្ឋឲ្យពេញចិត្តខាងការសិក្សារៀនសូត្រ ជាឧសថទិព្វមួយ សម្រាប់កែរោគសង្គមទៀត ឲ្យឃ្លាតចេញចាកសន្តាន ដើម្បីនីធ្លរចនាប្រទេសយើងឲ្យសម្បូណ៌ទៅដោយអ្នកចេះដឹង, ជាហេតុធ្វើមាតុភូមិឲ្យឡើងទៅកាន់វឌ្ឍនធម៌បាន ។

៥- អារិសាធបទ

ព្រោះហេតុដូច្នេះ, អក្សរសាស្ត្រដែលនីធ្លឡើងទៅកាន់វឌ្ឍនភាពបាន មកពីមានជនជាតិខ្មែរនិយមអានសារពត៌មាន, ទស្សនាវដ្តី, សៀវភៅដោយភាគច្រើន ។ សត្វថ្លែប្រទេសកម្ពុជាសម្បូណ៌ទៅដោយអ្នកនិពន្ធ, ចំណែកអ្នកអានមានចំនួនតិច ។ បើបានប្រតិបត្តិតាមល័ក្ខគោលពាំង ៧ ខាងលើ, ប្រទេសកម្ពុជា នីធ្លទៅជាសម្បូណ៌ដោយអ្នកអានច្រើនទៅវិញ ជាហេតុឲ្យអ្នកនិពន្ធមានកំឡាំង ក្នុងការ

តែងសៀវភៅគ្រប់យ៉ាង ។ ចុះបើអ្នកនិពន្ធតែងសៀវភៅហើយ គ្មានអ្នកអាន, អ្នកទិញ, តើអ្នកនិពន្ធមានកំឡាំងពីណាមក ដើម្បីនឹងតែងសៀវភៅតទៅទៀត, មុខជាក្តីនដូចកវែ្ចបខែ្ចាំង, ឬដូចទំពាំងខែ្ចាំង ។ ម្ល៉ោះហើយ ចំនួនអ្នកនិពន្ធនឹងអន់ខន់ខ្លាយជាដកបហើយវិជ្ជាអក្សរសាស្ត្រក៏រេចរៃ វិនាសសាបសូន្យមិនខាន, អក្សរសាស្ត្រសាប់សូន្យ, បរទេសជាតិមាតុភូមិ សាសនា ក៏សាបសូន្យទៅជាមួយផង ។

បើជនរួមឈាមខ្មែរយើងតិច ១ ម៉ោងក្នុង១ថ្ងៃ សម្រាប់អានសារពត៌មាន, ទស្សនាវដ្តី, សៀវភៅ ប្រហែលជាប្រទេសកម្ពុជាទឹងចំរើនយ៉ាងណាទៅ ? បើប្រទេសកម្ពុជាវែ្ចបស្ងាត់ការហើយ, អ្នកនិពន្ធនឹងមានកំឡាំងទៅស្រាវជ្រាវឯកសារផ្សេង ។ តាមបណ្ណាល័យក្នុងទីក្រុង, ហើយអក្សរសាស្ត្រខែ្មរនឹងមានការចាត់ចង ខាងអក្សរសាស្ត្រប្រទេសនានា ទឹងវែ្បរតាំទៅជាអក្សរសាស្ត្រមួយថ្មី ក្នុងកាលអនាគតមិនខាន ។ បណ្ណាល័យតាំងអស់ ទឹងទៅជាឃ្លាំងវិជ្ជាមួយធំ សម្រាប់ឲ្យប្រជាជាតិទៅស្រាវជ្រាវបានតាមចិត្តបំណង ។

ចប់

លោក ស៊ុន-ហ៊ាន ប្រែរៀបរៀង

លោក យ៊ូរ-អ៊ុន ពិនិត្យកែសម្រួល

(ពមក)

កាលអមាត្យជាលិតនិយាយមកដល់ត្រឹមនេះ, នាងកាញ្ចនាតិតភ័យខ្លាំង ក៏សួរអមាត្យជាលិតដោយរួសរាន់:

– ឫទ្ធិស័ត្យធ្វើការសម្រេចទេលោក? ។

– "សម្រេច។ នាងក្នុង ៦ ៣ ត្រីប៉ុណ្ណោះ", រួចអមាត្យជាលិតនិយាយបន្តទៀតថា:

– ឫទ្ធិស័ត្យនិយាយថា លោកមានគុណធម៌មិនខុសអំពីបុត្តប្រុសដែលឈ្មោះសុវពលទេ ឫទ្ធិស័ត្យមានសេចក្តីស្មោះត្រង់ចំពោះកូនស្រីរបស់លោក ដែលជាស្រីប្រកបដោយគុណធម៌ដ៏ស្មោះត្រង់ គេមិនព្រមទទួលព្រះពរអំណោយអំពីព្រះពរជានៃនគរវេសាលីឡើយ ព្រះពរជាអង្គនោះទ្រង់មានព្រះធីតាដែលឫទ្ធិស័ត្យ បានចាត់ការថ្វាយព្រះទេសឲ្យបាត់ប្រយោជន ព្រះអង្គទើបត្រាស់ចំពោះមុខឫទ្ធិនឹងបណ្តាមុខអមាត្យទាំងឡាយថា ឫទ្ធិស័ត្យចូរថ្វាយវត្ថុណាដែលព្រះអង្គអាចនឹងឲ្យបាន ព្រះអង្គនឹងព្រះពរជាន តែឫទ្ធិស័ត្យបានទូលសុំវត្ថុដែលនរណាៗ ស្មានមិនត្រូវថាសូមលាត្រឡប់ទៅក្រុងពរគ្រឹះវិញ ឫទ្ធិស័ត្យបានច្រាប់ខ្ញុំថា ទិដ្ឋតាមរកលោកនឹងត្រូវការលោកឲ្យជួបជាមុនសិន តែគេមិនអាចនឹងមកជាមួយ

ទឹងខ្ញុំបានទេ ព្រោះគេមានការគិតដល់ប៊ីតាដែលចាស់ជរា ឥឡូវនេះគេដើរផ្លូវសំដៅទៅក្រុងភ្នំពេញហើយ ។

កាលដែលអមាត្យចាស់តកំពុងនិយាយរឿងបុត្តិស័ត្យនោះ សុរពលបានឡើងមកអង្គុយស្តាប់ហើយសម្លឹងមើលទៅនាងកាញ្ចនា ឃើញនាងអង្គុយមានមុខស្រក់ដោយសេចក្តីកិតក្តៃ ចំពោះសេចក្តីប្រព្រឹត្តិរបស់បុត្តិស័ត្យ ទើបសួរអមាត្យចាស់តថា:

- បុះបុត្តិស័ត្យបានប្រាប់លោកថា គេនឹងមកឯនគរពារាណសីក្នុងថ្ងៃណាដែរឬទេ? ។

- មិនប្រាប់ទេ មុននឹងបែកផ្លូវគ្នា បុត្តិស័ត្យគ្រាន់តែប្រាប់ខ្ញុំថាត្រាយពីទៅជួបទឹងប៊ីតាហើយ គេនឹងនៅផ្ទះអស់រយៈពេលមួយសែមសួរបើប៊ីតាគេសុខសប្បាយ គេនឹងតាមមកកេលោកទឹងគ្រួសារលោក ។

- "ខ្ញុំភ្ញាក់ក្រែងបុត្តិស័ត្យនឹងខូចវេលាតាមកខ្ញុំទៀត អស់វេលាច្រើនឆ្នាំ ដូច្នេះខ្ញុំនឹងទៅកបុត្តិស័ត្យខ្លួនឯង ព្រោះខ្ញុំឃើញចិត្តថ្នើមសម្លាញ់ម្នាក់នេះល្អប្រពៃណាស់" និយាយហើយសុរពលក៏បែរទៅសុំយោបល់ពីលោកនន្ទិដាវុត:

- វុតទឹងព្រមឲ្យខ្ញុំទៅកបុត្តិស័ត្យក្នុងក្រុងភ្នំពេញឬទេ? ។

- តាមចិត្តកូនបុះ តែវុតចង់បង្ហាញឲ្យមនុស្សក្នុងក្រុងភ្នំពេញក្រែចមុនវុតសិន ។

អមាត្យចាស់តពេញចិត្តទឹងសុរពល តាំងពីបានដឹងកិត្តិគុណរបស់គេមក បានតាំងចិត្តថាទឹងនាំខ្លួនសុរពលចូលទៅថ្វាយព្រះរាជាក្រុងពា-

ភណាស៎ លុះបានឮថាសុរពលបង់ទៅកប្ដិស័ត្យ ទៅក្រុងពាជគឹរក៏ប្រញាប់ហាមឃាត់:

- កុំទៅដោយខ្លួនឯងឲ្យហត់ឡើយឡើយ សុរពល! ចាំខ្ញុំធ្វើសំបុត្រទៅប្រាប់ប្ដិស័ត្យវិញចុះ ។

សុរពលនឹងអមាត្យនឹ្ង ក៏ត្រេកអរបានយល់ព្រមតាមពាក្យអមាត្យប្រាប់ត ។ វេលាពេលនោះ អមាត្យប្រាប់តបានស្នាក់នៅក្នុងផ្ទះអមាត្យនឹ្ង.

ក្នុងពេលនោះ អមាត្យប្រាប់តបាននិយាយពាយរឿងដែលជាពុទ្ធបំណងរបស់ព្រះធម្មបតីពាជាបង់បានព្រះពុទ្ធសុណិសាដ៏ល្អ ដែលមានសេចក្ដីចេះដឹងក្នុងវិជ្ជាការផ្សេង ។ ទើបបានបញ្ជូនខ្លួនឲ្យត្រាប់ស្វែងរកបុរសដែលគួរជាព្រះពុទ្ធសុណិសាបាននោះ, កាលគេបានជួបនឹងប្ដិស័ត្យហើយ គេតាំងចិត្តថានឹងនាំខ្លួនប្ដិស័ត្យទៅថ្វាយព្រះធម្មបតីពាជា តែប្ដិស័ត្យជាអ្នកចំពាក់ចិត្តនឹងបិតាដែលចាស់ជាង ព្រមទាំងមានបំណងបង់ជួបនឹងគ្រួសារលោកនឹ្ងផង ខ្លួនគេទើបដើរផ្លូវបែកគ្នាត្រឡប់មកដោយសេចក្ដីខ្មុសបំណង លុះមកជួបនឹងសុរពលដែលបានភ្ជាប់ដឹងរឿងពីរឿងប្ដិស័ត្យហើយ គេទើបកើតបំណងជាថ្មីឡើងថានឹងសូមអញ្ជើញសុរពលចូលទៅគាន់ក្រុងពាណាស៎ក្នុងថ្ងៃព្រឹកឡើង ដើម្បីឲ្យសុរពលបានជួបនឹងព្រះធម្មបតីពាជា ។ ដោយហេតុផលដែលអមាត្យប្រាប់តលើកយកមកអាងផ្សេង។, ក្នុងជាន់ដំបូងសុរពលប្រកែក តែជស់អមាត្យប្រាប់តនាំហេតុផលមកអាងផ្សេង។ទៀត ដើម្បីឲ្យសុរពលកែខ្លួនអំពីកំហុស

ដែលព្រះពាជារបស់នគរពាជគ្រឹះបានធ្វើមកហើយ គេក៏ត្រឡប់ជាយល់ព្រមតាមពាក្យអញ្ជើញរបស់អមាត្យឫសិតវិញ ។

នន្ទិអមាត្យបានដឹងថា សុរពលព្រមទៅនគរពាកណាសីហើយ ក៏មានសេចក្តីត្រេកអរ បានយល់ព្រមឲ្យសុរពលចូលទៅគាន់នគរពាកណាសីតាមសេចក្តីបំណងរបស់អមាត្យឫសិត, ក្នុងទីបំផុត ព្រះពាជានៃនគរពាកណាសីក៏ទ្រង់ជ្រាបព្រឹត្តិការណ៍នៃជីវិតរបស់សុរពល នឹងនន្ទិអមាត្យតាំងអំពីដើម ព្រះអង្គទ្រង់ព្រះមេត្តា ហើយត្រូវការនឹងលើកស្ទួយទូវបុរសដែលមានគុណធម៌ ព្រមទាំងបែកបន្ទឹងពេលដែលទ្រង់មានព្រះពាជបំណងផង ។ មិនយូរប៉ុន្មានអមាត្យដែលបញ្ជូនទៅគាន់នគរផ្សេង ។ ក៏បានអញ្ជើញបុរសដែលមានគុណធម៌ចេះដឹងត្រឡប់មកគាន់នគរពាកណាសី ។ កាលព្រះពាជាបានទ្រង់ពិចារណាទូវសមត្ថភាពរបស់បុរសគ្រប់គ្នាដែលនាំមកអំពីប្រទេសដទៃៗហើយ ទ្រង់បានសម្រេចលើកស្ទួយសុរពល ហើយបែកបង់ជីវិតយ៉ាង១ឡារកក្នុងនគរពាកណាសី ។ សុរពលបានជាព្រះស្វាមីនៃធីតាអគ្គមហេសីដែលទ្រង់ព្រះនាមថា កល្យាណី អំពីកាលនោះមក ។

* * *

សូមវិលត្រឡប់ទៅនិយាយអំពីបុទ្ធិសត្វវិញ ៖

បុទ្ធិសត្វដើរចេញអំពីក្រុងវេសាលីទៅគាន់ក្រុងពាជគ្រឹះ ជាមួយនឹងពាហានរបស់ព្រះពាជា នគរវេសាលី ដរាបដល់ផ្ទះចិតាមាតាដោយសុវត្ថិភាព ។ លុះមកដល់ផ្ទះ, បុទ្ធិសត្វក៏ចុះពីខ្នងសេះ ហើយដើរចូល

តម្រង់ទៅរកបិតា មិនបានសាកសួរដំណឹងអំពីអ្នកណាជាមុនទេ, កាលឡើងទៅដល់បន្ទប់បិតា កំឃើញបិតាសម្លាប់ខ្លួនទៅលើគ្រែ មានបង្ហូនទឹងម្ខាយអង្គុយទៅដុំវិញ ឫទ្ធិស័ត្យឈរស្ទឹងជិតទ្វារទៅមួយស្របក់ រួចបន្ទន់ខ្លួនលើកដៃសំពះម្ដាយឪពុកហើយហៅ: ពុក ! ម៉ាក់ ! ។

មនុស្សដែលទៅកងទ័ពនោះ កំបែរមុខមកសម្លឹងមើល ឯមាតារបស់គេក៏យំ ។

ឫទ្ធិស័ត្យចូលទៅជិតគ្រែបិតា ជ្រប់មុខចុះទៅលើបាតដៃរបស់ឪពុកដែលបានហុចដៃមកឲ្យគេ ។ នាងចន្លាតែជាមាតាចុះអំពីលើគ្រែមកអង្គុយជិតហើយនុបក្រសោបខ្លួនគេ ។ ដោយនាងមានសេចក្ដីត្រេកអរដែលឃើញឫទ្ធិស័ត្យត្រឡប់មក ទឹងដោយនាងមានសេចក្ដីតូចចិត្តទឹងឫទ្ធិស័ត្យដែលធ្វើឲ្យនាងទឹងស្វាម៉ី កើតអាល័យជាខ្លាំងពាល់តែស្វាម៉ីនាងឈឺចាប់ដួលចុះដោយសេចក្ដីក្រៀមក្រំចិត្ត នាងទើបនិយាយថា:

- ឫទ្ធិស័ត្យ ! ឯងមិនគួរទឹងដើរចាលឪពុកម្ដាយយូរម៉្លេះសោះ, ឯងមិនដឹងថា ឪពុកឯងឈឺចាប់ដួលដេក តាំងអំពីឯងចេញទៅទេ, ឪពុកឯងចាំមើលតែផ្លូវឯង, គាត់សម្លាប់ឈឺ ចាំមើលតែផ្លូវ ជាវេលាជាង ១ ឆ្នាំហើយ, ឯងនេះជាកូនប្អូនគេបំផុត ដែលមិនគាប់មានកោះត្រើយទៅឡើយហើយយើងតែងតិតពីរឿងនេះជានិច្ច ហេតុអ្វីឯងធ្វើឲ្យឪពុកម្ដាយកើតទុក្ខទឹងឯងយ៉ាងនេះ, មើលចុះឪពុកឯងក្រោកមិនរួចទេ កូនអើយ ! ។

ឫទ្ធិស័ត្យមិនអាចនឹងនិយាយតែងសោះខ្លួនបានឡើយ មានសេចក្ដី

ចុតណែនក្នុងខ្លួន ដូចជាមានអ្វីមកចុតគ្រង់ដើមខ្លួន, បិតាអង្គុលក្បាលរបស់គេទៅមក ។ :

– កូនសម្លាញ់ ! ឥឡូវគេតែអរណាស់ដែលឯងត្រឡប់មកវិតវិញនេះ, ក្នុងរយៈពេលតែមួយនោះ ឥឡូវយល់សប្តិឃើញថា ឥឡូវបានទៅរកឯង ជាន់ជួបហើយច្រាប់ឲ្យឯងត្រឡប់មកទៅខ្ទឹងឥឡូវវិញ ឯងក៏ខ្ជួលត្រមថាខ្ទឹងត្រឡប់មក, អស់រលោ ២ ខែមកហើយដែលឥឡូវយល់សប្តិដូច្នោះ ចុះឯងមានគិតដល់ឥឡូវឬទេ ? ។

ការត្រឡប់វិញរបស់បុត្តិស័ត្យ ធ្វើឲ្យបិតារបស់គេជាន់ខ្ជួលសេចក្តីសុខសប្បាយ, ។ លោកមិនត្រមចរចាខ្ទឹងនរណា អស់រយៈជាង ១ អាទិត្យមកហើយ ។ ខណៈនេះ អាការរបស់លោកក៏ស្រាលស្បើងបន្តិច, វង្វន់ក្នែកកករល្អក់ក៏ជាត់ទៅ, លោកព្យាយាមខ្ទឹងនើបមើសៈស្បើងមើលមុខបុត្តិស័ត្យ តែមិនអាចខ្ទឹងនើបមើលជាន់ឡើយ ។ បុត្តិស័ត្យគ្រាបចុះដឹតមាតាហើយយំ, បណ្តាបង្អួនជាន់ចូលមកចោមសួរសុខទុក្ខកន្លងការដើរផ្លូវ, បុត្តិស័ត្យជាន់ទិហើយច្រាប់តាំងអំពីចេញពីកន្លះទៅ ឲ្យបិតាមាតាបង្អួនជ្រាបរហូតដល់ការដួយស្រាចស្រង់ដំរីតមនុស្សខ្ទឹងសត្វកន្លងតរវៀសលើហើយជាន់ដួបខ្ទឹងអមាត្យចារិត ត្រមតាំងព្រះរាជាដែលមានសេចក្តីសន្តោះចំពោះខ្លួនគេហើយជាន់ឲ្យគេត្រឡប់មកនគរវិញ ដោយឲ្យតាហានរបស់ព្រះអង្គតាមដួនមកជាកិត្តិយសផង ។ បង្អួនមានសេចក្តីត្រេកអរក៏រកយត្រៀបគ្នា បិតាដែលកំពុងឈឺជាន់ស្តាប់បុត្តិស័ត្យទិហើយដោយសេចក្តីរីករាយ តែមកមានសេចក្តីតក់ស្លុតកន្លងចិត្ត កាលបើជាន

ដឹងថាបុត្តិស័ត្យ មិនជួបនឹងនូវអមាត្យ លោកទើបបង្គាប់ឲ្យគេមើលថែតាំគាហានដែលជូនមកឲ្យបានត្រជាក់ចិត្តដោយអាហារនឹងទឹកស្អាត់ ។ មាតាបុត្តិស័ត្យបង្គាប់មនុស្សប៉ំរើឲ្យធ្វើតាមដែលលោកបង្គាប់មិនឲ្យមានការខ្វះខាតគ្រប់ប្រការ ។

រាប់អំពីថ្ងៃដែលបុត្តិស័ត្យចូលមកនៅក្នុងផ្ទះ ធ្លើសេចក្តីកក់ក្តៅឲ្យកើតមានដល់បងប្អូនជាច្រើន, បិតារបស់គេក៏ជាត់ឈឺមួយថ្ងៃបន្តិច ។ ដោយបាននូវថតីសេចក្តីរីករាយចិត្ត ។ លោកស្រឡាញ់បុត្តិស័ត្យហើយមណ្ណាយតាមចិត្តគេពេក, បុត្តិស័ត្យក៏ដឹងថា ការដែលនឹពុកព្រមឲ្យគេលាទៅតាមរកនូវអមាត្យនោះ ព្រោះលោកខ្លាចក្រែងគេនឹងកើតទុក្ខអាចបណ្តាលឲ្យមានអន្តរាយទៅថ្ងៃក្រោយ ។ កាលមកនៅផ្ទះបាន ៣ ថ្ងៃហើយ បុត្តិស័ត្យទើបអនុញ្ញាតឲ្យគាហានដែលជូនមកត្រឡប់ទៅនគរវេសាលិវិញ, គេបានសរសេរបុតហ្វាយគ្រាប់បង្គំទូលពីការដើរផ្លូវរបស់គេ មកដល់ក្រែងពាកណាស៊ីដោយសេចក្តីសួស្តី ព្រមទាំងគ្រាបបង្គំទូលព្រះអង្គថា ខណៈនេះបិតារបស់គេឈឺស្ទើរតែនឹងមកមិនបានផងតែឥឡូវនេះ បិតារបស់គេមានអាការស្រួលបន្តិចហើយ បើប្រសិនជាបិតាមានអាការស្រួលជូចប្រក្រតីវិញ គេនឹងមកឧបសម្ព័ទទៅនគរវេសាលី តាមដែលព្រះពាសុំអង្វរគេ, កាលសរសេរបុតហ្វាយស្រេចហើយប្រគល់ឲ្យគាហាន, បុត្តិស័ត្យក៏ចាត់របស់ប្លែក ។ មានសំពត់យ៉ាងល្អមានតម្លៃទៅថ្វាយព្រះពាជា ហើយឲ្យរង្វាន់ដល់ពួកគាហានដែលជូនមកព្រមទាំងស្បៀងអាហារសម្រាប់ក្នុងផ្លូវមិនឲ្យលំបាក គាហានទាំងនោះ

កំណាគេត្រឡប់ទៅក្រុងវេសាលី ព្រមទាំងនាំបុត្រហ្នាយឡើងថ្វាយព្រះពុទ្ធ. ព្រះពុទ្ធទ្រង់ជ្រាបក៏មានព្រះឱង្ការត្រាស់អប ព្រះអង្គទ្រង់តាំងព្រះឱង្ការថា កាលបើបុត្តិសត្យចូលមកទទួលសម្ព័ទហើយបើលាចាកសិក្ខាបទវិញ ព្រះអង្គនឹងទ្រង់លើកព្រះធម៌តាឲ្យ. ព្រះអង្គទ្រង់តាំងព្រះឱង្ការដូចគ្នាតែ ១ អង្គឯង រង់ចាំវេលានឹងមកដល់កន្លងថ្ងៃខាងមុខតទៅ ។

o

* *

សូមរំលេចទៅថ្ងៃអំពីព្រះពុទ្ធាធិបតីនៃនគរពុទ្ធគ្រឹះវិញ ៖

ព្រះមហាក្សត្រអង្គនេះតាំងអំពីបានដកអមាត្យនទ្ធិចេញចាកតំណែងរាជការហើយ ព្រះអង្គក៏ទ្រង់តែងតាំងអ្នកដទៃតាង ព្រះនេត្រព្រះការណិតទៅ ។ អ្នកដែលចូលមកធ្វើជាអមាត្យតាងព្រះនេត្រព្រះការណ៍ដំនួសនេះប្រតិបត្តិរាជការមិនមានសេចក្តីខន់ក្នុងដូចនទ្ធិអមាត្យឡើយ កិច្ចការផ្សេងៗជួនកាលក៏ខ្វះខាត ជួនកាលក៏យឺតយូរ មិនរហ័សរហួន តែសេចក្តីស្មោះត្រង់មិនខុសគ្នានឹងអមាត្យនទ្ធិប៉ុន្មាន ព្រះពុទ្ធបានផ្ទាស់ប្តូរបុគ្គលដទៃមកដំនួសច្រើនលាក់ច្រើនគ្រាណាស់ ទាំងមានការលំបាកដល់ព្រះអង្គជាខ្លាំង ដរាបមកដល់អមាត្យបុង់គ្រាយបំផុតធ្វើកិច្ចការផ្សេងៗបានរៀបរយជាទីពុកព្រះទ័យគប់យ៉ាង តែព្រះអង្គក៏នៅតែទ្រង់នឹកដល់នទ្ធិអមាត្យជានិច្ច ព្រះអង្គបានជ្រាបថានទ្ធិអមាត្យមិនបាននៅក្នុងក្រុងពុទ្ធគ្រឹះហើយមិនមាននរណាដឹងថា នទ្ធិអមាត្យទៅនៅក្នុងនគរណា ព្រះអង្គក៏ទ្រង់ជឿជាក់ថា អមាត្យនទ្ធិនឹងបុត្រជាអ្នកពុទ្ធិតយ៉ាងពិតប្រាកដ ព្រះអង្គក៏លែងគិតដល់អមាត្យនទ្ធិនឹងបុត្រនោះតទៅទៀត ។ (មានត)

កណ្ឌទី ២៦

ទកញ៉ាវិបុលភាដសេន ឆ្ន - ភិន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
តំងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

អ៊ីកៀតក៏ទទួលពាក្យស៊ុនសេក ហើយដំរះគាយឲ្យអស់មន្ទិល លុះវេលាព្រឹកឡើងថ្ងៃរះស្រឡះ មេឃកំពុងត្តៅ អ៊ីកៀតក៏ឡើងទៅលើភេនពិធី ហើយយកតួរចនាំតទ្ធនដេកហាលថ្ងៃបរិកម្មសុំទឹកភ្លៀង អ្នកស្រុកទាំងអស់ក៏នាំគ្នាមកមើលមិដេរជាស ។ អ៊ីកៀតក៏ស្រែកប្រាប់មកអ្នកស្រុកទាំងអស់គ្នាថា: យើងនឹងសុំទឹកភ្លៀងឲ្យធ្លាក់មកយ៉ាងធំ ឲ្យទឹកលិចផែនដីជាង ២ ហត្ថឯក ពស្លូទាំងឡាយនឹងដាយធ្លើស្រែឲ្យបានបរិបូណ៌ គោះបីនឹងធ្លើបានដូចប្រាថ្នាក្តី ក៏ជីវិតយើងគ្រានេះយើញជាមិនរួចពីសេចក្តីស្លាប់ឡើយ ។ អ្នកស្រុកទាំងអស់គ្នាក៏ធ្លើយឡើងព្រមគ្នាថា បើប្រសិនជាហៅភ្លៀងឲ្យធ្លាក់ចុះមកបានមែនស៊ុនសេកមុខជាមិនយកគោសលោកទេ ។ អ៊ីកៀតស្រែកមកទៀតថា អាយុដ៏វែងយើងត្រូវស្លាប់ក្នុងថ្ងៃនេះហើយ គោះបីនឹងមាននរណាមកជួយដូចម្តេចក៏មិនបានដែរ ។

ខណៈនោះស៊ុនសេកក៏បង្គាប់ទាហានទាំងពួងថា: ឲ្យជញ្ជូនចំបើងមកគរពុកគ្រែមកេងពំធី បើហួសថ្ងៃត្រង់ហើយគ្មានភ្លៀងចុះមកទេ ឲ្យអុជភ្លើងដុតអីកៀតឲ្យដល់សេចក្តីស្លាប់ក្នុងទីនោះតែម្តង ។ លុះដល់ពេលថ្ងៃត្រង់ក៏កើតឡរល់ព្យុះខ្យល់ងងឹតអំពួអស់ទំហំទុំសទាំងពួង ទាំងមេឃអាកាសក៏ងងឹតដិតឈឹង ស៊ុនសេកឃើញមិនមានភ្លៀងធ្លាក់ក៏ថា: "អីកៀតជាមនុស្សហ្មេកកុហក ឲ្យនទំនួលថាខ្លួនហៅភ្លៀងឲ្យធ្លាក់ចុះឲ្យនឥឡូវគ្មានភ្លៀងសោះ" ទើបប្រើទាហានឲ្យឡើងទៅយកខ្លួនអីកៀតចុះមកចងពុកលើគំនរចំបើង ហើយអុជភ្លើងដុតអីកៀតនោះឥឡើង ខ្នួលភ្លើងកំពុងតែឥឡើងសន្ធោឡើង ស្រាប់តែមានសូរផ្គរលាន់ខ្លាំងគ្រប់ទិសភ្លៀងក៏រំលោងធ្លាក់ចុះមកយ៉ាងសម្បើមអស្ចារ្យ ទឹកភ្លៀងជន់លិចលើដែនពស្ងុងប្រហែលជំរៅ ២ ហត្ថប្តាយ ភ្លើងដែលដុតកំពុងតែឥឡើងសន្ធោសន្ធោនោះក៏រលត់ជាត់សូន្យឈឹងទៅ ។ អីកៀតក៏ស្រែកថាឲ្យភ្លៀងពំងចុះ ភ្លៀងនោះហាក់ដូចជាមានវិញ្ញាណ ក៏ពំងឈឹងសូន្យអស់ទៅមួយរំពេច ។ ទាំមុនទឹងបណ្តាកស្តេតាំងពួងឃើញថា អីកៀតធ្វើការនោះឲ្យនតូវកែសំក្តីសំទ្ធិណាស់ ក៏នាំគ្នាលុយហែលទឹកចុះទៅដោយមិនមានសេចក្តីរង្គៀសខ្វាចទឹកឡើយ លុះដល់ហើយក៏ស្រាយចំណងអីកៀតចេញហើយពនាំយកខ្លួនអីកៀតឡើងមក អ្នកទាំងអស់គ្នាក៏តំនាប់អីកៀត ។

ស៊ុនសេកឃើញដូច្នោះក៏មានចិត្តឥច្ឆាថា "នាមុនទឹងបណ្តាកស្តេស្រឡាញ់កប់អានអីកៀតជាច្រើនណាស់" ហើយស្រែកតំពាមថា: "ដែលភ្លៀងធ្លាក់ចុះមកនេះព្រោះអំណាចទេវតា អីកៀតជាមនុស្សហ្មេក

តុហកឲ្យថាហៅក្ងែងឆ្កាន ហេតុម្តេចអ្នកចាំងពួងទាំងគ្នាពាប់អានអីក្បែតថា មានសេចក្តីចេះដឹងសំក្តីសំខ្ញី ។ ថាហើយស៊ុនសើកក៏ដកហូតគ្រប់បង្គាប់ឲ្យតាហានច្រញាប់ទៅចាប់ខ្លួនអីក្បែតយកទៅសម្លាប់ ។ នាម៉ឺនចាំងពួងឃើញដូច្នោះក៏ភ័យស្ងួតស្ងាំងចាំងអស់គ្នា ទាំងគ្នាចូលទៅអង្វរសូមទោសស៊ុនសើក ។ ឯស៊ុនសើកឃើញតែតែងខឹងខ្លាំងឡើងទៀតហើយថា "អ្នកពាល់គ្នាពាប់អានអីក្បែតមកសូមអាយុដ៏វែងទុកនោះ ធ្លាប់ថ្នាំងគប់គិតចូលគំនិតគ្នាច្រឡូសក៉ាយដល់យើងឬទ្ធ ? នាម៉ឺនចាំងអស់នៅស្ងៀមមិនឆ្លើយថាម្តេចសោះ ឯតាហានស៊ុនសើកក៏ចូលទៅអូសតាញក្ត្រាក់ចាប់យកខ្លួនអីក្បែតបានហើយនាំទៅច្រហារដ៏វែងស្ងាប់មួយរំពេច ស៊ុនសើកក៏បង្គាប់ឲ្យយកសពអីក្បែតទៅដោតផ្ងារទុកនៅកណ្តាលផ្លូវច្រៃកជា ៣ ដើម្បីកុំឲ្យអ្នកឯណាយកតច្រាប់តទៅ ។

លុះដល់ពេលភាក់កណ្តាលអាធ្រាត្រ មានក្ងែងរំលោភាក់មកម្តងទៀត ខ្មោចអីក្បែតក៏ប្លាត់ពីទីនោះទៅ តាហានដែលយាមក្បែនោះទៅច្រាប់ស៊ុនសើក ។ ឯស៊ុនសើកឮដំណាស់ តិតនឹងសម្លាប់តាហាននោះចេញទៀត ទ្ធួលក្រឡេកទៅឃើញរូបអីក្បែតដើរកែក្បាយចូលមកត្រង់មុខស៊ុនសើក ។ រឹតតែមានសេចក្តីខឹងខ្លាំងណាស់ទៀត ក៏កន្ត្រាក់គ្រប់ខឹងគាប់រូបអីក្បែតនោះ ស៊ុនសើកក៏ដួលសន្លប់ប្លាត់ស្មារតីពុំដឹងខ្លួនទៅដីនោះ តាហានចាំងពួងក៏ភ័យស្ងួតស្ងាំងកាំងរត់ចូលទៅពន្លាហ៍ស៊ុនសើកចូលទៅដាក់ខាងក្នុង ហើយកែខៃឲ្យដឹងខ្លួនឡើងវិញ ឯនាងដឺហ្ងុយិន

ជាមាតាលុះដឹងដំណឹងហើយក៏ចេញទៅសួរសុំនសើកថា: ព្រោះអ្នកធ្វើអន្តរាយដល់អ៊ីកៀតទើបកើតមានហេតុដូច្នេះ ។

សុំនសើកបានស្តាប់ក៏អស់សំណើច ហើយថាខ្លួនខ្ញុំបានបានទៅជាមួយនឹងបិតាតាលធ្វើទំពាំងបានសម្លាប់មនុស្សជាច្រើនណាស់ ។ បើដូចគ្រាប់ឮប្រាប់ហួសវិស័យដែលនឹងពិបាកបាន ខ្ញុំក៏មិនមានអន្តរាយ ដែលខ្ញុំបានសម្លាប់អ៊ីកៀតជាមនុស្សបោកកុហកកណ្តាលស្រុកចេញដូច្នេះ ប្តូនឹងធ្វើសន្តានចិត្តមនុស្សឲ្យតាំងនៅក្នុងសេចក្តីសុចរិតពិតត្រង់ កុំឲ្យលុះទៅក្នុងសេចក្តីល្ងង់ខ្លៅ ត្រូវធ្វើចិត្តឲ្យទៀងត្រង់ជាសច្ចៈ កុំឲ្យវិបត្តិតិតពាក់អាងមនុស្សឥតសច្ចៈតទៅ ហេតុម្តេចមាតាមកថាខ្ញុំបានកើតហេតុនេះព្រោះសម្លាប់អ៊ីកៀតនោះវិញ ។ នាងដ៏ហ្ស៊ីយ៉ិនតបថា ដែលកើតហេតុដូច្នេះ ព្រោះអ្នកមិនដឹកប់អាងអ៊ីកៀត អ្នកបួរធ្វើបុណ្យបញ្ជូនវិញទៅឲ្យអ៊ីកៀត ទើបនឹងបន្ធូរបន្ថយសេចក្តីអន្តរាយបាន ។ សុំនសើកនិយាយថាដែលខ្ញុំបានមានអត្ថន័យដូច្នេះព្រោះទេពតាឲ្យនោះ ហេតុម្តេចមាតាមកឲ្យខ្ញុំបានពាក់អាងមនុស្សកុហកនោះវិញ ។

នាងដ៏ហ្ស៊ីយ៉ិនឃើញថាសុំនសើកមិនខ្លួលស្តាប់ពាក្យសោះ ក៏ត្រឡប់វិលទៅផ្ទះវិញ ហើយគិតនឹងធ្វើបុណ្យនិងសូមបញ្ជូនទៅឲ្យអ៊ីកៀតលុះវេលាកណ្តាលអធ្រាត្រ សុំនសើកក៏ដេកលើគ្រែដំណេក ខ្លួលឮស្រែកមកខ្ទៀនក៏រលត់ទៅ ក្នុងមួយរំពេចនោះភ្លើងក៏ឆេះឡើងវិញ ហើយក្រឡេកមើលទៅឃើញរូបអ៊ីកៀតមកឈរនៅពីមុខ សុំនសើកក្រោកឡើងក៏ស្រែកគំហកហើយថា "ចិត្តអញនេះស្អប់មនុស្សកុហក

ចោកបញ្ឆោតផ្សឹកាន់ខ្មោចបិសាចបានជាអញសម្លាប់ឯងចេញ ឥឡូវស្លាប់ទៅហើយ ហេតុម្តេចទៅជាអសុរកាយមកដិតអញទៀត" ថាហើយក៏ហូតគ្រឿចោលទៅ ។ រូបអ៊ីកៀតក៏បាត់ពីទីនោះទៅវិញ; នាងធំហ៊ូយិនបានឮសំឡេងស៊ុនសេកនិយាយនឹងអ៊ីកៀតដូច្នោះ ក៏តែតែមានសេចក្តីទុក្ខព្រួយជាខ្លាំងឡើងទៀត ស៊ុនសេកដឹងថាមាតាមិនសប្បាយក៏ទៅសួរហើយនិយាយថា មាតាកុំកើតទុក្ខព្រួយដល់ខ្ញុំបានឡើយ ខ្ញុំបានមិនបានអន្តរាយដោយអ្វីទេ ។

នាងធំហ៊ូយិនថា: អ៊ីកៀតនោះគ្មានសេចក្តីខុសគ្គឯអ្វីសោះ កូនសម្លាប់គេ ។ ក៏មានតំហឹង ទើបបណ្តាលឲ្យឃើញជារូបអសុរកាយមកប្រទូសព៉ាយកូនវិញ ឥឡូវម៉ែឲ្យមនុស្សរៀបចំធ្វើបុណ្យនៅវត្តយ៉ុកសៀងគួន កូនចូរប្រញាប់ចេញទៅតំនាប់បូជាអ៊ីកៀតចុះ ទើបបានសេចក្តីសុខមិនមានគ្រោះថ្នាក់អន្តរាយ ។ ស៊ុនសេកខឹងណាស់មាតាពុំបានកំរិលត្រឡប់ទៅផ្ទះវិញ លុះដល់ព្រឹកឡើងស៊ុនសេកក៏ចេញទៅឯវត្តយ៉ុកសៀងគួន លោកមេវត្តនោះក៏និយាយថ្កាប់ស៊ុនសេកថា គ្រឿងបូជារៀបចំស្រេចអស់ហើយ ឲ្យលោកចូលទៅអុជទៀនធូបបូជាចុះ ។ ស៊ុនសេកក៏ចូលទៅអុជទៀនធូបឡើង តែមិនបានតំនាប់បូជា ក្នុងខណៈនោះក៏ឃើញរូបអ៊ីកៀតអង្គុយអណ្តែតលើផ្សែងធូប ស៊ុនសេកខឹងណាស់ជេរថា "អាអ៊ីកៀតចង្រៃអប្រិយ៍ចេញឆាប់ទៅ" ហើយដើរត្រឡប់មកដល់មាត់ទ្វារកើត ក៏ឃើញរូបអ៊ីកៀតឈរសំឡក់ក្បែរមាត់ទ្វារទៀត ស៊ុនសេកខឹងណាស់ក្រាក់គ្រឿចោលទៅត្រូវខោហានដែល

សម្ងាប់អីកៀតនោះដួលសន្ធប់ចុះ ចេញឈាមពីច្រមុះនឹងមាត់ដូចគេផ្ទុះ ចេញមកកំដាច់ខ្យល់ស្លាប់ ស៊ុនសេកមានសេចក្តីអាណិតណាស់ ឲ្យរៀបចំសពនាំទៅកប់តាមប្រពៃណី ស៊ុនសេកក៏ដើរចេញពីមាត់ទ្វារទៅ ឃើញរូបអីកៀតដើរធ្វេងទៅមកពីខាងមុខ ។

ស៊ុនសេកក៏ថា វត្តនេះមានខ្មោចបិសាចមកនៅច្រើនលង់ឃាយ៉ាកាចគេកណាស់ ទីង៉ុកតទៅមិនបាន ទើបបង្គាប់ឲ្យរើរុះចេញ តាហានតាំងពួងក៏ធ្វើតាម ឯរូបអីកៀតក៏ទៅនៅលើដំបូលវិហារយកក្បឿងរះចាលគ្រវែងចុះមកត្រូវតាហានរបួសតិចតួចគ្រប់គ្នា តាហានក៏ខ្លាចមិនអាចចូលទៅរើរុះបានឡើយ ស៊ុនសេកក៏បង្គាប់លោកមេវត្តឲ្យហៅគ្នាដើរចេញឲ្យអស់ពីកង៉វត្ត ហើយបង្គាប់ឲ្យតាហានយកភ្លើងមកតវដុតវត្តនោះឆេះឡើង ស្រាប់តែឃើញរូបអីកៀតអណ្តែតទៅកង៉អណ្តែតភ្លើង ស៊ុនសេកនឹកខឹងណាស់ក៏ត្រឡប់មកផ្ទះ ឃើញរូបអីកៀតមកឈរនៅទ្វារទៀត ស៊ុនសេកគ្រាទៅពុំបានក៏នាំសេនាតាហានទៅចោះទ័ពទៅខាងក្រៅស្រុក ហើយទីប្រឹក្សាមកពន្យល់ការនឹងលើកកងទ័ពទៅជួយអ៊ូនសៀវដើម្បីច្បាំងកំចាត់ចូជ្ជ ។

ទីប្រឹក្សាតាំងពួងនិយាយហាមឃាត់ថា: លោកមិនគាន់សះជាជម្ងឺរបួស បើប្រញាប់លើកទ័ពទៅនោះ របួសព្រួញក៏ទឹងកំរើបខ្លាំងឡើងទៀត សូមឲ្យបង្អង់ឈប់សិន បើបានសះជាវេលាណាសឹមលើកទ័ពទៅវេលានោះ ។ ស៊ុនសេកស្តាប់បានហើយក៏ឲ្យគេឲ្យមករក្សាជម្ងឺវិញ ។ វេលាយប់ ១ ស៊ុនសេកឃើញរូបអីកៀតមកឈរសំយ៉ាក

សក់លឿនអណ្តាតខមក្អែកខៅប្រមវែតដេក ស៊ុនសើកទឹងណាស់ត្រាក
ខ្លើនស្រែកតំហាកជារច្រើនជង្គាលតែដល់ក្តី នាងង៉ូហ៊ូយិនកឲ្យហៅខ្លួន
ស៊ុនសើកចូលខៅជួប នាងឃើញរូបស៊ុនសើកនោះស្គាំងស្គមខុសប្លែក
ឥរិយាបថតាក៏ទឹកភ្នែកយំបារម្ភយំសោកជាខ្លាំងហើយថា "មុខមាត់អ្នកសៅហ្មង
ស្គាំងស្គមខ្លាំងណាស់ ។ ស៊ុនសើកបានឮមាតាថាដូច្នោះក៏ពាញយក
តញ្ចក់មកឆ្លុះមើលមុខ ឃើញរូបរាងកាយដូចតាក្សម្លាយច្រាប់ក៏ស្តុតកង
ចំគ្គខើបថា "រូបរាងកាយខ្ញុំបានបង់ខោមខៅដល់យ៉ាងនេះ" ក៏ក្រឡេក
ខៅឃើញរូបអីកៀតខៅក្នុងតញ្ចក់ ស៊ុនសើកទឹងក៏ចោះតញ្ចក់នោះចេញ
ហើយស្រែកយ៉ាងខ្លាំង របួសប្លែញនោះក៏តែតែខ្លាំងខ្លើង លោហិត
ហូរចេញមកដួលសន្លប់ខៅខៅទីនោះ ។ កវិយាស៊ុនសុកទឹងស្រីតាំង
ពួងក៏នាំគ្នាគ្រាហ៍ពលើកខ្លើងជាស់ឲ្យដឹងខ្លួន ស៊ុនសើកដកឆ្អើមធំ
ហើយថាជីវិតយើងក្នុងគ្រានេះមុខជាមិនរួចពីសេចក្តីស្លាប់ខេ ខើបឲ្យ
ហៅស៊ុនគួនជាប្អូនទឹងខៀវចៀវមកប្រជុំគ្នា ទឹងទីប្រឹក្សាតាំងពួងខៅខាង
ក្នុងហើយនិយាយថា "ខ្ញុំនយើងពេលនេះមុខជាមិនរួចពីសេចក្តីស្លាប់ខេ
វែនដីសព្វថ្ងៃកើតចលោចលះផ្សេង។ ឯស្រុកតាំងតាំងនេះជាស្រុកធំ ខៀវ
ចៀវបួរដួយរៀបចំរៃគិតខំទុកបំរុងស៊ុនគួនផង ឲ្យស៊ុនគួនរក្សាស្រុក
ដោយទំនៀមទំលាប់ប្រពៃណីពីបុរាណ" ខើបឲ្យយកគ្រាស់ពង់ងារមក
ប្រគល់ឲ្យស៊ុនគួនហើយឆ្លាថា "ខ្ញុំនអ្នកត្រូវបានជាធំក្នុងស្រុកតាំងតាំង
នេះហើយ បួរតែរិះរិគិតការសង្គ្រាមឲ្យជំនាញស្ទាញស្ទាត់តាំងផ្លូវទឹកទឹង
ផ្លូវគោកដូចយ៉ាងបង តែឯការដែលប្រើចិត្តផ្លូវខ្លាយកេរពាយកប់អាន

សេនាគាហានោះ ប្អូនមានចិត្តគំនិតធ្ងន់ធ្ងរច្រើនជាងបងណាស់ បងនេះជាមនុស្សចិត្តស្រាលរហ័សមិនដូចប្អូនទេ មួយទៀតបើប្អូនខ្វល់អ្វីការអ្វី ។ គប្បីថ្នាក់ថ្នមរក្សាទុករបស់ជាកេរ្តិ៍ដំណែលដែលបិតានឹងបង**ចាន**គ្រប់គ្រងចាត់ចែងទុកមកដោយការនឿយលំបាក ទើបនឹងមានចរិបូណ៌ឡើងត្រឹមណេះ ប្អូនត្រូវបំរុងរក្សាកុំឲ្យរបស់ទាំងនោះអន្តរាយទៅវិញ ។ ស៊ុនគួនខឲ្លួយកត្រាសំពត់ងារ ហើយក៏តំនាំចាប់យកពាក្យបណ្តាំបងប្រុសដែលរំលឹកប្រដៅក៏សោកស្តាយអាលោះអាល័យ ។

ស៊ុនសេកក៏និយាយជំរាបមាតាថា ខ្លួនខ្ញុំបានឮដល់ខ្លូវសេចក្តីស្លាប់ហើយឯត្រាសំពត់ងារនោះ ខ្ញុំបានប្រគល់ឲ្យស៊ុនគួនជាប្អូនខឲ្លួលធ្វើការជំនួសតទៅ សេចក្តីទុក្ខត្រូវដូចម្តេចសូមអ្នកម្តាយជួយរំលឹកខ្លួនាន កុំឲ្យប្អូនខ្ញុំបានប្រមាថមើលងាយនាយគាហានដែលមានជាប់មកពីបិតា ។ ខាងឯ**ហ៊ូយ**ិនបានឮពាក្យស៊ុនសេក ក៏ស្រក់ទឹកភ្នែកយំយែកដោកជ្រាណាអាលោះអាល័យ ទើបស្រដីថា ស៊ុនគួនប្អូនអ្នកកំនៅក្មេងណាស់ គ្រែងនឹងរក្សាស្រុកតាំងតាំងនេះមិនបាន ។ ស៊ុនសេកឆ្លើយថា ឯស៊ុនគួននេះទោះប៉ន្មានក្មេងក៏ពិតមែនហើយ តែមានដម្រែជ្រាជាស្មារតីច្រើនជាងខ្ញុំបាន ១០ ភាគទៅទៀត ខ្ញុំបានយល់ឃើញថានឹងគ្រប់គ្រងស្រុកតាំងតាំងបាន ឯការខាងក្នុង ប៉ើលើសតំនិតឲ្យយកចិត្តពិគ្រោះប្រឹក្សានឹងទៀរៀបៀវ ឯការខាងសង្គ្រាមបើចាំបាច់ប្រការម្តេចក៏ឲ្យពិគ្រោះប្រឹក្សានឹងដ៏វាយីចុះ តែខ្ញុំបានទៅតូចចិត្តណាស់ព្រោះមិនបានជួបនឹងដ៏វាយីក្នុងវេលានេះមិនបានផ្តាំពាក្យពេចន៍ដល់មាត់នឹងមាត់សោះ ។ (មានត

រឿងព្រេងនិទាន

លោកសម៉ន ម្ចាស់ឆ្នេរជើមៈតែង

លោក ប៉ាយ-ប៊ុក ក្រមការដើមខ្សែ ប្រែរៀបរៀង

(ត)

និទានទីមួយ ទេពធីតាទី ៣១

មានកាលមួយថ្ងៃ, ព្រះបាទកោដៈទ្រង់តម៉ងជាតបល្ល័ង្កទិព្យដើម្បីទ្រង់ធ្វើមុខ្មាកិសេក, ស្រាប់តែរូបទេពធីតាទី៣១ សាមសិបមួយ ពោលថា: "ទូលព្រះបាទកោដៈ, សូមទ្រង់ព្រះសណ្ដាប់ខ្ញុំមហាសប្បុរិសធម៌នៃមហាកដវិក្រមាទិត្យដែលមានបល្ល័ង្កទិព្យនេះ ជាព្រះពជកម្មសិទ្ធិរបស់ព្រះអង្គ ដូចតទៅនេះ ៖

"ថ្ងៃមួយ, បុត្រនៃនាយពាណិជម្នាក់មកពីភូមិមួយ ធ្វើដំណើរទៅកាន់ទីក្រុងអវន្តី ដើម្បីទិញលក់នូវទំនិញផ្សេង ។ ។ នៅទីនោះ, បុរសបានពិនិត្យមើលដោយជាក់លាក់ នូវរបៀបរបបនៃពួកអ្នកនៅក្នុងនគរនៃព្រះពជមធ្យាបាយរបស់មហាកដវិក្រមាទិត្យ ។ ដល់វិលត្រឡប់ទៅកាន់ភូមិលំនៅវិញ, បុត្រនាយពាណិជនោះក៏បានពយាយាមរឿងផ្សេង។ ក្នុងកិច្ចធ្វើដំណើរ, នេះដំរាបបិតាថា: "ទូលបិតា! ខ្ញុំបានទៅដល់ទីក្រុងអវន្តី, បានជួបប្រទះនឹងវត្ថុមួយប្រកបដោយសេចក្តីអស្ចារ្យណាស់ ។ ទំនិញតាំងឡាយដែលស្ថិតនៅក្នុងពាណិជ្ជស្ថាន, មានអ្នកទិញមកទិញទំនិញ

ដែលខ្លួនពេញចិត្តហើយនាំយកទៅ, ទៅសល់តែទំនិញមិនល្អ, ព្រះមហាក្សត្រិយ៍វិក្រមាទិត្យ ដោយទ្រង់ខ្ជាប់ក្រែងខ្លួចកិត្តិស័ព្ទដល់ទនាព្រះអង្គ, ទ្រង់ក៏បានត្រាស់បង្គាប់ឲ្យទិញសម្រាប់ព្រះអង្គឯង តាមតម្លៃទំនិញនោះ ។

"នាយពាណិជពាលទុច្ចរិតនោះ ដោយបានស្តាប់ខ្សែសេចក្តីពណិនាវបស់បុត្រ, ក៏បាននាំយករូបមួយធ្វើពីដែកឈ្មោះថា ទារិទ្រ (Dâridra) ហើយក៏យករូបនោះទៅដាក់លក់ខ្សែផ្សារអន្តិ ។ ពួកអ្នកទិញក៏បានចូលទៅជិតនាយពាណិជពាលនោះ ហើយក៏បានសួរខ្សែតម្លៃនៃរូបនោះ ។ នាយពាណិជពាលក៏តបទៅអ្នកទិញវិញថា: "រូបនេះឈ្មោះ ទារិទ្រ, តម្លៃមួយម៉ឺនមូទ្រ: អ្នកដែលគាន់រូបនេះ បានដណ្តើមយកពីព្រះនាងលក្ស្មី, ព្រះនាងក៏ទ្រង់ប្រគល់រូបនេះឲ្យទៅគាត់ដាច់ដាកម្មសិទ្ធិ" ។ ពួកអ្នកទិញ, ដល់បានស្តាប់ខ្សែពាក្យអធិប្បាយនាយពាណិជទុច្ចរិតក៏ពោលថា: "យើងទុកឲ្យពួកបច្ចាមិត្តយើងទិញរូបនោះចុះ!", ហើយពួកអ្នកទិញក៏ដើរហួសទៅ ។ តាំងពីបុព្វណ្ហសម័យរហូតដល់សាយណ្ហសម័យ, រូបនោះគ្មានអ្នកណាទិញសោះឡើយ ។ លំដាប់តមក, ព្រះរាជអមាត្យ ក៏ជាផ្លែព្រះមហាក្សត្រិយ៍ ស្តេចយាងមកដល់ទីនោះ ។ ព្រះរាជអមាត្យ ក៏ក្រាបបង្គំទូលទ្រង់អំពីរឿងរ៉ាវសព្វគ្រប់ប្រការ ។ ដើម្បីប្រតិបត្តិតាមព្រះរាជកិច្ចសន្យារបស់ព្រះអង្គ, ទ្រង់ក៏ព្រះរាជទានខ្សែតម្លៃ ១០.០០០ មូទ្រទៅនាយពាណិជពាល, ហើយក៏ត្រាស់បង្គាប់ឲ្យយករូបនោះទៅរក្សាទុកក្នុងព្រះរាជឃ្លាំង ។

"កន្លងថ្ងៃនោះ ពេលយប់, ព្រះនាងលក្ស្មីដែលជាទេវតារក្សាស្ងួតច្នួត ចាន់បង្ហាញខ្លួរូបភាពចំពោះព្រះអង្គ ហើយសូមលាព្រះអង្គចេញពីព្រះបរមរាជវាំង ។ ខ្ញុំក៏ធ្វើអញ្ជលីចំពោះទេវធីតាលក្ស្មី ដោយសុភាពមិនដែលគាវគាត ហើយមានព្រះរាជឱង្ការថា "នុមាតា, ព្រះនាងលក្ស្មី តើខ្ញុំធ្វើអ្វីខុសទាស់ត្នងចំពោះព្រះនាង? ខ្ញុំមិនដែលធ្វើឲ្យព្រះនាងខ្ញុំអាក់អន់ព្រះចិត្តសោះឡើយ, ហេតុម្តេចក៏ព្រះនាងខ្ញុំបោះបង់ចោលខ្ញុំ?" ។ ព្រះនាងលក្ស្មីទូលព្រះបាទវិក្រមាទិត្យថា "ខ្ញុំមិនដែលធ្វើអ្វីឲ្យព្រះអង្គអាក់អន់ចិត្តទេ, តែព្រះអង្គមិនអាចស្ថិតនៅកន្លងទីនេះបានទេ ព្រោះទីនេះមានរូបទាវិទ្វេះ ជាហេតុឲ្យខ្ញុំត្រូវតែលះបង់ចោលទីនេះ" ។

កន្លងពេលនោះ ខ្ញុំក៏មានព្រះរាជឱង្ការថា "បើព្រះនាងខ្ញុំចេញចោលទីនេះដោយហេតុខាងលើ សូមខ្ញុំយាងចុះ, យើងមិនអាចក្បត់នូវកិច្ចសន្យា ដោយប្រការយ៉ាងណាសោះឡើយ" ។ ក្រោយដែលព្រះមហាក្សត្រិយ៍ខ្ញុំមានព្រះរាជបន្ទូលដូច្នោះ, ព្រះនាងលក្ស្មីខ្ញុំក៏យាងចេញពីព្រះបរមរាជវាំង, ហើយកន្លងពេលនោះព្រះរាជគុណាសម្បត្តិគឺ វិចារណៈ, សោរច្ចៈ, ខន្តី, មេត្តា, អប្បមាទ, ទឹងព្រះរាជគុណាសម្បត្តិឯទៀតជាច្រើនក៏បោះបង់ចោលព្រះអង្គ ព្រោះព្រះអង្គត្រូវបំពេញទៅតាមព្រះរាជកិច្ចសន្យា, ជាការចាំបាច់ខានមិនបាន ។

រួចព្រះរាជគុណាសម្បត្តិ "សច្ចៈ" ចាន់បង្ហាញខ្លួរូបភាពឲ្យឃើញជាក់ស្តែង ហើយសូមលាព្រះអង្គចេញពីព្រះបរមរាជវាំង ។ ខ្ញុំ

មិនត្រមង់ "សច្ចៈ" ចេញ, ហើយទ្រង់សុំឲ្យសច្ចៈស្ថិតនៅជាមួយទ័ណ្ឌព្រះអង្គ ។ ទ្រង់មានព្រះបន្ទូលតទៅទៀតថា: "ដោយហេតុយើងគាន់សច្ចៈ, ប៉ានជាព្រះនាងលក្ស្មីទ័ណ្ឌគុណសម្បត្តិឯទៀតលះបង់ចោលយើង ។ តើហេតុអ្វីបានជាសច្ចៈឯងចោះបង់ចោលយើង?" ។ គុណសម្បត្តិសច្ចៈក្រាបបង្គំទូលថា: "ទូលព្រះបង្គំដែលចោះបង់ចោលព្រះអង្គ ព្រោះទូលព្រះបង្គំមានបច្ច័យគាក់ទងនឹង វិចារណៈ, សោរច្ចៈ . . . ល . . . ។ បើទ្រង់មិនចង់ឲ្យទូលព្រះបង្គំចោះបង់ចោលទ្រង់ទេ, សូមទ្រង់លះបង់ខ្លួនព្រះកាកិច្ចសន្យាដែលទ្រង់បានបំពេញចំពោះគាត្រ ឬជាទ្រង់ធ្វើដោយព្រះហស្តព្រះអង្គឯង ឲ្យព្រះបរមរូបព្រះអង្គវិនាសអន្តរាយ, លះបង់ខ្លួនព្រះបរមរូបនេះ, ទូលព្រះបង្គំនឹងតាមព្រះអង្គទៅបរលោកនាយទៀត" ។

ព្រះអង្គទ្រង់ព្រះសណ្តាប់ខ្លួ "សច្ចៈ" គោលដូច្នោះ. ទ្រង់មានព្រះរាជហឫទ័យកំយតក់ស្ទុត់, ទ្រង់ធ្វើឲ្យវិនាសខ្លួកិច្ចសន្យាដែលទ្រង់បានបំពេញចំពោះ "សច្ចៈ" ហើយទ្រង់មិនអាចទ័ណ្ឌបែបែកខ្លួព្រះរាជទណ្ឌារបាន, ទ្រង់ក៏ចាប់ព្រះខ័នថ្វាយបង្គំទ័ណ្ឌតាត់ព្រះសិរសោ ។ ប៉ុន្តែ, ក្នុងពេលនោះ សច្ចៈក៏ស្ទុះមកចាប់ព្រះហស្តព្រះបាទរិត្រមាទិត្យ ហើយក្រាបបង្គំទូលព្រះអង្គថា: "បពិត្រព្រះសម្មតិទេព! ដោយទូលព្រះបង្គំចង់ពិសោធមើល តើព្រះរាជហឫទ័យស្មោះស្ម័គ្រទ័ណ្ឌព្រះរាជតរណីយកិច្ចរបស់ព្រះអង្គមានពលភាពត្រឹមណា, បានជាទូលព្រះបង្គំពោលដូច្នេះ ។ ទូលព្រះបង្គំបានយល់ហើយថា ទ្រង់មានព្រះរាជហឫទ័យខ្ជាប់ខ្ជួនទ័ណ្ឌប្រាប់មែនពិត ។ តំហេយវត្តនៃមនុស្សជាតិជាទីលំនៅរបស់ទូលព្រះបង្គំ;

ព្រោះហេតុដូច្នោះ, ខ្ញុំលែងបង្គំឈប់លះបង់ចោលព្រះអង្គហើយ, ខ្ញុំលែងបង្គំនឹងស្ថិតនៅជិតព្រះអង្គជានិច្ចនិរន្តរកាល" ។ បន្ទាប់, មិនយូរប៉ុន្មាន, ព្រះនាងលក្ស្មីនាងទេវធីតាព្រះពុទ្ធសូត្តច្ចត្រ ដែលមានសច្ចៈថាក់ទងនឹងវិចារណៈ ព្រមទាំងព្រះពុទ្ធគុណសម្បត្តិឯទៀត ក៏លែងឡប់មកនៅរួបរួមជាមួយព្រះអង្គវិញ ។

រួបទេពនិម្មិតទីសាមសិបមួយ ទូលបន្ទូលថា: "បពិត្រព្រះបាទគោជ: មហាបុរសដែលមានចិត្តជាប់ស្ថិតនឹងសច្ចៈធម៌ដូច្នេះ, ទើបអាចគង់នៅលើបល្ល័ង្កទិព្យនេះបាន" ។

កន្លងពេលដែលស្តាប់ទៅពាក្យរួបហើយ, ព្រះបាទគោជ:ទ្រង់យោងវិលត្រឡប់ទៅវិញ, ខាងឯព្រះពុទ្ធជាតិសេតវ៉ែ្ងនោះ ។

* * *

និទានដែលរួបទេពនិម្មិតទី ៣២

មានកាលមួយថ្ងៃ, ព្រះបាទគោជ:មានពុទ្ធបំណងចង់ធ្វើព្រះពុទ្ធជាតិសេតនៅលើបល្ល័ង្កទិព្យ ។ ស្រាប់តែរួបទេពនិម្មិតទីសាមសិបពីរក្រាបបង្គំទូលថា: "បពិត្រព្រះបាទគោជ:, មានតែមហាពុទ្ធវិក្រមាទិព្យទេដែលមានព្រះសីលធម៌អាចគង់នៅលើបល្ល័ង្កទិព្យនេះបាន ។ សូមទ្រង់ព្រះសណ្តាប់អំពីព្រះពុទ្ធគុណសម្បត្តិ របស់ព្រះពុទ្ធអង្គនោះដូចតទៅនេះ ៖

"មានកាលមួយថ្ងៃ ព្រះបាទវិក្រមាទិត្យទ្រង់បានជួបប្រទះនឹងសេចក្តីលំបាកយ៉ាងក្រៃលែង ដោយហេតុមានកូមិភាគជាច្រើនកន្លែងគ្មានស្រូវមួយគ្រាប់សោះ ។ ពួកប្រជាពស្តេចទៅរឹតតែ ។ ដែលមានទុព្ភិក្ខភ័យជាខ្លាំងក៏គិតគ្នាថា : "ព្រះមហាពងវិក្រមាទិត្យទ្រង់មានព្រះរាជហ្វាទ័យស្មោះស្ម័គ្រនឹងព្រះរាជការណ៍យកចិត្តពន់ពេក, នោះប្រទេសព្រះអង្គគ្មានទុព្ភិក្ខភ័យទេ, យើងតួរនាំគ្នាទៅទីនោះដើម្បីសូមឲ្យព្រះអង្គស្រោចស្រង់យើងទាំងអស់គ្នាឲ្យផុតពីភ័យខ្លាច" ។ ដល់គិតដូច្នេះពួកប្រជាពស្តេកំនាំគ្នាធ្វើដំណើរពីប្រទេសមួយទៅប្រទេសមួយរហូតដល់ព្រះពន្ធគាណាចក្រមហាពងវិក្រមាទិត្យ ។

ព្រះរាជបេសកៈព្រះអង្គកំយកសេចក្តីនេះ ក្រាបបង្គំទូលទ្រង់ ។ កំបានត្រាស់បង្គាប់ឲ្យធ្វើព្រះរាជសារលិខិត ផ្ញើយទៅគ្រប់ផ្នែរបស់ព្រះអង្គថា : "បើពួកបរជនមកដល់ប្រទេសព្រះអង្គ ដើម្បីនឹងសូនរកម្ហូបអាហារបរិភោគ, សូមឲ្យពួកនេះបរិភោគបានដោយសេរី, កុំឲ្យអ្នកណាហាមឃាត់សោះឡើយ ។ បើក្នុងពេលនោះពួកនេះទិញអស់ប្រាក់ចំនួនប៉ុន្មាន, ឃ្លាំងព្រះរាជទ្រព្យនឹងសងប្រាក់នោះឲ្យគ្រប់ចំនួន" ។ កាលណាព្រះរាជសារលិខិតនេះបានផ្សាយហើយ, មន្ត្រីទាំងអស់ក៏ប្រតិបត្តិតាមពេញលក្ខណៈ ឥតមានធ្វេសប្រហែសសោះ ។

ក្នុងពេលនោះ, មានពួកសេដ្ឋីនៅឯគរនោះ ដែលធ្វេសប្រហែសមិនបានទិញម្ហូបអាហារបម្រុងទុក, ក៏ចូលទៅក្រាបបង្គំគាល់ព្រះបាទវិក្រមាទិត្យហើយទូលថា : "បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំយើង

ខ្ញុំជាពលរដ្ឋនៅកន្លែងនេះ, ជាបុគ្គលិកមានកិត្តិយស, យើងខ្ញុំចាំងឡាយមិនបានផ្លាស់ប្តែរ ត្រូវតែទិញម្ហូបអាហារសម្រាប់ចិញ្ចឹមជីវិតដោយខ្លួនឯង, យើងខ្ញុំចាំងឡាយ សត្វថ្ងៃនៅសល់ក្រាក់តែចំនួន ១០០ មួយទេ; ព្រោះហេតុនេះ យើងខ្ញុំចាំងឡាយ គ្មានមធ្យោបាយណាខ្លឹងចិញ្ចឹមជីវិតខ្លួនឯង ព្រមទាំងចិញ្ចឹមមនុស្សអាស្រ័យនៅក្នុងគេហដ្ឋានបានឡើយ" ។

ក្រោយដែលទ្រង់ព្រះសណ្តាប់ខ្លឹវាក្យដែលបុគ្គលវិសេសទាំងនេះពោល, ទ្រង់ក៏មានព្រះពាជហ្ឫទ័យធ្ងៀងធ្ងល់ពន់ពេក, ហើយទ្រង់ព្រះតម្រិះថា "បើអញដេញចេញខ្លួវបជនដែលកំពុងលំបាកដោយសេចក្តីអត់ឃ្លាន, វាចារបស់អញគ្មានផលប្រយោជន៍អ្វីឡើយ; បើអញហាមក្រមមិនឲ្យអ្នកលក់ស្វែងរកផលប្រយោជន៍ចំពោះខ្លួនឯងឡើងវិញ, ការដែលអញជួយឧបត្ថម្ភជាសាកលខ្លួវប្រជាកស្តាំងអស់ ទីនៅជាមិនបានការ" ។ ដល់ទ្រង់មានព្រះពាជហ្ឫទ័យធ្ងល់ដូច្នេះ, ទ្រង់ក៏សំបូងសន្ធឹងដល់ព្រះនាងបរមេស្សរី (Parameçvari) ។ ក៏បង្ហាញខ្លួនព្រះនាងឲ្យព្រះអង្គឃើញជាក់ច្បាស់ ហើយក៏ពន្យល់បំភ្លឺព្រះអង្គថា: "បពិត្រព្រះមហាពាជ សូមព្រះអង្គកុំព្រួយព្រះពាជហ្ឫទ័យសោះឡើយ, សូមព្រះអង្គមានព្រះពាជបំណងយ៉ាងណា, សូមព្រះអង្គបញ្ជូញព្រះបន្ទូលសួរសុខទុក្ខមកចុះ" ។ ក្រោយដែលទ្រង់ព្រះសណ្តាប់ខ្លឹវាចារព្រះនាងបរមេស្សរី, ទ្រង់ក៏ធ្វើអញ្ជលីកម្មចំពោះព្រះនាង ហើយក៏សូត្របសំសកថាជាពាក្យកាព្យនិងពាក្យកាយ ថ្វាយពរសំពុសាធុការ

ចំពោះព្រះនាងហើយមានព្រះបន្ទូលថា: "បពិត្រព្រះទេវធីតា, បើព្រះនាងសប្បាយចិត្តនឹងយើង ។ សុំពរនេះពីព្រះនាង គឺសុំឲ្យគេហដ្ឋានមួយ ។ ដែលស្ថិតនៅក្នុងវដ្តទាំងអស់, មានម្លប់អាហារដ៏បរិបូណ៌ជាអនេកប្រការគេ" ។ ព្រះនាងទេវធីតាទ្រង់ឆ្លើយតបព្រះអង្គវិញថា: "សូមពរព្រះអង្គឲ្យបានសម្រេចនៅតាមព្រះពេជបំណង" ។ ព្រះនាងទ្រង់សព្វព្រះទ័យនឹងព្រះពេជ្ឈាទ័យដ៏ស្មោះស្ម័គ្រក្នុងកិច្ចបំពេញព្រះពេជការណ៍យកចិត្តព្រះអង្គ ដោយព្រះមហាសប្បុរសធម៌យ៉ាងក្រៃលែង, ទ្រង់ក៏ចាត់ឆ្មាំអណាយន្តវិសារទ្ធមួយឈ្មោះ "ចិន្តាមណី" រួចក៏ចាត់ទ្វីបពីទីនោះទៅ ។

ព្រះមហាក្សត្រិយ៍ ដោយមានព្រះពេជ្ឈាទ័យមហាសប្បុរសចំពោះដល់វិតសត្វទាំងអស់, ទ្រង់គង់លើបល្ល័ង្កទិព្យ ហើយគ្រាយវែលបានបីក្បាលមួយ ព្រះពេជទីបីក្បាល, នាយគ្រមក្នុងព្រះបរមពេជវាំង, រដ្ឋមន្ត្រី . . . ល . . . ទ្រង់ក៏បន្ទោញសួរសៀងថា ទ្រង់ទំនងស្តេចយាងទៅបូជនីយដ្ឋានឯស្រះពេលិសិដ្ឋឯណោះ ។ ទ្រង់ក៏ត្រាស់បង្គាប់ឲ្យរៀបចំប្រដាប់ប្រដាសព្វគ្រប់ព្រមទាំងគោដទាហារ, ដើម្បីទំនងធ្វើព្រះពេជ-ដំណើរទៅតាន់ទីនោះ ។

ក្នុងសម័យនោះ, មានសញ្ញាសី (Sannyasi) ម្នាក់មានចិត្តតាលខ្ពស់ចិត, ជាអ្នកបោកប្រាស ហើយជាអ្នកប្រកាន់ខ្ជាប់នូវលទ្ធិប្រទេសមដោយយល់ថារបស់អ្វីដែលយើញទាំងអស់ចក្ខុទើបយកជាការបាន ។ សញ្ញាសីនេះស្ទុះកាត់ស្បែកក្តាន់ភ្លាមកដល់មហាសន្ទិបាត ហើយក៏ចូលទៅជិត

ព្រះរាជបល្ង័ង្កទីត្យ ក្រាបបង្គំទូលព្រះអង្គថា: "បពិត្រព្រះមហារាជ, ហេតុអ្វីក៏មានគេរៀបចំខ្លួវែតខ្លាំងក្លាយដូច្នេះ?" ។ មហារាជវិក្រមាទិត្យ ទ្រង់មានព្រះរាជឧង្ការទៅកាន់សញ្ញាសីវិញថា: "យើងនឹងធ្វើដំណើរទៅកាន់ប្លង់និយដ្ឋានឯស្រែពិសិដ្ឋកន្លែងឥឡូវនេះ, ព្រោះហេតុដូច្នេះបានជាគេរៀបចំនេះ" ។ អ្នកកាន់លង្ហិរូបនិយមក៏ក្រាបបង្គំទូលតបថា: "ហេតុដូចម្តេចបានជាគេហៅស្រែ? តើគេទៅឯស្រែនោះធ្វើអ្វី?" ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជបន្ទូលតបវិញថា: "ស្រែគឺខ្ទេគង្គា ខ្ញុំដឹងជាប្រទេសខ្លាំងក្លាយ ។ កាលណាគេងូតទឹកឬគេធ្វើពិធីអ្វី។ កន្លែងខ្ទេគង្គា គេតែងបានបុណ្យ ។ បុណ្យនោះអាចនាំអ្នកដែលធ្វើឲ្យទៅកាន់ស្ថានសួគ៌បាន ។ អ្នកណាមិនទាន់បានសម្រេចផលនោះទេ ក៏ត្រូវតែធ្វើចិត្តឲ្យបរិសុទ្ធស្អាតត្រមាំងមាំទម្លាប់ដ៏ល្អ, កាន់សច្ចធម៌ ត្រមាំងមានធន្លុះបង់រួចផុតចាកទុក្ខថែមទៀត" ។

អ្នកពុប្ផញ្ញានិយម, ក្រោយដែលបានស្តាប់ព្រះរាជឧង្ការព្រះបាទវិក្រមាទិត្យ, ក៏សើចយ៉ាងខ្លាំង ហើយក្រាបបង្គំទូលថា: "សុំឲ្យស្តាប់ទៅ ពួកលង្ហិរូបនិយមបោកប្រាស់គេ ដែលបានបង្ហាញខ្លួកស្តាងឲ្យឃើញច្បាស់ខ្លួកាវឥតប្រយោជន៍, ទឹងការគាន់ប្រឡឹ! ។ តែព្រះអង្គទ្រង់ជាវិញ្ញាជន, ទ្រង់ជ្រាបច្បាស់ខ្លួបុព្វហេតុវែតខ្លាំងក្លាយ; ព្រះរាជបន្ទូលនេះមិនសមរម្យដល់ព្រះអង្គទេ ។ សូមទ្រង់ព្រះសណ្តាប់ នូវសុន្ទរកថារបស់បណ្ឌិតដែលបម្រុងទៅកាន់វត្តបំណងដ៏ឧត្តម ។ មនុស្សល្ងង់ដែលបំពេញសកម្មភាពដើម្បីទៅកាន់ស្ថានសួគ៌ គឺជាអ្នកប្រកបដោយមោហៈ។

ជានយើញសកម្មភាពជាត់បង់អំពីមំសចក្ខុទៅ, ហើយយល់ថា សកម្មភាព
នេះ លែងស្ថិតទៅ, ហើយដោយហេតុនៃការយោលយកតំណើតកន្លងផុត
សង្សារ តំណម្រែចថា ទីងជានផល គឺទៅសោយសុខសម្បត្តិទៅស្ថាន
សួគ៌ ! តែសកម្មភាពដែលលែងស្ថិតទៅ មិនអាចជាបុព្វហេតុ ឲ្យមាន
ប្រតិបត្តិការថ្មី, ប្រៀបដូចជាអំបោះដែលឆេះដោយភ្លើង មិនអាចជាបុព្វ-
ហេតុឲ្យកើតសំលៀកបំពាក់ជាន ។ ព្រោះហេតុដូច្នេះ, ស្ថានសួគ៌
មិនពិតហើយនរកក៏គ្មានដែរ ។ ដ៏តែដែលទីងមានកន្លងកាលជាអនាគត,
ក្រោយដែលរូបកាយសម័យបច្ចុប្បន្ន រលត់រលាយជាត់ទៅ, ឧជាន
ដែលធ្វើឲ្យអត្តាជាប់ស្អិតទីងផុតសង្សារ, នេះជាភាស្យមនុស្សខ្លាក់ក្អែក
តាំងពីរ, ដូចជាប្រពៃណីពួកសិទ្ធមានជាប់ត ។ គ្មានមកមិនជាប់ ។ គឺ
មិនមែនសោះ ត្រង់ថាអត្តាស្វែកតាក់ទូរូបកាយថ្មី ។ ព្រោះហេតុដូច្នេះ
ស្ថានសួគ៌, ស្ថានទរកគ្មាន ។ ប្រៀបដូចជា យុត្តិធម៌ ទីងអយុត្តិធម៌
ជាទ្រឹដ្ឋគ្មាន ។ មានគេថា "អត្តារស់ទៅ ក្រោយដែលរូបរលត់
រលាយជាត់" នេះជាសំដីលើអាកាស ដូចជាគេពោលថា មានបុប្ផាជ្រុះ
ពីលើមេឃដូច្នោះ ហើយមានជារុក្ខជាតិបែក ។ ទៅវិត្រហេមពាន្ត ។
ដ៏វិសត្វដែលស្ថិតទៅឯកឯង, ធ្វើឲ្យវិនាសវត្តជាំងឡាយ, បង្កើតរក្សាខ្លួន,
បំផ្លាញនូវសង្សារ, ព្រះឥស្សរ (ព្រះបរមជាម្ចាស់) នេះគឺពាក្យមិន
ពិតប្រាកដសោះឡើយ ។ ព្រោះហេតុដូច្នេះ, សេចក្តីយល់ឃើញ
ណាដែលបញ្ជាក់ដោយយកតុ ដែលមើលមិនឃើញមកជាមូលដ្ឋាន,
គ្មានភ័ស្តុតាងមាំមួនល្មមជឿជាន, សេចក្តីយល់ឃើញនោះជារបស់ពួក

ក្នុងខ្លៅ ក្អែកឆ្មឹតដោយអវិជ្ជា ដែលជាហេតុធ្វើឲ្យកើតមោហៈ ប្រៀបដូចជាគោលគុលៈ (Golângula ស្វា) ក្អែកខ្វាក់ដូច្នោះ, ហើយជាអ្នកខ្ជូន្នានដ៏លាមកបំផុត" ។

មហាភដ្ទវិក្រមាទិត្យ ក្រោយដែលខ្ញុំព្រះសណ្តាប់ធ្វើពាក្យសញ្ញាសីដែលរំឭកយាមនិយាយបំផ្លាញនូវសិទ្ធិនៃវេហើយ, ខ្ញុំមានព្រះពុទ្ធដីយោមនស្សបម្ពិចបន្តួច ហើយក៏មានព្រះបន្ទូលតបទៅវិញថាៈ 'ម្នាលអ្នកលង្ឃន់ អ្នកឯងប្រកាន់ថា បើពាក្យណាគ្មានភ័ស្តុតាងសម្រាប់បញ្ជាក់ឲ្យច្បាស់លាស់ទូវេបស់ ដែលយើញដោយមំសចក្ខុហើយពាក្យនោះទុកជាមិនពិត អ្នកឯងយកគោលការណ៍នេះជាធំ, អ្នកឯងបោះបង់ចោលនូវការពិចារណារកហេតុផល ដោយវិចារណញ្ញាណផ្សេងៗឯទៀត ដែលមានសភាពដូចគ្នា ដោយយល់ព្រមទទួលតែភ័ស្តុតាងកើតឡើងដោយមំសចក្ខុប៉ុណ្ណោះ, ធ្វើម្តេចទៅ បើជាបណ្ឌិតយ៉ាងំណាមានសភាពស្តាប់មិនឮ តើនឹងអាចយល់ចានូវវាក់ចាដែលខ្ជូនពោលនោះមានអានុភាពយ៉ាងណា ។ បើបណ្ឌិតនោះស្តាប់វាក់ចាខ្ជូនមិនបានហើយ, ខ្ជូនមិនអាចសម្រែចរឿងអ្វីបានសោះឡើយ ហើយត្រូវតែស្វែងរកក្នុងពិភពលោកនូវបណ្ឌិតម្នាក់ដែលមានសមត្ថភាពអាចប្រតិបត្តិតាមអនុទេសអ្នកដទៃបាន, គឺមានតែមធ្យោបាយមួយនេះទេដែលអាចសម្រែចនូវរឿងវេបស់ខ្ជូនបាន ។ មួយទៀតបើអ្នកឯងយល់សប្តិឃើញថាមានគេកាត់ក្បាលអ្នកឯង តើអ្នកឯងគាន់អាចប្រកិរិយាយ៉ាងណា ដល់ពេលដែលអ្នកឯងភ្ញាក់ពី "និគ្រ" តើអ្នកឯងស្តាប់ឬរស់? បើថា

អ្នកឯងគាន់អាកប្បកិរិយាជាមនុស្សស្លាប់ គេនឹងអាចថាអ្នកឯងប៉ុនប្រៃសប់ប្រែប្រួលខ្លួនមុខងារវេបសំខ្លួនមែន, ប៉ើជាអ្នកឯងគាន់អាកប្បកិរិយាជាមនុស្សវេស អ្នកឯងមិនអាចស្គាល់បានខ្លួនសិទ្ធិនៃវេបសវែលមើលឃើញដោយម៉ែសចក្ដុ ។ ព្រោះហេតុដូច្នេះ, ត្រូវតែអ្នកខុកសិទ្ធិបច្ច័យហេតុផល ដែលសាស្ត្រៈទាំងអស់បានពណ៌នាអំពីវត្ថុដ៏ឧត្តម ដែលម៉ែសចក្ដុមិនអាចយកបាន ជាការចាំបាច់មានខ្លួនភាពត្រឹមត្រូវ ។

"ហើយ, តទៅវិញនេះ យើងនឹងសួរអ្នកឯងត្រង់ចំណុចមួយ: តើយើងដែលមកគាន់ទីនេះឬអ្ន គឺយើងធ្លាក់ពុះពីលើមេឃ ឬយើងមកពីគ្រួសារផ្សេង។ ប៉ើអ្នកឯងតបថា: យើងធ្លាក់ពុះពីលើមេឃ អ្នកឯងជាមនុស្សខ្វែត; ប៉ើជាអ្នកឯងពោលថា: យើងកើតពីគ្រួសារទាំងឡាយ, ដោយហេតុនេះអ្នកឯងខុកខ្លួនកំណត់នៃគ្រួសារទាំងឡាយនោះថាមានសភាពត្រឹមត្រូវឬទេ? ។ ម្យ៉ាងទៀតវិញ, តើអ្នកឯងពោលយ៉ាងណាទៅចំពោះរឿងនេះ? មនុស្សដែលកើតតាំងអតីតកាលមុនយើង គឺកើតពីគ្រួសារដែរ ។ នេះហើយដែលយើងបានភ្ជុបគ្គលដែលខុកខ្លួនសិទ្ធិគំស្ដុតាង់ដោយយកវិចារណញ្ញាណជាមូលដ្ឋាន ថាមានសភាពត្រឹមត្រូវជាជាងខាត ។ ព្រោះហេតុដូច្នេះ ប៉ើទុកជាអ្នកឯងមិនយល់ព្រមអនុម័តតាមសេចក្ដីយល់ខាងលើនេះទេ, ក៏ត្រូវអ្នកឯងខុកសិទ្ធិវែងសំឡងដែលជាទំរង់នៃពាក្យមានអានុភាពថា ជាមានសភាពត្រឹមត្រូវតាមវិចារណញ្ញាណពិតប្រាកដមែន ។ ប៉ើទំរង់នោះមានហេតុមានបច្ច័យគប់គ្រាន់បរិបូណ៌, ហេតុបច្ច័យនោះមានតម្លៃ សិទ្ធិសំឡងនោះក៏មានតម្លៃដូចគ្នា, ហើយត្រូវ

ខុកកម្មវត្ថុនៃរឿងនេះ ថាមានសភាពត្រឹមត្រូវពិតប្រាកដដែរ ។ ព្រោះ
ហេតុដូច្នេះ, តាមក្បួនតក្កវិជ្ជា, គេមិនដែលខុកវត្ថុទាំងឡាយថា មាន
សភាពត្រឹមត្រូវតែពាក់កណ្តាលសោះឡើយ ។ អ្នកឯងត្រូវតែខុកវត្ថុ
ទាំងឡាយនោះថា មានសភាពត្រឹមត្រូវពេញលក្ខណៈដូចគេបានតែខុក
យូរមកហើយ អំពីវត្ថុដែលគេបញ្ជាក់ថាស្ថិតនៅជានិរន្តរ៍ គឺអាកាស,
កាល, បុព្វហេតុ, សុខ, ទុក្ខ ដែលជាបច្ច័យឲ្យកើតមានខ្លួវគុណ-
សម្បត្តិនឹងគុណវិបត្តិទាំងឡាយ, ដែលគេមិនអាចថាជាយល់សប្តិបាន,
ហើយជាវត្ថុដែលកើតឡើងតាមរបៀបធម្មជាតិ, បុព្វហេតុដែលកើត
សង្ឃព្រះអាទិទេពនោះឯង ។ ចូរអ្នកគិតដោយខុបាយនៃប្រាជ្ញាហើយ
ធ្វើវិចារណញ្ញាណកុងចិត្តហើយពោលថា: វត្ថុទាំងអស់ដែលអាចធ្វើឲ្យ
ចម្រើនឬធ្វើឲ្យតិចទៅ សុទ្ធតែមានព្រំដែន ។ ដូចគ្នានឹងបឹង,
ទន្លេ ល . ., ទឹកដែលមានសភាពស្រកឬជន់ក៏ត្រូវតែមានព្រំដែន
ដែលទឹកនោះត្រូវតែស្ថិតនៅ, អស់អាទុភាពត្រឹមនោះ; ចំណែកខាង
អធិបតេយ្យ, វីរភាព, កិត្តិគុណ, អាទុភាព, វិទ្យាសាស្ត្រ, ការរំលត់
ខ្លួវតណ្ហាដែលមានធម្មជាតិធ្វើឲ្យអន់ខន់ខ្សោយ ឬឲ្យចម្រើនក្នុងចំណោម
នៃសត្វលោក, យើងត្រូវតែខ្លួលស្គាល់ថា អធិបតេយ្យនោះត្រូវមានគុណ
សម្បត្តិដ៏ឧត្តមឯទៀតក៏ត្រូវតែមានព្រំដែនដូច្នោះដែរ ។ ព្រោះហេតុ
ដូច្នេះ វត្ថុដែលគេត្រូវតែខ្លួលស្គាល់ ជាការចាំបាច់ ខានមិនបានគឺ ព្រះ
អាទិទេពតែមួយព្រះអង្គនោះឯង ដែលមានលក្ខណៈដូច្នេះ គឺ ព្រះអង្គ
ខ្លះព្រះបរមនាមថា សត្ថុវិទូ ជាព្រះអាទិទេពជាម្ចាស់, ជាបុព្វហេតុនៃ

ដលជាអចិន្ត្រៃយ៍ត្រមាំងបុព្វហេតុនៃវត្ថុតាំងឡាយ, ជាគ្រឹះណៃវត្ថុតាំងអស់ដែលស្ថិតនាសេញ្ញអាកាស ។ គ្មានព្រះជាន់ទេ តែខ្ញុំយាងទៅកាន់គ្រប់ទិសទី, គ្មានព្រះហស្តទេ តែខ្ញុំកាន់វបស់ជាន់គ្រប់យ៉ាង, គ្មានចក្ខុទេ តែខ្ញុំឧតយល់ខ្លួរបុគ្គលប់យ៉ាង, គ្មានសោតឋសាទេ តែខ្ញុំព្រះសណ្តាប់ខ្លួរសំភូសំឡេងជាន់តាំងអស់, ខ្ញុំស្គាល់តាំងអស់, ខ្ញុំស្ថិតនៅគ្រប់ទិសទី ហើយគ្មានអ្នកណាអាចប៉ះពាល់ត្រូវជាន់សោះឡើយ, ខ្ញុំមិនមានអ្វីជាវត្ថុនាក់អាស្រ័យ. ខ្ញុំជាវត្ថុនាក់អាស្រ័យបំពោះវត្ថុតាំងអស់, ខ្ញុំមានធម្មជាតិជាសោតណាភាព, បញ្ញា, មហាសុកមន្តល; ពលភាពរបស់ខ្ញុំតស៊ូខ្លឹងខ្លួបសត្តគ្រប់យ៉ាងមានជោគជ័យដោយខ្ញុំបំនប្រសប់យ៉ាងក្រៃលែង, ព្រោះហេតុដូច្នេះ មហាមាយាក្រោយដែលស្តាបនាខ្លួរខ្ញុំ ជាន់ពោលកន្ទសាស្តុះថា: "ធម្មជាតិ (វបស់ខ្ញុំ) គឺជាព្រួហេតុប្លុសគល់នៃលោកតាំងអស់; ដោយហេតុនេះហើយជាន់ជាខ្ញុំមានព្រះបរមនាមថា: "ធម្មជាតិ ឬស Nature Racine" ។ អ្នកណាដែលជាន់ស្គាល់អានុភាពព្រះអង្គ អ្នកនោះអាចយល់ជាន់ថា លោកនេះជាផលស្ងួចស្តើងនៃអានុភាពព្រះអង្គ ដែលគេប្រៀបដូចជាយល់សប្តិ, កាលណាមហានិទ្រា (Grand Sommeil) ក្រោយដែលជាន់សាងខ្លួរពលភាព ព្រះអង្គពោលថា: ដោយមានសហការនៃពលភាពដ៏អស្ចារ្យនេះ ព្រះមហាអង្គដ៏ប្រសើរ គ្មានគុណសម្បត្តិ គ្មានសកម្មភាព បើពិនិត្យតាមធម្មជាតិ មានតែសោតណាភាព, បញ្ញាជ័រសេសវិសាល, មហាសុកមន្តល, ទឹងត្រូវមានចំពោះខ្លួនខ្លួរវិទ្យាសាស្ត្រនៃវត្ថុតាំងអស់

ឧត្តមគុណសម្បត្តិដ៏ធំធេងអស់ ។ បើគេធ្វើខ្ញុំវប្បសំសកថាសរសើរខ្ញុំវគុណានុភាពព្រះមហាអង្គដ៏ប្រសើរ ដូចបានពណ៌នាមកនេះ, ហើយការបន្តវិជ្ជានោះអស់យូរកាល, ជាហេតុឲ្យផុតចាកទុក្ខធំធ្ងន់មិនខាន" ។

មហាពជវិត្រមាទិត្យ ក្រោយដែលទ្រង់មានព្រះពជនង្ហាវចំពោះអ្នកទុប្បញ្ញាទិយម, ទ្រង់ក៏មានព្រះបន្ទូលតទៅទៀតថា: "នុអ្នកទុប្បញ្ញាទិយម, យើងនឹងពោលអំពីទំយែនៃសាស្ត្រៈធំធេងអស់; ចូរអ្នកស្តាប់យើងដូចជាមាតាម្ចាស់ ក្នុងពេលដែលមានបំណងចង់ឲ្យពេតបុត្រជាសះស្បើយ, នាងបំផឹកបុត្រនោះដោយទុសថដូរ, ហ៊ារ, ចត់, ក្រែនរំពុកដោយពាក្យថា: "នុបុត្រអើយ, កាលណាបើអ្នកផឹកខ្ញុំវទុសថនេះ មាតានឹងឲ្យអ្នកខ្ញុំវដំណាប់ប្លុកចាប្លែមពីពេះផ្សេង ។ នាងញ៉ាំងបុត្រឲ្យអាស្រ័យខ្ញុំវទុសថនេះ ដោយបង្ហាញខ្ញុំវវន្ទាន់ដូច្នោះ ។ ការបំបាត់ខ្ញុំវអាការពេតដែលមានឱមិត្តរូបជាតណ្ហា, ទោសៈ, លោភៈ, សកាពក្រអើតក្រទម, អត្តទត្តភាព, លទ្ធិ, ប្រៀបបីដូចជាមាតា, បង្ហាញខ្ញុំវផលមានទម្រង់ជាស្ថានសួគ៌ . . . ល . . . ញ៉ាំងចិត្តឲ្យប្រព្រឹត្តសកម្មភាពដែលត្រូវតែព្យាយាមជាយ៉ាងម៉ឺងម៉ាត់ទើបប្រព្រឹត្តទៅបាន ។ ដូចជាផលដែលជាសះស្បើយពេត គឺសុខភាព, ផលដែលលេត់ខ្ញុំវតណ្ហានឹងជាបធម៌ធំធ្ងន់ គឺស្ថានភាពនៃចិត្តដែលហ្វឹកហាត់ចិត្តឲ្យបឹតនៅក្រោមបង្គាប់បញ្ជានៃខ្លួន ។ សកម្មភាពនៃអ្នកដែលឈ្នះខ្លួន ។ ឯងតែងតែមានតម្លៃពន់ពេក, សកម្មភាពនៃអ្នកដែលចាញ់ខ្លួន ។ ឯងតែងមានសភាពឥតប្រយោជន៍ ហើយគ្មានផល ។ អ្នកឯងដែលមិនទាន់

ឈ្មោះខ្លួន ។ ឯង, ហេតុម្តេច ក៏អ្នកធ្វើឱ្យខ្ញុំចេះលេងសើចក្នុងវេលាសិក្សារៀនសូត្រ តែធម៌ជាន់កក់ដូច្នេះ ?

កាលណាអ្នកឧបាសិកាមិយមហានស្តាប់នូវព្រះពុទ្ធដីការព្រះបាទវិក្រមាទិត្យ ចំពោះការបរិភោគនូវនុសធិ (Aushadhi) តើណាជាតំនុសធ ចំណាន, ការមិនដឿងនូវអាទិទេពដែលមានចិស្សាចចំពាន់គំនិតខ្លួន ក៏លេងរលាយទៅដែរ ។ អ្នកឧបាសិកាមិយមក៏ក្រាបថ្វាយបង្គំព្រះបាទវិក្រមាទិត្យ សូមទុកទ្រង់ថាជាគ្រូអាចារ្យហើយប្តេជ្ញាថានឹងស្តាប់ព្រមទាំងប្រតិបត្តិតាមព្រះពុទ្ធដីការតទៅ ។ ក្នុងពេលនោះ, ព្រះបាទវិក្រមាទិត្យទ្រង់សព្វព្រះពុទ្ធហឫទ័យនឹងអ្នកឧបាសិកាមិយម ក៏ប្រទានព្រះពុទ្ធដីកា នូវកោតទ្រព្យដ៏ច្រើនតាមសមគួរ ។

*

* *

អវិសាធកថា

ក្រោយដែលរូបទេពនិម្មិតទី ៣៤ បញ្ចប់រឿងព្រះបាទវិក្រមាទិត្យ, រូបទេពនិម្មិតទាំង ៣៤ រូប មានទេវកថាថា: "បពិត្រព្រះបាទកោដៈ ដោយអះអាងទៅលើព្រះពុទ្ធគុណធម៌ដ៏ខ្ពង់ខ្ពស់នៃព្រះបាទវិក្រមាទិត្យ, យើងខ្ញុំព្រះអង្គបានពណ៌នាអំពីព្រះពុទ្ធគុណធម៌ជាអនេកប្បរិយាយ រៀបរាប់ស្តេចអង្គខ្លោះ ។ ព្រះបាទវិក្រមាទិត្យដែលយើងខ្ញុំពណ៌នានេះ ទ្រង់មានសមត្ថភាពគ្រប់គ្រាន់ល្មមគង់លើបល្ល័ង្កទិព្វនេះបាន; មហាក្សត្រិយ៍ ក្រៅពីព្រះបាទវិក្រមាទិត្យនេះ មិនអាចមកគង់លើបល្ល័ង្កទិព្វនេះបានឡើយ ។ ព្រោះហេតុដូច្នេះ, យើងដែលមានបំណងចង់ឱ្យទ្រង់បានសេចក្តីសុខ,

ជានយើងខ្ញុំព្រះអង្គខំព្យាយាមកុំឲ្យខ្វែងគន់លើបល្ល័ង្កទំព្រនេះ តែមិនមែនយើងមានចិត្តគោមនស្សនឹងព្រះអង្គទេ; បើតាមពិត ខ្វែងមានគុណូបការៈនឹងយើងខ្ញុំព្រះអង្គគាំងឡាយពន់ពេក ។ យើងខ្ញុំព្រះអង្គត្រូវសងបំណុលសំខាន់នេះ គឺយើងត្រូវជានរួចផុតចាកការបិតនៅនឹងសេ្មមដែលជាផលអកក្រក់ នៃកិច្ចដែលយើងត្រូវពាក្យបណ្តាសាមុនមួយរូប; យើងខ្ញុំព្រះអង្គមានសកាពធ្វើការចង់ទាជានតាមចិត្ត ។ សូមព្រះអង្គគន់នៅជាសុខក្នុងសិរីពេជសម្បត្តិ ប្រកបដោយសុគមង្គលគ្រប់ប្រការ យើងខ្ញុំព្រះអង្គសូមយកបល្ល័ង្កទំព្រនេះវិញ, ហើយយើងខ្ញុំព្រះអង្គនឹងវិលត្រឡប់ទៅកាន់គេហដ្ឋានហើយ ។

ក្រោយដែលជានក្រាបបង្គំទូលព្រះជាខកោដៈអំពីរឿងខាងលើ រូបទេពនិម្មិតក៏សែងបល្ល័ង្កទំព្រនោះយកទៅ, ហើយក៏ធ្វើដំណើរទៅកាន់នគរបស់ខ្លួន ។ ចំណែកឯព្រះជាខកៅដៈខ្វែងក៏ធ្វើព្រះពជដំណើរត្រឡប់ទៅកាន់ព្រះពជអាណាចក្ររបស់ព្រះអង្គវិញ ។

ចប់

ណែ្លសត្វធ្យូហែ្សន

រឿងព្រេងប្រទេសរ៉ូម៉ានី

លោក ផែង-ជ្រែរ នៅក្រសួងយោសនាការជាតិ

ប្រែចាកសៀវភៅ ក្នុងអេឡេសងនឹងរ៉ូម៉ានី

(Contes et légendes de Roumanie)

(ត ទំនងបន្ត)

លុះបានជ្រាបថា នៅឯទីគ្រែលង់ កន្លែងចិញ្ចឹមចៀម មានក្តួមួយមានតម្លៃស្មើមាស ព្រោះក្តួនោះបានជួយស្រង់ជីវិតកូនចៀមទាំងប៉ុន្មានពីមាត់ចចក ដែលតាំងពីច្រើនឆ្នាំមកហើយ ពួកអ្នកគង្វាលចៀមទាំងឡាយប្រជុំគ្នាគិតធ្វើការនោះមិនសម្រេច ព្រះអង្គម្ចាស់ស្វាម៉ីក៏រិយាគំប្រឹក្សាគ្នាថា: មានតែសុនខនោះ ដែលអាចជួយស្រង់ជីវិតកូនយើងបាន។

កាលបើពេលសម្រាលជិតមកដល់ ព្រះអង្គម្ចាស់ឲ្យគេទៅនិយាយទីងម្ចាស់ក្តួ សុំខ្ចីបានមួយរយបង់ ហើយទីងឲ្យមាសមួយពាន់ដំឡឹង បើការណ៍នោះសម្រេច ។ មុនដំបូង អ្នកគង្វាលមិនព្រមទទួលសោះ ព្រោះមិនចង់ឲ្យក្តួឃ្វាតឆ្ងាយពីខ្លួន ។ ប៉ុន្តែ ដោយការទទួចអង្វរនៃព្រះអង្គម្ចាស់ហើយទីងអ្នកគង្វាលដែរ ក៏ទន់ចិត្តហើយព្រមឲ្យខ្ចី ។ ប៉ុន្តែ ក៏បានទូលជាមុនថា មិនត្រូវចង មិនត្រូវឃ្លាតក្តួរបស់ក ដ្បិតក្តួកមិនចេះចេញទៅណាជាការឥតប្រយោជន៍ឡើយ ។

គេក៏ព្រមធ្វើតាមទាំងសន្យាដូចតាក្យដែលនិយាយ ។ ប៉ុន្តែ ព្រះអង្គម្ចាស់គ្មានតែយើញក្តួមកដល់ក្នុងទីធ្លា ស្រាប់តែចាប់ចងដឹកយកទៅចុកឯខាងក្រោយផ្ទះ ។

ដល់កណ្តាលអធ្រាត្រ ព្រះខាងជាកំរើយព្រះអង្គម្ចាស់ប្រសូតមក ។ គេរៀបចំបំពេញកិច្ចផ្សេង ។ ចំពោះមាតាទើបប្រុងបួចហើយ ។ លុះវេលាម៉ោងមួយ មនុស្សក្នុងធួរកំទាំគ្នាដេកលក់អស់ ។ ខណៈនោះមានអ្នកបួសមួយអង្គនិមន្តមកដល់ ។ ឆ្កែបានឃើញអ្នកបួសចូលមកហើយចេញរកយកចេញទៅ វាចង់សួរទៅខាំ ប៉ុន្តែវាជាប់ចំណងរកធ្វើអ្វីពុំកើត ។

ក្រោកឡើង ព្រះអង្គម្ចាស់ពុំឃើញកូន សួរយកដំបងសំពងឆ្កែយ៉ាងដំណាំ ។ រួចទ្រង់ស្រាយខ្សែ ដេញឆ្កែកំសត់នោះចេញពីផ្ទះ ។ ឆ្កែសន្សំខ្លួនខ្លាចលំបាកវេទនា ស្ទើរស្ទាប់មួយចំហៀងខ្លួន ទំរើងដើរទាំងត្រដរបីថ្ងៃទើបទៅដល់ទីក្រោលធំ ។ ឃើញឆ្កែបានសេចក្តីទុក្ខភ្ញាំងភេកដូច្នោះ អ្នកគង្វាលម្ចាស់ឆ្កែនឹកអាណិតក្នុងចិត្តទើងព្រះអង្គម្ចាស់ : « យ៉ាងដូច្នេះប្រុ ដែលថាធ្វើតាមទេសនារបស់អញ ។ អើចាំមើល ! បើលោកខ្លីឆ្កែនេះបានទៀត កែងតែមេឃថាជ» ។

អ្នកគង្វាលទំរើងរុំដំហៀ ដោយលាងទឹងទឹកភ្នែកឲ្យឆ្កែឆាលតែបានជាស្រួលដូចដើម ។

ដល់ក្រោយព្រះអង្គម្ចាស់កេតឲ្យបកនិយាយខ្លីឆ្កែម្តងទៀត ។ ម្តងនេះ គេឲ្យឈ្នួលជាមាសពីរោនដំឡឹង អាណិតតែឲ្យខ្លី ។

អ្នកគង្វាលនិយាយថា :

- ម្តងនេះ បើចង់បាន ឆាលតែខ្លួនខ្ញុំទៅជាមួយផង ។ ខ្ញុំមិនបណ្តោយឲ្យវាយឆ្កែខ្ញុំស្ទើរស្ទាប់យ៉ាងនេះ ព្រោះតែកូនតូចចង្រៃនោះឡើយ ។ ព្រះ

អគ្គម្ចាស់យល់ព្រម ព្រោះមិនមានមធ្យោបាយអ្វីក្រៅដៃ ។ លុះដល់ពេលកំណត់ អ្នកគង្វាលទាំងពីរនាក់ទៅជាមួយគ្នា គេត្រាលស្បែកចៀមនៅមុខផ្ទះ ហើយដេកផ្ដើរត្រង់ឯ ក្បែរដេកនៅចុងជើង ។

រំលងអធ្រាត្រ ឪពុកបបួតមក ។ មិនយូរប៉ុន្មាន អ្នកបួសមួយអគ្គីមកដល់ ចូលកន្លង់ធ្នះ ទាំបីកូនផឹតនៅដៃ ហើយបំរុងនឹងចេញទៅវិញ ។ ប៉ុន្តែ ក្នុងដែលបានបង់ប្រាក់ឲ្យលោកចូលទៅ គឺស្ទុះទៅស្អាប់លោកទៅតែងមាត់ភ្លាម ដើងពីរមុខជាន់ខ្លួន មាត់ទាតែងបំពង់កបំរុងនឹងសម្លាប់ ។ អ្នកបួសរៀបស្រែកថា:

- ខ្ញុំឲ្យហ្សែនក្លែស! អញដឹងថាអញទៅកន្លងំណាចឯងហើយ។ ឯងអាចសម្លាប់អញបានឥឡូវ ។ ប៉ុន្តែ អញសូមអង្វរ សូមឯងទុកជីវិតឲ្យអញ ។

ត្រានោះ ក្ញុំឲ្យហ្សែនគឹឈប់ទាំអ្នកបួស ហើយបើកឲ្យទិមន្តចេញទៅដោយទុកទាក់នៅកន្លងំនោះ ។ ព្រះអគ្គម្ចាស់នឹងតរិយា លុះព្រឹកឡើង រកបុត្រមិនឃើញ ទាំគ្នាទ្រហោយំ ។ ប៉ុន្តែ វេលាដើរឆ្ងងមាត់ភ្លារទៅ ទ្រង់បានឃើញទាក់ដេកនៅលើស្បែកចៀមជាចន្លោះអ្នកគង្វាលទាំងពីរ ដែលកំពុងដេកស្រមុកពុំទាន់ភ្ញាក់ខ្លួនឡើយ ។

ចូរយើងនឹកស្មានមើល អំពីស្ដេចក្ដីសប្បាយរបស់ព្រះអគ្គម្ចាស់នឹងតរិយារបស់ទ្រង់ តើមានទំហំប៉ុនណា ? អ្នកគង្វាលត្រូវបានមាសមួយភាន់ដំឡឹងផ្សេងទៀត ក្រៅពីចំនួនពីរភាន់ដំឡឹង ដែលគេសន្យាទុកឲ្យ។ ចំពោះរូបក្ញុំ គេចោះលុយមាសចន្លឹងក្រមុំ លុយមួយ ក្រមុំមួយ ។

គឺប្រហែលតាំងពីពេលនោះមកហើយ ឃ្មាន់ជាគេចេះប្រើគ្រឿងអលង្ការសម្រាប់តែងកាយ ។ រួចទើបគេលែងឆ្កែឲ្យទៅ ។

ខណៈនោះ ឆ្កែគិតដោយសេចក្តីរីករាយថា:

« អញនឹងរត់ទៅផ្ទះកំណើតវិញ ។ ម្ចាស់នេះប្រហែលមេម្រាយអញនឹងប្តឹងព្រមសុខចិត្តឲ្យអញទៅ ។ ទោះបីអញជាឆ្កែក៏ដោយចុះ ឲ្យតែអញបានអាស្រ័យនៅចាំផ្ទះនឹងខ្ញុំស្បែកអាតុកអញ » ។

គិតយ៉ាងណាក៏ធ្វើយ៉ាងនោះភ្លាម ។ លុះបានឃើញឆ្កែមានខ្លួនស្រោមមាសដូច្នោះ មេម្រាយនឹងអាសហាយក៏ស្រែកហៅថា:

- នែ តូឡូហ្សែនឆ្កែកំសត់ ! តូឡូហ្សែនឆ្កែកំសត់ . . . . ។

ប៉ុន្តែ កាលណាឆ្កែនោះចូលមកដល់ផ្ទះភ្លាម ក៏នាំគ្នាយកកន្ត្រែមកគាត់មាសយកអស់ សូម្បីតែលុយមួយកាក់គ្មានសល់ ។ ក្រោយដែលបានគាត់យកមាសហើយ តើក៏ទុកឲ្យឆ្កែនោះនៅនឹងផ្ទះដដែលឬដូចម្តេច ? មែនហើយ មុខជាទុកឲ្យនៅពេក ! អាចោរ មេចោរកំណាច ដោះយកអំពាត់មករលាស់ហើយពោលថា:

- ណ្លើយ ! កាលពីដើម ឯងជាឆ្កែសតូឡូហ្សែន ឥឡូវចូរឯងក្លាយទៅជាសតូតាសេះចុះ ។

ហើយគ្រាន់តែថាដូច្នោះ តូឡូហ្សែនក្លាយទៅជាសតូតាសេះ ដែលមានតូជរហូតមកដល់សព្វថ្ងៃ រកស៊ីតែចោរដើមឈើពុកយកដង្កូវជាអាហារ ។

តើឥឡូវធ្វើដូចម្តេច តាសេរកំសត់ ? តាសេរហ៊ីរទៅ ។ ឃាតដល់
ពៃតូចមួយ ។ រាប្រទះទឹងព្យុះភ្លៀងយ៉ាងខ្លាំង ។ តាសេរខំតំពួនទៅ
ក្នុងពៃនោះឲ្យលាប់ចក់មក ឆ្ងាយ រាងាត់ពីមែកមួយទៅមែកមួយ តាដើមមួយ
ទៅដើមមួយ ។ លុះកាលណាឆ្ងាយដល់ដីកាល ឲ្យលាក្លិចរលាស់ ដួល
ក្រឡាប់ផ្តាប់ផ្ងារឥតឈប់ឈរ រាយោបក់ព្រះមេឃក្នុងចំការនេះហូតដល់
ក្បួនផ្ទះមួយ ។ លុះឃាតដឹងខ្លួនឡើងវិញ តាសេរឃាមឃើញសួនដំណាំ
មួយ ។ ក្នុងសួននោះ មានគ្លាមួយសន្ធឹក . ហ៊ាយមានគ្រាប់សណ្តែក
ទៅលើនោះ ឃ្លានពេក តាសេរលោភទៅចឹកស៊ី . . . ។

ប៉ុន្តែ តាសេរមិនដឹងជាទៅលើគ្លានោះមានដំរីឃាម ។ ហើយ
កាលណារាចង់ហើរចេញ ជួរឯងហ៊ើរចុះហើរច្បែ ! . រាខំឥតស្ងាបស្ងុះ
ចេញតែឥតអំពើ ។

មិនយូរប៉ុន្មាន មានក្មេងប្លន់ពាក់ចេញមកពីក្នុងផ្ទះ ហើយនាំគ្នាស្ទុះ
រត់សំដៅតាសេរ ។ អាមួយស្រែកថា: "ម្លូតក" អាមួយទៀតថា:
"យកទៅកេលក្លឹង" អាពីរគ្រាយថា: "សម្លាប់ទៅ . . . " គឺថា
ក្មេងទាំងនោះសុទ្ធតែចិត្តអាក្រក់ ។

រាទាំគ្នាចាប់តាសេរយកទៅដ្រមុជទឹកស្ទាបឲ្យទឹក រួចយកទៅដាក់
ពីលើចង្រ្កាន ដើម្បីទំងចោចស្ងាប ។ ប៉ុន្តែ ចួនជារាជាលពេលឃ្លានបាយ
រាចង់ដើងតាសេរព្យាទុកនឹងបន្ទិច ហើយទៅស៊ីបាយមុន ។

ក្មេងចាំងនោះកំពុងតែបរិភោគថ្វាយ [សាច់តែអ្នកបួសមួយអង្គនិមន្ត
ចូលមក គឺលោកហ្នឹងហើយដែលតែងតែទៅលួចកូនព្រះអង្គម្ចាស់នោះ ។
កូនក្មេងក៏តេស្តុះទៅរកលួលោក ហើយនិយាយថាប់ថា :

– លោកនុពុក ចូរមើលខ្ទុះ យើងទើបនឹងចាប់បាន ។

ហើយក៏យកតាសេះមកបង្ហាញ ។

– យើងបានយកវាទៅលាងទឹក រួចយកទៅឆ្អែរក្តៅម្តងរួចហើយ ។
ចាំកាលណាស៊ីថ្វាយហើយ យើងនឹងយកទៅឆ្អែរម្តងទៀត រួចសម្លាប់វា
លោកនុពុក ។

– ខែកូន ! អ្នកកល់គ្នាបានជាជ្រុលធ្វើទៅហើយ កំរាហើយទៅ ។
ប៉ុន្តែ ឥឡូវកុំ ! ចូរនៅស្ងៀម ។

[គាន់តែអ្នកបួសចាលក្អែកទៅចំតាសេះ ដែលប្រឡាក់ផេះស្រម៉ក
លោកក៏អាចស្គាល់មួយរំពេចថា តាសេះនោះជាអ្វី ។ អ្នកបួសពោលថា :

– ទុតូឡូហ្សែន ឆ្កែសតំសត់ គ្មានខវាណាអាចដឹងកិច្ចការដែលត្រៃដ
សំណាងដឹកនាំឡើយ ឯងឃើញឬទេ ? ចិត្តគាបឬស្បាប់ពន្ធអ្នកនឹងតាម
បំផ្លាញអ្នកឲ្យដល់ទៅណា ? ប៉ុន្តែ មិនអីទេ ឯងបានសង្គ្រោះអាណិត
អញក្នុងយប់មួយ ចូរឯងដឹងថា មិនមែនឯងអាណិតដល់មនុស្សអកតញ្ញូ
ឡើយ ។ ខែកូនចាំងឡាយ ! ចូរឯងយកតាសេះនេះទៅលាងទឹកថ្នាឲ្យ
ស្អាតឲ្យអញ ពីព្រោះមិនគឺជាតាសេះដូចសត្វតាសេះផងចាំងពួងទេ ។

ពួកកូនក្មេងក៏យកតាសេះទៅលាងទឹកយ៉ាងស្អាត យកទៅដាក់ឲ្យ
ទំនៅលើថង្គងមួយក្បែរជញ្ជាំងដើម្បីឲ្យស្ងួតស្ងាប ចំណែកតាសេះវង្វា

ពេកញាក់តគ្រុន ។ លុះគាសេះបានស្រួលខ្លួនបន្តិចហើយ អ្នកបួស
យកទំប៉ុងមកហែកជាចំណិតតូច ។ ដាក់លើក្តារ រួចឲ្យគាសេះចិកស៊ី
ដើម្បីឲ្យមានកំឡាំងឡើងវិញ ។ កាលណាពួកក្មេងចេញទៅលេងអស់
នៅតែពីរនាក់ទេ គាសេះ អ្នកបួសអធិប្បាយខ្សឹបរឿងជាអាថ៌កំបាំងនៃពួក
ក្មេងដែលលោកលួចយកមកប្រាប់ដល់គាសេះ ។

ឯងឃើញឬទេ តូឡូហ្សែន ! កូនចាំងប៉ុន្មានដែលប្រពន្ធព្រះអង្គ
ម្ចាស់ សម្រាលមកទើងទៅជាមនុស្សកំណាចអាក្រក់ជាងគេបំផុតលើផែន
ដី ។ ហើយឯងកុំស្មានថាកូនពីរបីនាក់ដែលឯងបានក្បាលុកនៅឯអាពុកម្ដាយ
នោះជាក្មេងគ្រាន់បើ មិនមែនទេ ពាក់កណ្តាលតែទើងទៅជាមនុស្សកំណាចដូច
គ្នា ។ ចំណែកអាដែងបួននាក់ដែលឯងបានឃើញអម្បាញ់មិញនេះ ទើង
បានទៅជាមនុស្សហាវហ្មង គ្រាន់បើឬ ព្រោះហេតុដូច្នេះ បានជាអញ
លួចយកមក ។ រួចអ្នកបួសសួរថា :

— ឥឡូវ ឯងប្រាប់អញមើល តើឯងចង់ត្រឡប់ទៅផ្ទះឯងវិញឬ ?

គាសេះដែលមិនដឹងធ្វើយថាដូចម្តេច គ្រាន់តែងក់ក្បាលជាសញ្ញា
យល់ព្រម ។ ខណៈនោះ អ្នកបួសហៅកុមារទាំងនោះមក ឲ្យសឹងអាហារឲ្យចំនួនពីរ-បីថ្ងៃ ហើយប្រដៅឲ្យទៅចាំផ្ទះស្រួលបួល កុំធ្វើ
ផ្តេសផ្តាស កុំទាស់គ្នា ព្រោះលោកត្រូមិនទៅអស់កាលដ៏យូរបន្តិច ។
រួចលោករៀបចំស្បែងជាក់សៀវភៅធម៌ខាងក្នុង យកសត្វគាសេះឲ្យចំ
លើស្មា ហើយធ្វើដំណើរចេញទៅ ។

អ្នកបួសទៅយ៉ាងយូរទើបបានដល់តូមិតូឡូហ្សែន ។ លោកឈប់ជិតផ្ទាំរបង ហើយសួរតាសេះថា :

– ហ្នឹងឬ ផ្ទះរបស់ឯង ?

តាសេះងក់ក្បាលជាសញ្ញាថាមែន ។

ព្រះអាទិត្យជិតអស្តង្គតហើយ ។ អ្នកបួសយកតាសេះដាក់ក្នុងស្បែងរួចបូលកង់ទ្វាផ្ទះហើយសុំថា :

– ម្ចាស់អ្នកផ្ទះជាសប្បុរស សូមគាណិតឲ្យអាត្មាជ្រកសិងមួយយប់ផងបានឬទេ ?

– បពិត្រលោកអាពុក មានខាស់អី តែយើងសព្វថ្ងៃសុខសប្បាយណាស់ ។ ហើយអ្នកផ្ទះក៏និមន្តអ្នកបួសចូល ។

ប្ដីនិងប្រពន្ធចេញទៅធ្វើនេះធ្វើនោះរៀងខ្លួន តែខ្លះទៅឯណោះ ខ្លះទៅឯណោះ អ្នកបួសធ្វើជាទិមន្តតាម មិនហ៊ានទៅកង់ផ្ទះម្ចាស់ឯង ។

ប្ដីនិយាយថា :

– ទេ ! កុំលោកអាពុក, ត្រូវតែងទៅស្រែមហើយ ! យើងត្រឡប់មកវិញឥឡូវ ។

ប្រពន្ធទៅដងទឹក ប្ដីទៅពុះទស ។ អ្នកបួសបញ្ចេញតាសេះពីក្នុងស្បែងយ៉ាងប្រញាប់ ដោះយកវាំងត់ពីដៃគោល ដាក់លើតាសេះរួចស់ផ្ទាប់ហើយពោលថា :

– ឯងធ្វើជាត្បែនឯងតាសេះកំសាយណាស់ហើយ ឥឡូវឯងត្រូវទៅជាមនុស្សវិញចុះ ។

មានពុទ្ធដីការួចភ្លាម បក្សីក៏ត្រឡប់ក្លាយជាមនុស្សមួយរំពេច ។ អ្នកបួសហុចពាត់ឲ្យទៅគូឡូហ្សែន ។ អរគុណជាអនេក ចំពោះអ្នកបួស ហើយរង់ចាំការវិលត្រឡប់មកវិញនៃបុរសប្តីប្រពន្ធ ។

អាប្តីមកដល់មុន ។

គូឡូហ្សែនជាម្ចាស់ផ្ទះសួរថា :

- នែឯងធ្វើអ្វី សំឡាញ់ ?

អាសហាយអេះអុះមិនដឹងរកចំនុកនិយាយបាន ក៏ឆ្លើយថា :

- ឧត្តមអង្គអើយ ! ខ្ញុំធ្វើ . . . . ខ្ញុំធ្វើរបស់ដែលខ្ញុំគួរធ្វើ . . .

- អើ ! ពីមុនមក ឯងភ្ជាប់ជាមនុស្សយ៉ាងណា ឥឡូវ តាំងពីពេលនេះទៅ ចូរឯងទៅជាសត្វលាយ៉ាងនោះចុះ ។

រលាស់ពាក្យផ្ទាប់ អាសហាយក្លាយទៅជាសត្វលា ។

គូឡូហ្សែនថាស្ទើរតែមិនទាន់ផុត មេប្រពន្ធបួលមកដល់ ។ គាត់ជាក់ទណ្ឌកម្មឲ្យមេប្រពន្ធវានោះក្លាយទៅជាលាញី ។

ក្នុងវេលាបីឆ្នាំ លាទាំងពីរត្រូវស៊ីតែចំនំអាអូតជាអាហារ គ្មានបានស៊ីអ្វីដទៃឡើយ ។

លុះចប់កិច្ចហើយ អ្នកបួសក៏និមន្តវិលទៅលំនៅវិញ ។ ចំណែកគូឡូហ្សែន ក្រោយដែលបាននៅជាសុខក្នុងផ្ទះអស់កាលដ៏មិនយូរប៉ុន្មាន ក៏ដឹកលាទាំងពីរទៅកាន់ទីមួយយ៉ាងឆ្ងាយ លើកំពូមួយនៅក្បែរលំនៅអ្នកបួសនោះ ហើយក៏បណ្តោរឲ្យស៊ីតែចំនំអាអូតដូចលើកមុន ។

ក្នុងសម័យនោះ ខេមរដែនដៃ មានបុរសម្នាក់ឈ្មោះគ្រប់ៗគ្នា តែងប្រព្រឹត្តអាដែលគេជាអ្នកប្រមាញ់យ៉ាងចុងប្រសប់ ។ ពេលគាត់ទៅក្នុងព្រៃ ណាហើយ នោះយ៉ាងដូចម្តេច ក៏ចាប់បានអ្វីមួយជាមិនខាន: ជាឈ្លូសជាខន្ធាយ . . ។ ឲ្យតែគាត់ចេញពីផ្ទះ ទៀងតែគាត់ចាប់សត្វជាប្រាកដ ។

ប៉ុន្តែទៅមានរឿងរបស់គាត់ផ្សេងមួយទៀត ។ តាំងពីកើតមក បុរសនេះ មិនដែលណាងខ្លួនម្តងសោះ ដៃក៏ដូចមុខៗ ក៏ដូចដៃប្រហែលទេឬ ជួយរក្សាគាត់? បុរសនោះក៏មិនបានដឹងរឿងខ្លួនជាអ្វីដែរ ពីដើមមក ។

ថ្ងៃមួយ គាត់ចង់ទៅលេងផ្ទះបងរបស់គាត់ ព្រោះគាត់ខានបានជួបជាយូរអង្វែងហើយ ។ ដើម្បីទៅផ្ទះបង បុរសនោះត្រូវឆ្លងកាត់ព្រៃតូចមួយ ។ នៅព្រៃនោះ គាត់ចាប់បានកូនឈ្លូសមួយ ។ ចេញផុតពីព្រៃ បុរសត្រូវឆ្លងស្ទឹងទៀត ។ កំពុងឆ្លងស្ទឹង គាត់ឃើញទឹកថ្លាល្អ ហើយគាត់ទឹកថា:

«ឧត្តុង្គោអើយ! តាំងពីកើតមក អញមិនដែលលុបណាងខ្លួនម្តងសោះ តែទឹកក៏មិនដូចគេដទៃផង . . . ។ ឥឡូវ អញចង់ប្រចុយល្បាងលុបណាងម្តងមើល» ។

គិតដូច្នោះហើយ គាត់ដាក់កូនឈ្លូសទៅដី យកកាំភ្លើងដែកទឹងឈើរួចទន្ទឹកទឹក ។ ជីកហើយ គាត់លើកកូនឈ្លូសស្តាយឡើងព្រៃទឹងដើរទៅទៀត ។ ប៉ុន្តែ កូនឈ្លូសរស់ឡើងវិញ ហើយទំពាអៀងព្រៃធើយនៅក្នុងស្បៃ ។ គាត់ស្រែកថា:

– ឃើ ! អីផ្លែតអស្ចារ្យម្ល៉ះ !

គាត់ចាប់តាំងក្តើនបំរុងទិនចាញ់ទៀត ។ ប៉ុន្តែ កូនឈ្មួសនិយាយជាភាសាមនុស្សទ្រើយតបថា :

– ខែព្រះស្តេច ! ឯងកុំចាញ់ទៀត ។ ចាប់ពីពេលនេះទៅ ឯងអស់សំឡាប់សត្វចានទៀតហើយ ចូរដឹងចុះ ព្រោះឯងត្រូវការលុបលាងខ្លួន ! អ្នកណាចាប់ឱ្យឯងលាងមុខទឹងលាងវិញ ? ព្រះជាម្ចាស់ចានតម្រូវឱ្យឯងកុំលាងខ្លួនអស់មួយជីវិត ។

– តាមការពិត កាលដែលខ្ញុំចានឃើញទឹកថ្លាល្អ ហើយខ្ញុំចានលុបលាងខ្លួនទោះ តែខ្ញុំធ្វើដោយមិនដឹងខ្លួនទេ ។

– ខែព្រះស្តេច ! ឯងខុសហើយ ។ ចូរដឹងថាព្រះជាម្ចាស់មិនអត់ទោសឱ្យទ្រើយ ហើយឯងមិនអាចបរចាញ់ទៅទៀតចាន លុះត្រាតែឯងទៅរកតូឡូហែនឆ្កែសឱ្យឃើញ ហើយយកធ្វើជាសំឡាញ់ ។

រួចតែទោះ កូនឈ្មួសក៏តេះចូលព្រៃចាត់ តែប៉ែនចេះតែដើរតាមចំការទៅ ។

គាត់ដេរបួរ ទៅ ហើយនឹកក្នុងចិត្តថា មិនដឹងជាទៅរកឈ្មោះតូឡូហែនក្នុងទីណាទ្រើយ ។ កំពុងតែព្រួយចិត្ត មិនដឹងជារកតូឡូហែនឃើញ ឬមិនឃើញ ស្រាប់តែគ្រូប៉ែនមើលពីចម្ងាយ ឃើញអ្វីវើក ទៅលើកំពូលភ្នំ ។ លុះទៅដល់គាត់ឃើញមនុស្សម្នាក់នាំរំពាត់វាយសត្វចាំងពីរឱ្យស៊ីទ្រែងទ្រាយអស់ ។ គ្រូប៉ែនពោលថា :

– ម្នាលព្រះស្តេច ! ទ័ាស៊ីវិត្តិ ចូរមានដល់អ្នក !

តូឡូហ្សែនឆ្លើយថា :

– សូមអរគុណច្រើនទីឯព្រះស្តេច តើអ្នកមកមានការណ៍អ្វី ?

– ខ្ញុំនឹងថ្លែងរឿងខ្ញុំ ជូនអ្នកស្តាប់ ។

រួចគ្រូប៉េនក៏និយាយរឿងរបស់ខ្លួនតាំងពីដើមដល់ចប់ ។

– នែសំឡាញ់ ! បើដូច្នោះមែន សូមអង្គុយចុះ ខ្ញុំនឹងថ្លែងរឿងរបស់ខ្ញុំជូនស្តាប់វិញ តើយ៉ាងដូចម្តេច ឃានជាខ្ញុំបណ្តើរសត្វលាទាំងពីរនេះឲ្យស៊ីតែខ្ទេចអាអូត ?

តូឡូហ្សែនបញ្ឈប់លា យកស្មៅបន្ទាមួយក្តាប់ជាក់ឲ្យពីមុខ ចាប់និយាយប្រវត្តិរបស់ខ្លួនហូរហែសព្វគ្រប់ជូនគ្រូប៉េន ។ គាត់និយាយបន្ថែមទៀតថា គាត់ឃានសងសឹកគ្រឹមគ្រែវិញហើយ ។ ព្រមទាំងនឿយនឹងជីវិតទៀតផង ។

លុះតូឡូហ្សែនឃានគោលហើយស្ទើរមិនទាន់ផុតពីមាត់ លេចអ្នកឃួសនោះនិមន្តមក ហើយយកច្រែងលាបដនទាំងនោះ ព្រមទាំងឲ្យធម៌ផង ។ ហើយដនទាំងឃួន គឺគ្រូប៉េន តូឡូហ្សែន និងលាទាំងពីរ មិនយូរប៉ុន្មាន ក៏ក្លាយទៅជាគំនរផ្នឹងលើផែនដី ។

ជាទីបំផុត ព្រះជាម្ចាស់ (ព្រះអាទិទេព) ដង្ហើយហៅយកព្រលឹងអ្នកទាំងនោះទៅឯស្ថានសួគ៌ជាមួយព្រះអង្គ ។

ហេតុដូច្នេះ ឃានជាគេគោលថា : មនុស្សមិនអាចទៅបរបាញ់ដោយគ្មានឆ្កែឡើយ ហើយសត្វលាតែងចូលចិត្តស៊ីស្មៅមានបន្ទាជាអាហារ ។

សារស្តាចចក្ក

ជាគតិដំបូន្មានមិនឲ្យលោភនិងចចក

លោក បាប-ពិន ពិនិត្យកែសម្រួល

ចំពោះពាក្យដែលភ្ញាក់ឡើងតាមសេចក្តីខឹងក្បួនពាក្យឡើងវិញ

(តបប់)

ដេរបេងត្រូវតែ ពិតពិនិត្យពិនិយាំ សេចក្តីកែពាក្យតាំ
ពាក្យពីគាលចចកនោះ ។ ក្រឹណាក្រុយនឹពន្ធា យកម្ទីមាលោលោតចុះ
រើសខ្មោចចចកនេះ នាំប្រពន្ធបរកោក្តា ។ ស៊ុសាច់ហែកហុតឈាម
ហូរហាមៈពញមុខា ឈាមស្រក់ទៅត្រង់ណា យក្សនលិទ្ធតមាន
សល់ ។ ឆ្អឹងឆ្អែងយក្សទំពារ ត្រង់រលាក្បាលសំណល់ បរិភោគ
ឆ្អែតស្កប់ស្កល់ នាំប្រពន្ធរំលងហានបិត ។ រីឯខ្មោចចចក ស្លាប់ទៅ
យកជាតិដូចចិត្ត កើតជាត្រអាតិត្យ រុងរឿងរត្រែចរថ្ងា ។ ទុំខែឆ
ចែងច្រាលន្លៀ ក្តីសន្ធៀតាំងលោកា សំគ្គិសំខ្ចីខ្ចីចេស្តា មានបរិវារ
សម្រាប់បុណ្យ ។ ហេតុផលចចកបាន សាច់ឲ្យទានមកពីមុន ផ្តួយ
ជួនកើតដោយគុណ បុណ្យចិត្តកាត់មិនសង្ស័យ ។ សុរិយាចចកគិត
អាក្រក់ចិត្តឥតឧបមា ចារុក្តីប្រាថ្នា អង្គអញអើយនាប់ឆុតកែ ។
ម្ល៉ះហើយគ្មាននរណា ធ្មឹមចេស្តាមានតេជៈ រុងរឿងខ្ចើងជោគជ័យ
នៃអង្គអញពេញក្រៃវិភូ ។ រីឯយំណើរនេះ ខឹងឈប់ស្ងៃពុំចរចា
ចចកសែងសុរិយា ខ័ណ្ឌខាទទុកពុំស្រេជី ។ ទើបនឹងនិទានពី

ចចកញ៉ាក់ឡើងខ្ញី ឈ្មោលចាត់អង្គឺក្តី ញ៉ែតវកតក្តមា ។ ស្រែងខ្ញីនវកតាមផ្លូវ ដល់ជ្រោះជ្រៃឃើញសិរសោ សំណល់យក្សកោក្តា ញ៉ីច្រាសច្រាណដួលសន្ធប់ ។ កាន់តាំងតាំងស្មារតី អស់តន្ត្រីយ ញ៉ែរចំប្រៃប់ ដង្ហើមហួតប្រសប់ ប្រដេញខ្យល់សល់សែនខ្ញី ។ ហើយហៀបហក់ក្សីណាក្សយ ក្សីណាប្រលំយជន្មដ៏រី សូន្យសុងសូន្យនៅតី ជ្រោះដែលឈ្មោលក្សយ៉ែនោះណា ។ លុះបានដឹងស្មារតី ភ្ញាក់ឥន្ត្រីយខ្លួនទៅថា ទុម្មុកប្រុសស្នេហា ម្តេចអ្នកមកក្សយបង់ចាត់ ។ ចាកចោលប្អូនវង្វា ខៅតំព្រាស្ងៀមស្ងប់ស្ងាត់ ខំកសច្រាសព្រាកព្រាត់ ផុតពីខ្ញែងប្អូនទៅហើយ ។ តាំងពីថ្ងៃនេះទៅ សមប្អូនខៅឯងឥតត្រើយ អ្នកប្រុសថ្លៃប្អូនអើយ ប្អូនទៅកកអ្នកឯណា ។ ឲ្យជួបប្រុសវាមិត្ត មិត្តខ្វឹមចិត្តឥតសង្កា ប្អូនប៉ងផ្ញើរថ្លា ដួងដីវិតនឹងអ្នកថ្លៃ ។ ម្តេចអ្នកចោលប្អូនទៅ ឲ្យប្អូននៅតំព្រាក្រៃ ឥតពឹងគិតអាស្រ័យ ចោះបង់ស្ងាត់ចាត់ទៅហោង ។ សូវក្សយដីវិតទៅ ជាជាងនៅកើតសៅហ្មង ខ្លាំងខ្លួនៗចំបង រងសំចាកលុះអស់កាល ។ ធ្លាប់ធឹកធ្លាប់កោក្តា ធ្លាប់ចរចាធ្លាប់ស្និទ្ធស្នាល ធ្លាប់នៃបធ្លាប់ត្រែអាល ធ្លាប់រួមសេរួមមណ្ឌល ។ ឥឡូវអ្នកប្រុសច្រាស ច្រាសទឹកសព៌តពុំយល់ អ្នកអើយសមប្អូនខ្លាំ ខ្លួនកណ្តែងកណ្តាលព្រៃ ។ តាំងខ្លួញតីប្រលប់ លុះចួបបបប់ចូលដល់ថ្ងៃ រឿងរ៉ះប្លាស់ព្រឹក្សព្រៃ ព្រឹកព្រាងស្ងាងសែងសុរិយា ។ ចចកឃើញថ្លៃជាក់ ថាទុម្មុកប្រុសស្នេហា អ្នកបានជាសុរិយា រុងរឿងរ៉ះត្រចះផ្លៅ ។ អ្នកយកប្អូនទៅធង ស្និទ្ធស្នេហ៍

ស្នងនៃបទិត្យនៅ លើហានទំពូសន្ទៅ សោះហ្នងសៅសែនទុក្ខា ។
ចចកញីខ្លួញខៀត តំងចង្អើតកង្កងទុក ជ្រាសជ្រាណសែនសោកា
សែនអាលោះអាល័យលន់ ។ ពីព្រឹកលុះដល់ត្រង់ សោកសូន្យសុងខល់ទុក្ខធ្ងន់ លុះថ្ងៃទេរទាបទន់ ទាបទៅខៀបបុងព្រឹក្សព្រៃ ។
ក្ងេចផឹកក្ងេចគោក្តា អត់គោជនាស្តមសន្ធៃ សន្ធឹកទឹកអាល័យ ខៀនខ្លួញខៀតដួលជ្រាសជ្រាណ ។ ថានព្រះសុរិយា ស្ងួនស្នេហាមិត្តកល្យាណ ជ្រៀងជ្រែរបែរបៀតថាន បៀតទៅខៀបចូលសន្ធិយា ។
អ្នកអើយប្អូនក្តៅក្តាត់ ថ្ងើមប្រមាត់ឈឺដួលផ្សា ដូចអ្នកយកទាន់ថ្នាំ
កាប់កាត់ប្អូនអស់ពន់ពោះ ។ ចចកញីសន្ធប់ ញ៉ីរចំប្រប់សូន្យសុងសោះ
ដួលដេកនៅទីនោះ លុះព្រលប់ចូលសន្ធិយា ។ សន្ធៃម្រមាក់ចុះត្រង់
ជាបជោកអង្គសព្វភេមា តែជាក់អស់អង្គា ភ្ញាក់ឡើងខ្លួញសែនសល់ខ្លាត ។ ខ្លួញតាំងពីប្រលប់ លុះចួបចប់ចូលអាធ្រាត តពារះព្រាងព្រាត ភ្លឺតែចះពេញមេឃា ។ ចចកមៀងមើលផ្កាយ
ពុំសប្បាយថែមទុក្ខា ថានផ្កាយនេះណា ជាបរិវារអ្នកប្រុសតន់ ។
ប្អូនឃើញតែបរិវារ ជាត់សង្ឃារប្រុសល្អាសល្អន់ អ្នកអើយប្អូនតយតន់
រកមិលមិនឃើញអ្នក ។ ចចកខ្លួញខល់ទុក្ខ គ្មានសាន្តសុខអួលអន់អាក់
លុះព្រឹកព្រាងស្ងាងជាក់ ខៀងខ្លួញខៀតសព្វវេលា ។ មួយថ្ងៃខ្លួញបីដង រឹងរិតរងទុក្ខវេទនា មួយយប់ខ្លួញបីគ្រា ជាទិវន្តរៀងទៅ ។
ពុំផឹកពុំបរិភោគ ស្តមងោរងោកផោកជាំទៅ កំលាំងថយតិចទៅ

ខ្សោយ ឥតបង់ពន់ប្រមាណ ។ ដើរដួលតាំងដំហរ ទឹងត្រាំឈរដេកពុំបាន ក្សីណាក្សយចាកចោលហាន តាំងខមូនតោរតេញតោះ ។

ដំណើរចចកញី កូយជាវីក្នុងគ្រានោះ ឈប់ស្ទេរនៅនេះចុះ ទឹងនិងឯសុរិយា ។ រុនរឿងខ្ទើងឆ្ងី ស្វាងរស្មីភ្លឺលោកា ជួបជុំនួបួនមាសា មានពពកមកបាំងបិទ ។ បាំងបែងសែងសុរីយ៍ អ័ប្បរស្មីដុំជុកជិត ឃាត់វង្សព្រះអាទិត្យ តេញមណ្ឌលខ្លាមេយា ។ ក្សីណានោះអគ្គសុរិយា ចចកណាទ្រង់ត្រាធា ថាហើយលើកហត្ថា សុំក្រតាចាកពិមាន ។

នេះបទតំនោលនិទាន ដំណើរដោយជាន ឯអគ្គចចកសុរិយា ។ ត្រែវត្រាធលោលោតសោះសា តរែះហត្ថា ក្រឡេកក្រឡៃប្រឹងឃ្លាណ ។ ថាយើនរណាហៅហាន ចាំងមុខអញឃាន ខទឹងខែងមិរមក ។ មើលជាក់ថាយើពពក ហ៊ានជាសពាសមក តបតបះទឹងអញ ។ អើយើងមិនញ៉ាមចុះចាញ់ តយុទ្ធវិលវិញ ឲ្យដឹងតេជៈដែរឥឡូវ ។ សុរិយាប្រឹងបែងចាំងទៅ ពពកទឹងទៅ ពុំមានកត្រើកត្រៅណា ។ ចាំងបិទជុំជិតសុរិយា រឹងត្រែវត្រាធ ថាអះអង្គអញសព្វថ្ងៃ ។ មិនមានខរណាមួយកៃ ផ្ទឹមស្មើតេជៈ ប្រឡងអំណាចខះខែង ។ មានតែអគ្គអញឯកឯង ជាធំចំណែង ចិញ្ចេចឥតគូផ្ទឹមបាន ។ ឥឡូវពពកសាមាន្យ ចាំងសែងសូរ្យធាន ជុំជិតងងឹតមេយា ។ អះអញលែងជាតិសុរិយា ហើយសូមថ្វាយ តើតជាពពកធុតធាប់ ។ ដើរជាសពេញពាសខ្ចាន់ខ្ចាប់ សុរិយាអន់អាប់ ងងឹត

ឯងឯល់ណាស់ណា ។ ពពកចចកត្រឡា អរឯងឯមហិមា ស្រួលសើចសំណើចក្អាកក្អាយ ។ ថាអើនេះហៅសប្បាយ លើសលែងសព្វសាយ ស័ក្តិសិទ្ធិរើងរឹទ្ធិចេស្តា ។ អង្គអញលើសលែងលោតា ម្ល៉េះគ្មានឧណាជាគូតតបរឿងរឹទ្ធិ ។ អញចាំងសូរ្យសែងព្រះអាទិត្យ ដេរដាសឯងឆឹតគ្មានរឹទ្ធិស្មើអញឡើយណា ។ កាលនោះរដូវវស្សា មានព្យុះពេញមាសន្ធឹកសន្ធាប់ខ្ទាំងវៃក្រៃ ។ បក់ចោកវាសកដលស័យ ចាក់មែកឈើវៃត្រៃលំរាលើងត្រៃបត្រា ។ ផាត់ផាយផុយផង់ពសុធា ផ្សែងផ្សព្វមហិមាទង្គ្រាលខ្ទឹមមីរមក ។ បក់ដល់សុរិយោពពក ផាត់ផាយចាបចោក ចាត់បង់ពុំគង់ប៉ុនល្អង ។ សុរិយោពពកនោះហោង គ្រោធវៃក្រៃកន្ធង ថាយើអង្គអញសព្វថៃ្ង ។ មិនមានឧណាតដៃ តឡូវនេះវៃក្រៃ មានខ្យល់ដ៏ខ្លាំងបក់ផាត់ ។ កើតជាពពកខ្យាយក្តាត់ អញចង់គិតកាត់ ផាត់ជាពពកចោលចេញ ។ ឡុកថ្នាកើតជាខ្យល់ញៃ ខ្យល់នេះគ្មានចាញ់គ្មានខ្លាចអំណាចឧណា ។ កាលនោះពពកសុរិយោ តាំងចិត្តឡុកថ្នាកើតជាវាយោផាត់ផាយ ។ ផាត់ផង់ធូលីខ្ចាត់ខ្ចាយ ព្រឹក្សាអន្តកាយរលើងរលំគ្មានសល់ ។ ញាប់ញ័រច្រើបពីមណ្ឌល ចោកបក់ទៅដល់ដំបូកធំស្តុកខ្ពស់ខ្ពង់ ។ ខ្យល់បក់ធាបធក់ត្រូវត្រែងំ ដំបូកទៅតង់ ដំហរដំហើមទប់ទល់ ។ នៅទឹងបីទ្រមឹងជូចដល់ តតមានអំពល់ កត្រែកអំពើកឡើយណា ។ វាយោពពកគិតថា យើមានឧណា មកទាល់អង្គអញជាខ្យល់ ។ អញបក់ព្រឹក្សាត្រៃគ្មានសល់ ច្រើបពីមណ្ឌលញាប់ញ័រឧត្តង់ណាស់ណា ។ ទោះទឹកសមុទ្រគគ្លាំ អញបក់បែកជា

រលកវលាមគ្មានសល់ ។ គាលណោះវាយោគតទួល ក្នុងចិត្តខ្វាយខ្វល់
ថាអនដំបូកស្លុកស្តឹង ។ ជំហាមត្រមាមបិទ្រមឹង ទ្រមឹកស្តឹកស្តឹង
រិទ្ធរឹងមិនចាញ់នណា ។ ឈ្មះអញជាមហាភ័តា ខ្មោះអញថ្កាថ្នា
កើតជាដំបូកវិញចុះ ។ វាះយាតពក្តគិតខ្មោះ លែងជាតិខ្សល់នោះ
កើតជាដំបូកស្លុកស្តឹង ។ ព្រងើយទ្រមើយទ្រមឹង ខ្សល់បក់ទៅ
ខឹង មិនមានកម្រើកដល់តិច ។ គោះបីខ្សល់ព្យុះម្តេច ។ បក់ប្រាកខ្លាំង
តិច ដំបូកក៏នៅនឹងថ្កល់ ។ ដំបូកចចកឥតទួល ថានេះត្រូវគល់ បិត្តអញ
ថ្កាថ្នាមួនមាំ ។ ខ្សល់ព្យុះបក់ចុះតន់ តាំ ក្តៀងខ្យះជោគជាំ អញថាំអញ
ទ្រទ្រង់បាន ។ កាលនោះមានសត្តគិរាជ្ជាន ក្តាន់ត្រាសមួយមាន
ហ្វូងក្តាន់ដើរតាមត្រៀបត្រា ។ ក្តាន់ដល់ដំបូកនោះណា ចូលលិទ្ធកោក្តា
ខ្លះវែងខ្លះដល់នោមជុះ ។ ខ្លះកាយរលាយរលុះ ដំបូកធំនោះ ពុំអាច
ថាំទ្រទៅបាន ។ ដំណែរយូរខ្លីឆាយចេញថ្កាន ក្តាន់លែងជាលាន រលំ
ដំបូកនោះទៅ ។ ចចកដំបូកនោះស្ងួត ខេទិងក្រញូរ ក្រវែញងអង្រែន
សរសៃ ។ ដំបូកចចកគិតថា អញចង់ថ្កាថ្នា ទៅកើតជាក្តាន់នោះវិញ ។
គិតហើយប្រែថ្កាណាចាកចេញ ពីដំបូកមិញ ទៅកើតជាក្តាន់ដូចចិត្ត ។
ក្តាន់ដើរកស៊ីឆ្ងាយដាត ឥតមានភ័យគាត ក្នុងចិត្តត្រេកអរគិតថា ។
អញថ្កាន់ដូចចិត្តថ្កាថ្នា ម្ល៉ះគ្មាននណា ជាតិខ្មែងអញទៀតទេ ។
ប្រទះក្តាន់ត្រាសទៅឯ ត្រៃដល់ទាល់តែ ចាលចាញ់តែងភ្នាញ់ចូលត្រៃ ។
ដំណើរក្តាន់ត្រាសនោះនៃ ឈប់ស្ងៀមវិលវៃ ពុំមានទិទានឡើយណា ។

នេះនឹងប្រែបន កាកកតំណាត់ តំណាញ់បរបា
កេរ្តិ៍កាលនោះមាន ព្រៃព្រានមួយណា គ្រែចត្រង់យាត្រា រុករក
បរបាញ់ ។ រួបពង់តំបើស តំបោង់ក្រញេស ក្រញេងក្រញាញ់ ក្រ-
ញូរក្រញើត ក្អែកស្មើតសក់ច្រាញ់ ក្អួចចាកកណ្តាញ់ កណ្តូបពង
ពាស ។ ព្រានដើរតត្រុក ព្រៃស្បាតភនុក រកបាញ់រមាស រមាំង
ប្រើសក្តាន់ តាប់តាន់ចេញពាស រកស៊ុដេរជាស ក្រហមតាំងព្រៃ ។
ក្តាន់ដំបូក រួបពង់ធំស្កូក ការហ្មូងរាំព័ ពាទក្តាន់ឡើងក ចូលមកវ័ងរៃ
ក្តាន់ដេញតិតក័យ ចូលជិតពុំបាន ។ រីឯព្រានព្រៃ ឃើញក្តាន់ធំព្រៃ
អរពន់ប្រមាណ ដំឡើងស្មាកើត ក្រអឹតប្រុងប្រាណ លុតលបឈរឈោង
ដើរទាតិចទៅ ។ លួងក៏រួចលិត ក្អែកម្ខាងព្រានបិទ ម្ខាងបើកក្រឡៃ
ក្រឡែកមុខមៀវ ស្រេងរៀសំរដៅ សម្រុកត្រង់ទៅ លោះតែស្មាភ្លាត់ ។
ត្រូវត្រង់ជាន់ឡើង ក្តាន់ដួលចាស់ជើង ស្ទុះគ្រាតឡើងថ្លាត់ ឈឺធ្មៀប
ផ្សាយផ្សា ទុពក្តៅក្តាត់ ដំរេតក់ភាគាត់ ចេញមុខរុនភ្លាយចេញ ។ ឈាម
ហូរច្រាស់ច្រាល ខ្ទុំខែងរន្ធាល ដោរដន់ពាសពេញ ប្រឹងប្រែបែរចោល
ដួលថ្នាលចុះវិញ ជង្រើមប្រែដេញ ញាក់ញ័រអង្គា ។ ក្តាន់តិតរំពឹង
ថាអញ្ជានេះទឹង ក្សួយចោលរួចា បើអញ្ជាទឹងក្សួយ ប្រល័យជន្ម សូម
ចាប់ជាតិជា បន្ទោះស្មាវិញ ។ ក្តាន់តិតតែម្ន៉ោះ ក្សីណាក្សួយសូន្យសោះ
ក្រឡាប់ជាតិចេញ ពីក្តាន់ចចក ផ្លោះផ្លូតវិលវិញ វិលវឹងមកមិញ កើត
ជាព្រៃត្រស្នា ។ រីឯព្រានព្រៃ ឃើញក្តាន់ក្សីណាក្សួយ ព្រានចូលម្ខ័ម្ខា
ពន្លះយកសាច់ សម្រែចកោដនា ឆ្នឹងឆ្អែនរលា ក្បាលព្រានចោល

ចេញ ។ រួចហើយព្រានទៅ ផ្ទះទីលំនៅ ព្រានដូចដើមវិញ មាន
កាលមួយថ្ងៃ ព្រានដែលចេញ ទៅរកបរបាញ់ សត្វដូចសព្វគ្រា ។
តុំបានសត្វសោះ រីឯមកពីនោះ ព្រានគន់គិតថា អញដើរចេញ រក
បាញ់ម្ដេចគ្មា សត្វថ្ងៃហាក់ជា មានជ័យមានលាភ ។ អ៊ុនអញស្ដាយ
កាលអញស៊ីបាយ ក្ងេចថ្ងាយបា"យា"ប ហេតុនោះអញស្មែន ក៏ឆ្នែងឥត
លាភ ណ្ហើយចុះបា"យា"ប ថ្ងៃក្រែាយសឹមថ្ងាយ ។ ហើយទើបព្រានដែ
ឆៀងក្នែករំពៃ ព្រឹក្សាតំងឡាយ មានមែកសាខា បុប្ផាតែពាយ ក្នុងទឹក
សប្បាយ ក្នុងចិត្តគិតថា ។ ឧអស់ផ្ការផង ក្រែអូបកន្ទុង សប្បាយ
ណាស់ណា អញចង់ដែឆៀងជ្រង ចាន់ម្ដងទៅ"- ហើយព្រានដែឆៀងជា
ខ្នុកស្ងួខ្នុស្នេហ៍ ។ ជ្រងអើយនាងជ្រង បងចេញចាញ់ម្ដង ត្រកាល
ជាងគេ ក៏ឆ្នែងអច្ឆិយ ចានអ្វីផ្ទើមេ រីឯវិញទេ លិខ្នុផេះចង្ក្រាន ។
ដែស្រែកដែឆៀងបណ្ដើរ អេក្បាលឆើរឆើរ រមិលខ្នួនចាំណា មុខស្ងួញមាត់
ស្ងិញ សង្ខេញដូចចាន ព្រានដែឆៀងកំសាន្ត ដើរដោយមាគ៌ា ។ លុះ
ចានដល់ទ្បប់ ដែមួយកូលឈប់ ចូលចតនំគ្រា នៅក្រោមទ្បប់ដែ
ព្រានដែផ្ដែកស្នា ប្រែបគល់ព្រឹក្សា ដេកលង់លក់ទៅ ។ មែនមានចចក
កំព្រាយកំព្រត កំព្រឹងហ្មងសៅ ចេញពីព្រឹក្សា ម៉ឺម្ចាចូលទៅ ត្រង់
ព្រានដេកនៅ ក្រោមទ្បប់ដែនោះ ។ ចចកថាព្រាន ក៏បាញ់មិនចាន
សត្វដល់មួយសោះ អញចាំគោក្ដា ដោយសារព្រាននោះ ថ្ងៃនេះឆ្នែងសោះ
គ្មានអ្វីគោក្ដា ។ ចចកមើលទៅ ឃើញស្នាផ្ដែកនោ គល់ដែសាខា
ចចកថាតុ! លាគោលាកា អញទៅទំពារ បន្ទោះស្នានោះ ។ អង្គើម

ស៊ុំលេង កុំឲ្យភ្លែង ភាបង់ដើង្គសោះ ចចកទំពា ព្រ័ត្រស្មាក្រៀម
ក្រោះ ទាល់ផ្ទាយជាប់ស្មោះ ស៊ុជាគោជនា ។ ឯក្តាន់ធំនោះ ច្រាំថ្ម
ចំពោះ កើតជាព្រ័ត្រស្មា លុះដល់ចចក កំព្រកមោហា ទំពាព្រ័ត្រស្មា
ជាប់ទៅដូច្នោះ ។ រឹងខឹងគ្នាន់ខ្លាញ់ គិតថាអង្គអញ កើតជាបន្ទោះ
ស្មានេះមានរំខុំ សក្តិសិទ្ធិពោះ ឥតគេស្មើស្មោះ ផ្ទឹមនឹងអញច្រាំន ។
ឥឡូវចចក នេះតើវាមក ពិណាហៅហ្មាន ចូលមកទំពា ព្រ័ត្រស្មាជាប់
ជាន ចចកនេះមាន អំណាចជាខ្លា ។ ម៉ៅខ្លោះគួរអញ ច្រាំថ្មវិលវិញ
យោនយកជាតិជា ចចកតើបជាន មែនមានបុគ្គា គិតស្រែចត្រឡា
ក្រឡាប់ជាតិទៅ ។ កើតជាចចក កំព្រយកំព្រក កំព្រើលហ្នង់សៅ
ដូចដើមដែលវិញ តើឲ្យគាបទៅ ព្រោះលោភកំឡៅ កំឡាំងមោហា ។
លោភលន់លើសលែង ហេតុកម្មខ្លោះឯង នាំឲ្យច្រាំថ្មា កើតជាចចក
កំព្រកនោះណា ឥតគេស្មើហា ជាមិត្តនិត្យទៅ ។ ហេតុនោះពាក្យព្រៃង
ព្រឹទ្ធច្រាំជ្រុកតែង ខ្លួនាន្តកូនចៅ ឲ្យវៃប្រលះលោភ ចេញចាកចោលទៅ
កូនអើយនេះហៅ គំនិតឆ្កែតឿ ។ ទុកតជាប្បាប់ ទៅមុខគ្រាន់គ្រាប់
គ្រាន់ត្រង់កុំឆ្ងើ កុំឲ្យចូលចិត្ត គំនិតឆ្កែតឿ គួរខាំគួរជឿ គួរចៀសឲ្យ
ឆ្ងាយ ។ កុំត្រាប់ចចក មោហាកំព្រក កំព្រើលអន្តរាយ លោភគ្រៃ
គន្ធង អ្នកផងតាំងឡាយ លោភលុះអន្តរាយ ជាតិដួងប្រិយ ។

នេះបទព្រហ្មកឹត ចប់ចួបជិតដូចសេចក្តី ល្បិចល្បែកលើកជា
ថ្នី ពីដំណើរសត្វចចក ។ ចែងចប់គ្រប់និទាន ពីបូរាណមានរៀងមក
និយាយរាយរាប់រក ជាតំណតទៅមុខ ។ លើកគ្រាន់ម៉ើលកំសាន្ត គ្រាន់

ទើងបានតែអង្គុក ជាកេរ្តិ៍តទៅមុខ មានប្រការដូច្នេះស្រាប់ ។ ព្រះពុទ្ធ-សកពជគ្រាន់ គ្រប់ពីរពាន់ប្លនរយកាប់ វស្សាថ្ងៃយឯកសប្ត ខែកន្ទូងដប់មាសា ។ ថ្ងៃចុនម្ភៃថ្ងៃ ក្នុងឆ្នាំចសេតា ហេមន្តរដូវថា ខែផល្គុនខាងឯខ្ញើត ។ ថ្ងៃព្រហស្បត៍ វេលាទីដប់ពីរកើត ពាក្យតេចន៍តោលពុំឆើត ខុសខាតជួនជួនមិនសម ។ នាមខ្ញុំនោះសោតសឹង អ្នកផងដឹងមិនច្រឡំ អក្សរតួមចំ ដើងបុកគ្រាមជាក់កម្ពុំ ។ ហើយគួសលើពីរផង តាមចំនងអ្នកជ្ញាជ្ញុក ឲ្យរឿនជាចំនុក ចិត្តសំគាល់តួអក្ខរ ។ បើលោកណាមើលមៀង កុំកួនជៀងជៀលនិន្ទា ឆ្គាំឆ្គងពាក្យត្រង់ណា ជួយតម្រង់ផងឲ្យពាន ។ សុវេចបទបរិយាយ ជានិយាយពីបូរាណ រឿងមកឯរំមាន ប្រការដូច្នេះឯងហោង ។

សន្ត្រាបបកនេះ

អ្នកឧកញ៉ាសុន្ទរវោហារម៉ុក

តែង



អង្គមង្គុស្ស ៤ ពួក :

ការតស៊ូជាអគ្គនៃកូនប្រុស,

ស្គាល់ត្រូវខុសជាអគ្គនៃអ្នកជ្ញា,

អគ្គព្រះមហាក្សត្រតីអំណាច,

ចិត្តអង់អាចជាអគ្គអ្នកចម្បាំង ។

គុយ - សូត្រ

បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

របស់គ្រូសង្ឃធម្មការ

(តមក)

សញ្ញាប័ត្រលេខ ១២១២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ុច - ធិម នាមឆាយា មង្គលជោត កើតឆ្នាំកុរ អាយុ ៦៥ វស្សា ៤៤ ជាគ្រូសូត្រស្តាំវត្តព្រែកក្រឹចៀ ឃុំព្រែកក្រឹចៀ ស្រុកកងមាស ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ១២១៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កោត - ម៉ូវ នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំច្រូវ អាយុ ៦៣ វស្សា ៤៣ ជាគ្រូសូត្រឆ្វេង វត្តព្រែកក្រឹចៀ ឃុំព្រែកក្រឹចៀ ស្រុកកងមាស ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ១២១៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ក់ - សេន នាមឆាយា សុខ្ញរត្ថេរ កើតឆ្នាំមមែ អាយុ ៣២ វស្សា ១២ ជាចៅអធិការ វត្តទួលត្រាច ឃុំអង្គពពេល ស្រុកគងពីសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ១២១៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ែរ - ឡាយ នាមឆាយា ចន្ទរត្ថេរ កើតឆ្នាំវក អាយុ ៣២ វស្សា ១២ ជាចៅអធិការ វត្តអង្គក្តី ឃុំទួលអម្ពិល ស្រុកគងពីសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ១២១៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កែវ - វ៉ែន នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំរកា អាយុ ៤២ វស្សា ២២ ជាចៅអធិការ វត្តអង្គតាផល ឃុំកក់ ស្រុកគងពីសី កំពង់ស្ពឺ ។ (មានត)